សៀវភៅ មង្គលត្ថឌីបនីប្រែ

ភាគទី៣ នេះ

ខ្ញុំអនុញ្ញាតឲ្យផ្សាយជាធម្មទានតាម វ៉ីបសាយ នេះ បានតាមត្រូវការ ។

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក ថ្ងៃ ១៥ កើត ខែមាឃ ព.ស.២៥៥៨

2630 N, Grand Ave.
Santa Ana, CA 92705
(714) 771-7344

ធម្មទានឈ្មះអស់ទានទាំងពួង

មង្គលត្ថឌីបនីប្រែ

ភាគទី៣

ប្រែនិងរៀបរៀងដោយ

ភិក្ខុវិនយធរោ

(មហាយិន-ន្យើន

ផ្សាយជាធម្មទាន

លើកទី១

ចំនួន ១២០០ ក្បាល

រក្សាសិទ្ធិ

ព.ស.២៥៣៨

មន្តសត្តឌីបនី ប្រែ

ភាគទី ៣

—

ឥន្ទមិនយសសោ

(មហាឃិត-រឡឹត)

ប្រែនិងរៀបរៀង

ជំនួយពាណិសម្ថណសិសូកុត្ថិកមឡមសិកូត

និង

ឥន្ទយតាធម្មទាន រណីកទី ១

ចិន្ទុត ១.២០០ក្បាល

—

ឧឡាសិត្ថិ

ព.ស.២៥៣៣ ត.ស.១៩៩៥

ឃាមគិញ-លាវ

មង្គលត្ថទីបនី ប្រែ

ភាគទី ៣

តិក្ខុទិនយធរោ

(មហាយិន-នៀន)

ប្រែនិងរៀបរៀង

ចំនួយជល់សមណសិស្សពុទ្ធិកមធ្យមសិក្សា

និង

ឆ្សាយជាទម្ចមាន លើកទី ១

ចំនួន ១.២០០ក្សាល

រក្សាសិទ្ធិ

ព.ស.២៥៣៨ គ.ស.១៩៩៥

ហាមធិញ-លក់

រក្សាសិទ្ធិគ្រប់យ៉ាង

រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ។

រូបរាងកាយរបស់សត្វទាំងឡាយតែងចាស់ជរាគ្រាំគ្រា
ចំណែកឯនាមនិងគោត្រ មិនដែលចាស់ជរាឡើយ ។



ឥន្ទុចិនយធរោ មហាយិន-នៀន

មានដើមកំណើតនៅ

ភូមិខាងជើង ឃុំទួលព្រហ្ម ស្រុកមោងបូស្សី ខេត្តបាត់ដំបង

សៀវភៅមគ្គលក្ខនីយនីប្រៃ ទាំង៤ភាគនេះ ខ្ញុំអ្នកប្រៃ សូមបញ្ជាក់ថា កាលធ្វើជាលើកដំបូងនេះ គឺប្រៀបឧបមាដូចជាការទ្រែសត្រាយកាប់ឆ្ការផ្លូវទុកតែប៉ុណ្ណោះឯង ពុំទាន់ចាត់ថា បានធ្វើល្អត្រឹមត្រូវមួយរយភាគរយនោះទេ ព្រោះខ្ញុំមានចំណេះចេះដឹងខាងផ្នែកអក្សរសាស្ត្រខ្មែរ-បាលីតិចតួចស្តួចស្តើងណាស់ ។

ចោះពុម្ពជំនួយសមណសិស្សពុទ្ធិកមធ្យមសិក្សា
និងចែកផ្សាយជាធម្មទាន

ចេញអំពី

មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ និង ពុទ្ធិកសមាគមន៍សង្ឃ
នៅតាមចតុនានា ប្រចាំសហរដ្ឋអាមេរិក

* * *

សូមសមណសិស្សដែលបានខ្ចីសៀវភៅនេះ ទៅសិក្សារៀនសូត្រគ្រប់ៗរូប មេត្តាជួយថែរក្សាសៀវភៅនេះឱ្យបានល្អ កុំឱ្យសរសេរ កុំឱ្យមានការរហែកដាច់ដាចខូចខាត...ហើយពេលសិក្សាចប់ សូមមេត្តាយកទៅកម្ពស់ទុកក្នុងបណ្ណាល័យវត្តដែលបានខ្ចីមកនោះដូចដើមវិញ ដើម្បីឱ្យសមណសិស្សជំនាន់ក្រោយខ្ចីយកទៅសិក្សាបន្តទៅទៀត ព្រោះសៀវភៅនេះមានតិចតួចណាស់ ។

សូមអរគុណ

សៀវភៅ **មង្គលត្ថទីបនីប្រែ** *ទាំង ៤ ភាគនេះ*
បានចោះពុម្ពផ្សាយជាធម្មទាន លើកទី១ នៅថ្ងៃសៅរ៍
១៥ កើត ខែវិសាខ ឆ្នាំកុរ សប្តស័ក ព.ស.២៥៣៨
ត្រូវនឹងថ្ងៃ ១៣ ខែឧសភា ១៩៩៥

សៀវភៅ **មគ្គលក្ខណីបនីប្រៃ តាគធី ៣** នេះ

សម្រាប់តម្កល់ទុកជា **សម្បត្តិសង្ឃ** ក្នុង

បណ្ណាល័យ

វត្ត----------

ឃុំ----------

ស្រុក----------

ខេត្ត----------

នៅថ្ងៃ---កើត----រោច ខែ----------

ឆ្នាំ----------ព.ស.២៥៣---

និងសម្រាប់ឲ្យសមណសិស្សពុទ្ធិកវិទ្យាល័យ ខ្ចីយកទៅសិក្សារៀនសូត្រស្រាវជ្រាវ រួចហើយត្រូវយកមកតម្កល់ទុកក្នុងបណ្ណាល័យវិញ ព្រោះជាសម្បត្តិសង្ឃ មួយទៀត ព្រោះសៀវភៅនេះមានចំនួនតិចតួចពេកណាស់ ។

អ្នកចែក----------

អ្នកទទួល----------

សេចក្តីបញ្ជាក់

ខ្ញុំបានត្រួតពិនិត្យដោយរហ័សជាទីបំផុត នូវសៀវភៅមង្គលត្ថទីបនីនេះ ដែលបានប្រែនិងរៀបរៀងដោយ ព្រះមហា យិន នឿន វិនយធរោ ក្នុងគោលបំណងជាជំនួយ ដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា និងចែកជាធម្មទានផង ។

ដូច្នេះ ដើម្បីឱ្យវណ្ណកម្មនេះ មានលក្ខណៈទូលំទូលាយមែនទែនទៀតនោះ ព្រះមហា យិន នឿន តំណែងរបស់ព្រះអង្គជាអនុប្រធានទី២ របស់សហគមន៍ព្រះសង្ឆខ្មែរ ក៏បានប្រគល់ទៅឱ្យសហគមន៍ព្រះសង្ឆខ្មែរ ដែលមានព្រះភិក្ខុ សៅ-យន ធម្មថេរោ ជាប្រធានជួយពិនិត្យ និងកែសម្រួលជាចុងក្រោយ ។

អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថា សៀវភៅនេះមានប្រយោជន៍ច្រើនណាស់ សម្រាប់សមណសិស្ស ដែលកំពុងរៀនប្រែគម្ពីរមង្គលថ្មីៗ ព្រោះអាចធ្វើឱ្យយល់ងាយ បានតាមគួរដល់សេចក្តីត្រូវការពុំខានឡើយ ។

<u>សូមអរគុណ</u>

មណ្ឌលសហគមន៍ ថ្ងៃទី[illegible] ខែសីហា ឆ្នាំ១៩៩៥

ប្រធានសហគមន៍ព្រះសង្ឆខ្មែរ

ព្រះភិក្ខុ សៅ យិន ធម្មថេរោ

មាតិការៀង

ឈ្មោះធម៌	ទំព័រ
១-អារម្ភកថារបស់អ្នកជ្រៃនិងរៀបរៀង	**ក**
២-ពណ៌នាអំពីសេចក្តីនៃគាថាទី ៥	**១**
ពណ៌នាអំពីទាន	២
ពណ៌នាអំពីការប្រព្រឹត្តិធម៌	៩០
ពណ៌នាអំពីការសង្រ្គោះញាតិ	១៦១
ពណ៌នាអំពីកម្មដែលមិនមានទោស	១៨៤
៣-ពណ៌នាអំពីសេចក្តីនៃគាថាទី ៦	២៥៤
បាបវិរតិមជ្ឈបានសំយមកថា	២៥៥
ពណ៌នាអំពីសេចក្តីមិនប្រមាទ	៣៧៣
៤-ពណ៌នាអំពីសេចក្តីនៃគាថាទី ៧	៣៩៨
ពណ៌នាអំពីសេចក្តីគោរព	៣៩៩
ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន	៤៤៥
ពណ៌នាអំពីសេចក្តីសន្តោស	៤៦១

អារម្ភកថា

សៀវភៅ **មន្តលត្ថទីបនីប្រែ តាតទី ៣** នេះ គឺ ខ្ញុំ ភិក្ខុ **ទិនយធរោ មហាយិន~ទៀន** បំរុងនឹងផ្ទួចផ្ទើមប្រែ រៀបរៀង មកជាភាសាខ្មែរយើង ជាយូរយារណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំ កំពុងនៅសិក្សាមកម្លេ៉ះ (ព. ស. ២៥២៤ គ. ស. ១៩៨១) តែឱកាសពុំបានហុចឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរីកចំរើនឡើងជាបន្ថែមតទៅទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្បួនច្បាប់ដែលជាភាសាខ្មែរសម្រាប់ជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏ពុំបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្តែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនាមានវប្បធម៌ ទំនៀមទំលាប់ ខុសប្លែកផ្សេងពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះនៅតែដក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក ចត្វាស័ក

ព.ស.២៥៣៥ ត្រូវនឹងថ្ងៃទី ២៧ ខែឧសភា ១៩៩២ (ឆ្នាំដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបចំធ្វើការបោះឆ្នោតនៅប្រទេសកម្ពុជា) ខ្ញុំក៏បានវិលត្រឡប់ចូលមកទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យមើលការសិក្សាព្រះបរិយត្តិធម៌ ទាំងផ្នែកបាលី ទាំងផ្នែកព្រះធម្មវិន័យ ដែលព្រះសង្ឃកំពុងតែសិក្សានៅតាមវត្តនានា ដូចជា *វត្តមហាមន្ត្រី វត្តលង្កា វត្តនិរោធរង្សី* ជាដើម ដោយមាន **សម្តេចព្រះមន្ថុលទេពាចារ្យ** (**អ៊ឹ - ស៊ឹ**) អគ្គាធិការពុទ្ធិកសិក្សាបាននាំដំណើរជួនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយបានឃើញនូវព្រះសង្ឃអង្គសាមណេរ ខិតខំយកព្រះទ័យទុកដាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឮព្រះភិក្ខុសង្ឃសាមណេរអង្គខ្លះកំពុងទន្ទេញបាលីវេយ្យាករណ៍ អង្គខ្លះទន្ទេញប្រជុំកងធម៌ អង្គខ្លះហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះកំពុងបង្ហាត់ប្រៃលោតប្រយោគ តាមបែបពីបូរាណ... តំហើញ និងការឮសូរសព្ទព្រះធម៌ដ៏ពិរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរំភើប

ចិត្តឥតឧបមា ព្រោះនឹកសង្ឃឹម ថា ព្រះពុទ្ធសាសនា ដែលបាន
វិនាសសាបសូន្យ ស្ទើរតែរលត់អស់ ដោយសារភ្លើងសង្គ្រាម
ជាងពីរទសវត្សរ៍ មកហើយនោះ នឹងបានរីកចំរើនឡើងវិញ
ដោយពិត ហើយបានជំរុញខ្ញុំ ឱ្យរឹតតែមានសទ្ធាជ្រះថ្លាឡើង
ជាភិយ្យោភាព ...។ មួយទៀតសោត ធ្វើឲ្យខ្ញុំនឹកគិត ថា តើ
នឹងរកពិធីជួយ ដល់សមណសិស្សបែបណា? ខ្ញុំយល់ឃើញ
ថា សមណសិស្សដែលកំពុងសិក្សាពុទ្ធិកបឋមសិក្សា (ពេល
នោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និងក្បួនច្បាប់
សម្រាប់ជួយច្រើន តែចំណែកតទៅឆ្នាំក្រោយ។ ទៀត នឹង
មានសមណសិស្សពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និងក្បួន
ច្បាប់ខ្ញុំយល់ឃើញ ថា ដូចជាមានបញ្ហាខ្វះខាតខ្លះ។ ។

ហេតុនេះហើយ ខ្ញុំមានគំនិតគិត ថា នឹងរកសៀវភៅ
មង្គលត្ថទីបនី ដែលនៅជាភាសាចាលីទាំង ៤ ភាគ មកបកប្រែ
ជាភាសាសម្រាយខ្មែរយើង ដើម្បីជាជំនួយ ដល់សមណសិស្ស
ពុទ្ធិកមធ្យមសិក្សា ដែលនឹងមានក្នុងអនាគតកាល ហើយបាន
ដើរស្រាវជ្រាវរកសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បី

តែ **សម្តេចព្រះមន្តលធេពាចារ្យ (អ៊ុំ - ស៊ុំ)** ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះរោងពុម្ពជប៉ុនពុំទាន់បានចោះពុម្ពជាជំនួយ ។

ពេលខ្ញុំត្រឡប់ទៅវត្តខេមរពុទ្ធិកាភាម សហរដ្ឋអាមេរិកវិញ ស្រាប់តែមានព្រះភិក្ខុមួយអង្គ ព្រះនាម **ប៊ួ - ហួយ** លោកបានយកនូវសៀវភៅមង្គលត្ថទីបនី ភាគទី ៣ និងទី ៤ ដែលជាភាសាបាលីមកបង្ហាញឱ្យខ្ញុំមើល ហើយខ្ញុំក៏បានសុំខ្ចីលោកសិន ដើម្បីនឹងយកមកប្រែជាភាសាខ្មែរយើង ដោយបានចាប់ផ្តើមប្រែ នៅថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ១៦ ខែមេសា ១៩៩៣ ហើយបានប្រែចប់សព្វគ្រប់ នៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៣ វេលាព្រឹក ។

លុះប្រែចប់ហើយ ខ្ញុំក៏បានផ្ញើរសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេនព្រះតេជះគុណព្រះ **ធម្មលិខិត លាស់-ឡាយ**[1] វត្តសន្សំកុសល ក្រុងភ្នំពេញ ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវតែភាគទី ៣ នេះ ព្រះអង្គពុំអាចជួយត្រួតពិនិត្យបានទេ ព្រោះ

១- ភាគទី ១-២ ព្រះអង្គបានជួយត្រួតពិនិត្យចប់សព្វគ្រប់ ។

មានការជាប់រវល់ច្រើនពេក ក្នុងកិច្ចការផ្សាយព្រះពុទ្ធសាសនា ក្រោយមក ខ្ញុំក៏បានយកសំណៅ *មង្គលត្ថទីបនី ប្រែ ភាគទី ៣* នេះ ទៅប្រគេនព្រះតេជះគុណ **អធិបតីសង្ឃ (សៅ-ឃន)** ប្រចាំសហគមន៍ព្រះសង្ឃខ្មែរ គង់នៅ*វត្តត្រៃរតនារាម ទីក្រុងឡូរ៉ែល រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក* ដើម្បីឱ្យព្រះអង្គជួយត្រួតពិនិត្យជំនួសវិញ ព្រះអង្គក៏បានទទួលយល់ព្រមដោយពេញព្រះទ័យជាទីបំផុត ហើយបានជួយត្រួតពិនិត្យរហូតដល់បានសម្រេចជាស្តាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ខុស ឃ្លាតចាកអំពីអត្ថន័យធម៌អាថ៌ខ្លះ ។ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគច្រើន មានន័យ ថា គឺមិនចង់ឱ្យឃ្លាតចាកអំពីភាសាបាលីច្រើនឡើយ ដើម្បីឱ្យអ្នកសិក្សាឆាប់រកស័ព្ទប្រែបានដោយងាយ តែខេមរភាសា (ភាសាខ្មែរយើង) ពិតជានឹងពិបាកស្តាប់បន្តិច ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តីអភ័យទោសអំពី សំណាក់ព្រះតេជៈគុណ និងអស់លោកដែលធ្លៀវឆ្លាត ក្នុង អក្សរសាស្ត្រចាលីក្តី ខ្មែរក្តី បើមានការខុសភ្លាំងភ្លាត់ត្រង់កន្លែង ណានិមួយនោះ ហើយសូមមេត្តាជួយឱ្យយោបល់ និងជួយកែ តម្រូវ ដើម្បីធ្វើសៀវភៅនេះ ឱ្យវិតតែបានល្អប្រសើរឡើង ។ សង្ឃឹម ថា ព្រះតេជៈគុណ អស់លោក នឹងផ្តល់យោបល់ដ៏ល្អ ហើយអភ័យទោសដល់ខ្ញុំជាពុំខាន ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះ អង្គ និងពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សា ឱ្យបានឆាប់ ចេះឆាប់យល់ ធ្លៀវឆ្លាតក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌ នោះទៅផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយ ព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនឡើងតរៀងទៅ ។

ម្ួយទៀត សូមឱ្យការសិក្សា នូវព្រះធម្មវិន័យ របស់ សមណសិស្សគ្រប់ ។ រូប និងពុទ្ធបរិស័ទទាំងអស់ បានសម្រេច សមដូចមនោរថ ដែលបានប្រាថ្នាហើយ កុំបីអាក់ខានឡើយ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតអំពីធម្មទាននេះ

ជូនចំពោះបិតាឈ្មោះ **យិន - យ៉ឹម** មាតាឈ្មោះ **ហិច - អម** ព្រមទាំងជីដូនជីតា ញាតិកាទាំង ៧ សន្តាន និងសព្វសត្វទាំងអស់ ដែលបានចែកឋានទៅហើយនោះ សូមឱ្យវិញ្ញាណក្ខន្ធរបស់លោកអ្នកទាំងនោះ បានទទួលអនុមោទនា នូវបុណ្យកុសលដែលខ្ញុំបានឧទ្ទិសផ្សាយទៅឱ្យនេះ ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

សន្តខេមរពុទ្ធិការាម

2100 W. Willow Street
Long Beach, CA 90810
U. S. A.

ថ្ងៃសៅរ៍ ១៥កើត ខែមាឃ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃទី ៦ ខែកុម្ភៈ ១៩៩៣

សេចក្តីថ្លែងអំណរព្រះគុណនិងអរគុណ

◎ ◎ ◎

ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ

-ចំពោះ **សម្តេចព្រះមន្តលទេពាចារ្យ (អ៊ឹ - ស៊ឹ)** អគ្គាធិការនៃពុទ្ធិកសិក្សា *វត្តមហាមន្ត្រី* ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គបានផ្តល់ព្រះយោបល់ដ៏ល្អ។ និងបានផ្តល់នូវក្បួនច្បាប់ផ្សេង។ មានសៀវភៅមង្គលត្ថទីបនីនេះ និងបទានុក្រមធម្មបទជាដើម តាមសេចក្តីត្រូវការ ។

-ចំពោះ ព្រះតេជះគុណ **អធិបតីសង្ឃ (សៅ-ឃន)** ប្រចាំ *មជ្ឈមណ្ឌលសហគមព្រះសង្ឃខ្មែរ នៅវត្តត្រៃរតនារាម ទីក្រុងឡូវ៉ែល រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក* ដែលបានចំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និងអត្ថន័យផ្សេង។ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង រហូតដល់បានចប់សព្វគ្រប់ ។

-ចំពោះ ព្រះតេជះគុណ **គង់ - ឈាន** ចៅអធិការ

ឫត្តខ្មែរ ខេមរពុទ្ធិការាម ទីក្រុងឡងបិច សហរដ្ឋអាមេរិក ដែលបានជួយផ្តល់យោបល់និងគំនិតផ្សេង ។ ។

-ចំពោះ ភិក្ខុ **ឃួ - ហូយ** ដែលបានឱ្យខ្ចីសៀវភៅមង្គលត្ថទីបនីភាគទី ៣ និងភាគទី ៤ ដើម្បីយកមកប្រៃ ។

-ចំពោះ ភិក្ខុ **អ៊ុង - អ៊ុន** វត្តហ្រោះស្ទូ ក្រុងហ្រោះស្ទូ សហរដ្ឋអាមេរិក, ភិក្ខុ **ឆ្រាញ - សាវ៉ាន** វត្តឧណ្ណាលោម កុដិលេខ ៤២ ទីក្រុងភ្នំពេញ និងលោកបណ្ឌិតកវីនិពន្ធ **ហ្យៀម - ត្យើន** ដែលបានជួយយកសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេន **ព្រះធម្មលិខិត ឈាស់ -ឡាយ** ដើម្បីត្រួតពិនិត្យ តែ ភាគទី ៣-៤ នេះ ព្រះតេជះគុណ **ឈាស់-ឡាយ** ពុំបានត្រួតទេ ។

-ចំពោះ ព្រះតេជះគុណ **ឯម-ត្យើង អតិប្បញ្ញោ មេតឈា ខេត្តកំពត** ដែលបានជួយត្រួតពិនិត្យនូវអក្ខរាវិរុទ្ធ និងពាក្យពេចន៍ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង ។

-ចំពោះ ភិក្ខុ **ព្រះមហា សម - ស៊ក្តិ** សុវណ្ណរតនោ ដែលបានជួយយកសៀវភៅមង្គលត្ថទីបនីនេះ ទៅចូលរោង

ពុម្ព ដើម្បីចោះពុម្ពឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-ចំពោះ លោក **ឃឹម-ជ័យ** និងលោក **ឃុំ-ឆយ** ដែលបានជួយកែសម្រួល និងជួយដំឡើងគ្រឿងកុំព្យូទ័រដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណនិងអរគុណជាទីបំផុត ចំពោះព្រះតេជៈគុណ ព្រះថេរានុថេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោមជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភ ក្នុងការចោះពុម្ពសៀវភៅនេះ ឱ្យបានសម្រេចជាស្តាពរ ។

សូមប្រគេនមគ្គផល ដែលកើតពីធម្មទានានិសង្សនេះ ដល់ព្រះតេជៈគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមឱ្យព្រះអង្គមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលនូវបុណ្យកុសលនេះ ស្មើៗគ្នា និងសូមឱ្យបានជួបប្រទះតែនឹងសេចក្តីសុខ-ចម្រើនគ្រប់ប្រការ កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ឆាប់បាន ទទួលនូវសុខសន្តិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះ សម្មាសម្ពុទ្ធបរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងគ្រប់គណៈបក្សទាំងអស់ ជីកនាំប្រទេសជាតិ ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្តីសុខ-ចម្រើន និងសុភមង្គល ជូនដល់ប្រជានុរាស្ត្រទូទាំងប្រទេស ដែលកំពុងក្រីក្រលំបាក ស្រែកឃ្លាន នូវសេចក្តីសុខសន្តិភាព និងស្ងប់ខ្ពើមបំផុតនូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឧទ្ទិសកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់គ្រប់ជាន់គ្រប់ស្រទាប់ ដែលបានបូជាជីវិតដើម្បីមាតុភូមិ ដោយចិត្តស្មោះស្ម័គ្រ គ្រប់កាលៈទេសៈ សូមបានទទួលកុសលដែលកើតអំពីធម្មទាននេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នកទាំងអស់នោះ បានសោយសុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីខាន ។

សៀវភៅ "មង្គលត្ថទីបនីប្រែ" ទាំង ៤ ភាគ
នេះ ខ្ញុំបានបកប្រែចេញ្ចាពីភាសាបាលី មកដា
ចរមភាសា នៅថ្ងៃសៅរ៍ ២ កើត ខែភទ្របទ
ឆ្នាំវក ចត្វាស័ក ព.ស.២៤៣៤ ត្រូវនឹងថ្ងៃ
ទី ២៧ ខែសីហា ឆ្នាំ ១៩៩២ ហើយបាន
ប្រែចប់សព្វគ្រប់ នៅថ្ងៃសុក្រ ១៤ កើត
ខែមាឃ ឆ្នាំច ឆស័ក ព.ស.២៤៣៧ ត្រូវ
នឹងថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៤ រយៈ
ពេល ១ ឆ្នាំ ៥ ខែ ២៨ ថ្ងៃ ។

ដោយសំណាចដណានិសម្បីនៃឆម្មបាន
ដែលកើតឡើងពីការព្យាយាមប្រឹងប្រែង
ប្រែសូវមង្គលត្ថទីបនីនេះ ខ្ញុំសូមប្រាថ្នាឲបាន
រយៈពៅសូវរាសវក្តិលេស ក្នុងរយនាគតជាតិ
ក្រុមីវានឡើយ ។

មង្គលត្ថទីបនីប្រែ

ភាគទី ៣

***

ពណ៌នាសេចក្តីនៃគាថាទី ៥

(១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៥ ។ ចេតនាជាហេតុឲ្យ ឈ្មោះថា **ទាន** ។ កិរិយាប្រព្រឹត្តិ គឺកិរិយាធ្វើនូវធម៌ ឈ្មោះថា **ធម្មចរិយា** ។ បទថា "**ញាតកានំ**" មានសេចក្តីថា កិរិយាសង្គ្រោះនូវញាតិទាំងឡាយ របស់ខ្លួន ។ បទថា "**អនវជ្ជានិ**" បានដល់ កម្មទាំងឡាយ មានឧបោសថកម្មជាដើម ដែលមិនមានទោស គឺបណ្ឌិតមិននិន្ទា មិនតិះដៀលហើយ ។ បទថា "**ឯតំ**" មានសេចក្តីថា ម្នាលទេវតា អ្នកចូរសម្គាល់យកថា "ទាន ១ ការប្រព្រឹត្តិធម៌ ១ ការសង្គ្រោះញាតិ ១ កម្មដែលមិនមានទោស ១, កម្មទាំង ៤ យ៉ាង មានទានជាដើមនេះ ជាមង្គលដ៏ខ្ពង់ខ្ពស់ " ។

សេចក្តីសង្ខេប ក្នុងគាថាទី ៥ នេះ មានតែប៉ុណ្ណេះ ។

ចំណែកសេចក្តីពិស្តារ ក្នុងគាថាទី ៥ នេះ មានដូចតទៅនេះ ÷

ពណ៌នាអំពីទាន

(ទាន ៣ យ៉ាង)

(២) ឈ្មោះថា ទាន មាន ៣ យ៉ាង ដោយអំណាចនៃចាគចេតនា វិរត្តិ និងទេយ្យធម៌ ។ ពិតមែនយ៉ាងនោះ ចាគចេតនា ឈ្មោះថា **ទាន** ក្នុងទានសូត្រ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ថា " **សទ្ធា ១ ភាពជាអ្នកមានហិរិ ១ ទានដែលជាកុសល ១** " ដូច្នេះជាដើម ។

អដ្ឋកថាទានសូត្រនោះ ថា " ព្រះអរិយសាវ័ក រមែងឲ្យទានដោយសទ្ធាណា, សទ្ធានោះ ព្រះដ៏មានព្រះភាគ ទ្រង់អធិប្បាយថា ' **សទ្ធា** ' ក្នុងគាថានោះ ។ ព្រះអរិយសាវ័ក រមែងឲ្យទានដោយហិរិណា, ហិរិនោះឯង ព្រះអង្គទ្រង់ត្រាស់ អធិប្បាយថា ' **ហិរីយំ** ' ។ ទានដែលគ្មានទោស ឈ្មោះថា **ទានជាកុសល** " ។

វិរត្តិ ឈ្មោះថា **ទាន** ក្នុងអាគតស្ថានថា " ព្រះអរិយសាវ័ក រមែងឲ្យនូវអភ័យ " ។ ក្នុងពាក្យថា " **អភយំ ទេតិ** " នោះ មានសេចក្តីអធិប្បាយថា ' ព្រះអរិយសាវ័ក រមែងធ្វើអភ័យទាន គឺ សមាទាននូវការវៀរចាក ពោលគឺសីល ៥ ' ។ ទាន គឺការវៀរចាកនេះ នឹងមានប្រាកដ ក្នុងមង្គលបទ ថា ' **អារតី វិរតី បាបា** ' នុ៎ះ ។

ទេយ្យធម៌ ឈ្មោះថា **ទាន** ក្នុងអាគតស្ថានថា "ព្រះអរិយសាវ័ក រមែងឲ្យទាន គឺបាយនិងទឹក" ដូច្នេះជាដើម ។

(វិគ្រោះទាន)

(៣) សូម្បីក្នុងអដ្ឋកថាកថាវត្ថុ លោកពោលថា "បណ្តាទានទាំង ៣ យ៉ាងនោះ ចាគចេតនា ឈ្មោះថា **ទាន** ព្រោះវិគ្រោះថា 'ចាគចេតនា រមែងឲ្យនូវទេយ្យធម៌, ម្យ៉ាងទៀត ជនទាំងឡាយ រមែងឲ្យទេយ្យធម៌ ដោយចេតនានុ៎ះ' ។ វិរ័តិ ឈ្មោះថា **ទាន** ព្រោះសេចក្តីថា កាត់ផ្តាច់ផ្តិល និងព្រោះសេចក្តីថា កាត់' ។ មែនពិត វិរ័តិនោះ កាលកើតឡើង រមែងកាត់ផ្តាច់និងរមែងកាត់នូវចេតនា របស់បុគ្គលអ្នកទ្រុស្តសីល ពោលគឺ សេចក្តីភិតភ័យនិងសេចក្តីខ្លាចជាដើម ហេតុនោះ ទើបឈ្មោះថា **ទាន** ។ ទេយ្យធម៌ ឈ្មោះថា **ទាន** ព្រោះសេចក្តីថា ដែលបុគ្គលឲ្យ ។ ទាននេះ សូម្បីមាន ៣ យ៉ាង ដូចជាបានពោលមកហើយនេះ ដោយសេចក្តី ក៏មាន ២ យ៉ាង គឺ ធម៌ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ១ ទេយ្យធម៌ ១" ។

បណ្តាទានទាំង ២ យ៉ាងនោះ ភាវៈនៃទានជាមង្គល ក្នុងទានដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ទើបត្រឹមត្រូវ, ក្នុងទានដែលមិនប្រព្រឹត្តទៅតាមផ្លូវចិត្ត មិនត្រឹមត្រូវទេ ។ ព្រោះហេតុនោះ ទាន

គឺទេយ្យធម៌ ដែលមិនប្រព្រឹត្តទៅតាមផ្លូវចិត្ត ទើបមិនបាន ក្នុងមង្គលបទថា **ទាន** នេះ ។ សូម្បីវិរ័តិនោះ ក៏រមែងមិនបាន ក្នុងមង្គលបទនេះ ព្រោះវិរ័តិ សូម្បីក្នុងទានដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ព្រះដ៏មានព្រះភាគទ្រង់ប្រកាន់យក ដោយការវៀរចាកបាប និងការសង្រួមចាកការជីកនូវទឹកស្រវឹង ពួជខាងមុខ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសន្និដ្ឋាន ដោយបាវិសេសនัย ថា " ចាគចេតនា ឈ្មោះថា **ទាន** ។ ក៏ពាក្យថា " **ចេតនា** " លោកពោលហើយ ដោយអំណាចពាក្យជាប្រធាន ។ ក៏សូម្បីសេចក្តីមិនលោភ ដែលប្រកបដោយចាគចេតនានោះ ក៏ឈ្មោះថា **ទាន** ព្រោះមានចាគចេតនានោះជាគតិ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា " ចេតនាជាហេតុបរិច្ចាគទាន ដែលមានវត្ថុ ๑๐ មានបាយជាដើម ដែលមានបញ្ញាគ្រឿងដឹងយល់ ដោយប្រពៃ ជាមុន ចំពោះបុគ្គលដទៃ ឈ្មោះថា **ទាន**, ម្យ៉ាងទៀត អលោភៈ ដែលប្រកបដោយចាគចេតនានោះ ក៏ឈ្មោះថា **ទាន** " ដូច្នេះ ។

(๔) បណ្តាបទទាំងនោះ បទថា " **សុពុទ្ធិបុព្វិកា** " មានសេចក្តីថា មានសម្មាទិដ្ឋិប្រព្រឹត្តទៅខាងមុខ ។ មែនពិត សម្មាទិដ្ឋិដែលប្រព្រឹត្តទៅដោយនัយថា " **ទានដែលទាយក ឲ្យហើយ រមែងមានផល** " ដូច្នេះជាដើម ឈ្មោះថា បញ្ញាជាគ្រឿងដឹងយល់ ដោយ

ប្រពៃ ក្នុងបទថា "**សុពុទ្ធិបុព្វិកា**" នេះ ។ សម្មាទិដ្ឋិកបុគ្គល តែម្នាក់ប៉ុណ្ណោះ ជាអ្នកមានលទ្ធិត្រឹមត្រូវថា "ទានដែលបុគ្គលឲ្យ ហើយ រមែងមានផល" ដូច្នេះ ដឿថា "ឈ្មោះថា ទានជាធម្មជាត ប្រសើរ បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ បណ្ឌិតបានបញ្ញត្តទុកហើយ" រមែងឲ្យទាន ដោយខ្លួនឯងខ្លះ បបួលទាំងអ្នកដទៃ ក្នុងទាននោះខ្លះ ។ មិច្ឆាទិដ្ឋិកបុគ្គល មិនមែនជាអ្នក ដូច្នោះឡើយ ។ ពិតមែនដូច្នោះ គ្រូអ្នកធ្វើលទ្ធិដូចជាកំពង់ ឈ្មោះ អជិត អ្នកមានលទ្ធិខុសថា "ទានដែលទាយកឲ្យហើយ គ្មានផល" ដូច្នេះ ពោលយ៉ាងនេះថា "ការបូជាទាំងឡាយ មានផេះជាទីបំផុត ទាននេះឯណា, ទាននោះ គឺបុគ្គលលួងខ្លៅបញ្ញត្តហើយ" ។

អដ្ឋកថាសាមញ្ញផលសូត្រ និងអដ្ឋកថាទិដ្ឋិសំយុត្ត ក្នុងខន្ធកវគ្គ ថា "បណ្តាបទទាំងនោះ បទថា '**ភស្សន្តា**' ប្រែថា មានផេះជាទីបំផុត ។ ម្យ៉ាងទៀត បាលីក៏នัยនេះ ដូចគ្នាដែរ ។ បទថា '**ហុតិយោ**' មានសេចក្តីថា ទានដែលទាយកឲ្យហើយ ផ្សេងគ្នា ដោយជាសក្ការៈដើម្បីភ្ញៀវជាដើមឯណា, ទានទាំងអស់នោះ ជាទានសុទ្ធតែមានផេះជាទីបំផុតទាំងស្រុង ។ អធិប្បាយថា 'ទាន នោះជាទានឲ្យផលផ្សេងទៅជាដទៃទៀតចាកភាពជាផេះនោះមិនបាន ឡើយ' ។ បទថា '**ទត្តុប្បញ្ញត្តំ**' បានដល់ ដែលបុគ្គលលួងខ្លៅ

គឺមនុស្សពាល បញ្ញត្តទុកហើយ ។ មានពាក្យដែលគ្រូឈ្មោះអជិតៈពោលថា 'គ្រូអជិតៈនោះសំដែងថា 'ទាននេះ គឺពួកមនុស្សពាល គឺពួកអ្នកដែលមិនដឹង បញ្ញត្តទុកហើយ, មិនមែនពួកបណ្ឌិតបញ្ញត្តទេ, មនុស្សពាលរមែងឲ្យទាន, មនុស្សឆ្លាតទទួល (ទាន)" ។

ជីកាសាមញ្ញផលសូត្រថា "ជនទាំងឡាយណា លួងខ្លៅ គឺវង្វែង ហេតុនោះ ជនទាំងឡាយនោះ ឈ្មោះថា ជនលួងខ្លៅ គឺជនអ្នកវង្វែង" ។

(ទានវត្ថុ ១០ យ៉ាង)

(៥) បទថា "**អន្នាទិទសវត្ថុកា**" មានសេចក្តីថា មានវត្ថុដែលជាទេយ្យធម៌ ដែលលោកពោលហើយ យ៉ាងដូច្នេះថា ÷

> "**ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះ គឺ បាយ ទឹកសំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យ គ្រឿងប្រទីប**" ។

អដ្ឋកថាអវុដ្ឋិកសូត្រ ក្នុងតតិយវគ្គ នៃតិកនិបាត ឥតិវុត្តកៈថា "បណ្តាបទទាំងនោះ បទថា 'អន្នំ' បានដល់ របស់ដែលគួរទំពារស៊ី គឺរបស់ដែលគួរបរិភោគ គ្រប់បែបយ៉ាង ។ បទថា 'បានំ' បានដល់ ទឹកសម្រាប់ផឹកមានទឹកស្វាយជាដើម ។ បទថា 'វត្ថំ'

បានដល់ គ្រឿងចិទចាំង មានសំពត់សម្រាប់ស្លៀក-ពាក់ជាដើម ។ បទថា '**យានំ**' បានដល់ របស់ដែលជួយឲ្យទៅបានសម្រេច មានរថយន្ត និងស្នែងជាដើម ដោយហោចទៅ រហូតដល់ស្បែកជើង ។ បទថា '**មាលា**' បានដល់ ផ្កាគ្រប់បែបយ៉ាង ផ្សេងដោយផ្កាឈើដែលក្រងហើយ និងផ្កាឈើដែលមិនបានក្រង ។ បទថា '**គន្ធំ**' បានដល់ គ្រឿងក្រអូបគ្រប់យ៉ាង និងគ្រឿងខុបករណ៍ នៃគ្រឿងក្រអូបដែលគេកិនហើយ និងមិនបានកិន ។ បទថា '**វិលេបនំ**' បានដល់ គ្រឿងសម្រាប់លាបស្បែក ។ បទថា '**សេយ្យា**' បានដល់ របស់ដែលគប្បីប្រើដេក មានគ្រែ និងកៅអីជាដើម និងមានសំពត់បាវារនិងកម្រាលព្រំដ៏វិសេសជាដើម ។ ក៏ដោយ **សេយ្យ** សព្ទ ក្នុងបទថា '**សេយ្យាវសថំ**' នេះ គប្បីជ្រាបថា 'លោកបានកំណត់យកហើយទាំងអាសនៈផងដែរ' ។ បទថា '**អាវសថំ**' បានដល់ ទីនៅអាស្រ័យសម្រាប់កំចាត់បង់ នូវអន្តរាយមានខ្យល់ និងកំដៅថ្ងៃជាដើម ។ បទថា '**បទីបេយ្យំ**' បានដល់ គ្រឿងខុបករណ៍នៃប្រទីប មានប្រទីបដែលមានជង្ងជាដើម "។

(៦) អដ្ឋកថានាគសំយុត្ត ក្នុងខន្ធកវគ្គថា " បទថា '**អន្នំ**' បានដល់ របស់ដែលគួរទំពារស៊ី និងរបស់ដែលគួរបរិភោគ ។ បទថា '**បានំ**' បានដល់ គ្រឿងក្រេចជញ្ជក់គ្រប់មុខ ។ បទថា

'**វត្ថុំ**' បានដល់ សំពត់សម្រាប់ស្លៀកពាក់ ។ បទថា '**យានំ**' បានដល់ បច្ច័យនៃការធ្វើដំណើរគ្រប់យ៉ាង តាំងអំពីឆ្កែនិងស្បែកជើងជាដើមឡើងទៅ ។ បទថា '**មាលំ**' បានដល់ ផ្កាឈើគ្រប់យ៉ាង មានកម្រងផ្កាម្ជិះជាដើម ។ បទថា '**គន្ធំ**' បានដល់ គ្រឿងលាបគ្រប់យ៉ាងមានចន្ទន៍ជាដើម ។ ២ បទថា '**សេយ្យាវសថំ បទីបេយ្យំ**' បានដល់ ទីដេកមានគ្រែនិងកៅអីជាដើម ទីនៅអាស្រ័យមានផ្ទះមួយខ្នងជាដើម គ្រឿងឧបករណ៍នៃប្រទីប មានប្រឆេះ និងប្រេងជាដើម" ។

(៧) ជីកានាគសំយុត្តនោះថា "ឈ្មោះថា **អន្នៈ** ព្រោះជារបស់ដែលគួរទំពាស៊ី ។ ឈ្មោះថា **ខជ្ជៈ** ព្រោះជារបស់ដែលគួរបរិភោគ ។ ឈ្មោះថា **បានៈ** ព្រោះជារបស់គួរផឹក ។ ឈ្មោះថា **សាយនៈ** ព្រោះជារបស់ដែលគួរក្រេបជញ្ជក់ គឺទឹកផឹកមានទឹកផ្លែស្វាយជាដើម ។ ឈ្មោះថា **និវាសនៈ** ព្រោះជារបស់ដែលគួរនឹងស្លៀក ។ ឈ្មោះថា **បារុបនៈ** ព្រោះជារបស់ដែលគួរដណ្តប់ ។ ឈ្មោះថា **យាន** ព្រោះជាគ្រឿងធ្វើដំណើរទៅ គឺយានមានស្បែកជើងជាដើម ។ ក៏ដោយ **អាទិ** សព្ទ ក្នុងបទថា '**ឧបាហនាទិ**' នេះ សង្គ្រោះវហ៍និងគ្រែស្នែងជាដើមផងដែរ ។ ព្រះអដ្ឋកថាចារ្យពោលថា '**ឆត្តុបាហនំ**' ព្រោះធ្វើអធិប្បាយថា 'សូម្បីតែឆត្រ ក៏

ឈ្មោះថា ជាហេតុឱ្យសម្រេចការធ្វើដំណើរបានដែរ ព្រោះជាគ្រឿងការពារទុក្ខព្រោះភ្លៀង និងកំដៅថ្ងៃ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'យង្កិញ្ចិ គមនប្បច្ចយំ** " ។

ជីកាចតុត្ថវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយថា " វត្តណា ដែលបុគ្គលគប្បីច្រកចញ្ចូល គឺគប្បីនាំទៅ ក្នុងគ្រឿងប្រទីប គឺវត្តុសម្រាប់ដុតចំភ្លឺ ហេតុនោះ វត្តុនោះ ឈ្មោះថា **បទីបេយ្យ** (វត្តុដែលគប្បីដុតក្នុងប្រទីប) បានដល់ គ្រឿងឧបករណ៍មានប្រេងជាដើម ។

(បានៈ ១៦ យ៉ាង)

(៨) ដោយនិទ្ទេសន័យ ពាក្យថា " បានៈ " មាន ១៦ យ៉ាង ។ ដោយហេតុនោះ ទើបព្រះធម្មសេនាបតីពោល ថា " បានៈ ៨ យ៉ាង[1] គឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែច័ន្ទ ទឹកក្រឌីឈូក ទឹកផ្លែមាក់ព្រាង ។ បានៈ ៨ យ៉ាង សូម្បីដទៃទៀត គឺ ទឹកផ្លែសង្ឃរ ទឹកផ្លែពុទ្រាតូច ទឹកផ្លែពុទ្រាធំ ទឹកដោះថ្លា ទឹកគីប្រែង ទឹកដោះស្រស់ ទឹកយាគូ (បបរ) ទឹករស (ស្លឹកឈើជាដើម) " ។

បាលីក្នុងនិទ្ទេសនៃតុវដ្តកសូត្រ ។

---

១ ត្រៃបិដក ភាគទី ៦៦ / ទំព័រទី ៦១

(៩) អដ្ឋកថាតុវដ្តកសូត្រនោះថា “ ទឹកដែលគេធ្វើអំពីផ្លែស្វាយខ្ចីក្តី ទុំក្តី ឈ្មោះថា ទឹកផ្លែស្វាយ ។ បណ្តាផ្លែស្វាយខ្ចីនិងទុំទាំង ២ យ៉ាងនោះ កិក្ខុកាលធ្វើអំពីផ្លែស្វាយខ្ចី គប្បីដំកំទេចផ្លែស្វាយខ្ចីៗ ត្រាំក្នុងទឹកហាលថ្ងៃឱ្យស្ងួត (ឆ្អិន) ព្រោះកំដៅព្រះអាទិត្យ រួចហើយត្រងផ្សំធ្វើ ដោយទឹកឃ្មុំ ស្ករក្រួស និងកប៊ូរជាដើម ដែលទទួលប្រគេនទុកក្នុងថ្ងៃនោះ ។ ទឹកដែលគេធ្វើអំពីផ្លែព្រីង ឈ្មោះថា ទឹកផ្លែព្រីង ។ ទឹកដែលគេធ្វើអំពីផ្លែចេកមានគ្រាប់ ឈ្មោះថា ទឹកផ្លែចេកមានគ្រាប់ ។ ទឹកដែលគេធ្វើអំពីផ្លែចេកឥតគ្រាប់ ឈ្មោះថា ទឹកផ្លែចេកឥតគ្រាប់ ។ ទឹកដែលគេធ្វើអំពីរសជាតិ នៃផ្លែស្រគំ ឈ្មោះថា ទឹកផ្លែស្រគំ ។ ក៏ទឹកស្រគំនោះ ផ្សំជាមួយនឹងទឹក ទើបគួរ, សុទ្ធ ។ មិនគួរឡើយ ។ ទឹកដែលគេច្របាច់ផ្លែច័ន្ទ ក្នុងទឹកធ្វើដូចទឹកផ្លែស្វាយ ឈ្មោះថា ទឹកផ្លែច័ន្ទ ។ ទឹកដែលគេកិនក្រឌី (មើម) នៃឈូកក្រហម និងឈូកខៀវជាដើមធ្វើ ឈ្មោះថា ទឹកក្រឌីឈូក ។ ទឹកដែលគេធ្វើអំពីផ្លែមាក់ប្រាង ដូចជាទឹកផ្លែស្វាយ ឈ្មោះថា ទឹកមាក់ប្រាង ។ ទឹកដែលគេធ្វើអំពីផ្លែសង្ឃ័រ ឈ្មោះថា ទឹកផ្លែសង្ឃ័រ ។ ទឹកដែលគេធ្វើអំពីផ្លែពុទ្រាតូច ឈ្មោះថា ទឹកផ្លែពុទ្រាតូច ។ ទឹកដែលគេធ្វើអំពីផ្លែពុទ្រាធំ ដូចទឹកផ្លែស្វាយ ឈ្មោះថា ទឹកផ្លែពុទ្រាធំ ។ បាន: ១១ យ៉ាងនេះ ត្រជាក់ក្តី ឆ្អិនព្រោះព្រះអាទិត្យក្តី ក៏សមគួរ ។

ទឹកដោះរាវថ្លា ឈ្មោះថា ទឹកដោះថ្លា ។ ទឹកគឺប្រែងដែលធ្វើអំពីប្រែងល្ងជាដើម ឈ្មោះថា ទឹកគឺប្រែង ។ ទឹកបបរដែលត្រជាក់ជាដើម ឈ្មោះថា ទឹកបបរ ។ ទឹកដោះស្រស់ ឈ្មោះថា ទឹកដោះស្រស់ ។ ទឹកដែលផ្សំដោយរស មានបន្លែត្រាំជាដើម ឈ្មោះថា ទឹករស " ។

ចេតនាជាហេតុឱ្យ មានវត្ថុ ១០ ប្រការ មានបាយជាដើម ប្រកបដោយអលោភៈ ដូចបានពោលមកនេះ ឈ្មោះថា **ទាន** ក្នុងមង្គលបទថា "**ទាន**" នេះ ។ ព្រោះថា បុគ្គលប្រគល់ឱ្យនូវវត្ថុរបស់ខ្លួន សូម្បីដោយអលោភៈ (ក៏ឈ្មោះថាទាន) ។ ដោយហេតុនោះ ក្នុងអដ្ឋកថា លោកសំដៅយកទានចេតនានិងអលោភៈ ទាំង ២ យ៉ាងនោះ ទើបបានពោលថា "ទានចេតនា ឈ្មោះថា ទាន ព្រោះសេចក្តីថា "ជាហេតុដែលបុគ្គលឱ្យ" ដូច្នេះ, អលោភៈ ឈ្មោះថាទាន ព្រោះសេចក្តីថា "រមែងប្រគល់ឱ្យនូវវត្ថុរបស់ខ្លួន ដល់បុគ្គលដទៃ" ដូច្នេះ ។

(ទានប្រកបដោយអង្គ ៦ យ៉ាង)

(១០) ក៏ទាននេះនោះ ប្រកបដោយអង្គ ៦ យ៉ាង ប៉ុណ្ណោះ រមែងជាទានមានផលច្រើន ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏ទក្ខិណា ប្រកបដោយអង្គ ៦ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនា

នេះ អង្គរបស់អ្នកឲ្យ មាន ៣, អង្គរបស់អ្នកទទួល មាន ៣ ។ ចុះអង្គរបស់ទាយក ៣ តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទាយកជាអ្នកមានចិត្តត្រេកអរមុន អំពីកាលឲ្យ ១, កំពុងតែឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា ១, លុះឲ្យហើយ មានចិត្តរីករាយ ១ ។ នេះជាអង្គរបស់ទាយក ៣ យ៉ាង ។ ចុះអង្គរបស់បដិគ្គាហកៈ ទាំងឡាយ មាន ៣ តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់នូវរាគៈ ១, ប្រាសចាកទោសៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់នូវទោសៈ ១, ប្រាសចាកមោហៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់នូវមោហៈ ១ ។ នេះជាអង្គ របស់បដិគ្គាហកទាំងឡាយ មាន ៣ យ៉ាង ។ អង្គរបស់ទាយក មាន ៣, អង្គរបស់បដិគ្គាហកៈ មាន ៣ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ នូវប្រមាណនៃបុណ្យ របស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងដូច្នេះថា 'គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ មានប៉ុណ្ណោះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខ' ដូច្នេះបានឡើយ, ដោយ

ពិតនោះ បុណ្យនោះគ្រាន់តែដល់ នូវការរាប់ថា 'គំនរនៃបុណ្យដ៏ច្រើន គប្បីរាប់មិនបាន ប្រមាណមិនកើត' ដូច្នេះតែប៉ុណ្ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុគ្គលដែលមិនងាយ កំណត់នូវប្រមាណនៃទឹក ក្នុងមហាសមុទ្រថា 'ទឹកប៉ុណ្ណោះអាឡ្ហកក្តី, ទឹកប៉ុណ្ណោះរយអាឡ្ហកក្តី, ទឹកប៉ុណ្ណោះពាន់អាឡ្ហកក្តី, ទឹកប៉ុណ្ណោះសែនអាឡ្ហកក្តី' ដូច្នេះបានឡើយ, ដោយពិតនោះ ទឹកនោះ គ្រាន់តែដល់នូវការរាប់ថា 'គំនរនៃទឹកដ៏ច្រើន គប្បីរាប់មិនបាន ប្រមាណមិនកើត' ដូច្នេះប៉ុណ្ណោះបាន យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ នូវប្រមាណនៃបុណ្យ របស់ទក្ខិណា ដែលប្រកបដោយអង្គ ៦ យ៉ាងដូច្នេះថា 'គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឱនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌មានប៉ុណ្ណោះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខ' ដូច្នេះ បានឡើយ, ដោយពិតនោះ បុណ្យនោះគ្រាន់តែដល់នូវការរាប់ថា 'គំនរនៃបុណ្យដ៏ច្រើន គប្បីរាប់មិនបានប្រមាណមិនកើត' ដូច្នេះប៉ុណ្ណោះបាន ក៏យ៉ាងដូច្នោះដែរ" ។

ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់គាថាពន្ធនេះទៀតថា÷

(១១) "ទាយកជាអ្នកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ, កំពុងតែឲ្យ គប្បីធ្វើចិត្តឲ្យជ្រះថ្លា, លុះឲ្យរួចហើយ ក៏មានចិត្តត្រេកអរ, នេះជាសេចក្តីបរិបូណ៌ នៃទាន ។ បដិគ្គាហកៈជាអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ មានសេចក្តីសង្រួម ជាព្រហ្មចារី ឈ្មោះថាជាខេត្ត នៃទានដ៏បរិបូណ៌ ។ ទាននុ៎ះ ជាទានមានផលច្រើន ដល់ខ្លួនឯងផង ដល់អ្នកដទៃផង ព្រោះខ្ចល់ខ្ចាយ ដោយខ្លួនឯង ព្រោះឲ្យដោយដៃខ្លួនឯង, អ្នកមានប្រាជ្ញា ជាបណ្ឌិត ជាអ្នកមានសទ្ធា មានចិត្តផុតស្រឡះ (ចាកសេចក្តីកំណាញ់) លុះឲ្យទាន យ៉ាងនេះហើយ រមែងចូលដល់ទេវលោក មិនមានការបៀតបៀនជាសុខ"។

ឆឡង្គទានសូត្រ មកក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសកៈ ក្នុងឆក្កនិបាត អង្គុត្តរនិកាយ ។

(១២) អដ្ឋកថាឆឡង្គសូត្រថា "បទថា 'ឆឡង្គសមន្នាគតា' ប្រែថា ប្រកបដោយអង្គនៃគុណ ៦ ។ ទាន ឈ្មោះថា ទក្ខិណា ។ ច្រើនបទថា 'បុព្ពេ ទានា សុមនោ' មានសេចក្តីថា រមែងជា

អ្នកដល់ហើយនូវសោមនស្ស តាំងអំពី ១ ខែ និងកន្លះខែមកថា 'អញ
នឹងឲ្យទាន' ដូច្នេះ ។ ក៏បណ្តាចេតនាទាំង ៣ យ៉ាងនេះ បុព្វចេតនា
បានដល់ទាយកអ្នកគិត ចាប់ដើមអំពីចាប់ចងស្រែថា 'អញនឹងឲ្យទាន
ដោយផលដែលបានសម្រេចមក អំពីស្រែនេះ' ដូច្នេះ តាំងអំពីវេលា
ដែលកើតឡើង នៃចិត្តថា 'អញនឹងឲ្យទាន' ដូច្នេះ ។ ចំណែក
មុញ្ចនចេតនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ យ៉ាងនេះថា 'ទាយក
កំពុងឲ្យ រមែងញុំាងចិត្តឲ្យជ្រះថ្លា' រមែងបាន ក្នុងពេលដែលឲ្យទាន
នុ៎ះឯង ។ ចំណែក អបរាបរចេតនានេះថា 'លុះឲ្យទានរួចហើយ ក៏
រមែងមានចិត្តត្រេកអរ' ដូច្នេះ រមែងបានដល់ទាយក អ្នកនឹករលឹក
តាមជាបន្តបន្ទាប់មក ។ បទថា **'វីតរាគា'** គឺ មានរាគៈទៅប្រាស
ហើយ បានដល់ អស់អាសវៈហើយ ។ ២ បទថា **'រាគវិនយាយ
វា បដិបន្នា'** មានសេចក្តីថា ប្រតិបត្តិនូវបដិបទាគ្រឿងកំចាត់បង់
នូវរាគៈ ។ ក៏ទេសនានេះ សំដែងបដិគ្គាហកៈយ៉ាងខ្ពង់ខ្ពស់ ។ ក៏
ទក្ខិណាដែលឲ្យ ដល់ព្រះខីណាស្រពទាំងឡាយ តែមួយពួក ទើប
ជាទក្ខិណាប្រកបដោយអង្គ ៦ ក៏មិនមែនទេ, ទក្ខិណាដែលឲ្យសូម្បី
ដល់ព្រះអនាគាមី ព្រះសកទាគាមីនិងព្រះសោតាបន្នទាំងឡាយ ដោយ
ហោចទៅ សូម្បីដល់សាមណេរអ្នកកាន់នូវភណ្ឌៈ ដែលបួសក្នុងថ្ងៃ
នោះ ក៏ប្រកបដោយអង្គ ៦ ដូចគ្នាដែរ ។ ព្រោះថា សូម្បី

សាមណេរនោះ ឈ្មោះថា បួសហើយ ដើម្បីសោតាបត្តិមគ្គមែនពិត”។

(១៣) ជីការឆឡង្គសូត្រនោះថា “សម្បត្តិទាំងឡាយ រមែងចំរើន គឺរុងរឿង ដោយគុណជាតិនេះ ហេតុនោះ គុណជាតិនេះ ឈ្មោះថា ទក្ខិណា (ជាគ្រឿងចំរើននៃសម្បត្តិ) គឺបុណ្យដែលសំរេចដោយការបរិច្ចាគ និងទេយ្យធម៌ដែលជាគ្រឿងឧបករណ៍ នៃបុណ្យនោះ។ តែក្នុងបទថា ‘**ទក្ខិណា**’ នេះ លោកចំណាងយកទេយ្យធម៌។ ២ បទថា ‘**ឥតោ ឧដ្ឋិតេន**’ មានសេចក្តីថា កើតឡើងហើយ អំពីស្រែនេះ។ រាគៈ គឺបដិគ្គាហកៈ តែងកំចាត់ ដោយធម៌នុ៎ះ ហេតុនោះ ធម៌នុ៎ះ ឈ្មោះថា រាគវិនយៈ (ជាគ្រឿងកំចាត់រាគៈ) គឺបដិបទាជាហេតុកំចាត់បង់រាគៈ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ‘ប្រតិបត្តិនូវបដិបទា ដើម្បីបន្ទោបង់នូវរាគៈ” ដូច្នេះ។

(១៤) អដ្ឋកថាបឋមវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងចតុក្កនិបាតអង្គុត្តរនិកាយថា “ការហូរមក នៃបុណ្យ ឈ្មោះថា បុញ្ញាភិសន្ទា អធិប្បាយថា ‘ការចូលដល់នៃបុណ្យ’។ ពាក្យថា ‘**កុសលាភិសន្ទា**’ ជាពាក្យវេវចនៈនៃពាក្យថា **បុញ្ញាភិសន្ទា** នោះឯង។ ក៏ការហៀរហូរមក នៃបុណ្យទាំងនោះនុ៎ះ ឈ្មោះថា **សុខស្សាហារា** ព្រោះអត្ថថា ‘នាំសេចក្តីសុខមកឲ្យ’។ ឈ្មោះថា **សោវគ្គិកា** ព្រោះអត្ថថា ‘ឲ្យអារម្មណ៍ទាំងឡាយ មានរូបជាដើម ដ៏ប្រសើរ ដោយប្រពៃ’។

ឈ្មោះថា **សុខវិបាកា** ព្រោះអត្ថថា 'មានវិបាកជាសុខ'។ កិរិយាកើតឡើង ក្នុងស្ថានសួគ៌ ឈ្មោះថា **សគ្គៈ**។ ការហូរមកនៃបុណ្យ ឈ្មោះថា **សគ្គសំវត្តនិកា** ព្រោះអត្ថថា 'ប្រព្រឹតទៅព្រម ដើម្បីការកើតឡើង ក្នុងស្ថានសួគ៌"។

ដីកាបឋមវគ្គនោះថា "ម្យ៉ាងទៀត ស្នឹងនៃបុណ្យ ឈ្មោះថា បុញ្ញាភិសន្ទា។ ក៏បុណ្យទាំងឡាយដែលបុគ្គលឲ្យប្រព្រឹត្តទៅជាច់ជានិច្ច ដោយមិនឲ្យដាច់រយៈ ហៅថា '**បុញ្ញាភិសន្ទា**' ព្រោះអត្ថថា ជាគ្រឿងហៀរហូរមក"។

(១៥) អដ្ឋកថាឆឡង្គសូត្រថា "២ បទថា '**យញ្ញស្ស សម្បទា**' គឺ សេចក្តីបរិបូណ៌ នៃទាន។ បទថា '**សញ្ញតា**' គឺ ឈ្មោះថា ជាអ្នកសង្រួមហើយ ព្រោះសង្រួមសីល។ បាទគាថាថា '**សយំ អាចមយិត្វាន**' មានសេចក្តីថា ព្រោះលាងដៃ និងជើងហើយ ឲ្យខ្ពុរមាត់ចេញ ដោយខ្លួនឯង។ ២ បទថា '**សយេហិ បាណិភិ**' គឺ ដោយដៃទាំង ២ របស់ខ្លួន។ បាលីថា '**សកេហិ**' ដូច្នេះក៏មាន។ បទថា '**សទ្ធោ**' បានដល់ ជឿគុណព្រះរតនត្រៃ។ ២ បទថា '**មុត្តេន ចេតសា**' បានដល់ មានចិត្តផុតស្រឡះហើយ ចាកលោភៈនិងមច្ឆរិយៈជាដើម។ បាទគាថាថា '**អព្យាបជ្ឈំ សុខំ លោកំ**' បានដល់ ទេវលោក ដែលឥតមានសេចក្តីទុក្ខ មានតែ

សេចក្តីសុខ និងសោមនស្ស យ៉ាងប្រសើរ ”។

(១៦) ជីកាឆឡង្គសូត្រនោះថា “២ បទថា ‘**បុព្វេ ទានា**’ មានសេចក្តីថា ក្នុងពេលមុន អំពីមុញ្ចនចេតនា គឺចាប់ដើមអំពីការចាត់ចែងឧបករណ៍នៃទាន ។ បទថា ‘**សុមនោ**’ មានសេចក្តីថា គប្បីជាអ្នកដល់នូវសោមនស្សថា ‘អាត្មាអញនឹងកប់ នូវកំណប់ទ្រព្យ ដែលជាហេតុ នៃសម្បត្តិ មានប្រក្រតីជាប់តាម (ខ្លួន) ទៅបាន’។ បាទគាថាថា ‘**ទទំ ចិត្តំ បសាទយេ**’ មានសេចក្តីថា ទាយកកំពុងឲ្យជាក់នូវទេយ្យធម៌ចំពោះ ក្នុងដៃនៃទក្ខិណេយ្យបុគ្គល គប្បីធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លាថា ‘អាត្មាអញកំពុងតែធ្វើនូវការកាន់យកខ្ចីមសារ អំពីទ្រព្យ ដែលមិនមានខ្ចីមសារដូច្នេះ។ បាទគាថាថា ‘**ទត្វា អត្តមនោ ហោតិ**’ មានសេចក្តីថា ទាយកបរិច្ចាគទេយ្យធម៌ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយហើយ ជាអ្នកមានចិត្តត្រេកអរ រីករាយ សប្បាយ គឺ កើតបីតិសោមនស្សថា ‘ទាន ដែលឈ្មោះថា បណ្ឌិតបញ្ញត្តទុកហើយ អាត្មាអញ ក៏បានតាមគម្កល់ទុកហើយ, ឱ! ទានរបស់អាត្មាអញ សម្រេចប្រយោជន៍ដោយល្អហើយហ្ន៎!’។ បទថា ‘**ឯសា**’ មានសេចក្តីថា សេចក្តីបរិបូណ៌ នៃចេតនាទាំង ៣ យ៉ាង ដែលទៅតាមនូវការជឿកម្មនិងផល ដែលសោមនស្សកាន់កាប់ហើយទាំងនេះ គឺ បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា នេះឯណា,

សេចក្តីបរិបូណ៌នៃចេតនានេះ ។ បទថា 'សីលសញ្ញមេន' មានសេចក្តីថា ព្រោះសេចក្តីសង្រួមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវវាចា ។ បទថា 'ហត្ថបាទេ' គឺដៃនិងជើងរបស់ទក្ខិណេយ្យបុគ្គលទាំងឡាយ ។ ២ បទថា 'មុខំ វិក្ខាលេត្វា' មានសេចក្តីថា ព្រះទក្ខិណេយ្យបុគ្គលទាំងឡាយនោះឯង ខ្ពុរមាត់, អធិប្បាយថា 'ព្រោះឲ្យនូវទឹកខ្ពុរមាត់ ដោយខ្លួនឯង" ។

(១៧) ក្នុងអធិការនៃចេតនានេះ អាចារ្យអ្នកចោទសួរ បានពោលថា "ចេតនាទាំង ៣ យ៉ាងនេះ ជាចេតនាឲ្យឋជិសន្ធិឬ ?" ។ អាចារ្យអ្នកឆ្លើយ ពោលថា "មែនហើយ ចេតនាទាំង ៣ យ៉ាងនេះ ឲ្យនូវបដិសន្ធិនោះ ពិតមែន" ។ ក៏ក្នុងសេចក្តីនេះ មានចេតនាទាំងឡាយ របស់សេដ្ឋីជាអ្នកមិនមានកូន ជាឧទាហរណ៍ ÷

(រឿងអបុត្តកសេដ្ឋី)

បានឮថា ក្នុងអតីតកាល អបុត្តកសេដ្ឋីនោះ ជាសេដ្ឋី ក្នុងទីក្រុងពារាណសី ថ្ងៃមួយ បានក្រោកឡើង តាំងពីព្រឹកព្រលឹមស្រាង បរិភោគភ័ត្តស្រេចហើយ ក៏ទៅកាន់ព្រះរាជសំណាក់ បានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមតគរសិខី ទើបប្រើឲ្យគេប្រគេនបិណ្ឌបាត ដល់ព្រះបច្ចេកពុទ្ធអង្គនោះហើយ ក៏ចៀសចេញទៅ ។ សេចក្តីសង្ខេប

ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ គប្បីត្រួតពិនិត្យមើល ក្នុងអដ្ឋកថាមឃ្លកសកុណជាតក ក្នុងទុតិយវគ្គ នៃឆក្កនិបាត និងអដ្ឋកថាទុតិយវគ្គ ក្នុងកោសលសំយុត្ត ។

អបុត្តកសេដ្ឋីនោះ ចូលដល់សុគតិប៉ុណ្ណោះ អស់វារៈ ១៤ ដង ដោយកម្មនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដល់ព្រះបាទកោសលរាជថា "បពិត្រមហារាជ សេដ្ឋីគហបតីនោះ បានផ្គត់ផ្គង់នូវព្រះបច្ចេ[illegible] ទ្រង់ព្រះនាមតគរសិខី ដោយបិណ្ឌបាតឯណោ, ព្រោះវិបាកនៃកម្មនោះ សេដ្ឋីនោះ បានចូលដល់សុគតិ សួគ៌ ទេវលោក អស់ពេល ៧ ដង, ព្រោះសេសសល់នៃផលនៃកម្មនោះឯង សេដ្ឋីនោះ គ្រប់គ្រងភាពជាសេដ្ឋី អស់វារៈ ៧ ដង ក្នុងទីក្រុងសាវត្ថីនេះឯង" ដូច្នេះ ។

(១៨) អដ្ឋកថាកោសលសំយុត្តនោះថា "បណ្តាបទទាំងនោះ បទថា '**បដិបាទេសិ**' បានដល់ ចិញ្ចឹមបីបាច់ ព្រមទាំងបិណ្ឌបាត, អធិប្បាយថា 'បានប្រគេនហើយនូវបិណ្ឌបាត' ។ បទថា '**សត្តក្ខត្តុំ**' គឺ អស់វារៈ ៧ ដង ។ ក៏ក្នុងពាក្យថា '**សត្តក្ខត្តុំ**' នេះ គប្បីជ្រាបសេចក្តី ដោយអំណាចបុព្វចេតនានិងបច្ឆិមចេតនា ។ មែនពិត ក្នុងពេលប្រគេនបិណ្ឌបាតមួយដង ចេតនាតែមួយដួងប៉ុណ្ណោះ នឹងឱ្យនូវបដិសន្ធិ ២ ដង មិនបានឡើយ ។ ក៏អបុត្តកសេដ្ឋីនោះ កើត

ហើយ ក្នុងស្ថានសួគ៌ អស់វារៈ ៧ ដង ក្នុងត្រកូលនៃសេដ្ឋី អស់វារៈ ៧ ដង ព្រោះបុព្វចេតនា និងបច្ឆិមចេតនា "។

ជីកាកោសលសំយុត្តនោះថា "កាលបើសេដ្ឋីពោលថា 'ចូរអ្នកប្រគេននូវបិណ្ឌបាត ដល់សមណរូបនេះ' ដូច្នេះ, សេចក្តីសម្រេចនៃប្រយោជន៍ រមែងមាន ដោយអំណាចនៃជវនវិថីតែ ១ ដងប៉ុណ្ណោះ, តាមពិតនោះ ក្នុងពេលប្រគេនបិណ្ឌបាតមួយគ្រានោះ វារៈនៃជវនៈដែលប្រព្រឹត្តទៅពួដ៏ខាងដើមក្តី វារៈនៃជវនៈដែលប្រព្រឹត្តទៅ ត្រង់កណ្តាល ពួដ៏ខាងក្រោយក្តី រមែងមាន, ព្រះអដ្ឋកថាចារ្យសំដៅយកជវនៈទាំង ២ នោះ ទើបពោលថា '**បុព្វបច្ឆិមចេតនា**' ដូច្នេះ "។

(១៩) ព្រោះហេតុនោះ ចេតនាទាំង ៣ គប្បីធ្វើឱ្យបានបរិបូណ៌ ។ ព្រោះថា កាលធ្វើដូច្នោះ ទានរមែងមានផលច្រើន ។ ដោយហេតុនោះ ក្នុងអដ្ឋកថាមឃុកសកុណជាតក លោកពោលថា "ក៏ធម្មតាទាន រមែងមានផលច្រើន ដល់បុគ្គលអ្នកអាចដើម្បីនឹងធ្វើចេតនាទាំង ៣ ឱ្យបានបរិបូណ៌ប៉ុណ្ណោះ "ដូច្នេះ ។

(២០) ម្យ៉ាងទៀត ភាវៈនៃទាននោះ ជាទានមានផលច្រើន គប្បីជ្រាប សូម្បីដោយវេលាមសូត្រ និងទក្ខិណាវិភង្គសូត្រ ។

មែនពិត ក្នុងវេលាមសូត្រ ក្នុងនវកនិបាត អង្គុត្តរនិកាយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវទាន ១៤ យ៉ាង ដោយប្រភេទ ។

មានសេចក្តីថា វេលាមព្រាហ្មណ៍ បានឲ្យបើយ នូវអាហារ ផ្សេងដោយគ្រឿងគួរទំពារស៊ី និងគ្រឿងបរិភោគជាដើម មិនមាន ប្រមាណ ដល់លោកិយមហាជន អស់រយៈពេល ៧ ឆ្នាំ ៧ ខែ នៅ ក្នុងថ្ងៃជាទីបញ្ចប់ បានឲ្យភាជន៍មាស ភាជន៍ប្រាក់ និងភាជន៍សំរិទ្ធ ដែលពេញទៅដោយរូបិយៈមាស និងប្រាក់ តាមលំដាប់ រាប់បានមួយ មុខៗ ៨៤,០០០ បានឲ្យជំរី រថ នាងកញ្ញា បល្ល័ង្ក ដែលប្រដាប់ ដោយគ្រឿងអលង្ការទាំងពួង រាប់បានមួយមុខៗ ៨៤,០០០ និង បានឲ្យមេគោ និងសំពត់សាដក រាប់បានមួយមុខៗ ៨៤,០០០ ។ ទាននោះ បានឈ្មោះថា មហាទាន ។ ការប្រគេនបាយ ដល់ព្រះ សោតាបន្នមួយរូប មានផលច្រើនជាងមហាទាននោះទៅទៀត ។ ការប្រគេនបាយ ដល់ព្រះសកទាគាមីមួយរូប មានផលច្រើនជាង ប្រគេនបាយ ដល់ព្រះសោតាបន្ន ១០០ រូបទៅទៀត ។ ប្រគេន បាយ ដល់ព្រះអនាគាមីមួយរូប មានផលច្រើនជាងប្រគេនបាយ ដល់ព្រះសកទាគាមី ១០០ រូប ។ ប្រគេនបាយ ដល់ព្រះអរហន្ត មួយរូប មានផលច្រើនជាងប្រគេនបាយ ដល់ព្រះអនាគាមី ១០០ រូប ។ ប្រគេនបាយ ដល់ព្រះបច្ចេកពុទ្ធមួយអង្គ មានផលច្រើនជាង ប្រគេនបាយ ដល់ព្រះអរហន្ត ១០០ រូប ។ ប្រគេនបាយ ដល់ ព្រះសម្មាសម្ពុទ្ធមួយអង្គ មានផលច្រើនជាងប្រគេនបាយ ដល់ព្រះ

បច្ចេកពុទ្ធ ១០០ អង្គ ។ ប្រគេនបាយ ដល់ព្រះសង្ឃដែលមានព្រះពុទ្ធជាប្រធាន មានផលច្រើនជាងប្រគេនបាយ ដល់ព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ។ ប្រគេនវិហារ ដល់ព្រះសង្ឃដែលនិមន្តមកអំពីទិសទាំង ៤ មានផលច្រើនជាងប្រគេនបាយ ដល់សង្ឃដែលមានព្រះសម្មាសម្ពុទ្ធជាប្រធាននោះទៅទៀត" ដូច្នេះ ។

(២១) ក៏ក្នុងទក្ខិណាវិភង្គសូត្រ ក្នុងចតុត្ថវគ្គខុទ្ទកនិកាយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទានទុក ២១ យ៉ាង ។ ក៏បណ្តាទានទាំង ២១ យ៉ាងនោះ ទានណា ដែលបុគ្គលឲ្យហើយ ដល់សត្វតិរច្ឆាន ដើម្បីនឹងចិញ្ចឹម ដោយអំណាចគុណ មានការដល់ព្រមដោយលក្ខណៈជាដើម និងដោយអំណាចឧបការៈ មានការបានទឹកដោះនិងការចាំថែរក្សាជាដើម, ទាននោះ ព្រះអង្គមិនទ្រង់កំណាត់យកទេ ព្រោះមិនប្រកបដោយលក្ខណៈនៃទាន ។ មែនពិត ការបរិច្ចាគវត្ថុដែលគប្បីឲ្យរបស់ខ្លួន ដោយអំណាចសេចក្តីប្រាថ្នា ដើម្បីសេចក្តីអនុគ្រោះនិងការបូជា ឈ្មោះថា ទាន ។ ការបរិច្ចាគវត្ថុដែលគប្បីឲ្យ ដោយអំណាចការភ័យខ្លាច សេចក្តីស្រឡាញ់និងប្រាថ្នាការស៊ូកប៉ាន់ជាដើម មិនឈ្មោះថាទានទេ ព្រោះជាទានដែលមានទោស ។ វត្ថុសូម្បីត្រឹមតែពំនូតបាយកន្លះពំនូតឯណា ដែលបុគ្គលឲ្យហើយ, សូម្បីវត្ថុនោះ ព្រះអង្គក៏មិនបានកំណាត់យកដែរ ព្រោះមិនអាច

ក្នុងការឲ្យផលបានតាមដែលប្រាថ្នាចង់បាន ព្រោះភាវៈនៃទានដែលល្មមដល់សេចក្តីត្រូវការ នៅមិនទាន់បានបរិបូណ៌ ។ ក៏ទានណាដែលបុគ្គលប្រាថ្នាចំពោះផល ដោយន័យជាដើមថា "បុណ្យដែលសម្រេចដោយទាននេះឯង ចូរមានដើម្បីសេចក្តីចំរើននៃប្រយោជន៍សុខ តទៅ" ដូច្នេះហើយ បានឲ្យ ដល់បណ្តាសត្វតិរច្ឆាន មានសុនខជ្រូក មាន់ និងក្ដែកជាដើម សត្វឯណាមួយ ដែលខ្លួនបានជួបប្រទះហើយ ល្មមដល់សេចក្តីត្រូវការ, ទាននោះ ព្រះអង្គទ្រង់កំណត់យកហើយថា "ទាន ក្នុងសត្វតិរច្ឆាន" ។ ទានក្នុងសត្វតិរច្ឆាននោះ ឈ្មោះថា មានអានិសង្ស ១០០ ដង ព្រោះឲ្យអានិសង្ស ៥០០ គឺ ឲ្យអាយុ ក្នុង ១០០ អត្តភាព, ឲ្យពណ៌សម្បុរ ឲ្យសេចក្តីសុខ ឲ្យកម្លាំង ឲ្យបដិភាណៈ ក្នុង ១០០ អត្តភាព ។ គប្បីជ្រាបន័យសូម្បីក្នុងទានដែលខ្ពស់ឡើងៗ ទៅ យ៉ាងដូច្នេះដែរ ។ មួយទៀតជនទាំងឡាយមានព្រានសំណាញ់ និងអ្នកចាប់ត្រីជាដើម ដែលចិញ្ចឹមជីវិត ដោយការបៀតបៀនសត្វដទៃ ឈ្មោះថា បុថុជ្ជនទ្រុស្តសីល ។ ទានដែលគេឲ្យហើយ ដល់បុថុជ្ជនទ្រុស្តសីលនោះ មានអានិសង្ស មួយពាន់ ដង ។ ម្យ៉ាងទៀត បុគ្គលអ្នកមានសីល ដូចជាអ្នកមានសីល ជាអ្នកមិនអួតអាង មិនមានមាយា មិនបៀតបៀន នូវសត្វដទៃ ចិញ្ចឹមជីវិត ដោយកសិកម្ម ឬពាណិជ្ជកម្ម ដោយធម៌ស្មាំស្មើ ឈ្មោះថា

បុថុជ្ជនមានសីល ។ ទានដែលគេឱ្យ ដល់បុថុជ្ជនមានសីលនោះ មានអានិសង្ស មួយសែន ដង ។ មួយទៀត តាបសអ្នកបានអភិញ្ញា ៥ ដែលជាលោកិយ មានប្រក្រតីពោលកម្ម ជាអ្នកបួសខាងក្រៅ (អំពីសាសនា) ឈ្មោះថា ជាអ្នកគ្មានសេចក្តីត្រេកអរ ក្នុងកាមទាំងឡាយ, ទានដែលគេឱ្យហើយ ដល់តាបសអ្នកមិនមានសេចក្តីត្រេកអរ ក្នុងកាមទាំងឡាយនោះ មានអានិសង្ស មួយសែនកោដិ ។ ទានដែលគេបានឱ្យហើយ ដល់អ្នកទទួលទាំងឡាយ ១០ នេះ គឺ ដល់បុគ្គលដែលប្រតិបត្តិដើម្បីសោតាបត្តិផល ដល់ព្រះសោតាបន្ន ដល់បុគ្គលដែលប្រតិបត្តិដើម្បីសកទាគាមិផល ដល់ព្រះសកទាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអនាគាមិផល ដល់ព្រះអនាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអរហត្តផល ដល់ព្រះអរហន្ត ដល់ព្រះបច្ចេកពុទ្ធ ដល់ព្រះសម្មាសម្ពុទ្ធ ជាទានដែលរាប់មិនបាន ដោយផល ។

សួរថា "សេចក្តីប្លែកផ្សេងគ្នា នៃទានដែលគេឱ្យហើយ ដល់បដិគ្គាហកៈទាំង ១០ ពួកនោះ តើដូចម្តេចខ្លះ ?" ។ ឆ្លើយថា "ភាវៈនៃទានដែលគេឱ្យហើយ ចំពោះបុគ្គលអ្នកដែលប្រតិបត្តិដើម្បីប្រយោជន៍ដល់សោតាបត្តិផល មានផលរាប់មិនបាន គប្បីជ្រាបដូចជាទឹកក្នុងចង្អុរជារបស់ដែលរាប់មិនបានដូច្នោះ ។ ភាវៈនៃទានដែលបុគ្គលថ្វាយហើយ ចំពោះព្រះអរិយបុគ្គលទាំងឡាយ មានព្រះ

សោតាបន្នជាដើម ជាទានមានផលរាប់មិនបាន ដោយអំណាចគុណខ្ពស់ក្រៃលែងជាងគ្នា គប្បីជ្រាប ដូចជាទឹក ក្នុងមហានទី និងក្នុងមហាសមុទ្រនោះៗ ជារបស់ដែលរាប់មិនបានដូច្នោះ ។ សេចក្តីនេះ គប្បីជ្រាប សូម្បីក្នុងភាវៈនៃអាចម៍ដី ចាប់ដើមអំពីអាចម៍ដី ក្នុងប្រទេស ដែលមានទំហំស្មើនឹងមណ្ឌលលាន នៃផែនដី រហូតដល់អាចម៍ដី ពេញទាំងផែនដី ប្រមាណមិនបាន ។ មែនពិត សូម្បីកាលបើមាន ភាវៈនៃទានទាំងនោះ ជាទានស្មើគ្នាដោយភាវៈជាទានមានផលរាប់មិនបាន, ភាវៈនៃទានជារបស់តិចនិងច្រើនរមែងមានដូចគ្នា គប្បីជ្រាបដូចជាសំវដ្តកប្បជាដើម ជារបស់រាប់មិនបាន និងភាវៈនៃមហាកប្ប ក៏ជារបស់ដែលរាប់មិនបានដូច្នោះ ។ បណ្តាអ្នកទទួលទាំងនោះ អ្នកទទួលទាំងឡាយ ៨ នេះ គឺ ឧបាសកអ្នកដល់នូវព្រះត្រៃសរណៈ, ឧបាសកអ្នកតាំងនៅ ក្នុងសីល ៥, ឧបាសកអ្នកតាំងនៅ ក្នុងសីល ១០, សាមណេរដែលបួសក្នុងថ្ងៃនោះ, ភិក្ខុអ្នកគ្រាន់តែបួសហើយភ្លាម, ភិក្ខុអ្នកដល់ព្រមដោយវត្ត, ភិក្ខុអ្នកប្រារព្ធវិបស្សនា, ភិក្ខុអ្នកតាំងនៅ ក្នុងបឋមមគ្គ ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ ដល់សោតាបត្តិផល ។ មែនពិត ការចុះកាន់ព្រះសាសនា ក៏ត្រឹមតែដើម្បីរលាស់ចេញនូវទុក្ខ ក្នុងវដ្តសំសារ និងត្រឹមតែដើម្បីចាក់ផ្តុះនូវមគ្គ តែប៉ុណ្ណោះ, ព្រោះហេតុនោះ កិរិយា

ដល់នូវសរណៈ ការសមាទានសិក្ខាបទ បព្វជ្ជា ឧបសម្បទ ការញុំាង
សីលឱ្យបរិបូណ៌ ការប្រកបរឿយៗនូវអធិចិត្តសិក្ខា វិបស្សនា ដែល
ជាចំណែកនៃការត្រាស់ដឹង សរុបទៅ បដិបទាទាំងនេះជាការបតិបត្តិ
ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ដោយពិត ។ ប្រៀបដូច
ជាសមាធិភាវនា ដែលជាចំណែកនៃកិរិយាត្រាស់ដឹង រមែងជា
ឧបនិស្សយ ដោយភាវៈជាបច្ច័យ នៃការសម្រេចនូវអរិយមគ្គ ជា
បន្តបន្ទាប់គ្នាទៅ យ៉ាងណាមិញ, ការធ្វើសីលឱ្យបរិបូណ៌ ឧបសម្បទ
បព្វជ្ជា កិរិយាតាំងនៅ ក្នុងសីល ១០ ឬសីល ៥ របស់ឧបាសក
ដែលជាចំណែកនៃការត្រាស់ដឹង ដោយហោចទៅ សូម្បីការដល់នូវ
សរណៈ ដែលជាចំណែកនៃការត្រាស់ដឹង រមែងជាឧបនិស្សយនៃ
ការបានសម្រេចនូវអរិយមគ្គ ក៏យ៉ាងដូច្នោះដែរ ព្រោះហេតុនោះ
បដិបទាទាំងអស់នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ជាសេចក្តី
បតិបត្តិ ដើម្បីប្រយោជន៍ដល់សោតាបត្តិផល" ដូច្នេះ ។ បណ្តា
បដិគ្គាហកៈទាំង ៨ ពួកនោះ សូម្បីទានដែលបុគ្គលឱ្យហើយ ដល់
ឧបាសកអ្នកដល់នូវ ត្រ័យសរណៈ ក៏រមែងមានផលរាប់មិនបាន ។
ក៏សេចក្តីជ្រះថ្លា ដែលញ្ញាណជម្រះហើយ ដែលសង្គ្រោះ ដោយ
សេចក្តីរាប់អាន និងសេចក្តីគោរពដ៏ច្រើន ក្នុងព្រះដ៏មានព្រះភាគ
ក្នុងព្រះសទ្ធម្ម ក្នុងព្រះសង្ឃ ដោយអាការៈយ៉ាងប្រសើរក្រៃលែង

ដែលប្រព្រឹត្តទៅហើយ ដោយអាការៈថា ភាវៈជាអ្នកមានព្រះរតនត្រៃ នោះជាខាងដើម ជាអាទិ៍ថា “ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ដឹង ដោយប្រពៃ ចំពោះព្រះអង្គឯង, ព្រះធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ដោយល្អ, ព្រះសង្ឃជាអ្នកប្រតិបត្តិហើយ ដោយល្អ ” ដូច្នេះ ឈ្មោះថា សរណាគមន៍ ។ បុណ្យដែលបុគ្គលធ្វើហើយ ក្នុងសន្តាន ដែលខ្លួនអប់រំហើយ ដោយសេចក្តីជ្រះថ្លា ដែលប្រព្រឹត្តទៅ ក្នុងវត្ថុ (ព្រះរតនត្រៃ) នោះ រមែងជាទានមានផលច្រើន ព្រោះកិរិយាដល់ព្រមនៃខេត្ត ដោយប្រការដូច្នេះឯង ។ ទានដែលបុគ្គលឱ្យហើយ ដល់ឧបាសកអ្នកមានសីល ៥ ជាទានមានផលច្រើន ជាងទាននោះ ។ ព្រោះថា សរណាគមន៍ គឺជាកិរិយាដល់ព្រមនៃអធ្យាស្រ័យ ព្រោះមានសេចក្តីជ្រះថ្លា ក្នុងវត្ថុ ៣ យ៉ាង (ព្រះរតនត្រៃ) សរូបសេចក្តីទៅ សីល ៥ របស់ឧបាសកអ្នកប្រាកដដូច្នោះនោះ ក៏គឺសេចក្តីសង្រួមកាយវាចា ដែលកិរិយាដល់ព្រមនៃអធ្យាស្រ័យឧបត្ថម្ភហើយ ព្រោះហេតុនោះ ទានដែលបុគ្គលបានឱ្យហើយ ចំពោះឧបាសកអ្នកមានសីល ៥ នោះ ទើបឈ្មោះថា មានផលច្រើន យ៉ាងដូច្នេះ ។ ទានដែលបុគ្គលឱ្យហើយ ដល់ឧបាសកអ្នកមានសីល ១០ មានផលច្រើនជាង ទានដែលគេឱ្យ ដល់ឧបាសកអ្នកមានសីល ៥ នោះ ។ មែនពិត សីល ១០ ឈ្មោះថា សីល របស់

ឧបាសក យ៉ាងបរិបូណ៌ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០ នោះ ទើបមានផលច្រើន ដូច្នេះ ។ ទានដែលបុគ្គលប្រគេនហើយ ដល់សាមណេរ មានផលច្រើនជាងទាននោះ ។ ទានដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកគ្រាន់តែបួសស្រេចហើយភ្លាម មានផលច្រើនជាងទាននោះ ។ ទានដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកដល់ព្រមដោយវត្ត មានផលច្រើនជាងទាននោះ ។ ទានដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកប្រារព្ធវិបស្សនា មានផលច្រើនជាងទាននោះ ។ ក៏ភាវៈនៃទានដែលបុគ្គលឲ្យហើយ ចំពោះបដិគ្គាហកៈនោះ ។ ជាទានមានផលច្រើនប្លែកផ្សេងៗគ្នា ព្រោះភាវៈនៃគុណ មានសីលរបស់សាមណេរជាដើម ប្រសើរជាងគ្នាជាអាទិ៍ ព្រោះគុណដែលប្រសើរខ្ពង់ខ្ពស់ជាងគ្នា ដូច្នេះ ។ ក៏ភាវៈនៃលោកអ្នកដែលព្រមព្រៀងដោយមគ្គ ឈ្មោះថា ជាអ្នកមានគុណមិនទាន់ពេញបរិបូណ៌ ព្រោះលោកជាអ្នកមិនទាន់បានសម្រេចកិច្ច ព្រោះសង្កិលេសធម៌ទាំងឡាយ លោកកំពុងតែលះបង់ និង ព្រោះវោទានធម៌ទាំងឡាយ គឺលោកកំពុងតែចំរើន ដោយចំណែកនោះ ។, ភាវៈនៃលោកអ្នកដែលព្រមព្រៀងដោយផលទាំងឡាយ ឈ្មោះថា ជាអ្នកមានគុណបរិបូណ៌ហើយ ព្រោះលោកជាអ្នកមានកិច្ចសម្រេចហើយ ព្រោះហេតុនោះ គប្បីជ្រាប

ភាវៈនៃលោកអ្នក ដែលតាំងនៅក្នុងផល ជាខេត្ត ដ៏ខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅក្នុងមគ្គនោះៗ ។ មួយទៀត ភាវៈនៃលោកអ្នកដែលតាំងនៅ ក្នុងមគ្គខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ជាងលោកអ្នកដែលតាំងនៅ ក្នុងមគ្គខាងក្រោម និងភាវៈនៃលោកអ្នកដែលតាំងនៅ ក្នុងផលខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ជាងលោកអ្នកដែលតាំងនៅ ក្នុងផលខាងក្រោម ប្រាកដហើយមែនពិត ។ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ភាវៈ នៃទានដែលបុគ្គលប្រគេនហើយ ដល់ព្រះអរិយបុគ្គលអ្នកមានគុណខ្ពង់ខ្ពស់ទាំងឡាយ ជាទានមានផលច្រើន ។ សួរថា "ឈ្មោះថា ភាវៈនៃលោកអ្នកដែលព្រមព្រៀងដោយមគ្គ ដែលធម្មតាកំណត់ហើយ ដោយលក្ខណៈនៃមគ្គចិត្ត, ក៏ក្នុងខណៈនោះ ការប្រគេនទានក្តី ការទទួលទានក្តី នឹងមានព្រម យ៉ាងដូចម្តេច ?" ។ ឆ្លើយថា "ភិក្ខុអ្នកប្រារព្ធវិបស្សនា ជាអ្នកឈរនៅត្រង់មាត់ទ្វារផ្ទះ ឬអង្គុយនៅក្នុងវិហារ និងសាលារាន់, ទាយកទទួលបាត្រ របស់លោក ហើយក៏ដាក់នូវរបស់ដែលគួរឆាន់ គួរបរិភោគចូលទៅ, ក្នុងខណៈនោះ ការចេញ (ចាកកិលេស) ដោយមគ្គ រមែងមានដល់ភិក្ខុ, ទាននេះ ឈ្មោះថា ជាទានដែលប្រគេនហើយ ដល់លោកអ្នកដែលព្រមព្រៀងដោយមគ្គ ។ ទាន ១៤ យ៉ាងនេះ ឈ្មោះថា បាដិបុគ្គលិកទាន

ព្រោះធ្វើវិគ្រោះថា "ចំពោះបុគ្គល គឺចំពោះបុគ្គលម្នាក់ ឈ្មោះថា ចំពោះបុគ្គល, ទានដែលឈ្មោះថា បាដិបុគ្គលិក ព្រោះអត្ថថា 'គឺគេឱ្យដល់បុគ្គលចំពោះនោះ"។ ក៏ទានដែលបុគ្គលប្រគេនហើយដល់បុគ្គលទាំង ៧ ពួកនេះ គឺ ដល់ព្រះសង្ឃទាំង ២ ផ្នែក ដែលមានព្រះពុទ្ធជាប្រធាន ដល់ព្រះសង្ឃទាំង ២ ផ្នែកទាំងស្រុង ដល់ព្រះភិក្ខុសង្ឃ ដល់ភិក្ខុនីសង្ឃ ដល់បដិគ្គាហកៈដែលទាយកនិមន្តចំពោះចាកព្រះសង្ឃទាំង ២ ផ្នែក ដល់បដិគ្គាហកៈដែលទាយកនិមន្តចំពោះចាកព្រះភិក្ខុសង្ឃ ដល់បដិគ្គាហកៈដែលទាយកនិមន្តចំពោះចាកព្រះភិក្ខុនីសង្ឃ ឈ្មោះថា ទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ។ ទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃទាំងអស់នោះ មានផលរាប់មិនបាន។

ដោយហេតុនោះ ក្នុងអដ្ឋកថាទក្ខិណាវិភង្គសូត្រ ទើបលោកពោលថា "សូម្បីទក្ខិណា ដែលបុគ្គលប្រគេនហើយ ចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា 'ឈ្មោះថាជាទានមានផលរាប់មិនបាន' ព្រោះការរាប់ដោយគុណ" ដូច្នេះ។ មែនពិត ទក្ខិណាដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឃ រមែងមាន ដល់បុគ្គលដែលអាច ដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះព្រះសង្ឃ។ តែកិរិយាធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះព្រះសង្ឃ ជាកិច្ចដែលធ្វើបានដោយកម្រ។ ក៏បុគ្គលណា ចាត់ចែងនូវ

ទេយ្យធម៌ ដោយគិតថា "អាត្មាអញនឹងប្រគេននូវទាន ដែលប្រព្រឹត្ត
ទៅក្នុងព្រះសង្ឃ" ដូច្នេះ ទៅកាន់វត្តហើយ ពោលថា "បពិត្រព្រះ
គុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ឱ្យនូវព្រះថេរៈមួយរូប ចំពោះ
ចាកព្រះសង្ឃ" ដូច្នេះ, លុះដល់បានសាមណេរ ចាកព្រះសង្ឃហើយ
ក៏រមែងដល់នូវភាពជាជនទៃ (អាក់អន់ចិត្ត) ថា "អាត្មាអញបាន
សាមណេរ" ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះ រមែងមិនឈ្មោះថា
ប្រព្រឹត្តទៅក្នុងព្រះសង្ឃទេ ។ សូម្បីកាលបើបានព្រះមហាថេរ
ហើយ ទោះជាធ្វើសេចក្តីសោមនស្សឱ្យកើតឡើងថា "អាត្មាអញ
បានព្រះមហាថេរ" ដូច្នេះ, ទក្ខិណានោះ ក៏មិនឈ្មោះថា ប្រព្រឹត្តទៅ
ក្នុងព្រះសង្ឃ ដូចគ្នាដែរ ។ ចំណែកបុគ្គលណា បាននូវបដិគ្គាហកៈ
ជាសាមណេរ ឬឧបសម្បន្ន ជាកម្លោះ ឬព្រះថេរៈ ជាពាល ឬបណ្ឌិត
រូបណាមួយ ចាកព្រះសង្ឃ ជាអ្នកមិនមានសេចក្តីសង្ស័យ រមែង
អាច ដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃថា
"អាត្មាអញប្រគេនដល់ព្រះសង្ឃ" ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះ
រមែងឈ្មោះថា ជាទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ ។ សមណៈ
ដែលទាយកនិមន្តចំពោះ ចាកព្រះសង្ឃ ជាបុថុជ្ជន, បាដិបុគ្គលិក
ជាព្រះសោតាបន្ន, កាលបើបុគ្គល អាចធ្វើសេចក្តីគោរពកោតក្រែង
ក្នុងព្រះសង្ឃ, ទានដែលបុគ្គលប្រគេនហើយ ចំពោះសមណៈដែល

ជាបុថុជ្ជន ក៏ជាទានមានផលច្រើនជាង ។ សូម្បីក្នុងពាក្យជាដើមថា "សមណៈដែលទាយកនិមន្តចំពោះ (ចាកសង្ឃ) ជាព្រះសោតាបន្ន បាដិគ្គាហកៈជាព្រះសកទាគាមី" ក៏នัยនេះ ដូចគ្នាដែរ ។ មែនពិត កាលបើបុគ្គលអាច ដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះព្រះសង្ឃ, ទានដែលបុគ្គលប្រគេនហើយ សូម្បីចំពោះសមណៈទ្រុស្តសីល ដែលគេនិមន្តចំពោះ (ចាកសង្ឃ) ក៏ជាទានមានផលច្រើនជាង ទានដែលគេប្រគេន ចំពោះព្រះខីណាស្រព ដោយពិត ។ ក៏ព្រះតម្រាស់ណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា 'បពិត្រព្រះមហារាជ ទានដែលបុគ្គលប្រគេនហើយ ដល់សមណៈអ្នកមានសីល ជាទានមានផលច្រើន, ដែលប្រគេនហើយ ដល់សមណៈអ្នកទ្រុស្តសីល មិនមានផលច្រើន យ៉ាងដូច្នោះទេ' ដូច្នេះ, ព្រះតម្រាស់នោះ ព្រះអង្គទ្រង់ត្រាស់ លះបង់នัยនេះចោល" ។

(២២) ជីកាទក្ខិណាវិភង្គសូត្រនោះ ថា "បទថា 'គុណាសង្ខាយ' មានសេចក្តីថា ព្រោះការគណនារាប់ ដោយផលអានិសង្ស គឺព្រោះភាវៈនៃទានមានផលច្រើន ។ ទក្ខិណាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា 'មានផលរាប់មិនបាន' ក៏ព្រោះភាវៈនៃទក្ខិណានោះ គឺបុគ្គលប្រគេនហើយ ចំពោះព្រះសង្ឃ ។ ក៏ការប្រគេន ចំពោះព្រះសង្ឃ រមែងមាន ដោយវិធីណា, ដើម្បីនឹង

សំដែងនូវវិធីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាដើមថា '**សង្ឆគតា ទក្ខិណា ហិ**' ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា '**ចិតិការំ**' បានដល់ សេចក្តីគោរព ។ ចាកព្រះសង្ឆ មិ៉នមែនចាកបុគ្គល ។ បទថា '**អញ្ញថត្តំ**' មានសេចក្តីថា មិនញ្ចាំងចិត្តឲ្យកើតឡើង យ៉ាងនេះថា 'ទាន ជាទាន គឺអាត្មាអញបានឲ្យហើយ ដល់បុគ្គលនេះ' ដូច្នេះ ហើយចាត់ចែងនូវទេយ្យធម៌ ដោយគិតថា 'អាត្មាអញនឹងប្រគេន ដល់ព្រះសង្ឆ' ដូច្នេះ រមែងដល់នូវភាវៈជាអ្នកមានចិត្តផ្សេង (អន់ចិត្ត) ថា 'ទាន ឈ្មោះថា ជាទានដែលអាត្មាអញគប្បីប្រគេន ដល់សាមណេរ' ដូច្នេះ, ព្រោះហេតុនោះ ទក្ខិណា របស់បុគ្គលនោះ រមែងមិនឈ្មោះថា ជាទានដែលប្រព្រឹត្តទៅ ក្នុងព្រះសង្ឆឡើយ, ទក្ខិណា រមែងមិនឈ្មោះថា ប្រព្រឹត្តទៅ ក្នុងព្រះសង្ឆបាន ក៏ព្រោះធ្វើចិត្តឲ្យប្រែប្រួលទៅ ដោយអំណាចនៃបុគ្គល ។ ២ បទថា '**និព្វេមតិកោ ហុត្វា**' មានសេចក្តីថា មិនញ្ចាំងសេចក្តីសង្ឆ័យឲ្យកើតឡើងថា 'ទាន ជាទានដែលអាត្មាអញបានឲ្យហើយដល់បុគ្គលនេះ ឬក៏មិនបានឲ្យហើយឬទេហ្នុ៉?' ។ ២ បទថា '**សង្ឆេ ចិតិការំ**' មានសេចក្តីថា កាលបើបុគ្គលនឹករលឹកដល់គុណនៃព្រះសង្ឆ មានភាវៈជាអ្នកប្រតិបត្តិប្រពៃជាដើមប្រគេន ដោយអំណាចសេចក្តីគោរព ដែលកើតឡើងហើយ ក្នុង

បុគ្គលនោះ ប្រៀបដូចជាប្រគេន នៅចំពោះមុខ នៃព្រះសង្ឆ ដោយ
សេចក្តីជ្រះថ្លា ក្នុងសង្ឆគុណ, ទានដែលបុគ្គលប្រគេនហើយចំពោះ
សមណៈជាបុថុជ្ជន ក៏រមែងមានផលច្រើនជាង ។ ទានដែលបុគ្គល
ប្រគេនហើយ ចំពោះសមណៈអ្នកទ្រុស្តសីល រមែងជាទានមានផល
ច្រើនជាង (ទានដែលគេប្រគេនចំពោះព្រះខីណាស្រព) ដោយពិត
ព្រោះសមណៈនោះ គេនិមន្ត ចំពោះ អំពីព្រះសង្ឆ និងព្រោះគេ
ប្រគេនហើយ ដោយគិត យ៉ាងនេះថា 'អាត្មាអញនឹងប្រគេន ដល់
ព្រះសង្ឆ' ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់ថា 'ម្នាលអានន្ទ តថាគត មិនពោលនូវបាដិបុគ្គលិកទាន
ថាជាទានមានផលច្រើន ជាងទក្ខិណា ដែលប្រព្រឹត្តទៅក្នុងព្រះសង្ឆ
ដោយបរិយាយណាមួយសោះឡើយ' ដូច្នេះ ។ ព្រះអដ្ឋកថាចារ្យ
ចោទសួរថា 'ប្រសិនបើទានដែលគេប្រគេនហើយ សូម្បីចំពោះ
សមណៈអ្នកទ្រុស្តសីល ដែលគេនិមន្តចំពោះ អំពីព្រះសង្ឆ រមែង
ជាទានមានផលច្រើនជាង ទានដែលបុគ្គលប្រគេនហើយ ចំពោះ
ព្រះខីណាស្រព, កាលបើមានយ៉ាងដូច្នោះ, ពាក្យថា 'បពិត្រព្រះ
មហារាជ ទានដែលបុគ្គលប្រគេនហើយ ដល់បុគ្គលអ្នកមានសីល
នុ៉ះឯង ជាទានមានផលច្រើន, ដែលប្រគេន ដល់បុគ្គលទ្រុស្តសីល
មិនមានផលច្រើន យ៉ាងដូច្នោះទេ' ដូច្នេះ នេះ តើយ៉ាងដូចម្តេចហ្នា!'

ដូច្នេះហើយ ទើបពោលថា 'ពាក្យនោះ ព្រះដ៏មានព្រះភាគ ត្រាស់ហើយ លះបង់នូវនិយ្យានេះចោល" ដូច្នេះ ។ ឆ្លើយថា 'ពាក្យនោះ ព្រះអង្គទ្រង់លះចោលនូវវិធីនិមន្តចំពោះ អំពីព្រះសង្ឃ ហើយត្រាស់ដោយអំណាចការនិមន្តសមណៈអ្នកទ្រុស្តសីល តែម្យ៉ាង' ដូច្នេះ"។

(២៣) ទាននោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃកិរិយាបានសម្រេចផលដ៏វិសេស ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ននិងសម្បរាយភព មានភាពជាអ្នកជាទីស្រឡាញ់ពេញចិត្ត នៃជនច្រើនជាដើម ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ដល់សេនាបតី ឈ្មោះថាសីហៈ ទើបទ្រង់ត្រាស់ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា "ម្នាលសីហៈ ទាយក អ្នកម្ចាស់ទាន រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត របស់ជនច្រើន, ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន រមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនច្រើន ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទាន ដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកអ្នកម្ចាស់ទាន, ម្នាលសីហៈ ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកអ្នកម្ចាស់ទាន ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទាន ដែលបុគ្គលគប្បីឃើញជាក់ច្បាស់ ដោយខ្លួនឯង ។

ម្នាលសីហៈ មួយទៀត កិត្តិសព្ទដ៏ពីរោះ របស់ទាយកអ្នកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ, ម្នាលសីហៈ កិត្តិសព្ទដ៏ពីរោះ របស់ទាយក អ្នកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទាន ដែលបុគ្គលគប្បីឃើញច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកអ្នកម្ចាស់ទាន ចូលទៅកាន់បរិសទ្យណាមួយ ទោះជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី, រមែងជាអ្នកក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ចូលទៅកាន់បរិសទ្យនោះ, ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ចូលទៅកាន់បរិសទ្យណាមួយ ទោះជាខត្តិយ-បរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី, ជាអ្នកក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស រមែងចូលទៅកាន់បរិសទ្យនោះ ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទានដែល បុគ្គលគប្បីឃើញជាក់ច្បាស់ ដោយខ្លួនឯង ។ ម្នាលសីហៈ មួយទៀត ទាយកអ្នកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក, ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក ដោយហេតុណា, ម្នាលសីហៈ ហេតុនេះឯង ជាផលនៃទាន មានក្នុងលោកខាងមុខ" ដូច្នេះ ។

ក៏ព្រះមានព្រះភាគ លុះទ្រង់ត្រាស់ យ៉ាងនេះហើយ ទើបទ្រង់បានត្រាស់នូវព្រះគាថាទាំងនេះ ថា ÷

“ទាយកអ្នកឲ្យទាន រមែងជាទីស្រឡាញ់[1] (របស់ជនច្រើនផង), ពួកសប្បុរសជាច្រើនរមែងរាប់រកទាយកនោះផង, ទាយកនោះ រមែងដល់នូវកិត្តិសព្ទផង, យស រមែងចំរើន ដល់ទាយកនោះផង, នរជនអ្នកមិនមានសេចក្តីកំណាញ់ ជាអ្នកមិនមានសេចក្តីអៀនខ្មាស មានសេចក្តីក្លៀវក្លា ចូលទៅកាន់បរិសទ្យ, ព្រោះហេតុនោះឯង បណ្ឌិតទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ ត្រូវលះបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទានទាំងឡាយ, បណ្ឌិតទាំងឡាយនោះ ស្ថិតនៅ ក្នុងស្ថានត្រៃត្រឹង្ស រស់កាលដ៏យូរអង្វែង, បណ្ឌិតទាំងនោះ ដល់នូវភាពជាមួយគ្នា នៃពួកទេវតារមែងរីករាយសប្បាយ, បណ្ឌិតទាំងនោះ ជាអ្នកមានឱកាសធ្វើហើយ មានកុសលធ្វើហើយ ច្យុតអំពីលោកនេះ មានរស្មីខ្លួនឯង អន្លោលទៅ ក្នុងទីជាទីត្រេកអរ, បណ្ឌិតទាំងនោះ ស្កប់ស្កល់ហើយ ដោយ

---

១ ត្រៃបិដក ភាគទី ៤៤ / ទំព័រទី ៧៩

កាមគុណទាំង ៥ ត្រេកអរ រីករាយ សប្បាយ ក្នុងទីជាទីត្រេកអរនោះ ។ ពួកសាវ័កទាំងអស់ របស់ព្រះសុគត ធ្វើតាមពាក្យ របស់ព្រះតថាគត ព្រះអង្គមិនជាប់ដោយអកុសលធម៌ ទ្រង់ប្រកបដោយតាទិគុណហើយ រមែងរីករាយសប្បាយ" ។

សីហសូត្រ ក្នុងសុមនវគ្គទី ៤ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ចប់ ។

(២៤) ក្នុងអដ្ឋកថាអដ្ឋកនិបាត អង្គុត្តរនិកាយ លោកពោលថា "ពាក្យថា '**សីហោ សេនាបតិ**' បានដល់ ព្រះរាជកុមារទ្រង់ព្រះនាមយ៉ាងនោះ ទ្រង់ជាមេបញ្ជាការនៃទ័ព ។ មែនពិត ក្នុងក្រុងវេសាលី មានព្រះរាជា ៧,៧០៧ ព្រះអង្គ, ព្រះរាជាទាំងអស់ព្រះអង្គនោះ ទ្រង់ប្រជុំ ប្រឹក្សាគ្នា ថា 'សូមអ្នកទាំងឡាយ ជ្រើសរើសរកនូវបុគ្គលម្នាក់ ដែលអង់អាច ដើម្បីនឹងយកចិត្ត របស់ពួកប្រជាជនហើយ រៀបចំចាត់ចែង រដ្ឋធានីបាន' ដូច្នេះ កាលជ្រើសរើសរក ក៏ទ្រង់ឃើញនូវសីហរាជកុមារហើយ ទ្រង់ធ្វើសេចក្តីសម្រេចព្រះទ័យថា 'ព្រះសីហរាជកុមារអង្គនេះ នឹងអាច' ដូច្នេះ ទ្រង់បានព្រះរាជទាននូវឆ័ត្រនៃសេនាបតី (តំណែង) ដែលមានពណ៌កែវមណីក្រហម ដែលស្រោបដោយសំពត់កម្ពល ដល់សីហរាជកុមារនោះ" ។

(២៥) អដ្ឋកថាសីហាសូត្រនោះថា "បទថា **'សន្និដ្ឋិកំ'** បានដល់ ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ។ បទថា **'ទាយកោ'** បានដល់ អ្នកអង់អាចក្នុងទាន ។ អធិប្បាយថា 'អ្នកនោះ មិនឈប់នៅដោយហេតុត្រឹមតែសេចក្តីជឿថា 'ទាន ញុំាងប្រយោជន៍ឲ្យសម្រេច' ប៉ុណ្ណោះទេ រមែងអាច សូម្បីលះបង់បានផង' ដូច្នេះ ។ បទថា **'ទានបតី'** មានសេចក្តីថា បុគ្គលរមែងឲ្យនូវទានណា, រមែងជាម្ចាស់ នៃទាននោះឲ្យ, មិនមែនជាខ្ញុំបម្រើ នៃទាននោះ, មិនមែនជាសំឡាញ់ នៃទាននោះឲ្យទេ ។ មែនពិត បុគ្គលណា បរិភោគនូវរបស់ដែលល្អ ដោយខ្លួនឯង (តែ) ឲ្យនូវរបស់ដែលមិនល្អ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាខ្ញុំបម្រើ នៃទេយ្យធម៌ ពោលគឺទានហើយឲ្យ ។ បុគ្គលណាបរិភោគ នូវរបស់ណា ដោយខ្លួនឯង ក៏ឲ្យនូវរបស់នោះឯង (ដល់អ្នកដទៃ), បុគ្គលនោះ ឈ្មោះថា ជាសំឡាញ់ នៃទានហើយឲ្យ ។ ចំណែកបុគ្គលណា ខ្លួនឯង ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយរបស់ឯណាមួយ (តែ) ឲ្យនូវរបស់ដែលល្អ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាម្ចាស់ ជាធំ ជាចៅហ្វាយនាយ នៃទានឲ្យ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកបុគ្គលអ្នកប្រាកដដូច្នោះ ទើបទ្រង់ត្រាស់ថា 'ទានបតី' ដូច្នេះ ។ បទថា **'អមង្គុភូតោ'** គឺ មិនមែនជាអ្នកប្រាសចាកតេជៈបារមី ។ បទថា

'**វិសារទោ**' គឺ ជាអ្នកដល់នូវសោមនស្ស ដែលសម្បយុត្ត ដោយ ញាណ។ ២ បទថា '**សហព្យតំ គតា**' មានសេចក្តីថា ដល់នូវ ភាពជាមួយគ្នា គឺភាពជាពួកតែមួយ។ បទថា '**កតាវកាសា**' មានសេចក្តីថា ឈ្មោះថា ជាអ្នកមានឱកាសដែលធ្វើហើយ ព្រោះជា អ្នកធ្វើកម្ម ដែលជាហេតុមានឱកាស ក្នុងនន្ទវនៃនោះ។ ក៏កម្មនោះ ជាកុសលតែម្យ៉ាង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមាន ព្រះភាគ ទ្រង់ត្រាស់ថា 'ជាអ្នកមានកុសលបានធ្វើហើយ' ដូច្នេះ។ បទថា '**មោទរេ**' ប្រែថា រមែងត្រេកអរ គឺរីករាយសប្បាយ។ បទថា '**អសិតស្ស**' មានសេចក្តីថា របស់ព្រះតថាគត ព្រះអង្គគឺ តណ្ហាមិនអាស្រ័យហើយ។ បទថា '**តាទិនោ**' បានដល់ អ្នកដល់ នូវលក្ខណៈ នៃបុគ្គលអ្នកមិនញាប់ញ័រ"។

(២៦) ជីកាសីហាសូត្រនោះថា "បទថា '**សន្ទិដ្ឋិកំ**' មាន សេចក្តីថា ឈ្មោះថា គឺបុគ្គលគប្បីឃើញ ព្រោះភាវៈជាផលដែលមិន ប្រព្រឹត្តទៅ ក្នុងសម្បរាយភព គឺដែលបុគ្គលគប្បីសោយ ដោយខ្លួន ឯង ជារបស់ប្រាកដច្បាស់ចំពោះខ្លួន គឺ ប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ន។ ច្រើនបទថា '**សាហុ ទានន្តិ សទ្ធាមត្តកេនេវ តិដ្ឋតិ**' មានសេចក្តី ថា ទាយកនោះ រមែង (មិន) ឈប់នៅនឹង ដោយហេតុត្រឹមតែ សេចក្តីជឿ យ៉ាងដូច្នេះថា 'ឈ្មោះថា ទាន ជាធម្មជាតឱ្យសម្រេច

ប្រយោជន៍ ជារបស់ប្រសើរ ដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមទ្រង់ក្រាស់សរសើរហើយ'។ ច្រើនបទថា **'យំ ទានំ ទេតិ'** មានសេចក្តីថា បុគ្គលរមែងឱ្យនូវទេយ្យធម៌ណា ដល់បុគ្គលដទៃ។ ច្រើនបទថា **'តស្ស បតិ ហុត្វា ទេតិ'** មានសេចក្តីថា ទាយកគ្របសង្កត់នូវសេចក្តីលោភលន់បាន ដោយល្អ ឈ្មោះថា ជាម្ចាស់នៃទាននោះឱ្យ ព្រោះភាវៈនៃខ្លួន គឺសេចក្តីលោភនោះ គប្បីគ្របសង្កត់មិនបាន។ ព្រះអដ្ឋកថាចារ្យពោលថា **'យោ ហិ'** ដូច្នេះជាដើម ដើម្បីនឹងសំដែង នូវពាក្យទាំង ២ យ៉ាងនោះ គឺ **ន ទាសោ ន សហាយោ** ដោយន័យដែលអនុលោម និងបដិលោម។ ទាយក ឈ្មោះថា ជាខ្ញុំបម្រើ (នៃទាន) ឱ្យ ព្រោះភាវៈ នៃខ្លួនជាអ្នកខិតចូលទៅជិត នៃភាពជាខ្ញុំបម្រើ នៃតណ្ហា។ ទាយក ឈ្មោះថា ជាសំឡាញ់ (នៃទាន) ឱ្យ ព្រោះលះបង់នូវភាវៈ នៃរបស់ដែលមិនជាទីស្រឡាញ់ នៃទេយ្យធម៌នោះចោលបាន។ ទាយក ឈ្មោះថា ជាម្ចាស់ (នៃទាន) ឱ្យ ព្រោះរើបម្រះខ្លួនចេញ អំពីភាពជាខ្ញុំបម្រើ នៃតណ្ហា ក្នុងទាននោះហើយ ប្រព្រឹត្តគ្របសង្កត់។

ម្យ៉ាងទៀត បុគ្គលណា ឈ្មោះថា ជាទាយក ព្រោះឱ្យទានជាប្រក្រតី, បុគ្គលនោះ ដោយប្រភេទនៃកិរិយាប្រព្រឹត្តិទៅ ក្នុងទានរមែងមាន ៣ ប្រការ គឺ ជាខ្ញុំបម្រើនៃទាន ជាសំឡាញ់នៃទាន

ជាម្ចាស់នៃទាន, ដើម្បីនឹងសំដែងវែកញែកបំបែក នូវភាវៈនៃទាយក ជាអ្នកមាន ៣ ប្រភេទនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យថា 'យោ ហិ' ដូច្នេះជាដើម ។ បាយនិងទឹកជាដើម ឈ្មោះថា ទាន ព្រោះអត្ថថាជារបស់ដែលគប្បីឲ្យ ។ បណ្តាទាយកទាំង ៣ ប្រភេទនោះ បុគ្គលបរិភោគនូវវត្ថុណា ដោយខ្លួនឯង, បុគ្គលនោះ ឈ្មោះថា ប្រៀបដូចជាខ្ញុំបម្រើ ព្រោះប្រព្រឹត្តទៅ ក្នុងអំណាចនៃវត្ថុនោះ ព្រោះភាវៈនៃខ្លួនត្រូវតណ្ហាគ្របសង្កត់, ឈ្មោះថា ប្រៀបដូចជាខ្ញុំបម្រើ ព្រោះប្រព្រឹត្តទៅ ក្នុងអំណាចនៃវត្ថុ ដែលខ្លួនមិនឲ្យដល់ពួកជនដទៃ ។ ក្នុងបទថា 'តត្ថ' ព្រះអដ្ឋកថាចារ្យ ពោលពាក្យនេះថា 'ជាខ្ញុំបម្រើ នៃទេយ្យធម៌ ពោលគឺការឲ្យ' ដូច្នេះ ក៏ព្រោះភាវៈនៃបាយនិងទឹកជាដើម ជារបស់ស្មើគ្នា ។ ទាយក ឈ្មោះថា ជាសំឡាញ់ឲ្យ ព្រោះចាត់ចែង នូវរបស់ដែលខ្លួនគប្បីបរិភោគ និងរបស់ដែលខ្លួនគប្បីឲ្យ ដល់ពួកជនដទៃទុក ដោយភាពស្មើៗគ្នា ។ ទាយក ឈ្មោះថា ជាម្ចាស់ (នៃទាន) ឲ្យ ព្រោះមិនប្រព្រឹត្តទៅ ក្នុងអំណាចនៃទេយ្យធម៌ ដោយខ្លួនឯង (ប៉ុន្តែ) ញុំាងទេយ្យធម៌នោះ ឲ្យប្រព្រឹត្តទៅ ក្នុងអំណាចរបស់ខ្លួនទៅវិញ ។

នំយមួយទៀត បុគ្គលណា ខ្លួនឯង បរិភោគនូវវត្ថុដ៏ប្រសើរហើយ ឲ្យនូវវត្ថុមិនប្រសើរ ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា

ជាខ្មុំបម្រើនៃទាន ព្រោះដល់នូវភាវៈជាបុគ្គលថោកទាប ដែលមានការឱ្យរបស់ថោកទាបនោះជានិមិត្ត ។ បុគ្គលណា ខ្លួនឯងបរិភោគនូវវត្ថុបែបណា ឱ្យនូវវត្ថុបែបនោះឯង ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាសំឡាញ់នៃទាន ព្រោះដល់នូវភាពជាអ្នកស្មើគ្នា ដោយការលះបង់នូវភាវៈ នៃបុគ្គលជាអ្នកថោកទាប និងជាអ្នកខ្ពង់ខ្ពស់ ដែលមានការឱ្យរបស់ដែលស្មើគ្នានោះជានិមិត្ត ។ បុគ្គលណា បរិភោគនូវវត្ថុថោកទាប ដោយខ្លួនឯង ហើយឱ្យនូវវត្ថុដ៏ប្រណីត ដល់ពួកជនដទៃ, បុគ្គលនោះ ឈ្មោះថា ជាម្ចាស់នៃទាន ព្រោះដល់នូវភាពជាបុគ្គលប្រសើរ មានការឱ្យនូវវត្ថុប្រណីតនោះជានិមិត្ត ។ មិនមែនជាអ្នកប្រាសចាកតេជៈ ព្រោះសេចក្តីសម្រេចនៃតេជៈ ។ ទាយកណា តែងទៅ គឺ ធ្វើដំណើរទៅ រួមជាមួយគ្នា ហេតុនោះ ទាយកនោះ ឈ្មោះថា អ្នកទៅរួមគ្នា គឺធ្វើដំណើរទៅរួមគ្នា, ភាវៈនៃបុគ្គលអ្នកទៅរួមគ្នានោះ ឈ្មោះថា **សហព្យតា** គឺធ្វើដំណើរទៅរួមគ្នា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**សហភាវំ ឯកីភាវំ គតា**' ដូច្នេះ ។ មួយទៀត បទថា '**អសិតស្ស**' បានដល់ ជាអ្នកដែលគ្រឿងចងរឹត គឺតណ្ហា ចងរឹតមិនបាន" ។

(២៧) អដ្ឋកថាមាយសូត្រ ក្នុងសុតនិបាតថា "២ បទថា '**ទាយកោ ទានបតិ**' ប្រែថា ជាទាយកផង ជាម្ចាស់នៃទានផង ។

មែនពិត បុគ្គលណា ត្រូវគេបង្គាប់ ក៏ឱ្យវត្ថុដែលជារបស់ នៃបុគ្គលដទៃ, សូម្បីបុគ្គលនោះ ក៏ឈ្មោះថា ជាទាយក, តែមិនឈ្មោះថា ជាទានបតីទេ ព្រោះមិនមានឥស្សរៈ ក្នុងទាននោះ ។ ក៏មាឃមាណពនេះ តែងឱ្យនូវវត្ថុដែលជារបស់នៃខ្លួនតែប៉ុណ្ណោះ, ដោយហេតុនោះ ទើបមាឃមាណពនោះ ពោលថា 'បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គ ជាទាយក ជាទានបតី ដោយពិត' ដូច្នេះជាដើម ។ សេចក្តីក្នុងមាឃសូត្រនេះ មានតែប៉ុណ្ណោះ ។ ចំណែក ក្នុងទីដទៃទៀត នឹងពោល ដោយន័យជាដើមថា 'ជាអ្នក ត្រូវសេចក្តីកំណាញ់គ្របសង្កត់ ក្នុងចន្លោះ។ បានឈ្មោះថា ជាទាយក, ជាអ្នក ដែលសេចក្តីកំណាញ់គ្របសង្កត់មិនបាន ឈ្មោះថា ជាទានបតី' ដូច្នេះ ក៏គួរ" ។

បឋមន័យ ចប់ ។

(២៨) ន័យមួយទៀត ។ ឈ្មោះថា ទាន មាន ២ យ៉ាង ដោយអំណាច នៃធម្មទាន និង អាមិសទាន ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងតតិយវគ្គ នៃតតិយបណ្ណាសកៈ ក្នុងទុកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ ទាននេះ មាន ២ យ៉ាង ។ ទាន ២ យ៉ាង តើដូចម្តេចខ្លះ ?។ ទាន ២ យ៉ាងនេះ គឺ អាមិសទាន ១ ធម្មទាន ១ ។ ម្នាលភិក្ខុទាំងឡាយ ទាន មាន ២ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ យ៉ាងនេះ

ធម្មទាននុ៎ះ ជាទានប្រសើរជាង ” ។

ទានសូត្រ ចប់ ។

(២៩) អដ្ឋកថាទានសូត្រនោះ ថា “ទានវត្ថុ ដោយអំណាច នៃរបស់ដែលបុគ្គលគប្បីឲ្យ ឈ្មោះថា ទាន ។ ពាក្យនុ៎ះ ជាឈ្មោះ នៃទេយ្យធម៌ ។ មួយទៀត ចេតនាព្រមទាំងវត្ថុ ឈ្មោះថា ទាន ។ ពាក្យនុ៎ះ ជាឈ្មោះ នៃកិរិយាចរិច្ចាគនូវសម្បត្តិ ” ។

ជីកាទានសូត្រនោះ ថា “វត្ថុណា ដែលបុគ្គលឲ្យ ហេតុនោះ វត្ថុនោះ ឈ្មោះថា ទាន ។ ពាក្យនុ៎ះ ជាឈ្មោះ នៃទេយ្យធម៌ ។ មួយទៀត ឈ្មោះថាទាន ព្រោះជាគ្រឿងដែលបុគ្គលឲ្យ ។ ពាក្យនុ៎ះ ជាឈ្មោះ នៃចេតនាគ្រឿងបរិច្ចាគ ។ សូម្បីសេចក្តីទាំង ២ យ៉ាង នេះ លោកអធិប្បាយហើយ ក្នុងពាក្យថា ‘**ទាន**’ នេះ ព្រោះហេតុ នោះ ទើបលោកពោលពាក្យថា ‘**ទិយ្យនកវសេន ទានានិ**’ ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា ‘**ទិយ្យនកវសេន**’ បានដល់ ដោយអំណាច នៃវត្ថុដែលបុគ្គលគប្បីឲ្យ ” ។

(៣០) អដ្ឋកថាបញ្ចមវគ្គ តិកនិបាត ក្នុងឥតិវុត្តកៈថា “បទថា ‘**អាមិសទានំ**’ មានសេចក្តីថា បច្ច័យ ៤ ឈ្មោះថា អាមិសទាន ដោយអំណាចនៃវត្ថុដែលបុគ្គលគប្បីឲ្យ ។ មែនពិត បច្ច័យទាំង ៤ នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា ‘អាមិស’ ព្រោះជា

របស់ដែលគេគប្បីប៉ះពាល់ត្រូវ ដោយកិលេសមានតណ្ហាជាដើម ។ មួយទៀត ចេតនាជាគ្រឿងបរិច្ចាគនូវបច្ច័យទាំង ៤ នោះ ឈ្មោះថា អាមិសទាន ” ។

(៣១) ភាវៈនៃអាមិសទាននោះ ជាមង្គល មានប្រការដូច ជាបានពោលមកហើយនុ៎ះឯង ។ មួយទៀត អាមិសទាន ឈ្មោះថា ជាមង្គល ព្រោះជាហេតុបានចំពោះ នូវប្រយោជន៍សុខ ដោយពិត ។ ព្រោះថា បុគ្គលអ្នកប្រគេនបច្ច័យ ៤ រមែងបាននូវហិតសុខ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

(រឿងព្រះបាទនន្ទៈ)

ក្នុងអតីតកាល កុដុម្ពីក៍ម្នាក់ ជាអ្នកនៅក្នុងទីក្រុងពារាណសី ត្រាច់ទៅ ក្នុងព្រៃ បានឃើញសំពត់អនុវាត របស់ព្រះបច្ចេកពុទ្ធ លោកកំពុងធ្វើចីពរ មិនគ្រប់គ្រាន់ ទើបបានប្រគេននូវសំពត់ដណ្តប់ របស់ខ្លួន ។ កុដុម្ពីក៍នោះ បានទៅកើត ក្នុងភពតាវតឹង្ស ព្រោះកម្មនោះ សោយនូវទិព្វសម្បត្តិ ច្យុតចាកភពតាវតឹង្សនោះហើយ ក៏បានមកកើត ក្នុងត្រកូលនៃអាមាត្យ ក្នុងទីប្រមាណ ១ យោជន៍ អំពីក្រុងពារាណសី បានចំរើនពេញវ័យហើយ ក្នុងថ្ងៃនក្ខត្តឫក្ស បានពោលថា “បពិត្រអ្នកម្តាយ សូមអ្នកម្តាយឱ្យសំពត់សាដក ដល់ខ្ញុំ,

ខ្ញុំនឹងលែងនក្ខត្តឫក្ស "។ មាតានោះ បានឱ្យសំពត់ពណ៌ស, (ប៉ុន្តែ) កាលកូននោះ ពោលថា "សំពត់នេះសាច់មិនល្អទេ" ដូច្នេះ, ទើបបានឱ្យសំពត់ផ្សេងទៀត ។ កូននោះ ហាមនូវសំពត់នោះទៀត។ ម្តាយនោះ ពោលថា "ក្នុងផ្ទះ របស់យើង គ្មានសំពត់ល្អជាងនេះទេ" ។ កូននោះ ពោលថា "បពិត្រអ្នកម្តាយ ខ្ញុំនឹងទៅកន្លែងដែលបាន" ។ ម្តាយនោះ បានពោលថា "នែកូន ម្តាយប្រាថ្នាចង់ឱ្យកូនឯងបាននូវរាជសម្បត្តិក្នុងទីក្រុងពារាណសី ក្នុងថ្ងៃនេះទៀតផង" ។ កូននោះ ពោលថា "បពិត្រអ្នកម្តាយ ប្រពៃហើយ" ដូច្នេះ ថ្វាយបង្គំមាតាត្រូវនិយាមនៃបុណ្យជាស់គ្រឿនហើយ ក៏បានទៅកាន់ក្រុងពារាណសី ដេកដណ្តប់ (គ្រប) នូវអវយវៈ ព្រមទាំងក្បាល លើផ្នាំងសីលាដែលជាមង្គល ក្នុងឧទ្យាន ។ ក៏ថ្ងៃនោះ ជាថ្ងៃទី ៧ នៃព្រះរាជាក្រុងពារាណសីទ្រង់បានទិវង្គតទៅ។ ជនទាំងឡាយមានអាមាត្យជាដើម បានបូជាព្រះសរីរកិច្ច របស់ព្រះរាជាហើយ ទើបប្រឹក្សាគ្នាថា "ព្រះរាជាទ្រង់មានព្រះធីតាតែមួយព្រះអង្គប៉ុណ្ណោះ, គ្មានព្រះរាជឱរសទេ, រាជសម្បត្តិ ដែលប្រាសចាកព្រះរាជា នឹងតាំងនៅពុំបានឡើយ" ដូច្នេះហើយ កាលនឹងលែងនូវបុស្សរថ (រថមានពណ៌ស) ទៅ បានទឹមសេះសិន្ធព ៤ ដែលមានសម្បុរដូចជាផ្ការកោមុទ ហើយបានតាំងរាជកុក្កុធភ័ណ្ឌ ៥ ប្រការ លើរថ ស្រេចហើយ ក៏លែងរថទៅ ។

រថបានចេញទៅ តាមមាត់ទ្វារទិសខាងកើត ចូលទៅកាន់ឧទ្យាន ធ្វើ
ប្រទក្សិណកុមារហើយ ក៏បានត្រៀមនឹងកល់ ហើយឈប់នៅ ។
បុរោហិត បានបើកជាយសំពត់ដែលដណ្តប់ហើយ ត្រួតពិនិត្យមើល
ផ្ទៃនៃបាទជើង ពោលថា "កុមារនេះ សមគួរហើយ ដើម្បីគ្រប់គ្រង
រាជសម្បត្តិ" ដូច្នេះហើយ ឱ្យគេប្រគុំនូវដូរតន្ត្រី អស់វារៈ ៣ ដង ។
គ្រានោះ កុមារបានបើកមុខឡើងហើយ ពោលថា "បពិត្រលោក
ឱពុក តើមានហេតុអ្វី ?" ។ បុរោហិត ពោលថា "បពិត្រលោក
ម្ចាស់ រាជសម្បត្តិ រមែងសម្រេច ដល់លោកម្ចាស់" ។ កុមារ
សួរថា "ចុះព្រះរាជា របស់អ្នកទាំងឡាយ ស្តេចយាងទៅណា ?" ។
បុរោហិត ពោលថា "បពិត្រលោកម្ចាស់ ព្រះអង្គទ្រង់ស្តេចទិវង្គត
ទៅហើយ" ។ កុមារសួរថា "កន្លងទៅបានប៉ុន្មានថ្ងៃហើយ ?" ។
បុរោហិត ពោលថា "ថ្ងៃនេះ ជាថ្ងៃទី ៧" ។ កុមារបានសួរថា
"ព្រះរាជឱរសក្តី ព្រះរាជធីតាក្តី មិនមានទេឬ ?" ។ បុរោហិត
ពោលថា "បពិត្រលោកម្ចាស់ មានតែព្រះរាជធីតា (តែ) ព្រះរាជ
ឱរសមិនមានទេ" ។ កុមារ ពោលថា "បើដូច្នោះ ខ្ញុំនឹងគ្រប់គ្រង
នូវរាជសម្បត្តិ" ។ ពួកអាមាត្យទាំងនោះ នាំគ្នាធ្វើមណ្ឌបសម្រាប់
អភិសេក ក្នុងពេលនោះភ្លាម ហើយក៏បានអភិសេក ក្នុងមណ្ឌបនោះ
រួចហើយ បានបង្ហោនសំពត់ដែលមានតម្លៃ ១ ពាន់ ចូលទៅថ្វាយ ។

ព្រះរាជាអង្គនោះ មានព្រះរាជឱង្ការថា “សំពត់នេះ មានសាច់មិនល្អ, អ្នកទាំងឡាយ ចូរនាំយកកន្ទីទឹកមាសមក, ខ្ញុំនឹងបាននូវសំពត់” ដូច្នេះហើយ ស្តេចក្រោកឡើង ទ្រង់យកព្រះហស្តក្បង់ទឹកហើយ ទ្រង់សាចទៅទិសខាងកើត ។ ដើមកប្បព្រឹក្ស ៨ ដើម បានទំលាយផែនដីដ៏ក្រាស ជុសឡើងហើយ ក្នុងពេលនោះភ្លាម ។ ដើមកប្បព្រឹក្ស ៨ ដើម ជុសឡើងហើយ ត្រង់ទិសទក្សិណ, ៨ ដើម ជុសឡើងហើយ ត្រង់ទិសបច្ឆិម, ៨ ដើម ជុសឡើងហើយ ត្រង់ទិសឧត្តរ ដោយឧបាយនេះ ។ ដើមកប្បព្រឹកទាំងអស់ មាន ៣២ ដើម ជុះឡើងហើយ ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះ ទ្រង់ស្លៀកសំពត់ទិព្វមួយ ទ្រង់បានដណ្តប់សំពត់ទិព្វមួយ ទ្រង់ត្រាស់បញ្ជាឱ្យពួកអាមាត្យ វាយស្គរជ័យឃោសនា ក្នុងរដ្ឋធានី របស់ព្រះបាទនន្ទរាជថា “ស្ត្រីទាំងឡាយ កុំត្បាញសូត្រឡើយ” ហើយទ្រង់ត្រាស់បញ្ជាឱ្យលើកឆត្រឡើង ហើយស្តេចឡើងលើកជំរីដ៏ប្រសើរ ទ្រង់យាងចូលទៅព្រះនគរ ស្តេចឡើងលើប្រាសាទ ទ្រង់សោយនូវមហាសម្បត្តិ គ្រប់គ្រងរដ្ឋធានី របស់ព្រះអង្គទាំងអស់ ប្រៀបដូចជាឧត្តរកុរុទ្វីប ទ្រង់បានព្រះរាជទានសំពត់ទិព្វទាំងឡាយ ដល់មនុស្សទាំងឡាយ ដែលបានមកហើយៗ ក្រោយមក ទ្រង់បានសាងព្រះផ្នួសព្រមទាំងព្រះទេវី នៅក្នុងព្រះឧទ្យាន ញុំាងឈានឱ្យកើតឡើង

ហើយ មានឈានមិនសាបសូន្យហើយ បានទៅកើតក្នុងព្រហ្មលោក។ ក្នុងពេលនេះ ព្រះរាជាអង្គនោះ បានកើតជាព្រះមហាកស្សបត្ថេរ, ព្រះទេវី បានមកកើតជានាងភទ្ទកាបិលានី ដូច្នេះឯង ។

រឿង ព្រះពាទន្ធរាជ មកក្នុងអដ្ឋកថាសំសារមោចកបេតវត្ថុ ។

(រឿងស្ត្រីអ្នកក្រីក្រ)

(៣២) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ស្ត្រីអ្នកក្រីក្រម្នាក់ ឃើញស្ត្រីទាំងឡាយ ដែលបរិបូណ៌ដោយបុណ្យ ស្លៀកសំពត់ដែលជ្រលក់ដោយផ្កាដកគាំ កំពុងលេង ក្នុងថ្ងៃមហោស្រព ជាអ្នកប្រាថ្នានឹងស្លៀកសំពត់ដូច្នោះ ហើយលេង (នឹងគេ) បានប្រាប់ដល់មាតាបិតា, កាលបើមាតាបិតា ពោលថា "នែកូនស្រី ពួកយើងជាអ្នកក្រីក្រ, សំពត់បែបនេះ នឹងមានដល់ពួកយើង អំពីណាមក?" ដូច្នេះ, ទើបពោលថា "បើដូច្នោះ នាងខ្ញុំនឹងធ្វើនូវការស៊ីឈ្នួល ក្នុងត្រកូលអ្នកស្តុកស្តម្ភមួយ, អ្នកទាំងនោះ ជឹងនូវគុណ របស់ពួកយើងហើយ ក៏នឹងឱ្យ" ដូច្នេះ ហើយបានចូលទៅរកត្រកូលមួយ ពោលថា "នាងខ្ញុំនឹងធ្វើ នូវការស៊ីឈ្នួល ព្រោះសំពត់ក្រហម ដែលជ្រលក់ដោយផ្កាដកគាំ" ។ ជនក្នុងត្រកូលទាំងនោះ ពោលថា "កាលបើនាងធ្វើការងារ រហូត ៣ ឆ្នាំហើយ, ពួកយើងនឹងឱ្យ ដល់នាង" ។

ស្ត្រីអ្នកក្រីក្រនោះ ទទួលព្រមថា "ល្អហើយ" ហើយបានធ្វើការងារ។ កាលបើ ៣ ឆ្នាំ មិនទាន់គ្រប់បរិបូណ៌ហើយនុ៎ះឯង, ពួកជនទាំងនោះ ដឹងនូវគុណ របស់នាងហើយ ក៏បានឱ្យហើយ នូវសំពត់សូម្បីឯទៀត ព្រមទាំងសំពត់ក្រហម ដែលជ្រលក់ដោយផ្កាកុសុម្ភៈ ដែលមានសាច់ក្រាស ដល់ស្ត្រីនោះ។ ស្ត្រីអ្នកក្រីក្រនោះ បានទៅហើយ ដាក់នូវសំពត់ពណ៌ក្រហម នៅក្បែរមាត់ស្ទឹង ហើយចុះងូតទឹក។ ក្នុងខណៈនោះ សាវ័ករបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ មួយអង្គ មានចីពរត្រូវចោរលួចយកទៅ ស្លៀកនិងគ្រងនូវមែកឈើដែលកាច់មកហើយ បានមកដល់ប្រទេសនោះ។ នាងគិតថា "ភិក្ខុរូបនេះ នឹងមានចីពរត្រូវចោរលួចយកហើយ, សំពត់សំរាប់ស្លៀករបស់អាត្មាអញ ជារបស់ដែលរកបានដោយកម្រ ព្រោះអាត្មាអញមិនបានឱ្យហើយក្នុងកាលមុន" ដូច្នេះហើយ ក៏បានបែកសំពត់នោះ ត្រង់ពាក់កណ្តាល បានប្រគេនសំពត់ មួយកំណាត់ ដល់ព្រះថេរៈនោះ។ ព្រះថេរៈឈរនៅ ក្នុងទីបិទបាំង ចោលមែកឈើដែលកាច់ហើយ ក៏ស្លៀកកំណាត់សំពត់នោះ មួយចម្រៀក គ្រងមួយចម្រៀក និមន្តចេញទៅហើយ។ គ្រានោះ សរីរៈទាំងអស់ របស់ព្រះថេរៈ បានមានវណ្ណៈតែមួយ ដូចជាព្រះអាទិត្យដែលខ្ចី ព្រោះអានុភាពនៃសំពត់។ នាងបានឃើញព្រះថេរៈនោះហើយ ក៏គិតថា "ជាដំបូង ព្រះគុណម្ចាស់

របស់អាត្មាអញ មិនស្រស់ទេ (តែ) ឥឡូវនេះ រមែងរុងរឿង ដូចជាព្រះអាទិត្យដែលខ្ចីៗ, អាត្មាអញ នឹងប្រគេននូវសំពត់នេះ ដល់ព្រះគុណម្ចាស់នុ៉ះឯង" ដូច្នេះហើយ ក៏បានប្រគេន នូវចំណែកទី ២ ហើយ បានធ្វើសេចក្តីប្រាថ្នាថា "បពិត្រព្រះគុណម្ចាស់ នាងខ្ញុំកាលត្រាច់រង្គាត់ទៅ ក្នុងភព គប្បីជាអ្នកទ្រទ្រង់នូវរូបដ៏ស្រស់, បុរសឯណាមួយ បានឃើញនាងខ្ញុំហើយ មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាពរបស់ខ្លួនបានឡើយ, ស្ត្រីឯទៀតៗ ឈ្មោះថា ជាអ្នកមានរូបល្អស្អាតជាងនាងខ្ញុំ កុំបីមានឡើយ"ៗ ឯព្រះថេរៈបានធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ៗ នាងកាលអន្ទោលទៅកាន់ទេវលោកច្យុតអំពីទេវលោកនោះហើយ បានមកកើតជាធីតា របស់សេដ្ឋីអ្នកមានភោគសម្បត្តិ ៨០ កោដិ ឈ្មោះថាតិរិដិវច្ឆៈ ក្នុងអរិដ្ឋបុរីក្នុងសិវិរដ្ឋ ៗ នាងធីតានោះ ជាអ្នកទ្រទ្រង់រូបដ៏ស្រស់ ដល់នូវភាពជាអ្នកល្អប្រសើរលើស ដោយសេចក្តីសោភា ញ្ជាំងបុរសអ្នកដែលឃើញខ្លួននាង ឲ្យវង្វេងវង្វន់ និងមិនឲ្យបុរសនោះ តាំងសតិស្មារតីបានឡើយ ៗ ព្រោះហេតុនោះ ជនទាំងឡាយ ទើបបានតាំងឈ្មោះឲ្យនាងថា "នាងឧម្មាទន្តី"ៗ ក្នុងពេលដែលនាងមានអាយុ ១៦ ឆ្នាំ នាងមានពណ៌សម្បុរល្អកន្លងពណ៌សម្បុរនៃមនុស្ស ប្រៀបដូចជានាងទេពអប្សរ ៗ ពួកបុថុជ្ជនណា ៗ ឃើញនូវនាងឧម្មាទន្តីនោះ,

ពួកបុថុជ្ជននោះៗ មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាវៈនៃខ្លួនបាន ជាអ្នកស្រវឹងហើយ ដោយសេចក្តីស្រវឹងព្រោះកិលេស ដូចជាស្រវឹងព្រោះគ្រឿងស្រវឹង មិនអាច ដើម្បីផ្គង់សតិឲ្យស្ថិតនៅបានឡើយ ។ លោកសេដ្ឋីតិវិជិវច្ឆៈ បានចូលទៅគាល់ព្រះបាទសិវិរាជហើយ ក្រាបទូលថា " បពិត្រព្រះសម្មតិទេព ឥត្ថីរត្ន កើតឡើងហើយ ក្នុងផ្ទះនៃទូលព្រះបង្គំ ជាអ្នកសមគួរ ដល់ព្រះអង្គតែប៉ុណ្ណោះ, សូមព្រះអង្គទ្រង់បញ្ជូនអ្នកទាយនូវលក្ខណៈទៅ ហើយទ្រង់ឲ្យត្រួតពិនិត្យមើលនូវស្ត្រីរត្ននោះ " ។ ព្រះរាជា ទ្រង់បានបញ្ជូនពួកព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទាំងនោះ ទៅហើយ ត្រូវសេដ្ឋីធ្វើសក្ការៈនិងសេចក្តីរាក់ទាក់ហើយ បរិភោគ ។ ក្នុងខណៈនោះ នាងខុម្មាទន្តី ទៅកាន់សំណាក់របស់ព្រាហ្មណ៍ទាំងនោះ ។ ព្រាហ្មណ៍ទាំងនោះ បានឃើញនាងហើយ ក៏មិនអាចដើម្បីនឹងតាំងសតិស្មារតីនៅបាន ជាអ្នកវង្វែងដោយសេចក្តីវង្វែង ព្រោះកិលេស មិនដឹងនូវការបរិភោគដែលខុសប្រក្រតី របស់ខ្លួន, ពួកខ្លះយកពំនូតបាយ ដាក់លើក្បាល ដោយគិតថា " នឹងបរិភោគ " ដូច្នេះ, ពួកខ្លះ ធាក់ជញ្ជាំង, ពួកខ្លះ ញាត់ពំនូតបាយ ក្នុងចន្លោះរន្ធក្លៀក, ពួកព្រាហ្មណ៍ទាំងអស់ បានជាអ្នកឆ្កួតវង្វែងហើយ ។ នាងខុម្មាទន្តី បានឃើញពួកព្រាហ្មណ៍ទាំងនោះហើយ ក៏បានឲ្យគេចណ្តេញចេញទៅ ដោយពាក្យថា " បានឮថា ពួក

ព្រាហ្មណ៍ទាំងនេះ នឹងពិចារណានូវលក្ខណៈ របស់ខ្ញុំ, ចូរអ្នកទាំងឡាយ ចាប់ព្រាហ្មណ៍ទាំងនេះ ត្រង់កហើយ បណ្តេញចេញទៅ" ។ ព្រាហ្មណ៍ទាំងនោះ ជាអ្នកខ្មាសអៀនហើយ ក្រោធខឹង ចំពោះនាងក្រាបទូលថា "បពិត្រព្រះសម្មតិទេព ស្ត្រីនោះ ជាអ្នកកាឡកណ្ណីមិនសមគួរដល់ព្រះអង្គឡើយ" ។ ចំណែកព្រះរាជា មិនបានត្រាស់បញ្ជាឲ្យនាំយកនាងឧម្មាទន្តីនោះមកទេ ព្រោះទ្រង់សម្គាល់ថា "បានញ្ជថា នាងជាស្រីកាឡកណ្ណី" ។ ឯនាងឧម្មាទន្តីនោះ ស្តាប់រឿងនោះហើយ បានចងអាឃាត ចំពោះព្រះរាជាអង្គនោះថា "រឿងនោះលើកទុកសិនចុះ, បើអាត្មាអញចូលគាល់ព្រះរាជអង្គនោះ ក៏គង់តែដឹង" ។ គ្រានោះ សេដ្ឋីបានលើកនាងឲ្យ ដល់សេនាបតី ឈ្មោះអភិបារកៈ ជាសំឡាញ់របស់ព្រះរាជា ។ នាងបានជាទីស្រឡាញ់ពេញចិត្ត របស់សេនាបតីនោះ ។ ក្រោយមក ថ្ងៃមួយ សេនាបតីកាលទៅកាន់ទីរក្សា របស់ខ្លួន បានពោលថា "នែនាងដ៏ចំរើនថ្ងៃនេះ ជាថ្ងៃមហោស្រព ពេញបូណ៌មី ខែកត្តិក, ព្រះរាជានឹងទ្រង់ធ្វើប្រទក្សិណព្រះនគរ ទ្រង់ស្តេចយាងមកកាន់ទ្វារផ្ទះនេះ ជាបឋម, ចូរនាងកុំបង្ហាញខ្លួន ដល់ព្រះរាជាអង្គនោះឡើយ, ព្រោះព្រះរាជាអង្គនោះ ឃើញប្ជូនហើយ ក៏នឹងមិនអាច ដើម្បីទ្រង់តាំងព្រះសតិស្មារតីឲ្យស្ថិតនៅបាន" ដូច្នេះហើយ ទើបគេចចេញទៅ ។

ចំណែកព្រះរាជា, កាលបើព្រះអាទិត្យអស្តង្គតទៅហើយ, កាលបើព្រះចន្ទពេញវង់ រះឡើងហើយ, ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយយសបារមីដ៏ធំ ទ្រង់ស្តេចយាងទៅកាន់មាត់ទ្វារផ្ទះ របស់សេនាបតី ជាបឋមភ្លាម ទ្រង់បានទតព្រះនេត្រឃើញនាងខុម្មាទន្តីឈរនៅក្បែរបង្អួច ទ្រង់ជាអ្នកឆ្កួតវង្វេង ដោយសេចក្តីឆ្កួតវង្វេង ព្រោះកិលេសមិនអាចដើម្បីនឹងទ្រង់តាំងព្រះសតិឲ្យស្ថិតនៅបាន មិនទ្រង់ញុាំងព្រះទ័យ ក្នុងការធ្វើប្រទក្សិណព្រះនគរ ឲ្យកើតឡើង ទ្រង់ស្តេចត្រឡប់អំពីទីនោះ ហើយស្តេចឡើងកាន់ប្រាសាទ ទ្រង់ព្រះបន្ទំ រវើរវាយ ប្រារព្ធនាងខុម្មាទន្តី ដោយប្រការផ្សេងៗ ។ សេនាបតី ដឹងរឿងនោះហើយ ក៏គិតថា “ព្រះរាជាអង្គនេះ ទ្រង់មានព្រះទ័យប្រតិព័ទ្ធ ចំពោះនាងខុម្មាទន្តី កាលទ្រង់មិនបាន ក៏នឹងទ្រង់ទិវង្គត, ការដែលអាត្មាអញ ថ្វាយជីវិត ដល់ព្រះអង្គ ទើបសមគួរ” ដូច្នេះហើយ បានបង្គាប់ខុបដ្ឋាកម្នាក់ ថា “អ្នកចូរទៅ, រុក្ខចេតិយដែលមានប្រហោង ក្នុងទីឯណោះមាន, ចូរអ្នកកុំឲ្យអ្នកឯណាមួយដឹង ហើយអង្គុយ ពួនខាងក្នុងនៃដើមឈើ, ខ្ញុំទៅក្នុងទីនោះហើយ ក៏នឹងធ្វើនូវពលីកម្ម ហើយពោល យ៉ាងនេះ, គ្រានោះ អ្នកចូរពោលយ៉ាងដូច្នេះ”។ ខុបដ្ឋាកនោះ ពោល ថា “ប្រពៃណាស់” ហើយក៏បានទៅ ក្នុងទីនោះ ។ ចំណែកសេនាបតី លុះស្អែកឡើង ក៏បាន

ទៅក្នុងទីនោះ ធ្វើពលីកម្មស្រេចហើយ ក៏ពោលថា "បពិត្រទេវតា ព្រះរាជារបស់ពួកយើងខ្ញុំ, កាលបើមហោស្រព កំពុងតែប្រព្រឹត្តទៅ, មិនទ្រង់ព្រះក្រសាល ស្តេចយាងចូលព្រះក្រឡាបន្ទំដ៏មានសិរីទ្រង់បន្ទំ រើរាយហើយ, ព្រះអង្គទ្រង់រើរាយ ព្រោះអាស្រ័យរឿងអ្វី ?"។ ឧបដ្ឋាកនោះ ប្រែសំឡេងហើយ ពោលថា "ម្នាលសេនាបតី ព្រះរាជារបស់ពួកអ្នក ទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះនាងឧម្មាទន្តី ដែលជាភរិយារបស់លោក, បើព្រះអង្គនឹងបាននាងឧម្មាទន្តីនោះ នឹងមិនទ្រង់ចូលទិវង្គត, បើនឹងមិនបានទេ ក៏នឹងទ្រង់ចូលទិវង្គត, ព្រោះហេតុនោះ ចូរអ្នកថ្វាយនាងឧម្មាទន្តីនោះ ដល់ព្រះរាជាអង្គនោះ"។ សេនាបតី ពោលថា "ល្អណាស់" ហើយ បានចូលទៅគាល់ព្រះរាជា ក្រាបទូលរឿងនោះ ហើយក្រាបទូលថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ សូមថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គ"។ ព្រះរាជាទ្រង់ត្រាស់សួរ ថា "នែអភិបារកៈ អ្នកជាសំឡាញ់ សូម្បីពួកយក្ស រមែងដឹងនូវភាវៈនៃខ្ញុំជាអ្នករើរាយ ព្រោះមានចិត្តប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តីឬ ?"។ សេនាបតី ក្រាបទូលថា "បពិត្រព្រះសម្មតិទេព ពិតមែនហើយ"។ ព្រះរាជាទ្រង់ព្រះតម្រិះ ថា "បានឮថា ភាវៈនៃអាត្មាអញជាអ្នកលាមក ប្រជាលោកគ្រប់គ្នា បានដឹងអស់ហើយ" ដូច្នេះ ទ្រង់អៀនខ្មាសព្រះទ័យ

ទ្រង់តាំងនៅហើយ ក្នុងធម៌ ទ្រង់បន្ទោបង់ហើយនូវព្រះទ័យប្រដិព័ទ្ធ ចំពោះនាងខុម្មាទន្តី ទ្រង់មិនបានទទួលយកនូវនាងខុម្មាទន្តីនោះទេ ។ រឿងស្ត្រីក្រីក្រ មកក្នុងអដ្ឋកថាខុម្មាទន្តីជាតក ក្នុងបញ្ញាសនិបាត ។

ឯរឿងមានជាអាទិ៍យ៉ាងនេះ គឺ រឿងចូឡេកសាដកព្រាហ្មណ៍ ក្នុងបាបវគ្គ នៃធម្មបទ រឿងមហោកសាកដព្រាហ្មណ៍ ក្នុងអដ្ឋកថា-ឯកនិបាត អង្គុត្តរនិកាយ ក៏គប្បីរួមបញ្ចូល ក្នុងចីវរទាន ។

(រឿងព្រះទេវីព្រះនាមគោបាលមាតា)

(៣៣) ក្នុងចន្លោះផ្លូវទៅកាន់នគរខុជ្ជេនី មាននិគមមួយឈ្មោះតេលនាឡី ។ ក្នុងនិគមនោះ មានធីតារបស់សេដ្ឋី ២ នាក់, ធីតាម្នាក់ជាអ្នកក្រីក្រ ដោយកាលកន្លងទៅនៃមាតាបិតា អាស្រ័យនូវស្រែមេនំ ចិញ្ចឹមជីវិត ជាអ្នកមានអត្តភាពស្អាតស្រស់ មានសក់វែង ជាងពួកស្ត្រីឯទៀត, ធីតាម្នាក់ជាអ្នកស្កុកស្កម្ភ (តែ) មិនមានសក់ ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរ ព្រមទាំងភិក្ខុ ៧ រូប មានប្រាថ្នានឹងក្រាបទូលនូវការកើតឡើង នៃព្រះពុទ្ធដល់ព្រះរាជាទ្រង់ព្រះនាមចណ្ឌប្បជ្ជោត ទើបនិមន្តទៅ កាន់ក្រុងខុជ្ជេនី ដល់និគមនោះហើយ ក៏ចូលទៅបិណ្ឌបាត ក្នុងនិគមនោះ (តែ) ឥតបានវត្ថុអ្វីឡើយ ។ សេដ្ឋីធីតា ដែលមានសក់វែង ដឹងរឿងនោះ

ហើយ ក៏បញ្ជូនស្រីមេនំទៅ ដោយប្រាប់ថា "ចូរនាងនិមន្តព្រះថេរៈទាំងឡាយហើយ ឲ្យគង់ក្នុងផ្ទះ"។ ស្រីមេនំនោះ បានធ្វើហើយយ៉ាងដូច្នោះ។ សេដ្ឋីធីតា បានចូលទៅកាន់បន្ទប់ហើយ ឲ្យស្រីមេនំកាត់សក់របស់ខ្លួន បញ្ជូនទៅហើយ ដោយប្រាប់ថា "នែនាង ចូរនាងឲ្យសក់ទាំងនេះ ដល់សេដ្ឋីធីតា ដែលមិនមានសក់ឈ្មោះនុ៎ះ, ធីតារបស់សេដ្ឋីនោះ ឲ្យនូវវត្ថុអ្វី, ចូរនាំយកវត្ថុនោះមក, ពួកយើងនឹងប្រគេនបិណ្ឌបាត ដល់ព្រះគុណម្ចាស់ទាំងឡាយ ដោយវត្ថុនោះ"។ នាង បានធ្វើ យ៉ាងដូច្នោះហើយ បានទទួលយកទ្រព្យ ៨ កហាបណៈមកឲ្យហើយ ដល់សេដ្ឋីធីតាដែលមានសក់។ សេដ្ឋីធីតានោះ បានធ្វើបិណ្ឌបាតមួយ។ ឲ្យទៅជាមួយៗកហាបណៈ ហើយញុំាងបុគ្គលឲ្យប្រគេនហើយ ដល់ព្រះថេរៈទាំងឡាយ ខ្លួនឯងនៅ ក្នុងបន្ទប់។ ព្រះមហាកច្ចាយនត្ថេរ ដឹងហេតុការណ៍នោះហើយ បានឲ្យបុគ្គលទៅហៅសេដ្ឋីធីតានោះមកហើយ។ សេដ្ឋីធីតានោះ បានមកហើយ ព្រោះសេចក្តីគោរព ចំពោះព្រះថេរៈ ថ្វាយបង្គំព្រះថេរៈទាំងឡាយហើយ ក៏បានញុំាងសទ្ធាជ្រះថ្លាដ៏មានកម្លាំង ឲ្យកើតឡើងហើយ។ ឈ្មោះថា ទាន ដែលនាងប្រគេនហើយ ក្នុងខេត្តដ៏ល្អ រមែងឲ្យនូវវិបាក ក្នុងបច្ចុប្បន្នទាន់ភ្នែក ព្រោះហេតុនោះ សក់ទាំងឡាយ របស់នាង បានដុះឡើងវិញហើយ ក្នុងការៈតាមប្រក្រតីភ្លាម ព្រមជាមួយ

គ្នានឹងការថ្វាយបង្គំព្រះថេរៈ ។ ព្រះថេរៈទាំងឡាយ ទទួលចិណ្ឌបាត
ហើយ, កាលសេដ្ឋីធីតានោះ ឃើញនុ៎ះឯង, ក៏ហោះឡើងទៅកាន់
អាកាសវេហាស៍ បានចុះក្នុងឧទ្យានឈ្មោះកាញ្ចនវន ហើយធ្វើនូវ
ភត្តកិច្ច ។ បុគ្គលអ្នករក្សាឧទ្យាន ឃើញព្រះថេរៈទាំងឡាយហើយ
ក៏បានក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជា ស្តេចយាងទៅកាន់ព្រះ
ឧទ្យាន ទ្រង់ទតព្រះនេត្រឃើញព្រះថេរៈទាំងឡាយហើយ ទ្រង់បាន
ត្រាស់សួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ក្នុងថ្ងៃនេះ ព្រះគុណ
ម្ចាស់ទាំងឡាយ បានហើយនូវកិច្ចា ក្នុងទីឯណា ?" ដូច្នេះហើយ
ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទ្រង់ស្តេចយាងទៅព្រះដំណាក់
ទ្រង់ត្រាស់ឱ្យនាំសេដ្ឋីធីតានោះមក ក្នុងថ្ងៃនោះឯង ហើយទ្រង់បាន
អភិសេក(នាង) ជាព្រះអគ្គមហេសី ។ ក្នុងកាលក្រោយមក ព្រះ
នាង ទ្រង់បានប្រសូតព្រះរាជបុត្រ បានយកឈ្មោះ របស់សេដ្ឋីដែល
ជាអយ្យកា របស់ព្រះរាជឱរស ថ្វាយព្រះនាមថា "**គោបាល**"
(ចំណែកព្រះនាង) ប្រាកដព្រះនាមថា "**គោបាលមាតាទេវី**"
ដោយអំណាចព្រះនាម របស់ព្រះរាជឱរស ទ្រង់ជ្រះថ្លាហើយយ៉ាង
ក្រៃលែង ចំពោះព្រះថេរៈ ទ្រង់បានឱ្យបុគ្គលកសាងព្រះវិហារ ថ្វាយ
ព្រះថេរៈហើយ ក្នុងព្រះឧទ្យានឈ្មោះកាញ្ចនវន ដូច្នេះឯង ។
រឿងព្រះនាងគោបាលទេវី មកក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ។

(រឿងព្រះនាងមល្លិកាទេវី)

(៣៤) ក្នុងក្រុងសាវត្ថី មានធីតារបស់នាយមាលាការ ដែលជាចម្បងជាងគេម្នាក់ ជាស្ត្រីមានរូបឆោមល្អប្រសើរជាច់គេ ជាអ្នកមានបុណ្យច្រើន មានអាយុ ១៦ ឆ្នាំ ។ ថ្ងៃមួយ នាងធីតានោះបានដាក់នំកុម្មាស ៣ ដុំ ក្នុងកញ្ជើផ្កាឈើ ហើយដើរទៅកាន់សួនច្បារ ឃើញព្រះសាស្តា ព្រមទាំងព្រះសង្ឃ កំពុងតែស្តេចយាងទៅកាន់ទីក្រុង ដើម្បីទ្រង់បិណ្ឌបាត ក៏មានចិត្តត្រេកអរ ហើយបានដាក់នំទាំងនោះ ក្នុងបាត្រនៃព្រះសាស្តា ថ្វាយបង្គំហើយ ក៏ញុំាងចីតិប្រារព្ធនូវព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើងហើយ បានឈរនៅ ក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា កាលទ្រង់ទតព្រះនេត្រមើលនាងធីតានោះ ទ្រង់ធ្វើនូវការញញឹម ត្រូវព្រះអានន្ទត្ថេរ ក្រាបទូលសួរនូវហេតុនៃការទ្រង់ញញឹម ទើបទ្រង់ត្រាស់ថា "ម្នាលអានន្ទ នាងកុមារិកានេះនឹងបានជាព្រះអគ្គមហេសី របស់ព្រះរាជាព្រះនាមកោសល ក្នុងថ្ងៃនេះឯង ព្រោះផលនៃការប្រគេននំកុម្មាស" ដូច្នេះហើយ ទើបស្តេចយាងគេចចេញទៅ ។ ឯនាងធីតានោះ ទៅកាន់សួនច្បារហើយ ច្រៀងបណ្តើរកាច់ផ្កាបណ្តើរ ។ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់ព្រះនាមកោសល ទ្រង់ច្បាំងជាមួយនឹងព្រះបាទអជាតសត្រូវ ទ្រង់ចរាជ័យហើយ ស្តេចគេចចេញ ទ្រង់គង់សេះយាងទៅ ទ្រង់

ព្រះសណ្តាប់នូវសំឡេងច្រៀង របស់នាងធីតានោះ ទ្រង់មានព្រះទ័យ ប្រតិព័ទ្ធហើយ ទ្រង់ស្តេចយាងទៅកាន់សួនច្បារ ទ្រង់ជ្រាបថានាង ជាអ្នកមិនមានស្វាមី ទើបទ្រង់ឲ្យនាងអង្គុយ លើខ្នងសេះ មានពួក ពលចោមរោមហើយ ស្តេចយាងចូលទៅកាន់ព្រះនគរ ទ្រង់បាន បញ្ជូននាងទៅកាន់ផ្ទះនៃត្រកូល ក្នុងពេលល្ងាច ទ្រង់បានត្រាស់ឲ្យនាំ មកអំពីទីនោះ ដោយសក្តារៈដ៏ច្រើន ទ្រង់អភិសេក លើគំនរនៃ រតនៈ ទ្រង់បានធ្វើហើយ ជាព្រះអគ្គមហេសី ។ ព្រះនាង ទ្រង់បាន ជាទីស្រឡាញ់ ជាទីពេញព្រះទ័យ នៃព្រះរាជា ទ្រង់បានជាទីស្និទ្ធ ស្នាល សូម្បីនៃអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ទើបទ្រង់បាន ប្រាកដ (ព្រះនាម) ថា "ព្រះនាងមល្លិកាទេវី" ។

រឿង ព្រះនាងមល្លិកាទេវី មកក្នុងអដ្ឋកថាកុម្មាសបិណ្ឌិយជាតក ក្នុងសត្តកនិបាត ។

រឿង ២ ក្នុងសត្តកនិបាតន៉ុះឯង គឺ រឿងព្រះរាជាប្រគេន នំកុម្មាស រឿងព្រះទេវីដែលទ្រង់ប្រគេនភិក្ខា (និង) រឿងមាន ជាអាទិ៍យ៉ាងនេះ គឺ រឿងមហាទុគ្គតសេដ្ឋី ២ រឿង ក្នុងអដ្ឋកថា កុណ្ឌកបូវជាតក ក្នុងឯកាទសមវគ្គ នៃឯកនិបាត ក៏គប្បីប្រមូល យកមកបញ្ជូល ក្នុងបិណ្ឌបាតទាន ។

(រឿងនន្ទិយឧបាសក)

(៣៥) ក្នុងក្រុងពារាណសី មានឧបាសកម្នាក់ ឈ្មោះនន្ទិយៈ ជាអ្នកមានសទ្ធាជ្រះថ្លាហើយ ។ ឧបាសកនោះ ស្តាប់អានិសង្សកថា នៃអារាមទាន របស់ព្រះសាស្តាហើយ ញុំាងបុគ្គលឲ្យកសាងសាលា មានមុខ ៤ ប្រដាប់ប្រដាដោយ ៤ បន្ទប់ ក្បែរមហាវិហារ ក្នុងព្រៃឥសិបតនៈ ឲ្យតាំងនូវវត្ថុទាំងឡាយ មានគ្រែនិងកៅអីជាដើម កាលនឹងវេរប្រគេន នូវទីលំនៅនោះ បានប្រគេនភោជនទាន ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ស្រោចទឹកទក្ខិណោទក លើព្រះហស្តនៃព្រះសាស្តា វេរប្រគេនហើយ ។ ប្រាសាទទិព្វ បណ្តោយនិងទទឹង ១២ យោជន៍ កំពស់ ១០០ យោជន៍ សម្រេចដោយរតនៈ ៧ ប្រការ សម្បូរដោយពពួកនារី បានកើតឡើងហើយ ក្នុងកពតាវត្តីង្ស ព្រមជាមួយគ្នានឹងកិរិយាស្រោចទឹកទក្ខិណោទក លើព្រះហស្ត របស់ព្រះសាស្តានុ៎ះឯង ។ ក្រោយមក ថ្ងៃមួយ ព្រះមហាមោគ្គល្លានត្ថេរ និមន្តត្រាច់ទៅទេវលោក ឃើញប្រាសាទនោះហើយ ក៏ត្រឡប់មកវិញ បានក្រាបទូល ដល់ព្រះសាស្តា ។ ចំណែកនន្ទិយឧបាសក ស្តាប់នូវការកើតឡើងនៃប្រាសាទ ដើម្បីខ្លួនទើបធ្វើបុណ្យទាំងឡាយ មានទានជាដើម ដោយប្រមាណ យ៉ាងក្រៃលែង ក្នុងពេលអស់អាយុ ក៏បានទៅកើត ក្នុងប្រាសាទនោះឯង ។

រឿងនន្ទិយៈឧបាសក មកក្នុងអដ្ឋកថាបិយវគ្គ នៃធម្មបទ និង អដ្ឋកថាវេតីវិមាន ក្នុងវិមានវត្ថុ ។

រឿងកុដុម្ពីក៍ ឈ្មោះអចរាជិត អ្នកកសាងព្រះគន្ធកុដិ ជើម្បី ព្រះពុទ្ធទ្រង់ព្រះនាមវិបស្សី ក្នុងអដ្ឋកថាព្រាហ្មណវគ្គ នៃធម្មបទ រឿងគហបតីម្នាក់ អ្នកកសាងបណ្ណសាលាប្រគេន ដល់ភិក្ខុអ្នកនៅ ក្នុងព្រៃជាវគ្គ ក្នុងអដ្ឋកថាមហាសុទស្សនសូត្រ និង សូម្បីរឿងដទៃ ទៀតក្រៅអំពីរឿងនោះ ក៏គប្បីប្រមូលមករួម ក្នុងសេនាសនទាន ។

(រឿងព្រះបាទអសោក)

(៣៦) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី អ្នកលក់ទឹកឃ្មុំ ម្នាក់ បានលក់ទឹកឃ្មុំ ក្នុងផ្សារ ។ គ្រានោះ ព្រះបច្ចេកពុទ្ធ មួយ អង្គ បានកើតរោគរបេង ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធ មួយអង្គ ទៀត កាលនិមន្តទៅបិណ្ឌបាតទឹកឃ្មុំ ជើម្បីធ្វើថ្នាំ ប្រគេនព្រះ បច្ចេកពុទ្ធអង្គនោះ ក៏បានចុះអំពីភ្នំគន្ធមាទន៍ហើយ និមន្តចូលទៅ កាន់ទីក្រុងពារាណសី ។ នាងកុម្ភទាសី អ្នកទៅកំពង់ទឹក ឃើញ ព្រះបច្ចេកពុទ្ធអង្គនោះហើយ ក៏ក្រាបទូលសួរ ស្តាប់រឿងនោះហើយ ទើបលាតដៃចេញ បង្ហាញនូវផ្សារទឹកឃ្មុំ ដោយពាក្យថា " បពិត្រ ព្រះគុណម្ចាស់ដ៏ចំរើន អ្នកលក់ទឹកឃ្មុំ នៅក្នុងទីនោះ, សូមព្រះគុណ

ម្ចាស់ និមន្តទៅ ក្នុងទីនោះចុះ" ដូច្នេះហើយ ក៏បានឈរគិត នៅក្នុងទីនោះឯងថា "បើអ្នកលក់ទឹកឃ្មុំ មិនប្រគេនទឹកឃ្មុំ ដល់ព្រះគុណាម្ចាស់ទេ, អាត្មាអញ នឹងទៅក្នុងទីនោះហើយ យកទឹកឃ្មុំមកប្រគេនដល់ព្រះគុណាម្ចាស់ ក្រោយមក ចាំស្វែងរកទ្រព្យ មកឱ្យនូវថ្លៃ (នៃទឹកឃ្មុំ)" ដូច្នេះ ។ ព្រះបច្ចេកពុទ្ធ បាននិមន្តទៅហើយ ក្នុងផ្សារនោះ ។ អ្នកលក់ទឹកឃ្មុំ ឃើញព្រះបច្ចេកពុទ្ធហើយ ក៏មានចិត្តត្រេកអរ បានប្រគេនទឹកឃ្មុំពេញបាត្រ ឃើញទឹកឃ្មុំហូរហៀរស្រក់ចេញអំពីមាត់បាត្រ ធ្លាក់ស្រក់ចុះ លើផែនដី ជ្រះថ្លាហើយ យ៉ាងខ្លាំង ទើបបានប្រាថ្នាថា "បពិត្រព្រះគុណាម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា គប្បីគ្រប់គ្រងឯករាជ ក្នុងជម្ពូទ្វីប ដោយបុញ្ញកម្មនេះ, ក៏អាជ្ញា របស់ខ្ញុំព្រះករុណា ចូរផ្សព្វផ្សាយទៅ ក្នុងស្ថានទីប្រមាណ ១ យោជន៍ ទាំងលើអាកាសនិងលើផែនដី" ដូច្នេះ ។ ព្រះបច្ចេកពុទ្ធ ត្រាស់ថា "ម្នាលឧបាសក សេចក្តីប្រាថ្នារបស់អ្នក ចូរសម្រេច យ៉ាងនោះចុះ" ដូច្នេះហើយ ទើបបាននិមន្តមកវិញ ។ នាងកុម្ភទាសីនោះ ឃើញនូវព្រះបច្ចេកពុទ្ធហើយ ទើបទូលសួរថា "បពិត្រព្រះគុណាម្ចាស់ដ៏ចំរើន តើព្រះគុណាម្ចាស់ បាននូវទឹកឃ្មុំហើយឬ ?" ។ ព្រះបច្ចេកពុទ្ធ បានតបវិញថា "ម្នាលបួនស្រី អ្នកលក់ទឹកឃ្មុំនោះបានប្រគេនទឹកឃ្មុំដល់អាត្មាហើយ ប្រាថ្នាយ៉ាងដូច្នេះ" ។ នាងកុម្ភទាសីនោះ ស្តាប់នូវ

រឿងនោះហើយ ទើបប្រាថ្នានូវភាវៈជាអគ្គមហេសី នៃអ្នកលក់ទឹកឃ្មុំនោះ ។ បណ្តាជនទាំង ២ នោះ អ្នកលក់ទឹកឃ្មុំ បានជាព្រះអសោកកុមារ ជាអ្នកចម្បងជាងគេបង្អស់ បណ្តាព្រះរាជបុត្រ ១០១ ព្រះអង្គ របស់ព្រះបាទពិន្ទុសារ ក្នុងនគរបាដលីបុត្រ ដោយកាលកន្លងទៅ នៃព្រះបិតា បានធ្វើគត់ព្រះអនុជទាំងឡាយ ដទៃអំពីនោះ លើកលែងតែព្រះតិស្សកុមារ ដែលរួមព្រះមាតាជាមួយគ្នាចេញ នៅមិនទាន់បានអភិសេកផង ក៏បានគ្រប់គ្រងរាជសម្បត្តិ រហូត ៤ ឆ្នាំ ដោយកន្លងទៅ ៤ ឆ្នាំ ទើបបានដល់នូវការអភិសេក ជាព្រះរាជ ១ ព្រះអង្គ ក្នុងជម្ពូទ្វីទាំងមូល ក្នុងឆ្នាំទី ១៨ ដែលជាឆ្នាំទីបំផុតនៃសតវត្សរ៍ទី ២ (២១៨) អំពីការបរិនិព្វាន នៃព្រះសាស្តាទៅ ។ ក៏ព្រះរាជឫទ្ធិទាំងឡាយនេះ មកហើយ ដល់ព្រះអសោកកុមារនោះ ដោយអានុភាពនៃការអភិសេក ។ មែនពិត ព្រះរាជឫទ្ធិទាំងឡាយ សូម្បីដែលបុគ្គលគប្បីសម្រេច ដោយអានុភាពនៃបុណ្យ រមែងមក ដោយអានុភាពនៃការអភិសេក ដែលកើតអំពីបយោគសម្បត្តិនុ៎ះឯង ប្រៀបដូចជាគុណវិសេស ដែលសេសសល់ មានបដិសម្ភិទាជាដើម ដែលមកហើយ ដោយព្រះអរហត្តមគ្គ ។ ពួកខាងក្រោមនៃផែនដី ព្រះអាជ្ញាផ្សព្វផ្សាយទៅ ក្នុងទីប្រមាណ ១ យោជន៍, ពួកខាងលើនៃអាកាស ក៏ដូចគ្នាដែរ ។ ទេវតាទាំងឡាយ តែងនាំយកទឹកសំរាប់

សោយ មកអំពីអនោតត្តស្រះ មួយថ្ងៃ ៗ ១៦ ក្អម (និងនាំ) ឈើ ស្ទន់ ឈ្មោះនាគលតា មានរសជាត ដ៏ទន់រមួត ផ្លែកន្ទួតព្រៃដែលជា ថ្នាំ ផ្លែស្រម៉ដែលជាថ្នាំ និងផ្លែស្វាយទុំ ដែលដល់ព្រមដោយក្លិននិង រសជាត មានពណ៌ដូចមាស មកអំពីព្រៃហិមវន្ត រៀងរាល់ថ្ងៃ ៗ ផ្លែកន្ទួតព្រៃ ដែលជាឱសថ ដែលនាំរបស់ដែលជាទោសទាំងពួង ចេញ អាចជម្រះសរីរៈជាដើមបាន ដោយការបរិភោគតែបន្តិច បន្តួចប៉ុណ្ណោះ ឈ្មោះថា ផ្លែកន្ទួតព្រៃដែលជាថ្នាំ ៗ សូម្បីផ្លែ ស្រម៉ដែលជាថ្នាំ ក៏ដូច្នោះដែរ ៗ បានញ្ចថា ព្រះរាជាទ្រង់សោយ បណ្តាផ្លែកន្ទួតព្រៃនិងផ្លែស្រម៉ទាំង ២ មុខនោះ ផ្លែណាមួយ តាម ព្រះរាជប្រាថ្នា ៗ ទេវតាទាំងឡាយនុ៉ះឯង តែងនាំនូវសំពត់សំរាប់ ស្លៀកដណ្តប់ មាន ៥ ពណ៌ សំពត់ពណ៌លឿង សំពត់ជូតព្រះហស្ត និង ទឹកដែលជាទិព្ធ មកអំពីទេវវិមានដែលស្ថិតនៅ ក្បែរស្រះ ឈ្មោះឆទ្ទន្ត ជារៀងរាល់ថ្ងៃ ៗ អាចារ្យពួកខ្លះ ពោលថា "ឯដើម កប្បព្រឹក្សទាំងឡាយ តែងមាន ក្បែរស្រះឈ្មោះឆទ្ទន្ត, ទេវតាទាំង ឡាយ តែងនាំមក អំពីដើមកប្បព្រឹក្សនោះ" ដូច្នេះ ក៏មានដែរ ៗ នាគរាជទាំងឡាយ តែងនាំសុគន្ធវារីសម្រាប់ស្រង់ គ្រឿងក្រអូប សម្រាប់លាប សំពត់ផ្តាម្ចិះ ដែលមិនបានត្បាញដោយអំបោះ ដើម្បី ប្រយោជន៍ដល់កិរិយាទ្រង់ និងឱសថសម្រាប់បន្តក់ព្រះនេត្រ ដែល

មានតម្លៃដ៏ច្រើន មកអំពីភពនៃនាគ ជារៀងរាល់ថ្ងៃ ។ សំពត់ទិព្វ ដែលកើតអំពីដើមកប្បព្រឹក្ស មិនបានត្បាញ ដោយអំបោះ ឈ្មោះថា អសុត្តមយិកៈ, សំពត់នោះ ជាសំពត់សាច់ល្អិតម៉ដ្ដ ក្នុងទីគ្រប់ស្ថាន ឈ្មោះថា ជាសំពត់ផ្កាម្លិះ ព្រោះមានផ្កាផុសប៉ោងឡើង ។ សត្វសេកទាំងឡាយ តែងនាំស្រូវសាលី ៩,០០០ រទេះ ដែលកើតឯងក្បែរស្រះឆទ្ទន្ត មកជារៀងរាល់ថ្ងៃ ។ ក៏គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា "វាហសហស្សានិ" នេះ ដូចតទៅ ÷ ៤ កំបង់ ត្រូវជា ១ កុឌុវៈ, ៤ កុឌុវៈ ត្រូវជា ១ បត្ថៈ, ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ, ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ, ៤ ទោណៈ ត្រូវជា ១ មានិកៈ, ៤ មានិកៈ ត្រូវជា ១ ខារី, ២០ ខារី ត្រូវជា ១ វាហៈ, វាហៈ នុ៎ះឯង គឺ ១ រទេះ ។ កណ្ដុរទាំងឡាយ តែងកកេរនូវអង្ករទាំងឡាយ ឱ្យប្រាសចាកអង្កាមនិងកុណ្ឌក (កន្ទក់) ។ អង្ករដែលបាក់ សូម្បីមួយគ្រាប់ ក៏មិនបានមានហើយ ។ សត្វឃ្មុំទាំងឡាយ តែងហើរមក ធ្វើទឹកឃ្មុំ ក្នុងទីជិតបង្គើយ ។ សត្វខ្លាឃ្មុំទាំងឡាយ តែងពុះខ្ទស ក្នុងសាលានៃជាងមាស ។ សត្វកវឹកទាំងឡាយ តែងមក ស្រែកយំបញ្ចេញសំឡេងដ៏ពិរោះ ធ្វើពលីកម្ម ថ្វាយដល់ព្រះរាជា ដូចជាអ្នកនគរ ដែលធ្វើពលីកម្ម ក្នុងវារៈដែលមកដល់ហើយយ៉ាងដូច្នោះ ។ អាចារ្យពួកខ្លះ តែងពោលថា "សត្វកវឹកទាំងនោះ

ហើរមក ធ្វើសំឡេង ពួដ៏អាកាសនុ៎ះឯង មិនឲ្យអ្នកណាស្គាល់ខ្លួន ស្រេចហើយ ក៏ហើរទៅ" ដូច្នេះក៏មាន ។ អ្នកលក់ទឹកឃ្មុំនោះ បានជាព្រះធម្មរាជា ទ្រង់ព្រះនាមអសោក ទ្រង់ប្រកបព្រម ដោយព្រះរាជឫទ្ធិទាំងនេះ ព្រោះការប្រគេនទឹកឃ្មុំ ដើម្បីធ្វើថ្នាំ ដូចបានពណ៌នាមកហើយ ។ ចំណែកនាងកុម្ភទាសីនោះ បានកើតជាព្រះអគ្គមហេសី នៃព្រះបាទអសោកធម្មរាជនោះ ទ្រង់ព្រះនាមថា ព្រះនាងអសន្ធិមិត្តា ។ បានឮថា ដំណាទាំងឡាយ ត្រង់ព្រះហស្ត និងព្រះបាទទាំងឡាយ របស់ព្រះនាង រាបរលើងស្មើ មិនប្រាកដហើយក្នុងកាលឯទៀត រឿរលែងតែកិរិយាបត់ចូល ព្រោះផលនៃបុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយការខ្ជល់ខ្ជាយ គឺកិរិយាចង្អុលបង្ហាញនូវផ្សារទឹកឃ្មុំ ព្រោះហេតុនោះ ព្រះនាងទើបទ្រង់មានព្រះនាមថា អសន្ធិមិត្តា ។

រឿង ព្រះបាទអសោក មកក្នុងគម្ពីរមហាវង្សជាដើម ។

អបទានរបស់ព្រះពក្កុលត្ថេរ ក្នុងចត្តាលីសមវគ្គក្តី អបទានរបស់ព្រះសប្បិទាយកត្ថេរ ក្នុងសត្តរសមវគ្គក្តី និង សូម្បីរឿងផ្សេងៗទៀត ក្រៅអំពីរឿងនោះក្តី ក៏គួរនាំយកមករួមបញ្ចូលគ្នាក្នុងភេសជ្ជទានដែរ ។

(៣៧) បុគ្គលអ្នកប្រគេនបច្ច័យ ៤ រមែងបានសេចក្តីសុខដូច្នេះឯង ព្រោះហេតុនោះ ទាន គឺបុគ្គលគប្បីឲ្យប្រព្រឹត្តទៅ សូម្បីខ្លួនឯង ។ សូម្បីយ័ញ្ញតាមត្រកូល ក៏មិនគប្បីកាត់ផ្តាច់ដែរ, ព្រោះយ័ញ្ញតាមត្រកូលនោះ ក៏មានផលច្រើនដូចគ្នាដែរ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់កូដទន្តព្រាហ្មណ៍ ទើបទ្រង់ត្រាស់ថា “ម្នាលព្រាហ្មណ៍ ទានទាំងឡាយណាមួយ គឺនិច្ចទាន យ័ញ្ញតាមត្រកូល គឺកុលបុត្រតែងប្រគេន ឧទ្ទិសចំពោះបព្វជិតអ្នកមានសីល, ម្នាលព្រាហ្មណ៍ យ័ញ្ញនេះឯង ។ល។ មានផលច្រើនជាង មានអានិសង្សច្រើនជាង” ដូច្នេះ ។

(៣៨) អដ្ឋកថាកូដទន្តសូត្រនោះថា “ទានយឺនយូរ គឺនិច្ចភ័ត្តទាំងឡាយ ឈ្មោះថា **និច្ចទាន** ក្នុងសូត្រនោះ ។ យ័ញ្ញទាំងឡាយឯណាមួយ សូម្បីគឺកុលទាយាទ ដែលជាបុរសអ្នកក្រីក្រ ក្នុងកាលជាខាងក្រោយ ធ្វើមនស្សិការថា “និច្ចទានទាំងឡាយ គឺបិតានិងជីតាជាដើម របស់ពួកយើង បានឲ្យប្រព្រឹត្តទៅហើយ” ដូច្នេះ គប្បីឲ្យប្រព្រឹត្តទៅ តាមលំដាប់នៃវង្សត្រកូល ឈ្មោះថា យ័ញ្ញដែលប្រព្រឹត្តទៅតាមត្រកូល ។ បានឮថា ជនទាំងឡាយ ក្នុងត្រកូលទាំងនោះ សូម្បីធ្លាក់ខ្លួនក្រីក្រ រមែងមិនកាត់ផ្តាច់ នូវទានជាប្រចាំ ឧទ្ទិសចំពោះអ្នកមានសីល យ៉ាងនោះដែរ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាខុទាហរណ៍) ÷

(រឿងអនាថបិណ្ឌិកសេដ្ឋី)

បានឮថា ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី និច្ចភត្ត ៥០០ គឺបុគ្គលបានប្រគេនហើយ ។ សលាកដែលធ្វើហើយដោយភ្លុក ៥០០ បានមានហើយ, គ្រាក្រោយមក ត្រកូលនោះ ត្រូវសេចក្តីក្រីក្រ គ្របសង្កត់ហើយ ដោយលំដាប់ ។ នាងទាវិកាម្នាក់ ក្នុងត្រកូលនោះ មិនអាចដើម្បីនឹងប្រគេន ឱ្យលើសពីមួយសលាកបានឡើយ ។ ចំណែកនាងទាវិកានោះ ខាងក្រោយមក បានទៅកាន់រដ្ឋធានីឈ្មោះសេតវាហនៈ បានប្រគេនហើយនូវសលាកនោះ ដោយធញ្ញជាត ដែលខ្លួននាងបោសសំអាតលានបានហើយ ។ ព្រះថេរៈមួយរូប បានទូលហើយ ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បាននាំនាងទាវិកានោះមកហើយ ទ្រង់តែងតាំងហើយ ក្នុងតំណែង នៃព្រះអគ្គមហេសី ។ តាំងអំពីពេលនោះមក ព្រះនាងបានឱ្យសលាកភត្តទាំង ៥០០ ប្រព្រឹត្តទៅហើយ បន្តទៅទៀត ” ។

(៣៩) ជីវកូដទន្តសូត្រនោះ ថា “ទាន ដែលបុគ្គលធ្វើឱ្យឃើនយូរ គឺឱ្យស្ថិតស្ថេរ មិនឱ្យដាច់រយៈ ហើយគប្បីប្រគេន ឈ្មោះថា ទានឃើនយូរ ។ ទាន ដែលបុគ្គលអាស្រ័យលំដាប់នៃត្រកូល

គឺ អនុលោមទៅតាមត្រកូល ហើយគប្បីឲ្យ ឈ្មោះថា យ័ញ្ញដែល ប្រព្រឹត្តទៅតាមត្រកូល ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា "**អម្ហាកំ**" ដូច្នេះជាដើម ។ ទាន ដែលបុគ្គលកំណត់ គឺនិយមហើយ ឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃប្រពៃណី ឈ្មោះថា ទានយឺនយូរស្ថិតស្ថេរ ។ បុគ្គលទាំងឡាយ តែងកត់ឈ្មោះ នៃពួក ទាយកទុក ក្នុងសលាកឯណា, សលាកដែលបុគ្គលឲ្យប្រព្រឹត្តទៅ ដោយភ្នក់ជំរីនោះ ឈ្មោះថា សលាកធ្វើអំពីភ្នក់ជំរី ។ បទថា "**រញ្ញោ**" បានដល់ ព្រះបាទសេតវាហនៈ" ។

ពណ៌នាអំពីអាមិសទាន ចប់ ។

(៤០) អដ្ឋកថាទុកនិបាត អង្គុត្តរនិកាយ ថា "បទថា '**ធម្មទានំ**' មានសេចក្តីថា ព្រះធម្មកថិកអង្គខ្លះ ក្នុងព្រះសាសនានេះ រមែងសំដែងនូវបដិបទា ជាហេតុឲ្យសម្រេចអមតៈ ហើយទើបឲ្យ, នេះ ឈ្មោះថា **ធម្មទាន**" ។

ជីកាទុកនិបាត អង្គុត្តរនិកាយនោះថា "បទថា '**អមតប្បត្តិ-ប្បដិបទំ**' បានដល់ បដិបទាត្រូវ ដែលជាហេតុសម្រេចអមតៈ" ។

(៤១) អដ្ឋកថាឥតិវុត្តកៈថា "ព្រះធម្មកថិកអង្គខ្លះ ក្នុងព្រះ ព្រះសាសនានេះ ចែកនូវកម្មបថដែលជាកុសល និង អកុសល ថា

'ធម៌ទាំងឡាយនេះ ជាកុសល, ធម៌ទាំងឡាយនេះ ជាអកុសល, ធម៌ទាំងឡាយនេះ មានទោស, ធម៌ទាំងឡាយនេះ មិនមានទោស, ធម៌ទាំងឡាយនេះ គឺវិញ្ញូជនគិះដៀលហើយ, ធម៌ទាំងឡាយនេះ គឺវិញ្ញូជនសរសើរហើយ, ធម៌ទាំងឡាយនេះ គឺបុគ្គលសមាទានឱ្យបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ, ធម៌ទាំងឡាយនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ' ដូច្នេះ ធ្វើនូវកម្មនិងវិបាកនៃកម្ម ឱ្យប្រាកដ ដូចជាសំដែងប្រាប់នូវលោកនេះ និងលោកខាងមុខ ដោយជាក់ច្បាស់ ញុំាងបុគ្គលអ្នកស្តាប់ ឱ្យត្រឡប់ (ចិត្តគំនិត) អំពីអកុសលធម៌ទាំងឡាយ ឱ្យស្ថិតនៅស៊ប់ ក្នុងកុសលធម៌ទាំងឡាយ សំដែងនូវធម៌, កិរិយាធ្វើនេះ ឈ្មោះថា **ធម្មទាន** ។ តែព្រះធម្មកថិកអង្គណា ប្រកាសនូវសច្ចៈទាំងឡាយថា 'ធម៌ទាំងឡាយនេះ បុគ្គលគប្បីដឹងយ៉ាងក្រៃលែង, ធម៌ទាំងឡាយនេះ បុគ្គលគប្បីកំណត់ដឹង, ធម៌ទាំងឡាយនេះ បុគ្គលគប្បីលះបង់ចោល, ធម៌ទាំងឡាយនេះ បុគ្គលគប្បីធ្វើឱ្យជាក់ច្បាស់, ធម៌ទាំងឡាយនេះ បុគ្គលគប្បីចំរើន' ដូច្នេះ សំដែងនូវបដិបត្តិធម៌ ដើម្បីសម្រេចនូវអមតៈ, កិរិយាធ្វើយ៉ាងនេះ ឈ្មោះថា ធម្មទាន ដែលដល់ហើយនូវភាវៈជាកំពូល ។ បទថា '**ឯតទគ្គំ**' កាត់បទជា **ឯតំ អគ្គំ** ។ បទថា '**យទិទំ**'

មានសេចក្តីថា បណ្តាទានទាំង ២ យ៉ាងនេះ ធម្មទាន ដែលព្រះធម្មកថិកនោះ សំដែងនុ៎ះ ជាធម្មទានដ៏លើស ដ៏ប្រសើរ ខ្ពង់ខ្ពស់ ។ មែនពិត បុគ្គលអាស្រ័យនូវធម្មទាន ដែលញុំាងសត្វឲ្យដល់នូវវិវដ្តៈ រមែងរួចផុតស្រឡះ អំពីសេចក្តីអន្តរាយគ្រប់បែបយ៉ាង, រមែងកន្លងផុតនូវសេចក្តីទុក្ខក្នុងវដ្តៈទាំងអស់ ។ ក៏ធម្មទានដែលជាលោកិយ រមែងជាជើមហេតុ នៃទានទាំងឡាយទាំងពួង ជាឫសគល់ នៃទ្រព្យសម្បត្តិគ្រប់បែបយ៉ាង ។ សូម្បីអភ័យទាន ក៏គប្បីឃើញថា ‘ព្រះដ៏មានព្រះភាគ ទ្រង់សង្គ្រោះហើយ ដោយធម្មទានបណ្តាទានទាំង ២ យ៉ាងនេះ ដូចគ្នា’ ដូច្នេះ ” ។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលថា “ក៏ការសំដែងធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសហើយ ដែលជាហេតុអស់ទៅនៃសេចក្តីទុក្ខ និងនាំសេចក្តីសុខមកឲ្យ ក្នុងលោកនេះ និងលោកខាងមុខ ដើម្បីភាពជាអ្នកប្រាថ្នានូវប្រយោជន៍សុខ ដល់បុគ្គលដទៃ ឈ្មោះថា ធម្មទាន ” ។

(៤២) មែនពិត ធម្មទាន ចាត់ថាជាទានដ៏លើស ដ៏ប្រសើរ ក៏ព្រោះឈ្នះនូវអាមិសទានទាំងពួង ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់សក្កទេវរាជ ដែលជាស្តេចនៃទេវតា ទើបទ្រង់ត្រាស់ទុក ក្នុងគណ្ឋាវគ្គ នៃធម្មបទ ថា ÷

"ធម្មទាន រមែងឈ្នះនូវទានទាំងពួង, ធម្មរស រមែងឈ្នះនូវរស់ទាំងពួង, សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះនូវសេចក្តីត្រេកអរទាំងពួង, កិរិយារអស់ទៅនៃតណ្ហា រមែងឈ្នះនូវសេចក្តីទុក្ខទាំងពួង"។

ជីកាទេវគាសំយុត្ត ក្នុងសគាថវគ្គ ថា "អាមិទាន អភ័យទាន គាមដែលពោលមកហើយ ឈ្មោះថា ទានទាំងពួង។ បទថា 'ធម្មទានំ' បានដល់ ការសំដែងនូវធម៌"។

(៤៣) អដ្ឋកថាធម្មបទ ថា "ក៏ប្រសិនបើបុគ្គលគប្បីប្រគេននូវចីពរទាំងឡាយ ដូចជាស្រទាប់ត្រយូងចេក ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះខីណាស្រពទាំងឡាយ ដែលបានគង់ជាប់ៗគ្នា ក្នុងផ្ទៃនៃចក្រវាល រហូតទៅទល់គ្នានឹងព្រហ្មលោក, កិរិយាអនុមោទនា ដែលព្រះពុទ្ធជាដើម ទ្រង់បានធ្វើហើយ ដោយព្រះគាថាប្រកបដោយ ៤ បាទ ក្នុងសមាគមនោះឯង ប្រសើរបំផុត។ ព្រោះថា ទាននោះ រមែងមិនដល់តម្លៃ នូវចំណែកទី ១៦ នៃព្រះគាថានោះទេ។ ការសំដែងក្តី ការប្រាប់ក្តី ការស្តាប់ក្តី នូវធម៌ជាធម្មជាតមានផលច្រើន យ៉ាងដូច្នេះ។ មួយទៀត បុគ្គលឯណាមួយ ឱ្យគេធ្វើការស្តាប់ធម៌នោះ, អានិសង្សដ៏ច្រើន រមែងមាន

ដល់បុគ្គលនោះពិត ។ ធម្មទាន ដែលព្រះពុទ្ធជាដើម ទ្រង់បានឲ្យ ប្រព្រឹត្តទៅហើយ សូម្បីដោយអំណាចនៃអនុមោទនា ដោយហោច ទៅ ដោយព្រះគាថាប្រកបដោយ ៤ បាទប៉ុណ្ណោះ ជាធម្មជាតដ៏ ប្រសើរ សូម្បីជាងទាន ដែលទាយកញុំាងបាត្រឲ្យពេញ ដោយ បិណ្ឌបាតដ៏ប្រណីតហើយ ប្រគេនដល់បរិសទ្យអ្នកប្រាកដដូច្នោះឯង សូម្បីជាងភេសជ្ជទាន ដែលទាយកញុំាងបាត្រឲ្យពេញ ដោយទឹក ដោះរាវថ្លា និងប្រេងជាដើមហើយប្រគេន សូម្បីជាងសេនាសន-ទាន ដែលទាយកញុំាងបុគ្គល ឲ្យសាងព្រះវិហារទាំងឡាយ ដូចជា ព្រះមហាវិហារនិងប្រាសាទទាំងឡាយ ដូចជាលោហាប្រាសាទ រាប់ ច្រើនសែនខ្នងជាអនេកហើយប្រគេន សូម្បីជាងការបរិច្ចាគ ដែល អនាថបិណ្ឌិកសេដ្ឋី ប្រារព្ធព្រះវិហារធ្វើហើយ ។ ព្រោះហេតុអ្វី ?។ ព្រោះថា បុគ្គលទាំងឡាយ កាលនឹងធ្វើបុណ្យយ៉ាងដូច្នេះ ត្រូវតែ ស្តាប់ធម៌សិនហើយ ទើបធ្វើទៅបាន, មិនបានស្តាប់ធម៌ហើយ ក៏មិន បានធ្វើដែរ ។ ក៏ប្រសិនបើសត្វទាំងនេះ មិនគប្បីស្តាប់ធម៌ទេ, ក៏មិន គប្បីប្រគេន សូម្បីនូវបបរត្រឹមមួយក្បាយ សូម្បីនូវបាយត្រឹមតែ មួយវែកដែរ, ហេតុនេះ ធម្មទាននុ៎ះឯង ជាទានប្រសើរ ជាងទាន ទាំងពួង ។ មួយទៀត លើកលែងតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធ ទាំងឡាយចេញហើយ សូម្បីព្រះសាវ័កទាំងឡាយ មានព្រះសារីបុត្រ

ជាដើម ជាអ្នកប្រកបដោយបញ្ញាដែលអាច ដើម្បីនឹងរាប់ដំណក់ទឹកភ្លៀងទាំងឡាយបាន កាលបើភ្លៀងកំពុងធ្លាក់ រហូតកប្បទាំងមួលក៏មិនអាច ដើម្បីនឹងសម្រេចសោតាបត្តិផលជាដើម ដោយធម្មតារបស់ខ្លួនបានឡើយ, លុះត្រាតែស្តាប់ធម៌ ដែលព្រះអស្សជិត្ថេរជាដើមសំដែងហើយ ទើបធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលបាន, (និង) ធ្វើឲ្យជាក់ច្បាស់នូវសាវកបារមីញ្ញាណ ដោយព្រះធម៌ទេសនារបស់ព្រះសាស្តាបាន ។ បពិត្រព្រះមហារាជ ព្រោះហេតុនេះឯង ធម្មទាននុ៎ះឯង ជាទានដ៏ប្រសើរបំផុត ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា '**ធម្មទាន រមែងឈ្នះ នូវទានទាំងពួង**' ដូច្នេះជាដើម ។ មួយទៀត រសគ្រប់យ៉ាងមានរសដែលកើតអំពីគល់ជាដើម ដោយខ្ទុះក្រឌួ សូម្បីរសនៃសុធាភោជន៍របស់ទេវតាទាំងឡាយ រមែងជាបច្ច័យ នៃកិរិយាញុំាងសត្វឲ្យធ្លាក់ទៅក្នុងសំសារវដ្តហើយ សោយសេចក្តីទុក្ខដោយពិត ។ ចំណែកព្រះធម៌ ពោលគឺពោធិបក្ខិយធម៌ ៣៧ ប្រការក្តី ពោលគឺព្រះលោកុត្តរធម៌ ៩ ប្រការក្តី នេះឯង ប្រសើរជាងរសទាំងពួង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ ថា '**ធម្មរស រមែងឈ្នះ នូវរសទាំងពួង**' ដូច្នេះ" ។

ជីកាសគាថាវគ្គ ថា "បីតិនិងប្រាមោជ្ជៈ ដែលព្រះសទ្ធម្មសន្ធ

ហើយ ឈ្មោះថា រសនៃព្រះធម៌ ” ។

(៤៤) អដ្ឋកថាធម្មបទ ថា “ មួយវិញទៀត សូម្បីសេចក្តីត្រេកអរចំពោះបុត្រ សេចក្តីត្រេកអចំពោះធីតា សេចក្តីត្រេកអរចំពោះស្ត្រី និងសេចក្តីត្រេកអរមានប្រភេទជាអនេក ផ្សេងដោយសេចក្តីត្រេកអរចំពោះការលេង មានការរាំ ច្រៀង និងប្រគំជាដើមនោះឯង រមែងជាបច្ច័យ នៃកិរិយាញុាំងសត្វឱ្យធ្លាក់ចុះទៅ ក្នុងវដ្តៈ ហើយសោយសេចក្តីទុក្ខដោយពិត ។ ចំណែកសេចក្តីឆ្អែតចិត្តនេះឯណា ដែលកើតឡើង ក្នុងខាងក្នុង (ចិត្ត) នៃបុគ្គលអ្នកសំដែងធម៌ក្តី អ្នកស្តាប់ធម៌ក្តី រមែងញុាំងភាពជាអ្នកមានចិត្តខ្ពស់ ឱ្យកើតឡើង ញុាំងទឹកភ្នែកឱ្យស្រក់ចុះ ញុាំងការព្រឺព្រួចរោម ឱ្យកើតឡើង, សេចក្តីឆ្អែតចិត្តនេះនោះ រមែងធ្វើនូវទីបំផុត នៃសំសារវដ្តៈ មានព្រះអរហត្តជាទីបំផុត ព្រោះហេតុនោះ សេចក្តីត្រេកអរក្នុងព្រះធម៌ យ៉ាងដូច្នេះឯង ជាសេចក្តីត្រេកអរប្រសើរ ជាងសេចក្តីត្រេកអរទាំងពួង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា ‘ **សេចក្តីត្រេកអរ ក្នុងព្រះធម៌ រមែងឈ្នះ នូវសេចក្តីត្រេកអរទាំងពួង** ’ ដូច្នេះ ” ។

ជីកាសគាថវគ្គ ថា “ សេចក្តីត្រេកអរក្នុងព្រះធម៌ គឺសមថៈ និងវិបស្សនា ឈ្មោះថា សេចក្តីត្រេកអរក្នុងព្រះធម៌ ” ។

អដ្ឋកថាធម្មបទនោះថា " ចំណែកកិរិយាអស់ទៅ នៃតណ្ហា គឺ ព្រះអរហន្ត ដែលកើតឡើង ក្នុងទីចំផុតនៃការអស់ទៅ នៃតណ្ហា, ព្រះអរហន្តនោះ ប្រសើរជាងអ្វីគ្រប់បែបយ៉ាងដោយពិត ព្រោះ គ្រប់សង្កត់នូវសេចក្តីទុក្ខក្នុងវដ្តៈ ទាំងមូលបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ' **កិរិយាអស់ទៅ នៃតណ្ហា រមែងឈ្នះ នូវសេចក្តីទុក្ខទាំងពួង** ' ដូច្នេះ " ។

(៤៥) ព្រះធម្មកថិក សូម្បីកាលនឹងសំដែងធម៌ គប្បីជាអ្នក មានចិត្តទន់ជ្រួញជ្រាយទៅ ដើម្បីជាប្រយោជន៍ដោយពិត មិនគប្បីជា អ្នកធ្ងន់ក្នុងលាភ ។ ព្រោះថា ធម្មទាន របស់ព្រះធម្មកថិកអ្នកធ្ងន់ ក្នុងលាភ រមែងមិនមានផលច្រើនឡើយ ។ ដោយហេតុនោះ ទើប លោកពោលទុកហើយ ក្នុងអដ្ឋកថាសង្គីតិសូត្រថា " ព្រះធម្មកថិក មួយរូប ស្ថិតនៅក្នុងសេចក្តីប្រាថ្នាថា ' បុគ្គលទាំងឡាយ នឹងដឹង នូវអាត្មាអញថា ' ជាព្រះធម្មកថិក ដោយប្រការយ៉ាងនេះ ' ដូច្នេះ ហើយ ជាអ្នកធ្ងន់ក្នុងលាភ សំដែង (នូវធម៌), ធម្មទាននោះ មិន មានផលច្រើនឡើយ ។ ព្រះធម្មកថិកមួយរូប មិនប្រាថ្នា (យ៉ាង ដូច្នោះ) ឡើយ សំដែងធម៌ដែលខ្លួនស្គាល់ជំនាញ ដល់ជនទាំងឡាយ ឯទៀត, ធម្មទាននេះ ឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចមក អំពីការសំដែងធម៌ " ។

ជីកាសង្គីតិសូត្រនោះថា "ធម្មទាននោះ ឈ្មោះថាមិនមានផលច្រើន ព្រោះត្រូវតណ្ហាច៉ះពាល់ត្រូវហើយ។ បណ្ឌិតគប្បីនាំយកនូវពាក្យថា **'បរេសំ ទេសេតិ ហិតផរណេន មុទុចិត្តេន'** មកសម្ព័ន្ធចូលជាមួយគ្នា"។

(៤៦) មែនពិត ព្រះធម្មកថិក កាលនឹងសំដែងធម៌ គប្បីតម្កល់ធម៌ ៥ យ៉ាង ទុកក្នុងខ្លួនឲ្យបាន។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងបឋមវគ្គ នៃចតុត្ថបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ(១) ថា "ម្នាលអានន្ទ ការសំដែងធម៌ ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ, ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ ដល់ជនដទៃ គប្បីតម្កល់ធម៌ ៥ យ៉ាង ឲ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ ដល់ជនដទៃ, ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ?។ គឺភិក្ខុត្រូវសំដែងធម៌ ដល់ជនដទៃ ដោយតាំងចិត្តថា 'អាត្មាអញនឹងសំដែងនូវអនុបុព្វិកថា ១' ... 'អាត្មាអញនឹងសំដែងពាក្យ លើកអាងហេតុផល ១' ... 'អាត្មាអញនឹងសំដែងពាក្យ ដោយអាស្រ័យនូវសេចក្តីអាណិត (ដល់អ្នកស្តាប់) ១' ... 'អាត្មាអញនឹងមិនអាស្រ័យអាមិសជាហេតុ សំដែងធម៌ ១' ភិក្ខុត្រូវសំដែងធម៌ ដល់ជនដទៃ ដោយតាំងចិត្តថា 'អាត្មាអញនឹងសំដែងធម៌ ដោយមិនបានបៀតបៀនខ្លួនឯង និងបុគ្គលដទៃ ១'។

---

១ ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ១១១

ម្នាលអានន្ទ ការសំដែងធម៌ ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ, ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ ដល់ជនដទៃ គប្បីតម្កល់ធម៌ ៥ យ៉ាងនេះ ឱ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ ដល់ជនដទៃ "។

ឧទាយីសូត្រ ចប់ ។

(៤៧) អដ្ឋកថាឧទាយីសូត្រនោះ ថា "បទថា **'អនុបុព្វីកថំ'** មានសេចក្តីថា ព្រះធម្មកថិកគប្បីញុំាងចិត្តឱ្យតាំងនៅ ថា 'អាត្មាអញនឹងសំដែងនូវទេសនាអនុបុព្វីកថា យ៉ាងនេះ ថា 'សីលក្នុងលំដាប់នៃទាន ស្ថានសួគ៌ក្នុងលំដាប់នៃសីល' ដូច្នេះជាដើម ឬថាបទព្រះសូត្រ ឬបទព្រះគាថាណា។ ជាបទដែលតាំងទុកហើយ, (នឹងសំដែង) ពាក្យដែលសមគួរ ដល់បទនៃសូត្រនិងគាថានោះ។' ដូច្នេះហើយ ទើបគួរសំដែងធម៌ ដល់ជនដទៃ ។ បទថា **'បរិយាយទស្សាវី'** មានសេចក្តីថា កាលសំដែងនូវហេតុនោះ។ នៃផលនោះ ។ ។ ក៏ហេតុ លោកពោលថា 'បរិយាយ' ក្នុងបទថា **'បរិយាយទស្សាវី'** នេះ។ ២បទថា **'អនុទ្ទយតំ បដិច្ច'** មានសេចក្តីថា អាស្រ័យសេចក្តីអនុគ្រោះ ថា 'អាត្មាអញ នឹងដោះលែង នូវសត្វទាំងឡាយ ដែលជាប់សេចក្តីចង្អៀតចង្អល់ចិត្តដ៏ច្រើន ចេញពីសេចក្តីចង្អៀតចង្អល់ចិត្ត' ។ បទថា **'ន អាមិសន្តរោ'** បានដល់ មិនមានអាមិសជាហេតុ

អធិប្បាយថា 'មិនប្រាថ្នានូវការបានបច្ច័យ ៤ ដើម្បីខ្លួនឡើយ' ។ ច្រើនបទថា '**អត្តានញ្ច បរញ្ច អនុបហច្ច**' មានសេចក្តីថា មិនបានចូលទៅបៀតបៀនខ្លួនឯង និងជនដទៃ ដោយអំណាចការលើកតម្កើងខ្លួនឯងនិងបន្ទាបបន្ថោកជនដទៃ ដោយការប៉ះទង្គិចគុណ" ។

ក៏អនុបុព្វីកថា អ្នកប្រាថ្នា (ចង់ដឹង) សេចក្តីនោះ ដោយពិស្តារ គប្បីទាញយក អំពីអដ្ឋកថាអម្ពដ្ឋសូត្រ ក្នុងសីលក្ខន្ធវគ្គ អំពីអដ្ឋកថាឱបាលីសូត្រ ក្នុងបឋមវគ្គ នៃបជ្ឈិមបណ្ណាសកៈ និងអំពីអដ្ឋកថាទុតិយសូត្រ ក្នុងទុតិយវគ្គ នៃអដ្ឋកនិបាត អង្គុត្តរនិកាយ ។

ព្រះធម្មកថិក គប្បីតម្កល់ធម៌ ៥ យ៉ាង ទុកក្នុងខ្លួន យ៉ាងដូច្នេះហើយ ទើបគួរសំដែងធម៌ ដល់ជនដទៃ ដោយពិត ។

មែនពិត ការសំដែងក្តី ការប្រាប់ក្តី (នូវធម៌) ដល់ជនដទៃ រមែងប្រព្រឹត្តទៅ ដើម្បីតិរិយាតាំងនៅស៊ប់ នៃព្រះសាសនា ។

(៤៨) ប៉ុន្តែ ការមិនសំដែង (ធម៌) ជាដើម រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ នៃព្រះសាសនានោះ ។ ហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយនុ៎ះឯងថា "ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំង

ឡាយ ក្នុងសាសនានេះ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនសំដែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២... ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនបង្ហាញនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី៣... ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនធ្វើនូវការទន្ទេញនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤... ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនត្រិះរិះរឿយៗ មិនពិចារណារឿយៗ ដោយចិត្ត មិនជញ្ជឹងរឿយៗ ក្នុងចិត្ត នូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំង

ឡាយ ធម៌ទាំងឡាយ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះ សទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងព្រះ សាសនានេះ រមែងរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ . . . វេទល្លៈ, ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ សំដែងធម៌ តាម ដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយ ពិស្តារ, បង្ហាញនូវធម៌ . . . ដល់បុគ្គលដទៃ ដោយពិស្តារ, ធ្វើនូវ ការស្វាធ្យាយនូវធម៌ . . . ដោយពិស្តារ, ត្រិះរិះរៀយ ៗ ពិចារណា រៀយ ៗ ដោយចិត្ត ជញ្ជឹងគិតរៀយ ៗ ក្នុងចិត្ត នូវធម៌ តាមដែល បានស្តាប់មក តាមដែលបានរៀនមក, ម្នាលភិក្ខុទាំងឡាយ នេះជា ធម៌ទី ៥ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ . . . ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៥ យ៉ាងនេះឯង រមែងប្រព្រឹត្ត ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ" [(១)] ។

សូត្រទី ៥ ចប់ ។

(៤៩) អដ្ឋកថាទសមវគ្គ ឯកនិបាត អង្គុត្តរនិកាយ ថា

---

១ ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ៩៦

"បទថា 'សទ្ធម្មស្ស' បានដល់ ធម៌ល្អ អធិប្បាយថា 'សាសនា'។ បទថា 'សម្មោសាយ' បានដល់ ដើម្បីសេចក្តីវិនាស។ បទថា 'អន្តរធានាយ' បានដល់ ដើម្បីមិនឲ្យប្រាកដ"។

អដ្ឋកថានៃសូត្រខាងដើម អំពីបញ្ចមសូត្រនោះ ក្នុងបញ្ចក-និបាត អង្គុត្តរនិកាយ ថា "បទថា 'ន បរិយាបុណន្តិ' បានដល់ រមែងមិនសិក្សារៀនសូត្រ"។

(៥០) ក៏ព្រោះធម្មទាន ជាបទដ្ឋាន នៃគុណមានភាវៈជាអ្នកដឹងជាក់ច្បាស់នូវអត្ថជាដើម, ហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ជាមង្គល"។ សមដូចជាព្រះអង្គទ្រង់ត្រាស់ទុកក្នុងតតិយវគ្គ បឋមបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយ ដែលជាគរុដ្ឋានីយបុគ្គល មិនសំដែងធម៌ ដល់ភិក្ខុសោះឡើយ, ក៏ប៉ុន្តែថា ព្រះសាស្តាឬភិក្ខុជាសព្រហ្មចារីនោះ សំដែងធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុសំដែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ដោយប្រការណា។, ភិក្ខុនោះ រមែងជាអ្នកដឹងច្បាស់នូវអត្ថផង ជាអ្នកដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ។ ដោយប្រការនោះ។, កាលបើ

ភិក្ខុនោះដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌, បាមោជ្ជៈ ក៏កើតឡើង, ចើមានបាមោជ្ជៈហើយ, បីតិក៏កើតឡើង, កាលបើមានចិត្តប្រកបដោយបីតិហើយ, កាយក៏ស្ងប់រម្ងាប់, ភិក្ខុអ្នកមានកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលសេចក្តីសុខ, ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ តែងតម្កល់មាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិមុត្តាយតនៈ ទី ២ ដែលជាគុណជាត សម្រាប់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តស្ថុងទៅ (កាន់ព្រះនិព្វាន) នៅ ចិត្តដែលមិនទាន់រួចស្រឡះ ក៏រមែងរួចស្រឡះផង អាសវៈដែលមិនទាន់អស់ទៅ ក៏រមែងដល់នូវការអស់ទៅផង ចិត្តដែលមិនទាន់ដល់នូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏រមែងដល់ផង[1] "។

បាលីវិមុត្តិសូត្រ ចប់ ។

(៥១) អដ្ឋកថាវិមុត្តិសូត្រនោះ ថា "បទថា '**ធម្មំ**' បានដល់ រមែងសំដែងនូវធម៌ គឺសច្ចៈ ៤ ។ បទថា '**អត្ថប្បដិសំវេទិនោ**' បានដល់ អ្នកដឹងសព្វនូវសេចក្តីនៃបាលី ។ បទ '**ធម្មប្បដិសំវេទិនោ**' បានដល់ អ្នកដឹងសព្វគ្រប់នូវបាលី ។ បីតិដែលទន់ ។ ឈ្មោះថា បាមោជ្ជៈ ។ បីតិដ៏មានកម្លាំង ដែលមានអាការត្រេកអរ ឈ្មោះថា បីតិ ។ នាមកាយ ឈ្មោះថា កាយ ។ បទថា '**បស្សម្ភតិ**'

---

១ ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ៤១

ប្រែថា តែងស្ងប់រម្ងាប់ ។ ២ បទថា "**សុខំ វេទេតិ**" មានសេចក្តីថា រមែងបានចំពោះនូវសេចក្តីសុខ ។ បទថា '**សមាធិយតិ**' មានសេចក្តីថា ចិត្តរមែងតម្កល់មាំ ដោយសមាធិដែលសម្បយុត្ត ដោយព្រះអរហត្តផល ។ មែនពិត ភិក្ខុនេះ កាលស្តាប់ធម៌នោះ រមែងដឹងនូវឈានវិបស្សនា មគ្គ និងផល ក្នុងឋានៈដែលមកហើយ ។, កាលបើភិក្ខុនោះ ដឹងយ៉ាងដូច្នេះ, ចីតិរមែងកើតឡើង, ភិក្ខុនោះ កាលមិនឲ្យ ដើម្បីបន្ធូរបន្ថយ ក្នុងចន្លោះនៃចីតិនោះបានទេ ជាអ្នកប្រកបដោយខុបចារកម្មដ្ឋាន ចំរើនវិបស្សនាហើយ រមែងសម្រេចនូវព្រះអរហត្ត; ព្រះដ៏មានព្រះភាគទ្រង់សំដៅយកព្រះអរហត្តនោះ ទើបទ្រង់ត្រាស់ព្រះតម្រាស់ថា '**ចិត្តំ សមាធិយតិ**' ដូច្នេះ" ។

(៥២) នយមកក្នុងអដ្ឋកថានៃវិមុត្តិសូត្រនោះថា "បទថា '**វិមុត្តាយតនំ**' បានដល់ ហេតុនៃការរួចផុត ។ បទថា '**យត្ថ**' មានសេចក្តីថា ក្នុងហេតុនៃការរួចផុតណា" ។

ដីកាវិមុត្តិសូត្រនោះថា "២ បទថា '**បាលិអត្ថំ អាជានន្តស្ស**' មានសេចក្តីថា ជាអ្នកដឹងនូវសេចក្តីនៃបាលីនោះ ។ តាមសេចក្តីពិតដោយន័យជាដើមថា 'សីលមកហើយ ក្នុងបាលីប្រទេសនេះ, សមាធិមកហើយ ក្នុងបាលីប្រទេសនេះ, បញ្ញាមកហើយ ក្នុងបាលីប្រទេសនេះ' ដូច្នេះ ឈ្មោះថា ជាអ្នកដឹងសព្វគ្រប់នូវបាលី ព្រោះបាលីជា

គ្រឿងដឹងនូវសេចក្តីនៃបាលីនោះ ។ ២ បទថា **'តរុណា បីតិ'** មានសេចក្តីថា បីតិដ៏ស្រាល គ្រាន់តែកើតឡើង រមែងកើតឡើង ។ សួរថា 'កើតឡើង ដូចម្តេច ?' ។ ឆ្លើយថា 'បាមោជ្ជៈដែលមានសេចក្តីរីករាយសប្បាយជាលក្ខណៈ រមែងកើតឡើង ដល់ភិក្ខុអ្នកដែលពិចារណានូវធម៌ តាមដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយ ជាអ្នកប្រកាន់យកនូវសមាចារខាងផ្លូវកាយ វាចា និងចិត្តរបស់ខ្លួន ដែលសមគួរដល់ធម៌នោះឯង និងសម្រេចសោមនស្ស ។ ២ បទថា **'តុដ្ឋាការភូតា ពលវប្បីតិ'** មានសេចក្តីថា បីតិដ៏មានកម្លាំង ឈ្មោះថា មានអាការត្រេកអរយ៉ាងក្រៃលែង ព្រោះភាវៈជាបីតិដែលមានអាសេវនៈ ដែលបានហើយ ដោយអំណាចនៃបីតិដែលកើតមុន ឈ្មោះថា អាចដើម្បីនឹងជាបច្ច័យ នៃបស្សទ្ធិ ព្រោះអាចរម្ងាប់នូវសេចក្តីខ្ទល់ខ្ទាយខាងផ្លូវកាយ និងចិត្តបាន ។ ព្រោះកាលបើនាមកាយស្ងប់រម្ងាប់, សូម្បីរូបកាយ ក៏រមែងស្ងប់រម្ងាប់ផងដែរ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលយ៉ាងនេះថា **'នាមកាយោ បស្សម្ភតិ'** ដូច្នេះ ។ ២ បទថា **'សុខំ បដិលភតិ'** មានសេចក្តីថា រមែងបានចំពោះ នូវនិរាសមិសសុខ ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ដែលអាច ដើម្បីនឹងជាបច្ច័យ នៃការតាំងមាំនៃចិត្ត ដែលកំពុងតែពោល ។ ក្នុងបទថា **'សមាធិយតិ'** នេះ ព្រះអដ្ឋកថាចារ្យ កាល

នឹងសំដែង ថា 'ព្រះមានព្រះភាគ ទ្រង់មិនអធិប្បាយ សមាធិទូទៅទេ, តាមពិតហើយ ទ្រង់អធិប្បាយសមាធិដ៏ខ្ពង់ខ្ពស់' ដូច្នេះ ទើបពោលថា **'អរហត្តផលសមាធិនា សមាធិយតិ'**។ ពាក្យថា **'អយញ្ហិ'** ជាដើម ជាគ្រឿងប្រកាសនូវភាវៈ នៃទេសនារបស់ភិក្ខុនោះ ជាហេតុឲ្យបុគ្គលដូច្នោះ បានចំពោះសមាធិដូចបានពោលមកហើយ, ព្រោះទេសនានោះ ជាហេតុនៃវិមុត្តិ។ បទថា **'ខិសក្កិតុំ'** គឺ ដើម្បីវិនាស"។

(៥៣) នយជីកានៃវិមុត្តិសូត្រនោះ ថា "ទីកើត គឺហេតុនៃវិមុត្តិ គឺការរួចផុត អំពីវដ្តទុក្ខ ឈ្មោះថា វិមុត្តាយតនៈ ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'វិមុច្ចនការណំ'** ដូច្នេះ"។

គប្បីឃើញសនិដ្ឋានថា "ការស្តាប់ធម៌ និងអភ័យទាន ព្រះមានព្រះភាគទ្រង់សង្គ្រោះ ដោយធម្មទានដូចគ្នា ក៏ពិតមែន, ទោះបីជាដូច្នោះ ការស្តាប់ធម៌ និងអភ័យទានទាំង ២ នោះ រមែងមិនបាន ក្នុងមង្គលបទនេះ ព្រោះបណ្តាការស្តាប់ធម៌ និងអភ័យទានទាំង ២ នោះ អភ័យទាន ខ្ញុំនឹងកំណត់យក ក្នុងមង្គលបទ ថា **'អារតី វិរតី បាបា'** នេះ និងការស្តាប់ធម៌ក្រៅអំពីនេះ ខ្ញុំនឹងពោល ក្នុងមង្គលបទ ថា **'កាលេន ធម្មស្សវនំ'** ដូច្នេះឯង"។

ពណ៌នាអំពីបទ ថា "ទាន" ចប់។

* * *

ពណ៌នាអំពីការប្រព្រឹត្តិធម៌

---

(៥៤) ព្រះអដ្ឋកថាចារ្យ ពោល ក្នុងអដ្ឋកថាមង្គលសូត្រនេះ ថា "ការប្រព្រឹត្តិកុសលកម្មបថ ១០ ប្រការ ឈ្មោះថា ធម្មចរិយា"។

អដ្ឋកថានៃឆដ្ឋសូត្រ ក្នុងទុតិយវគ្គ នៃទុកនិបាត អង្គុត្តរនិកាយ ថា "កុសលកម្មបថ ១០ ប្រការ ឈ្មោះថា ការប្រព្រឹត្តិធម៌ និង កិរិយាប្រព្រឹត្តិដ៏សមគួរ"។

កុសលកម្មបថ ១០ ប្រការ ក្នុងអដ្ឋកថាទាំង ២ នោះ ខ្ញុំបាន ពោលហើយ ក្នុងអាគារិយវិនិយ ព្ធដ៏ខាងក្រោយនុ៎ះឯង ។

ព្រះអដ្ឋកថាចារ្យ ពោលពាក្យនេះ ក្នុងអដ្ឋកថានៃមង្គលសូត្រ នេះថា "ការប្រព្រឹត្តិធម៌ ឬ ការប្រព្រឹត្តិ ដែលមិនប្រាសចាកធម៌ ឈ្មោះថា ធម្មចរិយា"។

និយដែលមក ក្នុងអដ្ឋកថាសារលេយ្យកសូត្រថា "ការប្រព្រឹត្តិ ធម៌ ឈ្មោះថា ធម្មចរិយា គឺ កិរិយាធ្វើតាមធម៌"។

និយដែលមក ក្នុងដីកានៃសារលេយ្យកសូត្រនោះថា "ចេតនា ដែលប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ ឈ្មោះថា ធម្មចរិយា ព្រោះ អត្ថវិគ្រោះថា 'បុគ្គលរមែងប្រព្រឹត្តធម៌ ដោយចេតនានុ៎ះ'។ មួយទៀត ប្រយោគ ដែលមានចេតនានោះជាសមុដ្ឋាន បណ្ឌិត

គប្បីឃើញ ថា 'ជាធម៌' ។ មួយទៀត ធម្មជាតិឯណា មិនទៅ ប្រាសចាកធម៌ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ធម៌, ធម៌ និង កិរិយាប្រព្រឹត្តិនោះ ហេតុនោះ ទើបឈ្មោះថា ធម្មចរិយា" ។

(៥៥) កិរិយាប្រព្រឹត្តិធម៌នោះ បណ្ឌិតគប្បីជ្រាប ថា "ជាមង្គល" ព្រោះជាហេតុ នៃឥដ្ឋផលមានការកើត ក្នុងឋានសួគ៌ ជាដើម ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ព្រាហ្មណ៍ និង គហបតីទាំងឡាយ អ្នកឈ្មោះថា សាលេយ្យកៈ ព្រោះជាអ្នកអាស្រ័យនៅ ក្នុងសាលគ្រាម ក្នុងកោសលរដ្ឋ ទើប ទ្រង់ត្រាស់ទុកហើយ ក្នុងសាលេយ្យកសូត្រ ក្នុងបញ្ចមវគ្គ នៃ មូលបណ្ណាសកៈ (១) ថា 'ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ សត្វទាំង ឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយ ខាងមុខបន្ទាប់អំពី សេចក្តីស្លាប់ទៅ រមែងទៅកើត ក្នុងលោក គឺ (មនុស្ស) សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាម ធម៌ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ កិរិយា ប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ, ដោយវាចាមាន ៤, កិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌

---

១ ត្រៃបិដក ភាគទី ២២ / ទំព័រទី ២៤០

ដោយចិត្តមាន ៣ ប្រការ ។ ម្នាលព្រាហ្មណ៍ និង គហបតីទាំងឡាយ ក៏កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្តេច ? ។ ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ជាអ្នកដាក់ចុះនូវសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់នៅ, ជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងខ្ចប់ករណ៍ គឺសម្បត្តិនៃបុគ្គលឯណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ក៏ជាអ្នកមិនកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួចឡើយ, ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ទោះបីស្ត្រីទាំងឡាយណា ដែលមាតារក្សា បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្ត្រីរក្សា ញាតិរក្សា មានស្វាមី ប្រកបដោយអាជ្ញា ដោយហោចទៅ សូម្បីស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ក៏ជាអ្នកមិនដល់នូវការប្រព្រឹត្តិកន្លង ក្នុងស្ត្រីទាំងឡាយមានសភាពដូច្នោះឡើយ, ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌ ដោយកាយមាន ៣ ប្រការដូច្នេះឯង ។ ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ

កិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចា មាន ៤ ប្រការ តើដូចម្តេចខ្លះ ? ។ ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកលះបង់នូវមុសាវាទ រៀរស្រឡះចាកមុសាវាទ ទោះឋិតនៅក្នុងរោងសភាក្តី ឋិតនៅក្នុងបរិស័ទ្យក្តី ឋិតនៅកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីយ៍ក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សីហើយសួរថា 'នែបុរសដ៏ចំរើន ចូរអ្នកមកនេះ, អ្នកដឹងនូវហេតុណា ចូរនិយាយប្រាប់នូវហេតុនោះ' ដូច្នេះ, បុរសនោះ កាលមិនដឹង ក៏និយាយថា 'ខ្ញុំមិនដឹង' ឬកាលដឹង ក៏និយាយប្រាប់ថា 'ខ្ញុំដឹង' កាលមិនឃើញ ក៏និយាយប្រាប់ថា 'ខ្ញុំមិនឃើញ' ឬកាលឃើញ ក៏និយាយប្រាប់ថា 'ខ្ញុំឃើញ' ដូច្នេះ, ជាអ្នកមិនពោល នូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុ នៃបុគ្គលដទៃក្តី ព្រោះហេតុតែសំណូក គឺអាមិសបន្តិចបន្តួចក្តី, ជាអ្នកលះបង់នូវបិសុណវាចា រៀរស្រឡះចាកបិសុណវាចា គឺពុពាក្យអំពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះផង ពុពាក្យអំពីជនឯណោះហើយ មិនមកប្រាប់ជនទាំងនេះ ដើម្បីបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាហើយផង ជាអ្នកទំនុកបំរុងនូវពួកជន ដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរតែក្នុងសេចក្តីព្រមព្រៀង

ត្នា ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយ
តែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកពោលនូវវាចា ដែលធ្វើឲ្យកើត
សេចក្តីព្រមព្រៀងគ្នា ដោយប្រការដូច្នេះ, ជាអ្នកលះបង់ផរុសវាចា
វៀរស្រឡះចាកផរុសវាចា គឺវាចាណាមិនមានទោស ជាសុខដល់
ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជា
វាចាអ្នកបុរី ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជន
ច្រើន ជាអ្នកពោលនូវវាចាមានសភាពដូច្នោះ, ជាអ្នកលះបង់នូវ
សម្ជប្បលាបៈ វៀរស្រឡះចាកសម្ជប្បលាបៈ ពោលពាក្យត្រូវតាម
កាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែល
ជាធម៌ ពោលពាក្យជាវិន័យ ជាអ្នកពោលពាក្យ ដែលគួរឲ្យតាំងទុក
ក្នុងហឫទ័យ ត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមាន
ទីបំផុត ប្រកបដោយប្រយោជន៍, ម្នាលព្រាហ្មណ៍និងគហបតីទាំង
ឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចា
មាន ៤ ប្រការ យ៉ាងដូច្នេះឯង ។ ម្នាលព្រាហ្មណ៍និងគហបតីទាំង
ឡាយ ក៏កិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយចិត្ត
មាន ៣ ប្រការ តើដូម្តេចខ្លះ ? ។ ម្នាលព្រាហ្មណ៍និងគហបតីទាំង
ឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនច្រើនដោយអភិជ្ឈា,
គ្រឿងឧបករណ៍ដែលជាសម្បត្តិ នៃបុគ្គលដទៃឯណា, ក៏ជាអ្នកមិន

គយគន់នូវគ្រឿងឧបករណ៍នោះថា 'ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិ នៃបុគ្គលដទៃឯណា, គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ' ដូច្នេះឡើយ, មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្ត ដែលទោសមិនប្រទូស្តហើយថា 'សត្វទាំងឡាយនេះ ចូរកុំមានពៀរ កុំមានព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឱ្យបានសេចក្តីសុខចុះ' ដូច្នេះ, មួយវិញទៀត ជាអ្នកមានគំនិតយល់ត្រូវ ឃើញនូវសេចក្តីមិនវិបរិតថា 'ទានដែលបុគ្គលឱ្យហើយ មានផល, ការបូជាធំមានផល, ការបូជាតូចមានផល, ផលនិងវិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើល្អនិងអាក្រក់មាន, លោកនេះមាន, លោកខាងមុខមាន, មាតាមានគុណ, បិតាមានគុណ, សត្វទាំងឡាយ ដែលជាឧបបាតិកៈកំណើតមាន, ពួកសមណព្រាហ្មណ៍ ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯង នូវលោកនេះនិងលោកខាងមុខ ហើយប្រកាសក៏មាន' ដូច្នេះ, ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ កិរិយាប្រព្រឹត្តិស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយចិត្ត មាន ៣ ប្រការដូច្នេះឯង ។ ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងចូលទៅកាន់សុគតិ សួគ៌ ទេវលោក

យ៉ាងនេះ ព្រោះតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ យ៉ាងដូច្នេះឯង ។ ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ បើបុគ្គលជាអ្នកប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ គប្បីប្រាថ្នាថា 'ឱហ្ន៎ អាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ សូមបានចូលទៅកាន់ភាពជាអ្នកនៅរួមគ្នា ជាមួយនឹងពួកខត្តិយមហាសាលទាំងឡាយ' ដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏បានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានចូលទៅ កាន់ភាពអ្នកជានៅរួមជាមួយគ្នា នឹងខត្តិយមហាសាលទាំងឡាយមែន, សេចក្តីនោះ ព្រោះហេតុដូចម្តេច ? ព្រោះហេតុថាបុគ្គលនោះ ជាអ្នកប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ ។ ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ បើបុគ្គលឯណា ជាអ្នកប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ គប្បីប្រាថ្នាថា 'ឱហ្ន៎ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានចូលទៅកាន់ភាពជាអ្នកនៅរួម ជាមួយនឹងពួកព្រាហ្មណ៍មហាសាល ... ពួកគហបតិមហាសាល ... ពួកទេវតាជាន់ចាតុមហារាជិកា ... ពួកទេវតាជាន់តាវត្តឹង្ស ... ពួកទេវតាជាន់យាមា ... ពួកទេវតាជាន់តុសិត ... ពួកទេវតាជាន់និម្មានរតី ... ពួកទេវតាជាន់បរនិម្មិតវសវត្តី ពួកទេវតាជាន់ព្រហ្មកាយិកា ... ពួកទេវតាជាន់អាភា ... ពួកទេវតា

ជាន់ចវិត្តាភា . . . ពួកទេវតាជាន់អប្បមាណាភា . . . ពួកទេវតាជាន់អាភស្សរា . . . ពួកទេវតាជាន់សុភា . . . ពួកទេវតាជាន់បរិត្តសុភា . . . ពួកទេវតាជាន់អប្បមាណសុភា . . . ពួកទេវតាជាន់សុភកិណ្ហា . . . ពួកទេវតាជាន់វេហប្ផលា . . . ពួកទេវតាជាន់អវិហា . . . ពួកទេវតាជាន់អតប្បា. . . ពួកទេវតាជាន់សុទស្សា . . . ពួកទេវតាជាន់សុទស្សី . . . ពួកទេវតាជាន់អកនិដ្ឋកា . . . ពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនៈ . . .ពួកទេវតាដែលកើត ក្នុងវិញ្ញាណញ្ចាយតនៈ . . .ពួកទេវតាដែលកើត ក្នុងអាកិញ្ចញ្ញាយតនៈ . . . ពួកទេវតាដែលកើត ក្នុងនេវសញ្ញានាសញ្ញាយតនៈ ដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះលុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយគ្នានឹងពួកទេវតាទាំងឡាយ ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈមែន, សេចក្តីនោះ ព្រោះហេតុដូចម្តេច ? ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ ។ ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ បើបុគ្គលជាអ្នកប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ គប្បីប្រាថ្នាថា ‘ឱហ្ន៎ ខ្លួនអាត្មាអញ សូមធ្វើឱ្យបានជាក់ច្បាស់ហើយ សម្រេចចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលគ្មានអាសវៈ ព្រោះការអស់ទៅ នៃអាសវៈទាំងឡាយ ដោយប្រាជ្ញាចំពោះខ្លួនឯង

ក្នុងបច្ចុប្បន្ននេះនុ៎ះឯង ដូច្នេះ, ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ គប្បីធ្វើឱ្យជាក់ច្បាស់ហើយ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅ នៃអាសវៈទាំងឡាយ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ននេះ, សេចក្តីនោះ ព្រោះហេតុដូចម្តេច ? ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តតាមធម៌ ជាអ្នកប្រព្រឹត្តស្មើ" ។

ចប់ ។

(អដ្ឋកថា)

(៥៦) នយដែលមកក្នុងអដ្ឋកថាទុកនិបាត អង្គុត្តរនិកាយ ថា "បទថា '**ធម្មចរិយសមចរិយហេតុ**' គឺ មានការប្រព្រឹត្តិស្មើស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌ជាហេតុ, អធិប្បាយថា 'ព្រោះហេតុនៃការប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌នោះ បានដល់ មានការប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌នោះជាបច្ច័យ" ។

អដ្ឋកថាសាលេយ្យកសូត្រ ថា "បទថា '**តិវិធំ**' គឺ ដោយចំណែកទាំងឡាយ ៣ ។ បទថា '**កាយេន**' គឺ ដោយកាយទ្វារ"។

នយដែលមក ក្នុងអដ្ឋកថាសាលេយ្យកសូត្រ និង ទុកនិបាត អង្គុត្តរនិកាយ ថា " កិរិយាប្រព្រឹត្តិស្មើស្មើ ឬកិរិយាប្រព្រឹត្តិនូវកម្ម

ដែលត្រឹមត្រូវ ព្រោះហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តិស្មើ ។ ការប្រព្រឹត្តិតាមធម៌ និង ការប្រព្រឹត្តិស្មើនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តិតាមធម៌ និង ការប្រព្រឹត្តិស្មើ, អធិប្បាយថា 'កិរិយាប្រព្រឹត្តិស្មើ ពោលគឺកិរិយាប្រព្រឹត្តិតាមធម៌ "។

(៥៧) អដ្ឋកថាចូឡហត្ថិបទោបមសូត្រ ក្នុងតតិយវគ្គ នៃមូលបណ្ណាសកៈ និង អដ្ឋកថាចតុត្ថបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយថា "២បទថា **'បាណាតិបាតំ បហាយ'** គឺ លះបង់ភាពនៃទោសគ្រឿងទ្រុស្តសីល ពោលគឺចេតនា ដែលញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ។ បទថា **'បដិវិរតោ'** មានសេចក្តីថា រមែងជាអ្នកវៀរចាក គឺវៀរស្រឡះ ចាកភាពជាអ្នកមានទោសនៃគ្រឿងទ្រុស្តសីលនោះ ចាប់ដើមអំពីពេលដែលខ្លួនលះបង់ហើយ ។ ២ បទថា **'និហិតទណ្ឌោ និហិតសត្ថោ'** មានសេចក្តីថា ឈ្មោះថាជាអ្នកមានដំបងទម្លាក់ចោលហើយ និង ជាអ្នកមានសស្ត្រាវុធទម្លាក់ចោលហើយ ព្រោះមិនប្រព្រឹត្តកាន់យកនូវដំបង ឬ សស្ត្រាវុធដើម្បីប្រយោជន៍ ដល់ការចូលទៅសម្លាប់សត្វដទៃ ។ ក៏គ្រឿងឧបករណ៍ដែលសេសសល់ទាំងអស់ លើកលែងតែដំបងចេញ គប្បីជ្រាប ថា 'សស្ត្រា' ក្នុងបទថា **'និក្ខិត្តសត្ថោ'** នេះ ព្រោះជាគ្រឿងបៀតបៀននូវសត្វទាំងឡាយ ។ ប៉ុន្តែថា ពួកភិក្ខុទាំងឡាយ

កាន់យកនូវឈើច្រត់ របស់មនុស្សចាស់ក្តី ឈើជម្រះធ្មេញក្តី កាំបិតព្រាក្តី កាំបិតបត់ក្តីឯណាមួយ ស្រាច់ចរទៅ, វត្ថុមានឈើច្រត់ជាដើមនោះ មិនចាត់ថាជារបស់សម្រាប់បៀតបៀនបុគ្គលដទៃឡើយ, ព្រោះហេតុនោះ ភិក្ខុទាំងនោះ រមែងដល់នូវការរាប់ថា 'ជាអ្នកមានដំបងទម្លាក់ចុះហើយ មានសស្ត្រាវុធទម្លាក់ចុះហើយមែនពិត' ។ បទថា '**លដ្ឋី**' គឺ ជាអ្នកប្រកបដោយសេចក្តីអៀនខ្មាស ដែលមានការខ្ពើមរអើមបាបជាលក្ខណៈ ។ បទថា '**ទយាបន្នោ**' គឺ ដល់នូវសេចក្តីអាណិត បានដល់ នូវភាពជាអ្នកមានចិត្តមេត្តា ។ បទថា '**សព្វប្បាណភូតហិតានុកម្បី**' គឺ ជាអ្នកអនុគ្រោះពួកសត្វទាំងពួងដោយប្រយោជន៍សុខ, អធិប្បាយថា 'ឈ្មោះថា ជាអ្នកមានចិត្តប្រកបដោយប្រយោជន៍ ដល់ពួកសត្វទាំងឡាយទាំងពួង ព្រោះជាអ្នកមានសេចក្តីអាណិតនោះឯង ។ បទថា '**វិហរតិ**' គឺ រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ បានដល់ ចិញ្ចឹមជីវិត" ។

(៥៨) អដ្ឋកថាសាលេយ្យកសូត្រ ថា " ពាក្យថា '**ឃនំ បរស្ស**' គឺ ទ្រព្យដែលជារបស់អ្នកដទៃឯណានីមួយ ។ បទថា '**បរវិត្តូបករណំ**' គឺ វត្ថុជាឧបករណ៍ ដល់ទ្រព្យគ្រឿងពេញចិត្ត បានដល់ ទ្រព្យសម្បត្តិដែលជាបរិក្ខារ ដែលញុំាងសេចក្តីត្រេកអរឱ្យកើតឡើង របស់បុគ្គលដទៃនោះឯង ។ បទថា '**គាមគតំ វា**'

គឺ ដែលបុគ្គលតាំងទុកខាងក្នុងនៃស្រុកក្តី ។ បទថា **'អរញ្ញគតំ វា'** គឺ ដែលបុគ្គលដាក់ទុក ក្នុងព្រៃ គឺ ក្នុងទីទាំងឡាយ មានបង្គាបនៃដើមឈើនិងលើកំពូលភ្នំជាដើម ។ បទថា **'អទិន្នំ'** គឺ ដែលបុគ្គលទាំងឡាយដទៃនោះ មិនបានឲ្យហើយ ដោយកាយឬដោយវាចា ។ ក្នុងបទថា **'ថេយ្យសង្ខាតំ'** នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ ចោរ បុគ្គលហៅថា អ្នកលួច, ភាពនៃបុគ្គលអ្នកលួច ឈ្មោះថា ភាពនៃចោរ ។ បទថា **'ថេយ្យំ'** នុ៎ះ ជាឈ្មោះនៃចិត្ត ដែលជាគ្រឿងលួច ។ បទថា **'សង្ខាតំ'** នុ៎ះ ដោយសេចក្តី ជាឈ្មោះនៃចំណែកមួយ ដូចជា **សង្ខាត** សព្ទ ក្នុងខទាហរណ៍ទាំងឡាយថា 'ក៏ចំណែក នៃធម៌គ្រឿងយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ' ដូច្នេះជាដើម ។ ចំណែកនោះផង ភាពនៃចិត្តលួចផង ព្រោះហេតុនោះ ទើបឈ្មោះថា **ថេយ្យសង្ខាតំ**, អធិប្បាយថា 'ចំណែកនៃចិត្តមួយ ដែលជាចំណែកនៃចិត្តលួច" ។ ក៏ពាក្យថា **'ថេយ្យសង្ខាតំ'** នុ៎ះ ជាបឋមាវិភ័ត្តិ ចុះក្នុងអត្ថនៃតតិយាវិភ័ត្តិ, ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញ ដោយសេចក្តីថា 'ដោយចំណែកនៃចិត្តលួច' ។ បទថា **'មាតុរក្ខិតា'** មានសេចក្តីថា មាតាប្រតិបត្តិស្ត្រីណា, កាលបើបិតាបាត់បង់ទៅក្តី ស្លាប់ចោលហើយក្តី, ដោយសង្គហវត្ថុទាំងឡាយមានអាហារនិងគ្រឿងស្លៀកពាក់ជាដើម ថែរក្សា ដោយតាំង

ចិត្តថា 'អាត្មាអញ នឹងឱ្យនូវធីតារបស់អាត្មាអញ ដែលចំរើនវ័យហើយ ក្នុងផ្ទះនៃត្រកូល' ដូច្នេះ, ស្ត្រីនេះ ឈ្មោះថា ស្ត្រីដែលមាតារក្សាហើយ ។ សូម្បីស្ត្រីដែលបិតារក្សាជាដើម បណ្ឌិតក៏គប្បីជ្រាបដោយនុបាយនុ៎ះ ។ ចំណែកត្រកូលទាំងឡាយ, សូម្បីកាលបើពួកសត្វដែលកើតក្នុងគ៌ភ កើតហើយក្នុងផ្ទៃពោះ, ក៏ធ្វើកតិកាគ្នាថា 'បើខ្ញុំមានកូនប្រុស, អ្នកមានកូនស្រី, ធីតារបស់អ្នក នឹងមិនបានដើម្បីនឹងទៅក្នុងត្រកូលដទៃ, ចូរបានដល់កូនប្រុសរបស់ខ្ញុំ' ដូច្នេះ, ស្ត្រីដែលមាតានិងបិតា បានដណ្តឹងទុកហើយ សូម្បីក្នុងផ្ទៃពោះយ៉ាងនេះ ឈ្មោះថា ស្ត្រីដែលមានស្វាមី ។ មួយទៀត ស្ត្រីដែលមានអាជ្ញា ដែលឥស្សរជនមានព្រះរាជាជាដើម បានតាំងទុកផ្តោតចំឈ្មោះក្តី ផ្ទះក្តី ផ្លូវផ្តល់ក្តី យ៉ាងនេះថា 'បុរសណា កន្តងនូវស្ត្រីអ្នកមានឈ្មោះយ៉ាងនេះ, អាជ្ញាមានប្រមាណប៉ុណ្ណោះ នឹងមានដល់បុរសនោះ' ដូច្នេះ ឈ្មោះថា ស្ត្រីដែលមានអាជ្ញាជុំវិញខ្លួន ។ ២ បទថា **'អន្តមសោ មាលាគុឡបរិក្ខិត្តាបិ'** មានសេចក្តីថា ដោយកំណត់ទីបំផុតនៃកំណត់ទាំងពួង ស្ត្រីដែលបុរសខ្លះ បោះផ្កាកម្រងទៅពួតខ្ទង់លើក្បាលនៃស្ត្រីនោះ ដោយសំគាល់ថា 'ស្ត្រីនេះជាភរិយារបស់ខ្ញុំ' ដូច្នេះ បំពាក់ សូម្បីដោយវត្តុត្រឹមតែកម្រងផ្កាឱ្យ ។ ច្រើនបទ បទ **'តថារូបាសុ ចារិត្តំ អាបជ្ជិតា'** មានសេចក្តីថា រមែងជា

អ្នកធ្វើការល្មើស ក្នុងស្ត្រីបែបនោះ ដោយអំណាចលក្ខណៈនៃមិច្ឆាចារ ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងសម្មាទិដ្ឋិសូត្រ ។ បទថា **'សភគ្គតោ'** គឺ នៅហើយក្នុងរោងសភា ។ បទថា **'បរិសគ្គតោ'** គឺ នៅហើយក្នុងបរិស័ទនៃអ្នកស្រុក ។ បទថា **'ញាតិមជ្ឈគតោ'** គឺ នៅហើយក្នុងកណ្តាលនៃបុគ្គលអ្នកទទួលទ្រព្យមតកទាំងឡាយ ។ បទថា **'បូគមជ្ឈគតោ'** គឺ នៅហើយក្នុងកណ្តាល នៃសេនាទាំងឡាយ ។ បទថា **'រាជកុលមជ្ឈគតោ'** គឺ នៅហើយក្នុងកណ្តាលរាជត្រកូល បានដល់ ក្នុងរោងវិនិច្ឆ័យដ៏ធំ ។ បទថា **'អភិនីតោ'** គឺ ត្រូវគេនាំទៅ ដើម្បីនឹងដណ្តឹងសួរ ។ ២ បទថា **'សក្ខឹ បុដ្ឋោ'** គឺ ត្រូវគេអាងធ្វើជាសាក្សីហើយចោទសួរ ។ ពាក្យថា **'ឯហម្ភោ បុរិសា'** នុ៎ះ គឺជាពាក្យអាលបនៈ ។ ពាក្យថា **'អត្តហេតុ វា បរហេតុ វា'** មានសេចក្តីថា ព្រោះហេតុនៃអវយវៈ មានដៃនិងជើងជាដើម ឬព្រោះហេតុនៃទ្រព្យ របស់ខ្លួនឬរបស់អ្នកដទៃ ។ ក្នុងបទថា **'អាមិសកិញ្ចិក្ខហេតុ វា'** នេះ លោកព្រះមានព្រះភាគទ្រង់ត្រាស់អធិប្បាយហើយ ។ បទថា **'កិញ្ចិក្ខំ'** គឺ វត្ថុណានីមួយ បានដល់ វត្ថុបន្តិចបន្តួច ។ អធិប្បាយថា 'ព្រោះហេតុនៃថ្លៃឈ្នួលដោយហោចទៅ សូម្បីវត្ថុបន្តិចបន្តួច មានសត្វទទា សត្វក្រួច ទឹកដោះរាវថ្លាមួយពែង និងទឹកដោះខាប់មួយដុំជាដើម ។ បទថា

'**សម្បជានមុសាភាសិតា**' គឺជាអ្នកដឹងខ្លួនន៎ុះឯង ធ្វើការពោលពាក្យកុហក ។ ២ បទថា '**ឥមេសំ ភេទាយ**' គឺ ខ្លួនស្តាប់ពាក្យក្នុងសំណាក់នៃពួកជនណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា '**ឥតោ**' ដូច្នេះ, ដើម្បីបំបែកជនទាំងឡាយនោះ ។ ២ បទថា '**អមូសំ ភេទាយ**' គឺ ខ្លួនបានស្តាប់ពាក្យ ក្នុងសំណាក់ នៃជនទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា '**អមុត្រ**' ដូច្នេះ, ដើម្បីបំបែកបំបាក់ជនទាំងឡាយនោះ "។

(៥៩) អដ្ឋកថាហាត្ថិបទោបមសូត្រជាដើមថា "ច្រើនបទថា '**ភិន្នានំ វា សន្ធាតា**' មានសេចក្តីថា កាលថើជនទាំងឡាយ ២ ពួកដែលជាមិត្រនឹងគ្នា ឬជាអ្នកជាប់ទាក់ទងគ្នា មានរួមព្រះឧបជ្ឈាយ៍ជាមួយគ្នាជាដើម បែកបាក់គ្នាហើយ ដោយហេតុឯណានីមួយន៎ុះឯង, បុគ្គលអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ចូលទៅរកពួកមួយៗ ហើយ និយាយធ្វើសេចក្តីផ្សះផ្សាគ្នាឡើងវិញ មានជាអាទិ៍ថា 'រឿងយ៉ាងដូច្នេះ មិនសមគួរ ដល់ពួកអ្នកទាំងឡាយ ដែលកើតក្នុងត្រកូលយ៉ាងនេះ ជាពហុស្សូត យ៉ាងដូច្នេះសោះឡើយ' ដូច្នេះ ។ បទថា '**អនុប្បទាតា**' គឺ ជាអ្នកទំនុកបំរុងនូវពួកជនដែលផ្សះផ្សាគ្នាហើយ, អធិប្បាយថា 'ធម្មចារិសមចារីបុគ្គល ឃើញជនទាំង ២ ពួក មានការព្រមព្រៀង សាមគ្គីគ្នាហើយ និយាយធ្វើឲ្យបានរឹងប៉ឹងមាំមួន

មានជាអាទិ៍ថា 'កិច្ចការនេះ ជាកិច្ចការសមគួរហើយ ដល់ពួកអ្នកទាំងឡាយ ដែលកើតក្នុងត្រកូលយ៉ាងនេះ អ្នកដល់ព្រម ដោយគុណបែបនេះ' ដូច្នេះ ។ សេចក្តីសាមគ្គី ជាទីមកត្រេកអរមានដល់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានសេចក្តីសាមគ្គីជាទីមកត្រេកអរ, អធិប្បាយថា 'ពួកជនអ្នកសាមគ្គីគ្នា មិនមាន ក្នុងទីណា, ធម្មចារិសមចារីបុគ្គល រមែងមិនប្រាថ្នា សូម្បីដើម្បីនឹងរស់នៅ ក្នុងទីនោះឡើយ' ។ បាលីថា '**សមគ្គរាមោ**' ដូច្នេះក៏មានខ្លះ ។ សេចក្តីក៏មានន័យដូចគ្នាដែរ ។ បទថា '**សមគ្គរតោ**' គឺ ជាអ្នកត្រេកអរហើយ ក្នុងពួកជនដែលព្រមព្រៀងគ្នាហើយ, អធិប្បាយថា 'ធម្មចារិសមចារីបុគ្គល រមែងមិនប្រាថ្នា សូម្បីដើម្បីនឹងលះបង់ចោលនូវពួកជនអ្នកព្រមព្រៀងគ្នាហើយទាំងនោះ ហើយទៅ ក្នុងទីដទៃទៀតឡើយ' ។ ឈ្មោះថា ជាអ្នកត្រេកអរ ក្នុងពួកជនដែលព្រមព្រៀងគ្នាហើយ ព្រោះវិគ្រោះថា 'ធម្មចារិសមចារីបុគ្គល បានឃើញក្តី បានស្តាប់ក្តី នូវពួកជនអ្នកព្រមព្រៀងគ្នាហើយ រមែងត្រេកអរ' ។ ពាក្យថា '**សមគ្គករណី វាចំ ភាសិតា**' មានសេចក្តីថា វាចាឯណាមួយ តែងធ្វើនូវសត្វទាំងឡាយ ឱ្យជាអ្នកមានការព្រមព្រៀងគ្នាឡើងវិញ, ធម្មចារិសមចារីបុគ្គល រមែងពោលនូវវាចានោះ ដែលជាវាចាសំដែងគុណនៃសេចក្តីសាមគ្គីគ្នា តែម្យ៉ាងប៉ុណ្ណោះ,

តែងមិនពោល នូវវាចាផ្សេងទៀតក្រៅអំពីនេះឡើយ" ។

(៦០) អដ្ឋកថាសាលេយ្យកសូត្រ និងនិក្ខេបកណ្ឌថា "ពាក្យថា **'ផរុសំ វាចំ បហាយ'** មានសេចក្តីថា វាចាឯណានីមួយជាវាចាគ្រោតគ្រាត រឹងត្អឹង ក្តៅក្រហាយដល់អ្នកដទៃ ប៉ះទង្គិចដល់បុគ្គលដទៃ ជិតដល់សេចក្តីក្រោធខឹង មិនប្រព្រឹត្តទៅដើម្បីសមាធិ, លះបង់ចោលនូវវាចាបែបនោះ ។ បណ្តាវាចាទាំងនោះ វាចាគ្រោតគ្រាត ដោយពាក្យជេរប្រទេច និង ពាក្យជិះជាន់សង្កត់សង្កិនជាដើម ព្រោះជាវាចាដែលមានទោស ប្រៀបដូចជាក្រម៉ ដែលកើតឡើង លើដើមឈើដែលមានស្នាមជំពៅយ៉ាងដូច្នោះឯង ឈ្មោះថា វាចាគ្រោតគ្រាតដូចជាដុំក្រម៉ ។ ពាក្យពោលអាក្រក់ ឈ្មោះថា វាចារឹងត្អឹង ។ វាចាអាក្រក់នោះ ជាវាចាដែលរឹងរូស ដូចជាចូលទៅមុតនូវក្រចៀក ប្រៀបឧបមាដូចជាដើមឈើ ដែលស្មុយជាឈើរឹង មានល្អងកំទេចធ្លាក់ចេញដូច្នោះ, ព្រោះហេតុនោះ ទើបលោកពោលថា 'ជាវាចារឹងត្អឹង' ដូច្នេះ ។ វាចាក្តៅក្រហាយ គឺវាចាមិនជាទីពេញចិត្ត ដល់បុគ្គលទាំងឡាយដទៃ ជាវាចាដែលញុំងទោសឲ្យកើតឡើង ដល់បុគ្គលទាំងឡាយឯទៀត ឈ្មោះថាជាវាចាធ្វើឲ្យក្តៅក្រហាយដល់បុគ្គលដទៃ ។ វាចាដែលប៉ះទង្គិច ដល់ជនទាំងឡាយដទៃ គឺវាចាដែលធ្វើសេចក្តីថ្នាំងថ្នាក់ចិត្ត មិនឲ្យដើម្បីនឹង

ទៅ សូម្បីដល់បុគ្គលទាំងឡាយ អ្នកដែលប្រាថ្នានឹងធ្វើដំណើរទៅបាន ឡើយ ព្រោះចាក់ដោត ក្នុងវត្ថុដែលជាទីស្រឡាញ់ទាំងឡាយ ឧបមា ដូចជាចុងបន្លាដែលកោងដូច្នោះ ឈ្មោះថា វាចាប៉ះទង្គិចដល់បុគ្គល ដទៃ ។ វាចាដែលជិតដល់សេចក្តីក្រោធខឹង ឈ្មោះថា វាចាជិតដល់ សេចក្តីក្រោធ ។ វាចាដែលមិនប្រព្រឹត្តទៅ ដើម្បីអប្បនាសមាធិ ឬឧបចារសមាធិ ឈ្មោះថា វាចាដែលមិនប្រព្រឹត្តទៅដើម្បីសមាធិ ។ ពាក្យទាំងឡាយទាំងពួង មានពាក្យថា '**អណ្ហកា**' ជាដើម នេះឯង ជាពាក្យវេវចនៈ នៃវាចាដែលមិនមានទោស យ៉ាងដូច្នេះឯង" ។

(៦១) អដ្ឋកថានៃសូត្រមានចូឡហត្ថិបទោបមសូត្រជាដើម ថា " ក្នុងបទថា '**នេឡា**' ដូច្នេះ ទោស លោកហៅថា **នេឡំ**, ទោស របស់វាចានោះ មិនមាន ហេតុនោះ វាចានោះ ឈ្មោះថា វាចាមិនមានទោស, អធិប្បាយថា ជាវាចាដែលគ្មានទោស ។ បទថា '**នេឡា**' នោះ ប្រៀបដូចជា **នេឡ** សព្ទ ដែលព្រះមានព្រះ ភាគទ្រង់ត្រាស់ហើយ ក្នុងគាថានេះថា '**នេឡង្គោ សេតបច្ឆាទោ**' ដូច្នេះជាដើម ។ វាចា ឈ្មោះថានាំសេចក្តីសុខមកដល់ត្រចៀក គឺមិន ញ៉ាំងសេចក្តីចាក់ដោតដល់ត្រចៀក ដូចជាត្រូវម្ជុលចាក់ដោត ឲ្យកើត ឡើង ព្រោះជាវាចាដែលពីរោះដោយព្យញ្ជនៈ ឈ្មោះថា ជាវាចា ដែលសប្បាយដល់ត្រចៀក ។ វាចាណា មិនញ៉ាំងសេចក្តីក្រោធ

ខឹងឲ្យកើតឡើង ញុាំងសេចក្តីស្រឡាញ់ឲ្យកើតឡើង ក្នុងសរីរៈរាងកាយទាំងមូល ព្រោះជាវាចាដែលពីរោះដោយសេចក្តី ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា ជាវាចាដែលគួរឲ្យកើតសេចក្តីស្រឡាញ់ ។ ឈ្មោះថា ជាវាចាចូលទៅដល់ហឫទ័យ ព្រោះវិគ្រោះថា 'វាចានោះ រមែងដល់នូវហឫទ័យ គឺមិនប៉ះទង្គិច ចូលទៅដល់ចិត្ត ដោយសប្បាយ' ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះថា 'វាចានោះ មាននៅក្នុងក្រុង ព្រោះជាវាចាដែលបរិបូណ៌ដោយគុណ' ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះថា 'វាចានោះ ជាវាចាដ៏ទន់ភ្លន់ ប្រៀបដូចជានារីដែលចំរើន ក្នុងបុរី' ដូច្នេះខ្លះ ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវិគ្រោះថា 'វាចានោះ ជាវាចារបស់អ្នកទីក្រុង' ដូច្នេះក៏មាន ។ ២ បទថា **'បរស្ស ឯសា'** មានសេចក្តីថា ជាវាចារបស់អ្នកនគរទាំងឡាយ ។ ព្រោះថា អ្នកនគរទាំងឡាយ រមែងជាអ្នកមានវាចាដ៏សមគួរ គឺ តែងហៅនូវបុគ្គលអ្នកល្មមសមជាបិតាបានថា 'បិតា' អ្នកល្មមសមជាមាតាបានថា 'ជាមាតា' អ្នកល្មមសមជាបងប្អូនបានថា 'ជាបងប្អូន' ដូច្នេះ ។ ឈ្មោះថា ជាវាចាជាទីស្រឡាញ់ ដល់ជនច្រើន ព្រោះវិគ្រោះថា 'វាចាបែបនេះឯង រមែងជាវាចា ដែលជនច្រើនស្រឡាញ់' ។ ឈ្មោះថា ជាវាចាជាទីពេញចិត្ត ដល់ជនច្រើន ព្រោះវិគ្រោះថា

'វាចានោះ ជាវាចាជាទីពេញចិត្ត គឺ ធ្វើសេចក្តីចំរើននៃចិត្ត ដល់ជនច្រើន ព្រោះជាវាចាដែលជនច្រើនពេញចិត្ត" ។

(៦២) បទថា "**សមុប្បណ្ណាបំ**" មានសេចក្តីថា វាចាណានីមួយ ជាវាចាមិនមានព័ស្តុតាង មិនមានទីអាងដល់ មិនមានទីបំផុត មិនប្រកបដោយប្រយោជន៍, លះបង់នូវវាចាបៃបនោះចោល" ។

(ព្រះធម្មកថិកពួរជ្រៃ)

ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាសាលេយ្យកសូត្រ ថា "បទថា '**អនិធានវតី**' គឺ នូវវាចាដែលមិនសមគួរ ដើម្បីនឹងកប់ទុក ក្នុងហិរ គឺហឫទ័យបានឡើយ ។ បទថា '**អនបទេសំ**' គឺ ប្រាសចាកទីអាងដល់ ពោលគឺសូត្រ ។ បទថា '**អបរិយន្តវតី**' គឺ នូវវាចាដែលមិនមានកំណត់ ។ ព្រះធម្មកថិក លើកឡើងនូវសូត្រឬជាតកហើយ នាំមកនូវឧបារម្ភកថា ឬឧបមា ឬក៏រឿង នៃសូត្រ ឬ ជាតកនោះហើយ ក៏ត្រឡប់ទៅជាសំដែងរឿងខាងក្រៅវិញ, សូត្រឬជាតក ដែលព្រះធម្មកថិកនោះ លើកឡើងហើយ ក៏គ្រាន់តែបានលើកយកមកប៉ុណ្ណោះឯង, ព្រះធម្មកថិកនោះ រមែងដល់នូវភាពជាអ្នកដែលជនទាំងឡាយ គប្បីពោលថា 'ព្រះធម្មកថិករូបនេះ សំដែងនូវសូត្រអ្វីហ្ន៎ ? នូវជាតកអ្វីហ្ន៎ ?, ពួកយើងទាំង

ឡាយ មិនឃើញនូវទីបំផុត ឬចុងផុត នៃសូត្រ ឬ ជាតកនោះសោះឡើយ ដូច្នេះ ។ ពួរជ្រៃទាំងឡាយ រមែងលូតចុះមក ក្នុងទីនៃមែកជ្រៃទាំងឡាយលូតលាស់ទៅហើយ ។ ដល់ក្នុងទីកន្លែងដែលខ្លួនលូតលាស់ចុះហើយ ។ រមែងលូតលាស់ចំរើនឡើងជាថ្មីម្តងទៀត ដូចដើម, ដើមជ្រៃទាំងឡាយ រមែងដុះធំរាលទៅ ។ ដោយប្រការដូច្នេះឯង រហូតដល់កន្លះយោជន៍ខ្លះ ១ យោជន៍ខ្លះ, ក៏កាលបើកាលវេលាកន្លងផុតទៅ ។, ដើមចាស់ ក៏រមែងវិនាសស្លាប់ទៅ, ពន្លកថ្មីទាំងឡាយនុ៎ះឯង ក៏រមែងដុះឡើង យ៉ាងណាមិញ, ចំណែកព្រះធម្មកថិកពួរជ្រៃនេះ ក៏ដូច្នោះដែរ រមែងឈ្មោះថា ជាព្រះធម្មកថិកពួរជ្រៃ ព្រះធម្មកថិកនេះ រមែងធ្វើនូវសូត្រឬជាតកដែលខ្លួនលើកឡើងហើយ ឱ្យគ្រាន់តែខ្លួនលើកឡើងហើយប៉ុណ្ណោះឯង ហើយក៏គេចបង្វាងទៅ ដោយខាងៗវិញ ។ ក៏ព្រះធម្មកថិករូបណាសូម្បីពោលពាក្យយ៉ាងច្រើន ក៏អាចដើម្បីនឹងលើកទាញយកមកឱ្យជនទាំងឡាយយល់បានថា 'ព្រះសូត្រនេះ មានសេចក្តីយ៉ាងនេះ' ដូច្នេះ, កិរិយាសំដែង របស់ព្រះធម្មកថិករូបនោះ ទើបសមគួរ ។ បទថា **'អនត្ថសញ្ហិតំ'** គឺ មិនអាស្រ័យនូវប្រយោជន៍ឡើយ" ។

(៦៣) អដ្ឋកថាចូឡហត្ថិបទោបមសូត្រជាដើមថា "បុគ្គលឯណា តែងពោល ក្នុងកាល ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា

កាលវាទី, អធិប្បាយថា 'បុគ្គលនោះកំណត់នូវកាលដែលគួរពោលហើយ ទើបពោល'។ បុគ្គលណា រមែងពោលនូវពាក្យពិត គឺពាក្យត្រង់ បានដល់ ពាក្យពិតត្រង់តែម្យ៉ាង ហេតុនោះ បុគ្គលនោះឈ្មោះថា ភូតវាទី។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលអាស្រ័យអត្ថ ព្រោះអត្ថថា 'បុគ្គលនោះ រមែងពោល ធ្វើឲ្យជាពាក្យអាស្រ័យប្រយោជន៍ ដែលជាទិដ្ឋធម្មិកៈ និងសម្បរាយិកៈ តែម្យ៉ាង'។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលអាស្រ័យធម៌ ព្រោះអត្ថថា 'បុគ្គលនោះ រមែងពោល ធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរធម៌ ៩ ប្រការ'។ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលអាស្រ័យវិនัย ព្រោះអត្ថថា 'បុគ្គលនោះ រមែងពោល ធ្វើឲ្យជាពាក្យអាស្រ័យសំវរវិនัย និងបហានវិនัយ'។ ឱកាសដែលជាទីតាំង បណ្ឌិតពោលថាព័ស្តុតាង។ ព័ស្តុតាង នៃវាចានោះ មាន ហេតុនោះ វាចានោះ ឈ្មោះថា ជាវាចាមានព័ស្តុតាង, អធិប្បាយថា 'ធម្មចារិសមចារីបុគ្គល រមែងជាអ្នកពោលនូវវាចា ដែលសមគួរដើម្បីនឹងកប់ទុក ក្នុងហាឫទ័យ'។ បទថា **'កាលេន'** មានសេចក្តីថា ក៏ធម្មចារិសមចារីបុគ្គល សូម្បីកាលពោលនូវពាក្យដូច្នេះ រមែងមិនពោល ដោយកាលមិនគួរទេ ដោយគិតថា 'អាត្មាអញ នឹងពោលពាក្យដែលមានព័ស្តុតាង' ដូច្នេះ, តែពិចារណា នូវកាលដែលសមគួរហើយ ទើបពោល។ បទថា

'**សាបទេសំ**' មានសេចក្តីថា មានឧបមា មានហេតុ ។ បទថា '**បរិយន្តវតី**' មានសេចក្តីថា ការកំណត់នៃវាចានោះ រមែងប្រាកដបាន ដោយប្រការណា, ធម្មចារិសមចារីបុគ្គល រមែងពោលសំដែងហើយ ។ នូវការកំណត់ ដោយប្រការនោះ ។ បទថា '**អត្ថសញ្ហិតំ**' គឺ ឈ្មោះថា ជាវាចាដល់ព្រមដោយប្រយោជន៍ ព្រោះវាចានោះ គឺបុគ្គលអ្នកចំណែក ដោយនិយសូម្បីជាអនេក ក៏មិនគប្បីអាចដើម្បីនឹងឱ្យកំណត់យកបានឡើយ ។ មួយទៀត មានសេចក្តីថា បុគ្គលអ្នកមានប្រក្រតីពោលអត្ថនោះ តែងពោលនូវប្រយោជន៍ណា, ធម្មចារិសមចារីបុគ្គល រមែងពោលនូវវាចាដែលឈ្មោះថា ជាវាចាប្រកបដោយប្រយោជន៍ ព្រោះវាចានោះជាវាចាប្រកបហើយ ដោយប្រយោជន៍នោះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់អធិប្បាយទុកថា 'ធម្មចារិសមចារីបុគ្គល មិនលើកយកពាក្យណាមួយហើយទៅពោលពាក្យដទៃទៀតឡើយ ដូច្នេះ" ។

(៦៤) អដ្ឋកថាភយភេរវសូត្រថា "បទថា '**អភិជ្ឈាលុ**' គឺ ជាអ្នកមានប្រក្រតីសំឡឹងរំពៃ នូវទ្រព្យសម្បត្តិ របស់បុគ្គលដទៃទាំងឡាយ" ។

អដ្ឋកថាសាលេយ្យកសូត្រថា "២ បទថា '**អភិជ្ឈាតា ហោតិ**' គឺ រមែងជាអ្នកក្រឡេកមើលហើយ ដោយកិរិយាសំឡឹងរំពៃ ។

ក៏សព្ទ ក្នុងបទថា '**អហោ វត**' នុ៎ះ ជាសព្ទនិបាត ។ ក៏ការបែកធ្លាយ នៃកម្មបថ ក្នុងមនោកម្មនេះ រមែងមិនមាន ដោយអាការៈត្រឹមតែក្រឡេកមើល ដោយកិរិយាសំឡឹងរំពៃ ។ ប៉ុន្តែ ក្នុងពេលណា បុគ្គលបង្ហោន (នូវភ័ណ្ឌៈរបស់ជនដទៃ) មកដើម្បីខ្លួន ដោយគិតថា 'ធ្វើដូចម្តេចហ្ន៎ ? ទ្រព្យរបស់អ្នកដទៃនេះ គប្បីបានមកជារបស់អញ, អញគប្បីញុំាងអំណាច ឲ្យប្រព្រឹត្តទៅ ក្នុងទ្រព្យរបស់នុ៎ះ' ដូច្នេះ, ពេលនោះ ការបែកធ្លាយកម្មបថ ទើបមាន ។ សេចក្តីនេះ ព្រះមានព្រះភាគ ទ្រង់បានអធិប្បាយហើយ ក្នុងពាក្យថា '**អភិជ្ឈាតា ហោតិ**' នេះ ។ បទថា '**ព្យាបន្នចិត្តោ**' គឺ ជាអ្នកមានចិត្តវិបត្តិហើយ បានដល់ មានចិត្តជាធម្មជាតស្អុយ ។ បទថា '**បទុដ្ឋមនសង្កប្បោ**' គឺ ជាអ្នកមានសេចក្តីត្រិះរិះក្នុងចិត្ត ដែលទោសប្រទូសរ៉ាយហើយ " ។

(៦៥) អដ្ឋកថាភយភេរវសូត្រ ថា " បទថា '**ព្យាបន្នចិត្តោ**' គឺ ឈ្មោះថា ជាអ្នកមានចិត្តវិបត្តិហើយ ព្រោះលះបង់នូវភាវៈនៃចិត្តជាប្រក្រតីចោល ។ ក៏ចិត្តដែលប្រែកបទៅតាមកិលេស រមែងលះបង់ នូវភាពនៃចិត្តជាប្រក្រតីចោល, រមែងជាចិត្តស្អុយ ប្រៀបដូចជាបាយនិងសម្លដែលផ្អូមដូច្នោះ ។ បទថា '**បទុដ្ឋមនសង្កប្បោ**' គឺ ជាអ្នកមានសេចក្តីត្រិះរិះ ក្នុងចិត្ត ត្រូវទោសប្រទូសរ៉ាយហើយ

បានដល់ ជាអ្នកប្រកបព្រមហើយ ដោយសេចក្តីត្រិះរិះក្នុងចិត្ត ដែលមិនចំរើន គឺ ដែលធ្វើសេចក្តីវិនាសឲ្យកើតឡើង ដល់ពួកជនដទៃ"។

ពាក្យថា "**អនភិជ្ឈាលុ**" ជាដើម បណ្ឌិតគប្បីកាន់យក ដោយបដិបក្ខនัย នឹងពាក្យដែលខ្ញុំពោលហើយ ។

ក៏ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាបដិសម្ភិទាមគ្គ ថា "បទថា '**អវេរា**' គឺ វៀរចាកពៀរវេរាហើយ ។ បទថា '**អព្យាបជ្ឈា**' គឺ វៀរចាកព្យាបាទ ។ បទថា '**អនីឃា**' គឺ មិនមានសេចក្តីទុក្ខ ។ បាលីថា '**អនីឃា**' ដូច្នេះក៏មាន ។ ពាក្យថា '**សុខី អត្តានំ បរិហរន្តុ**' មានសេចក្តីថា សត្វទាំងឡាយ ចូរជាអ្នកមានសេចក្តីសុខ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅចុះ ។ បណ្ឌិតគប្បីជ្រាបសម្ពន្ធ នៃពាក្យ ក្នុងបទថា '**អវេរា**' ជាដើមនោះ យ៉ាងដូច្នេះថា 'ក៏ព្រះសារីបុត្រ សំដែងភាពជាអ្នកមិនមានពៀរវេរា ព្រោះអាស្រ័យពួកជនដទៃ ដែលជាប់ទាក់ទងនឹងខ្លួន និងព្រោះអាស្រ័យពួកជនដទៃក្រៅពីនេះ ដែលជាប់ទាក់ទងនឹងជនដទៃ ដោយបទថា '**អវេរា**' ដូច្នេះ ។ សំដែងសេចក្តីមិនមានការអាក់អន់ចិត្ត ដែលមានការមិនមានពៀរវេរានោះ ជាមូលហេតុ ព្រោះការមិនមានពៀរវេរា ដោយបទថា '**អព្យាបជ្ឈា**' ។ សំដែងការមិនមានសេចក្តីទុក្ខ ដែលមានការមិនអាក់អន់ចិត្តនោះជាមូល ព្រោះមិនមានការ

អាក់អន់ចិត្ត ដោយបទថា 'អនីឃា'។ សំដែងការបរិហារអត្តភាព ដោយសេចក្តីសុខ ព្រោះមិនមានសេចក្តីទុក្ខ ដោយបទថា 'សុខី អត្តានំ បរិហរន្តុ' ដូច្នេះ"។

(៦៦) នយមកហើយ ក្នុងអដ្ឋកថាសល្លេខសូត្រថា "កិរិយា ឃើញ ត្រឹមត្រូវ គឺល្អប្រពៃ ដែលវិញ្ញូជនសរសើរហើយ របស់បុគ្គលនោះ មាន ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានការយល់ឃើញត្រឹមត្រូវ, មានសេចក្តីអធិប្បាយថា 'បុគ្គលជាសម្មាទិដ្ឋិក៍នោះ ជាអ្នកប្រកបព្រមហើយ ដោយទិដ្ឋិដែលជាកម្មស្សកតាញ្ញាណ មានឃើញថា 'ទានដែលបុគ្គលឲ្យហើយ មានផល' ដូច្នេះជាដើម ដែលរាប់បញ្ចូលក្នុងកម្មបថ និងដោយទិដ្ឋិដែលសម្បយុត្ត ដោយមគ្គដែលរាប់បញ្ចូល ក្នុងសេចក្តីត្រឹមត្រូវទៀងទាត់"។

អដ្ឋកថាសាលេយ្យកសូត្រ និងអដ្ឋកថាតតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយថា "បុគ្គលជាអ្នកមានសេចក្តីយល់ឃើញខុស ពោលសំដៅយក នូវការមិនមានផល នៃទានថា 'នត្ថិ ទិន្នំ' ដូច្នេះ។ មហាយញ្ញ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា យិដ្ឋំ។ សក្ការៈដែលបុគ្គលគប្បីធ្វើដល់ភ្ញៀវ ព្រះអង្គត្រាស់អធិប្បាយហើយ ក្នុងបទថា 'ហុតំ'។ មិច្ឆាទិដ្ឋិកបុគ្គល សំដៅយកនូវមហាយញ្ញ និងយញ្ញតូចទាំង ២ យ៉ាងនោះថា មិនមានផលពិត ទើបបានហាម។

បទថា **'សុកតទុក្កដានំ'** មានសេចក្តីថា នៃកម្មដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់ទាំងឡាយ គឺ នៃកុសលកម្មនិងអកុសលកម្មទាំងឡាយ ។ មិច្ឆាទិដ្ឋិកបុគ្គលពោលថា 'ធម្មជាតិណា ដែលគេហៅថា 'ផល' ឬ 'វិបាក' ដូច្នេះ, ធម្មជាតិនោះ រមែងមិនមាន' ដូច្នេះ ដោយបទ ថា **'ផលវិបាកោ'** ។ ពាក្យថា **'នត្ថិ អយំ លោកោ'** មានសេចក្តីថា លោកនេះ របស់បុគ្គលអ្នកស្ថិតនៅ ក្នុងបរលោក រមែងមិនមាន ។ ពាក្យថា **'នត្ថិ បរោ លោកោ'** មានសេចក្តីថា លោកខាងមុខ សូម្បីរបស់បុគ្គលអ្នកស្ថិតនៅហើយ ក្នុងលោកនេះ ក៏មិនមាន ។ មិច្ឆាទិដ្ឋិកបុគ្គល សំដែងថា 'សត្វទាំងឡាយទាំងពួង តែងបាត់សូន្យ ក្នុងភពនោះៗតែម្តង' ។ មិច្ឆាទិដ្ឋិកបុគ្គល រមែងពោលថា **'នត្ថិ មាតា នត្ថិ បិតា'** ដូច្នេះ ដោយអំណាចនៃការមិនមានផល នៃការប្រតិបត្តិត្រឹមត្រូវ និងការប្រតិបត្តិខុស ក្នុងមាតាបិតាទាំងនោះ ។ មិច្ឆាទិដ្ឋិកបុគ្គល រមែងពោលថា 'ធម្មតាសត្វដែលច្យុតហើយ កើតមកវិញ (ទៀត) តែងមិនមាន' ដូច្នេះ ដោយបទថា **'នត្ថិ សត្តា ឱបបាតិកា'** ដូច្នេះ" ។

អដ្ឋកថាទិដ្ឋុបាទាននិទ្ទេស ក្នុងនិក្ខេបកណ្ឌ ថា " ២ បទថា **'សមគ្គតា សម្មាបដិបន្នា'** មានសេចក្តីថា សមណៈនិងព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ទាំងឡាយ ជាអ្នកប្រតិបត្តិបដិបទាដ៏សមគួរ" ។

អដ្ឋកថាសាលេយ្យកសូត្រថា "ពាក្យថា 'សយំ អភិញ្ញា សច្ឆិកត្វា' មានសេចក្តីថា មិច្ឆាទិដ្ឋិកបុគ្គល សំដែងនូវការមិនមាន នៃព្រះសព្វញ្ញុពុទ្ធទាំងឡាយថា 'សមណៈនិងព្រាហ្មណ៍ទាំងឡាណា រមែងប្រកាសនូវលោកនេះ និងលោកខាងមុខ ធ្វើឲ្យជាក់ច្បាស់ទាំងពួង ដោយបញ្ញាដ៏ប្រសើរក្រៃលែង, សមណៈនិងព្រាហ្មណ៍ទាំងឡាយនោះ មិនមានឡើយ' ដូច្នេះ"។

ពាក្យថា "**នត្ថិ ទិន្នំ**" ដូច្នេះជាដើម បណ្ឌិតគប្បីប្រកាន់យក ដោយបដិបក្ខនัย នឹងពាក្យដែលខ្ញុំពោលហើយ ។

(៦៧) ក៏អដ្ឋកថាបឋមវគ្គ ក្នុងកោសលសំយុត្តថា 'ខត្តិយ-មហាសាល គឺ ក្សត្រទាំងឡាយ អ្នកបរិបូណ៌ដោយទ្រព្យដែលមានខ្ជឹមសារជាច្រើន ឈ្មោះថា ក្សត្រមហាសាល ។ អធិប្បាយថា មែនពិត ក្សត្រទាំងឡាយណា មានទ្រព្យសម្បត្តិជាដើមទុនប្រមាណ ១០០ កោដិ ដោយយ៉ាងទាបបំផុត មានកហាបណៈប្រមាណ ៣ កុម្ភៈ ធ្វើឲ្យជាគំនរកប់ទុក ក្នុងកណ្តាលឃ្លាំង ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់, ក្សត្រទាំងឡាយនោះ ឈ្មោះថា ក្សត្រមហាសាល ។ ព្រាហ្មណ៍ទាំងឡាយណា មានទ្រព្យសម្បត្តិកប់ទុកជាដើមទុន ចំនួន (យ៉ាងទាប) ៨០ កោដិ មានកហាបណៈប្រមាណកន្លះកុម្ភៈ ធ្វើឲ្យជាគំនរកប់ទុក ត្រង់កណ្តាលផ្ទះ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់

ព្រាហ្មណ៍ទាំងឡាយនោះ ឈ្មោះថា ព្រាហ្មណ៍មហាសាល ។ គហបតី ទាំងឡាយណា មានទ្រព្យសម្បត្តិកប់ទុកជាដើមទុន ប្រមាណ ៤០ កោដិ មានកហាបណៈ ប្រមាណ ១ កុម្ភៈ ធ្វើឲ្យជាគំនរកប់ទុក ត្រង់កណ្តាលផ្ទះ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់, គហបតីទាំងឡាយនោះ ឈ្មោះថា គហបតីមហាសាល" ។

អដ្ឋកថាសាលេយ្យកសូត្រថា " ពាក្យថា '**សហព្យតំ ឧបបជ្ជេយ្យំ**' គឺ គប្បីចូលដល់ភាពជាសំឡាញ់ ។ ២ បទថា '**ព្រហ្មកាយិកានំ ទេវានំ**' គឺ នៃទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងបឋមឈាន ។ ទេវតាមួយផ្នែក ឈ្មោះថា អាភា ក្នុងពាក្យថា '**អាភានំ ទេវានំ**' ដូច្នេះ មិនមាន ។ ពាក្យថា អាភានោះ ជាឈ្មោះនៃបរិត្តាភាទេវតា អប្បមាណាភាទេវតា និង អភស្សរាទេវតាទាំងឡាយ ។ ចំណែកពាក្យថា '**បរិត្តាភានំ**' ជាដើម ជាគ្រឿងប្រកាន់យកនូវទេវតាទាំងឡាយនោះឯង ដោយប្រភេទ ព្រោះមិនប្រកាន់យក ដោយចំណែកមួយ ។ សូម្បីក្នុងបទទាំងឡាយ មានបទថា '**សុភានំ បរិត្តសុភានំ**' ដូច្នេះជាដើម ក៏នัยនេះដូចគ្នា" ។

(៦៨) អដ្ឋកថាអាកង្ខេយ្យសូត្រ ក្នុងបឋមវគ្គ នៃមូលបណ្ណាសកៈថា " ២ បទថា '**អាសវានំ ខយា**' គឺ ព្រោះកិរិយាអស់ទៅ នៃកិលេសទាំងពួងទាំងឡាយ ដោយអរហត្តមគ្គ ។

បទថា **'អនាសវំ'** គឺ ប្រាសចាកអាសវៈ ។ ក្នុង ២ បទនេះថា **'ចេតោវិមុត្តិ បញ្ញាវិមុត្តិ'** ដូច្នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ សមាធិ ដែលសម្បយុត្តដោយអរហត្តផល ដោយចេតោសព្ទ និង ព្រះអង្គទ្រង់ត្រាស់បញ្ញា ដែលសម្បយុត្ត ដោយអរហត្តផលនោះ ដោយបញ្ញាសព្ទ ។ ក៏បណ្តាធម៌ទាំង ២ យ៉ាងនោះ សមាធិ បណ្ឌិតគប្បីជ្រាបថា 'ចេតោវិមុត្តិ' ព្រោះជាធម្មជាតដែលរួចផុត អំពីសេចក្តីតម្រេក, បញ្ញាបណ្ឌិតគប្បីជ្រាបថា 'បញ្ញាវិមុត្តិ' ព្រោះរួចផុតស្រឡះអំពីអវិជ្ជា ។ មែនពិត ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា 'ម្នាលភិក្ខុទាំងឡាយ ក៏សមាធិឯណា គប្បីមានបាន, សមាធិនោះ គប្បីជាសមាធិន្ទ្រីយ៍, ម្នាលភិក្ខុទាំងឡាយ បញ្ញាឯណា គប្បីមានបាន, បញ្ញានោះ គប្បីជាបញ្ញិន្ទ្រីយ៍, ម្នាលភិក្ខុទាំងឡាយ សមាធិ ឈ្មោះថា ចេតោវិមុត្តិ ព្រោះសម្រេករាគៈ, បញ្ញា ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះសម្រេកអវិជ្ជា យ៉ាងដូច្នេះឯង' ។ ម្យ៉ាងទៀត បណ្តាវិមុត្តិទាំង ២ យ៉ាងនោះ ផលនៃសមថៈ បណ្ឌិតគប្បីជ្រាបថា 'ចេតោវិមុត្តិ' ផលនៃវិបស្សនា បណ្ឌិតគប្បីជ្រាបថា 'បញ្ញាវិមុត្តិ'។ ២ បទថា **'ទិដ្ឋេវ ធម្មេ'** គឺក្នុងអត្តភាពនេះឯង។ ពាក្យថា **'សយំ អភិញ្ញា សច្ឆិកត្វា'** គឺ ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដោយខ្លួនឯងពិត, អធិប្បាយថា 'ដឹង ដោយមិនមានបុគ្គល

ជទៃជាបច្ច័យ' ។ ២ បទថា 'ឧបសម្បជ្ជ វិហរេយ្យុំ' គឺ គប្បីបានសម្រេច គឺ គប្បីធ្វើឱ្យបានសម្រេច ហើយនៅ" ។

(ទេវលោក ២៦ ជាន់)

(៦៩) អដ្ឋកថាសាលេយ្យកសូត្រថា "ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងការអស់ទៅនៃអាសវៈហើយ ទ្រង់ញុំាងព្រះធម្មទេសនាឱ្យចប់ ដោយធម៌ជាកំពូល គឺព្រះអរហត្ត ដោយប្រការដូច្នេះឯង ។

ក៏ទេវលោក បណ្ឌិតគប្បីប្រមូលមក រួបរួមទុក ក្នុងនិទ្ទេសនៃធម្មចរិយសមចរិយានេះ ។ ទេវលោក ១៨ ជាន់ គឺ÷ ព្រហ្មលោក ៩ ជាន់ ដោយអំណាច នៃភូមិនៃឈានទាំងឡាយ ៣ ជាមុន, សុទ្ធាវាស ៥ ជាន់ ត្រូវជា ៩ ជាមួយគ្នានឹងអរូបព្រហ្ម ៤ ជាន់ផង, ទេវលោក ទាំង ១៨ ជាន់នោះ ត្រូវជា ១៩ ជាន់ ព្រមទាំងជាន់វេហប្ផលាផង, រួមបញ្ចូលទាំងអសញ្ញព្រហ្មផង ទើបត្រូវជាព្រហ្ម ២០ ជាន់ ។ មួយអន្លើដោយកាមាវចរ ៦ ជាន់ផង ទើបឈ្មោះថា ទេវលោក ២៦ ជាន់ ដោយប្រការដូច្នេះឯង ។

ព្រះមានព្រះភាគ ទ្រង់សំដែងកិរិយាកើតឡើង សូម្បីនៃពួកទេវតាទាំងពួងនោះ ដោយកុសលកម្មបថ ១០ ប្រការ ។ ក្នុងទេវលោកទាំង ២៦ ជាន់នោះ ការកើតឡើង ក្នុងកាមាវចរ ៦ ជាន់

រមែងមាន ដោយផលនៃសុចរិត ៣ យ៉ាងនុ៎ះឯង ។ ក៏កម្មបថទាំងនេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយអំណាចឧបនិស្សយនៃទេវលោកជាន់ខ្ពស់ៗទាំងឡាយ ។ មែនពិត កុសលកម្មបថ ១០ ប្រការ ឈ្មោះថា សីល, ការបរិកម្មកសិណ រមែងសម្រេចបានដល់បុគ្គលអ្នកមានសីលប៉ុណ្ណោះ ព្រោះហេតុនោះ បុគ្គលស្ថិតនៅក្នុងសីលហើយ ធ្វើបរិកម្មកសិណ ញុំាងបឋមឈាន ឲ្យកើតឡើងហើយ រមែងកើតឡើង ក្នុងភូមិនៃបឋមឈាន, បុគ្គលចំរើនឈានខ្ពស់ៗ មានទុតិយឈានជាដើមហើយ រមែងកើតឡើង ក្នុងភូមិនៃឈាន មានតតិយឈានជាដើម, បុគ្គលធ្វើរូបាវចរឈាន ឲ្យជាបាទចំរើនវិបស្សនាហើយ តាំងនៅក្នុងអនាគាមិផល រមែងទៅកើតក្នុងជាន់សុទ្ធាវាសទាំង ៥ ជាន់, បុគ្គលធ្វើរូបាវចរឈាន ឲ្យជាបាទ ញុំាងអរូបាវចរសមាបត្តិ ឲ្យកើតឡើងហើយ រមែងទៅកើត ក្នុងអរូបព្រហ្មទាំង ៤ ជាន់, បុគ្គលធ្វើរូបឈាននិងអរូបឈាន ឲ្យជាបាទ ចំរើនវិបស្សនាហើយ រមែងសម្រេចព្រះអរហត្ត ។ ចំណែកភពដែលជាទីនៅ របស់អសញ្ញីសត្វ គឺតាបសនិងបរិព្វាជកទាំងឡាយ ដែលជាអ្នកបួសខាងក្រៅសាសនា បានប្រព្រឹត្តមកហើយ ហេតុនោះ ទើបព្រះមានព្រះភាគ មិនបានសំដែង ក្នុងសូត្រនេះ” ។

(៧០) ជីកាសាលេយ្យកសូត្រថា "**វិធ** សព្ទ មាន **កោដ្ឋា** សព្ទជាសេចក្តី ដូច **វិធ** សព្ទ ក្នុងប្រយោគទាំងឡាយថា '**ឯកវិធេន ញាណវត្ថុំ**' ដូច្នេះជាដើម ។ មួយទៀត **វិធ** សព្ទនោះ មាន **តិ** សព្ទជាបទដើម ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា '**តិវិធំ**' ដូច្នេះ ដោយអំណាច នៃបឋមាវិភក្តិ ឯកវចនៈ ព្រោះធ្វើបឋមាវិភក្តិ និង ឯកវចនៈ ឱ្យវិបល្លាស ។ ក៏ប៉ុន្តែ សេចក្តី បណ្ឌិតគប្បីឃើញ ដោយអំណាចនៃតតិយាវិភក្តិ ពហុវចនៈ ព្រោះហេតុនោះ ទើប ព្រះអដ្ឋកថាចារ្យ ពោលថា '**តិវិធន្តិ តីហិ កោដ្ឋាសេហិ**' ដូច្នេះ ។ កាយដែលកម្រើកបាន ព្រះមានព្រះភាគ ទ្រង់អធិប្បាយហើយថា '**កាយ**' ក្នុងបទថា '**កាយេន**' នេះ ។ ក៏ចោទកាយនោះ ឈ្មោះថា ជាមាត់ទ្វារ (ផ្លូវ) នៃការប្រព្រឹត្តិធម៌ ព្រោះប្រាសចាកកាយទ្វារនោះហើយ ការប្រព្រឹត្តិធម៌នោះ ក៏ប្រព្រឹត្តទៅមិនបានឡើយ ។ ក៏បទថា '**កាយេន**' នុ៎ះ ជាតតិយាវិភក្តិ ចុះក្នុងហេតុ ។ មែនពិត វិញ្ញត្តិនោះ ជាសមុដ្ឋាននៃចេតនា ពោលគឺការប្រព្រឹត្តិធម៌, ប៉ុន្តែ វិញ្ញត្តិនោះ មិនមែនជាបច្ច័យ នៃចេតនា ដោយជាបច្ច័យ សូម្បីបច្ច័យ ១ បណ្តាបច្ច័យទាំង ២៤ យ៉ាង ដែលមកហើយ ក្នុងបករណ៍ ឈ្មោះថា បដ្ឋានឡើយ ក៏ពិតមែន, ទោះជាដូច្នោះ រមែងគ្រាន់តែជាពាក្យវោហារ ប្រៀបដូចជាហេតុ នៃចេតនា និង ជាគ្រឿងធ្វើ

នូវចេតនានោះ ព្រោះភាវៈនៃចេតនានោះ គឺបុគ្គលគប្បីកំណត់បាន ដោយទ្វារនោះ ព្រោះសេចក្តី ថា 'សេចក្តីប្រព្រឹត្តទៅ នៃចេតនា ដែលមានឈ្មោះថា កាយកម្ម ដែលកំពុងតែប្រព្រឹត្តទៅ រមែងមាន ព្រោះសេចក្តីប្រព្រឹត្តទៅ នៃវិញ្ញត្តិនោះ'។ ម្យ៉ាងទៀត បទថា **'កាយទ្វារេន'** នោះ គឺ ព្រោះប្រកាន់យកសេចក្តីថា 'មានកាយទ្វារ' ដូច្នេះ ទើបជាតតិយាវិភត្តិ ចុះក្នុងឥត្ថម្ភូត"។

នយមកហើយ ក្នុងជីកាទុកនិបាត អង្គុត្តរនិកាយ ថា "សព្ទថា 'សមំ' ជាសព្ទសំដែងភាវៈ នៃនបុំសកលិង្គ"។

នយមកហើយ ក្នុងអដ្ឋកថាសាលេយ្យកសូត្រ ថា "មួយទៀត ការប្រព្រឹត្តិដូចគ្នា គឺដ៏សមគួរ ដល់ភាពជាសមណៈ ដោយអត្ថថា រម្ងាប់ចោលនូវធម៌ដែលជាសឹកសត្រូវ ព្រោះហេតុនោះ សេចក្តីប្រព្រឹត្តិនោះ ទើបឈ្មោះថា ត្រឹមត្រូវ គឺសុចរិត។ ការប្រព្រឹត្តិនោះឯង ឈ្មោះថា សមចរិយា"។

(៧១) ជីកានៃចូឡហត្ថិបទោបមសូត្រ និង ចតុក្កនិបាត អង្គុត្តរនិកាយ ថា "បទថា **'បជហិត្វា'** គឺ លះបង់ហើយ ដោយអំណាចនៃការសមាទាន។ ព្រះអដ្ឋកថាចារ្យ សំដែងនូវភាវៈនៃការលះបង់ និង ការវៀរចាកថាជាកិរិយាដែលមានកាលមិនស្មើគ្នា ដោយពាក្យនេះ ថា **'បហីនកាលតោ . . . វិរតោ វា'** ដូច្នេះ។

មានពាក្យចោទសួរ ថា 'ប្រសិនបើ កាលបើព្រះអដ្ឋកថាចារ្យ បានប្រកាន់យក យ៉ាងនេះហើយ, សព្ទថា 'បហាយ' ជាសព្ទសំដែងនូវបុរិមកាល បានយ៉ាងដូចម្តេច ?'។ មានពាក្យឆ្លើយថា 'បហាយ សព្ទ ជាសព្ទសំដែងបុរិមកាលបាន ដោយការប្រៀបធៀប នូវភាវៈនៃកាលដែលបុគ្គលគប្បីប្រកាន់យក យ៉ាងដូច្នោះ'។ មែនពិត កាលបើអាចារ្យសំឡឹងយក ភាវៈនៃធម៌ទាំងឡាយ ដែលជាបច្ច័យ និងអាស្រ័យបច្ច័យកើតឡើង, កិរិយាប្រកាន់យក សូម្បីនូវធម៌ទាំងឡាយដែលកើតឡើងព្រមជាមួយគ្នា រមែងមាន ដោយការកើតឡើងជាមុន និង ខាងក្រោយបានដូចគ្នា ព្រោះភាវៈ នៃធម៌ទាំងឡាយជាបច្ច័យ និង អាស្រ័យបច្ច័យកើតឡើង ព្រោះហេតុនោះ ពាក្យពោលនូវបុរិមកាល ដោយបហានកិរិយា ព្រោះធម៌ទាំងឡាយមានហិរិ ឱត្តប្ប: និង ញាណជាដើម ដែលជាបច្ច័យ និង ពាក្យពោលនូវអបរកាល ដោយវិរមណកិរិយា ព្រោះវិរតិទាំងឡាយដែលអាស្រ័យបច្ច័យកើតឡើង រមែងមាន ដោយអំណាចនៃអាការៈ នៃកិរិយាប្រកាន់យក និង កិរិយាប្រព្រឹត្តិ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា 'បហាយ បដិវិរតោ' ដូច្នេះ។ ម្យ៉ាងទៀត បទថា 'បហាយ' ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចការធ្វើ ក្នុងវេលាសមាទាន។ បទថា 'បដិវិរតោ'

ព្រះអង្គទ្រង់ត្រាស់ហើយ ដោយអំណាចនៃការជួបប្រទះនូវវត្ថុដែលខ្លួនគប្បីកន្តង ក្នុងកាលជាខាងក្រោយ ។ មួយទៀត បទថា 'បហាយ' បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃសមានកាល ដូចជាសមានកាល ក្នុងប្រយោគទាំងឡាយ មានជាអាទិ៍ យ៉ាងដូច្នេះថា ÷

'ព្រះអាទិត្យ គ្រាន់តែរះឡើងភ្លាម ក៏កំចាត់នូវគំនរនៃសេចក្តីងងឹតបាន និងប្រយោគថា ព្រះច័ន្ទរះឡើងភ្លឺស្វាងហើយ រមែងភ្លឺស្វាងត្រចះត្រចង់' ដូច្នេះ ។

ម្យ៉ាងវិញទៀត ពាក្យថា 'បហាយ បដិវិរតោ' បណ្ឌិតគប្បីជ្រាបសេចក្តីថា 'សត្វ គឺបុគ្គលតែងសម្លាប់ ដោយចេតនាធម៌ន៎ុះហេតុនោះ ចេតនាធម៌ន៎ុះ ទើបឈ្មោះថា បាណាតិបាត គឺសង្កិលេសធម៌ មានចេតនាជាប្រធាន ដែលប្រកបដោយការមិនខ្មាសបាប មិនខ្លាចបាប ទោសៈ មោហៈ និងការបៀតបៀនជាដើម ដែលជាហេតុឱ្យសម្លាប់សត្វមានជីវិត ។ ធម្មចារិសមចារីបុគ្គល លះបង់ចោលនូវបាណាតិបាតនោះ ដោយអំណាចការសមាទាន រមែងជាអ្នកវៀរចាកដាច់ស្រឡះ អំពីបាណាតិបាតនោះ ។ ព្រះអដ្ឋកថាចារ្យសំដែងនូវភាវៈនៃវិរតិនោះ ថាជាកិរិយាមិនមានទីបញ្ចប់ ដោយអំណាចនៃកាលជាដើម ដោយអវធារណសទ្ទ ក្នុងបទថា 'វិរតោ វ' ដូច្នេះ ។

ប្រៀបដូចជា បុគ្គលទាំងឡាយឯទៀត សូម្បីជាអ្នកមានវិរ័តិ គឺខ្លួនសមាទានហើយ រមែងទំលាយនូវការសមាទានចោល ព្រោះហេតុនៃវត្ថុដែលជាទីស្រឡាញ់ មានលាភនិងជីវិតជាដើម ព្រោះភាពនៃខ្លួនជាអ្នកមានចិត្តមិនរឹងប៉ឹង យ៉ាងណាមិញ, ធម្មចារិសមចារីបុគ្គលនេះ មិនមែនជាយ៉ាងដូច្នោះឡើយ ។ តែធម្មចារិសមចារីបុគ្គលនេះ រមែងជាអ្នកវៀរចាក ចាប់ដើមអំពីកាលដែលខ្លួនសមាទានរួចហើយ ទើបឈ្មោះថា ជាអ្នកវៀរចាកស្រឡះហើយ ដូច្នេះឯង ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា **'អទិន្នាទានំ បហាយ'** ដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបសេចក្តី ដោយន័យនេះ ដូចគ្នាដែរ ។ វត្ថុជាគ្រឿងញុំាងសត្វឲ្យធ្លាក់ចុះ គឺដំបង ឈ្មោះថា ទ័ណ្ឌៈ បានដល់គ្រឿងប្រហារពិសេស មានអន្ទងជាដើម ព្រោះហេតុនោះ គ្រឿងប្រហារពិសេស ព្រះមានព្រះភាគ ទ្រង់ត្រាស់អធិប្បាយហើយ ក្នុងបទថា **'និហិតទណ្ឌោ'** នេះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'ឋបេត្វា ទណ្ឌំ សព្ពម្បិ អវសេសំ ឧបករណំ'** ដូច្នេះ ។ ក៏កិរិយាពោលដល់ការទម្លាក់ចោល នូវដំបងនិង សស្ត្រាក៏ដើម្បីនឹងសំដែងភាវៈនៃគ្រឿងបៀតបៀននូវបុគ្គលដទៃ ពោលគឺគ្រឿងដាក់ទ័ណ្ឌកម្ម ដែលធម្មចារិសមចារីបុគ្គល បានលះបង់ហើយ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'បរូបឃាតត្ថាយ'**

ដូច្នេះជាដើម ។ មិនមែនពោល ដើម្បីភាវៈជាគ្រឿងបៀតបៀនទេឬ ។ សូម្បីសេចក្តីខ្លាចបាប បណ្ឌិតគប្បីជ្រាបថា 'ព្រះអដ្ឋកថាចារ្យ ពោលហើយ ដោយលជ្ជាសព្ទ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងបទថា **'លជ្ជី'** នេះ ។ សេចក្តីខ្លាសបាបរបស់បុគ្គលអ្នកប្រកបដោយសេចក្តីស្អប់ខ្ពើមបាប រមែងជាការមិនភ័យខ្លាចបាប ក៏ទេដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **'លជ្ជី'** ដូច្នេះតែប៉ុណ្ណោះ ។ មានពាក្យសួរថា 'ព្រះអដ្ឋកថាចារ្យ ពោលថា **'ទយំ មេត្តចិត្តតំ អាបន្នោ'** ដូច្នេះ ព្រោះហេតុអ្វី ?, **ទយា** សព្ទ រមែងប្រព្រឹត្តទៅ ក្នុងអត្ថនៃករុណាសព្ទ ដូចជាករុណាសព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **'អទយាបន្នោ'** ដូច្នេះជាដើម មិនមែនទេឬ?' ។ មានពាក្យឆ្លើយថា 'ដំណើរនោះ ពិតមែន ។ ប៉ុន្តែថា **ទយា** សព្ទនេះ ធ្វើនូវជលត្រឹមតែការតាមថែរក្សា ឲ្យជាកិច្ចដែលខ្លួននាំទៅហើយ ព្ធដ៏ខាងក្នុង កាលប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅ ក្នុងអត្ថនៃមេត្តាសព្ទ និងករុណាសព្ទ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល **ទយា** សព្ទ ដែលប្រព្រឹត្តទៅ ក្នុងអត្ថនៃមេត្តាសព្ទទុកក្នុងទីនេះ' ។ ធម្មជាតិណា ដែលបុគ្គលស្រឡាញ់ គឺស្នេហា ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា មេត្តា, មេត្តា របស់ចិត្តនុ៎ះ រមែងមាន

ហេតុនោះ ចិត្តនោះ ទើបឈ្មោះថា មានមេត្តា, ចិត្តមានមេត្តា របស់បុគ្គលនោះ មាន ហេតុនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានចិត្តមានមេត្តា, ភាវៈនៃបុគ្គលជាអ្នកមានចិត្តមានមេត្តានោះ ឈ្មោះថា ភាវៈនៃបុគ្គលជាអ្នកមានចិត្តមានមេត្តា, បណ្ឌិតគប្បីជ្រាបសេចក្តីដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនូវភាវៈនៃវិរ័តិនោះ ជាកិរិយាមិនមានទីបញ្ចប់ ដោយអំណាចនៃសត្វ ដោយពាក្យថា '**សព្វប្បាណភូតហិតានុកម្បិ**' នេះ ។ បទថា '**បាណភូតេ**' គឺ នូវសត្វទាំងឡាយ ។ បទថា '**អនុកម្បកោ**' គឺ ជាអ្នកប្រព្រឹត្តនូវករុណា ។ ក៏មេត្តា រមែងមានបច្ច័យខុសប្លែកផ្សេងអំពីករុណា ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**តាយ ឯវ ទយាបន្ធតាយ**' ដូច្នេះ ។ បណ្ឌិតគប្បីឃើញសេចក្តី ក្នុងពាក្យថា '**ទយំ មេត្តចិត្តតំ អាបន្នោ**' នោះ យ៉ាងដូច្នេះថា 'កិរិយាវៀរចាកបាណាតិបាត រមែងសម្រេចបាន ដោយធម៌ទាំងឡាយណា, ព្រះអដ្ឋកថាចារ្យសំដែងភាវៈនៃបុគ្គលជាអ្នកប្រកបព្រម ដោយធម៌ទាំងឡាយនោះ គឺ សេចក្តីអៀនខ្មាស មេត្តា និងករុណា ព្រមជាមួយគ្នា នឹងធម៌ដែលប្រព្រឹត្តទៅឆ្ងាយ ខាងក្រោយ' ។ ព្រះអដ្ឋកថាចារ្យ ពោលចោទសួរ ក្នុងសេចក្តីនេះថា 'ព្រះមានព្រះភាគ ទ្រង់ធ្វើសព្ទសំដែងឯកវចនៈ ក្នុងបាលីថា

'**បាណាតិបាតំ បហាយ**' ដូច្នេះ ព្រោះហេតុអ្វី ? ការវៀរចាកកិរិយាញុំាងសត្វទាំងឡាយ ដែលមិនមានសេសសល់ ឲ្យធ្លាក់ចុះកន្លងព្រះមានព្រះភាគ ទ្រង់ត្រាស់អធិប្បាយហើយ ក្នុងពាក្យនេះ មិនមែនទេឬ ? ។ ពិតមែនយ៉ាងដូច្នោះ ព្រះអង្គទ្រង់ត្រាស់ហើយថា '**សព្វប្បាណភូតហិតានុកម្បី វិហរតិ**' ដូច្នេះ ។ ដោយហេតុនោះឯង ព្រះអដ្ឋកថាចារ្យ ទើបពោល ក្នុងអដ្ឋកថាថា 'ព្រះមានព្រះភាគ គប្បីធ្វើសំដែងជាពហុវចនៈថា '**សព្វេ បាណភូតេ ហិតេន អនុកម្បកោ**' ដូច្នេះ' ។ គប្បីជ្រាបវិសជ្ជនាថា 'ពាក្យដែលលោកពោលហើយនុ៎ះពិតមែន ។ ក៏ប៉ុន្តែថា ព្រះមានព្រះភាគ សូម្បីទ្រង់ធ្វើសព្ទ ក្នុងពាក្យនោះ ឲ្យជាសព្ទសំដែងជាឯកវចនៈ តាំងអំពីដើមមក ក្នុងព្រះបាលី ដោយអំណាចនៃភាវៈជាសត្វស្មើគ្នា ដោយភាពជាសត្វដែលមានជីវិត, បុគ្គលនឹងដឹងបានថាជាពហុវចនៈក៏ដោយការសន្និដ្ឋានសព្ទនុ៎ះឯង ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបមិនបានធ្វើ ឲ្យជាសព្ទសំដែងស្មើគ្នា ហើយបានពោលសេចក្តីក្នុងអដ្ឋកថា ដោយអំណាចជាពហុវចនៈ ដើម្បីនឹងសំដែងសេចក្តីនោះ ដោយអំណាចប្រាថ្នាចង់ឲ្យមានវចនៈផ្សេងអំពីគ្នា ។ បណ្ឌិតគប្បីជ្រាបសេចក្តីបន្តិចបន្តួច ដោយក្រៃលែងថា 'ព្រះអដ្ឋកថាចារ្យបានធ្វើការប្លែកផ្សេងអំពីគ្នា នៃវចនៈនេះ ដើម្បីនឹងសំដែងនូវ

សេចក្តីប្លែងផ្សេងគ្នានេះថា 'សំវរសមាទាន ដោយភាពជាសមាទានទូទៅ សេចក្តីខុសប្លែកផ្សេងគ្នានៃសំវរៈ ជាអាការប្លែកផ្សេង អំពីសំវរសមាទាននោះ'។ បទថា **'វិហរតិ'** មានសេចក្តីថា ធម្មចារិ-សមចារីបុគ្គល ជាអ្នកមានប្រការដូចពោលហើយ រមែងចំបាត់នូវទុក្ខដែលកើតឡើងហើយ ព្រោះឥរិយាបថ១ ដោយឥរិយាបថមួយទៀត នាំអត្តភាពទៅ គឺ តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ បានដល់ឲ្យរស់នៅ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'ឥរិយតិ បាលេតិ'** ដូច្នេះ"។

(៧២) ជីកានៃសារលេយ្យកសូត្រថា " សព្ទថា **'បរស្ស'** ជាសព្ទសំដែងឆដ្ឋីវិភ័ក្តិ ដោយអំណាចនៃទ្រព្យឯណា, ទ្រព្យនោះព្រះមានព្រះភាគ ទ្រង់កំណត់យកហើយមែនពិត ដោយភាពជាទ្រព្យស្មើគ្នា ដោយបទថា **'យន្តំ'** ដូច្នេះ ជាទ្រព្យដែលព្រះអង្គទ្រង់ប្រកាសហើយ ដោយសំដែងជាឆដ្ឋីវិភ័ក្តិនុ៎ះឯង ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'បរសន្តកំ'** ដូច្នេះ។ មួយទៀត ពាក្យថា **'បរស្ស បរិក្ខបករណំ'** នោះ ជាបទសមាសតែមួយនុ៎ះឯង។ អធិប្បាយថា 'ទ្រព្យជារបស់ជនដទៃ ឯណានីមួយ ឬទ្រព្យដែលជាឧបករណ៍គ្រឿងពេញចិត្ត របស់ជនដទៃ ដោយភាពជាទ្រព្យផ្សេងៗគ្នា។ ២ បទថា **'តេហិ បរេហិ'** គឺទ្រព្យ

ដែលជារបស់ នៃជនទាំងឡាយណា, គឺជនទាំងឡាយនោះ (មិនបាន
ឱ្យហើយ)។ បុគ្គលដែលគេហៅថា 'អ្នកលួច' ដោយអំណាចនៃ
ចិត្តណា, ចិត្តនោះ ឈ្មោះថា **ថេយ្យៈ** (ចិត្តគិតនឹងលួច) ព្រោះ
ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**អវហរណចិត្តស្សេតំ
អធិវចនំ**' ដូច្នេះ។ បុគ្គលរមែងជាអ្នកកាន់យកនូវទ្រព្យរបស់
នៃជនដទៃ ដោយចំណែកនៃចិត្តគិតនឹងលួច, អធិប្បាយថា 'មិន
មែនជាអ្នកកាន់យក ដោយអំណាចនៃសេចក្តីបរិសុទ្ធិ មានសេចក្តី
ស្និទ្ធស្នាលគ្នា និងសុំខ្ចីជាដើមឡើយ'។ **វា** សព្ទ ក្នុងបទថា
'**មតេ វា**' ជាវិកប្បត្ថៈ ដែលលោកមិនបានពោលទុកហើយ។
ដោយហេតុនោះ **វា** សព្ទនោះ ទើបសង្គ្រោះនូវហេតុមានភាពជា
បព្វជិតជាដើមបញ្ចូលជាមួយផង។ ព្រះអដ្ឋកថាចារ្យ ពោលថា
'**តេនុប្បាយេន**' ដូច្នេះ សំដៅយកពាក្យមានជាអាទិ៍ យ៉ាងនេះថា
'កាលបើមាតា ស្លាប់ហើយក្តី **វិនាសបាត់ទៅហើយក្តី**, បិតារក្សា
នូវកូនស្រីណា, កូនស្រីនោះ ឈ្មោះថា ស្ត្រីដែលបិតាថែរក្សាហើយ,
កាលបើមាតា និង បិតាទាំង ២ នាក់ មិនមានទេ, បងប្អូនប្រុស
តែងថែរក្សានូវស្ត្រីណា, ស្ត្រីនោះ ឈ្មោះថា ស្ត្រីដែលបងប្អូនប្រុស
ថែរក្សាហើយ' ដូច្នេះ។ បទថា '**សភាគកុលានិ**' គឺ ត្រកូលទាំង
ឡាយដែលស្មើភាពគ្នា ដោយការធ្វើអាវាហៈ និង **វិវាហមង្គល**"។

(៧៣) មែនពិត ព្រះមានព្រះភាគ ទ្រង់មិនបានសំដែងនូវពាក្យនេះ ថា "**គោត្តរក្ខិតា ធម្មរក្ខិតា សារក្ខា**" ដូច្នេះ ទុកក្នុងព្រះបាលីទេ, ប៉ុន្តែពាក្យ ថា "**សស្សាមិកា**" នេះ មកហើយ ក្នុងទីស្ថាននៃសារក្ខសព្ទ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងជីកាសម្មាទិដ្ឋិសូត្រជាដើម ថា "**សស្សាមិកា សារក្ខា**" ដូច្នេះ ។

(៧៤) ជីកាសាលេយ្យកសូត្រ ថា "ឥស្សរជនទាំងឡាយមានព្រះរាជាជាដើម បានតាំងអាជ្ញាទុកចំពោះថ្នល់ឈ្មោះនុ៎ះឬ (ផ្ទះឈ្មោះនុ៎ះ) ។ បទថា '**សម្មាទិដ្ឋិសុត្តេ**' គឺ បុគ្គលរមែងជាអ្នកធ្វើនូវសេចក្តីល្មើស ដោយអំណាចលក្ខណៈនៃការប្រព្រឹត្តិខុស ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ យ៉ាងដូច្នេះថា 'ចេតនាជាហេតុកន្លងល្មើស នូវអគមនីយដ្ឋាន ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយប្រាថ្នានឹងសេពនូវអសទ្ធម្ម' ដូច្នេះ ។ បទថា '**ហត្ថបាទាទិហេតុ**' គឺ ព្រោះហេតុនៃការត្រូវកាត់នូវអវយវៈមានដៃនិងជើងជាដើម ។ បទថា '**ធនហេតុ**' គឺ ព្រោះហេតុនៃការបានទ្រព្យសម្បត្តិ និង ព្រោះហេតុនៃការសាបសូន្យចាកទ្រព្យ ។ ភោគៈមានអាហារនិងគ្រឿងស្លៀកពាក់ជាដើម ឈ្មោះថា លាភ ។ ឈ្មោះថា លាភ ព្រោះវិគ្រោះថា 'ដែលបុគ្គលតែងបាន' ដូច្នេះ ។

បទថា 'កិញ្ចិកំ្ខ' គឺ នូវអាមិសមានប្រមាណបន្តិចបន្តួច ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលពាក្យជាអាទិ៍ថា 'ឃំ វា' ដូច្នេះ ។ បទថា 'សម្បជានន្តោ វ' គឺ ទាំងដឹងថា ជាពាក្យកុហកបានដល់ (ដឹង) ថាវត្ថុនោះ ជារបស់មិនពិតនុ៎ះឯង" ។

(៧៥) ជីកានៃចូឡហត្ថិបទោបមសូត្រជាដើមថា "បទថា 'អនុប្បទាតា' គឺ អ្នកតាមផ្តល់ឱ្យនូវកម្លាំង, មួយទៀត ជាអ្នកជួយឧបត្ថម្ភ ដោយអំណាចនៃការប្រព្រឹត្តិតាម ។ មានពាក្យសួរថា 'ក៏ការប្រព្រឹត្តិតាមនិងការជួយឧបត្ថម្ភ នូវអ្វី ?' ដូច្នេះ, បណ្ឌិតរមែងជ្រាបពាក្យវិនិច្ឆ័យថា 'ការប្រព្រឹត្តិតាម និង ការជួយឧបត្ថម្ភ នូវសេចក្តីព្រមព្រៀងគ្នា ព្រោះពាក្យថា 'សមាហិតានំ' ព្រះមានព្រះភាគទ្រង់បានត្រាស់ទុកហើយ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'សន្ធានានុប្បទាតា' ដូច្នេះ ។ មួយទៀត ការផ្តល់ឱ្យក្តី ការប្រគល់ឱ្យក្តី ការថែរក្សាក្តី នូវការព្រមព្រៀងគ្នា ដោយអំណាចការប្រព្រឹត្តិតាម ឈ្មោះថា ជាការធ្វើឱ្យបានមាំមួន ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា 'ទ្វេ ជនេ សមគ្គេ ទិស្វា' ដូច្នេះជាដើម ។ ជនទាំងឡាយ រមែងត្រេកអរក្រៃលែង ក្នុងការព្រមព្រៀងគ្នានេះ ព្រោះហេតុនោះ ការព្រមព្រៀងគ្នានេះ ទើបឈ្មោះថា **អារាមោ** គឺ

ឋានៈដែលបុគ្គលគប្បីត្រេកអរ ។ ក៏ព្រោះសេចក្តីនេះ សូម្បីប្រាសចាក **អា** អក្សរ ក៏ប្រើការបាន, ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលបាលីថា '**សមគ្គរាមោ**' ដូច្នេះក៏មានខ្លះ ។ សេចក្តីក៏ដូចគ្នានេះដែរ "។

(៧៦) ដីកាសាលេយ្យកសូត្រថា "ដុំពកទាំងឡាយ ដូចជាក្រម៉ ពួដ៏ដើមឈើ គេហៅថា **អណ្ឌកា**, ក្រម៉ទាំងឡាយនោះជារបស់រឹង មិនរាបស្មើ និង ជារបស់ដែលចោះទម្លុះបានដោយក្រយ៉ាងណា, សូម្បីវាចាដែលប្រព្រឹត្តទៅហើយ ដោយអំណាចការពោលមួលបង្កាច់ និង ការពោលសង្កត់សង្កិន ក៏យ៉ាងដូច្នោះដែរ ហេតុនោះ វាចានោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**អណ្ឌកា**'។ ដោយហេតុនោះ ទើបលោកពោលថា '**យថា សទោសេ រុក្ខេ**' ដូច្នេះជាដើម "។

ដីកានៃសង្គីតិសូត្រ និង ខុទ្ទកនិកាយថា "បុគ្គលទាំងឡាយ រមែងហៅនូវដុំនៃជ័រឈើទាំងឡាយ (ជ័រចុង) ឬពួជមានផ្សិតក្បាលពស់ជាដើម ដែលកើតឡើងហើយ ពួដ៏ដើមឈើពុកស្តុយ គឺមានដំបៅ ថា '**អណ្ឌកា**' ដូច្នេះ ។ មួយទៀត ដុំនៃលំអិត ឬដុំពក នៃដើមឈើដែលមានក្រម៉ មានដំបៅឃ្លង់កើតឡើង ដូចជាដុំពក ឈ្មោះថា **អណ្ឌកា** ។ ក៏ក្នុងវចីកម្មនេះ

បណ្ឌិតគប្បីឃើញវាចា ដែលឈ្មោះថា **អណ្ហកា** ដោយមានចំណែកដូចជាក្រម៉ ព្រោះភាវៈជាវាចាឲ្យបានដល់នូវសេចក្តីវិនាស និង ជាវាចារឹងរូសជាដើម, វាចាដែលចូលទៅច៉ះត្រចៀក ប្រៀបដូចជាដើម (ទង) បទុម បណ្ឌិតគប្បីឃើញថា ជាវាចាអាក្រក់ "។

ដីកានៃសាលេយ្យកសូត្រថា "បទថា '**កក្កសា**' គឺ ជាវាចាអាក្រក់នុ៎ះឯង ។ ក៏ភាវៈនៃវាចានោះ ជាវាចាអាក្រក់នោះ ព្រោះមានព្យាបាទជាគ្រឿងសម្គាល់ ឈ្មោះថា ជាវាចាស្ទួយ ព្រោះវាចានោះ ជាវាចាអាក្រក់ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា '**យថា នាម**' ដូច្នេះជាដើម ។ បទថា '**កដុកា**' គឺ ជាវាចាដែលបុគ្គលមិនប្រាថ្នាហើយ ។ បទថា '**អមនាបា**' គឺ ជាវាចាមិនជាទីចំរើនដល់ចិត្ត ។ ព្រោះជាវាចាមិនជាទីចំរើនដល់ចិត្តនោះឯង ទើបជាវាចាញុំាងទោសឲ្យកើតឡើង គឺ ជាវាចាដែលញុំាងទោសឲ្យកើតឡើងក្នុងចិត្ត ។ បទថា '**មម្មេសុ**' គឺ ក្នុងការជេរទាំងឡាយ មានជាតិជាដើម ប្រៀបដូចជារបស់ដែលស្រឡាញ់ ព្រោះសេចក្តីទុក្ខកើតឡើងបាន ដោយការចាក់ដោត ។ បទថា '**លគ្គនការី**' គឺ ជាវាចាធ្វើនូវសេចក្តីជាប់ជំពាក់ ដោយសេចក្តីប្រាថ្នាថា 'អាត្មាអញ នឹងពោលយ៉ាងនេះ' ដូច្នេះ, មិនមែនជាវាចាធ្វើនូវសេចក្តីជាប់ជំពាក់ ដោយអំណាច នៃការមិនធ្វើនូវ

សេចក្តីយល់ព្រមទេ ។ ឈ្មោះថា ជាវាចាជិតដល់សេចក្តីក្រោធខឹង ព្រោះជាហេតុនៃសេចក្តីក្រោធនោះ "។

ជីកានៃសង្គីតិសូត្រ និង ទុកនិបាតអង្គុត្តរនិកាយថា "ជាវាចាកើតឡើង ព្រោះសេចក្តីក្រោធ គឺ ជាបរិវារនៃសេចក្តីក្រោធនោះ ឈ្មោះថា ជាវាចាជិតដល់សេចក្តីក្រោធ "។

ជីកានៃសាលេយ្យកសូត្រថា "បទថា **'សទោសវាចាយ'** គឺ បទទាំងឡាយមាន **អណ្ហកា** ជាដើម ជាឈ្មោះនៃវាចាដែលមានទោស ដោយអំណាចញុំាងទោស ឲ្យកើតឡើង ដល់ខ្លួន "។

(៧៧) ជីកានៃចូឡហត្ថិបទោបមសូត្រជាដើមថា "បទថា **'ឯត្ត'** មានសេចក្តីថា ក្នុងគាថានេះថា ÷

> **'រថណា មានតួមិនមានទោស មានដំបូលពណ៌ស មានកាំតែមួយ ប្រព្រឹត្តទៅ, ចូរអ្នកមើលនូវរថនោះ ដែលចង្អៀត កាត់ខ្សែនៃតណ្ហាចោលបាន មិនមានគ្រឿងចង ដែលកំពុងប្រព្រឹត្តទៅ'** ដូច្នេះ,

ក៏សីល ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយថា 'មានអង្គមិនមានទោស' ក្នុងគាថានេះ ។ ដោយហេតុនោះឯង ទើបចិត្តគហបតីក្រាបទូលថា 'បពិត្រព្រះអង្គដ៏ចំរើន ពាក្យថា 'នេឡង្គំ' នេះឯង

ជាឈ្មោះ នៃសីលទាំងឡាយ ដូច្នេះ ។ បទថា **'កុសុមារា'** គឺ ឈ្មោះថា ជាវាចាដែលទន់ភ្លន់ ព្រោះជាវាចាមិនអាក្រក់ ។ ក្នុងពាក្យថា **'បុរស្ស ឯសា'** នុ៎ះ **បុរ** សព្ទ បណ្ឌិតគប្បីឃើញថា ជាសព្ទបញ្ជាក់ដល់បុគ្គលអ្នកនៅអាស្រ័យ ក្នុងបុរីនោះ ដូចជា **គាម** សព្ទ ក្នុងប្រយោគទាំងឡាយថា **'គាមោ អាគតោ'** ដូច្នេះ ជាដើម ។ ដោយហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យពោលថា **'នគរវាសីនំ'** ដូច្នេះ ។ វាចាណា ញុំាងចិត្តឲ្យរីករាយសប្បាយ គឺ ញុំាងចិត្តឲ្យចំរើន ហេតុនោះ វាចានោះ ឈ្មោះថា ជាវាចាញុំាងចិត្តឲ្យចំរើន ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា 'ជាវាចាធ្វើឲ្យចំរើនចិត្ត' ដូច្នេះ "។

(៧៨) ដីកាសាលេយ្យកសូត្រថា "បទថា **'ហទយមញ្ជុសាយ'** គឺ នូវវាចាដែលមិនគួរ ដើម្បីនឹងញុំាងចិត្តឲ្យត្រេកអរ រក្សាទុកបានឡើយ ព្រោះជាវាចាមិនមានប្រយោជន៍ ។ បទថា **'អនបទេសំ'** គឺ ប្រាសចាកទីអាង គឺ សូត្រថា 'ពាក្យយ៉ាងនេះ ព្រះមានព្រះភាគទ្រង់បានត្រាស់ទុកហើយ ក្នុងព្រះសូត្រឈ្មោះនុ៎ះ' ដូច្នេះ ។ បទថា **'អបរិច្ឆេទំ'** គឺ ប្រាសចាកការកំណត់ ។ ក៏វាចា រមែងជាវាចាប្រាសចាកកំណត់ ដោយប្រការណា, ដើម្បីសំដែងនូវប្រការនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យថា **'សុតំ វា'** ដូច្នេះជាដើម ។

បទថា **'ឧបារម្ភំ'** គឺ ពាក្យដែលប្រកបតាម, សូត្រឬជាតក ដែលប្រាសចាកការប្រកប ដោយពាហិរកថា ដែលខ្លួនបានលើកទុកហើយ ព្រះធម្មកថិក មិនបានទាញយកនូវពាក្យដែលជាដើមបទ នៃសូត្រឬជាតកនោះមកទេ ពោលតែពាក្យដែលមាននៅខាងក្រៅ នៃសូត្រឬជាតកនោះតែប៉ុណ្ណោះ ។ បទថា **'សម្បដ្ឋិត្វា'** គឺ ដល់ហើយនូវសេចក្តីចំរើនឡើង ។ បទថា **'បវេណិជាតា វ'** គឺ ឫសនៃដើមជ្រៃដែលកើតតៗគ្នាទាំងឡាយនុ៎ះឯង រមែងដុះឡើង ។ បទថា **'អាហរិត្វា'** គឺ នាំយកមកសូម្បីនូវពាក្យដទៃ អំពីសូត្រដែលខ្លួនបានលើកយកមកហើយ ឲ្យជាវាចាប្រកបដោយសូត្រនោះ ដោយអំណាចនៃការសោកសួរ ឧបមា និង រឿង ។ បទថា **'ជានាបេតុំ'** មានសេចក្តី ថា ព្រះធម្មកថិករូបណា តែងអាច ដើម្បីនឹងញុំាងអ្នកស្តាប់ឲ្យយល់បាន ថា 'ព្រះសូត្រនេះ មានសេចក្តីយ៉ាងនេះ' ដូច្នេះ, ព្រះធម្មកថិកនោះ នឹងសំដែង ក៏សមគួរ ។ ព្រះធម្មកថិករូបនោះ គឺ អ្នកប្រាកដដូច្នោះ សូម្បីជាសំដែងច្រើន ក៏សមគួរ ។ បទថា **'អនត្ថសញ្ហិតំ'** គឺ មិនមែនជាប្រយោជន៍ ដល់ខ្លួននិងជនដទៃ" ។

(៧៩) ជីកាចូឡហត្ថិបទោបមសូត្រជាដើម ថា "ពាក្យថា **'កាលវាទី'** ជាដើម ជាពាក្យសំដែងនូវសេចក្តីប្រតិបត្តិ នៃបុគ្គលដែលវៀរចាកពាក្យរាយមាយឥតប្រយោជន៍ ។ មែនពិត វាចា

សូម្បីប្រកបដោយប្រយោជន៍ (តែ) មិនគប្បីជាវាចាដែលនាំនូវប្រយោជន៍មកឲ្យ ព្រោះប្រកបក្នុងពេលដែលមិនគួរ ព្រោះហេតុនោះ ទើបអនុលោមដល់វាចាដែលញុំាងអ្នកស្តាប់ ឲ្យស្គាល់កាលដែលមិនមានប្រយោជន៍, ហេតុនោះ បុគ្គលអ្នកលះបង់នូវវាចារោយរាយឥតប្រយោជន៍ គប្បីចៀសវាងភាពជាអ្នកពោល ក្នុងវេលាមិនសមគួរចេញ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា '**កាលវាទី**' ដូច្នេះ ។ សូម្បីបុគ្គលពោល ក្នុងកាលដ៏គួរ ក៏គប្បីវៀរចាកពាក្យដែលមិនពិត ព្រោះមិនញុំាងឲ្យបានសម្រេចប្រយោជន៍ទាំង ២ ផ្នែក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា '**ភូតវាទី**' ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា '**អត្ថវាទី**' ដូច្នេះ ដើម្បីនឹងទ្រង់សំដែងថា 'ក៏បុគ្គលកាលនឹងពោលនូវពាក្យពិតត្រង់ គប្បីពោលពាក្យដែលញុំាងប្រយោជន៍សុខក្នុងលោកនេះ និងលោកខាងមុខឲ្យបានសម្រេចដោយពិត' ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា '**ធម្មវាទី**' ដូច្នេះ ដើម្បីនឹងទ្រង់សំដែងថា 'បុគ្គលសូម្បីពោលពាក្យ ដែលមានប្រយោជន៍ មិនត្រូវពោលពាក្យ ដែលអាស្រ័យលោកិយធម៌តែម្យ៉ាង គប្បីពោលពាក្យធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរធម៌ផងដែរ' ដូច្នេះ ។ ក៏សេចក្តីរមែងជាពាក្យអាស្រ័យលោកុត្តរធម៌បាន ដោយប្រការណា, ដើម្បី

ទ្រង់សំដែងនូវប្រការនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា **'វិនយវាទី'** ដូច្នេះ ។ ព្រោះថា សេចក្តីដែលបុគ្គលកំពុងពោល ដោយអំណាចនៃសំវរវិនិយ ៥ ប្រការ និងបហានវិនិយ ៥ ប្រការ ឈ្មោះថា ជាសេចក្តីអាស្រ័យលោកុត្តរធម៌ ព្រោះជាហេតុឲ្យបានសម្រេចនូវព្រះនិព្វាន ហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **'និធានវតី វាចំ ភាសិតា'** ដូច្នេះ ដើម្បីទ្រង់សំដែងថា 'ក៏សេចក្តីដែលប្រកបដោយគុណវិសេស សូម្បីយ៉ាងនេះ ដែលព្រះធម្មកថិកកំពុងពោល, កាលបើភាពជាអ្នកឆ្លាតក្នុងការសំដែងមាន, រមែងពីរោះ និង រមែងជាអ្នកធ្វើកិច្ច, មិនមែនជាអ្នកប្រព្រឹត្តទៅដោយប្រការដទៃឡើយ' ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យថា **'កាលេន'** ដូច្នេះជាដើម ដើម្បីទ្រង់ប្រកាសនូវភាពជាអ្នកឆ្លាត ក្នុងការសំដែងនោះ ។ វាចាដែលប្រកបដោយប្រយោជន៍ ក្នុងបទថា **'កាលេន'** ជាដើមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា 'ក៏ព្រះធម្មកថិក កំណត់នូវវិភាគ នៃព្យាករណ៍ មានឯកំសព្យាករណ៍ជាដើម ក្នុងរឿងនៃវាចាដែលសាកសួរបាន ដោយអំណាចនៃហេតុមានការចោទសួរជាដើម ហើយញុំាងបុគ្គលដទៃឲ្យតាំងនៅ ក្នុងធម៌តាមសេចក្តីពិត សមគួរដល់កម្លាំងនៃការចេះដឹង ដោយពាក្យដែលញុំាងអ្នកស្តាប់ ឲ្យយល់ច្បាស់បាន តាមសមគួរដល់

ហេតុនោះ។ ដោយឧបមា ហេតុ ឧទាហរណ៍ និង ការប្រៀបធៀប ជាពាក្យមានរូបសេចក្តី ដែលបុគ្គលប្រមាណនិងកំណត់បាន ជាកថា ដែលសង្គ្រោះ ដោយពាក្យដែលបរិបូណ៌ ជ្រាលជ្រៅក្រៃលែង ឱឡារិក មានសេចក្តីយ៉ាងក្រៃលែង និង ពិស្តារ ទើបលោកហៅថា 'ជាអ្នកឆ្លាត ក្នុងទេសនា' ដូច្នេះ"។

(៨០) ជីកានៃកយវេរវសូត្រថា "**ឈា** សទ្ទ មាន **អភិ** ជាបទខាងដើម មានការសំឡឹងរំពៃជាសេចក្តី ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**បរភណ្ឌានិ អភិជ្ឈាយនសីលា**"។

ជីកានៃសាលេយ្យកសូត្រថា "ដោយភាគច្រើន ការសំឡឹងរំពៃ រមែងមាន ដោយអំណាចនៃកិរិយាឃើញទ្រព្យដែលជារបស់នៃបុគ្គលដទៃ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**អភិជ្ឈាយ ឱលោកេតា ហោតិ**'។ ម្យ៉ាងទៀត របស់ (ឯណា) ដែលខ្លួនសំឡឹងរំពៃហើយ ដោយអភិជ្ឈា, បុគ្គលរមែងសំឡឹងរំពៃនូវរបស់នោះ ដូចបុគ្គលឃើញវត្តុដែលគេតាំងទុក ក្នុងទីណាមួយ ដោយជាក់ច្បាស់ យ៉ាងនោះឯង ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**អភិជ្ឈាយ ឱលោកេតា ហោតិ**"។ ពាក្យថា '**កម្មបថភេទោ ន ហោតិ**' មានសេចក្តីថា ការបែកធ្លាយនៃកម្មបថ រមែងមិនមាន ដោយហេតុត្រឹមតែសេចក្តីលោភ

តែមួយយ៉ាង ព្រោះសេចក្តីលោភនោះ មិនប្រព្រឹត្តទៅ ដោយអំណាចនៃកិរិយាបង្អោនចូលមកឡើយ ។ ការបែកធ្លាយនៃកម្មបថ រមែងមាន ដោយវិធីណា, ដើម្បីនឹងសំដែងនូវវិធីនោះ ទើបព្រះអដ្ឋកថាចារ្យពោល ថា **'ឃទា បន'** ដូច្នេះជាដើម ។ បុគ្គលរមែងបង្អោនចូលមក ដោយភាពជាទ្រព្យរបស់ខ្លួន (ក្នុងកាលណា ការបែកធ្លាយនៃកម្មបថ រមែងមាន ក្នុងកាលនោះ) ។ បទថា **'វិបន្នចិត្តោ'** គឺ ជាអ្នកមានចិត្ត ត្រូវសេចក្តីព្យាបាទ ឲ្យដល់ហើយនូវសេចក្តីវិបត្តិ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'បូតិភូតចិត្តោ'** ។ ព្រោះថា សេចក្តីព្យាបាទ រមែងញុំងភាពមិនល្អ (ស្អុយ) នៃចិត្តឲ្យកើតឡើង ប្រៀបដូចជាថ្នាំពិសញុំងលោហិត (មិនល្អ) ឲ្យកើតឡើងដូច្នោះ ។ ២ បទថា **'ទោសេន ទុដ្ឋចិត្តសង្កប្បោ'** មានសេចក្តីថា ជាអ្នកមានសេចក្តីត្រិះរិះ ក្នុងចិត្ត ត្រូវសេចក្តីក្រោធប្រទូសរ៉ាយហើយ ប្រៀបដូចជាភេសជ្ជៈមានទឹកដោះរាវថ្លាជាដើម ត្រូវថ្នាំពិសចូលជ្រៀតជ្រែកហើយ" ។

ជីកានៃភយភេរវសូត្រ ថា "បទថា **'បកតិភាវវិជហនេន'** គឺ ព្រោះលះបង់នូវភាពជាប្រក្រតី ពោលគឺ ភវង្គចិត្តដែលបរិសុទ្ធ និងពោលគឺភាពជាចិត្តដែលមិនមានទោស ។ ក៏បុគ្គលអ្នកច្រើនដោយអភិជ្ឈា រមែងជាអ្នកលះបង់ភាពនៃចិត្តមិនមានទោសចោល

ព្រោះញុំាងធម៌ដែលមានទោសឲ្យកើតឡើង ។ បទថា **'វិបន្នចិត្តា'** គឺ ឈ្មោះថា ជាអ្នកមានចិត្តខូច ព្រោះភាពជាអ្នកមានចិត្ត គឺភាវៈនៃសេចក្តីមិនល្អ គឺកិលេសប្រទូសរ៉ាយហើយ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'កិលេសានុគតញ្ហិ ... បូតិកំ ហោតិ'** ។ បទថា **'បទុដ្ឋចិត្តសង្កប្បា'** គឺ ជាអ្នកមានចិត្ត ត្រូវទោសប្រទូសរ៉ាយហើយ ប្រៀបដូចជាទឹកមូត្រស្អុយ ដែលផ្សំគ្នាដោយថ្នាំពិសដូច្នោះ" ។

(៨១) ជីកានៃសល្លេខសូត្រថា "បទថា **'សម្មា'** គឺ មិនវិបរិត្ត, ទិដ្ឋិដែលឈ្មោះថា ល្អ គឺប្រសើរ ព្រោះមិនវិបរិត្តនោះឯង, ឈ្មោះថា វិញ្ញូជនសរសើរហើយ ព្រោះភាវៈជាទិដ្ឋិ គឺវិញ្ញូជនទាំងឡាយមានព្រះពុទ្ធជាដើមសរសើរហើយ ។ ក៏ទិដ្ឋិនោះ ឈ្មោះថា ដល់ភាពជាកម្មបថតែម្តង ព្រោះភាវៈនៃទិដ្ឋិនោះរាប់បញ្ចូលក្នុងកម្មបថ" ។

ជីកានៃសាលេយ្យកសូត្រ និង តិកនិបាត អង្គុត្តរនិកាយថា "មិច្ឆាទិដ្ឋិកបុគ្គល ពោលទានថា **'ទិន្នំ'** ដូច្នេះ ដោយសំដៅយកទេយ្យធម៌ជាប្រធាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលថា **'ទានស្ស ផលាភាវំ សន្ធាយំ វទតិ'** ដូច្នេះ ។ ក៏មិច្ឆាទិដ្ឋិក-បុគ្គល រមែងហាមនូវវត្ថុដែលបុគ្គលឲ្យហើយ យ៉ាងដូចម្តេច ។

នៃយ សូម្បីក្នុងពាក្យថា 'យិដ្ឋំ ហុតំ' នេះ ក៏នៃយនេះដូចគ្នាដែរ ។ មហាទានដែលទូទៅ ដល់ជនទាំងពួង ឈ្មោះថា មហាយាគៈ ។ សក្ការៈដែលគេគប្បីធ្វើ ដើម្បីពួកភ្ញៀវ ឈ្មោះថា បហោនកសក្ការៈ ។ ផលគឺអានិសង្ស និង ផលជាគ្រឿងហូរចេញ ឈ្មោះថា ផល ។ ផលដូចគ្នា ឈ្មោះថា វិបាក ។ ពាក្យថា 'បរលោកេ ឋិតស្ស អយំ លោកោ នត្ថិ' មានសេចក្តីថា លោកនេះ គឺបុគ្គលអ្នកស្ថិតនៅក្នុងបរលោក គប្បីបាន ព្រោះកម្ម រមែងមិនមាន ។ ពាក្យថា 'ឥធលោកេ ឋិតស្សាបិ បរលោកោ នត្ថិ' មានសេចក្តីថា បរលោក គឺបុគ្គលអ្នកស្ថិតនៅ ក្នុងលោកនេះ គប្បីបាន ព្រោះកម្ម រមែងមិនមាន ។ មិច្ឆាទិដ្ឋិកបុគ្គល ពោលហេតុ ក្នុងឥធលោក និងបរលោកនោះថា 'សត្វទាំងឡាយទាំងពួង រមែងខាតសូន្យ ក្នុងភពនោះៗឯង' ដូច្នេះ ។ សត្វទាំងឡាយនេះ ស្ថិតនៅ ក្នុងទីណា ។ មានភព កំណើត និង គតិជាដើម រមែងខាតសូន្យ គឺ រមែងវិនាសទៅ ដោយសេចក្តីវិនាសដែលមិនមានពូជបន្ត ក្នុងទីនោះៗឯង ។ បទថា 'ផលាភាវវសេន' គឺ មិច្ឆាទិដ្ឋិកបុគ្គលពោលថា 'មាតានិងបិតា មិនមាន' ដោយអំណាចការមិនមានផល នៃការប្រតិបត្តិត្រូវ និងការប្រតិបត្តិខុស ក្នុងមាតាបិតាទាំងឡាយ ។ មិនមែនពោលដោយអំណាចការមិនមានមាតាបិតាទេ ។ ទាំងមិនមែនពោល

ដោយអំណាចការមិនមាន នៃការប្រតិបត្តិត្រូវ និងការប្រតិបត្តិខុស ក្នុងមាតាបិតាទាំងឡាយនោះឡើយ ព្រោះការប្រតិបត្តិត្រូវនិងការប្រតិបត្តិខុសក្នុងមាតាបិតាទាំងនោះ ជាកិច្ចជាក់ច្បាស់ដល់លោក ។ មិច្ឆាទិដ្ឋិកបុគ្គលពោលថា 'សត្វដែលអណ្តែតឡើងមកកើត មិនមាន' ដើម្បីសំដែងថា 'ធម្មតាការកើតឡើងនៃសត្វទាំងឡាយនេះ ប្រៀបដូចជាការកើតឡើងនៃដុំពពុះទឹក, មិនមែនមានការចុតិជាខាងដើម តែម្យ៉ាងឡើយ' ដូច្នេះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**ចវិត្វា ឧបបជ្ជនកសត្តា នាម នត្ថីតិ វទតិ**' ដូច្នេះ ។ ព្រះអដ្ឋកថាចារ្យពោលថា '**យេ ឥមញ្ច . . . ទីបេតិ**' ដូច្នេះ ដើម្បីនឹងសំដែងសេចក្តីបំណង របស់មិច្ឆាទិដ្ឋិកបុគ្គលថា 'ធម្មតាបុគ្គលអ្នកឈ្មោះថា ជាសមណៈ កាលដឹងតាមសេចក្តីពិតត្រង់ មិនគួរពោលនូវពាក្យអ្វីៗ ដល់អ្នកណាមួយឡើយ គប្បីជាអ្នកសង្រួម, ឈ្មោះថាសេចក្តីអួតអាង គប្បីមានដោយប្រការដទៃ ។ ក៏បុគ្គលដទៃ នឹងប្រាប់អ្វី ដល់បុគ្គលដទៃនុ៎ះ ? ។ ការជឿដល់វាទៈ របស់ខ្លួន យ៉ាងដូច្នោះ រមែងមិនមាន ដល់អ្នកណាមួយឡើយ ព្រោះសេចក្តីខាតសូន្យ ក្នុងទីនោះៗ ឯង' ដូច្នេះ" ។

(៨២) ដីកាកោសលសំយុត្ត ថា "ដោយបទថា '**មហាសារា**' នេះ ព្រះអដ្ឋកថាចារ្យសំដែង ថា 'ព្រះមានព្រះភាគ ទ្រង់អាទេសនូវ

រ អក្សរ ឱ្យទៅជា ល អក្សរ ហើយទ្រង់ត្រាស់ថា 'មហាសាលា' ដូច្នេះ ដូចជាឧទាហរណ៍ថា **បុរត្ថិយោ** ជា **បុលត្ថិយោ** ដូច្នោះ ។ បទថា 'មហាសារប្បត្តា' គឺ ដល់នូវទ្រព្យដែលមានខ្លឹមសារច្រើន បានដល់ មានទ្រព្យប្រមាណ ១០០ កោដិ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងដូច្នេះដែរ ។ អាចារ្យពួកខ្លះពោលថា '៦ អម្ពណៈ ឈ្មោះថា ១ តុម្ពៈ (១ ផ្តិល)" ។

(៨៣) ព្រះអាចារ្យឈ្មោះមោគ្គល្លានៈ ពោលទុកក្នុងវេស្សវគ្គ ថា "១០ អម្ពណៈ ត្រូវជា ១ កុម្ភៈ" ដូច្នេះ ។

នំយនៃដីកាវេស្សវគ្គនោះថា "១ ទូកដៃ ឈ្មោះថា ១ កុឌុវៈ, ៤ កុឌុវៈ ត្រូវជា ១ បត្ថៈ, ៤ បត្ថៈ ត្រូវជា ១ អាឡ្ហកៈ, អាចារ្យពួកខ្លះពោលថា 'តុម្ពៈ' ដូច្នេះក៏មាន, ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ១១ ទោណៈ ត្រូវជា ១ អម្ពណៈ, អាចារ្យពួកខ្លះពោលថា 'អម្ពណៈ' ដូច្នេះខ្លះក៏មាន ។ ១០ អម្ពណៈ ប្រមាណ ១១០ ទោណៈ ឈ្មោះថា ១ កុម្ភៈ ។ ព្រះអដ្ឋកថាចារ្យសំដែងគ្រឿងរង្វាល់ យ៉ាងពិសេស ១ យ៉ាង ឈ្មោះថា បត្ថៈ ដោយឈ្មោះថា 'ឃដៈ' ដោយបទថា 'កុម្ភោ' ដូច្នេះ" ។

(៨៤) ដីកានៃសាលេយ្យកសូត្រថា 'ទេវតាណា តែងទៅជាមួយគ្នា គឺ ទៅរួមគ្នា ហេតុនោះ ទេវតានោះ ឈ្មោះថា ជាអ្នក

ទៅជាមួយគ្នា គឺ ជាអ្នកប្រព្រឹត្តទៅរួមគ្នា, ភាវៈនៃទេវតាអ្នកទៅជាមួយគ្នានោះ ឈ្មោះថា **សហព្យតា** បានដល់ សេចក្តីប្រព្រឹត្តិទៅរួមជាមួយគ្នា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលហើយថា **'សហភាវំ ឧបគច្ឆេយ្យុំ'** ដូច្នេះ ។ ពួក គឺ ប្រជុំ នៃព្រហ្មទាំងឡាយ ហេតុនោះ ឈ្មោះថា ពួកនៃព្រហ្មទាំងឡាយ, ទេវតាទាំងឡាយណា ទៅហើយ ក្នុងពួកនៃព្រហ្មនោះ ហេតុនោះ ទេវតាទាំងឡាយនោះ ឈ្មោះថា ជាអ្នកទៅហើយក្នុងពួកនៃព្រហ្ម ព្រោះទេវតាទាំងឡាយនោះ ជាអ្នករាប់បញ្ចូលក្នុងពួកនៃព្រហ្មនោះ ។ ក៏ពាក្យថា **'ព្រហ្មកាយិកា'** នោះ គប្បីជាឈ្មោះ របស់ពួកព្រហ្មទាំងអស់នោះ ក៏ពិតមែន ។ ទុកជាដូច្នោះ ពាក្យថា **'ព្រហ្មកាយិកា'** នេះ ជាឈ្មោះ របស់ទេវតាទាំងឡាយ ដែលសេសសល់អំពីទេវតាជាន់ខ្ពស់ ។ មានទេវតាជាន់ទុតិយជ្ឈានជាដើមនោះ បណ្ឌិតគប្បីជ្រាបដោយពលវិទ្ធន័យ ដែលព្រះមានព្រះភាគទ្រង់ចាត់ទុកហើយ ក្នុងជាន់ខ្ពស់ ដោយបទថា **'អាភានំ'** ដូច្នេះជាដើម ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'ព្រហ្មកាយិកានំ ទេវានន្តិ បឋមជ្ឈានភូមិទេវានំ'** ដូច្នេះ ។ ទេវតាឈ្មោះថា អាភា ផ្នែកមួយ រមែងមិនមាន ព្រោះទេវតាមានទេវតាឈ្មោះថា បរិត្តាភាជាដើមនុ៎ះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់រួមបញ្ចូលជាមួយគ្នា ដោយភាពស្មើគ្នា

នៃភាពជាអ្នកមានរស្មី ។ ពាក្យថា **'អាភា'** នុ៎ះ ជាឈ្មោះរបស់ទេវតាឈ្មោះបរិត្តាភាជាដើម ដូចជាពាក្យថា **'ព្រហ្មកាយិកា'** ជាឈ្មោះ របស់ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា និង មហាព្រហ្មទាំងឡាយ យ៉ាងដូច្នោះ ។ ព្រះអដ្ឋកថាចារ្យ រួបរួមព្រះបាលីនេះថា **'អប្បមាណាភានំ ទេវានំ អាភស្សរានំ ទេវានំ'** ដូច្នេះ ចូលជាមួយ **អាទិ** សព្ទ ក្នុងពាក្យថា **'បរិត្តាភានន្តិ អាទិ បន'** ដូច្នេះ ។ ២ បទថា **'ឯកតោ អគ្គហេត្វា'** គឺ មិនកំណត់យកទេវតាឈ្មោះបរិត្តាភាជាដើម ដោយភាពជាពួកជាមួយគ្នាថា 'មានរស្មី' ឬថា មានកាយជាសភាពតែមួយ និង មានសញ្ញាជាធម្មជាតផ្សេងៗគ្នា' ដូច្នេះ ។ កំណត់យក ដោយភាពផ្សេងៗគ្នា នៃទេវតាទាំងឡាយនោះតែប៉ុណ្ណោះ គឺ ទេវតាដែលព្រះអដ្ឋកថាចារ្យ ពោលហើយថា **'អាភា'** ដូច្នេះតែប៉ុណ្ណោះ ។ ២ បទថា **'ភេទតោ គហណំ'** គឺ កិរិយាផ្សេងពីគ្នា បានដល់ ការប្លែកផ្សេងគ្នា នៃហេតុ គឺ ភាវៈនៃហេតុជាបច្ច័យផ្សេងគ្នា, កំណត់យកទេវតា មានទេវតាឈ្មោះថាបរិត្តាភាជាដើម ដោយអំណាចភាវៈ នៃហេតុជាបច្ច័យប្លែកផ្សេងអំពីគ្នានោះ " ។

(៨៥) ជីកាអាកង្ខេយ្យសូត្រថា " ២ បទថា **'អាសវានំ ខយា'** គឺ ព្រោះកិរិយាគាស់រំលើងបានដាច់ខាត នូវអាសវៈទាំង

ឡាយ ដែលនៅសេសសល់ អំពីអាសវៈដែលព្រះអរិយៈ ឱ្យអស់ទៅ
ហើយ ដោយមគ្គខាងក្រោម ដោយព្រះអរហត្តមគ្គ ។ ក៏ព្រោះ
អរហត្តមគ្គ មិនមែនញុំាងអាសវៈ ឱ្យអស់ទៅ តែម្យ៉ាងប៉ុណ្ណោះទេ,
តាមពិត រមែងញុំាងកិលេសទាំងពួង ដែលនៅសេសសល់ ឱ្យអស់
ទៅជងដែរ, ហេតុដូច្នោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា
'សព្វក្កិលេសានំ ខយា' ដូច្នេះ ។ តាមពិត **អាសវៈ** សព្ទ
ក្នុងពាក្យថា **'អាសវានំ ខយា'** នេះ គ្រាន់តែជាគ្រឿងចូលទៅ
កំណត់ ។ ឈ្មោះថា មិនមានអាសវៈ ព្រោះអាសវៈទាំងឡាយ មិន
ចូលទៅដល់ សូម្បីភាពជាអារម្មណ៍បាន ។ ក៏ព្រោះសូម្បីការនៅ
សេសសល់ នៃអាសវៈទាំងឡាយ ក្នុងពាក្យថា **'អាសវានំ ខយា'**
នេះ រមែងមិនមាន, ហេតុដូច្នោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា
'អាសវវិរហិតំ' ដូច្នេះ ។ អធិប្បាយថា 'សមាធិ ព្រះមានព្រះ
ភាគទ្រង់ត្រាស់ ដោយយកចិត្តជាប្រធាន ដូចជាឧទាហរណ៍ថា
នរជនជាអ្នកមានបញ្ញា តាំងនៅក្នុងសីល គប្បីញុំាងចិត្ត និង បញ្ញា
ឱ្យបានចំរើន យ៉ាងដូច្នោះ' ។ ពាក្យថា **'រាគតោ វិមុត្តត្តា**
អវិជ្ជាយ វិមុត្តត្តា' នេះ បណ្ឌិតគប្បីឃើញថា ជាពាក្យសំដែងនូវ
ធម៌ដែលស្ងប់រម្ងាប់ ចាកធម៌ដែលជាសឹកសត្រូវដោយត្រង់ ព្រោះ
បាបធម៌ទាំងឡាយឯទៀតក្រៅអំពីនោះ ជាធម៌ស្ងប់រម្ងាប់នឹងថ្កល់ ។

ឥឡូវនេះ ព្រះអដ្ឋកថាចារ្យពោលពាក្យថា **'វុត្តញ្ហេតំ'** ដូច្នេះ ជាដើម ដើម្បីនឹងសំដែងនូវភាវៈ នៃសមាធិ និង បញ្ញា ជាធម៌ដែលជាសឹកសត្រូវ ចំពោះរាគៈ និង អវិជ្ជានោះឯង ដោយជាទីមក ។ បទថា **'សមថផលំ'** មានសេចក្តីថា ចេតោវិមុត្តិ ឈ្មោះថា ជាផលរបស់សមថៈ ព្រោះមានផលដូចគ្នានឹងផល នៃលោកុត្តរសមថៈ ដែលមានកម្លាំង គឺសមថភាវនាដែលជាលោកិយៈ នាំបញ្ជូនឲ្យទៅដល់វិបស្សនា ។ សូម្បីក្នុងពាក្យថា **'វិបស្សនាផលំ'** នេះ ក៏នัយនេះ ដូចគ្នាដែរ ។ បទថា **'អត្តនាយេវ'** ជាដើម គឺ ធ្វើនូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិ ឲ្យបានជាក់ច្បាស់ ដោយបញ្ញា របស់ខ្លួន ដែលរួចផុតនូវការអាស្រ័យអ្នកដទៃ និង ការប្រកាន់យកនូវនัយរបស់អ្នកដទៃ ហើយបានសម្រេចភាវនា ដែលមិនបានសិក្សាអំពីពាក្យរបស់បុគ្គលដទៃ ប្រៀបដូចជាធ្វើឲ្យជាក់ច្បាស់ ដោយញាណមានសុតមយញាណជាដើម, អធិប្បាយថា 'មិនមែនដោយបញ្ញាដែលជាញាណ របស់ព្រះសយម្ភូឡើយ' ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'អបរប្បច្ចយេន ញត្វា"** ។

(៨៦) ដីកាសាលេយ្យកសូត្រថា "ពាក្យថា **'ឥតិ ភគវា អាសវក្ខយំ ទស្សេត្វា'** មានសេចក្តីថា ព្រះមានព្រះភាគ កាលនឹងចំណែកនូវធម្មចរិយសមចរិយា ឲ្យជាផ្លូវប្រតិបត្តិ ដែលញុំាងសត្វ

ឱ្យទៅដល់សុគតិ ដែលអាស្រ័យវដ្តៈ ឱ្យទៅជាផ្លូវប្រតិបត្តិដែលញុំាង
សត្វឱ្យដល់នូវការអស់ទៅនៃអាសវៈ ដែលអាស្រ័យនូវវិវដ្តៈ ឈ្មោះ
ថា ទ្រង់សំដែងនូវធម៌ជាទីអស់ទៅនៃអាសវៈ ទ្រង់ញុំាងធម៌ទេសនា
ឱ្យចប់ហើយ ដោយធម៌ដែលជាកំពូល គឺព្រះអរហត្ត យ៉ាងដូច្នេះ ។
២ បទថា **ឥធ បត្វា** គឺ តាំងទុកហើយ ក្នុងនិទ្ទេសនៃកិរិយា
ប្រព្រឹត្តិស្មើ ពោលគឺការប្រព្រឹត្តិតាមធម៌នេះ ។ ២ បទថា
ទេវលោកា សមានេតព្វា គឺ បណ្តិតគប្បីរួបរួមទេវលោកទាំង
២៦ ជាន់មក ។ ២ បទថា **វីសតិ ព្រហ្មានោ** មានសេចក្តីថា
ព្រហ្មលោក ២០ ជាន់ ដោយអំណាចនៃពួកព្រហ្មដែលរាប់បញ្ចូល
ក្នុងភពនោះៗ ។ បទថា **កុសលកម្មបថេហិ** មានសេចក្តីថា
ព្រះមានព្រះភាគទ្រង់សំដែងការកើតឡើង (ក្នុងទេវលោក) ព្រោះ
កុសលកម្មបថទាំងឡាយ ដែលជាកម្មបច្ច័យ និង ឧបនិស្សយបច្ច័យ
និងជាឧបនិស្សយបច្ច័យតែម្យ៉ាង ។ ២ បទថា **តិណ្ណំ សុចរិតានំ**
គឺ នៃសុចរិតដែលជាកាមាវចរ ៣ ប្រការ ។ ក៏សព្ទថា **កាមាវចរ**
ក្នុងបទសមាសនេះ លោកពោលហើយ ដោយការសំឡឹងយកនូវ
មនោសុចរិត ។ ដោយបទថា **វិបាកេនេវ** នេះ ព្រះអដ្ឋកថាចារ្យ
សំដែងថា ការកើតឡើង រមែងមានបាន ព្រោះការញុំាងវិបាកឱ្យ
កើតឡើងតែប៉ុណ្ណោះ, មិនមែនមាន ព្រោះហេតុត្រឹមតែភាពជា

ឧបនិស្ស័យឡើយ ដូច្នេះ ។ ព្រះអដ្ឋកថាចារ្យ ពោលពាក្យជាអាទិ៍ ថា **'ទស កុសលកម្មបថា'** ដូច្នេះ ដើម្បីនឹងបើកបង្ហាញសេចក្តី ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា **'ឧបនិស្សយវសេន'** តែម្យ៉ាង ។ បណ្ឌិតគប្បីនាំបទថា **'សីលេ បតិដ្ឋាយ'** ដូច្នេះ មកសម្ព័ន្ធ សូម្បីក្នុងបទទាំងឡាយថា **'ទុតិយាទីនិ ភាវេត្វា'** ដូច្នេះជាដើម ។ មានបុច្ឆាថា ' ក៏ព្រោះហេតុអ្វី ? ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'ឧបនិស្សយវសេន'** ដូច្នេះ ក្នុងដំណើរនេះ, ក្នុងបដិសម្ភិទាមគ្គ ព្រះសារីបុត្តត្ថេរ បានលើកយកសីលមកទុក ព្រោះឈានទាំងឡាយ សូម្បីព្រះយោគីបានហើយ ដោយន័យថា 'ការលះនូវនីវរណៈទាំងឡាយ ដោយបឋមឈាន ឈ្មោះថា សីល, ការវៀរចាក ឈ្មោះថា សីល, ចេតនា ឈ្មោះថា សីល, ការសង្រួម ឈ្មោះថា សីល, ការមិនប្រព្រឹត្តិកន្លង ឈ្មោះថា សីល' ដូច្នេះជាដើម មិនមែនទេឬ ? ហេតុនោះ កិរិយាកើតឡើង សូម្បីនៃពួកទេវលោកជាន់ខ្ពស់ ។ ព្រោះវិបាក ដោយអំណាចនៃសីលនោះ ទើបសមគួរ ដូច្នេះ ។ មានវិសជ្ជនាថា 'ព្រះអដ្ឋកថាចារ្យពោលថា **'ឧបនិស្សយវសេន'** ដូច្នេះ ទុកក្នុងអធិការនេះ ព្រោះសីលនោះ ជាបរិយាយទេសនា' ។ ក៏ព្រះអដ្ឋកថាចារ្យទាំងឡាយ ប្រកាសភាពនៃសីលនោះ ជាបរិយាយទេសនា ទុកក្នុងវិសុទ្ធិមគ្គ និង អដ្ឋកថានៃវិសុទ្ធិមគ្គនោះ ដោយ

ពាក្យថា 'ឯត្ថ ច បហានំ' ដូច្នេះជាដើម មែនពិត ។ ពិតមែនយ៉ាងដូច្នោះ សូម្បីក្នុងអធិការនេះ ព្រះអដ្ឋកថាចារ្យពោលការកើតឡើង ដែលប្រកាសភាពនៃសីលនោះ ជាឧបនិស្ស័យនៃរូបភព និងអរូបភពទាំងឡាយ ដោយពាក្យថា 'កុសលកម្មបថា ហិ សីលំ' ដូច្នេះជាដើម ។ ព្រះអដ្ឋកថាចារ្យពោលថា 'អសញ្ញិភវោ បន ...ន និទ្ទិដ្ឋោ' ដូច្នេះ ក៏ដើម្បីនឹងឆ្លើយបញ្ហា ដែលគប្បីមានថា 'ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់ចំណែក នូវសេចក្តីប្លែកផ្សេងគ្នានៃភព ដោយការប្រព្រឹត្តិធម៌ ដែលមានភាវនាជាលក្ខណៈ ទើបមិនទ្រង់យកអសញ្ញិភព មកបញ្ចូលរួម ក្នុងសាលេយ្យកសូត្រនេះផងដែរ ?" ។

(៨៧) ធម្មចរិយា មកហើយ ក្នុងសាលេយ្យកសូត្រ និងវេរញ្ជកសូត្រ ដែលជាលំដាប់ នៃសាលេយ្យកសូត្រនោះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដែងថា "ឧបនិស្ស័យ គឺ សីល រមែងញុំាងសត្វ ឱ្យសម្រេចសូម្បីនូវព្រះអរហត្តបាន" យ៉ាងដូច្នេះឯង ។

(ឧបនិស្ស័យ ៣ យ៉ាង)

ចំណែកក្នុងអដ្ឋកថាបឋមបណ្ណាសកៈ ក្នុងខន្ធកវគ្គ ព្រះអដ្ឋកថាចារ្យ ពោលថា 'ឧបនិស្ស័យទាំងនេះ មាន ៣ យ៉ាង គឺ

ទានូបនិស្សយ សីលូបនិស្សយ ភាវនូបនិស្សយ ។ បណ្តា ឧបនិស្សយទាំង ៣ យ៉ាងនោះ ទានូបនិស្សយ និង សីលូបនិស្សយ មានកម្លាំងខ្សោយ, ភាវនូបនិស្សយ មានកម្លាំង (ខ្លាំង) ។ ព្រោះ ថា ទានូបនិស្សយ និងសីលូបនិស្សយ រមែងញ្ចុាំងសត្វឲ្យបានសំរេច (តែ) មគ្គ ៣ និងផល ៣ (ប៉ុណ្ណោះ), (ចំណែក) ភាវនូបនិស្សយ រមែងញ្ចុាំងសត្វ ឲ្យបានសំរេចនូវព្រះអរហត្ត ។ ភិក្ខុអ្នកស្ថិតនៅ ក្នុងឧបនិស្សយដែលមានកម្លាំងខ្សោយ កាលព្យាយាម ប្រឹងប្រែង រមែងកាត់ផ្តាច់នូវគ្រឿងចង ដែលជាចំណែកខាងទាប ៥ ប្រការ ចោលហើយ ញ្ចុាំងមគ្គនិងផលទាំងឡាយ ៣ ឲ្យកើតឡើងបាន ដោយប្រការដូច្នេះ' ហើយពោលរឿងព្រះមិលក្ខត្ថេរ ។

(រឿងព្រះមិលក្ខត្ថេរ)

(៨៨) បានព្ឋមកថា ព្រះមិលក្ខត្ថេរនោះ ក្នុងពេលនៅជា គ្រហស្ថ ចិញ្ចឹមជីវិត ដោយការធ្វើបាណាតិបាត ដាក់ចម្រូង អន្នាក់ និង អង្គប់ មួយមុខ ១០០ ក្នុងព្រៃ សន្សំនូវបាបដ៏ច្រើន ។

ក្រោយមកថ្ងៃមួយ នាយមិលក្ខ: នោះ បរិភោគនូវសាច់ ដែលអាំងឆ្អិនហើយ ព្ធដ៏រងើកភ្លើង ក្រាច់ទៅ ក្នុងទីដាក់អន្នាក់ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ទើបបើកក្អមទឹក ដែល

តាំងនៅ ក្នុងទីមិនឆ្ងាយ នៃព្រះថេរ: អ្នកនៅក្នុងព្រៃមួយរូប កំពុងតែដើរចង្ក្រម កាលមិនឃើញទឹកសូម្បីត្រឹមតែទទឹកដៃ ក៏ក្រោធខឹង ហើយពោលថា "ម្នាលភិក្ខុ អ្នកបរិភោគភិក្ខា ដែលគ្រហស្ថទាំងឡាយប្រគេនហើយ ក៏សិងលក់, អ្នកមិន (ដង) ទឹកដាក់ក្នុងពាងទឹក គ្រាន់ធ្វើជាថ្នាំភ្នែកខ្លះ, ការធ្វើដូច្នេះ មិនសមគួរទេ"។ ព្រះថេរ: គិតថា "អាត្មាអញ បានដងទឹកដាក់ពាងពេញអស់ហើយ, ហេតុអ្វីទៅហ្នឹ ទើបនាយមិលក្ខ:នេះ ពោលដូច្នេះ ?" ដូច្នេះហើយ ក៏និមន្តទៅមើល បានឃើញពាងទឹកពេញប្រៀបហើយ ក៏យកស័ង្ខសម្រាប់ដងទឹក ដងចាក់ឲ្យពេញហើយទើបឲ្យ ។ នាយមិលក្ខ: នោះ ជឹកទឹកគ្រប់ ៣២ ស័ង្ខហើយ មានចិត្តសង្វេគថា "ធម្មតាពាងទឹកដែលមានទឹកពេញហើយ យ៉ាងដូច្នេះ អាស្រ័យកម្ម របស់អាត្មាអញ ទើបបានកើតឡើង ប្រៀបដូចជាអំបែងក្បឿងដ៏ក្តៅ, អត្តភាព (របស់អញ) ក្នុងអនាគតកាល នឹងកើតទៅជាយ៉ាងដូចម្តេចហ្នឹ ?" ដូច្នេះហើយ ក៏ពោលថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ មេត្តាញ៉ាំងខ្ញុំព្រះករុណាឲ្យបានបួសជង"។ ព្រះថេរ: ប្រាប់កម្មដ្ឋានមានស្បែកជាគម្រប់ ៥ ហើយ បានញ៉ាំងនាយមិលក្ខ: នោះ ឲ្យបួសហើយ ។ ស្ថានទីដែលនាយមិលក្ខនោះ សម្លាប់សត្វម្រឹគនិងជ្រូកជាច្រើន និងស្ថានទីដែលនាយមិលក្ខនោះ ដាក់អន្នាក់

និងអង្គប់ទាំងឡាយ រមែងប្រាកដ ដល់ភិក្ខុមិលក្ខៈនោះ ដែលកំពុង តែធ្វើនូវសមណធម៌, កាលបើភិក្ខុមិលក្ខៈនោះ តាមរលឹកនូវកម្ម ដែលបានធ្វើហើយនោះ, សេចក្តីក្តៅក្រហាយ ក៏កើតឡើង ក្នុង សរីររាងកាយ ។ ចិត្តរមែងមិនដើរទៅកាន់វិថីនៃកម្មដ្ឋាន ដូចជា គោកោង មិនព្រមដើរទៅកាន់គន្លងនង្គ័លដូច្នោះ ។ ភិក្ខុមិលក្ខៈ នោះ ត្រូវសេចក្តីមិនត្រេកអរគ្រប់សង្កត់ហើយ ដោយគិតថា "អាត្មា អញ នឹងធ្វើអ្វី ដោយភាពជាភិក្ខុ ?" ដូច្នេះហើយ ទៅកាន់សំណាក់ នៃព្រះថេរៈ ថ្វាយបង្គំហើយ ពោលថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះ ករុណាមិនអាចធ្វើសមណធម៌បានឡើយ" ។ ព្រះថេរៈ ពោលថា "ចូរអ្នកធ្វើនូវហត្ថកម្មចុះ" ។ ភិក្ខុនោះ បានទៅកាត់ដើមឈើ ស្រស់មានដើមខ្ទទម្ពរជាដើម មកធ្វើជាគំនរយ៉ាងធំ ហើយសួរថា "ឥឡូវនេះ ខ្ញុំព្រះករុណា នឹងធ្វើអ្វី ?" ។ ព្រះថេរៈ បានប្រាប់ថា "ចូរអ្នកដុតគំនរឈើនោះចោល" ។ ភិក្ខុនោះ ដុតភ្លើងក្នុងទិស ទាំង ៤ ហើយ ក៏មិនអាចដើម្បីដុតឲ្យឆេះបានឡើយ ។ ព្រះថេរៈ ពោលថា "បើដូច្នោះ ចូរអ្នកគេចចេញទៅ" ហើយធ្វើប្រឹថពីឲ្យ បែកចេញជាពីរផ្នែកហើយ នាំយកភ្លើងមានពន្លឺប្រមាណស្មើនឹង ពន្លឺអំពិលអំពែក អំពីអវចីនរក មកដាក់ លើគំនរឈើនោះឯង ។ ព្រះថេរៈនោះ ដុតគំនរឈើ ដែលមានទំហំប្រមាណប៉ុណ្ណោះ ឲ្យឆេះ

មួយរំពេច ដូចជាដុតស្លឹកឈើស្ងួតដូច្នោះ ។ គ្រានោះ ព្រះថេរៈលុះសំដែងអវចីនរកហើយ ទើបញ៉ាំងសេចក្តីសង្វេគ ឱ្យកើតឡើងដល់ភិក្ខុមិលក្ខៈនោះ ថា "បើអ្នកនឹងសឹក, អ្នកនឹងឆេះនៅ ក្នុងអវចីនរកនុ៎ះ" ។ ភិក្ខុមិលក្ខៈនោះ ចាប់ដើមតាំងពីបានឃើញអវចីនរកមក ក៏ភ័យស្លុតស្លន់ ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន តើព្រះពុទ្ធសាសនា ជាហេតុនាំសត្វឱ្យចេញចាកទុក្ខឬ ?" ដូច្នេះ ។ ព្រះថេរៈប្រាប់ថា "ម្នាលអ្នកដ៏មានអាយុ មែនហើយ" ។ ភិក្ខុនោះពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើន កាលបើព្រះពុទ្ធសាសនា ជានិយ្យានិកៈ, មិលក្ខៈនឹងធ្វើនូវការខ្ជើខ្ជូនឱ្យទាល់តែរួច, ចូរលោកម្ចាស់ កុំកង្វល់ឡើយ" ដូច្នេះ តាំងអំពីពេលនោះមក លោកធ្វើនូវសមណធម៌ ច្រឹងប្រែង ព្យាយាម ចំពេញវត្តប្រតិបត្តិ, កាលបើសេចក្តីងោកងុយ គ្របសង្កត់, ក៏បានដាក់ចំបើងទទឹក លើក្បាលហើយគង់ទម្លាក់ជើងទាំង ២ ចូលទៅក្នុងស្រះទឹក ។ ថ្ងៃមួយភិក្ខុនោះ ត្រងទឹកហើយ ដាក់ក្អមទឹកនៅលើភ្លៅ បានឈរង់ចាំការស្រក់ជាច់អស់ទៅ នៃទឹកពាង ។ លំដាប់នោះឯង ព្រះថេរៈឱ្យនូវនិទ្ទេសនេះ ដល់សាមណេរថា ÷

"យស រមែងចំរើនកុះករ ដល់បុគ្គលអ្នកមានសេចក្តី

ប្រឹងប្រែង មានស្មារតី មានការងារស្អាត ជាអ្នក
ពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់
នៅដោយធម៌ មិនមានសេចក្តីប្រមាទ"។

ភិក្ខុមិលក្ខៈនោះ បានបង្ហោននូវគាថា ទាំង ៤ បាទនោះ មក
ក្នុងខ្លួននុ៎ះឯងថា "ធម្មតាបុគ្គលអ្នកមានសេចក្តីប្រឹងប្រែង គប្បីដូច
ជាអាត្មាអញ, សូម្បីបុគ្គលអ្នកមានសតិស្មារតី ក៏គប្បីជាអ្នកដូចជា
អាត្មាអញដែរ ។ ល ។ សូម្បីបុគ្គលអ្នកមិនប្រមាទ ក៏ជាអ្នកគប្បី
ដូចជាអាត្មាអញផងដែរ"។ ភិក្ខុមិលក្ខៈនោះ លុះបង្ហោនគាថា
នោះ មកទុកក្នុងខ្លួន យ៉ាងដូច្នេះហើយ ឈរនៅក្នុងជំហ៊ានជើង
នោះឯង កាត់ផ្តាច់នូវសំយោជនៈ ដែលជាចំណែកខាងក្រោម ៥
យ៉ាងហើយ ញុំាងមគ្គនិងផលទាំងឡាយ ៣ ឲ្យកើតឡើងហើយ ។
រឿងព្រះមិលក្ខត្ថេរ ក្នុងអដ្ឋកថាទុតិយវគ្គ ឯកនិបាតអង្គុត្តរនិកាយ ។

(៨៩) ជីកានៃបឋមបណ្ណាសកៈ ក្នុងខន្ធកវគ្គនោះថា
"ឧបនិស្សយ គឺទាន ឈ្មោះថា ទានូបនិស្សយ, នីយ សូម្បីក្នុង
ឧបនិស្សយដ៏សេសសល់ ក៏នីយនេះដូចគ្នាដែរ ។ បណ្តាឧបនិស្សយ
ទាំង ៣ យ៉ាងនោះ ទានូបនិស្សយ រមែងមាន ព្រោះការគ្រប សង្កត់
នូវសេចក្តីលោភដ៏មានកម្លាំង ក្នុងវត្ថុទាំងឡាយ មានបាយជាដើម,

ព្រោះហេតុនោះ បុគ្គលអ្នកច្រើនដោយទានូបនិស្សយ កាលប្រកបវិបស្សនារឿយ ៗ រមែងសម្រេចនូវព្រះអនាគាមិផលបាន ក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានសេចក្តីត្រៀម បានធ្វើទុកហើយ ក្នុងការលះបង់នូវកាមរាគៈ ។ បុគ្គលអ្នកមានសីលូបនិស្សយ ដ៏បរិសុទ្ធ ក៏យ៉ាងដូច្នោះដែរ គឺ កាលប្រកបនូវវិបស្សនារឿយ ៗ រមែងសម្រេច នូវព្រះអនាគាមិផលបាន ក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកមានសេចក្តីត្រៀម បានធ្វើទុកហើយ ក្នុងការស្ដប់ខ្ពើមអំពីទោស គឺកាមគុណ ។ មានពាក្យចោទសួរថា 'ប្រសិនជាកាលបើទានូបនិស្សយ និង សីលូបនិស្សយ ជាហេតុឲ្យបុគ្គលបានសម្រេចអនាគាមិផល ក្នុងកាលមិនយូរ យ៉ាងដូច្នេះហើយ, ព្រោះហេតុអ្វី ឧបនិស្សយទាំង ២ យ៉ាងនេះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា 'មានកម្លាំងខ្សោយ ?' ដូច្នេះ ។ គប្បីឆ្លើយថា 'ព្រោះឧបនិស្សយទាំង ២ យ៉ាងនោះ ជាបច្ច័យនៃវិជ្ជូបមញ្ញាណតែម្យ៉ាង ។ មែនពិត ទានូបនិស្សយ និង សីលូបនិស្សយទាំង ២ នោះ នឹងទៅជាឧបនិស្សយដែលមានកម្លាំងបាន ក៏ព្រោះបាននូវភាវនូបនិស្សយ ជាសំឡាញ់នុ៉ះឯង, ភាវនូបនិស្សយ មិនមែនជាសំឡាញ់ របស់ឧបនិស្សយទាំង ២ យ៉ាងនោះ តែម្យ៉ាងឡើយ, ក៏ភាវនា ឈ្មោះថាជាឧបនិស្សយដែលមានកម្លាំង ព្រោះជាហេតុ យ៉ាងពិសេស នៃ

ការគ្រាស់ដឹង ។ ពិតមែនយ៉ាងដូច្នោះ ភាវនានោះ ជាបច្ច័យយ៉ាងពិសេស របស់វិជ្ជុបមញ្ញាណ រមែងញុំាងសត្វឲ្យសម្រេចព្រះអរហត្ត បាន ។ បទថា **'សោ'** នោះ សំដៅយកព្រះមិលក្ខត្ថេរ ។ ស្ថានទីសម្លាប់សត្វនិងជ្រូកជាច្រើន និង ស្ថានទីដែលដាក់អន្ទាក់ និង អង្គប់ទាំងឡាយ រមែងប្រាកដ ដោយខណៈចិត្តតែមួយ, ចិត្តរបស់ព្រះមិលក្ខត្ថេរ មិនចូលទៅកាន់វិថីនៃកម្មដ្ឋាន ដូចជាគោកោងមិនព្រមដើរទៅតាមគន្លងនង្គ័ល ដូច្នោះ ។ បទថា **'តត្ថ'** គឺ ក្នុងគំនរឈើស្រស់ ។ បទថា **'ឧទកមណិកានំ'** គឺ នៃខ្សែទឹកទាំងឡាយ ។ ព្រះមិលក្ខត្ថេរ ឈ្មោះថា បានបង្ហោនគាថានោះ មកទុកក្នុងខ្លួននុ៎ះឯង ព្រោះភាវៈនៃធម៌ទាំងឡាយដែលព្រះថេរៈសំដែងហើយ ដោយគាថាពួជខាងដើម ជាធម៌ដ៏បរិបូណ៌មាននៅក្នុងខ្លួន តាំងពីពេលបួសមកហើយ ។ ហេតុនោះ ព្រះមិលក្ខត្ថេរទើបពោលពាក្យថា **'ឧដ្ឋានវតា នាម'** ដូច្នេះជាដើម ។ ក៏ព្រះមិលក្ខត្ថេរនេះ ជាអ្នកមានការគោរព មានការជឿស្តាប់ ចំពោះការសិក្សា ជាអ្នកបំពេញវត្តនិងវត្តកប ជាអ្នកមានសីលដ៏បរិសុទ្ធស្ថិតនៅ, ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា **'ទុព្ភលូបនិស្សយេ បិតោ'** ដូច្នេះ" ។

ពណ៌នាអំពីការប្រព្រឹត្តិធម៌ ចប់ ។

* * *

ពណ៌នាអំពីការសង្គ្រោះញាតិ

---

(៩០) ព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងមង្គលទីបនីនេះថា "ជនទាំងឡាយដែលជាប់ទាក់ទងគ្នា ខាងបិតាក្តី ខាងមាតាក្តី រហូតដល់យុគនៃបិតាមហៈទី ៧ ឈ្មោះថា ញាតិ"។

អដ្ឋកថានៃចង្កីសូត្រ អដ្ឋកថានៃបឋមវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ និង អដ្ឋកថានៃចតុត្ថវគ្គ នៃតតិយ-បណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា "បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា **'យាវ សត្តមា បិតាមហយុគា'** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷ បិតា របស់បិតា (ជីតា) ឈ្មោះថា បិតាមហៈ, យុគនៃបិតាមហៈ ឈ្មោះថា បិតាមហយុគ។ ប្រមាណនៃអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា **'យុគ'**។ ក៏ពាក្យថា **'យុគ'** នោះ គ្រាន់តែជាពាក្យពោលចំពោះប៉ុណ្ណោះ, ប៉ុន្តែដោយសេចក្តី បិតាមហៈប៉ុណ្ណោះ ឈ្មោះថា បិតាមហយុគ។ បុព្វបុរសទាំងឡាយទាំងពួង បន្ទាប់អំពីបិតាមហៈនោះឡើងទៅ ព្រះមានព្រះភាគ ទ្រង់កំណត់យក ដោយ **បិតាមហ** សព្ទនុ៎ះឯង"។

ជីកានៃចង្កីសូត្រថា "បិតា និងមាតា ឈ្មោះថា បិតរោ (បិតានិងមាតាទាំងឡាយ), បិតានិងមាតា របស់បិតានិងមាតា

ទាំងឡាយ ឈ្មោះថា បិតាមហៈ, យុគ នៃបិតាមហៈទាំងឡាយនោះ ឈ្មោះថា បិតាមហាយុគ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសេចក្តី ក្នុងពាក្យនេះ យ៉ាងនេះថា 'រហូតដល់បិតាមហាយុគទី ៧' ។ ក៏ **យុគ** សព្ទ ក្នុងបទថា **'បិតាមហាយុគា'** នុ៎ះ បណ្ឌិតគប្បីឃើញដោយឯកទេសន័យថា 'យុគ និង យុគ ឈ្មោះថា យុគា' ដូច្នេះ ។ ក៏ដោយអធិប្បាយយ៉ាងនេះ ទើបបានជាលោកកំណត់យកហើយជាបន្តាប់ឡើងទៅ ក្នុងយុគនោះៗ ដោយពិត ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា **'តតោ ឧទ្ធំ សព្ពេបិ បុព្ពបុរិសា បិតាមហគ្គហណេនេវ គហិតា'** ដូច្នេះ ។ មួយទៀត **បុរិស** សព្ទ ក្នុងបទថា **'បុព្ពបុរិសា'** នុ៎ះ បណ្ឌិតគប្បីឃើញថា 'លោកធ្វើហើយដោយអំណាចការសំដែងបុព្វបុរសថ្នាក់ខ្ពស់ចំផុត' ។ ពាក្យបាលីថា **'មាតិតោ'** ក៏រមែងសម្រេចសេចក្តី យ៉ាងដូច្នេះឯង" ។

(៩១) ជីកានៃតិកនិបាត អង្គុត្តរនិកាយថា "បិតា និង... យុគនៃបិតាមហៈទាំងឡាយនោះ ឈ្មោះថា បិតាមហាយុគ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសេចក្តី ក្នុងពាក្យនុ៎ះ យ៉ាងដូច្នេះថា 'រហូតដល់យុគ នៃបិតាមហៈ គឺ គូនៃបិតាមហៈទី ៧' ។ ប៉ុន្តែ ព្រះអដ្ឋកថាចារ្យ មិនបានកំណត់យកគូ ទើបពោលទុក ក្នុងអដ្ឋកថាថា **'យុគន្តិ អាយុប្បមាណំ វុច្ចតិ'** ដូច្នេះ ។ លោកបានសំដែង

ភាវៈនៃយុគសព្ទជាសព្ទ មិនមានប្រយោជន៍ថា 'បិតាមាហៈប៉ុណ្ណោះ ឈ្មោះថា បិតាមហាយុគ' ។ មួយទៀត បុរិសសព្ទ ក្នុងបទថា 'បុព្វបុរិសា' នុ៎ះ រមែងសម្រេចសេចក្តីយ៉ាងនេះ" ។

ជីកាចញ្ចកនិបាត អង្គុត្តរនិកាយថា "បិតានិង . . .យុគនៃបិតាមហៈទាំងនោះ ឈ្មោះថា បិតាមហាយុគ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសេចក្តី ក្នុងពាក្យនោះ យ៉ាងដូច្នេះថា 'បិតានិង... រហូតដល់យុគ នៃបិតាមហៈ គឺគូនៃបិតាមហៈទី ៧' ដូច្នេះ ។ ដោយអធិប្បាយយ៉ាងដូច្នេះឯង សូម្បីមាតាមហៈ លោកប្រកាន់យកហើយ ដោយបិតាមហសព្ទដូចគ្នាដែរ ។

ក្នុងអដ្ឋកថា មាតាមហសព្ទនោះ លោកមិនបានលើកយកមកសំដែងហើយមួយផ្នែក ។ ក៏យុគសព្ទ ក្នុងបទថា 'បិតាមហាយុគា' នោះ បណ្ឌិតគប្បីឃើញ ដោយឯកទេសន័យថា 'គូ និង គូ ឈ្មោះថា យុគា' ដូច្នេះ ។ ដោយអធិប្បាយយ៉ាងនេះឯង . . . ព្រះមានព្រះភាគទ្រង់ប្រកាន់យក ដោយបិតាមហសព្ទនុ៎ះឯង ។ មួយទៀត បុរិសសព្ទ ក្នុងបទថា 'បុព្វបុរិសា' នុ៎ះ . . .រមែងសម្រេចសេចក្តីយ៉ាងដូច្នេះឯង" ។

(៩២) ជនទាំងឡាយអ្នកជាប់ទាក់ទងគ្នា ទាំងអស់នោះ ឈ្មោះថា ជាញាតិ ព្រោះអត្ថថា គប្បីស្គាល់គ្នា ។ ដោយហេតុនោះ

ក្នុងអដ្ឋកថា ទើបលោកពោលថា "ជនទាំងឡាយនេះ គេរមែងដឹងថា '(ជាញាតិ) របស់ពួកយើង' ដូច្នេះ ព្រោះហេតុនោះ ជនទាំងឡាយនេះ ឈ្មោះថា ជាញាតិ"។

ជីកានៃគតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយថា "ជនទាំងឡាយណា រមែងដឹង និង គេក៏ស្គាល់បាន យ៉ាងនេះថា 'ជនទាំងឡាយនេះ ជាអ្នកនៅខាងក្នុង' ដូច្នេះ ហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា ញាតិ"។

អដ្ឋកថាបណ្ឌរជាតកថា "បទថា **'សបក្ខា'** គឺ ពួកញាតិទាំងឡាយ ដែលជាពួកស្មើគ្នា មានបេយ្យកៈ (តាទួតឬជីតា) ខ្ញីពុកមា និង ខ្ញីពុកធំខាងម្តាយ បងប្អូនស្រីរបស់ខ្ញីពុក ម្តាយមីង និង ម្តាយធំខាងម្តាយជាដើម"។

ជីកានៃនវវគ្គថា "តាទួតឬជីតា របស់បិតា និង មាតាទាំងឡាយ ឈ្មោះថា បេយ្យកៈ, បងប្អូនប្រុស របស់មាតា ឈ្មោះថា មាតុលៈ, បងប្អូនស្រី របស់បិតា ឈ្មោះថា បិតុច្ឆា, បងប្អូនស្រី របស់មាតា ឈ្មោះថា មាតុច្ឆា"។

(៩៣) ការជួយឧបត្ថម្ភ នូវពួកញាតិទាំងនោះ ដែលត្រូវសេចក្តីសាបសូន្យនៃភោគសម្បត្តិ ឬសេចក្តីសាបសូន្យ ព្រោះព្យាធិគ្របសង្កត់ហើយ ជាអ្នកមកហើយកាន់សំណាក់របស់ខ្លួន ដោយ

គ្រឿងបរិភោគ គ្រឿងស្លៀកពាក់ ទ្រព្យ និង ធញ្ញាហារជាដើម តាមកម្លាំង ឈ្មោះថា ការសង្គ្រោះ ។ ការសង្គ្រោះញាតិនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុបានសម្រេចនូវគុណវិសេសទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន មានការសរសើរជាដើម និង ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព មានការទៅកាន់សុគតិជាដើម ។ ព្រោះហេតុនោះ ការសង្គ្រោះញាតិនោះ បុគ្គលគប្បីធ្វើដោយពិត ។ មួយទៀត បុគ្គលអ្នកធ្វើការសង្គ្រោះញាតិនោះ ឈ្មោះថា រមែងធ្វើតាមព្រះពោធិសត្វ ។ មែនពិត ព្រះពោធិសត្វទាំងឡាយ កាលប្រព្រឹត្តនូវការប្រព្រឹត្តិជាប្រយោជន៍ដល់ញាតិ ក៏បានធ្វើហើយ នូវការសង្គ្រោះញាតិនុ៎ះឯង ។

ក្នុងដំណើរនោះ មានរឿងទាំងឡាយនេះ (ជាខុទាហរណ៍)

(រឿងសត្វសុនខ)

(៩៤) ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាសត្វសុនខ មានសត្វសុនខជាច្រើនចោមរោម នៅហើយក្នុងព្រៃស្មសានដ៏ធំ ។ ក្រោយមកថ្ងៃមួយ ព្រះរាជាក្រុងពារាណសី ទ្រង់ព្រះក្រសាលក្នុងព្រះឧទ្យានរហូតមួយថ្ងៃ, កាលបើព្រះអាទិត្យអស្តង្គតហើយ, ទើបស្តេចយាងទៅកាន់ព្រះនគរ ដោយរាជរថដ៏ប្រសើរ ។

ពួកមនុស្ស បានបញ្ឈប់រាជរថនោះ ត្រង់ទីព្រះលាននៃព្រះរាជា ។ កាលថើស្តៀងឆ្លាក់ រហូតរាត្រី, សត្វសុនខដែលគេចិញ្ចឹម ក្នុងព្រះរាជត្រកូលទាំងឡាយ ក៏នាំគ្នាចុះអំពីប្រាសាទនៃព្រះរាជាមក កកេរស៊ី នូវស្បែកសំរាប់រុំព័ទ្ធ និង ស្បែកសំរាប់ចងរាជរថ ។ ក្នុងថ្ងៃស្អែកឡើង ពួកមនុស្ស បានក្រាបទូលដល់ព្រះរាជាថា "បពិត្រព្រះសម្មតិទេព សុនខទាំងឡាយ ចូលមក តាមផ្លូវបង្ហូរទឹកហើយ បានកកេរស៊ី នូវស្បែកសំរាប់រុំព័ទ្ធនិងស្បែកសំរាប់ចងរាជរថអស់" ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យ របស់មនុស្សទាំងនោះហើយ ស្តេចទ្រង់ព្រះពិរោធ ចំពោះសត្វសុនខទាំងឡាយ ទើបទ្រង់ត្រាស់ថា "ពួកអ្នកទាំងឡាយ ចូរសម្លាប់សត្វសុនខទាំងឡាយចោល ក្នុងទីកន្លែងដែលពួកអ្នកឃើញហើយ ។" ។ តាំងពីពេលនោះមក សត្វសុនខទាំងឡាយ មានភ័យកើតឡើងហើយ ត្រូវមនុស្សសម្លាប់ ក្នុងទីកន្លែងដែលគេឃើញហើយ ។ ក៏បានគេចរត់ទៅកាន់សំណាក់ នៃព្រះពោធិសត្វ ។ ព្រះពោធិសត្វដឹងហេតុនោះហើយ ក៏គិតថា "ឱកាសរមែងមិនមាន ដល់សុនខដែលនៅខាងក្រៅទាំងឡាយ ក្នុងទីកន្លែងដែលគេថែរក្សា, កម្មនោះ នឹងពិតជាកម្ម របស់សត្វសុនខដែលគេចិញ្ចឹម ក្នុងរាជត្រកូលទាំងឡាយ ពួជខាងក្នុងព្រះរាជវាំងនុ៎ះឯង" ដូច្នេះហើយ ក៏ប្រាថ្នានឹងធ្វើនូវការសង្គ្រោះ ដល់ញាតិ

ទើបនឹករឭកដល់បារមីទាំងឡាយ ធ្វើនូវមេត្តាភាវនា ឲ្យប្រព្រឹត្តទៅ ខាងមុខហើយ អធិដ្ឋាន ថា "សូមកុំឲ្យអ្នកណាមួយ ហ៊ានបោះដុំដី ឬក៏អន្លង ពួជខាងលើ (ខ្លួន) ខ្ញុំឡើយ" ដូច្នេះហើយ ក៏ដើរចូល ទៅកាន់ព្រះនគរតែម្នាក់ឯងប៉ុណ្ណោះ ។ គ្រានោះ បុគ្គលអ្នក ដែលបានឃើញព្រះពោធិសត្វនោះហើយ ឈ្មោះថា ក្រឡេកមើល ព្រោះក្រោធខឹង សូម្បីតែម្នាក់ ក៏មិនមានឡើយ ។ ព្រះពោធិសត្វ ស្ទុះចូលទៅ ពួជខាងក្រោមព្រះរាជអាសនៈ នៃព្រះរាជាទ្រង់ ស្តេចគង់នៅហើយ ក្នុងសាលាវិនិច្ឆ័យ ។ លំដាប់នោះ រាជបុរស ទាំងឡាយ ប្រារព្ធ ដើម្បីនឹងបណ្តេញព្រះពោធិសត្វនោះចេញ ។ ព្រះរាជា ទ្រង់ហាមរាជបុរសទាំងនោះ ។ ព្រះពោធិសត្វ សម្រាក បន្តិចហើយ ក៏ចេញពីក្រោមព្រះទីនាំង ថ្វាយបង្គំព្រះរាជាហើយ ទើបក្រាបទូលសួរថា "ព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យរាជបុរសសម្លាប់ សត្វសុនខទាំងឡាយមែនឬ ?" ។

ព្រះរាជា. អើមែនហើយ យើងឲ្យសម្លាប់ ។

ព្រះពោធិសត្វ. បពិត្រព្រះអង្គជាធំជាងនរជន តើសត្វសុនខ ទាំងនោះ មានសេចក្តីខុសឆ្គង យ៉ាងដូចម្តេចទៅ ? ។

ព្រះរាជា. ពួកវាខាំស៊ីស្បែកជ្រាម និង ស្បែកចងរាជរថ ។

ព្រះពោធិសត្វ. ព្រះអង្គទ្រង់ជ្រាបសុនខដែលកកេរស៊ីឬ ? ។

ព្រះរាជា. យើងមិនដឹងទេ ។

ព្រះពោធិសត្វ. បពិត្រព្រះសម្មតិទេព ការដែលព្រះអង្គ មិនទ្រង់ជ្រាបហើយ ត្រាស់បញ្ជាឱ្យរាជបុរសសម្លាប់សុនខទាំងឡាយ ក្នុងទីកន្លែងដែលគេឃើញហើយ ។ នុ៎ះឯង មិនសមគួរឡើយ ។

ព្រះរាជា. យើងបញ្ជាឱ្យសម្លាប់សុនខថា 'អ្នកទាំងឡាយ ចូរសម្លាប់ពួកសុនខទាំងអស់ ក្នុងទីកន្លែងដែលខ្លួនឃើញវហើយ ។ នុ៎ះឯង' ព្រោះសុនខទាំងឡាយ ខាំស៊ីស្បែកជ្រាមរាជរថ ។

ព្រះពោធិសត្វ. ក៏មនុស្សទាំងឡាយនោះ សម្លាប់សុនខបានទាំងអស់ឬ ? ឬក៏ពួកសុនខដែលមិនបានត្រូវសម្លាប់មានសល់ ? ។

ព្រះរាជា. ពួកសុនខដែលមិនត្រូវសម្លាប់នៅមាន, ពួកសត្វសុនខដែលចិញ្ចឹម ក្នុងសំណាក់ របស់យើង មិនបានត្រូវសម្លាប់ ។

ព្រះពោធិសត្វ ក្រាបទូលថា "បពិត្រព្រះមហារាជ ក្នុងពេលឥឡូវនេះឯង ព្រះអង្គទ្រង់ត្រាស់ថា 'យើងបញ្ជាឱ្យរាជបុរសសម្លាប់សុនខថា 'ពួកអ្នក ចូរសម្លាប់សុនខទាំងឡាយ ក្នុងទីដែលខ្លួនឃើញហើយ ។ ទាំងអស់តែម្តង' ដូច្នេះ ឥឡូវនេះ ទ្រង់ត្រាស់ទៀតថា 'ពួកសត្វសុនខដែលចិញ្ចឹម ក្នុងសំណាក់របស់យើង មិនបានត្រូវសម្លាប់' ដូច្នេះ, កាលបើយ៉ាងដូច្នោះ ព្រះអង្គទ្រង់ជល់នូវអគតិ ដោយអំណាច នៃឆន្ទាគតិជាដើម មិនមែនទេឬ ? ក៏ឈ្មោះថា

កិរិយាដល់នូវអគតិ មិនសមគួរទេ និង មិនមែនជារាជធម៌ឡើយ, ឈ្មោះថា ព្រះរាជាទ្រង់ជាអ្នកស្វែងរកហេតុនិងមិនមែនជាហេតុ និង ទ្រង់ជាអ្នកដូចជាជញ្ជីង ទើបសមគួរ" ។ ព្រះរាជាទ្រង់ត្រាស់សួរថា "ម្នាលបណ្ឌិត ក៏អ្នកដឹងថា 'សុនខឈ្មោះឯណោះ កកេរស៊ីស្បែកនៃវេឬ ?" ។ ព្រះពោធិសត្វទូលថា "ពិតមែនហើយព្រះអង្គ ទូលព្រះបង្គំដឹង ស្បែករាជវេនោះ ពួកសុនខដែលព្រះអង្គចិញ្ចឹមក្នុងរាជត្រកូល កកេរស៊ីហើយ, សូមព្រះអង្គត្រាស់ឱ្យរាជបុរសនាំយកទឹកដោះរាវជូរ និង ស្មៅចិញ្ចៀនមកបានបន្តិចហើយ ត្រាស់ឱ្យច្របាច់ (លាយគ្នា) ហើយឱ្យបញ្ច្រុកសុនខទាំងឡាយនោះ" ។ ព្រះរាជាទ្រង់បានធ្វើហើយ យ៉ាងដូច្នោះ ។ សុនខទាំងឡាយ បានក្អួតនូវទឹកដោះរាវជូរ និង ស្មៅចិញ្ចៀន ដែលខ្លួនបានផឹកហើយ ។ ចេញមក ព្រមទាំងស្បែក ។ ព្រះរាជាទ្រង់ត្រេកអរហើយ ថា "ព្យាករណ៍របស់ស្តេចសុនខនេះ ប្រៀបដូចជាព្យាករណ៍ របស់ព្រះសព្វញ្ញុពុទ្ធ" ហើយ ទ្រង់បានបូជាព្រះពោធិសត្វ ដោយស្វេតច្ឆត្រ ។ ព្រះពោធិសត្វនោះ សំដែងធម៌ ដល់ព្រះរាជា ដោយធម្មចរិយគាថា ទាំងឡាយ ១០ មានជាអាទិ៍ ថា ÷

"បពិត្រព្រះមហារាជ ដ៏ជាក្សត្រ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ចំពោះព្រះជនក និង ព្រះជននីចុះ..." ដូច្នេះ

ហើយ ទូល ថា "សូមព្រះអង្គទ្រង់ស្តេច កុំបីប្រមាទឡើយ" ដូច្នេះ ហើយ បានញុំាងព្រះរាជាឱ្យទ្រង់ស្ថិតនៅ ក្នុងបញ្ចសីល ថ្វាយនូវ ស្វែតច្ឆ័ត្រត្រឡប់ទៅព្រះរាជាវិញហើយ ក៏បានគេចចេញទៅ ។ ព្រះរាជាទ្រង់បានប្រទានអភ័យ ដល់សព្វសត្វហើយ ទ្រង់តាំងនូវ និច្ចភត្ត ដូចជាព្រះក្រយាស្មោយ របស់ព្រះអង្គនុ៎ះឯង ដល់សុនខ ទាំងឡាយទាំងពួង បន្ទាប់ពីព្រះពោធិសត្វចុះមក ។ ជនទាំងឡាយ តាំងនៅក្នុងឱវាទ របស់ព្រះពោធិសត្វហើយ បំពេញកុសលទាំង ឡាយ មានទានជាដើម ក៏បានទៅកើត ក្នុងទេវលោកហើយ ។ កុក្កុរោវាទ បានប្រព្រឹត្តទៅហើយ រហូត ១ ម៉ឺនឆ្នាំ យ៉ាងនេះឯង ។

រឿង សត្វសុនខ ក្នុងអដ្ឋកថាកុក្កុរជាតក ក្នុងតតិយវគ្គ នៃឯកនិបាត ចប់ ។

(រឿងសត្វក្អែក)

(៩៥) ក្នុងអតីតកាល ព្រះពោធិសត្វបានសោយព្រះជាតិ ជាសត្វក្អែក មានក្អែកប្រមាណ ៨ ម៉ឺន ចោមរោមហើយ រស់នៅ ក្នុងព្រៃស្មសានដ៏ធំ ។ ក្រោយមកថ្ងៃមួយ បុរោហិតរបស់ ព្រះរាជាក្រុងពារាណសី ងូតទឹកក្នុងស្ទឹង ខាងក្រៅព្រះនគរហើយ ចូលទៅកាន់ព្រះនគរ ។ ក្នុងកាលនោះ មានសត្វក្អែកពីរ

ទំលើកំពូលខ្លោងទ្វារព្រះនគរ ។ បណ្តាក្លែកទាំង ២ នោះ ក្លែក ១ ពោលថា "នែសំឡាញ់ ខ្ញុំនឹងបន្ទោបង់ឧច្ចារៈ លើក្បាលព្រាហ្មណ៍នេះ" ។ ក្លែកក្រៅនេះហាម ថា "ចូរអ្នកកុំធ្វើឡើយ, បុគ្គលនេះ ជាឥស្សរជន, ធម្មតាពៀរវេរា ជាមួយនឹងឥស្សរជន ជាបាបធ្ងន់, ព្រោះថា ព្រាហ្មណ៍នេះ ក្រោធហើយ ក៏នឹងញ្ញុំងក្លែកទាំងអស់ឲ្យវិនាសអស់" ។ ក្លែកនោះ មិនជឿតាម ក៏បានធ្វើ យ៉ាងដូច្នោះ ។ ព្រាហ្មណ៍ក្រោធហើយ បានចងពៀរវេរា ចំពោះក្លែកទាំងឡាយ ។ គ្រានោះ ស្ត្រីម្នាក់ហាលស្រូវព្ធដ៏កំកៅថ្ងៃ នៅរក្សា បានយកអង្កត់ភ្លើងមកវាយសត្វពពែ ដែលមកស៊ីស្រូវ ។ ភ្លើងបានចាប់ (ឆេះ) រោមទាំងឡាយរបស់សត្វពពែនោះ ។ សត្វពពែ គិត ថា "អញនឹងធ្វើឲ្យភ្លើងរលត់" ដូច្នេះហើយ ក៏បោលទៅកាន់រោងដំរី យ៉ាងលឿន ត្រដុសខ្លួន ត្រង់ខ្នមស្មៅមួយ ក្បែររោងដំរី ។ ខ្នមនោះ ក៏ឆេះឡើង ។ អណ្តាតភ្លើងឆេះធ្លាចេញអំពីខ្នមស្មៅនោះ ចាប់ (ឆេះ) រោងដំរី ។ កាលបើរោងដំរីត្រូវភ្លើងឆេះ, ដំរីជាច្រើនមានខ្លួនជាផ្លែដំបៅហើយ ។ ពួកពេទ្យដំរី មិនអាចរក្សាឲ្យជាបានទើបទៅក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់ត្រាស់សួរ បុរោហិត ថា "តើអ្នកចេះថ្នាំរក្សាអ្វីខ្លះឬទេ?" ។ បុរោហិត ក្រាបទូល ថា "ឯពិត្រព្រះមហារាជ ទូលព្រះបង្គំចេះ, ការបាននូវ

ខ្លាញ់រាវរបស់ក្អែក ទើបសមគួរ" ។ ព្រះរាជាទ្រង់ត្រាស់ថញ្ហាថា "បើដូច្នោះ ចូរពួកអ្នកសម្លាប់ក្អែកហើយ នាំយកខ្លាញ់រាវមក" ។

ចាប់ដើមពីពេលនោះមក ពួកមនុស្ស នាំគ្នាសម្លាប់ក្អែកទាំងឡាយហើយ (តែ) មិនបានខ្លាញ់រាវ ទើបធ្វើជាគំនរទុក ក្នុងទីកន្លែងនោះៗឯង ។ សត្វក្អែកទាំងឡាយ បានកើតភ័យធំហើយ ។ ព្រះពោធិសត្វ ដឹងហេតុនោះហើយ ប្រាថ្នានឹងធ្វើការសង្គ្រោះញាតិ ទើបនឹករឭកដល់បារមីទាំងឡាយ បានធ្វើមេត្តាបារមី ឱ្យប្រព្រឹត្តទៅខាងមុខ ហើរទៅយ៉ាងលឿនធ្លោ ចូលទៅតាមប្រឡោះបង្អួចដ៏ធំដែលកំពុងបិទហើយ ក៏ចូលទៅក្រោមព្រះទីនាំង របស់ព្រះរាជា ។

គ្រានោះ មនុស្សម្នាក់បានប្រាថ្នានឹងចាប់ព្រះពោធិសត្វនោះ ។ ព្រះរាជាទ្រង់ត្រាស់ហាមមនុស្សនោះហើយ ។ ព្រះពោធិសត្វបានឈប់សម្រាកបន្តិចហើយ ក៏ចេញពីក្រោមព្រះទីនាំងមក ក្រាបទូលថា "បពិត្រព្រះមហារាជ ធម្មតាព្រះរាជា គ្រប់គ្រងរាជសម្បត្តិមិនទ្រង់លុះអគតិ ដោយអំណាចឆន្ទាគតិជាដើម ទើបត្រឹមត្រូវ, ក៏ព្រះរាជកិច្ចណានីមួយៗ ជាព្រះរាជកិច្ចដែលព្រះអង្គត្រូវបំពេញ, ព្រះរាជកិច្ចនោះៗ ទាំងអស់ ព្រះអង្គទ្រង់ពិចារណា ជាមុនហើយទ្រង់បំពេញ ទើបត្រឹមត្រូវ, មួយទៀត ព្រះរាជកិច្ចឯណា កាលព្រះអង្គបំពេញ នឹងសម្រេចប្រយោជន៍បាន, ព្រះរាជកិច្ចនោះឯង

ព្រះអង្គបំពេញ ទើបត្រឹមត្រូវ, ព្រះរាជកិច្ចក្រៅអំពីនេះ ព្រះអង្គ ទ្រង់បំពេញ មិនត្រឹមត្រូវឡើយ, មែនពិត ព្រះរាជាទាំងឡាយ ក្នុងកាលមុន តែងមិនទ្រង់បំពេញនូវព្រះរាជកិច្ច ដែលកាលទ្រង់ បំពេញទៅ ក៏មិនបានសម្រេចប្រយោជន៍នោះ, បុរោហិត ជាអ្នក លុះក្នុងអំណាចនៃពៀរវេរា ទើបបានពោលមុសាវាទ, ធម្មតា ខ្លាញ់រាវរបស់សត្វក្អែកទាំងឡាយ មិនមានទេ" ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់មានព្រះរាជ ហឫទ័យត្រេកអរ បានឲ្យក្អែកព្រះពោធិសត្វនោះ ទំនៅលើទីនាំង មាសដ៏ប្រសើរ ទ្រង់ត្រាស់ឲ្យរាជបុរស លាបចន្លោះស្លាបទាំងឡាយ ដោយប្រេង ដែលស្ទួហើយ ១ រយដង ១ ពាន់ដងហើយ ទ្រង់ ត្រាស់ឲ្យព្រះរាជទាន នូវភោជនដ៏ប្រសើរ ដែលសមគួរដល់ព្រះ រាជា ក្នុងចានមាស ទ្រង់ឲ្យផឹកទឹកហើយ ទើបទ្រង់ត្រាស់សួរព្រះ តម្រាស់នេះ នឹងព្រះពោធិសត្វនោះ ដែលឆ្អែតស្កប់ស្កល់ហើយ ថា "ម្នាលបណ្ឌិត ព្រោះហេតុអ្វី ទើបខ្លាញ់រាវ របស់ក្អែកទាំងឡាយ មិនមាន ?" ។

ព្រះពោធិសត្វ កាលទ្រង់សំដែងធម៌ដែលប្រកាសហេតុ ដល់ ព្រះរាជាអង្គនោះ ក៏បានពោលគាថា ក្នុងកាកជាតក ក្នុងវគ្គទី ១៤ នៃឯកនិបាត ថា ÷

(៩៦) "ក្អែកទាំងឡាយ ជាសត្វមានហឫទ័យ[1] ក្លាក់ផ្អើលជានិច្ច ត្រូវមនុស្សលោកទាំងពួង បៀតបៀនហើយ ព្រោះហេតុនោះ បានជាខ្លាញ់រាវ នៃពួកក្អែក ជាញាតិនៃពួកទូលព្រះបង្គំនោះ មិនមាន" ។

បណ្តាបទទាំងនោះ បទថា "**ឧព្ពិគ្គហទយា**" មានសេចក្តីថា ចិត្តក្លាក់ផ្អើល គឺជាសត្វដល់ហើយនូវភ័យ រស់នៅជានិច្ច ។ បទថា "**សព្វលោកវិហេសិតា**" មានសេចក្តីថា ត្រូវប្រជាលោក គឺពួកមនុស្សទាំងឡាយ ទាំងពួង បៀតបៀនហើយ ព្រោះហេតុនោះ គឺព្រោះហេតុ ២ ប្រការនេះ ធម្មតាខ្លាញ់រាវនៃពួកក្អែកទាំងនោះ គឺដែលជាញាតិ របស់ពួកទូលព្រះបង្គំ បានដល់ អ្នកដែលស្គាល់គ្នា របស់ពួកទូលព្រះបង្គំ មិនចេះមានឡើយ, សូម្បីក្នុងអតីតកាល ក៏មិនធ្លាប់មានឡើយ, ក្នុងអនាគតកាល ក៏នឹងមិនមានដែរ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់បូជាព្រះពោធិសត្វ ដោយរាជសម្បត្តិ ។ ព្រះពោធិសត្វនោះ បានថ្វាយនូវរាជសម្បត្តិ ដល់ព្រះរាជា ត្រឡប់ដូចដើមវិញ ញុំាងព្រះរាជា ឱ្យទ្រង់ស្ថិតនៅ ក្នុងបញ្ចសីល បានទូលសុំអភ័យ ដល់សព្វសត្វហើយ

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៦១

ក៏គេចចេញទៅ ។ ព្រះរាជាទ្រង់បានព្រះរាជទានអភ័យ ដល់ពួកសព្វសត្វហើយ ទើបទ្រង់បានតាំងនូវទានជាប្រចាំ ដល់ក្អែកទាំងឡាយ ។ ព្រះអង្គទ្រង់ឱ្យដាំបាយ ប្រមាណ ១ អម្ពណៈនៃអង្ករ ផ្សំដោយអាហារ ដែលមានរសជាតដ៏ឆ្ងាញ់ផ្សេងៗហើយ ឱ្យដល់ពួកក្អែក រៀងរាល់ថ្ងៃ ។ ចំណែកព្រះក្រយាស្ងោយ នៃព្រះរាជានុ៎ះឯង ទ្រង់ព្រះរាជទាន ដល់ព្រះពោធិសត្វ យ៉ាងនេះឯង ។

រឿងសត្វក្អែក ចប់ ។

មហាកបិជាតក ក្នុងទុតិយវគ្គ សត្តកនិបាតក្តី ភទ្ទសាលជាតក ក្នុងទ្វាទសកនិបាតក្តី បណ្ឌិតគប្បីសំដែងផងដែរ ។

(៩៧) ចំណែកបុគ្គលឯណា រួបរួមទ្រព្យសម្បត្តិបានច្រើនហើយ ខ្លួនឯងមិនបរិភោគឡើយ, មិនបានសង្គ្រោះពួកញាតិ, បុគ្គលនោះ បណ្ឌិតហៅថា "ជាអ្នកស្មើនឹងសត្វមយ្ហកៈ" ។

មានរឿងសំដែងនូវសេចក្តីនោះ ដូចតទៅនេះ ÷

(រឿងសត្វមយ្ហកៈ)

ក្នុងអតីតកាល ព្រះពោធិសត្វ កើតជាបុត្រនៃសេដ្ឋី មានទ្រព្យប្រមាណ ៨០ កោដិ ក្នុងក្រុងពារាណសី ដោយកាលកន្លងទៅនៃមាតាបិតា ក៏បានសង្គ្រោះនូវបួនប្រុស ចំណាយទ្រព្យ ឱ្យគេសាង

សាលាទាន ក្បែរទ្វារផ្ទះ ថ្វាយមហាទាន នៅគ្រប់គ្រងផ្ទះ ក្នុងពេលដែលបុត្រដើរបាន ឃើញទោសក្នុងកាម និង អានិសង្សនៃបព្វជ្ជា ហើយ ក៏បានប្រគល់ទ្រព្យទាំងអស់ ព្រមទាំងបុត្រនិងភរិយា ឲ្យដល់ប្អូនប្រុស បួសជាតាបសឥសី ញុំាងឈាននិងអភិញ្ញាឲ្យកើតឡើង ហើយ ក៏អាស្រ័យនៅ ក្នុងហិមវន្តប្រទេស ។ ចំណែកប្អូនប្រុសរបស់តាបសនោះ បានកូនប្រុសមួយ ក៏គិតថា "កាលបើកូនប្រុសរបស់បងប្រុសអញ មានជីវិតរស់នៅ, ទ្រព្យសម្បត្តិ ក៏នឹងចែកជាពីរចំណែក, អញនឹងសម្លាប់កូនប្រុស របស់បងប្រុសចោល" ដូច្នេះហើយ ថ្ងៃមួយ ក៏បានចាប់កូននោះ ជ្រមុជ ក្នុងទឹកស្ទឹង ឲ្យស្លាប់ហើយ ងូតទឹករួចស្រេច ទើបទៅផ្ទះ ត្រូវភរិយារបស់បងប្រុសសួរហើយ ក៏ឆ្លើយថា "កូននោះ លេងក្នុងទឹកស្ទឹង, ក្នុងពេលនោះ បងបានរាវរក តែមិនបានឃើញឡើយ" ។ នាងបានស្រែកយំហើយ ក៏នៅស្ងៀម ។ ព្រះពោធិសត្វ ដឹងរឿងនោះហើយ ទើបគិតថា "អាត្មាអញនឹងធ្វើកិច្ចនេះ ឲ្យបានប្រាកដ" ដូច្នេះហើយ ក៏បានហោះទៅផ្ទះប្អូនប្រុស តាមអាកាស ឆាន់នូវភោជនដ៏ប្រសើរ ដែលប្អូនប្រុសប្រគេនហើយ សួរថា "ក្មេងនោះទៅទីណាហើយ ?" ។ ប្អូនប្រុសឆ្លើយថា "បពិត្រលោកម្ចាស់ ក្មេងនោះស្លាប់ហើយ ក្នុងទឹកនៃងលេងទឹក" ។ ព្រះពោធិសត្វ

ពោលថា "នែអសប្បុរស កិច្ចដែលអ្នកធ្វើហើយ បានប្រាកដហើយដល់យើង, អ្នកសម្លាប់ក្មេងនោះ ព្រោះហេតុឈ្មោះនេះ មិនមែនទេឬ ?, អ្នកគប្បីអាច ដើម្បីនឹងថែរក្សានូវទ្រព្យ ដែលកំពុងតែសាបសូន្យ ដោយអំណាចភ័យមានរាជភ័យជាដើម បានដែរឬទេ ?, កិរិយាធ្វើ របស់សត្វចក្បីឈ្មោះមយ្ហកៈ និងខ្លួនអ្នក នឹងផ្សេងគ្នាយ៉ាងដូចម្តេចទៅ" ដូច្នេះ កាលសំដែងធម៌ ដោយពុទ្ធលីលា ដល់ប្អូនប្រុសនោះ បានពោលគាថាទាំងនេះ ក្នុងមយ្ហកសកុណជាតក[1] ថា ÷

(៩៨) "សត្វស្លាប ឈ្មោះមយ្ហកៈ ហើរទៅតាមព្រៃកនិងច្រកភ្នំ ទៅទំដើមលៀប ដែលមានផ្លែទុំ ស្រែកយំកន្ទក់កន្ទេញថា 'របស់អញៗ' ដូច្នេះ ។ កាលបើសត្វមយ្ហកៈនោះ ស្រែកយំការពារ យ៉ាងដូច្នេះ, ពួកសត្វទិជជាតិ ក៏មកប្រជុំគ្នា ស៊ីផ្លែលៀបហើយ ទើបហើរទៅ, សត្វនោះ ក៏នៅតែស្រែកយំការពារនុ៎ះឯង យ៉ាងណាមិញ ។ បុគ្គលពួកខ្លះក្នុងលោកនេះ ក៏យ៉ាងដូច្នោះដែរ ប្រមូលមកនូវទ្រព្យ មានប្រមាណច្រើន ហើយមិនចាត់ចែងនូវទ្រព្យ ឱ្យសមគួរដល់ចំណែក ដើម្បីខ្លួន, មិនទំនុក

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ៦០

បម្រុងដល់ញាតិទាំងឡាយ ។ បុគ្គលនោះ រមែងមិនបានប្រើប្រាស់ នូវគ្រឿងស្លៀកពាក់ និង បាយមិនបានទ្រទ្រង់ នូវកម្រងផ្កា មិនបានលាបនូវគ្រឿងលាប មិនបានប្រើប្រាស់ នូវវត្ថុណាមួយ ជារបស់ខ្លួនទេ ទាំងមិនបានសង្គ្រោះ នូវញាតិទាំងឡាយឡើយ ។ កាលបើបុគ្គលនោះ ពោលរៀបរាប់ហួងហែងថា 'របស់អញៗ' យ៉ាងនេះ, ស្រាប់តែពួកព្រះរាជា ឬពួកចោរ និង ពួកជនអ្នកត្រូវទទួលមកិត អ្នកមិនជាទីស្រឡាញ់ ក៏នាំយកទ្រព្យនោះទៅ, បុគ្គលនោះក៏នៅតែពោលរៀបរាប់នុ៎ះឯង ។ ឯអ្នកប្រាជ្ញ បាននូវភោគៈហើយ រមែងសង្គ្រោះនូវញាតិទាំងឡាយ, អ្នកប្រាជ្ញនោះ រមែងបាន នូវសេចក្តីសរសើរ ដោយការសង្គ្រោះញាតិនោះ និងលុះលះលោកនេះទៅហើយ រមែងរីករាយសប្បាយក្នុងឋានសួគ៌ " ។

ន័យមក ក្នុងអដ្ឋកថាមយ្ហកសកុណជាតក ក្នុងឆដ្ឋនិបាត ថា " បណ្តាបទទាំងនោះ បទថា 'មយ្ហកោ' គឺ សត្វស្លាបដែលបាន

ឈ្មោះយ៉ាងនោះ ដោយអំណាចការស្រែកយំ ថា 'របស់អញ ៗ' ។ ក្នុងបទថា '**គិរិសានុទរីចរោ**' មានវិគ្រោះថា សត្វណារមែងហើរត្រាច់ទៅ ក្នុងញកនិងច្រកភ្នំទាំងឡាយ ហេតុនោះ សត្វនោះ ឈ្មោះថា សត្វដែលហើរត្រាច់ទៅ ក្នុងញកនិងច្រកនៃភ្នំ ។ ២ បទថា '**បក្តំ បិប្ជលឹ**' គឺ ដើមលៀបដែលសម្បូរ ដោយផ្លែមួយដើម ក្នុងព្រៃហិមវន្តប្រទេស ។ បទថា '**កន្ទតិ**' មានសេចក្តីថា ហើរទៅស្រែកយំថា 'របស់អញ ៗ' ដូច្នេះ ដើម្បីហាមប្រាមពួកសត្វទាំងឡាយ ដែលចោមរោម នូវដើមឈើនោះហើយ ស៊ីផ្លែដែលទុំ ៗ ។ ២ បទថា '**តស្សេវំ វិលបន្តស្ស**' គឺ កាលបើសត្វនោះ យំស្រែកយ៉ាងនោះឯង ។ បាទគាថា ថា '**ភុត្វាន បិប្ជលឹ យន្តិ**' មានសេចក្តីថា ហ្វូងបក្សី នាំគ្នាមកស៊ីផ្លែលៀបនោះហើយ ក៏ហើរទៅរកដើមឈើផ្សេងទៀត ដែលសម្បូរផ្លែ ។ បទ ថា '**វិលបតេវ**' មានសេចក្តីថា ចំណែកទិជជាតនោះ ក៏នៅតែស្រែកយំនុ៉ះឯង ។ បទថា '**យថោធឹ**' គឺ តាមសមគួរដល់ចំណែក បានដល់ ចំណែកឯណា ៗ (ដែលខ្លួនត្រូវឲ្យ) ដល់មាតាបិតា បងប្អូនប្រុស ស្រី បុត្រនិងធីតាជាដើម ដោយអំណាចជាគ្រឿងឧបភោគ និង បរិភោគ, មិនឲ្យនូវចំណែកនោះ ៗ ។ បទថា '**សកឹ**' គឺ ខ្លួនឯង ក៏មិនបានប្រើប្រាស់ សូម្បីម្តងឡើយ ។ អធិប្បាយថា មិនបានប្រើប្រាស់

នូវវត្ថុដែលជា របស់ខ្លួន ។ បទថា **'ន សង្គណ្ហាតិ'** គឺ មិនបានសង្គ្រោះ (នូវពួកញាតិ) ដោយអំណាចនៃវត្ថុ មានអាហារ គ្រឿងស្លៀកពាក់ ពូជ និង នង្គ័លជាដើម ។ បទថា **'វិលបតេវ'** មានសេចក្តីថា កាលបើជនទាំងឡាយ មានព្រះរាជាជាដើមនោះ នាំយកទ្រព្យទៅ, បុរសនោះ ក៏នៅតែពោលរៀបរាប់ តែម្យ៉ាងនុ៎ះឯង ។ បទថា **'ធីរោ'** បានដល់ បណ្ឌិត ។ បទថា **'សង្គណ្ហាតិ'** គឺ រមែងសង្គ្រោះ នូវញាតិដែលទុព្វលភាពទាំងឡាយ សូម្បីមកកាន់សំណាក់ របស់ខ្លួនហើយ ដោយការឲ្យវត្ថុមានអាហារ គ្រឿងស្លៀកពាក់ ពូជ និង នង្គ័លជាដើម ។ បទថា **'តេន'** មានសេចក្តីថា សប្បុរសជននោះ រមែងបាននូវកិត្តិយស និង ការពោលសរសើរខ្លួន ក្នុងកណ្តាលបរិស័ទទាំង ៤ ដោយការសង្គ្រោះ នូវញាតិទាំងឡាយនោះ, សប្បុរសនោះ លះលោកនេះទៅហើយ រមែងរីករាយសប្បាយ ក្នុងឋានសួគ៌ គឺ ក្នុងនគរនៃទេវតា ។

(៩៩) ព្រះពោធិសត្វ លុះសំដែងធម៌ ដល់ប្អូនប្រុសនោះ រួចស្រេចហើយ បានញុំាងប្អូនប្រុស ឲ្យធ្វើទាន ដែលគាត់បានកាត់ផ្តាច់ហើយ ឲ្យនៅតាមប្រក្រតីវិញ ទើបទៅកាន់ហិមវន្តប្រទេស ដូចដើម ជាអ្នកមិនសាបសូន្យឈាកឈាន បានទៅកើត ក្នុងព្រហ្មលោកហើយ ។ ចំណែកប្អូនប្រុស របស់ព្រះពោធិសត្វនោះ ឥឡូវនេះ

បានកើតមានឈ្មោះជាអាគន្តុកសេដ្ឋី ។ អាគន្តុកសេដ្ឋីនោះ មិនបានធ្វើបុណ្យ រហូតមួយជីវិត ធ្វើកាលកិរិយាហើយ ក៏បានទៅកើត ក្នុងរោរុវនរក ។ ទ្រព្យសម្បត្តិ ដែលជារបស់បុគ្គលអ្នកមិនមានបុត្រ របស់អាគន្តុកសេដ្ឋីណា, ពួករាជបុរស ក៏បានប្រមូលទ្រព្យសម្បត្តិ របស់អាគន្តុកសេដ្ឋីនោះ បញ្ចូលទៅកាន់ ព្រះឃ្លាំង របស់ព្រះបាទ បសេនទិកោសល អស់ ៧ ថ្ងៃ ៧ យប់ ” ។

ចំណែក ក្នុងកោសលសំយុត្ត ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “ បពិត្រព្រះមហារាជ សេដ្ឋីគហបតីនោះ បានផ្តាច់ចង់កូនប្រុស ម្នាក់ របស់ចងប្រុស ចាកជីវិត ព្រោះហេតុនៃទ្រព្យសម្បត្តិ ព្រោះកម្មឯណា, ព្រោះវិបាកនៃកម្មនោះ សេដ្ឋីនោះ ទើបត្រូវភ្លើងឆេះ ក្នុងនរក អស់ច្រើនឆ្នាំ គឺអស់ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ច្រើនសែនឆ្នាំ, ព្រោះវិបាកដ៏សេសសល់ នៃកម្មនោះឯង ពួករាជបុរស ទើបប្រមូល ទ្រព្យសម្បត្តិ ដែលរកបុត្រមិនមាន រហូតថ្ងៃទី ៧ នេះ បញ្ចូលទៅ កាន់ព្រះឃ្លាំងនៃព្រះរាជា ។ បពិត្រព្រះមហារាជ ក៏ក្នុងថ្ងៃនេះ សេដ្ឋីគហបតី ក៏ត្រូវភ្លើងឆេះ ក្នុងមហារោរុវនរក ”។

(១០០) អដ្ឋកថា នៃកោសលសំយុត្តនោះថា “ ពាក្យថា “ **សាបតេយ្យស្ស ការណា ជីវិតា វោរោបេសិ** ” មានសេចក្តីថា បានឮថា ក្នុងកាលនោះ កាលបើទ្រព្យសម្បត្តិ មិនទាន់

បានចែងចែកគ្នានៅឡើយ, មាតាបិតា និង បងប្រុស របស់សេដ្ឋី នោះ ក៏បានធ្វើកាលកិរិយាចោលហើយ ។ សេដ្ឋីនោះ ក៏បាននៅ រួមជាមួយនឹងភរិយារបស់បងប្រុសនោះឯង ។ ក៏បងប្រុស របស់ សេដ្ឋីនោះ មានកូនប្រុសមួយ ។ មនុស្សទាំងឡាយ ប្រាប់ក្មេង នោះ ដែលកំពុងតែលេង លើថ្នល់ថា "ខ្ញុំបម្រើប្រុសនេះ ខ្ញុំបម្រើ ស្រីនេះ យាននេះ ទ្រព្យនេះ ជាសម្បត្តិរបស់អ្នក" ។ ក្មេងនោះ ជឿស្តាប់ពាក្យ របស់មនុស្សទាំងនោះហើយ ពោលពាក្យជាអាទិ៍ថា "ខ្ញុំបម្រើប្រុសនេះ ជារបស់អាត្មាអញ" ដូច្នេះ ។

លំដាប់នោះ ឪពុកមារបស់ក្មេងនោះ គិតថា "ក្នុងកាលឥឡូវ នេះ ក្មេងតូចនេះ រមែងពោលយ៉ាងនេះឯង, ក្នុងពេលវាធំឡើង វា នឹងគប្បីឲ្យចែងចែកទ្រព្យសម្បត្តិ ត្រង់ពាក់កណ្តាល, អញនឹង ធ្វើកិច្ចដែលត្រូវធ្វើ ដល់ក្មេងនោះ ក្នុងពេលនេះតែម្តង" ។ ក្នុង ពេលថ្ងៃមួយ ឪពុកមា ទាញយកកាំបិតហើយពោលថា 'នែកូន អ្នកចូរមក, យើងនឹងទៅព្រៃ" ដូច្នេះហើយ ក៏នាំក្មេងនោះទៅព្រៃ សម្លាប់ក្មេងនោះ ដែលកំពុងតែស្រែកយំក្តែង ។ ហើយបោះចោល ទៅក្នុងអន្លង បានយកអាចម៍ជីកប់ហើយ" ។

ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាជាតកថា "សូម្បី អាគន្តុកសេដ្ឋី ដល់ភាពជាសេដ្ឋីបាន ក៏ព្រោះកិរិយាថ្វាយទាន ដល់

ព្រះបច្ចេកពុទ្ធ ទ្រង់ព្រះនាមថា តគរសិខី ដូចជាសេដ្ឋី (ដែលមានសម្លាប់កូយ ក្នុងព្រៃ) នេះ យ៉ាងដូច្នេះឯង" ។

ព្រោះហេតុដូច្នោះ បើសេដ្ឋីទាំង ២ នាក់នុ៎ះ ជាបុគ្គលតែមួយ ដោយសេចក្តី, សេចក្តីនៃមឃ្លកសកុណជាតក ក៏ខុស, បើផ្សេងពីគ្នា ក៏គួរតែត្រឹមត្រូវ, ពាក្យដែលពោលមកនេះ អ្នកមានប្រាជ្ញា គប្បីត្រួតពិនិត្យមើលផងចុះ" ។

រឿង សក្ខស្លាបឈ្មោះមឃ្លកៈ ចប់ ។

ពណ៌នាអំពីការសង្គ្រោះញាតិ ចប់ ។

សាសនាចម្រើន ព្រោះមានអ្នកសិក្សាត្រឹមត្រូវ និងប្រតិបត្តិត្រឹមត្រូវតាមការសិក្សា ។

ប្រែចប់ ថ្ងៃពុធ ១៣ កើត ខែជេស្ឋ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦

ថ្ងៃទី ២ មិថុនា ១៩៩៣

(១០១) ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា នៃមង្គលត្ថទីបនីនេះថា "ការងារទាំងឡាយ មានការសមាទាន នូវអង្គនៃឧបោសថ ការធ្វើកិច្ចជួយខ្វល់ខ្វាយ ការបណ្តុះដាំដើមឈើ ក្នុងវត្តអារាម និង ការកសាងស្ពានជាដើម ឈ្មោះថា ការងារដែលមិនមានទោស"។

(ឧបោសថកម្ម ២ យ៉ាង)

បណ្តាកម្មទាំងនោះ ឧបោសថកម្ម មាន ២ យ៉ាង ដោយអំណាចនៃបកតិឧបោសថ និង បដិជាគរឧបោសថ។ ពិតមែនយ៉ាងដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថារាជសូត្រ ក្នុងបឋមបណ្ណាសកៈ នៃតិកនិបាត អង្គុត្តរនិកាយថា "២ បទថា **'ឧបោសថំ ឧបវសន្តិ'** មានសេចក្តីថា ជនទាំងឡាយ រមែងអធិដ្ឋាន នូវអង្គនៃឧបោសថទាំងឡាយ ១ ខែ ៨ ដង។ បទថា **'បដិជាគរោន្តិ'** មានសេចក្តីថា រមែងធ្វើឧបោសថកម្ម ឈ្មោះថា បដិជាគរៈ។ ជនទាំងឡាយ កាលធ្វើនូវបដិជាគរឧបោសថនោះ រមែងធ្វើ ដោយអំណាច នៃការទទួល និង ការជូនដំណើរ នូវថ្ងៃ

ឧបោសថទាំងឡាយ ៤ ថ្ងៃ ក្នុងកន្លះខែមួយ ។ កាលបើទទួលនូវឧបោសថ ក្នុងតិថីទី ៥ រមែងជាអ្នករក្សាឧបោសថ ក្នុងតិថីទី ៤, កាលនឹងជូនដំណើរ រមែងជាអ្នករក្សាឧបោសថ ក្នុងតិថីទី ៦ ។ កាលនឹងទទួល នូវឧបោសថ ក្នុងតិថីទី ៨ រមែងជាអ្នករក្សានូវឧបោស ក្នុងតិថីទី ៧, កាលនឹងជូនដំណើរ រមែងជាអ្នករក្សានូវឧបោស ក្នុងតិថីទី ៩ ។ កាលនឹងទទួលនូវឧបោសថ ក្នុងតិថីទី ១៤ រមែងជាអ្នករក្សាឧបោសថ ក្នុងតិថីទី ១៣, កាលនឹងជូនដំណើរ នូវឧបោសថ ក្នុងតិថីទី ១៥ រមែងជាអ្នករក្សាឧបោសថ ក្នុងថ្ងៃបាដិបទ (ថ្ងៃ ១ រោច)" ដូច្នេះ ។

(១០២) ដីការាជសូត្រនោះថា "២ បទថា '**អដ្ឋ វារេ**' គឺ រហូត ៨ ដង យ៉ាងដូច្នេះ គឺ ÷ ក្នុងកន្លះខែមួយ ៤ ដង, ក្នុងកន្លះខែក្រៅអំពីនេះ ក៏យ៉ាងដូច្នោះដែរ ។ បទថា '**អធិដ្ឋហន្តិ**' ប្រែថា រមែងតាំងចិត្តខ្ជាប់ ។ បទថា '**បដិជាគរោន្តិ**' ប្រែថា រមែងភ្ញាក់រឭកដោយលំដាប់ ។ មែនពិត សត្វទាំងឡាយ កាលនឹងធ្វើបុណ្យទាំងឡាយ ឈ្មោះថា រមែងភ្ញាក់រឭក ព្រោះភាពជាអ្នកខ្វល់ខ្វាយ ក្នុងកិច្ចការដែលខ្លួនត្រូវធ្វើ ។ តែសត្វក្រៅអំពីនេះ ឈ្មោះថា រមែងដេកលក់ ព្រោះភាពជាអ្នកគេចមុខចេញ អំពីប្រយោជន៍របស់ខ្លួន និង ប្រយោជន៍របស់អ្នកដទៃ ។ ការទទួល

នូវឧបោសថ ក្នុងតិថីទី ១៥ រមែងមិនបាន ដូចជាការជូនដំណើរ នូវឧបោសថ ក្នុងតិថីទី ១៤ ទេ ព្រោះមិនមានថ្ងៃ" ។

សទ្ទនីតិបករណ៍ បានកែថា "**ជាគរ** ធាតុ ប្រព្រឹត្តទៅ ក្នុងការអស់ទៅនៃការដេកលក់, រូបនៃពួកធាតុ មាន **ភូ** ធាតុជាដើម ថា '**ជាគរតិ**' ដូច្នេះ, រូបនៃពួកធាតុ មាន **តន** ធាតុជាដើមថា '**ជាគរោតិ**' ដូច្នេះ ។

(១០៣) ចំណែកក្នុងកាល នៃឧបោសថនេះ មានការសន្និដ្ឋាន ដូចតទៅនេះ ÷ ៨ ថ្ងៃ នៃមួយខែ (១ខែ ៨ ថ្ងៃ) គឺ ក្នុងជុណ្ហបក្ខ (ខាងខ្មើត) ៤ ថ្ងៃ គឺ ថ្ងៃ ៥ កើត ៨ កើត ១៤ កើត ថ្ងៃ ១៥ កើត, ក្នុងកាឡបក្ខ (ខាងរនោច) ក៏យ៉ាងដូច្នោះដែរ គឺ ថ្ងៃ ៥ រោច ៨ រោច ១៤ រោច ថ្ងៃ ១៥ រោច ចាត់ជាកាលនៃបកតិឧបោសថ ។ ១១ ថ្ងៃនៃមួយខែ (មួយខែ ១១ ថ្ងៃ) គឺ ក្នុងជុណ្ហបក្ខ មាន ៥ ថ្ងៃ គឺ ថ្ងៃ ៤ កើត ៦ កើត ៧ កើត ៩ កើត ១៣ កើត, និងក្នុងកាឡបក្ខ មាន ៦ ថ្ងៃ គឺ ថ្ងៃ ១ រោច ៤ រោច ៦ រោច ៧ រោច ៩ រោច ១២ រោច ឬក៏ ថ្ងៃ ១៣ រោច ចាត់ជាកាល នៃបដិជាគរឧបោសថ ។ ១០ ថ្ងៃ ក្នុងខែដែលខ្វះ, ១១ ថ្ងៃ ក្នុងខែដែលពេញ ដែលក្រៅអំពីថ្ងៃទាំងនោះ មិនចាត់ជាកាលនៃឧបោសថទេ ។

(១០៤) ការដែលបុគ្គល មិនសមាទាន នូវឧបោសថ រក្សាសីល ៥ រហូតទាំង ១ ខែ ក៏សមគួរ ព្រោះហេតុនោះ ខែទាំងអស់ ទើបចាត់ជាកាលនៃសីល ៥ នោះ ។ ប៉ុន្តែបញ្ចសីលនេះ លោកពោលហើយ ដោយអំណាច នៃបុគ្គលអ្នកដែលមិនធ្វើ នូវបាដិហារិយបក្ខ ។

(បដិហារិយបក្ខឧបោសថ)

ចំណែកខែក្នុងរដូវភ្លៀង ៤ ខែ ចាត់ជាកាល នៃបុគ្គលអ្នកធ្វើបាដិហារិយបក្ខនោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថារាជសូត្រថា “ឧបោសថជាប្រចាំ រហូតអស់ ៣ ខែ ពួដ៏ខាងក្នុងនៃរដូវភ្លៀង ឈ្មោះថា បាដិហារិយបក្ខ, កាលបើមិនអាច អស់ទាំង ៣ ខែ នោះទេ, ឧបោសថជាប្រចាំ រហូតអស់មួយខែ ក្នុងចន្លោះ នៃថ្ងៃបវារណាទាំង ២ ឈ្មោះថា បាដិហារិយបក្ខ, កាលបើមិនអាច អស់ទាំង ១ ខែ នោះទេ, ចាប់អំពីថ្ងៃបវារណាខាងដើមមក កន្លះខែមួយ ក៏ឈ្មោះថា បាដិហារិយបក្ខដូចគ្នាដែរ” ។

ដីកានៃរាជសូត្រនោះថា “ឧបោសថជាប្រចាំ ឈ្មោះថា បាដិហារិយបក្ខ ព្រោះយើងត្រូវតែនាំទៅតាមលំដាប់ គឺ ព្រោះយើងត្រូវឲ្យប្រព្រឹត្តទៅ ជារៀងរាល់ឆ្នាំ” ។

អដ្ឋកថាខុទ្ទកវត្ថុវិមាន ថា "បទថា 'បាដិហារិយបក្ខញ្ច' មានសេចក្តីថា រហូតខុបនីហារណកបក្ខ និង បក្ខដែលប្រតិបត្តិខុបោសថ-សីល ដោយអំណាចការទទួលនិងការជូនដំណើរ ថ្ងៃទី ១៤ ១៥ និង ថ្ងៃទី ៨ តាំងតែពីដើម និង ទីបំផុត តាមលំដាប់, អធិប្បាយថា និងក្នុងថ្ងៃទី ១៣ ថ្ងៃទី ១ ថ្ងៃទី ៧ និងក្នុងថ្ងៃទី ៩" ។

(១០៥) អដ្ឋកថាធម្មិកសូត្រ ក្នុងទុតិយវគ្គ សុត្តនិបាត ថា "ខែទាំងឡាយ ៥ នេះ គឺ ខែអាសាឡ្ហៈ (ខែ ៨) ក្នុងចំណែកខាងដើម នៃថ្ងៃវស្សូបនាយិកា (ថ្ងៃចូលវស្សា), ខែទាំងឡាយ ៣ ពួកដ៏ខាងក្នុងវស្សា, ខែកត្តិក (ខែ ១២) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា 'បាដិហារិយបក្ខ' ។ អាចារ្យពួកខ្លះ ពោល ថា 'ខែអាសាឡ្ហៈ (ខែ ៨) ខែកត្តិក (ខែ ១២) ខែផគ្គុណ (ខែ ៤) តែ ៣ ខែប៉ុណ្ណោះ (ឈ្មោះថា បាដិហារិយបក្ខ)' ដូច្នេះ ។ អាចារ្យពួកខ្លះ ពោលថា 'ក្នុងមួយបក្ខៗ មាន ៤ ៗ ថ្ងៃ ពោលគឺ ថ្ងៃទី ១៣ ថ្ងៃទី ១ ថ្ងៃទី ៧ និង ថ្ងៃទី ៩ ដោយអំណាចនៃថ្ងៃខាងដើម និង ថ្ងៃខាងចុង នៃថ្ងៃខុបោសថក្នុងបក្ខ (ឈ្មោះថា បាដិហារិយបក្ខ)' ដូច្នេះ ។ បណ្ឌិតចូលចិត្តវិធីណាមួយ, គប្បីកាន់យកវិធីនោះចុះ ។ ក៏អ្នកប្រាថ្នាបុណ្យ ត្រូវធ្វើគ្រប់វិធី" ។

(១០៦) ចំណែកពាក្យណា ដែលលោកពោលហើយ ក្នុង

អដ្ឋកថាគង្គមាលជាតក ក្នុងអដ្ឋកនិបាតថា "បុត្រនិងភរិយាក្តី ជនដែលជាបរិវារក្តី របស់សេដ្ឋីនោះ ដោយហោចទៅ សូម្បីអ្នកគង្វាលគោ ក្នុងផ្ទះនោះៗ ទាំងអស់គ្នា តែងចូលរក្សាឧបោសថ ១ ខែ ៦ ថ្ងៃ" ដូច្នេះ, ពាក្យនោះ លោកពោលហើយ សំដៅយកនូវឧបោសថដែលបាន ដោយកាលជ្រួងក្រៅអំពី កាលនៃព្រះពុទ្ធ ។ បានឮថា ក្នុងកាលនោះ ការរក្សា ពោលគឺ ការមិនបរិភោគអាហារនុ៎ះឯង លោកហៅថា 'ឧបោសថ' ដូច្នេះ, មិនមែនអង្គ ៨ ទេ ។ ពិតមែន អង្គ ៨ នោះ រមែងរកបាន តែក្នុងសម័យ នៃការឧបត្ថម្ភឡើង នៃព្រះពុទ្ធប៉ុណ្ណោះ ។

(១០៧) ចំណែកក្នុងជីកាគង្គមាលជាតកនោះ លោកពោលហើយថា "មួយខែ មានថ្ងៃឧបោសថ ៦ ថ្ងៃ គឺ ក្នុងសុក្កបក្ខ (ខាងខ្មើត) មាន ៣ ថ្ងៃ គឺ ថ្ងៃអមាវាសី ថ្ងៃទី ៨ ថ្ងៃទី ១១, សូម្បីក្នុងកណ្ហបក្ខ (ខាងរនោច) ក៏មាន ៣ ថ្ងៃ ដូចគ្នាដែរ" ។

សូម្បីក្នុងអដ្ឋកថាវេស្សន្តរជាតក លោកក៏បានសំដៅយកនូវថ្ងៃឧបោសថ ជ្រួងក្រៅអំពីពុទ្ធកាលនេះឯង ហើយពោលថា "ព្រះមហាសត្វ ឡើងទ្រង់លើ កំរឹដ៏ប្រសើរ ស្តេចត្រួតពិនិត្យមើលរោងទាន ៦ កន្លែង មួយខែៗ ៦ ដង" ដូច្នេះ ។

ក៏ក្នុងជីកាគង្គមាលជាតកនេះ សូម្បីថ្ងៃបុណ្ណមី លោកក៏បាន

កំណត់យកហើយ ដោយបទថា "**អមាវាសី**" នេះ ។

ចំណែកក្នុងដីកានៃសគ្គកណ្ឌ លោកពោលថា "ថ្ងៃបណ្ណរសី (ថ្ងៃទី ១៥) ដែលជាថ្ងៃខាងកាឡបក្ខ លោកហៅថា 'អមាវសី' ដូច្នេះខ្លះ ហៅថា 'អមាវាសី' ដូច្នេះខ្លះក៏មាន ។ ព្រះអាទិត្យ និង ព្រះចន្ទ រមែងនៅរួមគ្នា គឺជាមួយគ្នា ក្នុងតិថីឯណា, តិថីនោះ ឈ្មោះថា **អមាវសី** និង ឈ្មោះថា **អមាវាសី** ព្រោះធ្វើទីឃៈ ។ **អមា** សព្ទ មាន **សហ** សព្ទជាសេចក្តី ជាអព្យយៈសព្ទ (គឺសព្ទដែលចែកនឹងវិភត្តិនាមមិនបាន)" ។

(១០៨) បណ្ឌិតគប្បីដល់សេចក្តីយល់ព្រម ក្នុងកាលនៃឧបោសថនេះថា "ថ្ងៃទាំងឡាយ ៨ នៃមួយខែ មានថ្ងៃបញ្ចមី (ថ្ងៃទី ៥) ជាដើម ចាត់ជាកាលនៃបកតិឧបោសថ, ថ្ងៃទាំងឡាយ ១១ មានថ្ងៃចតុទ្ទសី (ថ្ងៃទី ៤) ថ្ងៃឆដ្ឋី (ថ្ងៃទី ៦) ជាដើម ដែលជាថ្ងៃខាងដើម និង ខាងចុង នៃថ្ងៃទាំងឡាយទាំង ៨ នោះ ចាត់ជាកាល នៃបាដិជាគរឧបោសថ, ខែក្នុងរដូវក្តៀងទាំងអស់ ចាត់ជាកាល នៃបាដិហារិយឧបោសថ" ដោយប្រការដូច្នេះឯង ។

ចំណែកអាចារ្យពួកខ្លះ ពោលថា "ការធ្វើឧបោសថ ក្នុងថ្ងៃណាមួយ ក៏សមគួរដែរ" ។ ពាក្យនោះ មិនសមទេ ព្រោះថ្ងៃដែលបណ្ឌិតលោកកំណត់ទុក នឹងដល់ភាពជាថ្ងៃដែលមិនមាន

ប្រយោជន៍ ។ ព្រោះថា កាលបើដូច្នោះ ថ្ងៃដែលបណ្ឌិតលោកកំណត់ទុកថា ថ្ងៃចាតុទ្ទសី (ថ្ងៃទី ១៤) ជាដើម គប្បីជាថ្ងៃដែលមិនមានប្រយោជន៍, ប៉ុន្តែថ្ងៃដែលបណ្ឌិតលោកបានកំណត់ទុកនុ៎ះ មិនមែនជាថ្ងៃដែលមិនមានប្រយោជន៍ទេ ។ ដោយហេតុនោះ ក្នុងអដ្ឋកថាខុទ្ទវាវិមាន ព្រះអដ្ឋកថាចារ្យ ទើបសំដែងភាវៈនៃឧបោសថកម្មនោះ ជាកិច្ចដែលបុគ្គលគប្បីធ្វើ ក្នុងថ្ងៃដែលបណ្ឌិតលោកបានកំណត់ទុកប៉ុណ្ណោះ យ៉ាងនេះថា “ឧបោសថកម្មនោះ បុគ្គលគប្បីរក្សា ក្នុងថ្ងៃទាំងឡាយណា, ឧបោសថកម្មដូចម្តេចដែលបុគ្គលគប្បីរក្សា ដោយប្រការណា, នាងខុទ្ទវា កាលនឹងសំដែងនូវថ្ងៃទាំងនោះ ឧបោសថកម្មដូច្នោះ និង ប្រការដូច្នោះនោះ ទើបពោលថា ‘ចាតុទ្ទសី” ដូច្នេះជាដើម ។

(១០៩) សូម្បីក្នុងអដ្ឋកថាធម្មិកសូត្រ ព្រះអដ្ឋកថាចារ្យ ពោលថា “ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែងកាលនៃឧបោសថ ទើបត្រាស់ថា ‘តតោ ច បក្ខស្ស’ ដូច្នេះជាដើម”។

បាលីក្នុងធម្មិកសូត្រនោះ[1] មានដូចតទៅនេះ ÷

“ក៏វិញ្ញូជនអ្នកមានចិត្តជ្រះថ្លាហើយ រក្សានូវឧបោសថ ដែលប្រកបដោយអង្គ ៨ ធ្វើឱ្យ

---

១ ត្រៃបិដក ភាគទី ៤១ / ទំព័រទី ១០៧

មានអង្គគ្រប់ពេញបរិបូរ រហូតតិថីទី ១៤ តិថី ១៥ និងតិថីទី ៨ នៃបក្ខ និង រហូតបាដិហារិយបក្ខ”។

អដ្ឋកថាធម្មិកសូត្រនោះថា “សព្ទថា **‘តតោ’** ក្នុងគាថានោះជានិបាត ចុះក្នុងសេចក្តីគ្រាន់តែធ្វើបទឱ្យពេញ ។ បទថា **‘បក្ខស្សុបវស្សុបោសថំ’** នុ៎ះ បណ្ឌិតគប្បីប្រកប ដោយបទខាងចុងថា ‘រក្សាឧបោសថ គឺ ចូលរក្សាឧបោសថ ដែលប្រកបដោយអង្គ ៨ នុ៎ះឯង រហូតទាំង ៣ ថ្ងៃនេះ គឺ តិថីទី ១៤ តិថីទី ១៥ តិថីទី ៨ នៃបក្ខ’ ដូច្នេះ។ បទថា **‘បក្ខស្សុបវស្សុបោសថំ’** នុ៎ះ បណ្ឌិតគប្បីសម្ព័ន្ធចូលគ្នា យ៉ាងដូច្នេះថា ‘វិញ្ញូជនអ្នកមានចិត្តជ្រះថ្លាហើយ មិនបោះបង់ចោល នូវឧបោសថដែលប្រកបដោយអង្គ ៨ សូម្បីតែមួយថ្ងៃ ធ្វើឱ្យមានរូបគ្រប់បរិបូរ គឺ ធ្វើឱ្យមានអង្គគ្រប់បរិបូរល្អ ឈ្មោះថា រក្សាឧបោសថប្រកបដោយអង្គ ៨ (ធ្វើឱ្យមានអង្គពេញលេញ) រហូតបាដិហារិយបក្ខផង’ ដូច្នេះ” ។

(១១០) អដ្ឋកថាកយកេរវសូត្រ ក្នុងមូលបណ្ណាសកៈថា បទថា **‘ចាតុទ្ទសី’** បានដល់ រាត្រី ១ ជាទីពេញ នៃថ្ងៃទាំង ឡាយ ១៤ ចាប់ដើមអំពីថ្ងៃខាងដើមនៃបក្ខទៅ ។ ថ្ងៃទី ១៥ និងថ្ងៃទី ៨ ក៏យ៉ាងដូច្នោះដែរ ។ បទថា **‘បក្ខស្ស’** មានសេចក្តី

ថា ‘រាត្រីទាំងឡាយ ៦ បែងចែករាត្រីទាំងនោះ នៃសុក្កបក្ស និងកណ្ហបក្ស ឱ្យទៅជាបក្សមួយ ៗ មាន ៣ ៗ ព្រោះហេតុនោះ ពាក្យថា ‘បក្ស’ បណ្ឌិតគប្បីប្រកប ក្នុងគ្រប់ ៗ បទថា ‘**បក្ខស្ស ចាតុទ្ទសី បក្ខស្ស បញ្ចទសី បក្ខស្ស អដ្ឋមី**’ ដូច្នេះ” ។

ជីកាភយភេរវសូត្រនោះ ថា “២ បទថា ‘**បឋមទិវសតោ បភូតិ**’ គឺ ចាប់ដើមអំពីថ្ងៃ ១ រោច ជាដើមទៅ” ។

តិថីទី ៥ មិនបានមកហើយ ក្នុងបាលី ក៏ពិតមែនហើយ, ប៉ុន្តែតិថីទី ៥ នោះ ក៏គប្បីកំណត់យក ដោយពិត ព្រោះភាវៈជាថ្ងៃដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំងទុកហើយ ។ សេចក្តីនេះ នឹងមានជាក់ច្បាស់ ក្នុងមង្គលបទនេះថា “**កាលេន ធម្មស្សវនំ**” ដូច្នេះ ។

ពណ៌នាអំពីកាលនៃឧបោសថ ចប់ ។

(អង្គនៃឧបោសថ ៨ យ៉ាង)

(១១១) ក៏អង្គទាំង ៨ នៃឧបោសថនោះ មានចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់នាងវិសាខា ទ្រង់ត្រាស់ហើយ ក្នុងទុតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា ÷

"បុរស ឬ ស្ត្រី មិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចទ្រព្យដែលម្ចាស់គេមិនបានឲ្យ ១ មិនគប្បីនិយាយកុហកគេ ១ មិនគប្បីក្រេបផឹក នូវទឹកស្រវឹង ១ គប្បីវៀរចាកមេថុនដែលមិនមែនជាសេចក្តីប្រព្រឹត្តិប្រសើរ ១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងភោជនក្នុងវេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ (ដែលត្រូវប្រមាណ) ឬកម្រាលដែលក្រាលផ្ទាល់នឹងផែនដី ១ (បណ្ឌិតទាំងឡាយពោលសរសើរ) ឧបោសថដែលប្រកប ដោយអង្គ ៨ នុ៎ះឯង ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុតទុក្ខ ទ្រង់ប្រកាសទុកហើយ" ។ (១)

បាលីក្នុងឧបោសថសូត្រ ចប់ ។

បាលីក្នុងធម្មិកសូត្រ ក្នុងទុតិយវគ្គ នៃសុត្តនិបាត ក៏យ៉ាងដូច្នោះដែរ ។

(១១២) អដ្ឋកថា នៃធម្មិកសូត្រ ថា "បណ្តាបទទាំងនោះ បទថា 'អព្រហ្មចរិយា' គឺ ដែលជាសេចក្តីប្រព្រឹត្តិមិនប្រសើរ ។

---

១ ត្រៃបិដក ភាគទី ៤១ / ទំព័រទី ១៨២

បទថា '**មេថុនា**' គឺ ចាកការដល់ព្រម នៃមេថុនធម្ម" ។

អដ្ឋកថាឈ្មោះកង្ខាវិតរណី ថា "២ បទថា '**មេថុនំ ធម្មំ**' បានដល់ ធម៌របស់បុគ្គល ២ នាក់ ដែលស្មើគ្នា ដោយការរាលដាលឡើង នៃសេចក្តីតម្រេក" ។

ដីកានៃកង្ខាវិតរណីនោះ ថា "ធម៌នេះ ជាធម៌ របស់បុគ្គលគូគ្នាទាំងឡាយ ព្រោះដល់ភាវៈដូចគ្នា ដោយការរាលដាលឡើង នៃរាគៈ ព្រោះហេតុនោះ ធម៌ន៉ុះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ថា 'មេថុន' ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**រាគបរិយុដ្ឋានេន**' ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា '**រាគបរិយុដ្ឋានេន**' ប្រែថា ដោយការរាលដាលឡើងនៃរាគៈ ។ អធិប្បាយថា 'ដោយភាពជាអ្នកមានចិត្ត ត្រូវសេចក្តីប្រព្រឹត្តិទៅ នៃសេចក្តីត្រេកត្រអាលក្នុងមេថុន រូបរឹតហើយ' ។ អជ្ឈាចារ (គឺការប្រព្រឹត្តិល្មើសប្រពៃណី) ឈ្មោះថា ធម៌" ។

ដីកានៃចូឡហត្ថិបទោបមសូត្រ ថា "ធម៌នេះ ជាធម៌ របស់បុគ្គលដែលគូគ្នាទាំងឡាយ គឺ ជាគូ ។ ដោយអាការៈដែលពោលមកហើយ ហេតុនោះ ទើបឈ្មោះថា មេថុន" ។

(១១៣) អដ្ឋកថាធម្មិកសូត្រ ថា "បាទគាថា ថា '**រត្តឺ ន ភុញ្ជេយ្យ វិកាលភោជនំ**' មានសេចក្តី ថា មិនគប្បីបរិភោគ ទាំង

ក្នុងវេលារាត្រី, មិនគប្បីបរិភោគភោជន កន្លងហួសពេលទៅហើយ ទាំងក្នុងវេលាថ្ងៃ ។ សូម្បីវត្ថុទាំងឡាយ មានលំអិតគ្រឿងលាប ជាដើម បណ្ឌិតគប្បីជ្រាបថា 'ព្រះមានព្រះភាគ ទ្រង់កំណត់យកហើយ' ដោយគន្ធសព្ទ ក្នុងពាក្យថា '**ន ច គន្ធំ**' ដូច្នេះដែរ ។ បទថា '**មញ្ចោ**' គឺ គ្រែដែលសមគួរ ។ បទថា '**សន្តតេ**' បានដល់ ដែលបុគ្គលក្រាលហើយ ដោយគ្រឿងកម្រាលដែលសមគួរ មានកន្ទេលទន់ៗជើម ។ មួយទៀត (ការដែលទទួលទានដំណេក) លើផែនដី សូម្បីក្រាលហើយដោយសំពត់រោមសត្វជាដើម ក៏សមគួរ"។

(១១៤) អដ្ឋកថាខុទ្ទកបោសថសូត្រថា "បាទគាថាថា '**មញ្ចេ ឆមាយំ វ សយេថ សន្តតេ**' មានសេចក្តីថា គប្បីដេក លើគ្រែដែលសមគួរ ដែលមានជើងប្រមាណមួយគក់ ឬ លើផែនដីដែលបូកលាប ដោយកំបោរពណ៌សជាដើម ឬ លើទីកម្រាលដែលគេក្រាលស្មៅ ស្លឹកឈើ និង ចំបើងជាដើមហើយ ធ្វើទុក"។

អដ្ឋកថាធម្មិកសូត្រថា "បទថា '**អង្គង្គិកំ**' គឺ មិនរួចផុតអំពីអង្គ ៨ ដូចជាតន្ត្រីដែលប្រកបដោយអង្គ ៨ ប្រការ ដូច្នោះ។ បទថា '**ទុក្ខន្តគុនា**' គឺ អ្នកដល់នូវទីបំផុតនៃវដ្តទុក្ខហើយ"។

(១១៥) អដ្ឋកថានៃខុទ្ទកបាឋៈថា "បណ្តាអង្គទាំងនោះ ចេតនាជាហេតុកន្លងឋានៈ ដោយប្រាថ្នានឹងសេព នូវអសទ្ធម្ម ដែល

ប្រព្រឹត្តទៅតាមកាយទ្វារ ឈ្មោះថា កិរិយាប្រព្រឹត្តិមិនប្រសើរ "។

ជីកាព្រហ្មជាលសូត្រថា "ចេតនា ដែលញុំាងការដល់ចំពោះមគ្គ ដោយមគ្គ ឱ្យកើតឡើង ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយប្រាថ្នានឹងសេពអសទ្ធម្ម ឈ្មោះថា កិរិយាប្រព្រឹត្តិមិនប្រសើរ ។ អព្រហ្មចរិយៈនោះ មានអង្គ ២ គឺ ចិត្តប្រកបដោយភាពជាអ្នកប្រាថ្នានឹងសេព ១ ការញុំាងមគ្គ ដោយមគ្គ ឱ្យដល់គ្នា ១ "។

អដ្ឋកថាឈ្មោះកង្ខាវិតរណីថា "អព្រហ្មចរិយៈនោះ មានអង្គ ២ គឺ ចិត្តគិតនឹងសេព ១ ការញុំាងមគ្គឱ្យដល់មគ្គ ១ "។

អដ្ឋកថាខុទ្ទកបាឋៈថា "ក៏អព្រហ្មចរិយៈ មានអង្គ ៤ គឺ វត្ថុដែលគប្បីប្រព្រឹត្តកន្លង (គឺមគ្គទាំង ៣) តែងមាន ១ ចិត្តគិតនឹងសេព ក្នុងអជ្ឈាចរណីយវត្ថុនោះ ជាធម្មជាតប្រាកដហើយ ១ សេចក្តីព្យាយាម ដែលជាបច្ច័យនៃការសេព រមែងដល់ព្រម ១ សេចក្តីត្រេកអរ ១ "។

(១១៦) មគ្គទាំងឡាយ ៣០ ឈ្មោះថា អជ្ឈាចរណីយវត្ថុ ។ សមដូចជាពាក្យ ដែលព្រះអដ្ឋកថាចារ្យ បានពោលទុកហើយ ក្នុងអដ្ឋកថាឈ្មោះកង្ខាវិតរណីថា "ក៏ស្ត្រី មាន ៣ ពួក ដោយអំណាចនៃស្ត្រីដែលជាមនុស្ស អមនុស្ស និងសត្វតិរច្ឆានញី, មគ្គរបស់ស្ត្រីមនុស្ស អមនុស្ស និងសត្វតិរច្ឆានទាំងនោះ ចែកជាមួយពួក ។

មាន ៣ ។ ដោយអំណាច វច្ចមគ្គ បស្សាវមគ្គ និង មុខមគ្គ ត្រូវជា ៩ ។ មគ្គ របស់ពួកខ្មកគោព្យញ្ជនកទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ។ ចំណែកមគ្គ របស់បុរសទាំងឡាយ ចែកជាពួកមួយ ។ មាន ២ ។ ដោយអំណាច វច្ចមគ្គ និង មុខមគ្គ ត្រូវជាមគ្គ ៦ ។ មគ្គ របស់ពួកបណ្ឌោះ ក៏យ៉ាងដូច្នោះដែរ រួមត្រូវជាមគ្គ ៣០ ដូច្នេះឯង "។

ពាក្យដែលសេសសល់ ដែលខ្ញុំគប្បីពោល ក្នុងសិក្ខាបទនេះ និង ក្នុងសិក្ខាបទ ទី ១ ទី ២ ទី ៤ និង ទី ៥ បណ្ឌិតគប្បីជ្រាប ដោយន័យដែលខ្ញុំពោលហើយ ក្នុងអាគារិយវិន័យ ខាងក្រោយ ។

(១១៧) អដ្ឋកថាវិកាលភោជនសិក្ខាបទ ថា "ដោយបទថា 'កាលោ' លោកអធិប្បាយកាលជាទីឆាន់ របស់ភិក្ខុទាំងឡាយ ។ ក៏កាលនោះ ដោយកំណត់យ៉ាងទាបបំផុត គឺជាវេលាថ្ងៃត្រង់ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈ នៃសិក្ខាបទនោះ ព្រះខុបាលីទើបពោលថា 'ឈ្មោះថា វិកាល គឺ កាលបើវេលាថ្ងៃត្រង់កន្លងផុតទៅហើយ រហូតដល់ព្រះអាទិត្យរះឡើង' ដូច្នេះ ។ សូម្បីវេលាថ្ងៃត្រង់ ក៏រមែងដល់ នូវការសង្គ្រោះក្នុងកាល ។ ក៏ចាប់ដើមអំពីវេលាថ្ងៃត្រង់នោះទៅ ភិក្ខុមិនអាច ដើម្បីទំពារ ឬក៏ ឆាន់បានឡើយ, (ប៉ុន្តែ) ភិក្ខុគប្បីអាច ដើម្បីនឹងផឹក (ឆាន់) ដោយរួសរាន់បាន, តែភិក្ខុអ្នកមានសេចក្តីរង្កៀសសង្ស័យ មិនគួរផ្ញើឡើយ "។

ដីកាព្រហ្មជាលសូត្រ ចូឡហត្ថិបទោបមសូត្រ និងឱបោសថ-សូត្រថា "ចាប់ដើមតាំងអំពីព្រះអាទិត្យរះឡើងមក រហូតដល់ពេលថ្ងៃត្រង់ កាលនេះ រមែងជាកាលបរិភោគ ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម បានសន្សំអប់រំមកហើយ, កាលផ្សេងក្រៅអំពីកាលនោះ ចាត់ជាវេលាវិកាល" ។

ដីកាមហាខន្ធកៈថា "វត្ថុដែលឈ្មោះថា ភោជនៈ ព្រោះអត្ថថា គឺបុគ្គលគប្បីបរិភោគ គឺវត្ថុដែលជាយាវកាលិក គ្រប់បែបយ៉ាង មានយាគូ និងភត្តជាដើម ។ ប្រៀបដូចជា ការបរិភោគក្នុងវេលារាត្រី ក្នុងពាក្យថា '**រត្តិបរតោ**' នេះ លោកពោលថា '**រត្តិ**' ព្រោះលប់បទខាងក្រោយ យ៉ាងណា, ការលេបនូវភោជនៈចូលទៅក្នុងពាក្យថា '**វិកាលភោជនា**' នេះ លោកក៏ពោលថា '**ភោជនំ**' ដូច្នេះ ព្រោះលប់បទខាងក្រោយ ក៏យ៉ាងដូច្នោះដែរ ។ ការបរិភោគភោជនៈ ក្នុងវេលាវិកាល ឈ្មោះថា វិកាលភោជនៈ" ។

(១១៨) អដ្ឋកថាឈ្មោះកង្ខាវិតរណី ថា "ក្នុងវិកាលភោជនសិក្ខាបទនេះ មានអង្គទាំងឡាយ ៣ នេះ គឺ ភាពជាវេលាវិកាល ១ ភាពនៃវត្ថុជាយាវកាលិក ១ ការលេបចូលទៅ ១" ។

អដ្ឋកថាខុទ្ទកបាឋៈថា " វិកាលភោជនៈ មានអង្គ ៤ គឺ វេលាវិកាល ១ វត្ថុជាយាវកាលិក ១ ការលេបចូលទៅ ១ ភាព

ជាអ្នកមិនមែនជាមនុស្សឆ្កួត ១ ។ ការចំណែកអង្គ សូម្បីនៃសិក្ខាបទទាំងឡាយ ដ៏សេស បណ្ឌិតគប្បីជ្រាប ដោយទំនងនេះ” ។

ក៏អង្គថា “ភាពជាអ្នកមិនមែនជាមនុស្សឆ្កួត” នុ៎ះ ប្រសើរ ។ សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “មិនត្រូវអាបត្តិ ដល់ភិក្ខុជាអ្នកឆ្កួត” ។

(១១៩) ចំណែកអង្គទី ៧ មាន **នច្ចគីត** ជាដើម បណ្ឌិតគប្បីត្រួតពិនិត្យមើល ដោយពិស្តារ ក្នុងអដ្ឋកថាខុទ្ទកបាឋៈ និងអដ្ឋកថាព្រហ្មជាលសូត្រជាដើម ។ ចំណែកក្នុងអធិការនេះ មានសេចក្តីសង្ខេប ដូចតទៅនេះ ÷

អដ្ឋកថាព្រហ្មជាលសូត្រ និង ឱឃោសថសូត្រថា “ក៏កិរិយាប្រកប ដោយខ្លួនឯងក្តី កិរិយាប្រើឱ្យគេប្រកបក្តី នូវរបាំជាដើម ការមើលនូវរបាំ ដែលគេប្រកបហើយក្តី មិនសមគួរ ដល់ពួកភិក្ខុភិក្ខុនីទាំងឡាយឡើយ” ។

អដ្ឋកថាខុទ្ទកបាឋៈថា “ក៏កាលបើបុគ្គលចូលទៅ ដោយមានបំណងនឹងមើល ហើយមើលនុ៎ះឯង, សេចក្តីល្មើស ទើបមាន ក្នុងសិក្ខាបទនេះ ។ តែកាលបើបុគ្គលមើល នូវការរាំជាដើម ដែលមកហើយ ក្នុងឱកាសដែលខ្លួនឈរ អង្គុយ និងដេកក្តី កំពុងតែដើរទៅ ឃើញរបាំជាដើម ដែលមកប៉ះគន្លងនៃចក្ខុក្តី, សេចក្តី

សៅហ្មង គប្បីមាន, សេចក្តីល្មើស មិនមានឡើយ"។

(១២០) ដីកាព្រហ្មជាលសូត្រ ចូឡហត្ថិបទោបមសូត្រនិង ឧបោសថសូត្រថា "ការស្តាប់ចម្រៀង ដែលមិនមែនជាសឹកសត្រូវ រមែងសមគួរ ក្នុងពេលខ្លះ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកាថា 'ភ្លេងចម្រៀង ដែលប្រកបដោយធម៌ ទើបសមគួរ, ធម៌ដែលប្រកបដោយភ្លេងចម្រៀង មិនសមគួរទេ" ដូច្នេះ។

ពិតមែន ការដែលស្តាប់ភ្លេងចម្រៀង ដែលមិនមែនជាសឹកសត្រូវ រមែងសមគួរ។ ហេតុនោះ ក្នុងអដ្ឋកថាសក្កបញ្ហាសូត្រ ទើបលោកពោលថា "កាលបើបុគ្គលស្តាប់ នូវសំឡេង សូម្បីដែលមានអក្ខរៈដ៏វិចិត្រ និងមានព្យញ្ជនៈដ៏វិចិត្រណាមួយ, កិលេសទាំងឡាយមានរាគៈជាដើម រមែងកើតឡើង, សំឡេងដូច្នោះនោះ បុគ្គលមិនគួរសេព។ ប៉ុន្តែកាលបើបុគ្គលស្តាប់ នូវសំឡេងដែលអាស្រ័យអត្ថ អាស្រ័យធម៌ សូម្បីជាភ្លេងចម្រៀង របស់នាងកុម្ភទាសី, សេចក្តីជ្រះថ្លា រមែងកើតឡើងបាន ឬសេចក្តីធុញទ្រាន់ រមែងប្រាកដ, សំឡេងយ៉ាងដូច្នោះនោះ បុគ្គលគួរសេព"។

(១២១) ដីកាសក្កបញ្ហាសូត្រនោះថា "ព្រះអដ្ឋកថាចារ្យ សំដៅយកភ្លេងចម្រៀង ដែលប្រាកដឡើង ដោយភាវៈនៃភ្លេង

ចម្រៀងដែលពិរោះចាប់ចិត្ត ដោយអំណាចនៃការកំណត់ ដែលប្រព្រឹត្តទៅ យ៉ាងដូច្នោះ ព្រោះភាវៈជាទីប្រជុំ នៃភ្លេងចម្រៀងដែលវិចិត្រ ដោយអំណាច នៃការនិពន្ធនូវពាក្យកំណាព្យ និងភ្លេងចម្រៀងមានភ្លេងចម្រៀង របស់អ្នករបាំជាដើម និង ដោយអំណាចនៃការច្រៀងជូនដំណើរ ទើបពោលថា '**យំ ចិត្តក្ខរចិត្តព្យញ្ជនម្បិ ...ឧប្បជ្ជន្តិ**' ដូច្នេះ ។ បទថា '**អត្ថនិស្សិតំ**' គឺ ដែលអាស្រ័យប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងភពខាងមុខ ។ បទថា '**ធម្មនិស្សិតំ**' គឺ អាស្រ័យធម៌ដែលមិនត្រឡប់វិញ (ព្រះនិព្វាន) ។ ការជឿក្នុងព្រះរតនត្រ័យក្តី ការជឿក្នុងកម្មនិងផលនៃកម្មក្តី ឈ្មោះថាសេចក្តីជ្រះថ្លា ។ បទថា '**និព្ពិទា វា**' គឺ ឬថា សេចក្តីធុញទ្រាន់ចាកវដ្តៈ ដោយអំណាចអនិច្ចសញ្ញាជាដើម" ។

ចំណែកពាក្យណា ដែលលោកបានសរសេរទុកហើយ ក្នុងគម្ពីរអដ្ឋកថាខុទ្ទកបាឋៈថា "ក៏ក្នុងអង្គទី ៧ នេះ ភ្លេងចម្រៀងសូម្បីដែលប្រកបដោយធម៌ក្តី រមែងមិនសមគួរ, ចំណែកធម៌ដែលប្រកបដោយភ្លេងចម្រៀង ទើបសមគួរ" ដូច្នេះ ។ ពាក្យនោះរមែងមិនសម នឹងពាក្យដែលលោកនាំយកមកហើយ ក្នុងដីកានៃព្រហ្មជាលសូត្រជាដើម ។

(១២២) អដ្ឋកថាព្រហ្មជាលសូត្រ និង ខុទ្ទកបាឋសូត្រថា

អដ្ឋកថាព្រហ្មជាលសូត្រ និង ឧបោសថសូត្រថា "ទីដេកដែលខ្ពស់ហួសប្រមាណ ឈ្មោះថា ឧច្ចាសយនៈ។ ទីដេកដែលក្រាលដោយគ្រឿងកម្រាលដែលមិនសមគួរ ឈ្មោះថា មហាសយនៈ"។

ដីកាព្រហ្មជាលសូត្រ និង ឧបោសថសូត្រនោះថា "ទីដេកដែលខ្ពស់ និង ទីដេកដែលធំ ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយកទីដេកដែលប្រាសចាកសមណសារូប ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**បមាណាតិក្កន្តំ អកប្បិយត្ថតំ**' ដូច្នេះ"។

អដ្ឋកថាខុទ្ទកបាឋៈថា "ទីដេកដែលមិនសមគួរ និង គ្រឿងកម្រាលដែលមិនសមគួរ ឈ្មោះថា មហាសយនៈ"។

ដីកាព្រហ្មជាលសូត្រជាដើមថា "សព្ទថា '**ឧច្ចា**' ជាសព្ទពិសេសមួយ ដែលមានសេចក្តីស្មើនឹង **ឧច្ច** សព្ទ។ បុគ្គលតែងដេក ក្នុងទីនុ៎ះ ហេតុនោះ ទីនុ៎ះ ឈ្មោះថា ទីជាទីដេក គឺ អាសន្ទិ ជាដើម។ ក៏អាសនៈ លោកសង្គ្រោះហើយ ដោយ **សយន** សព្ទ ក្នុងបទថា '**ឧច្ចាសយនមហាសយនំ**' នុ៎ះ ដូច្នេះ"។

(១២៣) អដ្ឋកថាចម្មក្ខន្ធកៈថា "អាសនៈ ដែលខ្ពស់ហួសប្រមាណ ឈ្មោះថា អាសន្ទិ"។

ព្រះបាលីសេនាសនក្ខន្ធកៈថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត តាំងដែលមានជ្រុង ៤ សូម្បីខ្ពស់ក៏ដោយ"។

អដ្ឋកថាសេនាសនក្ខន្ធកៈនោះថា "តាំងមានរាង ៤ ជ្រុងស្មើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា 'អាសន្ទិក' ។ ក៏ព្រោះព្រះបាលីថា **'ឧច្ចកម្បិ អាសន្ទិកំ'** តាំងរាងវែង ដោយចំណែកមួយនុ៎ះឯង មានជើងប្រមាណ ៨ ធ្នាប់ ទើបសមគួរ ។ មួយទៀត អាសន្ទិ ៤ ជ្រុងចតុរស សូម្បីហួសប្រមាណ ក៏គប្បីជ្រាបថា 'គួរ' ។

ជីកាឈ្មោះវិមតិវិនោទនីថា "តាំងមានរាង ៤ ជ្រុងស្មើគ្នា ឈ្មោះថា **ចតុរស្សបីឋំ** ។ ពាក្យថា **'បមាណាតិក្កន្តោបិ'** លោកពោលសំដៅយក តាំងមានរាង ៤ ជ្រុងស្មើគ្នា ដូចគ្នាដែរ ។ ចំណែកឯតាំងដែលមានអង្គ ៧ និង តាំងដែលមានអង្គ ៥ ដែលមានរាង ៤ ជ្រុងស្មើ មានជើងខ្ពស់ មិនសមគួរ" ។

(១២៤) ពិតមែន ជើងត្រែ និង ជើងតាំង មានប្រមាណ ៨ ធ្នាប់ ដោយធ្នាប់ នៃព្រះសុគតប៉ុណ្ណោះ ទើបសមគួរ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា "មួយទៀត ភិក្ខុកាលនឹងឲ្យគេធ្វើត្រែ ឬ តាំងថ្មី គប្បីឲ្យគេធ្វើ ឲ្យមានជើងបានប្រមាណ ៨ ធ្នាប់ ដោយធ្នាប់ នៃព្រះសុគត រៀរលែងតែមេត្រែខាងក្រោមចេញ, កាលបើភិក្ខុធ្វើឲ្យខ្ពស់លើសហួសប្រមាណនោះ ត្រូវបាចិត្តីយ៍ មានការឲ្យកាត់ចេញជាវិនិយកម្ម" ។

(១២៥) ក៏ព្រោះព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុង

អដ្ឋកថាកុដិការសិក្ខាបទ ក្នុងកង្ខាវិតរណីថា "៣ ចំអាម របស់មជ្ឈិមបុរស ក្នុងពេលឥឡូវនេះ ឈ្មោះថា ១ ចំអាម នៃព្រះសុគត ត្រូវជា ១ ហត្ថ ១ ចំអាម ដោយហត្ថ នៃជាងឈើ" ដូច្នេះ ព្រោះហេតុនោះ ៣ ធ្នាប់ របស់មជ្ឈិមបុរស ត្រូវជា ១ ធ្នាប់ នៃព្រះសាស្តា ព្រោះហេតុនោះ ៨ ធ្នាប់ នៃព្រះសាស្តា ទើបត្រូវជា ២៤ ធ្នាប់ នៃមជ្ឈិមបុរស ។ ២៤ ធ្នាប់ នៃមជ្ឈិមបុរសនោះ ត្រូវជាមួយគក់ ។

ព្រោះហេតុនោះ ក្នុងដីកានៃឧបោសថសូត្រ ទើបលោកពោលថា "បទថា '**មុដ្ឋិហត្ថបាទកេ**' គឺ មានជើងប្រមាណមួយគត់ រាប់តាំងអំពីផ្ទៃនៃបាទជើងឡើងទៅ រហូតដល់ទីបំផុតខាងក្រោម នៃមេគ្រែ ។ ក៏មួយគក់ ដែលមានឈ្មោះថា ហត្ថ របស់ជាងឈើ ក្នុងពេលឥឡូវនេះ ស្មើគ្នានឹងហត្ថ របស់មជ្ឈិមបុរស ។ ក៏ព្រោះមួយធ្នាប់កន្លះ របស់បុរសតាមធម្មតា ត្រូវជាមួយធ្នាប់ របស់មជ្ឈិមបុរស, ចំអាម ហត្ថ លូក និង ញាម ក៏យ៉ាងដូច្នោះដែរ, ព្រោះហេតុនោះ បណ្ឌិតគប្បីដល់ការយល់ព្រម ក្នុងអធិការនេះថា 'មួយគក់ របស់មជ្ឈិមបុរស ត្រូវជាមួយគត់ មួយចំអាម នៃបុរសតាមធម្មតា" ។

(១២៦) ចំណែកទ្រនាប់គ្រែ ៨ ធ្នាប់ ដោយធ្នាប់

នៃមនុស្ស (ធម្មតា) ប៉ុណ្ណោះ ទើបសមគួរ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ ក្នុងសេនាសនក្ខន្ធកៈថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើទ្រនាប់គ្រែដែលខ្ពស់, ភិក្ខុណាគប្បីប្រើ, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតទ្រនាប់គ្រែ មិនលើសអំពី ៨ ធ្នាប់ឡើងទៅ" ។

ចំណែកក្នុងអដ្ឋកថាសេនាសនក្ខន្ធកៈនោះ លោកពោលថា "៨ ធ្នាប់ គឺធ្នាប់ដែលជាប្រមាណ របស់ពួកមនុស្សនុ៎ះឯង" ។

ព្រោះហេតុនោះ គ្រែនិងតាំង ដែលផ្សេងក្រៅអំពីអាសន្ទិ ដែលមាន ៤ ជ្រុងស្មើគ្នា មានទ្រនាប់ខ្ពស់ជាង ១ ហត្ថ ១ ចំអាមនិងគ្រែ ដែលមានទ្រនាប់ខ្ពស់ជាង ៨ ធ្នាប់ ឡើងទៅ ឈ្មោះថាទីដេកដែលខ្ពស់ហួសប្រមាណ ។ គ្រែនិងតាំង ដែលគេក្រាលដោយកម្រាលមិនសមគួរ ជារបស់ខ្ពស់ក្តី ទាបក្តី, គ្រែនិងតាំងនោះ ឈ្មោះថា ទីដេកធំហួសប្រមាណ ។ ទីដេកខ្ពស់ និង ទីដេកធំហួសប្រមាណទាំង ២ យ៉ាងនោះ រមែងមិនសមគួរ ។

ព្រោះហេតុនោះ ក្នុងអដ្ឋកថាខុទ្ទកបាឋៈ ទើបលោកពោលថា "ទីដេកខ្ពស់ និង ទីដេកធំហួសប្រមាណ សូម្បីទាំង ២ យ៉ាងនោះ រមែងមិនគួរ ដោយបរិយាយណាមួយ ដល់ភិក្ខុអ្នកត្រេកអរ" ។

(១២៧) ក៏គ្រឿងកម្រាលដែលមិនសមគួរ ដែលបុគ្គល

ក្រាលលើគ្រែនិងតាំង រមែងមិនសមគួរ, គ្រឿងកម្រាលផ្សេងទៀត មិនសមគួរក៏ទេ (គឺសមគួរ) ។ ដោយហេតុនោះ ក្នុងអដ្ឋកថាធម្មិកសូត្រ ទើបលោកពោលថា "ក៏ការដេកលើផែនដីសូម្បីក្រាលដោយកម្រាលរោមសត្វជាដើម ក៏សមគួរ"។

ជីកាព្រហ្មជាលសូត្រ និង ឧបោសថសូត្រថា "ក៏កាលបើគ្រឿងទ្រនាប់ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមហើយ, កិរិយាប្រើប្រាស់ នូវគ្រឿងទ្រនាប់នោះ រមែងជារបស់ដែលព្រះអង្គទ្រង់ត្រាស់ហាមហើយដែរ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ថា **'ឧច្চាសយនមហាសយនា'** ដូច្នេះ ។ ប៉ុន្តែដោយសេចក្តី ការរៀរចាកការអង្គុយនិងដេក ដែលជាការប្រើប្រាស់ នូវទីដេកខ្ពស់ និងទីដេកធំហួសប្រមាណនោះ បណ្ឌិតគប្បីជ្រាបថា 'ព្រះអង្គទ្រង់ត្រាស់សំដែងហើយ' ដូច្នេះ"។

(១២៨) ព្រោះរួមអង្គទី ៧ និងទី ៨ ទាំង ២ អង្គ ចូលជាមួយគ្នា ទើបមានអង្គ ៨ យ៉ាងដូច្នេះឯង ។ ដោយហេតុនោះ ក្នុងអដ្ឋកថាខុទ្ទកបាឋៈ ទើបលោកពោលថា "អង្គទាំងឡាយ ២ ខាងដើម និង អង្គទី ៤ ទី ៥ ជាអង្គដែលទូទៅ ចំពោះឧបាសក និងសាមណេរទាំងឡាយ ដោយអំណាចនៃនិច្ចសីល ។ អង្គទាំងឡាយទាំងពួង រួមទាំងអង្គ ទី ៧ និង ទី ៨ របស់ឧបាសកទាំងឡាយ

ជាអង្គមួយ ដោយអំណាចឧបោសថ រៀរចាកអង្គចុងក្រោយគេ បង្អស់ នៃអង្គទាំងពួង ជាអង្គទូទៅ នឹងសាមណេរទាំងឡាយ ។ តែអង្គចុងក្រោយនៃអង្គទាំងពួង ជាអង្គពិសេស ចំពោះសាមណេរ ទាំងឡាយ ប៉ុណ្ណោះ” ។

ចំណែកក្នុងគម្ពីរ ឈ្មោះវិសុទ្ធិមគ្គ លោកពោលថា “ សីល របស់គ្រហស្ថ យ៉ាងនេះ គឺ សម្រាប់ពួកឧបាសក និង ឧបាសិកា មានសិក្ខាបទ ៥ ដោយអំណាចជានិច្ចសីល, ឬកាលបើមាន សេចក្តីព្យាយាម, ក៏គប្បីរក្សាទាំង ១០ សិក្ខាបទ, មានសិក្ខាបទ ៨ ដោយអំណាចជាអង្គនៃឧបោសថ” ។

ដីកានៃគម្ពីរឈ្មោះវិសុទ្ធិមគ្គនោះថា “ ២ បទថា ‘**សតិ វា ឧស្សាហេ**’ គឺ កាលបើសេចក្តីព្យាយាម ដើម្បីនឹងព្យាយាមហើយ រក្សានូវសីលមាន ។ ដោយបទថា ‘**ទស**’ ព្រះពុទ្ធឃោសាចារ្យ ពោល នូវសីល ដែលសាមណេរទាំងឡាយ គប្បីរក្សា ដូចជាសីល របស់ឃដិការឧបាសកដូច្នោះ ជាដើម” ។

ក្នុងដីកាមហាខន្ធកៈ កែថា “ ក៏ពាក្យណា ដែលលោកពោល ហើយ ក្នុងអដ្ឋកថាឈ្មោះខុទ្ទកបាឋៈនេះ ថា ‘ ប៉ុន្តែអង្គចុងក្រោយ នៃអង្គទាំងពួង ជាអង្គដ៏ពិសេស សម្រាប់សាមណេរទាំងឡាយ ប៉ុណ្ណោះ ’ ដូច្នេះ, ពាក្យនោះ រមែងមិនសម ដោយពាក្យនេះថា

'ឬកាលបើមានការព្យាយាម, ក៏គួរក្សាទាំង ១០ សិក្ខាបទ' ដូច្នេះ"។

ពណ៌នាអំពីអង្គ ៨ ចប់ ។

(១២៩) អដ្ឋកថាខុបោសថសូត្រថា "ក៏បុគ្គលកាលនឹងរក្សានូវខុបោសថសីលនោះ គប្បីតាំងចិត្តថា 'ក្នុងថ្ងៃស្អែកនេះ អាត្មាអញ នឹងជាអ្នករក្សាខុបោសថ' ដូច្នេះហើយ គប្បីចាត់ចែងនូវការងារ មានការចាត់ចែងអាហារជាដើម ក្នុងថ្ងៃនេះឱ្យស្រេចតែម្តង ដោយប្រាប់ថា 'ពួកអ្នក គប្បីធ្វើកិច្ចការនេះផង នេះផង'។ ក្នុងថ្ងៃខុបោសថ គប្បីបញ្ចេញសំឡេង សមាទានអង្គ នៃខុបោសថទាំងឡាយ ក្នុងសំណាក់ នៃភិក្ខុ ឬ ភិក្ខុនី នៃឧបាសក ឬឧបាសិកា អ្នកដឹងលក្ខណៈនៃសីល ១០ តាំងអំពីព្រលឹមស្រាង ។ ប៉ុន្តែកាលបើមិនចេះបាលី គប្បីអធិដ្ឋានថា 'អាត្មាអញ អធិដ្ឋាននូវខុបោសថ ដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកហើយ' ដូច្នេះ ។ កាលបើមិនបានអ្នកដទៃ គប្បីអធិដ្ឋាន ដោយខ្លួនឯងក៏បានដែរ, តែគប្បីធ្វើការបញ្ចេញវាចា ដោយពិត ។ កាលរក្សានូវខុបោសថ មិនគប្បីចាត់ចែងការងារ ដែលទាក់ទង ដោយការបៀតបៀនអ្នកដទៃឡើយ ។ គប្បីធ្វើការរាប់អាយុនិងវ័យ ញុំាងពេលវេលាឱ្យកន្លងផុតទៅ, មួយទៀត គប្បីជាអ្នក ដូចជាភិក្ខុអ្នកមានភ័ត្តជាប្រចាំ បានអាហារក្នុងផ្ទះ បរិភោគស្រេចហើយ គប្បីទៅវត្ត ស្តាប់ធម៌,

ឬ គប្បីធ្វើទុកក្នុងចិត្តអារម្មណ៍ណាមួយ បណ្តាអារម្មណ៍ទាំង ៣៨ ប្រការ ”។

(១៣០) ជីកានៃខុបោសថសូត្រនោះថា “ចាប់ដើមអំពីការសមាទានសីល អ្នករក្សាខុបោសថ មិនគួរធ្វើកិច្ចការដទៃទៀត គប្បីញុំាងពេលវេលា ឲ្យកន្លងផុតទៅ ដោយការស្តាប់ធម៌ ឬធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **‘តម្បន ឧបវសន្តេន ។ល។ វិចារេតព្ពំ’** ដូច្នេះ ។ ក្នុង ២ បទថា **‘វាចំ កិន្តិត្វា’** គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ÷ អ្នករក្សាខុបោសថ គប្បីធ្វើការកំណត់កាលថា ‘(អាត្មាអញ នឹងរក្សានូវខុបោសថ) អស់យប់នេះ និងថ្ងៃនេះ’ ដូច្នេះហើយ ធ្វើដោយការរួមជាមួយគ្នា ដោយអំណាចអង្គខុបោសថថា ‘អាត្មាអញ សមាទាន នូវសិក្ខាបទទាំង ៨’ ដូច្នេះហើយ គប្បីធ្វើការបញ្ចេញវាចា សមាទាន អង្គខុបោសថ ជាបច្ចេកសមាទាន (ចំពោះអង្គ) តាមបាលី យ៉ាងនេះថា **‘បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ ។ល។ ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ’** ដូច្នេះ ។ ប៉ុន្តែកាលបើមិនចេះបាលី គប្បីសមាទាន ជាបច្ចេកសមាទាន តាមភាសា របស់ខ្លួន ឬ ដោយអំណាចការអធិដ្ឋាន ដោយរួមជាមួយគ្នាថា ‘អាត្មាអញ

អធិដ្ឋានឧបោសថ ដែលព្រះពុទ្ធទ្រង់បានបញ្ញត្តទុកហើយ' ដូច្នេះ។ បើមិនបានអ្នកដទៃ គប្បីអធិដ្ឋាន ដោយខ្លួនឯងក៏បាន។ ពិតមែន សីលរបស់ឧបាសក គឺបុគ្គលអ្នករក្សាឧបោសថ សមាទាន ដោយខ្លួនឯងក្តី ឈ្មោះថា បានសមាទានហើយ, សមាទាន ក្នុងសំណាក់នៃបុគ្គលដទៃក្តី ឈ្មោះថា បានសមាទានហើយ, សមាទានរួមគ្នា (ជាឯកជ្ឈសមាទាន) ក្តី សមាទាន ជាបច្ចេកសមាទាន (ចំពោះអង្គមួយៗ) ក្តី ក៏ឈ្មោះថា បានសមាទានស្រេចហើយ ដូចគ្នាដែរ។

សួរថា 'សេចក្តីខុសប្លែកអំពីគ្នា នឹងមាន យ៉ាងដូចម្តេច?'។

ឆ្លើយថា 'បើបុគ្គលសមាទាន ជាឯកជ្ឈសមាទាន (រួមគ្នា) វិរ័តិ ក៏ដូចគ្នាតែមួយប៉ុណ្ណោះ, ចេតនា ក៏មានមួយដួងដូចគ្នាដែរ។ ប៉ុន្តែវិរ័តិ និងចេតនាទាំង ២ នោះ ធ្វើកិច្ច នៃវិរ័តិ និងចេតនាគ្រប់បែបយ៉ាង ព្រោះហេតុនោះ សិក្ខាបទទាំងអស់ ចាត់ទុកថា គឺបុគ្គលអ្នករក្សាឧបោសថ បានសមាទានហើយ ដោយពិត ដោយការសមាទានរួមគ្នានោះឯង។ មួយទៀត បើបុគ្គលសមាទាន ជាបច្ចេកសមាទាន វិរ័តិ និងចេតនា ដែលផ្សេងៗគ្នា រមែងកើតឡើង តាមនាទីរបស់ខ្លួន ដោយអំណាចនៃកិច្ច។ ក៏ក្នុងការសមាទានគ្រប់យ៉ាង គប្បីធ្វើការបញ្ជេញវាចា ដោយពិត'។ បទថា '**បរោបរោធប្បដិសំយុត្តា**' គឺ ដែលជាប់ទាក់ទង ដោយ

ការបៀតបៀនអ្នកដទៃ" ដូច្នេះ ។

ពណ៌នាអំពីការសមាទានអង្គឧបោសថ ចប់ ។

(១៣១) ការសមាទានអង្គឧបោសថនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការកើតឡើង ក្នុងឋានសួគ៌ជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកថា "ម្នាលនាងវិសាខា [1] ប្រៀបដូចបុគ្គលឯណាមួយ គប្បីគ្រងរាជសម្បត្តិជាឥស្សរិយាធិបតី នៃមហាជនបទទាំង ១៦ នេះ ដែលមានរតនៈ ៧ ប្រការដ៏ច្រើន, មហាជនបទទាំង ១៦ គឺ អង្គៈ មគធៈ កាសី កោសល វជ្ជី មល្លៈ ចេតី វង្សៈ កុរុ បញ្ចាលៈ មច្ឆៈ សុរសេនៈ អស្សកៈ អវន្តី គន្ធារៈ កម្ពោជៈ, ការគ្រងរាជសម្បត្តិនុ៎ះ របស់បុគ្គលនោះ មិនមានតម្លៃស្មើនឹងចំណិតទី ១៦ ។ នៃឧបោសថដែលប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ? ។ ម្នាលនាងវិសាខា រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខ ដែលជាទិព្វ (ឃើញ) ស្តួចស្តើងណាស់ ។

ម្នាលនាងវិសាខា ៥០ ឆ្នាំ របស់មនុស្ស ត្រូវជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ, រាប់រាត្រីនោះ ៣០ រាត្រី ជាមួយខែ, រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ, រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុ របស់ពួក

---

១ ត្រៃបិដក ភាគទី ៤១ / ទំព័រទី ២៧៨

ទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់ទំលាយរាងកាយស្លាប់ទៅ កើតរួមជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការ កើតរួមជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈន៉ុះឯង ទើបបានពោលពាក្យនេះថា 'រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្ធ (ឃើញ) ស្ពួចស្ពើងណាស់' ។

ម្នាលនាងវិសាខា ១០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់តាវត្តិង្ស ។ ល ។ រាប់តាមឆ្នាំនោះ ១.០០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់ទំលាយរាងកាយ ស្លាប់ទៅ កើតរួមជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការ កើតរួម ជាមួយនឹងទេវតាជាន់តាវត្តិង្ស ទាំងឡាយន៉ុះឯង ទើបបានពោលពាក្យនេះថា 'រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្ធ ស្ពួចស្ពើងណាស់' ។

ម្នាលនាងវិសាខា ២០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់យាមៈ ។ល។ រាប់តាមឆ្នាំនោះ ២.០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់យាមៈ។ ម្នាលនាងវិសាខា ក៏ហេតុនុ៎ះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឱបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់ទំលាយរាងកាយស្លាប់ទៅ កើតរួមជាមួយនឹងពួកទេវតាជាន់យាមៈ។ ម្នាលនាងវិសាខា ក៏តថាគតសំដៅយកការទៅកើតរួម ជាមួយនឹងពួកទេវតាជាន់យាមៈ នុ៎ះឯង ទើបបានពោលថា 'រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្វ (ឃើញ) ស្តួចស្តើងណាស់'។

ម្នាលនាងវិសាខា ៤០០ ឆ្នាំ របស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់តុសិត ។ល។ រាប់តាមឆ្នាំនោះ ៤.០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តុសិត។ ម្នាលនាងវិសាខា ក៏ហេតុនុ៎ះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឱបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់ទំលាយរាងកាយស្លាប់ទៅ កើតរួមជាមួយនឹងពួកទេវតាជាន់តុសិត។ ម្នាលនាងវិសាខា ក៏តថាគតសំដៅយកការទៅកើតរួម ជាមួយនឹងពួកទេវតាជាន់តុសិត នុ៎ះឯង

ទើបបានពោលថា ‘ រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹង សេចក្តីសុខដ៏ជាទិព្ធ (ឃើញ) ស្ពួចស្តើងណាស់’ ។

ម្នាលនាងវិសាខា ៨០០ ឆ្នាំ របស់មនុស្ស ជាមួយយប់ មួយថ្ងៃ របស់ពួកទេវតាជាន់និម្មានរតី ។ ល ។ រាប់តាមឆ្នាំនោះ ៨.០០០ ឆ្នាំទិព្ធ ជាប្រមាណអាយុ នៃពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថ ប្រកបដោយ អង្គ ៨ ហើយ លុះដល់ទំលាយរាងកាយស្លាប់ទៅ កើតរួមជា មួយនឹងពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការទៅកើត រួមជាមួយពួកទេវតាជាន់និម្មានរតី ន៉ុះឯង ទើបបានពោលថា ‘ រាជសម្បត្តិ ជារបស់មនុស្ស ប្រៀបធៀបនឹង សេចក្តីសុខដ៏ជាទិព្ធ (ឃើញ) ស្ពួចស្តើងណាស់’ ។

ម្នាលនាងវិសាខា ១.៦០០ ឆ្នាំ របស់មនុស្ស ជាមួយយប់ មួយថ្ងៃ របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី, រាប់តាមរាត្រីនោះ ៣០ រាត្រី ជាមួយខែ, រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ, រាប់តាមឆ្នាំនោះ ១៦.០០០ ឆ្នាំទិព្ធ ជាប្រមាណនៃអាយុរបស់ពួក ទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ក៏ហេតុន៉ុះឯង រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ

រក្សាឧបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់ទំលាយរាងកាយស្លាប់ទៅ កើតរួមជាមួយ នឹងពួកទេវតាជាន់ចរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា ក៏តថាគត សំដៅយកការទៅកើតរួមជាមួយពួកទេវតាជាន់ចរនិម្មិតវសវត្តីនុ៎ះឯង ទើបបានពោលថា 'រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខដ៏ជាទិព្វ (ឃើញ) ស្ទួចស្តើងណាស់' ។

ចាលីឧបោសថសូត្រ ចប់ ។

(១៣២) អដ្ឋកថានៃឧបោសថសូត្រនោះ ថា " បទថា **'បហូតរត្តរតនានំ'** គឺ ប្រកបដោយរតនៈ ពោលគឺវត្ថុដែលញុំាងសេចក្តីត្រេកអរឲ្យកើត ដ៏ច្រើន ។ អធិប្បាយថា 'ពេញដោយរតនៈទាំង ៧ ប្រការ មានប្រមាណត្រឹមចង្កេះ ធ្វើផ្ទៃជម្ពូទ្វីបទាំងមូល ឲ្យដូចជាផ្ទៃនៃស្គរ ។ បទថា **'ឥស្សរិយាធិបច្ចំ'** គឺ ដោយភាពជាឥស្សរៈ និង ដោយភាពជាអធិបតី, មិនមែនដោយភាពជាព្រះរាជាថ្នាក់ទាបទេ ។ ម្យ៉ាងទៀត ភាពជាអធិបតី គឺ ភាពជាឥស្សរៈ ឈ្មោះថា ឥស្សរាធិបតី ព្រោះក្នុងរាជសម្បត្តិនេះ មិនមានកម្មដែលប្រព្រឹត្ត ដោយសេចក្តីគំរាមកំហែង ។ ២ បទថា **'រជ្ជំ ការេយ្យ'** គឺ គប្បីគ្រងចក្រពត្តិរាជ យ៉ាងនោះ ។ ពាក្យថា **'អង្គានំ'** ដូច្នេះជាដើម ជាឈ្មោះ នៃជនបទទាំងនោះ ។

ច្រើនបទថា 'កលំ នាគ្ឃតិ សោឡសឹ' មានសេចក្តីថា បុណ្យ នៃឧបោសថ ដែលបុគ្គលរក្សា អស់ថ្ងៃមួយ និងយប់មួយ ។ រមែងមិនដល់នូវចំណែកមួយ ចាកចំណែកទី ១៦ នោះ ព្រោះ បែងចែកឱ្យទៅជា ១៦ ចំណែក ។ អធិប្បាយថា 'ផល គឺវិបាក នៃចំណែកទី ១៦ នៃឧបោសថ អស់រាត្រីមួយណា, ផល គឺ វិបាកនៃចំណែកទី ១៦ នៃឧបោសថ អស់រាត្រីមួយនោះឯង ជាផលច្រើនជាងចក្រពត្តិរាជនោះ' ។ បទថា 'កបណំ' គឺ បន្តិចបន្តួច" ។

(១៣៣) ដីកានៃឧបោសថសូត្រនោះថា "**រត្ត** សំឌ្ឍ ជា បរិយាយ នៃ **រតន** សំឌ្ឍ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'បទថា '**បហូតរត្តរតនានំ**' គឺ ប្រកបដោយ រតនៈ ពោលគឺវត្ថុដែលញុំាងសេចក្តីត្រេកអរឱ្យកើត ដ៏ច្រើន' ។ ប៉ុន្តែក្នុងព្រះបាលី បាឋៈថា '**បហូតសត្តរតនានំ**' ដូច្នេះ តែង ប្រាកដមានខ្លះ ។ ២ បទថា '**ភេរិតលសទិសំ កត្វា**' គឺ ធ្វើឱ្យស្មើដូចជាផ្ទៃនៃស្គរ ។ ច្រើនបទថា '**តតោ ឯកំ ភាគំ ន អគ្ឃតិ**' គឺ ចក្រពត្តិរាជ តាមដែលពោលមកហើយ រមែង មិនដល់នូវចំណែកមួយ ចាកចំណែកទី ១៦ នោះ ។ ២ បទថា '**តតោ ពហុតរំ**' គឺ រមែងច្រើនជាងសិរី នៃចក្រពត្តិរាជ ។

ក្នុងបទថា '**ចាតុម្មហារាជិកានំ**' ដូច្នេះជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ ៩ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់ចាតុម្មហារាជិក: ដោយការរាប់ របស់មនុស្ស ។ ៣ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តាវត្តិង្ស ។ ១៤ កោដិ ៤ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់យាម: ។ ៥៧ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់តុសិត ។ ២៣០ កោដិ ៤ លានឆ្នាំ ជាប្រមាណ នៃអាយុ របស់ពួកទេវតាជាន់និម្មានរតី ។ ៩២១ កោដិ ៦ លានឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី" ។

(រឿងបុរោហិត)

(១៣៤) ក្នុងអតីតកាល ព្រះពោធិសត្ត សោយព្រះជាតិជាព្រះរាជាក្រុងពារាណសី ព្រះអង្គមិនទ្រង់ប្រមាទ ដោយព្រះអង្គឯង ក្នុងទាន សីល និងឧបោសថកម្ម ទ្រង់បានបបួល នូវអាមាត្យជាដើម សូម្បីដែលសេសសល់ ក្នុងទានជាដើម ។ ចំណែកបុរោហិត របស់ព្រះពោធិសត្វនោះ ត្រូវព្រះពោធិសត្ត តែងតាំងហើយ ក្នុងតំណែងវិនិច្ឆ័យ ជាអ្នកស៊ីសាច់ឆ្ពឹងខ្ពង របស់ជនដទៃ ដោយការស៊ីសំណូក ទើបមិនសមាទាន ។ ក្នុងថ្ងៃឧបោសថ ថ្ងៃ ១

បុរោហិតនោះទទួលសំណូក កាត់ក្តីកោង រហូតមួយថ្ងៃ ហើយបាន
ទៅកាន់ទីឧបដ្ឋាកនៃព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា "ម្នាល
អាចារ្យ លោករក្សាឧបោសថឬ?" ដូច្នេះហើយ ក្រាបទូល
កុហកថា "ពិតមែនហើយ ព្រះអង្គដ៏ចំរើន" ហើយ បានចុះអំពី
ប្រាសាទ។ គ្រានោះ អាមាត្យម្នាក់ ចោទបុរោហិតនោះថា
"លោកជាអ្នកមិនរក្សាឧបោសថ មិនមែនទេឬ?"។ បុរោហិត
នោះ ពោលថា "ខ្ញុំ បរិភោគតែក្នុងវេលាប៉ុណ្ណោះ ទៅផ្ទះហើយ
ខ្ពុរមាត់ស្រេច នឹងអធិដ្ឋាននូវឧបោសថ មិនបរិភោគ ក្នុងវេលា
ល្ងាច, ខ្ញុំនឹងរក្សាសីល ក្នុងវេលារាត្រី, បើដូច្នេះ ឧបោសថកម្ម
ពាក់កណ្តាល នឹងមានដល់ខ្ញុំ" ដូច្នេះហើយ ក៏ទៅផ្ទះ បានធ្វើហើយ
យ៉ាងដូច្នោះឯង។ ក្នុងថ្ងៃឧបោសថថ្ងៃមួយទៀត ស្ត្រីអ្នកមាន
សីលម្នាក់ កំពុងកាត់សេចក្តី កាលមិនបាន ដើម្បីនឹងទៅផ្ទះបាន ក៏
គិតថា "អាត្មាអញ នឹងមិនកន្លងនូវឧបោសថកម្ម" ដូច្នេះ, កាលបើ
វេលា ចូលខិតមកជិតហើយ, ក៏បានប្រារព្ធ ដើម្បីនឹងលាងមាត់។
បុរោហិតនោះ ដឹងថាស្ត្រីនោះ ជាអ្នករក្សាឧបោសថ ទើបពោលថា
"ចូរនាងបរិភោគផ្លែស្វាយនេះហើយ រក្សាឧបោសថចុះ" ហើយក៏
បានឲ្យផ្លែស្វាយ ដល់ស្ត្រីនោះ។ កម្មរបស់បុរោហិត មានតែ
ប៉ុណ្ណោះ។ ក្នុងកាលក្រោយមក បុរោហិតនោះ បានធ្វើ

មរណកាលហើយ បានកើតជាវេមានិកប្រេត មាននាងទេវកញ្ញា ១ ម៉ឺន ៦ ពាន់ ចោមរោមហើយ ក្នុងវិមានមាស ក្នុងព្រៃស្វាយ ប្រវែង ៣ យោជន៍ ក្បែរមាត់ទន្លេគង្គា ក្នុងព្រៃហិមវន្តប្រទេស ។ ក៏វេមានិកប្រេតនោះ សោយសម្បត្តិ តែក្នុងវេលារាត្រីប៉ុណ្ណោះ, កាលបើព្រះអរុណរះឡើង, ក៏ចូលទៅកាន់ព្រៃស្វាយ ។ ក្នុងពេលដែលវេមានិកប្រេតនោះចូលទៅនុ៎ះឯង អត្តភាពដែលជាទិព្វ ក៏អន្តរធានបាត់ទៅ, អត្តភាព មានទំហំប៉ុនដើមស្ពោត ប្រវែង ៨០ ហត្ថ ក៏កើតឡើង ។ សរីរៈទាំងអស់ ត្រូវភ្លើងឆេះ បានដូចជាផ្ការលួសផ្កុង (ផ្កាចារ) ដែលរីកក្រហាមច្រាល ។ ក្នុងដៃទាំង ២ មានម្រាមដៃ ម្ខាងមួយៗប៉ុណ្ណោះ ។ លើម្រាមដៃនោះ មានក្រចកទំហំប៉ុនចបដ៏ធំ ។ វេមានិកប្រេតនោះ យកក្រចកទាំងនោះ ហែកសាច់ខ្លួន របស់ខ្លួន ខ្ទេះទាញមកហើយៗ ទំពារស៊ី បានទទួលសេចក្តីឈឺចាប់ ស្រែកយំក្អែងៗ សោយនូវសេចក្តីទុក្ខ ។ កាលបើព្រះអាទិត្យ អស្តង្គតទៅហើយ, សរីរៈនោះ ក៏អន្តរធានបាត់ទៅ, សរីរៈដែលជាទិព្វ ក៏កើតឡើង ។ ស្ត្រីអ្នករបាំដ៏ជាទិព្វទាំងឡាយ អ្នកប្រដាប់តាក់តែងហើយ ក៏នាំគ្នាកាន់តន្ត្រីផ្សេងៗ មកចោមរោម នូវវេមានិកប្រេតនោះ ។ វេមានិកប្រេតនោះ សោយនូវមហាសម្បត្តិ ឡើងកាន់ប្រាសាទទិព្វ ក្នុងព្រៃស្វាយ ជាទីមនោរម្យ ។

វេមានិកប្រេតនោះ បានព្រៃស្វាយ ប្រវែង ៣ យោជន៍ ព្រោះផល នៃការឲ្យផ្លែស្វាយ ដល់ស្ត្រីអ្នករក្សាឧបោសថ, គាត់ខ្វេះហែកសាច់ ខ្នងស៊ី ព្រោះផលនៃការទទួលសំណូកហើយ កាត់សេចក្តីមិនបាន យុត្តិធម៌, គាត់បានសោយ នូវយសដ៏ធំ ក្នុងវេលាយប់ ព្រោះផល នៃការរក្សា នូវឧបោសថកម្ម ពាក់កណ្តាល ដោយប្រការដូច្នេះ ។

សូម្បីព្រះសាស្តា កាលទ្រង់សំដែងធម៌ ដល់ពួកឧបាសកអ្នក រក្សាឧបោសថ ទើបទ្រង់ត្រាស់ថា "ម្នាលឧបាសកទាំងឡាយ អ្នក ទាំងឡាយ រក្សាឧបោសថ ធ្វើកម្មប្រសើរហើយ, ឬរាណកបណ្ឌិត ទាំងឡាយ បានសោយ នូវយសដ៏ធំ ព្រោះផលនៃការរក្សានូវ ឧបោសថកម្ម ពាក់កណ្តាល" ដូច្នេះ ទ្រង់ញ្ចាំងរឿងនេះ ឲ្យបាន ពិស្តារហើយ ទ្រង់ត្រាស់កឹសន្ទជាតក ដែលជាជាតកខាងដើម នៃ ជាតកទាំងពួង ក្នុងតឹសនិបាត ទ្រង់បានប្រកាសសច្ចៈហើយ ។ ក្នុង វេលាចប់សច្ចៈ បណ្តាឧបាសកទាំងឡាយ ឧបាសកពួកខ្លះ បានជា សោតាបន្ន, ពួកខ្លះ បានជាសកទាគាមី, ពួកខ្លះ បានជា អនាគាមី ។

រឿងបុរោហិត ចប់ ។

(រឿងព្រះរាជាព្រះនាមឧទ័យ)

(១៣៥) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី បានមាន

សេដ្ឋីឈ្មោះថា សុចិបរិវារ មានទ្រព្យ ៨០ កោដិ ជាអ្នកត្រេកអរក្នុងបុណ្យមានទានជាដើម ។ បុត្រនិងភរិយាក្តី ជនជាបរិវារក្តី របស់សេដ្ឋីនោះ ដោយហោចទៅ សូម្បីអ្នកចិញ្ចឹមគោ ក្នុងផ្ទះនោះ គ្រប់គ្នាទាំងអស់ តែងរក្សានូវខ្មុបោសថ មួយខែ ៦ ថ្ងៃ ។

គ្រានោះ បុរសទីទាល់ក្រម្នាក់ ចិញ្ចឹមជីវិត ដោយការស៊ីឈ្នួលគេ បានចូលទៅរកសេដ្ឋីនោះ ថ្វាយបង្គំរួច បានឈរហើយ ។

សេដ្ឋីសួរថា “នែអ្នកដ៏ចំរើន អ្នកមកដើម្បីអ្វី ?” ។

បុរសនោះឆ្លើយថា “ខ្ញុំមក ដើម្បីបំណងនឹងធ្វើការងារដើម្បីថ្លៃឈ្នួល ក្នុងផ្ទះរបស់លោកសេដ្ឋី” ។

សេដ្ឋីប្រាប់ ក្នុងថ្ងៃដែលពួកអ្នកស៊ីឈ្នួលឯទៀត មកហើយនុ៎ះឯងថា “អ្នកទាំងឡាយ កាលធ្វើការងារ ក្នុងផ្ទះនេះ កាលបើអាច ដើម្បីរក្សាសីលបាន ចូរធ្វើការងារចុះ”។ តែសេដ្ឋី មិនបានធ្វើសញ្ញា ក្នុងការប្រាប់នូវការរក្សាសីល ដល់បុរសក្រីក្រនោះ ហើយបានប្រាប់ថា “នែអ្នក ប្រពៃហើយ, ចូរអ្នកធ្វើការងារតាមការចេះដឹង របស់ខ្លួន ដើម្បីថ្លៃឈ្នួលចុះ”។ បុរសនោះ តាំងពីពេលនោះមក ជាអ្នកដែលគេប្រដៅងាយ មិនបាននឹកគិតដល់សេចក្តីលំបាករបស់ខ្លួន ធ្វើកិច្ចការគ្រប់បែបយ៉ាង ទៅធ្វើការងារតាំងពីព្រឹកព្រលឹមហើយ មកវិញ ក្នុងពេលល្ងាច ។

ក្រោយមក ថ្ងៃមួយ សេដ្ឋី បានបញ្ជានាងទាសីថា "ថ្ងៃនេះ ជាថ្ងៃឧបោសថ, ចូរនាងដាំបាយ ឱ្យពួកកម្មករ ក្នុងផ្ទះ តាំងអំពីព្រឹកព្រលឹម, ពួកគេនឹងបរិភោគទាន់ពេលវេលាតែម្តង ហើយជាអ្នករក្សាឧបោសថ"។ នាងទាសីនោះ បានធ្វើហើយ យ៉ាងដូច្នោះ។ ឯបុរសក្រីក្រនោះ ក្រោកឡើងពីព្រលឹមហើយ ទៅធ្វើការងារ។ អ្នកណាមួយ ក៏មិនបានប្រាប់ នូវថ្ងៃឧបោសថ ដល់បុរសនោះទេ។ ជនទាំងឡាយ មានសេដ្ឋីជាដើម គ្រប់ៗគ្នា បរិភោគ តាំងពីព្រឹកព្រលឹម ជាអ្នករក្សាឧបោសថ អង្គុយពិចារណាសីល ក្នុងទីកន្លែងរបស់ខ្លួន (រៀងខ្លួន)។ បុរសទីទាល់ក្រ ធ្វើការងារ រហូតពេញមួយថ្ងៃ បានត្រឡប់មកវិញ ក្នុងវេលាដែលព្រះអាទិត្យអស្តង្គត, កាលបើគេបង្ហោនភត្តចូលមក, ទើបសួរថា "ក្នុងថ្ងៃដទៃទៀត (ថ្ងៃមុនៗ) ក្នុងវេលានេះ បានមានសំឡេងចៀវចាវយ៉ាងខ្លាំង, (តែ) ថ្ងៃនេះ តើពួកគេបានទៅណាអស់ហើយ?"។

នាងទាសីប្រាប់ថា "នែអ្នក ពួកគេទាំងអស់គ្នា ជាអ្នករក្សាឧបោសថ បានទៅកាន់ទីកន្លែងរបស់គេរៀងៗខ្លួនហើយ"។

បុរសនោះ គិតថា "ក្នុងចំណោម នៃពួកបុគ្គលអ្នកមានសីលមានប្រមាណប៉ុណ្ណោះ អាត្មាអញម្នាក់ឯង នឹងមិននៅជាមនុស្សទ្រុស្តសីលឡើយ" ហើយ ទើបមិនបរិភោគភត្ត ចូលទៅរកសេដ្ឋី

ហើយសួរថា "បពិត្រលោកម្ចាស់ កាលបើខ្ញុំអធិដ្ឋានឧបោសថ ក្នុងថ្ងៃឧបោសថ ពេលនេះ, តើឧបោសថកម្ម នឹងមាន ឬមិនមាន?"។ សេដ្ឋីឆ្លើយថា "នែអ្នក ព្រោះអ្នកមិនបានអធិដ្ឋាន តាំងអំពីព្រឹកព្រលឹម ឧបោសថកម្មទាំងអស់ ទើបមិនមាន, តែឧបោសថកម្មពាក់កណ្តាល នឹងមាន"។ បុរសនោះ គិតថា "សូម្បីតែប៉ុណ្ណោះក៏គ្រប់គ្រាន់ ដល់អាត្មាអញដែរ" ហើយ ជាអ្នកសមាទានសីល ក្នុងសំណាក់នៃសេដ្ឋី អធិដ្ឋានឧបោសថហើយ ក៏បានទៅកាន់ទីកន្លែងរបស់ខ្លួន ដេកពិចារណានូវសីលហើយ ។

គ្រានោះ ខ្យល់ក្តងពោះ កើតឡើងហើយ ដល់បុរសនោះ ក្នុងចន្លោះនៃបច្ឆិមយាម ព្រោះភាវៈនៃខ្លួនជាអ្នកអត់អាហារ អស់រយៈពេលពេញមួយថ្ងៃ ។ សេដ្ឋីបាននាំយកភេសជ្ជៈផ្សេងៗ មកពោលថា "ចូរអ្នកបរិភោគចុះ"។ បុរសនោះ គិតថា "អាត្មាអញ នឹងមិនទំលាយឧបោសថចោល" ហើយ ពោលថា "ខ្ញុំនឹងសមាទាន ធ្វើជីវិតឲ្យមានទីបំផុត" ហើយ មិនព្រមបរិភោគ ។ វេទនាដ៏មានកម្លាំង កើតឡើងហើយ ។ បុរសនោះ មិនអាចដើម្បីនឹងញ៉ាំងសតិ ឲ្យតាំងនៅបានឡើយ ក្នុងវេលាព្រះអរុណរះឡើង ។ ពេលនោះ ជនទាំងឡាយ ពោលថា "ឥឡូវនេះ បុរសនេះ នឹងស្លាប់" ហើយ ទើបបាននាំបុរសនោះចេញមក ឲ្យ

ដេកហើយ ក្នុងផ្ទះតូច ។ ក្នុងខណៈនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ធ្វើប្រទក្សិណព្រះនគរ ស្តេចយាងដល់ទីនោះ ។ បុរសទីទាល់ក្រ ឃើញព្រះរាជាហើយ ញ៉ាំងសេចក្តីលោភ ឱ្យកើតឡើង ប្រាថ្នាចង់បានរាជសម្បត្តិហើយ ក៏បានស្លាប់ទៅ ចាប់យកនូវបដិសន្ធិ ក្នុងព្រះឧទរ នៃព្រះអគ្គមហេសី របស់ព្រះរាជាអង្គនោះ ព្រោះផល នៃឧបោសថកម្មពាក់កណ្តាល ដោយកន្លងទៅបាន ១០ ខែ ទើបប្រសូតចេញមក ។ ព្រះមាតានិងព្រះបិតា ទ្រង់បានតាំងព្រះនាម ដល់ព្រះរាជកុមារនោះថា "ឧទ័យកុមារ" ដូច្នេះ ។ ព្រះឧទ័យកុមារនោះ ទ្រង់ចំរើនវ័យហើយ ដល់នូវការសម្រេចក្នុងសិល្បសាស្ត្រគ្រប់បែបយ៉ាង ទ្រង់រលឹកដល់បុព្វកម្ម របស់ព្រះអង្គបាន ដោយព្រះញាណគឺការរឭកជាតិ ទើបទ្រង់បានបញ្ចេញព្រះឧទានឡើង ជារឿយៗថា "នេះ គឺជាផល នៃកម្មដែលមានប្រមាណតិចតួច របស់អាត្មាអញ" ។ ព្រះឧទ័យរាជកុមារ អង្គនោះ ដោយកាលកន្លងទៅ នៃព្រះបិតា ទ្រង់បានទទួលរាជសម្បត្តិ ប្រាកដព្រះនាមថា "ព្រះបាទឧទ័យ" ។

ឯព្រះសាស្តា កាលទ្រង់សំដែងធម៌ ដល់ឧបាសកទាំងឡាយ អ្នករក្សាឧបោសថ ទ្រង់បានត្រាស់ថា "ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយ កាលរក្សាឧបោសថ ឈ្មោះថា បានធ្វើកម្មប្រសើរ

ហើយ, បោរាណកបណ្ឌិតទាំងឡាយ អាស្រ័យនូវបោសថកម្មពាក់កណ្តាលមួយ បានហើយនូវយសដ៏ធំ" ដូច្នេះហើយ ទ្រង់បានញុំាងរឿងនេះ ឲ្យពិស្តារហើយ ត្រាស់នូវគង្គមាលជាតក ។

រឿងព្រះបាទឧទ័យ ចប់ ។

សូម្បីរឿងនៃអ្នកស៊ីឈ្នួល ដែលនៅអាស្រ័យសេដ្ឋី ឈ្មោះអនាថបិណ្ឌិក ចិញ្ចឹមជីវិតដោយការស៊ីឈ្នួល បានទៅកើតជាទេវតាលើដើមជ្រៃ ក្នុងដងព្រៃព្រឹក្សា ព្រោះផលនៃនូវបោសថកម្មពាក់កណ្តាល ក៏គួរសំដែងផងដែរ ។ រឿងនោះ បណ្ឌិតគប្បីត្រួតពិនិត្យមើល ក្នុងអដ្ឋកថា នៃគាថាថា "**អប្បមាទោ អមតំ បទំ**" ដូច្នេះជាដើម ក្នុងអប្បមាទវគ្គ នៃធម្មបទ ។

(រឿងព្រះរាជាព្រះនាមសាធិនៈ)

(១៣៦) ក្នុងអតីតកាល ព្រះពោធិសត្វ បានសោយព្រះជាតិជាព្រះរាជាទ្រង់ព្រះនាមថា សាធិនៈ ក្នុងទីក្រុងមិថិលា ទ្រង់ត្រាស់បញ្ជាឲ្យរាជបុរសកសាងសាលាទាន ៦ កន្លែង ទ្រង់ញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដោយការបរិច្ចាគព្រះរាជទ្រព្យ ៦ សែន ជារៀងរាល់ថ្ងៃ ទ្រង់រក្សាសីល ៥ ខ្លះ ទ្រង់រក្សាឧបោសថខ្លះ ។ សូម្បីពួកជនអ្នកនៅក្នុងដែន ក៏ស្ថិតនៅក្នុងព្រះឱវាទ របស់ព្រះអង្គ

ធ្វើបុណ្យមានទានជាដើម ស្លាប់ទៅហើយៗ ក៏បានទៅកើត ក្នុងទេវបុរីទាំងអស់ ទៅកាន់សុធម្មទេវសភា អង្គុយហើយ ក៏នាំគ្នាពណ៌នាគុណ មានសីលនិងអាចារៈជាដើម របស់ព្រះរាជានុ៎ះឯង ។ ចំណែកពួកទេវតាដែលសេសសល់ បានស្តាប់គុណកថានោះហើយ មានសេចក្តីប្រាថ្នាចង់ឃើញព្រះរាជា ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបចិត្តរបស់ពួកទេវតាទាំងនោះហើយ ទើបទ្រង់គ្រាស់បញ្ជានូវមាតលីទេវបុត្រថា “ចូរអ្នកទៅ នាំយកព្រះរាជាព្រះនាមសាធិនៈដោយវេជយន្តរថ មក” ។ មាតលីទេវបុត្រនោះ ក៏បានទៅកាន់ទីក្រុងមិថិលា នាំយកព្រះរាជាព្រះនាមសាធិនៈនោះ មកហើយ ។ ពួកទេវតា ព្រមទាំងព្រះឥន្ទ ឃើញព្រះបាទសាធិនៈនោះហើយ ក៏មានចិត្តត្រេកអរ បានធ្វើការទទួលហើយ ។ គ្រានោះ សក្កទេវរាជ បានបែងទេវនគរ នាងទេព្វអប្សរ ២ កោដិកន្លះ និង វេជយន្ត-ប្រាសាទ ត្រង់ពាក់កណ្តាល ថ្វាយដល់ព្រះបាទសាធិនៈអង្គនោះ ។ កាលបើព្រះបាទសាធិនៈអង្គនោះ កំពុងសោយទិព្វសម្បត្តិ, ៧០០ ឆ្នាំ បានកន្លងផុតទៅហើយ ដោយការរាប់ឆ្នាំនៃមនុស្ស ។ តមកបុណ្យដែលជាហេតុនៅ ក្នុងទេវលោក ដោយអត្តភាពនោះ របស់ព្រះបាទសាធិនៈអង្គនោះ បានអស់ហើយ, សេចក្តីមិនត្រេកអរ បានកើតឡើងហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះ

ហើយ ទ្រង់បានបញ្ជានូវមាលីទេវបុត្រ ថា "អ្នកចូរទៅ ចូរនាំព្រះបាទសាធិនៈទៅកាន់ទីក្រុងមិថិលាហើយ ឱ្យចុះត្រង់ព្រះឧទ្យាន" ។ មាលីទេវបុត្រនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ បុរសអ្នករក្សាព្រះឧទ្យាន ឃើញព្រះបាទសាធិនៈអង្គនោះហើយ បានក្រាបទូលសួរហើយ ក៏បានក្រាបទូល ដល់ព្រះរាជាព្រះនាមនារទៈ ។ បានឮថា ព្រះរាជាព្រះនាមនារទៈ ត្រូវជាព្រះបនត្តា (ចៅ) ទី ៧ របស់ព្រះបាទសាធិនៈអង្គនោះ ។ បានឮថា កាលនោះ ជាកាលនៃសត្វដែលមានអាយុ ៧០០ ឆ្នាំ ។ ក៏ព្រះពោធិសត្វ ញុំាងកាលមានប្រមាណប៉ុណ្ណោះ ឱ្យកន្លងផុតទៅហើយ ដោយផលបុណ្យរបស់ព្រះអង្គ ។ ចំណែកព្រះបាទនារទៈ ស្តេចយាងមក ថ្វាយបង្គំព្រះអង្គហើយ ទ្រង់បានបបួល ដោយរាជសម្បត្តិ ។ ព្រះបាទសាធិនៈអង្គនោះ ទ្រង់ត្រាស់ថា "បពិត្រព្រះអង្គ ទូលបង្គំ មិនត្រូវការ ដោយរាជសម្បត្តិទេ, ក៏ទូលបង្គំមក ក្នុងទីនេះ ដើម្បីប្រយោជន៍ដល់រាជសម្បត្តិក៏ទេដែរ, (តែ) ទូលបង្គំ មកហើយ ដើម្បីប្រយោជន៍ដល់ការធ្វើបុណ្យ, ហេតុនោះ ទូលបង្គំជាអ្នកប្រាថ្នាដើម្បីនឹងឱ្យទាន ដែលបានបញ្ឈប់ចោល អស់ពេល ៧០០ ឆ្នាំ ដោយ ៧ ថ្ងៃ តែប៉ុណ្ណោះ"។ ព្រះបាទនារទៈ ទ្រង់ត្រាស់ ថា "ប្រពៃណាស់" ហើយ ទ្រង់បានចាត់ចែងនូវមហាទាន ។ ព្រះពោធិសត្វ ទ្រង់បានឱ្យទាន

រហូតដល់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ទិវង្គតហើយ ទ្រង់បានទៅកើត ក្នុងភពតាវត្តឹង្សនុ៎ះឯង ។

ឯព្រះសាស្តា កាលនឹងទ្រង់សំដែងធម៌ ដល់ឧបាសកទាំងឡាយ អ្នករក្សាឧបោសថ ទើបទ្រង់ត្រាស់ថា "ម្នាលឧបាសកទាំងឡាយ ឈ្មោះថា ឧបោសថកម្ម ជាធម្មជាត គួរបុគ្គលគប្បីរក្សា, បូរាណកបណ្ឌិតទាំងឡាយ អាស្រ័យឧបោសថកម្ម របស់ខ្លួនហើយ ទៅកាន់ទេវលោក ដោយទាំងសរីរៈជាមនុស្សតែម្តង នៅហើយអស់កាលដ៏យូរ" ដូច្នេះហើយ ទ្រង់សំដែងសាធិនជាតក ទី ១១ ក្នុងបកិណ្ណកវគ្គ ទ្រង់ប្រកាសហើយ នូវសច្ចៈទាំងឡាយ ។

ក្នុងទីបញ្ចប់នៃសច្ចៈ បណ្តាឧបាសកទាំងឡាយ ឧបាសកពួកខ្លះ បានជាព្រះសោតាបន្ន, ពួកខ្លះ បានជាព្រះសកទាគាមី ។

រឿងព្រះបាទសាធិនៈ ចប់ ។

(អ្នករក្សាឧបោសថដើម្បីសង្កត់កិលេស)

(១៣៧) ក្នុងអតីតកាល ក្នុងហិមវន្តប្រទេស តាបស ១ រូប អាស្រ័យជាតិ ទើបជាអ្នកធ្លាក់ ក្នុងអំណាចនៃមានៈ មិនអាចដើម្បីនឹងញុំាងឈាន ឲ្យកើតឡើងបានឡើយ ។ ថ្ងៃមួយ តាបសនោះ គិតថា "មានៈ របស់អាត្មាអញនេះ កាលចំរើនឡើង ក៏នឹង

នាំទៅកាន់នរក, ឥឡូវនេះ អញ សង្កត់សង្កិនកិលេសនេះមិនបានហើយ នឹងមិនទៅ ដើម្បីប្រយោជន៍ដល់ផលានុផល" ដូច្នេះហើយ ក៏អង្គុយ សមាទាននូវឧបោសថ ដើម្បីគ្របសង្កត់ញាំញីនូវមានៈ ។ ចំណែកសត្វព្រាបមួយ ត្រូវសេចក្តីក្តៅក្រហាយព្រោះរាគៈ ដុតរោលរាល ទើបគិតថា "ឥឡូវនេះ អញ សង្កត់សង្កិនរាគៈនេះមិនបានហើយ នឹងមិនហើរទៅ ដើម្បីរកចំណី" ដូច្នេះហើយ ទើបហើរទៅកាន់សំណាក់ នៃតាបស បានសមាទានឧបោសថ ដើម្បីសង្កត់សង្កិនរាគៈ ជេកហើយ ក្នុងទីដ៏សមគួរមួយ ។ ចំណែកពស់មួយ ក៏សមាទានឧបោសថ ដើម្បីសង្កត់សង្កិនសេចក្តីក្រោធ, ឯឆ្កែចចកមួយ ក៏សមាទានឧបោសថ ដើម្បីសង្កត់សង្កិនសេចក្តីលោភ, ចំណែកខ្លាឃ្មុំ ក៏សមាទានឧបោសថ ដើម្បីសង្កត់សង្កិនការប្រាថ្នាច្រើន (ម្ហាក់ៗ) បានជេក ក្នុងទីដ៏សមគួរមួយ យ៉ាងដូច្នោះឯង ។ បណ្ឌិតគប្បីឃើញថា "ឧបោសថកម្ម រមែងប្រព្រឹត្តទៅ ដើម្បីសង្កត់សង្កិននូវបាបបាន ដោយប្រការដូច្នេះ" ។

ចំណែកព្រះសាស្តា កាលទ្រង់សំដែងធម៌ ដល់ពួកឧបាសកដែលរក្សាឧបោសថ ទើបទ្រង់ត្រាស់ថា "ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយ បានធ្វើកម្មប្រសើរហើយ, ធម្មតាឧបោសថនុ៎ះជាប្រពៃណី របស់បោរាណកបណ្ឌិតទាំងឡាយ, ព្រោះថា

បោរាណកបណ្ឌិតទាំងឡាយ រក្សាឧបោសថ ដើម្បីសង្កត់សង្កិននូវកិលេសមានរាគៈជាដើម ” ហើយ ត្រាស់បញ្ចុបោសថជាតក ទី ៧ ក្នុងបកិណ្ណកវគ្គ ។

រឿង ជន ៥ នាក់ ចប់ ។

ពណ៌នាអំពីឧបោសថ ចប់ ។

(១៣៨) ចំណែកកិរិយាធ្វើកិច្ចខ្វល់ខ្វាយ តែងបានដោយអំណាចការធ្វើវត្តនិងវត្តកបជាដើម ដល់បុគ្គលដែលចាស់ជាង ។ ដោយហេតុនោះ ក្នុងអដ្ឋកថាពួក ៣ ក្នុងសង្គីតិសូត្រ ទើបលោកពោលថា “ បណ្ឌិតគប្បីជ្រាបកម្មដែលប្រកបព្រម ដោយការខ្វល់ខ្វាយ ដោយអំណាចនៃការធ្វើវត្តនិងវត្តកប ដល់បុគ្គលដែលមានវ័យចាស់ជាង ១ ដោយអំណាចនៃការឃើញ នូវភិក្ខុដែលចូលទៅកាន់ផ្ទះ ដើម្បីបិណ្ឌបាត ទទួលបាត្រហើយ បបួលពួកអ្នកស្រុកហើយបង្ហោន នូវអាហារចូលទៅ ១ ដោយអំណាចនៃការស្តាប់ថា “ អ្នកចូរទៅ, ចូរនាំបាត្ររបស់ភិក្ខុទាំងឡាយមក ” ដូច្នេះហើយក៏ប្រញាប់ប្រញាល់ ទៅទទួលយកបាត្រមកជាដើម ១ ” ។

ដីកានៃសង្គីតិសូត្រនោះថា “ បុគ្គល រមែងជាអ្នកខ្វល់ខ្វាយក្នុងវត្តនិងវត្តកប ដល់បុគ្គលអ្នកចំរើនហើយ ដោយវ័យនិងគុណទាំងឡាយ ដោយចេតនាឯណា, ចេតនានោះ ឈ្មោះថា វេយ្យាវច្ចៈ

(ចេតនាជាហេតុខ្លាំងខ្លាយ), វេយ្យាវច្ចៈនុ៎ះឯង ឈ្មោះថា ការប្រកបព្រមដោយចេតនាជាហេតុខ្លាំងខ្លាយ ។ ម្យ៉ាងវិញទៀត កម្មដែលទៅហើយ គឺដែលប្រព្រឹត្តទៅហើយ ព្រមដោយអំណាចនៃការញុំាងវត្ថុប្រតិបត្តិ ពោលគឺចេតនាជាហេតុខ្លាំងខ្លាយ ឱ្យកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា វេយ្យាវច្ចសហគតៈ (កម្មដែលប្រព្រឹត្តទៅហើយ ព្រមដោយចេតនាជាហេតុខ្លាំងខ្លាយ) ។ វេយ្យាវច្ចៈ ដែលបុគ្គលឱ្យប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ ជាវត្ថុជាទីតាំងនៃកិរិយាចំពេញបុណ្យ" ។

(១៣៩) វេយ្យាវច្ចៈនោះឯង ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការបាន នូវពាហានៈដ៏ប្រសើរ ក្នុងមង្គលត្ថទីបនីនេះ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍)

(រឿងព្រះរាជាព្រះនាមចណ្ឌបជ្ជោត)

ក្នុងអតីតកាល ឥស្សរជនម្នាក់ ងូតទឹកខាងក្រៅនគរ កាលត្រឡប់មកវិញ ក៏បានឃើញព្រះបច្ចេកពុទ្ធ ១ អង្គ ក្នុងចន្លោះផ្លូវ ។ បានឮថា ព្រះបច្ចេកពុទ្ធអង្គនោះ និមន្តទៅបិណ្ឌបាត ក្នុងទីក្រុងមិនបានហើយនូវភិក្ខា ព្រោះអ្នកក្រុងទាំងអស់ ត្រូវមារចង្អៀងចិត្តហើយ ទើបនិមន្តចេញមកហើយ ដោយបាត្រដែលខ្លួនលាង

ហើយយ៉ាងណា (ដោយបាត្រទទេ) ។ ឥស្សរជន ឃើញនូវ
ព្រះបច្ចេកពុទ្ធអង្គនោះហើយ ថ្វាយបង្គំ ទូលសួរថា "បពិត្រព្រះ
អង្គដ៏ចំរើន តើព្រះអង្គបានវត្ថុអ្វីៗ ខ្លះដែរឬទេ ?" ។

ព្រះបច្ចេកពុទ្ធ ទ្រង់ត្រាស់ថា "ម្នាលអ្នកដ៏មានអាយុ
អាត្មាបានចូលទៅ ត្រឡប់មកវិញហើយ" ។

ឥស្សរជននោះ គិតថា "ព្រះគុណាម្ចាស់ដ៏ចំរើន មិនឆ្លើយ
តបនូវពាក្យដែលអាត្មាអញសួរទេ ទៅពោលពាក្យដទៃវិញ, វត្ថុ
អ្វីៗ ព្រះគុណាម្ចាស់ដ៏ចំរើន នឹងមិនបានហើយ" ដូច្នេះហើយ ទើប
ក្រឡេកមើលបាត្រ ឃើញបាត្រទទេហើយ ជាអ្នកក្លៀវក្លា (តែ)
មិនអាច ដើម្បីនឹងទទួលយកបាត្រ ព្រោះមិនដឹងថា ភ័ត្តក្នុងផ្ទះបាន
សម្រេចហើយ ឬក៏មិនបានសម្រេច ទើបក្រាបទូលថា "បពិត្រ
ព្រះគុណាម្ចាស់ដ៏ចំរើន សូមព្រះគុណាម្ចាស់ និមន្តចាំ បន្តិចសិនចុះ"
ហើយ ក៏ប្រញាប់ប្រញាល់ទៅផ្ទះ ដឹងថាភ័ត្តសម្រេចហើយ ទើប
បានបញ្ជូនអ្នកបម្រើម្នាក់ទៅ ដោយប្រាប់ថា "នែអ្នក អ្នកចូរទៅ,
ចូរទៅទទួលយកបាត្រ របស់ព្រះគុណាម្ចាស់មក យ៉ាងប្រញាប់" ។
អ្នកបម្រើនោះ ក៏ស្ទុះទៅទទួលយកបាត្រមកហើយ ។ ចំណែក
ឥស្សរជន ដាក់ភ័ត្តពេញបាត្រហើយ បានពោលថា "អ្នកចូរញុំាង
ភ័ត្តនេះ ឲ្យដល់ព្រម ដល់ព្រះគុណាម្ចាស់ដ៏ចំរើន យ៉ាងប្រញាប់,

ខ្ញុំនឹងឱ្យនូវចំណែកបុណ្យ អំពីភត្តនេះ ដល់អ្នក" ។ អ្នកបម្រើ
នោះ ទៅហើយ យ៉ាងលឿន ប្រគេននូវបាត្រ ដល់ព្រះបច្ចេកពុទ្ធ
ហើយ ថ្វាយបង្គំ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះ
ករុណា ទៅនិងមកហើយ ដោយសន្ទុះជើង យ៉ាងលឿន ដោយ
គិតថា 'ពេលវេលា ជិតចូលមកដល់ហើយ' ដូច្នេះ, ដោយផលនៃ
សន្ទុះជើង របស់ខ្ញុំព្រះករុណានុ៎ះ សូមពាហនៈទាំងឡាយ ដែល
អាចស្ទុះទៅបាន ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍
១២០ យោជន៍ ចូរកើតមានឡើង, កាលខ្ញុំព្រះករុណា កំពុងមក
និងកំពុងទៅ, សរីរៈរាងកាយ ក្តៅហើយ ព្រោះកំដៅនៃព្រះ
អាទិត្យ, ដោយផលនៃសរីរៈ ដែលក្តៅហើយ ព្រោះកំដៅនៃព្រះ
អាទិត្យនោះ សូមឱ្យអាជ្ញា របស់ខ្ញុំព្រះករុណា ចូរប្រាកដស្មើដោយ
កំដៅនៃព្រះអាទិត្យ ក្នុងទីដែលខ្ញុំព្រះករុណាកើតឡើងហើយ ។,
ចំណែកបុណ្យ គឺម្ចាស់ (របស់ខ្ញុំ) បានឱ្យហើយ ដល់ខ្ញុំព្រះករុណា
ក្នុងបិណ្ឌបាតនេះ, ដោយផលនៃចំណែកបុណ្យនោះ ខ្ញុំព្រះករុណា
គប្បីជាអ្នកមានចំណែក នៃធម៌ ដែលព្រះអង្គបានឃើញហើយ" ។
ព្រះបច្ចេកពុទ្ធ ត្រាស់ថា "សូមសេចក្តីប្រាថ្នាដែលអ្នកប្រាថ្នាហើយ
ចូរបានសម្រេច យ៉ាងនោះចុះ" ដូច្នេះ ទើបបានអនុមោទនា ដោយ
គាថានៃព្រះបច្ចេកពុទ្ធទាំងឡាយហើយ ក៏និមន្តគេចចេញទៅ ។

អ្នកបម្រើនោះ កាលអន្ទោលទៅ ក្នុងពុទ្ធុប្បាទនេះ បានជាព្រះរាជា ទ្រង់ព្រះនាមថា ចណ្ឌបជ្ជោត ក្នុងនគរឈ្មោះឧជ្ជេនី ។ ពាហនៈទាំងឡាយ ៥ យ៉ាង កើតឡើងហើយ ដល់ព្រះអង្គ ព្រោះផលនៃកម្មនោះឯង គឺ ដំរីញីមួយ ឈ្មោះកទ្ទវតី រមែងដើរទៅបាន ៥០ យោជន៍ ក្នុងមួយថ្ងៃ, អ្នកបម្រើម្នាក់ ឈ្មោះកាកៈ រមែងធ្វើដំណើរទៅបាន ៦០ យោជន៍, សេះទាំងឡាយ ២ គឺ សេះឈ្មោះវេលកំសិ ១ សេះឈ្មោះ មុញ្ជកេសិ ១ ដើរទៅបាន ១០០ យោជន៍, ដំរីឈ្មោះ នាឡាគិរី ដើរទៅបាន ១២០ យោជន៍ ។

រឿងព្រះរាជា ទ្រង់ព្រះនាមចណ្ឌបជ្ជោត មកក្នុងអដ្ឋកថា នៃគាថាថា **"អប្បមាទោ អមតំ បទំ"** ដូច្នេះជាដើម ។

(១៤០) សូម្បីការបង្ហាញផ្លូវ ដល់ពួកយាចក អ្នកសុំទាន ក៏ឈ្មោះថា វេយ្យាវច្ចៈ ។ សូម្បីវេយ្យាវច្ចៈនោះ ក៏ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការបាននូវបាទដៃដ៏ពិសេសជាដើម ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាខុទាហរណ៍) ។

(រឿងជាងជុល)

ក្នុងអតីតកាល ក្នុងនគរឈ្មោះអសិតញ្ជៈ ក្នុងខុត្តរាបថ-ជនបទ ព្រះរាជាទ្រង់ព្រះនាមមហាកំសៈ ទ្រង់មានព្រះរាជធីតា

ព្រះនាមថា ទេវគព្ភា ។ ព្រះរាជធីតាអង្គនោះ ទ្រង់អាស្រ័យព្រះរាជកុមារ ព្រះនាមឧបសាគរៈ ដែលជាព្រះរាជបុត្រ របស់ព្រះរាជាទ្រង់ព្រះនាមមហាសាគរៈ ដែលទ្រង់ជាអធិបតី ក្នុងឧត្តរាជនបទ ទ្រង់បានហើយ នូវព្រះរាជបុត្រទាំងឡាយ ១១ ព្រះអង្គ គឺ ព្រះរាជធីតា ទ្រង់ព្រះនាមថា អញ្ញនទេវី ១ ព្រះរាជបុត្រ ទ្រង់ព្រះនាមថា វាសុទេព ១ ពលទេព ១ ចន្ទទេព ១ សុរិយទេព ១ អគ្គិទេព ១ វរុណទេព ១ អជ្ជុន ១ បជ្ជុន ១ ឃតបណ្ឌិត ១ អង្កុរៈ ១ ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះភាតាទាំង ១០ ព្រះអង្គ មានព្រះវាសុទេពជាដើម បានធ្វើគត់ព្រះរាជាទាំងអស់ ក្នុងព្រះនគរ ៦ ម៉ឺន ៣ ពាន់ ក្នុងជម្ពូទ្វីបទាំងមូល មាននគរឈ្មោះ អសិតញ្ជនៈជាដើម មាននគរទ្វារាវតីជាទីបំផុតហើយ ទ្រង់គង់នៅ ក្នុងនគរទ្វារាវតី ទ្រង់បានចែកទ្រព្យសម្បត្តិជា ១០ ចំណែក មិនទ្រង់នឹករលឹកដល់ព្រះជេដ្ឋភគិនីសោះឡើយ ។ កាលព្រះរាជាទាំងនោះ ទ្រង់បាននឹករលឹកម្តងទៀត ទើបទ្រង់ត្រាស់ ថា “ ពួកយើង នឹងចែកឱ្យទៅជា ១១ ចំណែក ” ដូច្នេះ, ព្រះរាជបុត្រព្រះនាមអង្កុរៈ ដែលជាព្រះកនិដ្ឋា នៃព្រះរាជាគ្រប់ព្រះអង្គ ទ្រង់ត្រាស់ ថា “ សូមព្រះម្ចាស់ឆង ទាំងឡាយ ព្រះរាជាទាន នូវចំណែក របស់ទូលព្រះបង្គំ ដល់ព្រះជេដ្ឋភគិនីនោះចុះ, ទូលព្រះបង្គំ នឹងធ្វើការ

លក់ដូរហើយ ចិញ្ចឹមជីវិត, សូមព្រះម្ចាស់ចងទាំងឡាយ ទ្រង់លះបង់នូវពន្ធជារ ក្នុងជនបទ របស់ខ្ញុំន ដល់ទូលព្រះបង្គំតែម្យ៉ាង" ។ ព្រះរាជាទាំងនោះ ទ្រង់ត្រាស់ថា "ប្រពៃហើយ" ទ្រង់បានព្រះរាជទាន នូវចំណែក របស់ព្រះអង្កុរៈនោះ ដល់ព្រះភគិនីហើយ ទ្រង់គង់នៅ ក្នុងនគរទ្វារវតី មួយអន្លើដោយព្រះភគិនីនោះ ។

សេចក្តីសង្ខេប ក្នុងរឿងនេះ មានតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ បណ្ឌិតគប្បីត្រួតមើល ក្នុងឃតបណ្ឌិតជាតក ក្នុងទសកនិបាត ។

(១៤១) ក៏ព្រះរាជាព្រះនាមអង្កុរៈ កាលទ្រង់ធ្វើការលក់ដូរ ទ្រង់បានថ្វាយហើយ នូវមហាទាន ជានិច្ច ។ ក៏អ្នកបម្រើរបស់ព្រះអង្គម្នាក់ ជាអ្នករក្សាព្រះឃ្លាំង ជាអ្នកប្រាថ្នាប្រយោជន៍ ។ ព្រះបាទអង្កុរៈ ទ្រង់បាននាំកុលធីតា មួយរូបមក ព្រះរាជទាន ដល់អ្នករក្សាព្រះឃ្លាំងនោះ ។ អ្នករក្សាព្រះឃ្លាំងនោះ, កាលបើកូននៅក្នុងផ្ទៃនុ៎ះឯង, ក៏បានធ្វើមរណកាលហើយ ។ ក៏កាលបើកូនរបស់អ្នករក្សាឃ្លាំងនោះ ធំពេញវ័យហើយ, ការវិនិច្ឆ័យ បានកើតឡើងហើយ ក្នុងរាជត្រកូលថា "ក្មេងនេះ ជាបាវព្រាវ ឬក៏មិនមែនជាបាវព្រាវ" ។ ព្រះនាងអញ្ជនទេវី ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់បានធ្វើឧបមា ដោយមេគោកូនខ្ចី ទ្រង់ត្រាស់ថា

"សូម្បីកូន របស់មាតាដែលជាបាវព្រាវ ក៏ជាបាវព្រាវដដែល" ហើយ ទ្រង់បានដោះលែង អំពីភាពជាបាវព្រាវ ។ តែក្មេងនោះ មិនអាចដើម្បីនឹងរស់នៅ ក្នុងទីនោះបាន ព្រោះសេចក្តីអៀនខ្មាស ទើបទៅកាន់នគរឈ្មោះរោរុវៈ ហើយទទួលយកកូនស្រី របស់ជាងជុល ក្នុងទីនោះ សម្រេចការនៅ ក្នុងទីជិតនៃផ្ទះ របស់មហាសេដ្ឋី ឈ្មោះអសយ្ហៈ បានចិញ្ចឹមជីវិត ដោយការងារ របស់នាយជាងជុល ។ ក្នុងពេលនោះ អសយ្ហមហាសេដ្ឋី បានញ៉ាំងមហាទាន ឲ្យប្រព្រឹត្តទៅហើយ ដល់មហាជន ។ ប្រសិនបើពួកយាចកឯណា មិនស្គាល់ផ្លូវទៅកាន់ផ្ទះ របស់អសយ្ហមហាសេដ្ឋី, ពួកយាចកទាំងនោះ តែងសួរនូវនាយជាងជុលនោះ ។ សូម្បីជាងជុលនោះ ក៏គិតថា "អាត្មាអញ ព្រោះជាអ្នកមិនបានធ្វើបុណ្យទុកមកហើយ ក្នុងកាលមុន ឥឡូវនេះ ទើបជាអ្នកមិនអាច ដើម្បីនឹងឲ្យវត្ថុអ្វីៗ ដល់ពួកជនអ្នកប្រាកដដូច្នេះបាន, ប៉ុន្តែ ក្នុងពេលនេះ អាត្មាអញ កាលសំដែងនូវរោងទាន ដល់ជនទាំងនេះ ញ៉ាំងចីតិឲ្យកើតឡើង ដោយការប្រាប់ឧបាយនៃលាភ នឹងប្រសព្វ នូវបុណ្យដ៏ច្រើន សូម្បីដោយហេតុមានប្រមាណប៉ុណ្ណោះ" ហើយ ញ៉ាំងសេចក្តីក្រោតក្រែង និងសេចក្តីគោរព ឲ្យកើតឡើងហើយ បានលាតដៃស្តាំចេញ សំដែងប្រាប់ថា "សូមពួកអ្នកទាំងនោះ ទៅក្នុង

ទីនោះហើយ ចូរបាននូវវត្ថុដែលខ្លួនគប្បីបានចុះ" ។ ក្នុងកាលក្រោយមក ជាងជុលនោះ ធ្វើមរណកាលហើយ ក៏បានទៅកើតជាភុម្មទេវតា លើដើមជ្រៃមួយដើម មានម្លប់យ៉ាងត្រឈឹងត្រឈៃ មានឫសច្រើនពាន់ មានប្រមាណ ៤ យោជន៍ ដោយបណ្តោយទទឹងនិងកំពស់ ក្នុងទន្លេខ្សាច់ដែលជាច់ស្រយាល ។ ដៃស្តាំរបស់ទេវតានោះ ជាដៃដែលឱ្យនូវវត្ថុជាទីប្រាថ្នា ។

ក្នុងកាលជាខាងក្រោយមក ព្រះរាជាព្រះនាមអង្គុរៈ ទ្រង់យកទេះទាំង ៥០០ មកដឹកនូវភ័ណ្ឌៈ ទៅដើម្បីលក់ដូរ ទៅដល់ទីជាច់ស្រយាលនោះហើយ ក៏ទ្រង់វង្វែងផ្លូវ ស្តេចយាងទៅ ក្នុងទីនោះឯង អស់ច្រើនថ្ងៃ ទ្រង់មានស្មៅ ទឹក និងអាហារអស់រលីងធេងហើយ ។ ពេលនោះ រុក្ខទេវតា បាននឹករលឹកដល់ខុបការៈដែលព្រះបាទអង្គុរៈ ទ្រង់បានធ្វើហើយ ដល់ខ្លួន ក្នុងកាលមុន ទើបបានសំដែងនូវដើមជ្រៃ របស់ខ្លួន ដល់ព្រះបាទអង្គុរៈអង្គនោះ ។ ព្រះរាជាព្រះនាមអង្គុរៈ ទ្រង់ទតព្រះនេត្រឃើញ នូវដើមជ្រៃនោះហើយ ទ្រង់មានព្រះទ័យត្រេកអរវីកវាយ ទ្រង់បានសម្រេចកិរិយាគង់នៅក្រោមដើមជ្រៃ ។ ទេវតា លាតដៃស្តាំចេញហើយ ជាបឋម ញាំងជនគ្រប់ៗគ្នា ឱ្យឆ្អែតស្កប់ស្កល់ ដោយទឹកផឹក ។ តអំពីនោះមក ជនឯណាៗ ប្រាថ្នានូវវត្ថុណាៗ នីមួយ, ទេវតា

នោះ បានឱ្យហើយនូវវត្ថុនោះៗ ដល់ជននោះៗ ។ ព្រះបាទអង្គុរៈ ទ្រង់ទតព្រះនេត្រឃើញទេវតានោះហើយ កាលទ្រង់ត្រាស់សួរ ទើបទ្រង់ត្រាស់គាថា (នេះ) ក្នុងរឿងនៃអង្គុរៈប្រែក ថា ÷

(១៤២) "ដៃទាំងអស់របស់អ្នក មានសម្បុរដូចជាមាស ទ្រទ្រង់នូវវត្ថុជាទីប្រាថ្នាដោយអង្គុលីទាំង ៥ បញ្ចេញនូវរសផ្អែម, ផលបុណ្យ សម្រេច ក្នុងដៃរបស់អ្នក ដោយការប្រព្រឹត្តិនូវធម៌ ដ៏ប្រសើរដូចម្តេច ?" ។ (១)

បណ្តាបទទាំងនោះ ២ បទ ថា "បាណិ តេ" បានដល់ ដៃស្តាំ (របស់អ្នក) ។ បទថា "សព្វសោវណ្ណោ" គឺ សម្រេចហើយ អំពីមាស ដោយប្រការទាំងពួង ។ បទថា "បញ្ចធារោ" គឺ ឈ្មោះថា ទ្រទ្រង់នូវវត្ថុជាទីប្រាថ្នា ដោយអង្គុលីទាំង ៥ ព្រោះអត្ថវិគ្រោះថា 'ពំនូក នៃវត្ថុដែលពួកជនដទៃប្រាថ្នា ដោយអង្គុលីទាំង ៥ របស់ទេវតានុ៎ះមាន' ។ បទថា "មធុស្សវោ" បានដល់ជាដែនហូរចេញនៃរសដ៏ផ្អែម ។ ព្រោះថា រសទាំងឡាយ ផ្សេងៗ មានរសផ្អែម រសហឺរ និង រសជូរជាដើមជាប្រភេទ រមែងហូរចេញ គឺស្រក់ចេញ អំពីសំណុំ នៃអង្គុលីទាំង ៥ នោះ ។ ២ បទថា

---

១ ត្រៃបិដក ភាគទី ៥៦ / ទំព័រទី ៤៦_៤៧

"កេន តេ" មានសេចក្តីថា ផលបុណ្យ ក្នុងដៃរបស់អ្នកនេះ គឺ ប្រាកដដូច្នេះ រមែងសម្រេច គឺ រមែងផ្តល់ផល ក្នុងពេលឥឡូវនេះ ព្រោះកិរិយាប្រព្រឹត្តិ នូវធម៌ដ៏ប្រសើរ ដូចម្តេច ?, សូមអ្នកប្រាប់ នូវហេតុនោះ ។ ក៏ផលបុណ្យ ព្រះបាទអង្គុរៈ ទ្រង់ព្រះចំណង យកហើយថា "បុណ្យ" ក្នុងគាថានេះ ព្រោះលប់បទខាងចុង ។

គ្រានោះ ទេវតាបានក្រាបទូល នូវសេចក្តីនេះ ដល់ព្រះបាទ អង្គុរៈនោះថា "ក្នុងជាតិមុន ទូលព្រះបង្គំ កើតជាជាងជុល ក្នុង នគរឈ្មោះរោរុវៈ អាស្រ័យការរស់នៅ ក្នុងទីជិតផ្ទះនៃមហាសេដ្ឋី ឈ្មោះថា អសយ្ហៈ, មួយទៀត វត្ថុដែលគួរឱ្យ បន្តិចបន្តួច របស់ ទូលព្រះបង្គំ ក៏គ្មាន, ពួកយាចក មិនដឹងផ្លូវទៅកាន់រោងទាន របស់អសយ្ហសេដ្ឋី ទើបសួរទូលព្រះបង្គំ, ទូលព្រះបង្គំ បានប្រាប់ ផ្លូវដល់ពួកយាចកទាំងនោះ" ដូច្នេះហើយ កាលសំដែងថា "ផល នេះ រមែងសម្រេច ព្រោះកម្មនោះ" ដូច្នេះ ទើបពោលគាថាថា

(១៤៣) "ដៃរបស់ទូលព្រះបង្គំ អាចឱ្យសម្រេច សេចក្តីប្រាថ្នា ដោយហេតុនោះ, ដៃរបស់ទូលព្រះ បង្គំ ជាដៃនហូរចេញ នៃរសដ៏ផ្អែមបាន ដោយ ហេតុនោះ, ផលបុណ្យ ក៏រមែងសម្រេច ក្នុងដៃ

របស់ទូលព្រះបង្គំ ព្រោះការប្រព្រឹត្តិដ៏ប្រសើរនោះ"។

បណ្តាបទទាំងនោះ បាទគាថាថា "**តេន បាណិ កាមទទោ**" មានសេចក្តីថា ដៃរបស់ទូលព្រះបង្គំ ក្នុងពេលឥឡូវនេះ ហូរចេញ នូវរបស់ដែលប្រាថ្នា គឺ ឱនូវរបស់ដែលគេត្រូវការហើយៗ ដូចជាដើមកប្បព្រឹក ព្រោះហេតុនោះ គឺ ព្រោះហេតុត្រឹមតែកិរិយាអនុមោទនា នូវទានដែលបុគ្គលដទៃធ្វើហើយ ក្នុងកាលនោះ ដោយគោរព ។ ដៃរបស់ទូលព្រះបង្គំ ជាដៃដែលអាចឱ្យសម្រេចសេចក្តីប្រាថ្នា និង ជាដែនហូរចេញ នៃរសដ៏ផ្អែម គឺជាដែនហូរចេញនៃវត្ថុដែលជាទីប្រាថ្នា ។

(១៤៤) ក្នុងអដ្ឋកថាអង្គុរប្រែតវត្ថុ ព្រះអដ្ឋកថាចារ្យបានសំដែងខេត្ត នៃ **ត** សព្ទ យ៉ាងដូច្នេះ ក្នុងគាថានេះហើយ ពោលទុក ក្នុងគាថាខាងមុខ ម្តងទៀតថា " ដៃនេះ អាចឱ្យសម្រេចសេចក្តីប្រាថ្នា ដោយហេតុត្រឹមតែកិរិយាប្រាប់ផ្លូវ ដែលទៅកាន់ផ្ទះរបស់ទានបតី ដែលមានការអនុមោទនា នូវបុណ្យដែលបុគ្គលដទៃបានធ្វើហើយ ជាខាងដើម" ដូច្នេះ ។

ដីកានៃមហាសីហនាទសូត្រថា "បាទគាថាថា '**តេន មេ ព្រហ្មចរិយេន**" គឺ ដោយកិរិយាប្រព្រឹត្តិដ៏ប្រសើរ ពោលគឺ កម្ម

គឺភាពជាអ្នកខ្វល់ខ្វាយខាងផ្លូវកាយ ដូចបានពោលមកហើយ រមែងទូលព្រះបង្គំនោះ" ។

ក៏ភាពជាអ្នកខ្វល់ខ្វាយ ឈ្មោះថា កិរិយាប្រព្រឹត្តិដ៏ប្រសើរក្នុងគាថានេះ ។ ក៏សេចក្តីនេះ នឹងមានប្រាកដ ក្នុងមង្គលបទថា "តបោ ច ព្រហ្មចរិយញ្ច" នេះ ។

ព្រះរាជាព្រះនាមអង្គុរៈ ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទើបស្តេចយាងទៅតាមព្រះបំណង ។ សេចក្តីសង្ខេប ក្នុងរឿងនេះ តែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ អ្នកសិក្សាគប្បីត្រួតពិនិត្យមើល ក្នុងអង្គុរប្រែតវត្ថុ ។

រឿងជាងជុល ចប់ ។

ពណ៌នាអំពីវេយ្យាវច្ចៈ ចប់ ។

(១៤៥) សូម្បីកិច្ចមានការដាំសួនច្បារ ដាំដើមឈើ និងសង់ស្ពានជាដើម ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃកិរិយាកើតឡើង ក្នុងឋានសួគ៌ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាខុទាហរណ៍)

(រឿងនៃឧបាសក)

ក្នុងទីក្រុងសាវត្ថី ឧបាសកម្នាក់ ធ្វើនូវទីកន្លែង ដែលមិន

រាបស្មើ ឱ្យបានរាបស្មើ ក្នុងផ្លូវជាទីនិមន្តមកកាន់ផ្ទះ ដើម្បីបិណ្ឌបាត ដល់ភិក្ខុទាំងឡាយ អ្នកនៅក្នុងព្រៃជាវត្ត នាំបន្លាចេញ ជម្រះនូវ ឈើកូច ៗ និង គុម្ពឈើទាំងឡាយ, ក្នុងពេលទឹកជន់ សង់ស្ពាន ក្នុង ប្រឡាយទាំងឡាយ, ក្នុងទីដែលមិនមានដើមឈើ ក៏ដាំដើមឈើ ដែលមានម្លប់ទាំងឡាយ, ជីកដី ក្នុងទីសំរាប់ឃាំងទឹកឡើង ធ្វើ ឱ្យធំទូលាយនិងជ្រៅ, ធ្វើកំពង់ទាំងឡាយ ឱ្យដល់ព្រម, ថ្វាយទាន តាមសមគួរដល់ទ្រព្យសម្បត្តិ និងរក្សាសីល ។ ក្នុងកាលតមក ឧបាសកនោះ ធ្វើមរណកាលហើយ ក៏ទៅកើត ក្នុងវិមានមាស មាន ប្រវែង ១២ យោជន៍ ក្នុងភពតាវត្តឹង្ស ។ ព្រះមហាមោគ្គល្លានត្ថេរ បានចូលទៅរកទេវបុត្រនោះ ហើយសួរ ដោយគាថាទាំងឡាយ ថា

(១៤៦) “[1] វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍, មានផ្ទះកំពូល ៧០០ ដ៏ឱឡារិក មានសសរកែវពិទូរ្យ ដែល ក្រាលកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ, អ្នក រមែងបិតនៅ ផឹក និង ស៊ី ក្នុងវិមាននោះ, ពិណ ជាទិព្វ លាន់ឮ ដ៏ពីរោះ, កាមគុណ ៥ មានរស ជាទិព្វ ក៏មាន ក្នុងវិមាននេះផង, ពួកនារីដែល

---

១ ត្រៃបិដក ភាគទី ៥៥ / ទំព័រទី ១៥៨

ប្រសព្រំដោយគ្រឿងមាស ក៏រាំក្នុងវិមាននេះផង, សម្បុររបស់អ្នក ប្រាកដដូច្នោះ តើសម្រេច ដោយបុណ្យអ្វី ?, ផលនៃសុចរិតរមែងសម្រេចដល់អ្នកក្នុងវិមាននេះផង, ភោគៈទាំងឡាយណានីមួយជាទីគាប់ចិត្ត, ភោគៈទាំងឡាយនោះ រមែងកើតឡើង ដល់អ្នកផង តើដោយបុណ្យដូចម្តេច ?, នែទេវតា អ្នកមានអានុភាពច្រើន អាត្មាសួរអ្នក, តើអ្នកកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី ទើបអ្នកមានអានុភាពរុងរឿង យ៉ាងដូច្នេះ ? ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់ សព្វទិសទី តើដោយបុណ្យអ្វី ?" ។

អដ្ឋកថាកក្កដរសទាយកវិមាន ក្នុងបញ្ចមវគ្គថា "បណ្តាបទទាំងនោះ បទថា '**ឧច្ចំ**' គឺ ខ្ពស់ក្រឡួច ។ បទថា '**មណិថូណំ**' គឺ ដែលស្រោបហើយ ដោយកែវមណី មានកែវទទឹមជាដើម ។ បទថា '**សមន្តតោ**' គឺ សូម្បីក្នុងជ្រុងទាំងឡាយ ៤ ។ បទថា '**រុចិរត្តតា**' គឺ ក្រាលដោយផ្ទាំងមាស លើផ្ទៃកម្រាលនោះ ។ ។ ដោយ ២. បទថា '**បិវសិ ខាទសិ**' ព្រះមហាមោគ្គល្លានត្ថេរ ពោល

សំដៅយកទឹកដែលមានក្លិនក្រអូប និង ភោជនដ៏ប្រសើរ ដែលប្រើប្រាស់ រៀងរាល់ពេល ។ បទថា **'បវេទន្តិ'** គឺ រមែងលាន់ឮឡើង ។ បាទគាថាថា **'ទិព្វរសា កាមគុណេត្ថ បញ្ច'** មានសេចក្តីថា កាមគុណទាំង ៥ ដែលមានរសជាទិព្វ គឺមិនមែនតិចតួច ក៏មានព្រម ក្នុងវិមាននេះ គឺ ក្នុងវិមានរបស់អ្នកនេះ ។ បទថា **'សុវណ្ណឆន្នា'** គឺ ប្រដាប់តាក់តែង ដោយគ្រឿងអាភរណៈដែលសម្រេចហើយ ដោយមាស"។

(១៤៧) នំយក្នុងអដ្ឋកថាបិដ្ឋវិមាន ដែលជារឿងទីមួយ នៃរឿងទាំងពួងថា "បទថា **'កេន'** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃហេតុ ។ មានសេចក្តីថា 'ព្រោះហេតុអ្វី ?'។ មានពាក្យដែលលោកអធិប្បាយថា 'ព្រោះបុណ្យយ៉ាងពិសេស ដូចម្តេច ដែលជាហេតុ ?'។ បទថា **'តេ'** គឺ របស់អ្នក ។ បទថា **'ឯតាទិសោ'** បានដល់ ប្រាកដដូច្នោះ, អធិប្បាយថា 'តាមដែលប្រាកដមាន ក្នុងពេលឥឡូវនេះ'។ ពណ៌សម្បុរនៃស្បែក ឈ្មោះថា វណ្ណៈ ។ អធិប្បាយថា 'សម្បុរនៃសរីរៈ ដែលអាចភ្លឺផ្សាយទៅបាន ១២ យោជន៍'។ បាទគាថាថា **'កេន តេ ឥធ ឥជ្ឈតិ'** គឺ ផលនៃសុចរិត ដ៏ឱឡារិក ដែលអ្នកកំពុងបាន ក្នុងទីនេះ ក្នុងពេលនេះ រមែងសម្រេច គឺ រមែងសម្រេចផល ដល់អ្នក ដោយបុណ្យ

ដ៏ប្រសើរ ដូចម្តេច ? ។ បទថា **ឧប្បជ្ជន្តិ** ប្រែថា រមែងកើត ។ អធិប្បាយថា 'រមែងប្រព្រឹត្តទៅខ្ពស់ឡើង ។ ដោយអំណាចមិនដាច់រយៈ' ។ គ្រឿងឧបករណ៍នៃទ្រព្យគ្រឿងពេញចិត្តដ៏ពិសេសមានសំពត់ និង គ្រឿងអាភរណៈជាដើម ដែលបានឈ្មោះថា ភោគៈ ព្រោះអត្ថថា គឺបុគ្គលគប្បីប្រើប្រាស់ ឈ្មោះថា ភោគៈ ។ សព្ទថា **'ឃេ'** ជាសព្ទសំដែងសេចក្តីមិននិយម ដោយភាពជាទ្រព្យទូទៅ ។ សព្ទថា **'កេចិ'** ជាសព្ទសំដែងសេចក្តីមិននិយម សំដៅយកការប្លែកផ្សេងគ្នានៃប្រការៈ ។ លោកសង្គ្រោះរួបរួម នូវភោគទាំងឡាយ ប្រាកដដូច្នោះ ផ្សេងដោយភោគៈ ដែលប្រណីតជាងគ្នាជាដើម ដែលទេវតាបាន ក្នុងវិមាននោះ ដោយមិនសេសសល់ ដោយបទទាំង ២ យ៉ាង ។ ក៏និទ្ទេសនេះ ជានិទ្ទេសដែលរួបរួមសេចក្តី ដោយមិនមានសេសសល់ ដូចជាឧទាហរណ៍ថា 'សង្ខារទាំងឡាយឯណានីមួយ' ដូច្នេះឯង ។ ២ បទថា **'មនសោ បិយា'** បានដល់ ដែលចិត្តគប្បីស្រឡាញ់, អធិប្បាយថា 'ជាទីស្រឡាញ់ នៃចិត្ត' ។ ក៏លោកសំដែងការដល់ព្រម នៃពណ៌សម្បុរ ដែលរាប់បញ្ចូលក្នុងអត្តភាព នៃទេវបុត្រនោះ ដែលពិសេសដូចបានពោលមកហើយ ពួដ៏ខាងក្រោម ដោយ ២ បទនេះថា **'ឯតាទិសោ វណ្ណោ'** ក្នុងគាថានេះ ។ លោកសំដែងការដល់ព្រម នៃកាមគុណា

មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលជាទិព្វ ជាប្រភេទ ដែលជាទីតាំង នៃគ្រឿងឧបភោគ និង គ្រឿងបរិភោគ ដោយបទថា **'ភោគា'** នេះ ។ លោកសំដែងភាវៈនៃរូបទាំងឡាយជាដើមនោះថា ជាទីប្រាថ្នា ជាទីត្រូវការ និងជាទីពេញចិត្ត ដោយ ២ បទថា **'មនសោ បិយា'** នេះ ។ លោកសំដែងការដល់ព្រម នៃអាយុ ពណ៌ សម្បុរ យសសក្តិ សេចក្តីសុខ និង ភាពជាអធិបតី ដែលជាទិព្វ ដោយ ២ បទថា **'ឥធ ឥជ្ឈតិ'** នេះ ។ បទថា **'បុច្ឆាមិ'** គឺ អាត្មាសូមតាំងនូវបញ្ហា ។ អធិប្បាយថា 'អាត្មា ប្រាថ្នាដើម្បីនឹងចង់ដឹង' ។ ក៏ពាក្យសួរនេះ ជាពាក្យសួរដែលមានសម្បត្តិ គឺ ព្រះថេរៈ បានឃើញហើយ ជាគ្រឿងប្រៀបធៀបមែនពិត ។ បទថា **'មនុស្សភូតោ'** បានដល់ កើត គឺ កើតហើយ ក្នុងមនុស្ស ឬថា ដល់ហើយ នូវភាពជាមនុស្ស ។ ២ បទថា **'កិមកាសិ បុញ្ញំ'** មានសេចក្តីថា អ្នកបានធ្វើ គឺ សន្សំនូវកុសលកម្ម ដែលជាសុចរិត ដែលបានឈ្មោះថា 'បុណ្យ' ព្រោះញុំាងផលឲ្យកើត ក្នុងភពដែលគេបូជា និង ព្រោះសំអាត គឺជម្រះនូវសន្តាន ដែលជាទីកើតឡើង នៃខ្លួនអ្វី គឺដូចម្តេច ក្នុងកុសលកម្ម មានទាន និងសីលជាដើមជាប្រភេទៗ?, អធិប្បាយថា 'ញុំាងកុសលកម្ម ដូចម្តេច ឲ្យកើតឡើង ?' ។ បទថា **'ជលិតានុភាវោ'** គឺ មាន

បុញ្ញឫទ្ធិ រុងរឿង ដោយប្រការទាំងពួង" ។

(១៤៨) ទេវបុត្រ ត្រូវព្រះថេរៈសួរ យ៉ាងដូច្នេះហើយ កាលនឹងព្យាករនូវបញ្ហា ទើបបានពោលគាថាទាំងនេះ ថា +

"ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានកសាង[1] ទីចង្រ្កម ត្រង់ផ្លូវ ក្នុងព្រៃផង ដាំដើមឈើជាសួន ច្បារផង, ពួកអ្នកមានសីល បានជាទីស្រឡាញ់ នៃខ្ញុំផង, ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយ និង ទឹក ដែលជាទានដ៏ធំទូលាយ ដោយគោរព ។ សម្បុរ របស់ខ្ញុំ បានច្រាកដដូច្នោះ ព្រោះបុញ្ញកម្ម នោះ, ផលនៃសុចរិត រមែងសម្រេច ដល់ខ្ញុំ ក្នុង វិមាននេះ ព្រោះបុញ្ញកម្មនោះ, មួយទៀត ភោគៈ ទាំងឡាយណានីមួយ ជាទីគាប់ចិត្ត, ភោគៈទាំង ឡាយនោះ រមែងកើតឡើង ដល់ខ្ញុំ ព្រោះបុញ្ញកម្ម នោះ ។ ខ្ញុំជាអ្នកមានអានុភាព ដ៏រុងរឿង យ៉ាងនេះ និង សម្បុរ របស់ខ្ញុំ រមែងភ្លឺច្បាស់ សព្វទិសទី ព្រោះបុញ្ញកម្មនោះ" ។

(១៤៩) អដ្ឋកថានៃមណិថូណវិមាន ក្នុងសត្តមវគ្គ ថា

---

១ ត្រៃបិដក ភាគទី ៥៥ / ទំព័រទី ១៥៩

"បណ្តាបទទាំងឡាយនោះ បទថា **'វិវនេ'** បានដល់ ក្នុងព្រៃ ។ បទថា **'អារាមរុក្ខានិ'** បានដល់ ដើមឈើ ដែលជាទីរីករាយ, ម្យ៉ាងទៀត បានដល់ ដើមឈើ ក្នុងសួនច្បារ ។ អធិប្បាយថា 'ខ្ញុំសាងសួនច្បារហើយ ក៏បានដាំដើមឈើទុក ក្នុងសួនច្បារនោះ"។

អដ្ឋកថានៃខុទ្ទកវិមាន ក្នុងឆដ្ឋមវគ្គថា "ពាក្យដែលសេសសល់ថា **'បរិច្ចជន្តោ'** អ្នកសិក្សា គប្បីនាំយកមកសម្ព័ន្ធចូល ដោយ ២ បទថា **'អន្នញ្ច បានញ្ច'** ។ ម្យ៉ាងទៀត គប្បីប្រកបពាក្យថា 'ខ្ញុំបានឲ្យទាន ដ៏បរិបូណ៌ ។ សួរថា 'បានឲ្យយ៉ាងដូចម្តេច ?'។ ឆ្លើយថា 'បានឲ្យដោយគោរព'។ សួរថា 'ទានដូចម្តេច ?'។ ឆ្លើយថា 'ទាន គឺបាយនិងទឹក' ដូច្នេះ "។

រឿងឧបាសក ក្នុងអដ្ឋកថាមណិថូណវិមាន ចប់ ។

(១៥០) ក្នុងអដ្ឋកថាសេរីសកវិមាន ក្នុងសត្តមវគ្គនុ៎ះឯង លោក បានពោលហើយថា "ក្នុងអតីតកាល ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា កស្សបៈ ព្រះខីណាស្រពមួយអង្គ និមន្តទៅ ក្នុងស្រុកមួយ ដើម្បីបិណ្ឌបាត បានធ្វើភត្តកិច្ច ក្នុងទីកន្លែងមួយ ខាងក្រៅស្រុក ជារៀងរាល់ថ្ងៃ ។ អ្នកចិញ្ចឹមគោម្នាក់ បានឃើញព្រះខីណាស្រពនោះហើយ ក៏គិតថា 'ព្រះគុណម្ចាស់ដ៏ចំរើន រមែង

លំបាក ព្រោះកំដៅនៃព្រះអាទិត្យ ហើយ មានចិត្តជ្រះថ្លា បានធ្វើមណ្ឌបមែកឈើ ដោយសសរដើមច្រេស ៤ ដើម ប្រគេនហើយ។ អាចារ្យពួកខ្លះ ពោលថា អ្នកចិញ្ចឹមគោនោះ ដាំដើមច្រេស ក្បែរមណ្ឌប ដូច្នេះក៏មាន។ អ្នកចិញ្ចឹមគោនោះ ធ្វើមរណកាលហើយ ក៏បានទៅកើត ក្នុងពួកទេវតាជាន់ចាតុមហារាជិកៈ ដោយបុញ្ញកម្មនោះឯង។ ព្រៃច្រេស ដែលល្អស្រស់បំព្រង សព្វៗកាល ដោយផ្កា ដល់ព្រមដោយពណ៌និងក្លិន ដែលបង្ហាញនូវកម្មអំពីកាលមុន របស់ទេវបុត្រនោះ កើតឡើងហើយ ក្បែរទ្វារនៃវិមាន។ ព្រោះហេតុនោះ វិមាននោះ ទើបប្រាកដថា សេរីសកៈ។ ក៏ទេវបុត្រនោះ អន្ទោលទៅមក ក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយពុទ្ធន្តរៈ ក្នុងពុទ្ធុប្បាទនេះ ជាអ្នកឈ្មោះថា គវម្បតិ ក្នុងចំណោមសំឡាញ់ ដែលជាគ្រហស្ថទាំង ៤ នាក់ របស់ព្រះយសត្ថេរ មានវិមលៈជាដើម ស្ថិតនៅហើយ ក្នុងព្រះអរហត្ត ព្រោះធម៌ទេសនារបស់ព្រះមានព្រះភាគ”។

(១៥១) ចំណែកក្នុងអដ្ឋកថាបាយាសិសូត្រ ក្នុងមហាវគ្គ ក្នុងទីឃនិកាយ លោកពោលទុកថា “បានឮថា ព្រះថេរៈ ក្នុងពេលជាមនុស្ស ក្នុងកាលមុន កើតជាប្រធាននៃពួកក្មេងចិញ្ចឹមគោ បានសំអាតគល់នៃដើមច្រេសដ៏ធំហើយ រោយដីខ្សាច់ ស្រេច

ហើយ និមន្តព្រះថេរៈមួយរូប ដែលប្រព្រឹត្តបិណ្ឌបាតជាវត្ត ឱ្យគង់ក្រោមដើមឈើ បានប្រគេនអាហារ ដែលខ្លួនបានហើយ ច្យុតអំពីទីនោះហើយ ក៏បានទៅកើត ក្នុងវិមានប្រាក់នោះ ដោយអានុភាពនៃកម្មនោះ ។ ដើមច្រេស បានស្ថិតនៅហើយ ក្បែរមាត់ទ្វារនៃវិមាន ។ ដើមច្រេសនោះ តែងចេញផល ដោយ ៥០ ឆ្នាំ ។ គ្រានោះ ទេវបុត្រ ដល់នូវសេចក្តីសង្វេគថា ‘៥០ ឆ្នាំ កន្លងផុតទៅហើយ’ ។ ទេវបុត្រនោះ បានកើត ក្នុងពួកមនុស្ស ក្នុងកាលនៃព្រះមានព្រះភាគ របស់យើងទាំងឡាយ បានស្តាប់នូវព្រះធម្មកថា របស់ព្រះសាស្តាហើយ ក៏បានសម្រេចព្រះអរហត្ត” ។

ជីកានៃបាយាសិសូត្រនោះថា “ បទថា ‘**តស្សានុភាវេន**’ គឺ ដោយអានុភាព នៃទាននោះ ។ ដើមច្រេស ដែលជាទិព្វ បរិបូណ៌ ដោយដើម ប្រគាប មែក និងសន្លឹក ជាទីផ្សាយចេញនៃរស្មី សំដែងនូវផលដែលជាទីគាប់ចិត្ត ឈ្មោះថា សិរីសរុក្ខៈ ។ បទថា ‘**អដ្ឋាសិ**’ មានសេចក្តីថា ដើមច្រេសនោះ បានដុះស្ថិតនៅហើយ ក្បែរមាត់ទ្វារនៃវិមាន សំដែងនូវភាវៈនៃផល ដែលបណ្ឌិត គប្បីឃើញសមស្មើដោយកម្ម” ។

រឿងអ្នកចិញ្ចឹមគោ ចប់ ។

(១៥២) កម្មដែលមិនមានទោសទាំងឡាយ មានកិរិយាសមាទាន នូវអង្គនៃខ្មោសថជាដើម បណ្ឌិតគប្បីជ្រាបថា "ជាមង្គល" ព្រោះជាហេតុនៃការបានសម្រេច នូវប្រយោជន៍សុខ មានការកើត ក្នុងឋានសួគ៌ជាដើម មានប្រការផ្សេងៗ យ៉ាងដូច្នេះ ។

ពណ៌នាអំពីកម្មដែលមិនមានទោស ចប់ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ពួក ៤ នៃមង្គល គឺ ទាន ១ កិរិយាប្រព្រឹត្តិធម៌ ១ កិរិយាសង្គ្រោះនូវញាតិ ១ ការងារដែលមិនមានទោស ១ ដោយព្រះគាថានេះឯង ដោយប្រការដូច្នេះ ។

ក្នុងគាថាទី ៥ នេះ បាទខាងដើម មានអក្សរ ៩ តួ, បាទទី ២ ត្រឹមត្រូវតាមលក្ខណៈ នៃបាទទី ២ នៃបថ្យាវត្ត, កន្លះគាថា ទី ២ ជាបថ្យាវត្ត ដូច្នេះឯង ។

ពណ៌នាសេចក្តីនៃគាថាទី ៥ ចប់ ។

ប្រែចប់ ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែជេស្ឋ ព.ស. ២៥៣៦.

ពណ៌នាសេចក្តីនៃគាថាទី៦

(១៥៣) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៦ ។ ការវៀរ ឈ្មោះថា **អារតិ** ។ ការវៀរស្រឡះ ឈ្មោះថា **វិរតិ** ។ ម្យ៉ាងទៀត ជនទាំងឡាយ រមែងវៀរ ដោយចេតនានុ៎ះ ព្រោះហេតុនោះ ចេតនានុ៎ះ ឈ្មោះថា **វិរតិ** ។ បទថា "**បាបា**" គឺ ចាកបាប បានដល់ ចាកអកុសល ។ បទថា "**មជ្ជបានា**" គឺ ចាកការផឹក បានដល់ ចាកការលេចចូល នូវសុរានិងមេរ័យ ដែលឈ្មោះថា មជ្ជៈ ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ សេចក្តីសង្រួម ឈ្មោះថា **សញ្ញមៈ** ។ សេចក្តីមិនប្រមាទ ឈ្មោះថា **អប្បមាទៈ** ។ បទថា "**ធម្មេសុ**" គឺ ក្នុងកុសលធម៌ទាំងឡាយ ។ បទថា "**ឯតំ**" ជាដើម មានសេចក្តីថា "ម្នាលទេវតា អ្នកចូរសម្គាល់យកថា 'កិរិយាមិនត្រេកអរ កិរិយាវៀរ ចាកបាប ១ សេចក្តីសង្រួម ចាកការផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១, កម្មទាំង ៣ យ៉ាង មានកិរិយាវៀរ ចាកបាបជាដើមនេះ ជាមង្គលដ៏ខ្ពង់ខ្ពស់' ដូច្នេះ"។

សេចក្តីសង្ខេប ក្នុងគាថាទី ៦ នេះ មានតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ ក្នុងគាថាទី ៦ នេះ មានដូចតទៅនេះ ÷

(ចិរ័តិ ៣ យ៉ាង)

(១៥៤) សេចក្តីមិនត្រេកអរក្រៃលែង ក្នុងចិត្តន៉ុះឯង នៃបុគ្គលអ្នកមានប្រក្រតីយើញទោស ក្នុងបាប ឈ្មោះថា អារតី ។ កិរិយាវៀរ (ចាកបាប) ដោយកាយនិងវាចា ដោយអំណាចនៃកម្មនិងទ្វារ ឈ្មោះថា វិរ័តិ ។ វិរ័តិនោះ មាន ៣ យ៉ាង គឺ សម្បត្តវិរ័តិ ១ សមាទានវិរ័តិ ១ សមុច្ឆេទវិរ័តិ ១ ។ ឥឡូវនេះ ខ្ញុំនឹងពោលបំព្រួញ វិរ័តិទាំង ៣ យ៉ាង តាមន័យដែលព្រះអដ្ឋកថាចារ្យពោលទុកហើយ ក្នុងអដ្ឋកថាអដ្ឋសាលិនីជាដើម ។

(១៥៥) ន័យដែលមក ក្នុងអដ្ឋកថា នៃអដ្ឋសាលិនី និងសម្មាទិដ្ឋិសូត្រថា "បណ្តាវិរ័តិទាំង ៣ នោះ វិរ័តិដែលកើតឡើងដល់បុគ្គលទាំងឡាយ អ្នកដែលមិនបានសមាទានសិក្ខាបទ (តែ) បានពិចារណា នូវឋានៈទាំងឡាយ របស់ខ្លួន មានជាតិ វ័យ និងពាហុសច្ចៈ ជាដើមហើយ មិនបានកន្លង នូវវត្ថុដែលមកជួបប្រទះ ដោយនឹកគិតថា 'ការធ្វើ យ៉ាងដូច្នេះ មិនសមគួរហើយ ដល់ពួកយើង' ដូច្នេះ បណ្ឌិតគប្បីជ្រាបថា 'សម្បត្តវិរ័តិ' ដូចជាវិរ័តិ របស់ឧបាសក ឈ្មោះថា ចក្តនៈ ក្នុងកោះសីហឡៈ ដូច្នោះឯង ។

បានញ្ចថា ក្នុងកាលដែលចក្តនឧបាសកនោះ នៅក្មេងន៉ុះឯង

រោគ កើតឡើងហើយ ដល់មាតា ។ ក៏គ្រូពេទ្យ ប្រាប់ថា 'ការ បាននូវសាច់ទន្សាយស្រស់ៗ(មកផ្សំថ្នាំ) ទើបគួរ' ។ គ្រានោះ បងប្រុស របស់កុមារចក្កនៈនោះ បានបញ្ជូន នូវកុមារចក្កនៈទៅ ដោយប្រាប់ថា 'នែប្អូន អ្នកចូរទៅស្រែ ស្វែងរកចុះ" ។ កុមារ ចក្កនៈនោះ បានទៅក្នុងស្រែនោះហើយ ។ ពេលនោះ ទន្សាយមួយ មកដើម្បីស៊ីស្រូវខ្ចី ឃើញកុមារចក្កនៈហើយ ទើបបោលទៅ យ៉ាង លឿន ត្រូវវ័ល្លិព័ន្ធហើយ ទើបបានស្រែកឮថា 'កិរិ កិរិ' ដូច្នេះ ។ កុមារចក្កនៈ បានឮសំឡេងនោះហើយ ក៏ទៅចាប់មក ដោយគិតថា 'អញនឹងធ្វើថ្នាំឱ្យមាតា' ដូច្នេះ (តែ) គិតថា 'ការដែលអាត្មា អញគប្បីផ្តាច់បង់សត្វដទៃ ចាកជីវិត ព្រោះហេតុនៃជីវិត របស់ មាតា នោះ មិនសមគួរ ដល់អាត្មាអញសោះឡើយ' ហើយ ក៏បាន ដោះលែងទៅ ដោយពោលថា 'អ្នកចូរទៅចុះ, ចូរស៊ីស្មៅ ផឹកទឹក ជាមួយនឹងទន្សាយទាំងឡាយ ក្នុងព្រៃចុះ' ។ កុមារចក្កនៈនោះ ទៅផ្ទះ ត្រូវបងប្រុសសួរហើយ ទើបប្រាប់រឿងនោះ ត្រូវបងប្រុស នោះ ជេរប្រទេច ទើបទៅកាន់សំណាក់ របស់មាតាហើយ បាន ឃើញពោលពាក្យសច្ចៈមានជាអាទិ៍ថា 'តាំងអំពីកាលដែលអាត្មាអញ កើតហើយ ដោយជាតិ មិនចេះក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ' ។ ក្នុងខណៈនោះភ្លាម មាតារបស់កុមារចក្កនៈនោះ ក៏ជាអ្នកបានជា

សះស្បើយរោគអស់ហើយ"។

ជីកាសម្ចាទិដ្ឋិសូត្រថា "សាច់ទន្សាយដែលរស់ ឈ្មោះថា សាច់ទន្សាយស្រស់។ ព្រោះជាសាច់ដែលប្រឡាក់ដោយឈាម ។ កុមារចក្កនៈនោះ ដោះលែងទន្សាយទៅ ព្រោះកិរិយាធ្វើស្មើគ្នា ចំពោះសត្វគ្រប់ជំពូក ។ កុមារចក្កនៈនោះ ពោលពាក្យសច្ចៈថា "ដោយកិរិយាពោលពាក្យសច្ចៈនេះ សូមឱ្យរោគ របស់មាតានៃខ្ញុំ ចូរស្ងប់រម្ងាប់ទៅ"។

(១៥៦) អដ្ឋកថាកូដទន្តសូត្រថា "បុគ្គលណា មិនបានទទួលនូវសិក្ខាបទទាំងឡាយទេ តែនឹករលឹកដល់ឋានៈទាំងឡាយ របស់ខ្លួន មានជាតិ គោត្រ ត្រកូល និងប្រទេសជាដើម តែម្យ៉ាងហើយ មិនធ្វើអកុសលកម្មទាំងឡាយ មានបាណាតិបាតជាដើម លះបង់ នូវវត្ថុដែលបានជួបប្រទះ ដោយគិតថា 'កម្មនេះ មិនសមគួរដល់អាត្មាអញឡើយ' ដូច្នេះ ឈ្មោះថា វៀរ លះបង់ ចាកវត្ថុនោះ, ការវៀរនោះ របស់បុគ្គលនោះ បណ្ឌិតគប្បីជ្រាបថា 'ជាសម្បត្តិវិរតិ'។ ចំណែកវិរតិ របស់បុគ្គលអ្នកដែលទទួលយកសិក្ខាបទទាំងឡាយ ដោយន័យដូច្នេះថា 'ក្នុងពេលមានថ្ងៃនេះ ជាដើមទៅ អាត្មាអញ នឹងមិនសម្លាប់សត្វ សូម្បីព្រោះហេតុនៃជីវិត' ដូច្នេះជាដើមក្តី ថា 'អាត្មាអញនឹងវៀរ ចាកបាណាតិបាត' ដូច្នេះ

ជាដើមក្តី ថា 'អាត្មាអញ សមាទាន ចេតនាជាហេតុវៀរ' ដូច្នេះក្តី បណ្ឌិតគប្បីជ្រាបថា 'សមាទានវិរតិ' ដូច្នេះ"។

ជីកានៃកូដទន្តសូត្រនោះ ថា "បទថា **'បរិហរតិ'** គឺ រមែងវៀរ ដោយអំណាចការមិនប្រព្រឹត្តកន្លង។ **ឥតិ** សព្ទ ក្នុងបទថា **'ន ហនាមិ'** នេះ មានអាទិសព្ទ ជាអត្ថ។ បណ្ឌិតគប្បីធ្វើការសង្គ្រោះសិក្ខាបទទាំងឡាយ មានជាអាទិ៍ យ៉ាងដូច្នេះថា **'អទិន្នំ នាទិយាមិ'** ដូច្នេះ ដោយឥតិសព្ទនោះ។ ម្យ៉ាងទៀត គប្បីធ្វើការសង្គ្រោះសិក្ខាបទទាំងឡាយនោះ ដោយវាសព្ទ (ក៏បាន)។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'សិក្ខាបទានិ គណ្ហន្តស្ស'** ដូច្នេះ"។

(១៥៧) នំយក្នុងអដ្ឋកថា នៃសម្មាទិដ្ឋិសូត្រ ជាដើមថា "ក៏វិរតិ ដែលកើតឡើង ដល់ជនទាំងឡាយ អ្នកដែលសមាទាននូវសិក្ខាបទហើយ ព្រមលះបង់សូម្បីជីវិត របស់ខ្លួន ទាំងក្នុងពេលសមាទានសិក្ខាបទ ទាំងក្នុងពេលដទៃក្រៅអំពីនោះ មិនប្រព្រឹត្តកន្លងនូវវត្ថុ បណ្ឌិតគប្បីជ្រាបថា 'សមាទានវិរតិ' ដូចជាវិរតិរបស់ឧបាសក អ្នកនៅក្បែរភ្នំឈ្មោះទន្តវឌ្ឍមានៈ ដូច្នោះ។

បានឮថា ឧបាសកនោះ ទទួលសិក្ខាបទ ក្នុងសំណាក់នៃព្រះចិង្គលពុទ្ធរក្ខិតត្ថេរ អ្នកនៅក្នុងអម្ពវិយវិហារ ហើយក្សត្រៃ

កាលបើគោ បាត់ហើយ, ក៏ស្វែងរកគោនោះ បានឡើងលើភ្នំឈ្មោះ ទន្តវឌ្ឍមានៈហើយ ។ ពស់ដ៏ធំ លើភ្នំនោះ បានរួបរឹតឧបាសក នោះហើយ ។ ឧបាសកនោះ គិតថា "អាត្មាអញ នឹងកាត់ក្បាលពស់ នោះ ដោយកំបិតដ៏មុតនេះ" ដូច្នេះ បានគិតហើយគិតទៀត ដល់ទៅ លើកទី ៣ យ៉ាងនេះថា "ការដែលអាត្មាអញ គប្បីទទួលសិក្ខាបទ ក្នុងសំណាក់ នៃគ្រូអ្នកដែលគួរសរសើរ ហើយគប្បីទំលាយចោល នោះ មិនសមគួរ ដល់អាត្មាអញសោះឡើយ" ដូច្នេះហើយ បាន កាត់ចិត្តថា "អាត្មាអញ នឹងលះបង់នូវជីវិត, នឹងមិនលះបង់នូវ សិក្ខាបទឡើយ" ហើយ ក៏បានបោះកំបិតព្រាដ៏មុត ដែលលើលើ ស្មា ចោលក្នុងព្រៃហើយ ។ ក្នុងខណៈនោះឯង ពស់ដ៏ធំ ក៏បាន រលាត វាទៅហើយមួយរំពេច" ។

ជីកានៃសម្មាទិដ្ឋិសូត្រថា "ពស់ថ្លាន់ ឈ្មោះថា ពស់ដ៏ធំ, ពស់ដ៏ធំនោះ បានរលាត វាទៅហើយ ដោយតេជៈនៃសីល" ។

(១៥៨) អដ្ឋកថានៃសម្មាទិដ្ឋិសូត្រជាដើម ថា "ក៏សូម្បី សេចក្តីគិតថា 'អាត្មាអញ នឹងសម្លាប់សត្វ' ដូច្នេះ រមែងមិនកើត ឡើង ដល់ព្រះអរិយបុគ្គលទាំងឡាយ ចាប់ដើមតាំងអំពីការកើត ឡើងនៃវិរតិណា, វិរតិនោះ សម្បយុត្តដោយអរិយមគ្គ បណ្ឌិត គប្បីជ្រាបថា 'សមុច្ឆេទវិរតិ' ដូច្នេះ" ។

ក៏ក្នុងពាក្យទាំងនេះ ដោយពាក្យថា "**ចិត្តម្បិ ន ឧប្បជ្ជតិ**" ដូច្នេះនុ៎ះ ព្រះអដ្ឋកថាចារ្យ សំដែងថា "ចិត្តដែលជាហេតុបង្កពៀរ ៥ យ៉ាង ស្ងប់រម្ងាប់ហើយមែនពិត" ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា "ភ័យ ពៀរទាំងឡាយ ៥ យ៉ាង របស់ព្រះអរិយសាវ័ក ជាធម្មជាតស្ងប់រម្ងាប់អស់ហើយ ចាប់ដើមតាំងអំពីសេចក្តីប្រព្រឹត្តទៅ នៃវិរ័ត្តិឯណា, វិរ័ត្តិនោះ សម្បយុត្តដោយអរិយមគ្គ ឈ្មោះថា សមុច្ឆេទវិរ័ត្តិ' ។

បណ្តាបទទាំងនោះ ចេតនាជាហេតុបង្កភ័យ និងពៀរទាំងឡាយ ឈ្មោះថា ភ័យ ពៀរទាំងឡាយ ។

សរុបវិរ័ត្តិ ៣ យ៉ាង ចប់ ។

(កម្មកិលេស ៤ យ៉ាង)

(១៥៩) អកុសលកម្ម ៤ យ៉ាង ពោលគឺកម្មកិលេស ឈ្មោះថា បាប ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគទ្រង់បានត្រាស់ទុក ក្នុងសិគាលសូត្រ ថា "កម្មកិលេសទាំងឡាយ ៤ ឯណានីមួយ ជាកម្មកិលេសដែលព្រះអរិយសាវ័កនោះ លះបង់បានហើយ ។ ម្នាលគហបតីបុត្រ គឺ ការសម្លាប់សត្វមានជីវិត ជាកម្មកិលេស ការយកទ្រព្យរបស់អ្នកដទៃ ដែលគេមិនបានឲ្យ

ជាកម្មកិលេស ការប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ ជាកម្មកិលេស ការពោលពាក្យកុហក ជាកម្មកិលេស, កម្មកិលេសទាំង ៤ យ៉ាង នេះ ជាបាបកម្មដែលព្រះអរិយសាវ័កនោះ លះបង់បានហើយ" ។

ព្រះដ៏មានព្រះភាគ បានត្រាស់សូត្រនេះហើយ លុះព្រះសុគត ជាសាស្តា ទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធ នេះ តទៅទៀត ថា ÷

"បណ្ឌិតទាំងឡាយ តែងមិនសរសើរ កម្មកិលេស ៤ យ៉ាង គឺ បាណាតិបាត ១ អទិន្នាទាន ១ មុសាវាទ ១ ការគប់រកភរិយារបស់អ្នកដទៃ ១ ដែលបណ្ឌិតហៅថា (ជាកម្មកិលេស)" ។

ដីកានៃសិគាលសូត្រនោះ ថា "បទថា 'កតមស្ស' កាត់បទជា **កតមេ អស្ស**" ។

បណ្តាបទទាំងនោះ បទថា "**អស្ស**" បានដល់ ដែលព្រះអរិយសាវ័ក ជាព្រះសោតាបន្ន ។

(១៦០) ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថានៃសិគាលសូត្រនោះថា "បទថា 'កម្មកិលេសា' នេះ មានវិនិច្ឆ័យ ថា ÷ សត្វទាំងឡាយ រមែងសៅហ្មង ព្រោះកម្មកិលេសទាំង

ឡាយនោះ ព្រោះហេតុនោះ កម្មកិលេសទាំងឡាយនោះ ទើប ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា កម្មកិលេស" ដូច្នេះហើយ ពោល តទៅទៀតថា "កម្មនោះផង ឈ្មោះថា ជាកិលេស ព្រោះ ភាវៈជាកម្មដែលសម្បយុត្ត ដោយកិលេសផង ហេតុនោះ ទើប ឈ្មោះថា កម្មកិលេស ។ មែនពិត បុគ្គលអ្នកមានកិលេស ប៉ុណ្ណោះ រមែងសម្លាប់សត្វ, បុគ្គលអ្នកមិនមានកិលេស រមែងមិន សម្លាប់សត្វឡើយ ព្រោះហេតុនោះ បាណាតិបាត ទើបព្រះមាន ភាគទ្រង់ត្រាស់ថា ជាកម្មកិលេស ។ សូម្បីក្នុងអទិន្នាទានជាដើម ក៏នំយនេះ ដូចគ្នាដែរ ។ បទថា '**អថាបរំ**' បានដល់ គាថាព័ន្ធ សូម្បីដទៃទៀត គឺ ដែលសំដែងនូវសេចក្តីនោះឯង" ។

(១៦១) ដីកានៃសិគាលសូត្រនោះថា "កិលេសទាំងឡាយ ដែលជាតួកម្ម ឈ្មោះថា កម្មកិលេស ។ បទថា '**កិលិស្សន្តិ**' ប្រែថា សៅហ្មង គឺ មួហ្មង, អធិប្បាយថា 'សត្វទាំងឡាយ ជា អ្នកត្រូវកម្មកិលេសនោះ បៀតបៀន និង ដុតរោលហើយ' ។ បទថា '**តស្មា**' បានដល់ ព្រោះភាវៈនៃកម្មនោះ មានសេចក្តីសៅ ហ្មងជានិមិត្ត ។ ២ បទថា '**កិលេសសម្បយុត្តត្តា កិលេសោ**' ព្រះអដ្ឋកថាចារ្យ ពោលភាវៈនៃកម្មប្រព្រឹត្តទៅ មួយអន្លើដោយ កិលេសនោះ ព្រោះប្រកបដោយកិលេសនោះ ដូចជាឧទាហរណ៍ថា

'បឋមឈាន មានចីតិនិងសុខ' និងថា 'សំពត់មានពណ៌ខៀវ' ដូច្នេះ។ ក៏ភាវៈនៃកម្មសម្បយុត្តដោយកិលេស ក្នុងបទថា **'កម្មកិលេសា'** នេះ បណ្ឌិតគប្បីជ្រាប ដោយភាវៈនៃកម្មដែលមានសេចក្តីដូចគ្នាតែមួយនឹងកិលេសនោះ, មិនគប្បីជ្រាប ដោយភាវៈជាកម្មដែលកើតឡើង ក្នុងខណៈជាមួយគ្នាជាដើមឡើយ។ ក៏ព្រោះធ្វើនូវសេចក្តីអធិប្បាយ យ៉ាងដូច្នេះ ភាវៈនៃកម្ម គឺ បាណាតិបាត ជាធម្មជាតិសៅហ្មងហើយ សូម្បីព្រោះកិលេសទាំងឡាយ មានទិដ្ឋិមានះនិងលោភៈជាដើម ទើបជាការសម្រេចហើយ។ ភាវៈនៃមិច្ឆាចារ ជាបាបធម៌សៅហ្មងហើយ ព្រោះកិលេសមានទោសៈជាដើម ក៏យ៉ាងដូច្នោះដែរ។ ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា 'សក្កិលេសោយេវ' ដូច្នេះ។ ចំណែកការពោលបរិយាយ នូវកម្មទាំងនោះ ថា ជាកិលេស រមែងបាន សូម្បីដោយទីចំពោះមុខតែម្តង ដោយអំណាចនៃសេចក្តីដែលបានពោលហើយ ក្នុងកាលមុន។ បទថា **'តទត្ថបរិទីបកមេវ'** គឺ សេចក្តីឯណាមួយ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយន័យជាដើមថា 'បាណាតិបាតោ ខោ' ដូច្នេះ, ដែលសំដែងសេចក្តីនោះឯង។ ដើម្បីនឹងចៀសវាងបញ្ហាថា 'បើដូច្នោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ម្តងទៀត?' ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យ

ពោល ថា 'គាថាពន្ធំ' ដូច្នេះ ។ អធិប្បាយថា 'ព្រះមានព្រះភាគ ទ្រង់បានត្រាស់ព្រះតម្រាស់ជាគាថាព័ន្ធទុក ដើម្បីកំណត់យកសេចក្តី នោះ បានដោយងាយស្រួល' ដូច្នេះ "។

(១៦២) ព្រោះព្រះបាលីថា "**កម្មក្កិលេសា**" ដូច្នេះ ទើបគួរប្រកាន់យកអកុសលធម៌ មានបាណាតិបាតជាដើម ដែលដល់ភាពជាកម្មបថប៉ុណ្ណោះ, មិនគួរប្រកាន់យកអកុសលធម៌ ដែលគ្រាន់តែជាទុច្ចរិតឡើយ ។ ព្រោះថា អកុសល ដែលមិនមែនជាកាយកម្មនិងវចីកម្ម គប្បីពោល ថា "ទុច្ចរិត" ដូច្នេះ ក៏មាន ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាឈ្មោះថាអដ្ឋសាលិនី ថា " ក៏អកុសល ដល់នូវការកម្រើកញាប់ញ័រ ក្នុងកាយទ្វារនិងវចីទ្វារទាំងឡាយហើយ សូម្បីមិនដល់នូវកម្មបថ ក៏មាន, មួយទៀត អកុសលដែលដល់នូវការជុសឡើងក្នុងមនោទ្វារហើយ សូម្បីមិនដល់នូវកម្មបថ ក៏មាន, បណ្ឌិតទាំងឡាយ ប្រកាន់យកអកុសលដែលមិនទាន់ដល់ ភាពជាកម្មបថនោះហើយ ទើបបានធ្វើ ឲ្យទៅជាបក្សពួកនៃទ្វារនោះៗ ប៉ុណ្ណោះ ។

ក្នុងពាក្យនោះ មានន័យ ដូចតទៅនេះ គឺ ÷

បុគ្គលគិត ថា " អាត្មាអញ នឹងទៅដេញសត្វម្រឹគ" ហើយត្រៀមនូវធ្នូ វេញនូវខ្សែ សំលៀងច្បូក បរិភោគអាហារ

ស្លៀកសំពត់, ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង អកុសលវមែង ជាធម្មជាតិដល់នូវការកម្រើកញាប់ញ័រ ក្នុងកាយទ្វារ ។ បុរសនោះ ស្រាច់ទៅក្នុងព្រៃ អស់មួយថ្ងៃ តែងមិនបាន ដោយហោចទៅ សូម្បីត្រឹមតែទន្សាយ និងខ្លាត្រី, សួរថា 'អកុសលនេះ នឹងឈ្មោះថា ជាកាយកម្ម ឬក៏មិនមែនជាកាយកម្ម ?' ។ ឆ្លើយថា 'អកុសលនេះ មិនឈ្មោះថា ជាកាយកម្មទេ' ។ ព្រោះហេតុអ្វី ទើបមិនមែនជាកាយកម្ម ? ។ ព្រោះមិនទាន់ដល់កម្មបថ ។ តែ អកុសលនេះ បណ្ឌិតគប្បីជ្រាបថា 'ឈ្មោះថា ជាកាយទុច្ចរិតតែម្យ៉ាង' ។ សូម្បីក្នុងប្រយោគទាំងឡាយ មានការចាប់ត្រីជាដើម ក៏នัยនេះដូចគ្នាដែរ ។ គប្បីជ្រាបវិនិច្ឆัย សូម្បីក្នុងវចីទ្វារ (ដូចតទៅនេះ)÷ កាលបើបុគ្គលបញ្ជា ថា 'ខ្ញុំនឹងទៅដេញសត្វម្រឹគ, ពួកអ្នក ចូរ រៀបចំនូវសស្ត្រាវុធ មានធ្នូជាដើម ដោយប្រញាប់' ដូច្នេះហើយ មិនបានអ្វី ។ ក្នុងព្រៃ ដោយនัយមុនដូចគ្នាដែរ, អកុសលដល់នូវ ការកម្រើក ក្នុងវចីទ្វារក៏ពិតមែនហើយ, ទោះបីជាដូច្នោះ ក៏មិន ទាន់ចាត់ថា ជាវចីកម្មដែរ ព្រោះមិនទាន់ដល់នូវកម្មបថ, ប៉ុន្តែ គប្បីជ្រាបថា 'ឈ្មោះថា ជាវចីទុច្ចរិតតែម្យ៉ាង' ។ ប៉ុន្តែកាលបើ ចេតនាអ្នកគិតនឹងសម្លាប់ គ្រាន់តែកើតឡើងហើយ ក្នុងមនោទ្វារ, ការបែកធ្លាយនៃកម្មបថ ក៏រមែងមាន ។ ក៏ការបែកធ្លាយ

នៃកម្មបថនោះឯង រមែងមាន ដោយអំណាចនៃព្យាបាទ, មិនមែនមាន ដោយអំណាចនៃបាណាតិបាតទេ ។ ព្រោះកាយកម្ម ដែលជាអកុសល រមែងតាំងឡើង ក្នុងកាយទ្វារនិងវចីទ្វារទាំងឡាយ, មិនមែនតាំងឡើង ក្នុងមនោទ្វារទេ ។ វចីកម្ម ដែលជាអកុសល ក៏ដូច្នោះដែរ ។ ចំណែកមនោកម្ម ដែលជាអកុសល រមែងតាំងឡើង ក្នុងទ្វារសូម្បីទាំង ៣ ។ កាយកម្ម វចីកម្ម និង មនោកម្ម ទាំងឡាយ ចំណែកខាងកុសល ក៏ដូច្នោះដែរ" ។

(១៦៣) ដីកានៃអដ្ឋកថាអដ្ឋសាលិនីនោះ ថា "ចេតនា ដែលញុំាងប្រយោគឱ្យសម្រេច ដែលដល់ភាពជាកម្មបថនុ៎ះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា 'កម្ម' ដោយព្រះបាលីថា 'ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ទាំង ៣ ប្រការ គឺជាកាយកម្ម ចំណែកខាងអកុសល' ដូច្នេះជាដើម ព្រោះហេតុនោះ ចេតនា ដែលមានខាងដើម ទាំងអស់ ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'មិនមែនជាកាយកម្ម' ។ ពាក្យថា '**អាណាបេត្វា ។ បេ ។ អលភន្តស្ស**' ព្រះអដ្ឋកថាចារ្យ ពោលសំដៅយកនូវភាវៈនៃសត្វនោះ គឺអ្នកដែលត្រូវគេបង្គាប់ មិនបានសម្លាប់ ។ អធិប្បាយថា 'អកុសលនោះ ឈ្មោះថាវចីទុច្ចរិត ព្រោះភាវៈមិនមែនជាកម្មបថ" ។

ក៏ការរៀរចាកបាបនោះ ដែលខ្ញុំសរុបពោល ចប់ ។

(១៦៤) វត្ថុជាហេតុនៃសេចក្តីស្រវឹង ១០ យ៉ាង ដោយអំណាចសុរា ៥ យ៉ាង និងមេរ័យ ៥ យ៉ាង ឈ្មោះថា ទឹកស្រវឹង ។ សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងសុរាបានសិក្ខាបទវិភង្គថា "សុរាធ្វើដោយមេរ្យា ១ សុរាធ្វើដោយនំ ១ សុរាធ្វើដោយបាយ ១ សុរាដែលគេដាក់ពូជសុរា ១ សុរាដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ ១ ឈ្មោះថា សុរា ។ ទឹកស្រាំដែលគេធ្វើដោយផ្កាឈើ ១ ទឹកស្រាំដែលគេធ្វើដោយផ្លែឈើ ១ ទឹកស្រាំដែលគេធ្វើដោយផ្លែច័ន្ទ ឬគេធ្វើដោយទឹកឃ្មុំ ១ ទឹកស្រាំដែលគេធ្វើដោយទឹកអំពៅ ១ ទឹកស្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ឈ្មោះថា មេរ័យ" ។

(១៦៥) ដីកាឈ្មោះថា សារត្ថទីបនី និង ដីកាសិគាលសូត្រថា "សុរាដែលគេដាក់មេរ្យា ក្នុងភាជនៈហើយ ថែមទឹកឱ្យសមគួរដល់មេរ្យានោះ ច្របាច់ធ្វើ ឈ្មោះថា សុរាធ្វើដោយមេរ្យា ។ សុរាដែលគេដាក់នំក្តី បាយក្តី ក្នុងភាជនៈ ហើយថែមទឹក ឱ្យល្មមសមគួរដល់នំ ឬបាយនោះ ច្របាច់ធ្វើ យ៉ាងដូច្នោះ លោកហៅថា សុរាធ្វើដោយនំ សុរាធ្វើដោយបាយ ។ ក៏ពូជ នៃសុរានោះ ឈ្មោះថា ពូជ (មេដំបែ) ។ ពូជទាំងឡាយណា ដែលគេហៅថា 'មេដំបែ នៃសុរា' ដូច្នេះខ្លះ, សុរាដែលគេដាក់នូវ

ពូជទាំងឡាយនោះ ហើយធ្វើ ឈ្មោះថា សុរាដែលគេដាក់ពូជសុរា ។ សុរាដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ មានផ្លែស្រម៉ និងគ្រាប់ស្ពៃជាដើម ឈ្មោះថា សុរាដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ" ។

ដីកាវិមតិវិនោទនីថា "សុរាដែលគេដាក់វត្ថុមានម្សៅនិងនំជាដើម ហើយដាក់ពូជ (មេ) សុរា មានពន្លកស្រូវជាដើម ដែលរាប់ថាជាពូជ ហើយធ្វើ ឈ្មោះថា សុរាដែលគេដាក់ពូជសុរា ។ សុរាដែលគេប្រកបព្រម ដោយគ្រឿងផ្សំច្រើនយ៉ាង មានគ្រាប់ស្ពៃជាដើម ឈ្មោះថា សុរាដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ" ។

(១៦៦) អដ្ឋកថាសុរាបានសិក្ខាបទ ថា "បានជាត ដែលគេដាក់ពូជម្សៅ ឈ្មោះថា សុរា, បានជាត ដែលគេធ្វើ ដោយរសជាតិ សូម្បីនៃផ្លែដូងជាដើម រមែងដល់នូវការរាប់ថា សុរាដូចគ្នាដែរ ។ អាចារ្យពួកខ្លះ ពោលថា 'កាលបើគេដងយករសដ៏ប្រសើរ (ទឹកថ្លា) នៃសុរាដែលគេដាក់ពូជ (មេ) នោះឯងហើយ, សុរាដែលនៅសល់ ក៏រមែងដល់ នូវការរាប់បញ្ចូលថាជាមេរ័យ មួយរំពេច' ។ ទឹកត្រាំដែលគេធ្វើ ដោយរសជាត នៃផ្កាឈើទាំងឡាយមានផ្កាចន្ទជាដើម ឈ្មោះថា ទឹកត្រាំដែលគេធ្វើ

ដោយផ្កាឈើ ។ ទឹកស្រាំដែលគេច្របាច់ផ្លែឈើទាំងឡាយ មានផ្លែចន្ទជាដើម ហើយធ្វើ ដោយរសជាតិ នៃផ្លែចន្ទទាំងឡាយនោះ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយផ្លែឈើ ។ ទឹកស្រាំដែលគេធ្វើដោយរសជាតិ នៃផ្លែចន្ទទាំងឡាយ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយផ្លែចន្ទ ឬគេធ្វើដោយទឹកឃ្មុំ ។ អាចារ្យពួកខ្លះ ពោលថា 'គេធ្វើដោយទឹកឃ្មុំខ្លះ' ដូច្នេះ "។

(១៦៧) ជីកានៃអដ្ឋកថាទាំងពួង តាមដែលបានពោលមក ហើយថា "រសជាតិនៃផ្កាឈើ មានផ្កាច័ន្ទ ផ្កាស្នោត ផ្កាដូងជាដើម ដែលគេស្រាំទុក យ៉ាងយូរ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយផ្កាឈើ ។ រសជាតិនៃផ្លែឈើមានផ្លែខ្នុរជាដើម ដែលគេស្រាំទុកយូរដូច្នោះ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយផ្លែឈើ ។ រសជាតិនៃផ្លែចន្ទ ដែលគេស្រាំទុកយូរ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយផ្លែចន្ទ ។ រសជាតិនៃអំពៅ ដែលគេស្រាំទុកយូរ ឈ្មោះថា ទឹកស្រាំដែលគេធ្វើដោយទឹកអំពៅ ។ រសជាតិ នៃគ្រឿងផ្សំផ្សេងៗ មានផ្លែស្រម៉ កន្ធកព្រៃ និងគ្រឿងក្តៅជាដើម ដែលស្រាំទុកយូរ ឈ្មោះថា ទឹកស្រាំដែលគេប្រកបព្រម ដោយគ្រឿងផ្សំផ្សេងៗ "។

ជីកានៃសិគាលសូត្រ ព្រមទាំងអដ្ឋកថាថា " វត្ថុទាំង ១០ យ៉ាង សូម្បីទាំងអស់នោះ ឈ្មោះថា ទឹកស្រវឹង ដោយអំណាចជា

ហេតុនៃសេចក្តីស្រវឹង ព្រោះធ្វើវិគ្រោះថា 'រមែងញុំាងអ្នកផឹក ឲ្យស្រវឹង' ដូច្នេះ"។

(១៦៨) អដ្ឋកថាខុទ្ទកបាឋថា "សុរានិងមេរ័យទាំង ២ យ៉ាងនោះឯង ឈ្មោះថា ទឹកស្រវឹង ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង, ក៏ម្យ៉ាងទៀតថា បានៈអ្វីមួយ សូម្បីផ្សេងទៀត ដែលជាទីតាំងនៃសេចក្តីស្រវឹង រមែងមាន, បាននោះ ក៏ឈ្មោះថា ទឹកស្រវឹង, បុគ្គលជាអ្នកស្រវឹង រង្វេងហើយ ព្រោះបានៈណា ដែលខ្លួនផឹកហើយ, បាននេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា 'ទឹកស្រវឹង' ដូច្នេះ"។

អដ្ឋកថាអាមកធញ្ញបេយ្យាល ក្នុងមហាវគ្គ សំយុត្តនិកាយ ថា "សុរានិងមេរ័យទាំង ២ យ៉ាងនោះឯង ឬក៏ បានៈសូម្បីផ្សេងទៀត ដែលរួចផុតអំពីសុរានិងទឹកស្រាំ ដែលជាទីតាំងនៃសេចក្តីស្រវឹង ឈ្មោះថា ទឹកស្រវឹង"។

ដីកានៃអាមកធញ្ញបេយ្យាលនោះថា "បទថា '**សុរាសវ-វិនិមុត្តំ**' គឺ រួចផុតចាកសុរានិងមេរ័យ តាមដែលពោលហើយ"។

(១៦៩) ចេតនាជាហេតុផឹក ពោលគឺ ជាទីតាំងនៃសេចក្តីប្រមាទ ឈ្មោះថា បានៈ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាអាមកធញ្ញបេយ្យាលថា "បុគ្គលទាំង

ឡាយ រមែងផឹកនូវទឹកស្រវឹងនោះ ដោយចេតនាឯណា, ចេតនានោះ ឈ្មោះថា ជាទីតាំងនៃសេចក្តីប្រមាទ ព្រោះជាហេតុនៃសេចក្តីប្រមាទ"។ អដ្ឋកថាខុទ្ទកបាឋៈ និងអដ្ឋកថាសិគាលសូត្រ ក៏យ៉ាងដូច្នោះដែរ ។ ការរៀរ ឈ្មោះថា សំយមៈ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុក ក្នុងអដ្ឋកថាថា "ឈ្មោះថាការសង្រួមចាកការផឹកនូវទឹកស្រវឹង គឺខ្ជុំនឹងពោល។ ពាក្យថា 'មជ្ជបានសញ្ញមោ' នេះ ជាឈ្មោះ នៃចេតនាគ្រឿងរៀរ ចាកហេតុជាទីតាំង នៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹង គឺសុរា និងមេរ័យ"។

ការសង្រួមចាកការផឹកនូវទឹកស្រវឹង គឺខ្ជុំសរុបពោល ចប់ ។

(១៧០) ក៏ប្រៀបដូចជា ការផឹកនូវសុរា ព្រះមានព្រះភាគ មិនទ្រង់ប្រកាន់យក ក្នុងពាក្យថា "**កម្មកិលេស**" នេះ ក្នុងសិគាលសូត្រនោះ យ៉ាងណា, សូម្បីក្នុងមង្គលបទថា "**អារតី វិរតី បាបា**" នេះ បណ្ឌិតមិនគួរប្រកាន់យកនូវការផឹកទឹកស្រវឹងនោះ ក្នុងបទថា "**បាបា**" នេះ ក៏យ៉ាងនោះដែរ ។ ហេតុក្នុងការមិនទ្រង់ចាត់សុរាបាននោះ ចូលទៅក្នុងសិគាលសូត្រនោះ មានន័យដែលព្រះដីកាចារ្យ ពោលទុកហើយ ក្នុងដីកាសិគាលសូត្រនុ៎ះឯង ។ ក៏អាចារ្យអ្នករចនាគម្ពីរដីកា ពោលយ៉ាងនេះថា

"សុរាបានៈ គឺឧបាសកទាំងឡាយគប្បីវៀរស្រឡះ ដោយភាវៈជាវៀរ ៥ ប្រការ ក៏ពិតមែន, ទោះជាដូច្នោះ ព្រះមានព្រះភាគទ្រង់លះបង់ចោល នូវសុរាបាននោះ ហើយទ្រង់ត្រាស់សំដៅយកនូវអកុសលធម៌ មានបាណាតិបាតប៉ុណ្ណោះថា 'កម្មកិលេស ៤ យ៉ាង' ព្រោះទ្រង់ព្រះបំណងនឹងត្រាស់ ខាងមុខ ព្រោះភាវៈនៃសុរាបាននោះ ជាផ្លូវនៃសេចក្តីវិនាសភោគៈ" ដូច្នេះហើយ ពោលទៀតថា "អាចារ្យមួយពួកទៀត ពោលថា 'ក៏ព្រោះភាវៈនៃសុរាបាននោះ មិនមែនជាកម្មបថ មួយផ្នែក' ដូច្នេះ។ អាចារ្យពួកខ្លះពោលថា 'សូម្បីការផឹកសុរា មកហើយ ដោយភាវៈជាកម្មបថមួយផ្នែក ព្រោះព្រះបាលីថា 'ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរា ដែលបុគ្គលសេព អប់រំ ធ្វើឱ្យច្រើនហើយ ជាកម្មញ៉ាំងសត្វឱ្យប្រព្រឹត្តទៅក្នុងនរក' ដូច្នេះជាដើម។ ពិតមែនដូច្នោះ ការផឹកសុរានោះ ជាទុច្ចរិត ទៀងទាត់ហើយ ក្នុងភាពជាផ្លូវសំរាប់ញ៉ាំងសត្វឱ្យទៅកាន់ទុគ្គតិ' ដូច្នេះ។ តាមមតិ របស់កេចិអាចារ្យទាំងនោះ កម្មបថ គប្បីមាន ១១ យ៉ាង, ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញការបូកបញ្ចូល (សុរាបានៈ) ក្នុងកម្មបថទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់បានត្រាស់ទុកហើយនុ៎ះឯង ដោយអំណាចភាពជាឧបការៈ និង ភាពស្មើគ្នា ព្រោះហេតុនោះ ពាក្យថា 'វិសុំ

កម្មបថភាវតោ ច ដូច្នេះនុ៎ះ ជាពាក្យដែលអាចារ្យដទៃទៀតពោលល្អហើយ ដូច្នេះ។ ក៏ក្នុងមង្គលបទ ថា "**អារតី វិរតី បាបា**" នេះ សូម្បីការផឹកសុរា នឹងជាបាប ក៏ពិតមែន, ទោះបីជាដូច្នោះ ព្រះមានព្រះភាគទ្រង់ប្រាថ្នា ដើម្បីនឹងត្រាស់កម្មកិលេសក្រៅអំពីការផឹកសុរានោះ ដោយភាវៈជាបាបហើយ ទើបទ្រង់ត្រាស់ការផឹកសុរានោះ ដោយភាវៈជាទឹកស្រវឹង ខាងមុខ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសន្និដ្ឋាន ថា "មិនគួរប្រកាន់យកសុរាបាននោះ ក្នុងបទថា 'បាបា' នេះទេ។ មួយទៀត វិរតិមានមេថុនវិរតិជាដើមក្តី មគ្គក្តី ឈ្មោះថា ការប្រព្រឹត្តិប្រសើរ ក្នុងគាថាទី ៩ ថា "**តបោ ច ព្រហ្មចរិយញ្ច**" នេះ ក៏ពិតមែន, ទោះជាដូច្នោះ ព្រហ្មចរិយៈដែលសល់អំពីមគ្គនោះ ឈ្មោះថា គឺព្រះមានព្រះភាគ ទ្រង់កំណត់យកហើយ ព្រោះភាវៈនៃមគ្គ គឺព្រះអង្គទ្រង់កំណត់យកហើយ ខាងមុខ ដោយកិរិយាឃើញនូវអរិយសច្ចៈ យ៉ាងណាមិញ, សេចក្តីឧបមេយ្យជាគ្រឿងញុំាងអត្ថឲ្យដល់ព្រមនេះ បណ្ឌិតគប្បីឃើញ ដូច្នោះដែរ។

(១៧១) ចេតនាជាហេតុបង្កពៀរទាំង ៥ យ៉ាង មានបាណាតិបាតជាដើម ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយបទទាំង ២ ថា "**បាបា មជ្ជបានា**"។ ចេតនាជាហេតុវៀរចាក

ពៀរទាំង ៥ យ៉ាងនោះ ព្រះអង្គទ្រង់ត្រាស់ទុក ដោយបទទាំង ២ ថា "**វិរតិ សំយមោ**" ដោយប្រការដូច្នេះ ។ បណ្តាពៀរទាំង ៥ យ៉ាងនោះ បាបធម៌ ៤ យ៉ាង មានបាណាតិបាតជាដើម អ្នកសិក្សាគប្បីជ្រាប តាមន័យដែលខ្ញុំពោលហើយ ក្នុងអាគារិយវិន័យ ឯដ៏ខាងក្រោយ ។ ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាប សូម្បីតាមន័យដែលព្រះអដ្ឋកថាចារ្យ បានពោលទុកហើយ ក្នុងអដ្ឋកថានៃមហាខន្ធកៈ ។ ពិតមែន ក្នុងអដ្ឋកថាមហាខន្ធកៈនោះ លោកបានពោលហើយថា "ប្រៀបដូចជាអាចត្តិផ្សេងៗ រមែងមាន ដល់ភិក្ខុទាំងឡាយ ព្រោះទោសមានបាណាតិបាតជាដើម យ៉ាងណា, នឹងមាន ដល់សាមណេរទាំងឡាយ យ៉ាងដូច្នោះ ក៏មិនមែនដែរ ។ ព្រោះ សាមណេរ សម្លាប់ស្រមោចខ្មៅនិងស្រមោចក្រហមក្តី ញែចពងសង្កើចក្តី រមែងដល់ នូវភាពជាអ្នក គឺភិក្ខុគប្បីធ្វើឲ្យវិនាស គឺឲ្យសឹកចេញភ្លាម ។ សរណគមន៍ក្តី ការកាន់យកព្រះឧបជ្ឈាយ៍ក្តី ការកាន់យកនូវសេនាសនៈក្តី របស់សាមណេរនោះ ក៏រមែងស្ងប់រម្ងាប់ ក្នុងខណៈនុ៎ះឯង ។ សាមណេរនោះ រមែងមិនបានលាភរបស់សង្ឃ ។ មានត្រឹមតែភេទមួយប៉ុណ្ណោះទេ ដែលជាលក្ខណៈនៅសល់ ។ សាមណេរនោះ មិនមែនជាសមណៈ ព្រោះវត្តសូម្បីត្រឹមតែសរសៃស្មៅ ក្នុងអទិន្នាទានសិក្ខាបទ, មិនមែនជាសមណៈ

ព្រោះច្រកិបត្តិខុស ក្នុងមគ្គណាមួយ បណ្តាមគ្គទាំង ៣ ក្នុងអព្រហ្មចរិយសិក្ខាបទ, មិនមែនជាសមណៈ ព្រោះពោលមុសាសូម្បីដោយប្រាថ្នានឹងសើចលេង ក្នុងមុសាវាទសិក្ខាបទ"។

(១៧២) ក្នុងដីកានៃវិមតិវិនោទនី លោកពោលថា "ព្រះអដ្ឋកថាចារ្យ សំដែងនូវការខាតវស្សា ដោយ ២ បទនេះថា **'សេនាសនគ្គាហោ ច បដិប្បស្សម្ភតិ'** ដូច្នេះ។ បណ្ឌិតគប្បីជ្រាបថា 'ការកាន់យកសេនាសនៈ សូម្បីនៃឧបសម្បន្នទាំងឡាយ ឈ្មោះថា រមែងស្ងប់រម្ងាប់ ព្រោះត្រូវអាបត្តិបារាជិក, ការកាន់យកសេនាសនៈ របស់សាមណេរ រមែងស្ងប់រម្ងាប់ ព្រោះការកំចាត់បង់ សូម្បីនូវគុណាគ្រឿងជាសាមណេរ មានសរណាគមន៍ជាដើម, សាមណេរទាំងនោះ រមែងមិនបានសូម្បីនូវសង្ឃលាភ"។

(១៧៣) ចំណែកការផឹកទឹកស្រវឹង អ្នកសិក្សាគប្បីជ្រាបដោយន័យដែលលោកពោលហើយ ក្នុងអដ្ឋកថា នៃខុទ្ទកបាឋៈថា "ចេតនា ដែលជាហេតុលេបចូលទៅ នូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយមានបំណងនឹងលេបចូលទៅ បណ្ឌិតគប្បីជ្រាបថា 'ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ'។ ក៏សុរាមេរយមជ្ជប្បមាទដ្ឋាន មានអង្គ ៤ យ៉ាងនេះ គឺ បណ្តាសុរាជាដើម ទឹកស្រវឹង

ណាមួយ ដែលជាទីតាំងនៃសេចក្តីស្រវឹង ១ ចិត្តមានភាពជាអ្នកប្រាថ្នាចង់ផឹក ប្រាកដឡើង ១ អ្នកផឹកដល់នូវសេចក្តីព្យាយាម ដែលកើតឡើងអំពីចិត្តនោះ ១ ទឹកស្រវឹងដែលខ្លួនផឹកហើយ រមែងហូរចូលទៅ ១" ។

ចំណែក ក្នុងដីកាសុរាបានសិក្ខាបទ លោកពោលហើយដោយអំណាចការផឹកសុរា របស់ភិក្ខុថា "ក៏ក្នុងសុរាបានសិក្ខាបទនេះ មានអង្គ ២ យ៉ាងនេះ គឺ ភាពជាទឹកស្រវឹង ១ ការផឹកនូវទឹកស្រវឹងនោះ ១" ។

(១៧៤) ក៏ពាក្យណា ដែលព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាសុរាបានសិក្ខាបទថា "ក៏ក្នុងសុរាបានសិក្ខាបទនេះ បណ្តិតគប្បីជ្រាប ភាវៈនៃការផឹកសុរានោះ ជាអចិត្តកៈ (មិនមានចិត្ត) ព្រោះមិនដឹងនូវវត្ថុ (ក៏ត្រូវអាបត្តិ) ។ ភាវៈនៃការផឹកសុរានោះ ឈ្មោះថា ជាលោកវជ្ជៈ (ទោសខាងផ្លូវលោក) ព្រោះភាវៈជាទឹកស្រវឹង ដែលបុគ្គលគប្បីផឹក ដោយចិត្តដែលជាអកុសលមែនពិត" ។ ក្នុងពាក្យនោះ ភាវៈនៃការផឹកសុរានោះ ជាអចិត្តកៈ រមែងបាន ដោយអំណាចនៃភិក្ខុ ។ ព្រោះហេតុនោះឯង ទើបលោកពោលទុកហើយ ក្នុងអដ្ឋកថាមហាខន្ធកៈថា "ក៏ក្នុងការផឹកទឹកស្រវឹង សម្រាប់ភិក្ខុអ្នកមិនដឹងហើយ ផឹកទឹកស្រវឹង តាំង

អំពីពូជ (មេ) ឡើងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។ ឯសាមណេរ កាលដឹងហើយផឹក រមែងដល់នូវការខាតនៃសីល, មិនដឹងហើយផឹក មិនដល់នូវការខាតសីលឡើយ ។ សម្រាប់ពួកសាមណេរ ការផឹកសុរា ជាសចិត្តកៈ ជាវត្ថុនៃបារាជិក" ។

ក្នុងដីកានៃវិមតិវិនោទនី នៃសុរាបានសិក្ខាបទនោះ លោកពោលថា "សាមណេរ មិនដឹងហើយផឹក រមែងមិនដល់នូវការខាតសីលទាំងពួង មានការរៀរចាកបាណាតិបាតជាដើម និង ការខាតសរណៈ ។ តែអកុសល បណ្ឌិតគប្បីឃើញថា 'ការខាតសីល គឺចេតនាជាហេតុរៀរចាកការផឹកសុរាប៉ុណ្ណោះ រមែងមាន ដូចជាការខាតសីល ព្រោះការប្រដាប់នូវផ្កាកម្រងជាដើម' ដូច្នេះ" ។

(១៧៥) ក៏ប្រសិនបើ មានពាក្យសួរ ថា "សីល គឺចេតនាជាហេតុរៀរចាកការផឹកសុរា រមែងខាត, កាលបើយ៉ាងដូច្នោះ ព្រោះហេតុអ្វី សីលក្រៅអំពីនេះ ទើបមិនខាត?" ។ គប្បីឆ្លើយថា "ក៏ការផឹកសុរា ព្រះអដ្ឋកថាចារ្យ បានពោលហើយ ក្នុងអដ្ឋកថាថា 'ជាវត្ថុនៃបារាជិក' ដូច្នេះ និង សីលអ្វីៗ រមែងមិនមាន ដល់សាមណេរដែលបារាជិកឡើយ" ។ សូម្បីក្នុងអដ្ឋកថានៃខុទ្ទកបាឋៈ លោកក៏បានពោល ថា "ក៏បណ្តាសិក្ខាបទទាំង ៥ ខាងដើមនុ៎ះ សម្រាប់សាមណេរ កាលបើសិក្ខាបទមួយខាតហើយ

សិក្ខាបទទាំងឡាយ សូម្បីទាំងអស់ ក៏តែងខាតដូចគ្នាដែរ ។ ព្រោះសិក្ខាទបទាំង ៥ ខាងដើមនោះ ជាសិក្ខាបទដែលស្ថិតនៅក្នុងឋានៈនៃបារាជិក" ។ ព្រោះហេតុនោះ បណ្ឌិតគប្បីពិចារណាពាក្យថា "**សុរាបានវេរមណីសីលភេទោ វ ហោតិ**" ។

(๑๗๖) ក្នុងអដ្ឋកថាសុរាបានសិក្ខាបទ លោកពោលថា "ថ្នាំត្រាំពិសេសឯណា ឈ្មោះថា អរិដ្ឋៈ មិនមែនជាទឹកស្រវឹង, មិនត្រូវអាបត្តិព្រោះថ្នាំត្រាំពិសេសឈ្មោះអរិដ្ឋៈនោះទេ ។ បានឮថា ជនទាំងឡាយ ធ្វើថ្នាំត្រាំពិសេសឈ្មោះអរិដ្ឋៈ ដោយរសនៃផ្លែកន្ទុតព្រៃជាដើមនុ៎ះឯង, ក៏ថ្នាំត្រាំពិសេសឈ្មោះអរិដ្ឋៈនោះ មានសម្បុរ ក្លិន និងរស ប្រហែលគ្នានឹងទឹកស្រវឹង, តែមិនមែនជាទឹកស្រវឹងទេ, ចំណែករសឯណា ដែលគេដាក់គ្រឿងផ្សំ ចាត់ថាជាទឹកស្រវឹង, រសនោះ មិនសមគួរ ចាប់ដើមអំពីពូជទៅ" ។

ជីកានៃវិមតិវិនោទនី នៃសុរាបានសិក្ខាបទនោះថា "បទថា 'ពីជតោ' គឺ ចាប់តាំងអំពីពេលដែលគេដាក់ម្សៅជាដើម តាមដែលបានពោលហើយ ចូលទៅក្នុងភាជនៈ ដើម្បីប្រយោជន៍ដល់ទឹកស្រវឹង" ។

ជីកានៃសុរាបានសិក្ខាបទថា "បទថា 'ពីជតោ' គឺ ចាប់ដើមតាំងអំពីពេល ដែលគេចាត់ចែងគ្រឿងផ្សំហើយ ដាក់ចូលទៅ

ក្នុងភាជនៈ និង ចាប់ដើមតាំងអំពីពេល, កាលចើរស នៃផ្កាឈើទាំង ឡាយ មានស្ពោត និង ដូងជាដើម ដែលគេត្រងទុក, រសនោះនៅ ថ្មីៗសុទ្ធ តែម្តង ។ ចំណែក ថ្នាំត្រាំពិសេស ដែលបុគ្គលផ្សំ ដោយគ្រឿងកេសជ្ជៈច្រើនយ៉ាង មិនមែនជាទឹកស្រវឹង ឈ្មោះថា លោណាសោចិរកសុត្តៈ” ។

ក៏ពាក្យថា “**អកិនវកាលតោ**” ក្នុងជីកាសុរាបានសិក្ខាបទ នុ៎ះ រមែងខុស ចាកពាក្យនេះថា “**ចិរបារិវាសិតោ**” ដូច្នេះ ។ ព្រោះ រសនៃផ្កាឈើ ដែលកើតឡើងថ្មីៗនុ៎ះ មិនគួរ ដើម្បីនឹង ពោលថា “ដែលគេត្រាំទុកយូរឡើយ” ដូច្នេះ ។

(១៧៧) ក៏កម្មកិលេស ៤ យ៉ាង តាមដែលពោលហើយ គឺជាគួចេតនា ដោយធម៌ មែនពិត ។ ដោយហេតុនោះ ក្នុង អដ្ឋកថាសម្មាទិដ្ឋិសូត្រជាដើម ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោល ទុកហើយ ក្នុងអធិការ នៃអកុសលកម្មបថ ថា “កម្មបថទាំង ៧ យ៉ាង ដោយលំដាប់ ជាចេតនាធម៌” ដូច្នេះ ។

បទថា “**សត្ត**” បានដល់ កម្មបថទាំង ៧ ដោយអំណាច នៃកាយកម្ម ៣ និង វចីកម្ម ៤ ។

ការពណ៌នាអំពីពៀរ ៥ យ៉ាង ចប់ ។

(អារម្មណ៍របស់កម្មបថ)

(១៧៨) សូម្បីចេតនា ជាហេតុរៀរចាកពៀរ ៥ យ៉ាង នោះ បណ្ឌិតគប្បីជ្រាប ដោយន័យដែលខ្ញុំបានពោលហើយ ក្នុងអធិការ នៃអកុសលកម្មបថ ឮដ៏ខាងក្រោយនុ៎ះឯង ។ ចំណែកអារម្មណ៍របស់វេរមណីនោះ លោកបានពោលហើយ ក្នុងអដ្ឋកថាទាំងឡាយ ។ ពិតដូច្នោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដៅយកលោកិយវិរតិ ទើបពោលហើយ ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រជាដើមថា “ អារម្មណ៍របស់បាបធម៌ទាំងឡាយ មានបាណាតិបាតជាដើមនុ៎ះឯង ជាអារម្មណ៍ របស់អកុសលកម្មបថទាំងនោះ ដូចគ្នាដែរ ។ ព្រោះថា ការរៀរចាកវត្ថុដែលគប្បីប្រព្រឹត្តកន្លងនុ៎ះឯង ជាកិរិយា ឈ្មោះថា វេរមណី ” ។

អដ្ឋកថាកូដទន្តសូត្រ ថា “ បណ្តាវិរតិទាំង ៣ យ៉ាងនោះ វិរតិ ២ យ៉ាង ខាងដើម ធ្វើវត្ថុមានជីវិតន្ទ្រីយ៍ជាដើម ដែលខ្លួនគប្បីប្រព្រឹត្តកន្លង ដោយអំណាចនៃកិរិយា មានការផ្តាច់បង់ (ជីវិត) ជាដើម ឲ្យជាអារម្មណ៍ហើយ ប្រព្រឹត្តទៅ, វិរតិចុងក្រោយគេ មានព្រះនិព្វាន ជាអារម្មណ៍ តែម្យ៉ាង ” ។

(១៧៩) សមាទានវិរតិ សូម្បីក្នុងសិក្ខាបទទាំងពួង រមែងសមគួរ ក្នុងវេលាដែលរៀរ ចាកវត្ថុដែលមកជួបប្រទះ

ព្ជដ៏ខាងក្រោយ អំពីខណៈដែលទទួលសិក្ខាបទប៉ុណ្ណោះ, មិនសម
គួរ ក្នុងខណៈដែលទទួលសិក្ខាបទនោះឡើយ ។ ព្រោះក្នុងខណៈ
នោះ សមាទានវិរតិ មានអកុសលដែលខ្លួនគប្បីវៀរ ជាអារម្មណ៍
តែម្យ៉ាង ។ ដោយហេតុនោះឯង ក្នុងអដ្ឋកថាខុទ្ទកបាឋៈ ទើប
លោកពោលថា "ក្នុងពាក្យថា '**វិរមតោ**' នេះ អាចារ្យអ្នកចោទ
ពោលថា 'បុគ្គលកាលនឹងវៀរ ចាកអកុសលធម៌ទាំងឡាយ មាន
បាណាតិបាតជាដើម ឈ្មោះថា រមែងវៀរ ចាកបាបធម៌អ្វី ?' ។
ខ្ញុំនឹងឆ្លើយ ។ បុគ្គលកាលនឹងវៀរ ដោយអំណាចសមាទានវិរតិ
ឈ្មោះថា រមែងវៀរ ចាកអកុសលធម៌ មានបាណាតិបាតជាដើម
របស់ខ្លួន ឬរបស់ជនទាំងឡាយឯទៀត ជាមុន ។ ប្រារព្ធអ្វី ? ។
ខ្លួន រមែងវៀរ ចាកអកុសលណាមួយ, ប្រារព្ធអកុសលនុ៎ះឯង ។
បុគ្គលកាលនឹងវៀរ សូម្បីដោយអំណាចសម្បត្តវិរតិ ក៏ឈ្មោះថា
វៀរ ចាកអកុសល មានប្រការដូចបានពោលមកហើយ ដូចគ្នា ។
ប្រារព្ធអ្វី ? ។ ប្រារព្ធអារម្មណ៍នៃអកុសលធម៌មានបាណាតិបាត
ជាដើម ដែលបានពោលហើយនុ៎ះឯង" ។

ចំណែក អាចារ្យពួកខ្លះ ពោលថា " បុគ្គលប្រារព្ធសង្ខារ
ពោលគឺទឹកស្រវឹងហើយ រមែងវៀរ ចាកហេតុជាទីតាំងនៃសេចក្តី
ប្រមាទ ព្រោះទឹកស្រវឹង ។ បណ្តាសត្វ និង សង្ខារទាំងឡាយ

សត្វ និង សង្ខារណា គឺខ្លួនគប្បីលួច និង គប្បីបំបាក់បំបែក, បុគ្គលប្រារព្ធសត្វ និង សង្ខារនោះ រៀរចាកអទិន្នាទាន និង មុសាវាទ, ប្រារព្ធតែសត្វទាំងឡាយប៉ុណ្ណោះ រមែងរៀរចាកបាណាតិបាត និង អព្រហ្មចរិយៈ" ។ ពាក្យរបស់អាចារ្យពួកខ្លះនោះ រមែងត្រូវដោយចរិយាយ ។

អាចារ្យដទៃទៀត ក្រៅអំពីកេចិអាចារ្យនោះ ពោលថា "កាលបើយ៉ាងដូច្នោះ បុគ្គលគិតកិច្ចផ្សេង (តែ) គប្បីធ្វើកិច្ចផ្សេង, មួយទៀត ខ្លួនលះនូវអកុសលណាមួយ, មិនគប្បីដឹងនូវអកុសលនោះ" ដូច្នេះហើយ កាលមិនពេញចិត្ត ទើបពោលថា "ខ្លួនលះអកុសលចំពោះ ខ ណាមួយ, ប្រារព្ធអកុសលមានបាណាតិបាតជាដើម ខនោះ របស់ខ្លួននុ៎ះឯង ហើយរៀរ" ។ ពាក្យរបស់អាចារ្យដទៃក្រៅអំពីកេចិអាចារ្យនោះ មិនត្រូវ ។ ព្រោះហេតុអ្វី ? ។ ព្រោះភាវៈនៃអកុសល មានបាណាតិបាតជាដើមនោះ មិនមានអារម្មណ៍ជាបច្ចុប្បន្ន និង ព្រោះមិនមានអារម្មណ៍ជាខាងក្រៅ ។ ក៏ភាវៈនៃសិក្ខាបទទាំងឡាយ មានអារម្មណ៍ជាបច្ចុប្បន្ន និង មានអារម្មណ៍ជាខាងក្រៅ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិភង្គបាឋៈ យ៉ាងនេះថា "ធម៌ទាំងឡាយ មានអារម្មណ៍ជាបច្ចុប្បន្ន, មានអារម្មណ៍ជាខាងក្រៅ" ដូច្នេះ ។ ព្រះតម្រាស់នោះ រមែង

មិនសមគួរ ដល់អ្នកប្រារព្ធអកុសល មានបាណាតិបាតជាដើមនោះ របស់ខ្លួន ហើយវៀរ ។ មួយទៀត ពាក្យឯណា ដែលអាចារ្យពួកខ្លះ ពោលថា "**អញ្ញំ ចិន្តេន្តោ**" ដូច្នេះជាដើម, ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះ បុគ្គលកាលប្រព្រឹត្ត ដោយអំណាចនៃការញុំាងកិច្ចឲ្យសម្រេច បណ្ដិតតែងមិនហៅថា "គិតកិច្ចដទៃ (តែ) ធ្វើកិច្ចដទៃ" ដូច្នេះ ឬថា "ខ្លួនលះនូវអកុសលបែបណា, រមែងមិនដឹង នូវអកុសលបែបនោះ" ដូច្នេះ ។

ក៏ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងមគ្គ ប្រារព្ធនូវអមតធម៌ហើយ លះបង់នូវបាបទាំងពួង គប្បីជាឧទាហរណ៍ ក្នុងរឿងនេះបាន ។

សេចក្ដីទាំងអស់នេះ គឺខ្ញុំបានមក អំពីអដ្ឋកថាខុទ្ទកបាឋៈ ។

(១៨០) សូម្បីក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រជាដើម ក៏ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដៅយកការចោទ ថា "កម្មបថទាំងឡាយ មានទោសគ្រឿងទ្រុស្តសីលជាអារម្មណ៍ និង មានជីវិតិន្ទ្រិយ៍ជាដើម ជាអារម្មណ៍ រមែងលះទោសគ្រឿងទ្រុស្តសីល បានយ៉ាងដូចម្ដេច ?" ដូច្នេះ ទើបពោល ថា "ប្រៀបដូចជា អរិយមគ្គ មានព្រះនិព្វានជាអារម្មណ៍ រមែងលះកិលេសទាំងឡាយបាន យ៉ាងណា,

កម្មបថទាំងឡាយនុ៎ះ មានជីវិតន្ទ្រិយ៍ជាដើម ជាអារម្មណ៍ បណ្ឌិតគប្បីជ្រាប ថា 'វមែងលះទោសគ្រឿងទ្រុស្តសីល មានបាណាតិបាតជាដើមបាន ក៏យ៉ាងដូច្នោះដែរ' ដូច្នេះ" ។

(១៨១) នំយក្នុងអដ្ឋកថាខុទ្ទកបាឋៈ ថា "សូម្បីសិក្ខាបទទាំងឡាយនុ៎ះ ដែលសាមណេរ សមាទាន ក្នុងសំណាក់នៃភិក្ខុប៉ុណ្ណោះ ជាសិក្ខាបទដែលបានសមាទានហើយ ។ ចំណែកឧបាសក (និងឧបាសិកា) សមាទានរួមគ្នាក្តី ចំពោះអង្គក្តី ដោយខ្លួនឯង ឬក្នុងសំណាក់ នៃបុគ្គលដទៃ ក៏ជាសិក្ខាបទដែលបានសមាទានហើយ ។

សួរថា "ក៏ (ការសមាទានរួមគ្នា និងការសមាទានចំពោះអង្គមួយៗ) មានការប្លែកគ្នា យ៉ាងដូចម្តេច ?" ។

ឆ្លើយថា "កាលបើឧបាសក (ឧបាសិកា) សមាទានរួមគ្នា, វិរ័តិក្តី ចេតនាក្តី ដូចគ្នាតែម្តង, តែភាវៈនៃវិរ័តិ និងចេតនាទាំងឡាយនោះ មាន ៥ យ៉ាង ព្រះមានព្រះភាគទ្រង់បញ្ញត្តិ ដោយអំណាចនៃកិច្ច ។ កាលបើឧបាសក (ឧបាសិកា) សមាទានចំពោះអង្គមួយៗ, វិរ័តិក្តី ចេតនាក្តី ក៏ (ចែកចេញ) ជា ៥ ផងដែរ ។ ក៏បណ្តាសិក្ខាបទទាំង ៥ ខាងដើមនេះ របស់ពួកសាមណេរទាំងឡាយ, កាលបើសិក្ខាបទមួយ ខាតហើយ, សិក្ខាបទ

សូម្បីទាំងអស់ ក៏ជាសិក្ខាបទខាតហើយដែរ ។ ព្រោះសិក្ខាបទទាំង ៥ នោះ តាំងនៅក្នុងឋានៈនៃបារាជិក ។ សិក្ខាបទនោះ ឯណាមួយ ជាវីតិក្កមៈ ដែលសាមណេរទាំងឡាយនោះ ប្រព្រឹត្តកន្លងហើយ, កម្មព័ន្ធ រមែងមាន ព្រោះសិក្ខាបទនោះប៉ុណ្ណោះ ។ ចំណែក សម្រាប់ពួកគ្រហស្ថ, កាលបើសិក្ខាបទមួយ ខាតហើយ, ក៏តែងខាតហើយ តែសិក្ខាបទមួយប៉ុណ្ណោះ, ព្រោះហេតុដែលសីលប្រកបដោយអង្គ ៥ រមែងសម្រេច ដល់គ្រហស្ថទាំងឡាយនោះ បានម្តងទៀត ក៏ដោយការសមាទាននូវសិក្ខាបទទាំងនោះនុ៎ះឯង ។ សិក្ខាបទនោះ ឯណាមួយ សូម្បីដែលពួកគ្រហស្ថទាំងឡាយនោះ បានប្រព្រឹត្តកន្លងហើយ, កម្មព័ន្ធ រមែងមាន ព្រោះសិក្ខាបទនោះតែប៉ុណ្ណោះ ។

ចំណែក អាចារ្យមួយពួកទៀត ពោលថា "បណ្តាសិក្ខាបទទាំងឡាយ ដែលពួកគ្រហស្ថទាំងនោះ បានសមាទានហើយ ផ្សេងៗគ្នា, កាលបើសិក្ខាបទមួយ ខាតហើយ, ក៏រមែងខាតហើយ តែសិក្ខាបទមួយប៉ុណ្ណោះ ។ ប៉ុន្តែកាលបើពួកគ្រហស្ថទាំងនោះ សមាទានរួមជាមួយគ្នា យ៉ាងដូច្នេះថា "អាត្មាអញ សមាទាននូវសីល ដែលប្រកបដោយអង្គ ៥" ដូច្នេះ, កាលបើសិក្ខាបទមួយ ខាតហើយ, សិក្ខាបទសូម្បីទាំងអស់ ក៏រមែងខាតហើយដែរ ។

ព្រោះហេតុអ្វី ? ។ ព្រោះការសមាទាន មិនញែកចេញពីគ្នា" ។

(១៨២) ក៏ពាក្យថា "**បរេ**" នុ៎ះ ព្រះអដ្ឋកថាចារ្យ ពោលសំដៅយក អាចារ្យអ្នកសំដែងគម្ពីរទីឃនិកាយ ។ ពិតដូច្នោះ ក្នុងអដ្ឋកថាកូដទន្តសូត្រ ព្រះអដ្ឋកថាចារ្យ ពោលហើយថា "អ្នកណា ទទួលសិក្ខាបទទាំង ៥ រួមជាមួយគ្នា, កាលបើសិក្ខាបទមួយរបស់អ្នកនោះ ធ្លុះធ្លាយហើយ, សិក្ខាបទសូម្បីទាំងអស់ ក៏រមែងធ្លុះធ្លាយហើយដែរ, អ្នកណា ទទួលយកចំពោះអង្គមួយៗ, អ្នកនោះ រមែងប្រព្រឹត្តកន្លង នូវសិក្ខាបទណាមួយ, សិក្ខាបទនោះតែប៉ុណ្ណោះ រមែងធ្លុះធ្លាយ" ។

ដីកានៃកូដទន្តសូត្រនោះ ថា "សិក្ខាបទសូម្បីទាំងអស់ ឈ្មោះថា រមែងធ្លុះធ្លាយហើយ ព្រោះភាវៈនៃសិក្ខាបទដែលបានសមាទានរួមជាមួយគ្នា ។ សិក្ខាបទនោះប៉ុណ្ណោះ ឈ្មោះថា រមែងធ្លុះធ្លាយ ព្រោះភាវៈនៃសិក្ខាបទដែលបានសមាទានផ្សេងៗគ្នា ។ ក៏ពិធីនុ៎ះ លោកបានពោលហើយ ដោយអំណាចគ្រហស្ថ" ។

(១៨៣) លោកិយវិរតិប៉ុណ្ណោះ មានសភាពធ្លុះធ្លាយ, លោកុត្តរវិរតិ មិនមានសភាពធ្លុះធ្លាយសោះឡើយ ។ ព្រោះហេតុនោះឯង ក្នុងអដ្ឋកថាកូដទន្តសូត្រ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយថា "ក៏ឈ្មោះថា ការធ្លុះធ្លាយ នៃសេតុឃាតវិរតិ

រមែងមិនមាន ។ ព្រោះ ព្រះអរិយសាវ័ក រមែងមិនសម្លាប់សត្វ មិនផឹកសុរា សូម្បីព្រោះហេតុនៃជីវិត សូម្បីក្នុងចន្លោះនៃភព ។ សូម្បីប្រសិនបើ ជនទាំងឡាយ ផ្សំនូវសុរានិងទឹកដោះស្រស់ ច្រកបញ្ចូលទៅ ក្នុងមាត់ របស់លោក, ទឹកដោះស្រស់ប៉ុណ្ណោះ រមែងហូរចូលទៅ, សុរាមិនបានហូរចូលទៅទេ, ដូចជាបានឮមកថា កាលបើទឹក ដែលផ្សំដោយទឹកដោះស្រស់ របស់សត្វក្រៀលទាំងឡាយ ទឹកដោះស្រស់ប៉ុណ្ណោះ រមែងហូរចូលទៅ, ទឹកមិនបានហូរចូលទៅទេ ។ ការដែលទឹក មិនបានហូរចូលទៅ ក្នុងមាត់នៃសត្វក្រៀលនេះ បណ្ឌិតគប្បីជ្រាបថា 'សម្រេច ដោយកំណើត' ដូច្នេះ, ការដែលសុរា មិនហូរចូលទៅ ក្នុងមាត់នៃព្រះអរិយសាវ័ក ក្រៅពីនេះ បណ្ឌិតគប្បីជ្រាបថា 'សម្រេចដោយធម្មតា' ដូច្នេះ" ។

ដីកាកូដទន្តសូត្រនោះថា " ឈ្មោះថា ការធ្លុះធ្លាយ នៃសេតុឃាតវិរ័តិ រមែងមិនមាន ព្រោះមានការមិនកម្រើកជាសភាព ព្រោះកាត់បានយ៉ាងដាច់ខាត នូវធម៌ដែលជាសឹកសត្រូវ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យមានជាអាទិ៍ថា **" ភវន្តរេបិ "** ដូច្នេះ ។

បទថា **" យោនិសិទ្ធំ "** មានសេចក្តីថា សម្រេចដោយជាតិ ប្រៀបដូចជា ភាវៈនៃមនុស្ស មានអវយវៈវែង ទៅខាងខ្ពស់ និង

សត្វតិរច្ឆាន មានអវយវៈវែង ទៅខាងទទឹងដូច្នោះឯង ។ សេចក្តីសម្រេចតាមធម្មតា គឺតាមសភាពនុ៎ះឯង ឈ្មោះថា សម្រេចដោយធម្មតា ដូចជាសីល សម្រេចដល់មាតារបស់ព្រះពោធិសត្វ កាលដែលព្រះពោធិសត្វនៅក្នុងគភ៌ យ៉ាងនោះឯង ។ ម្យ៉ាងទៀត សេចក្តីសម្រេច ដោយធម្មតានៃមគ្គ គឺតាមអនុភាពនៃអរិយមគ្គ ឈ្មោះថា សម្រេចដោយធម្មតា”។

ក៏វិរ័តិ ជាប្រធាន ក្នុងការរៀរ ចាកពៀរនោះ។ ព្រោះហេតុណា, ព្រោះហេតុនោះ ចេតនាដែលឈ្មោះថា វេរមណី ក្នុងសិក្ខាបទទាំងពួង ទើបលោកពោលថា“**វិរ័តិ**”។ មួយទៀត សូម្បីចេតនា ក៏ឈ្មោះថា វេរមណី ។ ដោយហេតុនោះឯង ក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រជាដើម ទើបព្រះអដ្ឋកថាចារ្យ ពោលថា“បណ្តាកម្មបថទាំង ១០ នុ៎ះ កម្មបថ ៧ ខ ដោយលំដាប់ រមែងសមគួរ ទាំងចេតនា ទាំងវិរ័តិ”។

(១៨៤) អាចារ្យអ្នកចោទ បានចោទ ក្នុងមង្គលបទនេះថា“ចេតនាជាហេតុវៀរ ចាកពៀរនោះ។ ព្រះមានព្រះភាគទ្រង់បានត្រាស់ហើយ ដោយបទថា ‘**វិរតី**’ នេះ មិនមែនទេឬ ?, ដើម្បីប្រយោជន៍អ្វី ទើបទ្រង់ត្រាស់ថា ‘**អារតី**’ ដូច្នេះ (ម្តងទៀត) ?”។ អាចារ្យអ្នកឆ្លើយ បានឆ្លើយថា“ព្រះអង្គ

ទ្រង់ត្រាស់ថា 'អារតី' ដូច្នេះ (ទៀត) ក៏ដើម្បីទ្រង់សំដែង នូវ
ភាវៈនៃចិត្តដែលមិនត្រេកអរក្រៃលែង ក្នុងបាប" ។ ព្រោះ
ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាថា
"សេចក្តីមិនត្រេកអរក្រៃលែង ដោយចិត្តន៉ុះឯង របស់បុគ្គលអ្នក
ឃើញទោសជាប្រក្រតី ក្នុងបាប ឈ្មោះថា អារតី" ។ មែនពិត
សូម្បីហេតុ ត្រឹមតែការកើតឡើងនៃចិត្ត ដោយអំណាចនៃការ
វៀរចាកបាប រមែងមានឧបការៈច្រើន ។ ដោយហេតុនោះឯង
ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ព្រះមហាចុន្ទត្ថេរ
ទើបទ្រង់សំដែងធម៌ជាគ្រឿងដុសខាត់ ដោយអាការៈ ៤៤ យ៉ាង
មានជាអាទិ៍ យ៉ាងនេះថា "ម្នាលចុន្ទៈ ក៏ធម៌ជាគ្រឿងដុសខាត់
ក្នុងសាសនានេះឯង គឺអ្នកទាំងឡាយ គប្បីធ្វើ ។ អ្នកទាំងឡាយ
គប្បីធ្វើធម៌ជាគ្រឿងដុសខាត់ថា 'ជនទាំងឡាយឯទៀត នឹងជា
អ្នកបៀតបៀនគ្នា, យើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា
ព្រោះរឿងនេះ' ដូច្នេះ, អ្នកទាំងឡាយគប្បីធ្វើធម៌ជាគ្រឿងដុស
ខាត់ថា 'ជនទាំងឡាយឯទៀត នឹងជាអ្នកសម្លាប់សត្ត, យើង
ទាំងឡាយ នឹងជាអ្នកវៀរ ចាកការសម្លាប់សត្ត ព្រោះរឿងនេះ"
ដូច្នេះហើយ កាលទ្រង់សំដែង នូវភាវៈសូម្បីនៃចិត្តុប្បាទ ក្នុងធម៌
ជាគ្រឿងដុសខាត់នោះ ជាធម្មជាតមានឧបការៈច្រើន ម្តងទៀត

ទើបទ្រង់ត្រាស់ នូវព្រះតម្រាស់ជាអាទិ៍ថា "ម្នាលចុន្ទៈ តថាគត ពោលសូម្បីចិត្តុប្បាទ ថា មានឧបការៈច្រើន ក្នុងកុសលធម៌ទាំង ឡាយ, នឹងចាំបាច់ពោលធ្វើអ្វី ក្នុងការធ្វើរឿយៗ ដោយកាយ និង ដោយវាចា ។ ម្នាលចុន្ទៈ ព្រោះហេតុនោះ ក្នុងរឿងនេះ អ្នកទាំងឡាយ គប្បីញុំាងចិត្ត ឲ្យកើតឡើងថា 'ជនទាំងឡាយ ឯទៀត នឹងជាអ្នកបៀតបៀនគ្នា, យើងទាំងឡាយ នឹងជាអ្នកមិន បៀតបៀនគ្នា ក្នុងរឿងនេះ' ដូច្នេះ ។ អ្នកទាំងឡាយ គប្បីញុំាង ចិត្តឲ្យកើតឡើងថា 'ជនទាំងឡាយឯទៀត នឹងជាអ្នកសម្លាប់សត្វ, យើងទាំងឡាយ នឹងជាអ្នកវៀរ ចាកការសម្លាប់សត្វ ក្នុងរឿង នេះ' ដូច្នេះ "។

(១៨៥) នយអដ្ឋកថាសល្លេខសូត្រនោះថា "បណ្តាបទទាំង នោះ បទថា 'ឥធ' នុ៎ះ ជាបទសំដែងរឿងមានវិហិង្សាជាដើម ។ ២ សព្ទថា 'ខោ បន' គ្រាន់តែជាសព្ទនិបាត ។ បទថា 'វោ' ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ សេចក្តីសង្ខេប ក្នុង សល្លេខសូត្រនោះ មានដូចតទៅនេះថា 'តថាគត ពោលរឿងមាន វិហិង្សាជាដើម នុ៎ះឯណាមួយ ដោយនយជាអាទិ៍ថា 'ជនទាំង ឡាយឯទៀត នឹងជាអ្នកបៀតបៀនគ្នា' ដូច្នេះ, ម្នាលចុន្ទៈ អ្នក ទាំងឡាយ គប្បីធ្វើធម៌ជាគ្រឿងដុសខាត់ ក្នុងរឿងនេះ' ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់មានព្រះបំណងនឹងញុំាងសេចក្តី ដែលទ្រង់ត្រាស់ហើយ ដោយសង្ខេប ឲ្យពិស្តារ ទើបទ្រង់ត្រាស់ ព្រះតម្រាស់មានជាអាទិ៍ថា **'បរេ វិហឹសកា'** ដូច្នេះ ។

(ចិត្តុប្បាទ មានឧបការៈច្រើន)

បណ្តាបទទាំងនោះ បទថា **'បរេ'** បានដល់ បុគ្គលទាំងឡាយឯណា ជាអ្នកប្រកបសល្លេខធម៌នេះ ។ បទថា **'វិហឹសកា'** មានសេចក្តីថា នឹងជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃ ឬ ដោយវត្ថុមានដុំដីជាដើម ។ បទថា **'មយមេត្ថ'** មានសេចក្តីថា ចំណែក យើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា ព្រោះរឿងដែលសត្វទាំងឡាយឯទៀតនុ៎ះឯង ជាអ្នកបៀតបៀនគ្នា គឺនឹងញុំាងការមិនបៀតបៀនគ្នា ឲ្យកើតឡើងហើយ រស់នៅ ។ ពាក្យថា **'ឥតិ សល្លេខោ ករណីយោ'** មានសេចក្តីថា ធម៌ជាគ្រឿងដុសខាត់ ពោលគឺការមិនបៀតបៀន គឺ អ្នកទាំងឡាយ គប្បីធ្វើ យ៉ាងដូច្នេះ ។ ព្រោះថា អវិហិង្សា ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ធម៌ជាគ្រឿងដុសខាត់ ព្រោះវិគ្រោះថា 'ធម៌ណា រមែងដុសខាត់ គឺរមែងកាត់ផ្តាច់ នូវសេចក្តីបៀតបៀនបាន' ។ នយ ក្នុងអាការៈទាំងពួង ក៏នយនេះដែរ ។ ព្រះមានព្រះភាគ ទ្រង់

សំដែងថា 'ក៏ការធ្វើរឿយៗដោយកាយ និងដោយវាចា នុ៎ះឯណា, គឺ ការធ្វើនូវធម៌ទាំងឡាយនោះ ដោយកាយ ឬ ការបង្គាប់ថា 'អ្នកទាំងឡាយ ចូរធ្វើ ដោយវាចា' ដូច្នេះ ឬ កិច្ចទាំងឡាយមានការសិក្សា និងការសាកសួរជាដើម ដូចជាចិត្តដួងទី ១ ដែលបានកើតឡើងហើយ ដូច្នោះឯង ។ នឹងចាំបាច់ពោលធ្វើអ្វីទៅ ក្នុងកិច្ចមានការធ្វើរឿយៗ ជាដើមនោះឡើយ, ព្រោះថា ការប្រកបរឿយៗនោះ មានឧបការៈច្រើន ដោយចំណែកមួយ មែនពិត' ដូច្នេះ ដោយបទថា '**អនុវិធិយនាសុ**' ។

សួរថា 'ក៏ព្រោះហេតុអ្វី សូម្បីចិត្តុប្បាទ ក្នុងកុសលធម៌ទាំងឡាយនេះ ទើបមានឧបការៈច្រើន ?' ។

ឆ្លើយថា 'ព្រោះជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកប្រគល់ឲ្យ ដោយចំណែកមួយ និង ព្រោះជាហេតុនៃកិរិយាប្រកបរឿយៗផង' ដូច្នេះ ។

ពិតដូច្នោះមែន សេចក្តីកើតឡើងនៃចិត្តថា 'អាត្មាអញនឹងឲ្យទាន' ដូច្នេះ រមែងជាហេតុនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ដោយចំណែកមួយ ដោយខ្លួនឯងខ្លះ ជាហេតុនៃការប្រកបរឿយៗខ្លះ ។ ក៏ព្រោះភាវៈនៃខ្លួនជាអ្នកមានចិត្តកើតឡើង យ៉ាងដូច្នេះឯង ក្នុងថ្ងៃទី ២ និងទី ៣ បុរសនោះ ទើបបាន

ចាត់ចែង នូវពិធីយ៉ាងធំ ធ្វើមហាមណ្ឌប ហើយថ្វាយទាន ដល់ភិក្ខុ ១០០ រូប ឬ ១.០០០ រូប, បញ្ជានូវពួកជនជាបរិវារថា 'អ្នកទាំងឡាយ ចូរនិមន្ត ចូរបូជា ចូរអង្គាស ព្រះភិក្ខុសង្ឃ' ដូច្នេះ, ការកើតឡើងនៃចិត្តថា 'អាត្មាអញ នឹងថ្វាយចីវរ សេនាសនៈ ភេសជ្ជៈ ដល់ព្រះសង្ឃ' ដូច្នេះ រមែងជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកឲ្យ ដោយចំណែកមួយ ដោយខ្លួនឯងខ្លះ ជាហេតុនៃការប្រកបរឿយៗ ខ្លះ ដោយប្រការដូច្នេះ ។ ក៏ព្រោះភាវៈជាអ្នកមានចិត្តកើតឡើង យ៉ាងដូច្នេះឯង បុរសនោះ ទើបចាត់ចែង ទើបថ្វាយខ្លួនឯង និង ឲ្យអ្នកដទៃថ្វាយ នូវបរិក្ខារទាំងឡាយ មានចីវរជាដើម ។ នំយក្នុងកុសលទាំងឡាយ មានសរណាគមន៍ជាដើម ក៏នំយនេះដែរ ។ ក៏បុគ្គលញុំាងចិត្ត ឲ្យកើតឡើងថា 'អាត្មាអញ នឹងដល់នូវសរណៈ' ដូច្នេះមុន ក្រោយមក ក៏ទទួលសរណៈ ដោយកាយ ឬ ដោយវាចា ។ មួយទៀត បុគ្គលញុំាងចិត្ត ឲ្យកើតឡើងថា 'អាត្មាអញ នឹងសមាទាន សីលដែលប្រកបដោយអង្គ ៥ អង្គ ៨ អង្គ ១០' ដូច្នេះមុន ហើយសមាទានដោយកាយ ឬ ដោយវាចា (ជាខាងក្រោយ) ។ បុគ្គលញុំាងចិត្ត ឲ្យកើតឡើងថា 'អាត្មាអញ នឹងបួស ហើយតាំងនៅ ក្នុងសីល ៤' ដូច្នេះមុន ហើយចំពេញសីល ដែលខ្លួនត្រូវចំពេញ ដោយកាយ ឬ

ដោយវាចា (ជាខាងក្រោយ) ។ បុគ្គលញុំាងចិត្ត ឲ្យកើតឡើងថា 'អាត្មាអញ នឹងរៀនព្រះពុទ្ធវចនៈ' ដូច្នេះមុន ហើយរៀន ១ និកាយ ២ - ៣ - ៤ ឬ ៥ និកាយ ដោយកាយ ឬ ដោយវាចា ។ រូបមន្តនៃចិត្តុប្បាទ បណ្ឌិតគប្បីនាំទៅ ដោយអំណាចការសមាទាន ធុត្តង្គ រៀនកម្មដ្ឋាន បរិកម្មកសិណ ឈាន សមាបត្តិ វិបស្សនា មគ្គ ផល បច្ចេកពោធិញ្ញាណ និងសម្មាសម្ពោធិញ្ញាណ ដោយនយដែលបានពោលហើយនេះ ។ ក៏ចិត្តុប្បាទថា 'អាត្មាអញ នឹងជាព្រះពុទ្ធ' ដូច្នេះ រមែងជាហេតុនាំប្រយោជន៍ និងសេចក្តីសុខមកប្រគល់ឲ្យ (ទាំង) ជាហេតុនៃការប្រកបរឿយៗផង ។ ក៏ព្រោះជាអ្នកមានចិត្តកើតឡើងហើយ យ៉ាងដូច្នេះឯង ដោយសម័យក្រោយទៀតមក បុរសនោះ ទើបបំពេញបារមីទាំងឡាយ ដោយកាយ ឬដោយវាចា អស់ពេល ៤ អសង្ខ្យៃ ក្រៃលែងដោយ ១ សែនកប្ប ទើបញុំាងលោក (នេះ) ព្រមទាំងទេវលោក ឲ្យឆ្លងផុត ស្រាច់ចរទៅ ។ សូម្បីចិត្តុប្បាទ ក្នុងកុសលធម៌ទាំងពួង រមែងមានឧបការៈច្រើន យ៉ាងដូច្នេះ, ចំណែក ការប្រកបរឿយៗ ដោយកាយ និង វាចា បណ្ឌិតគប្បីជ្រាបថា 'មានឧបការៈច្រើនក្រៃលែង មែនពិត' ។ ព្រះមានព្រះភាគ លុះទ្រង់សំដែង នូវភាវៈសូម្បីនៃចិត្តុប្បាទ ក្នុងកុសលធម៌ទាំងឡាយ ថា ជាគុណធម៌

មានឧបការៈច្រើន យ៉ាងដូច្នេះហើយ ឥឡូវនេះ កាលទ្រង់បបួល (នូវវេនេយ្យសត្វទាំងឡាយ) ក្នុងចិត្តុប្បាទនោះ ទើបទ្រង់ត្រាស់ ព្រះតម្រាស់ ថា '**តស្មាតិហ ត្វន្ត**' ដូច្នេះជាដើម" ។

(១៨៦) ដីកាសល្លេខសូត្រនោះ ថា "បទថា '**អាការេហិ**' គឺ ដោយប្រការ ៤៤ យ៉ាង មានអវិហង្សា ជាដើម ។ ២ បទថា '**កុសលេសុ ធម្មេសុ**' គឺ ក្នុងធម៌ដែលមិនមានទោស តាមដែលបានពោលហើយ មានអវិហិង្សាជាដើម ។ បទថា '**វិហីសាទិវត្ថុំ**' មានសេចក្តីថា តថាគត ពោលវត្ថុនៃអកុសលធម៌ មានវិហិង្សា ជាដើមនេះឯណា, ក្នុងវត្ថុនៃអកុសលធម៌ មានវិហិង្សា ជាដើមនេះ ។ ការប្រកបរឿយៗ នូវចិត្តុប្បាទ ដោយកាយ និងវាចា ឈ្មោះថា អនុវិធិយនា ។ ២ បទថា '**តេសំ ធម្មានំ**' គឺ នូវធម៌ទាំងឡាយ មានការមិនបៀតបៀនជាដើម, មួយទៀត សំដៅយកធម៌ទាំងឡាយ ដែលឱ្យប្រព្រឹត្តទៅ ដោយអំណាចចិត្តុប្បាទទាំងនោះ ។ ឥឡូវនេះ ដើម្បីសំដែងនូវសេចក្តី តាមដែលបានពោលហើយ ដោយពិស្តារ ទើបព្រះអដ្ឋកថាចារ្យ ផ្តើមពាក្យថា '**កស្មា បន**' ដូច្នេះជាដើម ។ ពាក្យថា '**កាយេន**' ព្រះអដ្ឋកថាចារ្យ ពោលហើយ ដោយអំណាច នៃបុគ្គលអ្នកមិនអាច ដើម្បីប្រកាសសូមសរណាគមន៍ ដោយវាចាបាន ។ នយសូម្បីក្នុងពាក្យថា '**សីលំ

កាយេន សមាទិយតិ នេះ ក៏នំយនេះ ដូចគ្នាដែរ ។

សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណោះ ។ ចំណែក សេចក្តីពិស្តារ អ្នកសិក្សាគប្បីត្រួតមើល ក្នុងសល្លេខសូត្រ ក្នុងបឋមវគ្គ នៃមូលបណ្ណាសកៈចុះ ។ សូម្បីចិត្តុប្បាទ ដោយអំណាច នៃការរៀរចាកបាប ក៏ជាគុណធម៌មានឧបការៈច្រើន ដោយប្រការដូច្នេះ, ព្រោះហេតុនោះឯង ភាវៈនៃចិត្តុប្បាទនោះ ជាមង្គល ទើបសមគួរ, ព្រោះហេតុនោះ ពាក្យថា **"អារតី"** នេះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដូច្នេះឯង ។

ពណ៌នាអំពីវិភាគនៃបកិណ្ណកៈ មានអារម្មណ៍ជាដើម នៃវិរតិទាំងឡាយ ចប់ ។

(១៨៧) អដ្ឋកថាខុទ្ទកបាឋៈថា "ក៏ក្នុងសិក្ខាបទទាំង ៥ នេះ បាណាតិបាត អទិន្នាទាន អព្រហ្មចរិយៈ ជាកាយកម្មតែម្យ៉ាង ដល់ភាពជាកម្មបថទាំងអស់ ។ មុសាវាទ ជាវចីកម្មតែម្យ៉ាង ។ តែមុសាវាទណា កំចាត់បង់នូវប្រយោជន៍, មុសាវាទនោះ រមែងដល់នូវភាពជាកម្មបថ, មុសាវាទក្រៅអំពីនេះ ជាកម្មប៉ុណ្ណោះ ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ជាកាយកម្មតែម្យ៉ាង ។ មួយទៀត បណ្តាវេរមណីទាំង ៥ យ៉ាងនេះ វេរមណីទាំង ៤ យ៉ាង គឺជាកាយកម្មទាំងអស់ ។ កិរិយារៀរ ចាកមុសាវាទ ជាវចីកម្ម" ។

(១៨៨) បណ្តាពៀរ ចេតនា និង ការធឹកទឹកស្រវឹងទាំងនោះ ចេតនាជាហេតុបង្កនូវពៀរ រមែងនាំមកនូវទុក្ខ ដែលសត្វគប្បីសោយក្នុងអបាយ ក្នុងទុគ្គតិភព និង រមែងនាំមកនូវភាពជាអ្នកមានអាយុខ្លី ក្នុងសុគតិភព ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ក្នុងសព្វលហុសសូត្រ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយថា "ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ, ផលនៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ដល់បុគ្គលអ្នកកើតជាមនុស្ស, ម្នាលភិក្ខុទាំងឡាយ អទិន្នាទាន ដែលបុគ្គលសេពថ្នឹកហើយ ... រមែងប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ, ផលនៃអទិន្នាទាន ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសនៃភោគៈ ដល់បុគ្គលអ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលសេពថ្នឹកហើយ... ផលនៃកាមេសុមិច្ឆាចារ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសត្រូវនិងពៀរដល់បុគ្គលអ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ មុសាវាទ ដែលបុគ្គលសេពថ្នឹកហើយ... ផលនៃមុសាវាទ ដែល

ស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីគេពោលបង្កាច់ដោយពាក្យមិនពិត ដល់បុគ្គលអ្នកកើតជាមនុស្ស។ ម្នាលភិក្ខុទាំងឡាយ ការធើកនូវសុរានិងមេរ័យ ដែលបុគ្គលសេពថ្នឹកហើយ . . . ផលនៃការធើកនូវសុរានិងមេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកឆ្កួត ដល់បុគ្គលអ្នកកើតជាមនុស្ស"។

(១៨៩) អដ្ឋកថាសព្វលហុសសូត្រនោះ ថា "បណ្តាបទទាំងនោះ ចេតនាជាហេតុសម្លាប់សត្វ ឈ្មោះថា បាណាតិបាត។ បទថា '**សព្វលហុសោ**' គឺ ដែលស្រាលជាងផលទាំងអស់។ បទថា '**អប្បាយុកសំវត្តនិកោ**' មានសេចក្តីថា បុគ្គលជាអ្នកមានអាយុខ្លី ព្រោះផលនៃកម្ម ដ៏តិចតួចនោះ, គឺ កាលបើបដិសន្ធិគ្រាន់តែជនកកម្ម ឱ្យផលហើយ, បុគ្គលនោះ រមែងលាយទៅ ឬគ្រាន់តែប្រសូតចេញ អំពីផ្ទៃពោះ នៃមាតាហើយ ក៏លាយទៅវិញ។ ក៏ផលប្រាកដដូច្នេះ នឹងជាផល របស់កម្មអ្វីដទៃទៀតក៏មិនមែនទេ, ផលប្រាកដដូច្នោះនេះ ជាផ្លូវនៃបាណាតិបាតនុ៎ះឯងទៅហើយ។ បទថា '**ភោគព្យសនសំវត្តនិកោ**' មានសេចក្តីថា ទ្រព្យត្រឹមតែមួយកាកណិក រមែងមិនជាប់នៅ ក្នុងដៃ យ៉ាងណា, ផលនៃអទិន្នាទាន រមែងញ៉ាំងសេចក្តីវិនាសភោគៈ ឱ្យប្រព្រឹត្តទៅ

ព្រម យ៉ាងដូច្នោះ ។ បទថា **'សបត្តវេរសំវត្តនិកោ'** មានសេចក្តីថា ផលនៃការមេសុមិច្ឆាចារ រមែងញុំាងពៀរ ឲ្យប្រព្រឹត្តទៅព្រមទាំងពួកសត្រូវ ។ មែនពិត ពួកសត្រូវរបស់ការមេសុមិច្ឆាចារីបុគ្គលនោះ រមែងមានច្រើន, ក៏បុគ្គលឯណា ។ រមែងជួបប្រទះ នូវការមេសុមិច្ឆាចារីបុគ្គលនោះ, បុគ្គលនោះ ។ រមែងញុំាងពៀរនុ៎ះឯង ឲ្យកើតឡើង គឺ មិនឲ្យរលត់ ក្នុងការមេសុមិច្ឆាចារីបុគ្គលនោះ ។ ក៏ផលប្រាកដដូច្នេះ ជាផលនៃការប្រព្រឹត្តិខុស ក្នុងភ័ណ្ឌៈ ដែលបុគ្គលដទៃ ថែរក្សាគ្រប់គ្រងហើយ ។ ២ បទថា **'អភូតព្ភក្ខាន-សំវត្តនិកោ ហោតិ'** មានសេចក្តីថា ផលនៃមុសាវាទ រមែងញុំាងការពោលមួលបង្កាច់ ដោយពាក្យមិនពិត ឲ្យប្រព្រឹត្តទៅព្រម, គឺកម្មដែលបុគ្គលឯណាមួយ ធ្វើហើយ រមែងធ្លាក់ទៅលើមុសាវាទីបុគ្គលនោះ តែប៉ុណ្ណោះ ។ ២ បទថា **'ឧម្មត្តក-សំវត្តនិកោ ហោតិ'** មានសេចក្តីថា ផលនៃការផឹក នូវសុរា និងមេរ័យ រមែងញុំាងភាពជាអ្នកឆ្កួត ឲ្យប្រព្រឹត្តទៅព្រម ។ មែនពិត មនុស្ស ជាអ្នកឆ្កួតក្តី ជាអ្នកមានចិត្តរវើរវាយក្តី ជាអ្នកឆ្កួតទឹកមាត់ក្តី ក៏ព្រោះវិបាកនៃការផឹកសុរា និងមេរ័យនោះឯង, នេះ គឺជាផលនៃការផឹកសុរា" ។

(១៩០) ចំណែក ទោសនៃការផឹកទឹកស្រវឹង មកហើយ

ដោយពិស្តារ ក្នុងកុម្ភជាតក និង ក្នុងសិគាលសូត្រ ។ ពិតដូច្នោះ ព្រះមានព្រះភាគត្រាស់ ក្នុងសិគាលសូត្រ ថា "ម្នាលគហបតីបុត្រ កិរិយាប្រកបរឿយៗ នូវកិរិយាផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីវិនាស នៃភោគៈទាំងឡាយ" ដូច្នេះហើយ ដើម្បីទ្រង់សំដែង នូវទោសនៃការផឹកនូវទឹកស្រវឹងនោះ ទើបទ្រង់ត្រាស់ថា "ម្នាលគហបតីបុត្រ ទោសក្នុងកិរិយាប្រកបរឿយៗ នូវការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ មាន ៦ យ៉ាង នេះឯង គឺ ជាហេតុនៃការខូចខាតទ្រព្យ ដែលបុគ្គលគប្បីឃើញ ទាន់ភ្នែក ១ ជាហេតុបង្កនូវជំលោះ ១ ជាទីកើតឡើងនៃរោគ ទាំងឡាយ ១ ជាហេតុញុំាងកេរ្តិ៍ឈ្មោះមិនល្អ ឲ្យកើតឡើង ១ ជាហេតុបើកកេរ្តិ៍ខ្មាស ឲ្យគេឃើញប្រាកដ ១ បទជាទីគម្រប់ ៦ ថា ជាហេតុធ្វើបញ្ញា ឲ្យចុះខ្សោយ ១" ។

(១៩១) អដ្ឋកថាសិគាលសូត្រនោះថា "បណ្តាបទទាំងនោះ បទថា **'អបាយមុខំ'** ប្រែថា ជាផ្លូវនៃសេចក្តីវិនាស ។ ការតាមប្រកប គឺ ការធ្វើរឿយៗ នូវការផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទនោះ ឈ្មោះថា អនុយោគោ ។ ក៏ព្រោះកាលបើបុគ្គលប្រកបរឿយៗ នូវការ

ផឹកនូវទឹកស្រវឹងនោះ, ភោគៈទាំងឡាយ ដែលកើតឡើងហើយ នុ៎ះឯង រមែងសាបសូន្យអស់ទៅ និង ភោគៈទាំងឡាយ ដែលមិនទាន់បានកើតឡើងហើយ រមែងមិនកើតឡើង, ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **'ភោគានំ អបាយមុខំ'** ។ បទថា **'សន្និដ្ឋិកា'** គឺ ដែលបុគ្គលគប្បីឃើញខ្លួនឯង បានដល់ដែលប្រាកដមាន ក្នុងលោកនេះ ។ បទថា **'ធនជានិ'** ប្រែថា ជាហេតុសាបសូន្យនៃទ្រព្យ ។ បទថា **'កលហប្បវឌ្ឍនី'** មានសេចក្តីថា ជាហេតុបង្កការឈ្លោះវិវាទគ្នា ដោយវាចានិងការឈ្លោះវិវាទគ្នា ដោយកាយ មានការចំបាប់គ្នា ដោយដៃជាដើម ឲ្យកើតឡើង ។ ២ បទថា **'រោគានំ អាយតនំ'** គឺ ជាខេត្តនៃរោគទាំងឡាយនោះ។ មានរោគក្អែកជាដើម ។ បទថា **'អកិត្តិសញ្ជននី'** មានសេចក្តីថា មែនពិត បុគ្គលពាលទាំងឡាយ ផឹកសុរាហើយ ប្រហារមាតាក៏បាន, បិតាក៏បាន, ពោលពាក្យដែលមិនគួរពោលដទៃទៀត បានយ៉ាងច្រើន, ធ្វើនូវកិច្ចដែលមិនគួរធ្វើ, ព្រោះកម្មនោះ ពួកគេតែងដល់នូវការតិះដៀលខ្លះ អាជ្ញាខ្លះ ដល់នូវការកាត់អវយវៈមានដៃនិងជើងជាដើមខ្លះ, រមែងដល់នូវការខូចឈ្មោះទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ។ សុរានោះ រមែងបុគ្គលពាលទាំងនោះ ទើបឈ្មោះថា ជាហេតុបង្កការខូចឈ្មោះ ឲ្យកើត

ឡើង ដូច្នេះឯង ។ បទថា **'កោបិននិទ្ទំសនី'** មានសេចក្តីថា ព្រោះទីកំបាំង ដែលបុគ្គលកំពុងបើក រមែងញុំាងការអៀនខ្មាស ឲ្យកម្រើក ហេតុដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **'កោបិនំ'** ដូច្នេះ។ ក៏ពួកបុគ្គលអ្នកស្រវឹងព្រោះស្រវឹងសុរា រមែងដើរបើកនូវអវយវៈនោះ, ព្រោះហេតុនោះ សុរារបស់បុគ្គលទាំងនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **'កោបិននិទ្ទំសនី'** ព្រោះជាហេតុបើកបង្ហាញ នូវអវយវៈ ដែលញុំាងការអៀនខ្មាស ឲ្យកម្រើក ។ ២ បទថា **'បញ្ញាយ ទុព្ពលីករណី'** មានសេចក្តីថា សុរានោះ រមែងធ្វើនូវកម្មស្សគតាបញ្ញា ឲ្យមានកម្លាំងខ្វិនថយ ដូចជាសុរារបស់ព្រះសាគតត្ថេរ ដូច្នោះឯង, ហេតុដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **'បញ្ញាយ ទុព្ពលីករណី'** ដូច្នេះ ។ តែសុរានោះ រមែងមិនអាច ដើម្បីនឹងធ្វើ នូវមគ្គបញ្ញា ឲ្យមានកម្លាំងខ្វិនថយបានឡើយ ។ ព្រោះសុរានោះ រមែងមិនហូរចូលទៅក្នុងមាត់ នៃបុគ្គលដែលបានសម្រេចមគ្គហើយនុ៎ះឯង ។ ២ បទថា **'ឆដ្ឋំ បទំ'** បានដល់ ហេតុជាគម្រប់ ៦ "។

(១៩២) ជីកានៃសិគាលសូត្រនោះថា "ភោគៈទាំងឡាយ រមែងអស់ទៅ គឺរមែងវិនាសទៅ ម្យ៉ាងទៀត ភោគៈទាំងឡាយ រមែងសាបសូន្យអស់ទៅ ព្រោះទោសនុ៎ះ ហេតុនោះ ទោសនុ៎ះ

ឈ្មោះថា ជាហេតុវិនាសនៃភោគៈទាំងឡាយ ។ ម្យ៉ាងទៀត ការប្រកបរឿយៗ នូវការផឹកសុរានោះ ជាផ្លូវ គឺអបាយ បានដល់ជាទ្វារ នៃសេចក្តីវិនាសភោគៈ ព្រោះហេតុនោះ ការប្រកបរឿយៗ នូវការផឹកសុរានោះ ឈ្មោះថា ជាផ្លូវ នៃសេចក្តីវិនាសនៃភោគៈ ។ សូម្បីក្នុងបទថា **'វិនាសមុខំ'** នេះ ក៏នយនោះឯង ។ ទីតាំងនៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹង គឺ សុរា និង មេរ័យ ឈ្មោះថា សុរាមេរយមជ្ជប្បមាទដ្ឋាន ។ ភាវៈជាអ្នកប្រកបព្រម ដោយការប្រកបរឿយៗ នូវសុរាមេរយមជ្ជប្បមាទដ្ឋាននោះ ឈ្មោះថា អនុយោគៈ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'បុនប្បុនំ ករណំ'** ។ មានសេចក្តីថា 'ប្រព្រឹត្តទៅហើយ ញឹកញាប់' ។ ភោគៈទាំងឡាយ ដែលកើតឡើងហើយនុ៎ះឯង ឈ្មោះថា រមែងវិនាសទៅ ព្រោះធ្វើសេចក្តីវិនាស ដោយសេចក្តីវិនាសព្រោះការផឹក ។ និងភោគៈទាំងឡាយ ដែលមិនទាន់កើតឡើង ឈ្មោះថា រមែងមិនកើតឡើង ព្រោះភាវៈនៃបុគ្គលអ្នកស្រវឹងហើយ មិនមានការខ្វល់ខ្វាយ ក្នុងការងារទាំងឡាយ ។ បទថា **'ភោគានំ'** បានដល់ កាមគុណទាំងឡាយ ដែលបានឈ្មោះថា 'ភោគៈ' ព្រោះអត្ថថា គឺបុគ្គលគប្បីបរិភោគ ។ ជលឯណា ដែលបុគ្គលអ្នកផឹក គប្បីឃើញដោយខ្លួនឯង ព្រោះ

ហេតុនោះ ផលនោះ ឈ្មោះថា ដែលបុគ្គលអ្នកផឹកគប្បីឃើញដោយខ្លួនឯង ។ សន្និដ្ឋៈនុ៎ះឯង គឺជាសន្និដ្ឋិកៈ ។ ក៏ព្រះមានព្រះភាគទ្រង់ធ្វើនិទ្ទេស ដោយអំណាចនៃឥត្តិលិង្គ ព្រោះទ្រង់សំឡឹងរំពៃដល់ **ធនជានិ** សព្ទ ។ ក្នុងបទថា '**សន្និដ្ឋិកំ**' នេះ មានសេចក្តីដូចតទៅនេះថា 'ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន' ដូច្នេះ, ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**ឥធលោកភាវិនី**' ។ ម្យ៉ាងទៀត សេចក្តីវិនាសទ្រព្យនោះ គឺបុគ្គលគប្បីឃើញ ព្រមគ្នា គឺរួមគ្នា (នឹងការផឹកសុរានោះ) ហេតុនោះ ទើបឈ្មោះថា ដែលបុគ្គលគប្បីឃើញព្រមជាមួយគ្នា ។ អធិប្បាយថា 'ប្រាកដផលក្នុងវេលា ព្រមជាមួយគ្នានឹងការផឹក ។ ឈ្មោះថា ជាហេតុបង្កនូវសេចក្តីឈ្លោះវិវាទគ្នា ព្រោះភាវៈនៃបុគ្គលអ្នកស្រវឹងហើយច្រើនតែមិនឃើញទោស ក្នុងសេចក្តីឈ្លោះវិវាទគ្នា ។ ឈ្មោះថា ជាខេត្ត (នៃរោគ) ព្រោះភាវៈនៃស្ថានទីដែលកើតឡើង ។ ម្យ៉ាងទៀត បទថា '**អាយតនំ**' ប្រែថា ជាហេតុ, អធិប្បាយថា 'ជាទីកើតឡើង' ។ បុគ្គលអ្នកផឹកសុរាទាំងឡាយ ឈ្មោះថា រមែងដល់នូវការខូចឈ្មោះ ទាំងក្នុងលោកនេះ ព្រោះការជួបប្រទះនូវកម្ម ដែលញុំាងការខូចឈ្មោះឲ្យប្រព្រឹត្តទៅ, មួយទៀត កម្មក្នុងទីស្ងាត់កំបាំង គឺបុគ្គលមិនគប្បីធ្វើ ដោយភាពជារបស់

បើកបង្ហាញ ឈ្មោះថា កោបិនៈ ។ បណ្ឌិតគប្បីឃើញសេចក្តី ក្នុងដំណើរនេះ យ៉ាងដូច្នេះថា 'ក៏បុគ្គលអ្នកស្រវឹង ព្រោះស្រវឹងសុរា ក្នុងពេលដែលខ្លួនមិនស្រវឹង បិទបាំងនូវកម្មដូច្នោះ ដែលខ្លួនធ្វើហើយ ក្នុងពេលមុន ដើរទៅ ក្នុងពេលស្រវឹងហើយ រមែងបើកបង្ហាញ គឺធ្វើឲ្យប្រាកដ សូម្បីដល់ជនទាំងឡាយ ដែលជាសឹកសត្រូវដោយហេតុនោះ សុរានោះ របស់ជនទាំងនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា **'កោបិននិទ្ទិសនី'** ព្រោះការបើកបង្ហាញនូវអវយវៈ ដែលជាហេតុញុំាងហិរិ ឲ្យកម្រើកនោះ' ។ បទថា **'កម្មស្សកតប្បញ្ញំ'** បណ្ឌិតគប្បីឃើញថាគ្រាន់តែជាខទាហរណ៍ ។ អ្នកណា ក៏អាចដើម្បីនឹងដឹងបានថា 'សុរា រមែងធ្វើនូវបញ្ញាណាមួយ ដែលជាលោកិយៈ ឲ្យមានកម្លាំងចុះខ្សោយ ដោយពិត' ។ ពិតមែនដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលពាក្យថា **'មគ្គប្បញ្ញម្បន'** ដូច្នេះជាដើម ដើម្បីនឹងទទួលស្គាល់ នូវសេចក្តីនោះ ដោយមុខដែលមានសេចក្តីផ្ទុយផ្សេងគ្នា ។ ដោយពាក្យថា **'អន្តោមុខមេវ នប្បវិសតិ'** នេះ ព្រះអដ្ឋកថាចារ្យ ពោលនូវភាវៈនៃការដែលសុរាធ្វើមគ្គបញ្ញា ឲ្យមានកម្លាំងចុះខ្សោយ ជាទោសត្រូវមគ្គបញ្ញាលើកឡើង ជុតរ្លាយហើយ ។

សួរថា 'ក៏ភាវៈដែលសុរាបំផ្លាញ នូវភាពជាអ្នកអាច

ក្នុងការធ្វើបញ្ញានោះ ឲ្យមានកម្លាំងខ្លិនថយ យ៉ាងដូច្នេះ ជារឿង ដែលព្រះអដ្ឋកថាចារ្យ មិនបានចោទប្រកាន់ហើយ ព្រោះភាវៈនៃ ការមិនចូលទៅខ្ចប់ខ្ជាំងសុរា នៃព្រះអរិយៈទាំងឡាយ គឺលោកបាន ជំទាស់ស្រេចហើយ មិនមែនទេឬ ?' ។

ឆ្លើយថា 'រឿងនេះ មិនមែនដូច្នេះទេ ។ ព្រោះលោក បានពោលសេចក្តីនេះទុកហើយ ថា 'ឈ្មោះថា សូម្បីការចូលទៅ ប្រកបនូវសុរានោះ រមែងមិនមាន ដល់ព្រះអរិយៈទាំងឡាយនោះ ការធ្វើកិច្ច នឹងមានមកពីណាបាន' ។ ក៏ប្រសិនបើការប្រកបសុរា នោះ គប្បីមាន ក្នុងពេលខ្លះ ដោយអំណាច នៃការកំណត់ដែល មិនសមគួរ, សូម្បីជាដូច្នោះ សុរានោះ ក៏ឈ្មោះថា មិនអាចដើម្បី នឹងធ្វើមគ្គបញ្ញានោះ ឲ្យចុះថយកម្លាំង សូម្បីបន្តិចបន្តួចបានឡើយ ព្រោះភាវៈនៃមគ្គបញ្ញានោះ តាំងនៅខ្ជាប់ខ្ជួនហើយ ដោយភាព ជាគុណជាតធ្ងន់ យ ចាកធម៌ដែលជាសឹកសត្រូវ ដោយត្រឹមត្រូវពិត ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**មគ្គប្បញ្ញម្បន ទុព្ពលំ កាតុំ ន សក្កា**' ដូច្នេះ ។ ក៏គប្បីឃើញសន្និដ្ឋាន ក្នុង អធិការនៃការធ្វើបញ្ញា ឲ្យមានកម្លាំងខ្លិនថយនេះ ដោយធម៌ជា ប្រធាន គឺមគ្គបញ្ញាថា 'ភាវៈនៃសុរាជាធម្មជាតិមិនអាច ក្នុងការ ញ៉ាំងបញ្ញាដែលជាលោកិយៈ និង លោកុត្តរៈ សូម្បីទាំងអស់ របស់

ព្រះអរិយៈទាំងឡាយ ឱ្យដល់នូវភាពជាគុណជាតមានកម្លាំងចុះថយ បាន គឺព្រះអដ្ឋកថាចារ្យ សំដែងទុកហើយ ។ ដល់រមែង សម្រេច ដោយធម្មជាតនុ៎ះឯង ហេតុនោះ ធម្មជាតនុ៎ះ ឈ្មោះថា ជាគ្រឿងដល់ គឺ ជាហេតុ ” ។

ក័កុម្ភជាតក បណ្ឌិតគប្បីត្រួតមើល ក្នុងគីសនិទាត ។

(១៩៣) ចេតនាជាហេតុបង្កពៀរ ឈ្មោះថា ជាអពមង្គល ព្រោះជាហេតុនាំមកនូវអនិដ្ឋផល មានទុក្ខដែលប្រព្រឹត្តទៅ ក្នុងអបាយជាដើម ដោយប្រការដូច្នេះ ។ ចំណែក ចេតនាជាហេតុវៀរចាកពៀរ ឈ្មោះថា ជាមង្គល ព្រោះខុសផ្សេងអំពីគ្នា ចាកចេតនាជាហេតុបង្កពៀរនោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាថា “ការវៀរនិង ការវៀរស្រឡះ ចាកបាបនោះ សូម្បីទាំងអស់នុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ‘ឈ្មោះថា ជាមង្គល’ ព្រោះជាហេតុនៃការលះបង់ មានការលះបង់ភ័យ និង ពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និង ប្រព្រឹត្តទៅ ក្នុងសម្បរាយិកភពជាដើម និង ជាហេតុនៃការបាន សម្រេចនូវគុណវិសេសផ្សេង ។ ។ ក៏ព្រោះហេតុដែលបុគ្គលអ្នកផឹកទឹកស្រវឹង រមែងមិនដឹងអត្ថ មិនដឹងធម៌ រមែងធ្វើសេចក្តីអន្តរាយ ដល់មាតា ដល់បិតា រមែងធ្វើសេចក្តីអន្តរាយ សូម្បី

ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវ័ក របស់ព្រះតថាគតទាំងឡាយ, រមែងដល់នូវការតិះដៀល ក្នុងបច្ចុប្បន្ន រមែងដល់នូវទុគ្គតិ ក្នុងសម្បរាយភព រមែងដល់នូវភាពជាអ្នកឆ្កួត ក្នុងភពជាបន្តៗទៅ, ចំណែក ការសង្រួម ចាកការផឹកនូវទឹកស្រវឹង រមែងដល់នូវការស្ងប់រម្ងាប់ទោសទាំងឡាយនោះ និងគុណសម្បត្តិដែលខុសផ្សេងពីគ្នាអំពីទោសនោះ ព្រោះហេតុនោះ ការសង្រួម ចាកការផឹកទឹកស្រវឹងនេះ បណ្ឌិតគប្បីជ្រាបថា 'ជាមង្គល' ដូច្នេះ" ។

(១៩៤) មែនពិត សូម្បីព្រះមានព្រះភាគកាលទ្រង់សំដែងធម៌ដល់អនាថបិណ្ឌិកៈ ទ្រង់ត្រាស់ទុក ក្នុងបឋមភយសូត្រ ក្នុងវគ្គទី ៤ នៃនិទានវគ្គ យ៉ាងដូច្នេះថា "ភ័យ ពៀរទាំងឡាយ ៥ យ៉ាង ដូចម្តេចខ្លះ រមែងស្ងប់រម្ងាប់ហើយ ? ។ ម្នាលគហបតី បុគ្គលអ្នកសម្លាប់សត្វ រមែងបាននូវភ័យ នូវពៀរ ជាបច្ចុប្បន្នផង រមែងបាន នូវភ័យ នូវពៀរទៅខាងមុខផង រមែងទទួល នូវទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យ គឺការសម្លាប់សត្វ ឯណា, ភ័យ ពៀរនោះ របស់បុគ្គលអ្នកវៀរចាកបាណាតិបាតបានហើយ រមែងស្ងប់រម្ងាប់ហើយ ដោយប្រការយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកកាន់យករបស់ដែលគេមិនបានឲ្យ រមែងបាននូវភ័យ នូវពៀរឯណា . . . ព្រោះបច្ច័យ គឺអទិន្នាទាន . . .

ម្នាលគហបតី បុគ្គលអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ រមែងបាននូវភ័យ នូវពៀរឯណា . . . ព្រោះបច្ច័យ គឺការប្រព្រឹត្តិខុស ក្នុងកាមទាំងឡាយ . . . ម្នាលគហបតី បុគ្គលអ្នកនិយាយកុហក រមែងបាននូវភ័យ នូវពៀរឯណា . . . ព្រោះបច្ច័យ គឺ មុសាវាទ . . . ម្នាលគហបតី បុគ្គលអ្នកផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីធ្វេសប្រហែស រមែងបាននូវភ័យ នូវពៀរឯណា ជាបច្ចុប្បន្នផង បាននូវភ័យ នូវពៀរទៅខាងមុខផង បានទទួលនូវទុក្ខ ទោសមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យ គឺសុរាមេរយមជ្ជប្បមាទដ្ឋាន, ភ័យ ពៀរនោះ របស់បុគ្គលអ្នកវៀរ ចាកសុរាមេរយមជ្ជប្បមាទដ្ឋានហើយ រមែងស្ងប់រម្ងាប់អស់ហើយ ដោយប្រការយ៉ាងនេះ ។ ភ័យ ពៀរទាំងឡាយ ៥ យ៉ាងនេះ រមែងស្ងប់រម្ងាប់អស់ហើយ" ។

(១៩៥) អដ្ឋកថាបឋមភយសូត្រនោះថា "បណ្តាបទទាំងនោះ ២ បទថា '**ភយានិ វេរានិ**' បានដល់ ចេតនាអ្នកបង្ក ភ័យ និងពៀរទាំងឡាយ ។ បទថា '**បាណាតិបាតប្បច្ចយា**' គឺ ព្រោះកម្ម គឺបាណាតិបាតជាហេតុ ។ ២ បទថា '**ភយំ វេរំ**' ដោយសេចក្តី គឺជាបទតែមួយ ។ ក៏ធម្មតាពៀរន៉ុះ មាន ២ យ៉ាង គឺ ពៀរខាងក្រៅ ១ ពៀរខាងក្នុង ១ ។ មែនពិត បិតារបស់បុរស

ម្នាក់ ជាអ្នកត្រូវបុរសម្នាក់សម្លាប់ហើយ ។ បុរសនោះ គិតថា 'បានឮថា បិតារបស់អញ ត្រូវបុរសនុ៎ះ សម្លាប់ហើយ, សូម្បីអញ ក៏នឹងសម្លាប់បុរសនោះផងដែរ' ដូច្នេះហើយ ក៏កាន់យកសស្ត្រាដែលសំលៀងហើយ ដើរទៅ ។ ចេតនាអ្នកចង្កៀរ ដែលកើតឡើងហើយ ក្នុងសណ្ដានរបស់បុរសនោះ ឯណា, ចេតនាកម្មនេះ ឈ្មោះថា ពៀរខាងក្រៅ ។ ចំណែក ចេតនារបស់បុរសក្រៅអំពីនេះ ឯណា ថា 'បានឮថា បុរសនេះ រមែងគ្រាច់ទៅ ដោយប្រាថ្នាថា 'នឹងសម្លាប់អញ' ដូច្នេះ, អញនេះឯង នឹងសម្លាប់បុរសនោះ ឱ្យបានមុន' ដូច្នេះ រមែងកើតឡើង, ចេតនាកម្មនេះ ឈ្មោះថា ពៀរខាងក្នុង ។ សូម្បីពៀរទាំង ២ យ៉ាងនេះ ក៏ជាពៀរដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នប៉ុណ្ណោះ ជាមុនសិន ។ ចំណែក ចេតនា របស់នាយនិរយបាល អ្នកឃើញនូវបុរសនោះ ដែលកើតក្នុងនរកហើយ ចាប់ជំពង់ដែកដែលឆេះសន្ធោសន្ធៅហើយ ដោយគិតថា 'អញនឹងប្រហារនូវបុរសនុ៎ះ' ដូច្នេះ ឯណា រមែងកើតឡើង, ចេតនាកម្មនេះ របស់នាយនិរយបាលនោះ ឈ្មោះថា ពៀរខាងក្រៅ ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ។ ចេតនាឯណា របស់សត្វនរកនោះ ថា 'នាយនិរយបាលនេះ កំពុងដើរមក ដោយគិតថា 'នឹងប្រហារអញអ្នកមិនមានទោស' ដូច្នេះ, អញនេះឯង

នឹងប្រហារបុរសនោះ ឲ្យបានមុន' ដូច្នេះ រមែងកើតឡើង, ចេតនាកម្មនេះ របស់សត្វនរកនោះ ឈ្មោះថា ពៀរខាងក្នុង ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ។ ក៏ពៀរខាងក្រៅនេះ ឯណា, ពៀរខាងក្រៅនោះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាថា 'ពៀររបស់បុគ្គល' ។ ២ បទថា **'ទុក្ខំ ទោមនស្សំ'** ដោយសេចក្តី គឺបទតែមួយនុ៎ះឯង ។ ក៏សេចក្តី ក្នុងបាទទី ១ នេះ ខ្ញុំបានពោលទុកហើយ យ៉ាងណា, សេចក្តី សូម្បីក្នុងបទដែលសេសសល់ទាំងឡាយ បណ្ឌិតក៏គប្បីជ្រាប យ៉ាងដូច្នោះដែរ ។ កិរិយាកើតឡើងនៃពៀរ បណ្ឌិតគប្បីជ្រាប ដោយន័យជាអាទិ៍ថា 'ភ័ណ្ឌៈរបស់អញ ត្រូវបុរសនេះ លួចយកហើយ, ភាពជាអ្នកប្រព្រឹត្តកន្លងក្នុងកិរិយា និងបុត្រទាំងឡាយ របស់អញ ត្រូវបុរសនេះ ដល់ហើយ, ប្រយោជន៍ របស់អញ ត្រូវបុរសនេះ ពោលមុសា កាច់ចំផ្លាញហើយ, កម្មឈ្មោះនេះ គឺបុគ្គលអ្នកស្រវឹងហើយ ព្រោះស្រវឹងសុរា បានធ្វើហើយ' ដូច្នេះ " ។

(១៩៦) ដីកាបឋមភយសូត្រនោះ ថា " ចេតនាទាំងឡាយដែលនាំភ័យ និងពៀរមកឲ្យ ឈ្មោះថា ចេតនាអ្នកបង្កភ័យនិងពៀរទាំងឡាយ ។ ម្យ៉ាងទៀត ចេតនាទាំងឡាយ ដែលបានឈ្មោះថា ភ័យ ព្រោះអត្ថថា គឺបុគ្គលគប្បីខ្លាច, ដែលបានឈ្មោះថា ពៀរ

ព្រោះអត្ថថា ជាហេតុឲ្យប្រសព្វនូវពៀរ ។ មែនពិត បាបធម៌ទាំង
ឡាយមានបាណាតិបាតជាដើម រមែងប្រព្រឹត្តទៅ ដល់បុគ្គលណា
និង ដែលបុគ្គលឲ្យប្រព្រឹត្តទៅ ចំពោះបុគ្គលឯណា រមែងជាបាប
ធម៌នាំភ័យ និងពៀរមកឲ្យ ដល់បុគ្គលទាំង ២ ពួកនោះ, ព្រោះជា
បាបធម៌ដែលនាំភ័យ និងពៀរមកឲ្យនោះឯង ទើបជាបាបធម៌ដែល
បុគ្គលគប្បីខ្លាច និងញុាំងពៀរឲ្យកើតឡើង ដូច្នេះ ។ បទថា
'**បាណាតិបាតកម្មការណា**' គឺ ព្រោះធ្វើកម្មដ៏លាមក ពោលគឺ
បាណាតិបាតជាហេតុ ។ សេចក្តីក្រោធខឹង ព្រះមានព្រះភាគ ទ្រង់
ត្រាស់ហៅថា ពៀរ ។ ពៀរនោះឯង ឈ្មោះថា ភ័យ ព្រោះភាព
ជាពៀរដែលបុគ្គលគប្បីខ្លាច ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ
ពោលថា '**ភយំ វេរន្តិ អត្ថតោ ឯកំ**' ដូច្នេះ ។ ពៀរនេះ
ឈ្មោះថា ពៀរខាងក្រៅ ព្រោះជាពៀរខាងក្រៅ ចាកបុគ្គលអ្នក
បង្កពៀរ ដែលជាមូលហេតុ នៃពៀរនោះ, ព្រោះហេតុនោះឯង
ទើបព្រះអដ្ឋកថាចារ្យ ពោលសំដៅយកពៀរដែលកើតឡើងហើយ
ដល់បុគ្គលអ្នកបង្កពៀរនោះថា '**ឥទំ អជ្ឈត្តិកវេរំ នាម**' ដូច្នេះ ។
អធិប្បាយថា 'ចេតនា រមែងកើតឡើង ដល់បុគ្គលអ្នកបង្កពៀរ
ដែលជាមូលហេតុនៃពៀរ ដែលអាស្រ័យពៀរខាងក្រៅនោះ សូម្បី
ជាអ្នកមិនអាច ដើម្បីនឹងប្រហារបាន' ។ មែនពិត ពួកសត្វនរក

ទាំងឡាយ នឹងមិនអាច ដើម្បីនឹងប្រហារគប ពួកនាយនិរយបាល បានឡើយ ។ ដោយបទថា '**និរយបាលស្ស ចេតនា ឧប្បជ្ជតិ**' ដូច្នេះនេះ ព្រះអដ្ឋកថាចារ្យសំដែងថា 'ក្នុងនរកមាននាយនិរយបាលពិតមែន' ដូច្នេះ ។ ពាក្យថា '**យម្បនេតំ ពាហិរវេរំ**' មានសេចក្តីថា ពៀរខាងក្រៅនេះ ឯណា ជាពៀរដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះផង ដែលប្រព្រឹត្តទៅក្នុងសម្បរាយភពផង, ពៀរខាងក្រៅនោះ ព្រះអដ្ឋកថាចារ្យ ពោលហើយថា 'ពៀរបស់បុគ្គល' ។ បទថា '**សេសបទេសុ**' បានដល់ ក្នុងចំណែកដែលសេសសល់ទាំងឡាយ ដែលមកហើយ ដោយនัยជាដើមថា '**អទិន្នាទាយី**' ដូច្នេះ ។ បទថា '**ភគ្គោ**' គឺ ប្រយោជន៍ គឺបុគ្គលនេះ ធ្វើឲ្យវិនាសហើយ" ។

ក៏បឋមកយសូត្រនុ៎ះឯង លោកបានចងក្រងទុកហើយ ក្នុងទសកនិបាត អង្គុត្តរនិកាយ ដោយឈ្មោះថា វេរសូត្រ, ព្រោះហេតុនោះ បឋមកយសូត្រនោះ អ្នកសិក្សាទាំងឡាយ គប្បីត្រួតមើលសូម្បីក្នុងទសកនិបាត អង្គុត្តរនិកាយនោះផង ។

(១៩៧) ចេតនាអ្នកបង្កពៀរទាំង ៥ យ៉ាង គឺបុគ្គលគប្បីភ័យខ្លាច ដោយប្រការដូច្នេះ ព្រោះហេតុនោះ បុគ្គលអ្នកភ័យខ្លាច គប្បីវៀរចាកពៀរទាំង ៥ យ៉ាងនោះឲ្យបាន ។ ព្រោះថា បុគ្គលកាលធ្វើ យ៉ាងដូច្នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា "ឈ្មោះថា

រមែងភ័យខ្លាច តែរបស់ដែលគួរភ័យខ្លាច" និងថា "ឈ្មោះថា រមែងជាអ្នកមិនរង្វេងរង្វន់" ។ ចំណែក បុគ្គលណា តែងភ័យខ្លាចតែរបស់ដែលមិនគួរភ័យខ្លាច, បុគ្គលនោះ ឈ្មោះថា ជាអ្នករង្វេងរង្វន់ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាព្រាហ្មណធម្មិកសូត្រ ក្នុងទុតិយវគ្គ នៃសុត្តនិបាត ថា "បានឮថា សត្វទាំងឡាយ ៤ ពួក គឺ សត្វជន្លេន សត្វត្រដេវវិច សត្វក្រៀល ព្រាហ្មណ៍ រមែងភ័យខ្លាចនូវរបស់ដែលមិនគួរខ្លាច" ។

(១៩៨) បានឮថា សត្វជន្លេនទាំងឡាយ ជាសត្វមានប្រក្រតីស៊ីដី (តែ) មិនស៊ីដីច្រើន ព្រោះភ័យខ្លាចមហាប្រឹថពីនឹងអស់ទៅ ។ ពួកសត្វត្រដេវវិចទាំងឡាយ រមែងដេកផ្ងារលើស៊ុត ព្រោះភ័យខ្លាចក្រែងអាកាស (មេឃ) រលំសង្កត់លើ ។ ពួកសត្វក្រៀល រមែងមិនយកជើងទាំង ២ ជាន់ផែនដី ដោយស្រួលទេ ព្រោះភ័យខ្លាចក្រែងផែនដីនឹងកម្រើករញ្ជួយ ។ ពួកព្រាហ្មណ៍ទាំងឡាយ រមែងស្វែងរកនូវភរិយា ព្រោះភ័យខ្លាចនូវការបាត់បង់រង្សត្រកូល ។ ក្នុងរឿងនៃសត្វដែលភ័យខ្លាច ក្នុងហេតុដែលមិនគួរភ័យខ្លាចនេះ បូរាណាចារ្យទាំងឡាយ ពោលថា÷

"ជនទាំងឡាយ (សត្វ) ដែលរង្វេងរង្វន់ ៤ ពួក

នេះ គឺ សត្វជន្លេន ១ សត្វត្រដេវវិច ១ សត្វ
ក្រៀល ១ ព្រាហ្មណ៍អ្នកប្រកាន់ខ្ជាប់នឹងទំនៀម ១
រមែងភ័យខ្លាច នូវរឿងដែលមិនគួរភ័យខ្លាច" ។

(១៩៩) ព្រោះហេតុនោះ បុគ្គលមិនត្រូវជាអ្នកវង្វេងវង្វន់
គប្បីលះបង់នូវពៀរហើយ សមាទាន ចេតនាជាហេតុបណ្តេញ នូវ
ពៀរ ។ ព្រោះថា បុគ្គលកាលធ្វើ យ៉ាងដូច្នេះ ឈ្មោះថា ជាអ្នក
មានសីល ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែង
ធម៌ ដល់អនាថបិណ្ឌិកៈ ទើបទ្រង់ត្រាស់ទុក ក្នុងវេរសូត្រ ក្នុង
ឧបាសកវគ្គ ក្នុងចតុត្ថបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយថា ÷

"នរៈណា សម្លាប់សត្វផង និយាយពាក្យកុហកផង
កាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង
ក្បត់នឹងប្រពន្ធជនដទៃផង, មួយទៀត នរៈណា
ប្រកបរឿយ ៗ នូវការផឹកសុរា និងមេរ័យ, នរៈអ្នក
មិនលះបង់ពៀរទាំង ៥ យ៉ាងនោះ បណ្ឌិតហៅថា
'ជាអ្នកទ្រុស្តសីល' 'ជាអ្នកអ័ប្បឥតបញ្ញា' លុះ
បែកធ្លាយរាងកាយទៅ រមែងទៅកើតក្នុងនរក ។
នរៈណា មិនសម្លាប់សត្វ មិននិយាយពាក្យកុហក

មិនកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ក្នុងលោក មិនក្បត់នឹងប្រពន្ធនៃជនដទៃ និង មិនប្រកបរឿយៗ នូវការធឹកសុរានិងមេរ័យ, នរៈនោះ លះបង់ពៀរទាំង ៥ យ៉ាងបានហើយ បណ្ឌិតហៅថា 'ជាអ្នកមានសីល' 'ជាអ្នកប្រកបដោយបញ្ញា' លុះបែកធ្លាយរាងកាយទៅ រមែងទៅកើត ក្នុងសុគតិ"[1] ។

(២០០) បណ្តាគាថាទាំងនោះ កន្លះគាថា ខាងដើម មកហើយ ក្នុងមលវគ្គ នៃធម្មបទក៏មាន ។

នំយក្នុងអដ្ឋកថាធម្មបទ ថា " បទថា **'បាណំ'** បានដល់ ឥន្ទ្រីយ៍ គឺជីវិត របស់សត្វដទៃ ។ បទថា **'អតិមាបេតិ'** គឺ រមែងចូលទៅកាត់ផ្តាច់ ។ បទថា **'មុសាវាទំ'** គឺ នូវពាក្យមុសា ដែលបំផ្លាញនូវប្រយោជន៍របស់ជនដទៃ ។ បទថា **'លោកេ'** បានដល់ ក្នុងសត្វលោក ។ ២ បទថា **'អទិន្នំ អាទិយតិ'** មានសេចក្តីថា រមែងកាន់យក គឺរមែងលួចយក នូវរបស់ដែលអ្នកដទៃមិនបានឲ្យហើយ ដោយកាយនិងវាចា គឺ ដែលអ្នកដទៃហួងហែងរក្សាហើយ ។ បទថា **'បរទារំ'** បានដល់ នូវទារៈ គឺភរិយារបស់បុរសដទៃ ។ បទថា **'គច្ឆតិ'** បានដល់ រមែងចូលទៅគប់

---

๑ ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ១៥៥

រក ដោយអំណាចការប្រព្រឹត្តកន្លង ។ អធិប្បាយថា 'រមែងខុស ក្នុងភណ្ឌៈដែលជាទារៈរបស់បុរសជទៃ គឺ ក្នុងភណ្ឌៈដែលអ្នកជទៃ រក្សាគ្រប់គ្រងហើយ' ។ បទថា **'សុរាមេរយបានំ'** បានដល់ ការផឹកសុរានិងមេរ័យ ។ បទថា **'អនុយុញ្ជតិ'** បានដល់ រមែង សេព គឺ រមែងធ្វើឲ្យច្រើន" ។

(២០១) ព្រោះហេតុដែលព្រះអដ្ឋកថាទាំងឡាយ ពោលទុកហើយ ក្នុងពួកនៃធាតុ មាន **ចុរ** ធាតុជាដើមថា "**មាប** ធាតុ ប្រព្រឹត្តទៅ ក្នុងការកសាង ដូចជាឧទាហរណ៍ថា '**បណ្ណសាលំ មាបេតិ** បុគ្គលរមែងកសាងនូវបណ្ណសាលា" ដូច្នេះខ្លះ, ថា '**យោ បាណមតិមាបេតិ** នរជនណា រមែងចំផ្លាញសត្វមានជីវិត" ដូច្នេះខ្លះ ។ ព្រោះហេតុនោះ បាឋៈថា "**មាបេតិ**" ដូច្នេះឯង ទើបសមគួរជាង ។

ចំណែក បុគ្គលណា មិនភ័យខ្លាច អំពីពៀរ រមែងធ្វើនូវ ពៀរនោះ ជារឿយៗ, បុគ្គលនោះ រមែងបានជួបប្រទះ នូវទុក្ខ មានទុក្ខដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នជាដើម ។

ក្នុងការទទួលទុក្ខនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

(រឿងនាយគោឃាតក៍)

(២០២) បានឮថា ក្នុងក្រុងសាវត្ថី អ្នកសម្លាប់គោម្នាក់ឈ្មោះ

នន្ទ: ធ្វើកម្មរបស់អ្នកសម្លាប់គោ ចិញ្ចឹមជីវិត ដោយការលក់សាច់ អស់រយៈពេល ៥៥ ឆ្នាំ ក្នុងមួយថ្ងៃ មិនដែលប្រគេនយាគូ ឬ ភ័ត្ត សូម្បីត្រឹមតែមួយវែក ដល់ព្រះពុទ្ធ ឬព្រះសាវ័កសោះ ។ ក៏ នាយគោឃាតក៍នោះ ប្រាស់ចាកសាច់ហើយ ក៏មិនបរិភោគ (អាហារ ដែរ) ។ ព្រោះហេតុនោះ ក្នុងថ្ងៃមួយ គាត់លក់សាច់ដទៃទៀត ក្នុងពេលថ្ងៃ ហើយក៏បានឲ្យដុំសាច់មួយដុំ ដល់ភរិយា ដោយប្រាប់ ថា "ចូរនាងចំអិនសាច់មួយដុំនេះ ដើម្បីប្រយោជន៍ ដល់បង" ដូច្នេះហើយ ក៏បានដើរទៅ ដើម្បីងូតទឹក ។ ក្នុងគ្រានោះ សំឡាញ់ម្នាក់ របស់នាយគោឃាតក៍នោះ បានមកកាន់ផ្ទះ របស់គាត់ ហើយ និយាយថា "ចូរនាងឲ្យសាច់បន្តិច ដល់ខ្ញុំចុះ, ភ្ញៀវបាន មកដល់ផ្ទះរបស់ខ្ញុំ" ដូច្នេះ, កាលបើភរិយារបស់នាយនន្ទ:នោះ ពោលថា "សាច់ដទៃដែលគប្បីលក់ មិនមានទេ, ក៏សាច់មួយដុំនេះ ជាសាច់ដែលសំឡាញ់ របស់អ្នកគប្បីបរិភោគ" ដូច្នេះ, ទើបពោល ថា "ចូរនាងឲ្យសាច់នោះ ដល់ខ្ញុំចុះ" ដូច្នេះ, កាលភរិយានាយនន្ទ: នោះ មិនឲ្យក៏ដោយ, ក៏បានចាប់យកដុំសាច់នោះ ដោយពលការ ហើយ ក៏ចៀសចេញទៅ ។ នាយគោឃាតក៍ មកវិញ ស្តាប់នូវ សេចក្តីនោះហើយ ក៏ចាប់កាំបិត លូតដៃចូលក្នុងមាត់គោមួយ ដែល ឈរនៅខាងក្រោយផ្ទះ ហើយក៏ទាញយកអណ្តាត ចេញមកក្រៅ

ហើយកាត់យកទៅអាំង លើរងើកភ្លើង ប្រារព្ធដើម្បីនឹងបរិភោគ ។ ក្នុងខណៈគ្រាន់តែនាយនន្ទៈនោះ បរិភោគដុំភ័ត្តមួយដុំហើយ ដាក់ដុំសាច់មួយដុំ ក្នុងមាត់ន៉ុះឯង អណ្តាតក៏ដាច់ធ្លាក់ទៅ ក្នុងថាសនៃភ័ត្តហើយ ។ នាយនន្ទៈនោះ បាននូវវិបាកដែលឃើញសមនឹងកម្ម (ដែលខ្លួនបានធ្វើ) ក្នុងខណៈនោះឯង ដោយប្រការដូច្នេះ ។ ក៏គោនោះឯង មានលោហិតហូរចេញ អំពីមាត់ហើយ ក៏ស្លាប់ ក្នុងទីនោះតែម្តង ។ ឯនាយគោឃាតក៏នោះសោតដើរស្រែករោទ៍ត្រង់កណ្តាលផ្ទះ ដូចជាគោ ធ្វើកាលៈហើយ បានទៅកើត ក្នុងអវិចីនរក ។

រឿងនាយគោឃាតក៏ឈ្មោះនន្ទៈ មកក្នុងមលវគ្គ នៃធម្មបទ ។

សូម្បីរឿងនាយចុន្ទសូករិក ក្នុងយមកវគ្គ នៃធម្មបទនោះ ដូចគ្នា បណ្ឌិតក៏គប្បីប្រមូលមក (ពោលជងដែរ) ។

(រឿងមតកភ័ត្តជាតក)

(២០៣) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រាហ្មណ៍ជាអាចារ្យទិសាបាមោក្ខ សម្លាប់សត្វពពែមួយហើយ បានថ្វាយនូវមតកភ័ត្ត ។ ព្រោះកម្មនោះ ព្រាហ្មណ៍នោះ ត្រូវកាត់ក្បាល ៤៩៩ អត្តភាព ក្នុងអត្តភាពជាគម្រប់ ៥០០ ក៏បានកើតជាពពែ របស់ព្រាហ្មណ៍ប្រាកដដូច្នោះឯង ។ ឯព្រាហ្មណ៍នោះ ក៏ប្រាថ្នាដើម្បី

នឹងធ្វើមតកកិត្ត ទើបប្រារព្ធដើម្បីសម្លាប់ពពែនោះ ។ ពពែរលឹកនូវកម្មដែលខ្លួនបានធ្វើហើយ ដោយញាណគ្រឿងរលឹកជាតិ សើចហើយ ក៏ស្រែកយំវិញទៀត ត្រូវព្រាហ្មណ៍សួរហើយ បានប្រាប់កម្មដែលខ្លួនបានធ្វើហើយ ពោលថា "ខ្ញុំមានចិត្តត្រេកអរហើយ ថា 'ក្នុងថ្ងៃនេះ អាត្មាអញ នឹងរួចចាកទុក្ខប្រាកដដូច្នេះ' ដូច្នេះ ទើបបានសើច, ខ្ញុំបែរមកស្រែកយំវិញ ព្រោះសេចក្តីអាណិត ចំពោះលោកថា 'សូម្បីព្រាហ្មណ៍នេះ សម្លាប់អញហើយ ក៏នឹងបានកាត់ក្បាល អស់ ៥០០ ជាតិ ដូចអាត្មាអញដែរ' ដូច្នេះ" ។ ព្រាហ្មណ៍ពោលថា "នែពពែ ចូរអ្នកកុំភ័យឡើយ, ខ្ញុំនឹងមិនសម្លាប់អ្នកទេ" ដូច្នេះ, កាលបើពពែពោលថា "កាលបើលោកសម្លាប់ខ្ញុំក្តី មិនសម្លាប់ខ្ញុំក្តី, ខ្ញុំក៏មិនអាច ដើម្បីនឹងរួចផុតអំពីសេចក្តីស្លាប់ ក្នុងថ្ងៃនេះ បានឡើយ" ដូច្នេះ, ទើបបានលែងពពែនោះទៅហើយគិតថា "អាត្មាអញ នឹងមិនឲ្យអ្នកណាមួយសម្លាប់ពពែនេះបានឡើយ" ដូច្នេះហើយ ក៏បាននាំពួកអន្តេវាសិក ដើរទៅជាមួយពពែនោះឯង ។ ចំណែក ពពែគ្រាន់តែព្រាហ្មណ៍លែងទៅហើយប៉ុណ្ណោះ ក៏ងើយកឡើង ត្រង់គុម្ពឈើដែលកើតអាស្រ័យផ្នាំងថ្មជាមួយដុំ ប្រារព្ធដើម្បីនឹងស៊ីស្លឹកឈើ ។ ក្នុងខណៈនោះឯង រន្ទះបានធ្លាក់ (បាញ់) ហើយលើផ្នាំងថ្មជានោះ ។ ចំណែកថ្មមួយដុំ បានបែកទៅកាត់ក

ដែលពពែ បានលាតចេញហើយ ។ ពពែនោះ បានធ្វើកាលៈហើយ ក្នុងទីនោះឯង ។

រឿងព្រាហ្មណ៍អ្នកសម្លាប់ពពែ មកក្នុងអដ្ឋកថាមតកភត្ត-ជាតក ក្នុងទុតិយវគ្គ នៃឯកនិបាត ។

ពណ៌នាអំពីរឿង ក្នុងតិណាតិបាត ចប់ ។

(សីលវិមំសជាតក)

(២០៤) ក្នុងទីក្រុងសាវត្ថី ព្រាហ្មណ៍ម្នាក់ ឈ្មោះថា សីលវិមំសកៈ ជាអ្នកដល់នូវសរណៈ ៣ មានសីល ៥ មិនធ្លុះធ្លាយ អាស្រ័យព្រះរាជាព្រះនាមកោសល ចិញ្ចឹមជីវិត ។ ព្រះរាជទ្រង់ធ្វើការរាប់អាន ដល់ព្រាហ្មណ៍នោះ ព្រមទាំងព្រាហ្មណ៍ឯទៀត ដោយទ្រង់ព្រះតម្រិះថា "ព្រាហ្មណ៍នេះ ជាអ្នកមានសីល" ។ ក្នុងថ្ងៃមួយ ព្រាហ្មណ៍នោះ គិតថា "ព្រះរាជាទ្រង់អាស្រ័យការដល់ព្រម ដោយជាតិ គោត្រ ត្រកូល ប្រទេស និងសិល្បៈ របស់អាត្មាអញហើយ ទើបទ្រង់ធ្វើនូវសេចក្តីរាប់អាន ឬក៏ ទ្រង់អាស្រ័យនូវការដល់ព្រម ដោយសីល (របស់អាត្មាអញ) ទើបទ្រង់ធ្វើឬហ្ន៎ ?, អាត្មាអញ នឹងសាកល្បងមើល" ដូច្នេះហើយ ក៏ទៅកាន់ទីចំរុង នៃព្រះរាជាកាលនឹង (ត្រឡប់) ទៅផ្ទះ មិនបានលាសោះឡើយ បានយកទ្រព្យ

មួយកហាបណៈ អំពីបន្ទះក្តារ របស់ហិរញ្ញិកម្នាក់ ទៅហើយ ។ ហិរញ្ញិក មិននិយាយពាក្យអ្វីៗឡើយ អង្គុយ (នៅស្ងៀម) ព្រោះសេចក្តីគោរព ចំពោះព្រាហ្មណ៍ ។ ក្នុងថ្ងៃទី ២ ព្រាហ្មណ៍នោះ បានយកទ្រព្យ ២ កហាបណៈ ។ ហិរញ្ញិកក៏បានអត់ទ្រាំ យ៉ាងដូច្នោះដែរ ។ ក្នុងថ្ងៃទី ៣ ព្រាហ្មណ៍នោះ ក៏បានយកកហាបណៈមួយក្តាប់ដៃ ។ ហិរញ្ញិក ក្រោធខឹងហើយ ស្រែកប្រាប់ ៣ ដង ថា "ខ្ញុំចាប់ចោរដែលប្លន់ទ្រព្យបានហើយ" ។ មនុស្សទាំងឡាយ បាននាំគ្នាមក អំពីទីនុ៎ះផង ទីនេះផង ពោលថា "ឥឡូវនេះ អ្នកធ្វើដូចជាអ្នកមានសីល ត្រាច់ទៅហើយ អស់កាលដ៏យូរ" ដូច្នេះហើយ ក៏ឱ្យការប្រហារ ២ - ៣ ដង ចងហើយ បានសំដែងដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់មានព្រះវិប្បដិសារី ទ្រង់មានព្រះរាជឱង្ការថា "នែព្រាហ្មណ៍ ព្រោះហេតុអ្វី ទើបអ្នកធ្វើកម្ម នៃបុគ្គលអ្នកទ្រុស្តសីល យ៉ាងដូច្នេះ ?" ហើយ ទ្រង់ត្រាស់បញ្ជាថា "អ្នកទាំងឡាយចូរទៅ, ចូរធ្វើរាជអាជ្ញាដល់ព្រាហ្មណ៍នោះចុះ" ។ ព្រាហ្មណ៍ បានក្រាបទូលថា "បពិត្រព្រះមហារាជ ទូលព្រះបង្គំមិនមែនជាចោរទេ, តាមពិត ទូលព្រះបង្គំ បានធ្វើហើយ យ៉ាងនេះព្រោះហេតុនេះ" ដូច្នេះហើយ ក្រាបទូលថា "ឥឡូវនេះ ទូលព្រះបង្គំ បានដឹងហើយ ដោយច្បាស់លាស់ថា 'ព្រះអង្គទ្រង់អាស្រ័យ

សីលប៉ុណ្ណោះ ទើបទ្រង់ធ្វើសេចក្តីរាប់អាន ដល់ទូលព្រះបង្គំ, មិនមែនទ្រង់អាស្រ័យជាតិជាដើមធ្វើឡើយ' ហើយ បានក្រាបទូលថា "ពិតមែនដូច្នោះ ឥឡូវនេះ ព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យធ្វើព្រះរាជអាជ្ញា ដល់ទូលព្រះបង្គំ, ដោយហេតុនេះ ទូលព្រះបង្គំនោះ ទើបដល់នូវការសន្និដ្ឋានថា 'ក្នុងលោកនេះ សីលប៉ុណ្ណោះ ប្រសើរបំផុត, សីលជាប្រធាន' ដូច្នេះ, មួយទៀត ទូលព្រះបង្គំកាលធ្វើនូវកម្មដែលសមគួរដល់សីលនេះ ស្ថិតនៅក្នុងផ្ទះ បរិភោគនូវកិលេសទាំងឡាយ នឹងមិនអាច ដើម្បីធ្វើបានឡើយ" ដូច្នេះហើយ ក្រាបទូលសុំព្រះរាជានុញ្ញាតថា "ក្នុងថ្ងៃនេះឯង ទូលព្រះបង្គំនឹងបួស ក្នុងសំណាក់នៃព្រះសាស្តា, បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះរាជទាននូវបព្វជ្ជា ដល់ទូលព្រះបង្គំផង" ដូច្នេះហើយ ក៏បានទៅកាន់វត្តជេតពន សូមបព្វជ្ជា នឹងព្រះសាស្តា បានហើយនូវបព្វជ្ជានិងឧបសម្បទ មិនលះបង់កម្មដ្ឋានហើយ ចំរើនវិបស្សនាបានសម្រេចហើយ នូវព្រះអរហត្ត ។ ក៏ការវាយហើយចងនូវព្រាហ្មណ៍នោះឯណា, ការវាយហើយចងនោះ បណ្ឌិតគប្បីឃើញថា "ជាផលនៃអទិន្នាទាន" ។

រឿងព្រាហ្មណ៍ មកហើយ ក្នុងអដ្ឋកថាសីលវិមំសជាតក ក្នុងនវមវគ្គ នៃឯកនិបាត ។

សូម្បីរឿងដែលកន្លងទៅហើយ ក្នុងនវមវគ្គ នៃឯកនិបាត នោះដូចគ្នា បណ្ឌិតក៏គប្បីប្រមូលមក (ពោលផងដែរ) ។

(រឿងតាបសកុហក)

(២០៥) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានតាបសកុហក ១ រូប ចូលទៅអាស្រ័យស្រុកមួយ នៅក្នុងបណ្ណសាលា ដែលកុដុម្ពីក៍ម្នាក់សាងប្រគេន ក្នុងព្រៃ តែងអាន់ជាប្រចាំ ក្នុងផ្ទះរបស់កុដុម្ពីក៍នោះ ។ កុដុម្ពីក៍ជឿថា "តាបសនេះ ជាអ្នកមានសីល" ព្រោះខ្លាចចោរ ទើបនាំយកមាស ១០០ និក្ខៈ ទៅកាន់បណ្ណសាលានៃតាបសនោះ បានកប់ទុកក្នុងផែនដីហើយ ពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ជួយមើលទ្រព្យនេះផង" ។ តាបសតបថា "នែអាវុសោ ធម្មតាពួកបព្វជិត ធ្វើយ៉ាងនេះ រមែងមិនសមគួរ, ឈ្មោះថា ការចង់បាន ក្នុងទ្រព្យរបស់អ្នកដទៃ រមែងមិនមាន ដល់ពួកអាត្មាទេ្បីយ" ។ កុដុម្ពីក៍នោះ ពោលថា "ប្រពៃណាស់" ហើយក៏គេចចេញទៅ ។ តាបសកុហក បានគិតថា អាត្មាអញ អាចចិញ្ចឹមជីវិត ដោយមាសមានប្រមាណប៉ុណ្ណោះបាន" ដូច្នេះ បានញុំាងពេលវេលាឱ្យកន្លងទៅបាន ២-៣ ថ្ងៃហើយ ទើបលួចយកមាសនោះ ទៅលាក់ទុក នៅក្នុងទីកន្លែងមួយ ក្នុងចន្លោះ

ផ្លូវ មកហើយ ក្នុងថ្ងៃស្អែកឡើង ធ្វើភ័ត្តកិច្ច ក្នុងផ្ទះរបស់កុដុម្ពីក៍
នោះ ហើយពោល ថា "ម្នាលអ្នកដ៏មានអាយុ អាត្មាភាព អាស្រ័យ
ពួកអ្នក នៅយូរណាស់ហើយ, ក៏កាលបើពួកបព្វជិតទាំងឡាយនៅ
ក្នុងទីកន្លែងមួយ យូរហួសពេក, ការជាប់ជំពាក់ ជាមួយពួកមនុស្ស
រមែងមាន, ក៏ធម្មតាការជាប់ជំពាក់ ជាមន្ទិល របស់បណ្ឌិតទាំង
ឡាយ, ព្រោះហេតុនោះ អាត្មាភាព នឹងទៅ" ដូច្នេះ សូម្បីត្រូវ
កុដុម្ពីក៍នោះ សុំអង្វរហើយអង្វរទៀត ក៏មិននៅ ទៅបានបន្តិច
ហើយគិត ថា "ការដែលអាត្មាអញបញ្ឈោតកុដុម្ពីក៍នេះ ទើបគួរ"
ហើយ ដាក់ស្មៅ ត្រង់ចន្លោះនៃជដា ត្រឡប់មកវិញ ។ កុដុម្ពីក៍
សួរថា "បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី បានជាលោកម្ចាស់ត្រឡប់
មកវិញ ?" ។ តាបសតបថា "ម្នាលអាវុសោ ស្មៅមួយសរសៃ
(ជ្រុះ) អំពីដំបូលផ្ទះ របស់អ្នក ជាប់នៅក្នុងជដា របស់អាត្មាភាព,
អាត្មាភាព ជាអ្នកមកហើយ ដោយគិតថា 'ឈ្មោះថា អទិន្នាទាន
រមែងមិនសមគួរ ដល់បព្វជិតទាំងឡាយ' ដូច្នេះ" ។ កុដុម្ពីក៍
ពោលថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ចោល (វា) ហើយ
និមន្តទៅចុះ" ហើយ បានជ្រះថ្លាថា "ព្រះគុណម្ចាស់ របស់អញ
មិនកាន់យក នូវរបស់នៃជនដទៃ សូម្បីសរសៃនៃស្មៅ, ឱ! ព្រះ
គុណម្ចាស់របស់អញ ជាអ្នករង្កៀសមែន" ដូច្នេះហើយ ក៏ថ្វាយបង្គំ

ចញ្ជូនទៅហើយ ។ គ្រានោះ ព្រះពោធិសត្វទៅកាន់បច្ចន្តជនបទ ដើម្បីប្រយោជន៍ដល់កំណើៈ ទិញរបស់បរិភោគ ក្នុងផ្ទះនោះ បានឮពាក្យរបស់តាបសហើយ ក៏គិតថា "វត្ថុអ្វីមួយ របស់កុដុម្ពីក៍នេះ នឹងត្រូវបានតាបសអាក្រក់រូបនេះ លួចយកហើយ ដោយពិត" ហើយ បានសួរកុដុម្ពីក៍ ស្តាប់សេចក្តីនោះហើយ ពោលថា "ម្នាលសំឡាញ់ ចើដូច្នោះ ចូរអ្នកទៅឲ្យឆាប់ ចូរត្រួតមើលទ្រព្យដែលអ្នកកប់ទុកនោះ" ។ កុដុម្ពីក៍ បានទៅកាន់បណ្ណាសាលាហើយ មិនឃើញមាស ទើបប្រញាប់ត្រឡប់មកវិញហើយ ប្រាប់ថា "ម្នាលសំឡាញ់ កំណប់នោះ មិនមានទេ" ។ ជនទាំង ២ នាក់នោះ បានទៅតាមតាបសនោះ យ៉ាងប្រញាប់ ចាប់វាយទាត់ នូវតាបសកុហក ដោយដៃនិងជើង ឲ្យតាបសនោះ យកមាសមកឲ្យវិញហើយ ទទួលយកហើយ ។ ព្រះពោធិសត្វ ឃើញមាសហើយ ក៏តិះដៀលតាបសនោះថា "នែជដិលកោង អ្នកធ្វើសេចក្តីរង្កៀស ក្នុងសរសៃស្មៅមួយសរសៃ ជាអ្នកបានជាប់ជំពាក់ហើយ ក្នុងវត្ថុត្រឹមតែស្មៅប៉ុន្តែ មាស (របស់គេ) ១០០ និក្ខៈនេះ អ្នកលួចយកទៅ មិនមានជាប់ជំពាក់សោះឡើយ" ដូច្នេះហើយ ទើបឲ្យឱវាទថា "នែជដិលកោង ចូរអ្នកកុំធ្វើកម្មយ៉ាងដូច្នេះ តទៅទៀតឡើយ" ហើយលែងតាបសកុហកនោះហើយ ក៏ត្រឡប់ទៅ (ផ្ទះខ្លួន) វិញហើយ ។

រឿងតាបសកុហក មកក្នុងអដ្ឋកថាកុហកជាតក ក្នុងនវមវគ្គ នៃឯកនិបាតនោះដូចគ្នាដែរ ។

ពណ៌នាអំពីរឿង ក្នុងអទិន្នាទាន ចប់ ។

(ទោសនៃការប្រព្រឹត្តិខុសក្នុងកាម)

(២០៦) ក្នុងអតីតកាល ព្រះរាជឱរស ៤ ព្រះអង្គ ក្នុងក្រុងសាវត្ថី ប្រព្រឹត្តខុស ក្នុងមាតុគ្រាមដែលជនដទៃរក្សាគ្រប់គ្រង ហើយ លេងសប្បាយតាមទំនើងចិត្ត ធ្វើបាបកម្មជាច្រើន ធ្វើកាលៈហើយ ក៏បានទៅកើត ក្នុងលោហកុម្ភីនរកទាំង ៤ ក្នុងទីជិតនៃទីក្រុងសាវត្ថី ។ ព្រះរាជបុត្រទាំង ៤ អង្គនោះ ឆេះនៅក្នុងទឹកដែលប្រៃជ្រា ពុះសម្អុលឡើងចេញមកជាពពុះ (ធ្លាក់ចុះ) ទៅបាតខាងក្រោម ប៉ះនឹងបាតឆ្នាំង ដោយកាលប្រមាណ ៣ ម៉ឺនឆ្នាំ កាលឡើងមកខាងលើ ឃើញមាត់ឆ្នាំង ដោយកាលប្រមាណ ៣ ម៉ឺនឆ្នាំដូចគ្នាដែរ ហើយគិតថា "ពេលណាហ្ន៎ ពួកយើងនឹងបានរួចអំពីសេចក្តីទុក្ខនេះ ?" ដូច្នេះ សូម្បីប្រាថ្នានឹងពោលគាថា ៤ គាថា ឱ្យគ្រប់បរិបូណ៌ ក៏មិនអាចដើម្បីនឹងធ្វើ យ៉ាងដូច្នោះបានដែរ ទើបពោលបានតែម្នាក់ៗអក្សរ ១ ៗ ប៉ុណ្ណោះថា "ទុ. ស. ន. សោ." ដូច្នេះហើយ ក៏បានលិចចុះទៅ ក្នុងលោហកុម្ភីនរកជាថ្មីម្តងទៀត ។

បណ្តាសត្វនរកទាំង ៤ នោះ សត្វដែលពោល **ទុ** អក្សរ ហើយលិចចុះទៅ (វិញ) ជាអ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះថា ÷

(២០៧) **"ទុជ្ជីវិតមជីវិម្ហា យេសំ នោ ន ទទាមួសេ**
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ហ អត្តនោ" ។

យើងទាំងឡាយណា, កាលភោគៈទាំងឡាយមាន, មិនបានឲ្យទាន មិនបានធ្វើ នូវទីពឹងបម្រុងខ្លួនសោះ (ហេតុនោះ) បានជាយើងទាំងឡាយនោះ រស់នៅ ដោយត្រជាបត្រដួស ។

បណ្តាបទទាំងនោះ បទថា **"ទុជ្ជីវិតំ"** មានសេចក្តីថា សត្វទាំងឡាយ កាលប្រព្រឹត្តទុច្ចរិតទាំង ៣ យ៉ាង ឈ្មោះថា រមែងរស់នៅដោយត្រជាបត្រដួស គឺរស់នៅយ៉ាងអាក្រក់ ។ សត្វនរកនោះ សំដៅយកការរស់នៅដ៏អាក្រក់នោះឯង ទើបពោល យ៉ាងដូច្នេះ ។ ២ បទថា **"យេសំ នោ"** មានសេចក្តីថា យើងទាំងឡាយណា, កាលបើទេយ្យធម៌ និង កាលបើបដិគ្គាហកៈមាននៅនុ៎ះឯង, រមែងមិនឲ្យទាន ។ ២ បទថា **"ទីបំ នាកម្ហ"** ប្រែថា មិនធ្វើហើយនូវទីពឹង ។

សត្វដែលពោល **ស** អក្សរ ហើយលិចចុះទៅ (វិញ) ជាអ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះថា ÷

(២០៨) "សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ" ។

យើងទាំងឡាយ ដែលឆេះនៅ ក្នុងនរក គ្រប់ជា ៦០.០០០ ឆ្នាំ ដោយអាការទាំងពួងហើយ, កាលណានឹងមានទីបំផុត(ទុក្ខ) ។

បណ្តាបទទាំងនោះ បទថា "សព្វសោ" ប្រែថា ដោយ អាការទាំងពួង ។ បទថា "បរិបុណ្ណានិ" គឺ មិនខ្វះ មិនលើស ។ បទថា "បច្ចមានានំ" មានសេចក្តីថា កាលយើងទាំងឡាយឆេះនៅ ក្នុងនរកនេះ ។

សត្វដែលពោល ន អក្សរ ហើយលិចចុះទៅ (វិញ) ជា អ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះថា ÷

(២០៩) "នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ
តទា ហិ បកតំ បាបំ តុយ្ហំ មញ្ហញ្ច មារិស" ។

ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត (នៃទុក្ខយើង) មិនមានទេ, ទីបំផុត នឹងមានមកអំពីណា, ទីបំផុត នឹងមិនប្រាកដទេ, ព្រោះថា ខ្ញុំនិងអ្នក បានធ្វើបាបហើយ ក្នុងកាលនោះ ។

បណ្តាបទទាំងនោះ ២ បទថា "នត្ថិ អន្តោ" មានសេចក្តីថា

ការកំណត់វេលា យ៉ាងនេះថា "ការរួចផុត នឹងមានដល់ពួកយើង ឈ្មោះក្នុងកាលនោះ" ដូច្នេះ រមែងមិនមាន ។ ២ បទថា "**កុតោ អន្តោ**" មានសេចក្តីថា ទីបំផុត នឹងប្រាកដ ព្រោះហេតុអ្វី ? ។ បទថា "**ន អន្តោ**" មានសេចក្តីថា ទីបំផុតនៃទុក្ខ នឹងមិនប្រាកដដល់ពួកយើង សូម្បីជាអ្នកប្រាថ្នាចង់ឃើញ នូវទីបំផុត ។ បទថា "**តទា ហិ**" គឺក្នុងកាលនោះ ។ បាឋៈថា "**តថា ហិ**" ក៏មានខ្លះ ។ អធិប្បាយថា "ទីបំផុតនៃទុក្ខនោះ ពួកយើងមិនអាចដើម្បីនឹងមើលឃើញបាន ដោយអាការណា, ពួកយើងបានធ្វើបាបទុកហើយ ដោយអាការនោះ" ។ បទថា "**បកតំ**" មានសេចក្តីថា បាប គឺ កម្មដែលបណ្ឌិតស្អប់ខ្ពើម គឺខ្ញុំផង អ្នកផង បានធ្វើហើយ គឺបានធ្វើយ៉ាងច្រើនក្រៃលែងតែម្តង ។ បទថា "**មារិស**" ប្រែថា ម្នាលអ្នកស្មើនឹងខ្ញុំ ។ ពាក្យថា "**មារិស**" នុ៎ះ ជាពាក្យសម្រាប់ហៅបុគ្គលដែលជាទីស្រឡាញ់ ។

សត្វដែលពោល **សោ** អក្សរ ហើយលិចចុះទៅ (វិញ) ជាអ្នកប្រាថ្នាចង់ពោល យ៉ាងដូច្នេះ ថា ÷

(២១០) "**សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ**
វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ" ។

ខ្ញុំនោះ លុះទៅអំពីទីនេះ បាននូវកំណើតជាមនុស្សហើយ ជាអ្នកដឹងនូវពាក្យនៃស្ងួម ជាអ្នកបរិបូណ៌ដោយសីល នឹងធ្វើនូវកុសលឲ្យបានច្រើន ដោយពិត ។

សព្ទថា "**នូន**" ក្នុងគាថានោះ ជានិបាត ចុះក្នុងអត្ថថា ដោយចំណែកមួយ ។ អធិប្បាយថា "ខ្ញុំនោះ ទៅអំពីទីនេះហើយ បានហើយ នូវកំណើតជាមនុស្ស ជាអ្នកដឹងនូវពាក្យនៃស្ងួម ជាអ្នកបរិបូណ៌ដោយសីល នឹងធ្វើនូវកុសលឲ្យបានច្រើន ដោយចំណែកមួយប៉ុណ្ណោះ" ។

ក្នុងកាលនោះ ព្រះរាជាព្រះនាមកោសល ទ្រង់ព្រះសណ្តាប់នូវសំឡេង របស់សត្វនរកទាំងនោះ ក្នុងចំណែកនៃរាត្រីហើយ ទ្រង់មានព្រះទ័យភ័យខ្លាច ក្នុងថ្ងៃទី ២ ទើបស្តេចយាងទៅកាន់សំណាក់ នៃព្រះសាស្តាហើយ បានក្រាបទូល (រឿងនោះ) ។

ព្រះសាស្តា លុះទ្រង់ធ្វើរឿងនោះ ឲ្យជាអតីតប្បត្តិហេតុហើយ ទើបទ្រង់សំដែងលោហកុម្ភីជាតក ក្នុងទុតិយវគ្គ នៃចតុក្កនិបាត ។

រឿងព្រះរាជឱរស ចប់ ។

សូម្បីរឿងព្រះនាងមល្លិកា ក្នុងជរាវគ្គ នៃធម្មបទ បណ្ឌិតក៏គប្បីប្រមូលមក (សំដែងផងដែរ) ។

ពណ៌នាអំពីរឿង ក្នុងការប្រព្រឹត្តខុស ចប់ ។

(រឿងទេវបុត្រ ៤ អង្គ)

(២១១) ក្នុងអតីតកាល បានមានមហោស្រព យ៉ាងធំ ក្នុងក្រុងពារាណសី ។ ពួកនាគ គ្រុឌ និងពួកទេវតា ដែលនៅលើផែនដី ជាច្រើន បាននាំគ្នាមកមើល (មហោស្រព) ។ ក៏ទេវបុត្រទាំង ៤ អង្គ បានធ្វើផ្កាត្រឡាចដ៏ជាទិព្វ ឱ្យជាឆ្នូត ពួដ៏សិរសីហើយ មកអំពីភពតាវត្តឹង្ស ដើម្បីមើលមហោស្រព បានឈរនៅហើយ ពួដ៏អាកាស លើព្រះលាននៃព្រះរាជា ដោយកាយដែលប្រាកដ ។ ក្លិនផ្កាដ៏ជាទិព្វ បានក្រអូបត្របទៅពេញព្រះនគរពារាណសី ដែលមានទំហំប្រមាណ ១២ យោជន៍ ។ មនុស្សទាំងឡាយ ក្រឡេកមើលឃើញទេវបុត្រទាំងនោះហើយ ទើបបានសូមបុប្ផាទិព្វ នឹងពួកទេវបុត្រទាំងនោះ ។ ទេវបុត្រទាំងនោះ កាលនឹងសំដែងថា “ បុប្ផាទាំងនេះ មិនសមគួរ ដល់បុគ្គលអ្នកទ្រុស្តសីលទាំងឡាយទេ, តែជនទាំងឡាយណា ប្រកបហើយ ដោយគុណទាំងឡាយនេះ, បុប្ផាទាំងឡាយនុ៎ះ សមគួរដល់ជនទាំងឡាយនោះ ” ដូច្នេះ បានពោលគាថាទាំងឡាយ ៤ ដោយលំដាប់ ។ ក៏បណ្តាទេវបុត្រទាំង ៤ អង្គនោះ ទេវបុត្រដែលជាធំ ពោលហើយ យ៉ាងនេះ ថា ÷

(២១២) “ បុគ្គលណា មិនលួច (ទ្រព្យគេ) ដោយ[1]

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ២១៣

កាយ មិននិយាយកុហក ដោយវាចា បានយសស័ក្តិ
ហើយ មិនគប្បីស្រវឹង, បុគ្គលនោះឯង គួរប្រដាប់
ផ្កាត្រឡាចជាទិព្វទាំងឡាយ" ។

បណ្តាបទទាំងនោះ បទថា "**នាវហារេ**" មានសេចក្តីថា
រមែងមិនលួច សូម្បីនូវសរសៃនៃស្មៅ ដែលជារបស់នៃជនដទៃ ។
បទថា "**មុសា**" ជាដើម មានសេចក្តីថា មួយទៀត សូម្បីលះបង់
ជីវិត ក៏មិនពោលពាក្យមុសា ដោយវាចា ។ មែនពិត ពាក្យថា
"**មុសា**" នុ៎ះ ជាកំពូលនៃទេសនាតែម្តង ។ ក្នុង ២ បាទគាថា
នោះ មានអធិប្បាយ យ៉ាងដូច្នេះថា "ក៏បុគ្គលឯណា មិនធ្វើនូវ
អកុសលកម្មបថ ១០ យ៉ាង ដោយកាយទ្វារ វចីទ្វារ និង មនោទ្វារ" ។
បាទគាថាថា "**យសោ លទ្ធា ន មជ្ជេយ្យ**" មានសេចក្តីថា មួយ
ទៀត បុគ្គលណា បានឥស្សរិយយសហើយ មិនគួរស្រវឹង ដោយ
សេចក្តីស្រវឹងនឹងឥស្សរិយយស ដល់នូវសេចក្តីប្រមាទ ។ បទថា
"**សវេ**" ជាដើម មានសេចក្តីថា បុគ្គលអ្នកប្រកបហើយ ដោយ
គុណទាំងឡាយនេះនោះ រមែងសមគួរ ដើម្បីនឹងសុំ និង ដើម្បីនឹង
ប្រដាប់នូវផ្កាទិព្វ ដែលឈ្មោះថាផ្កាត្រឡាច, អធិប្បាយថា
"ខ្ញុំនឹងឲ្យ ដល់បុគ្គលនោះ" ដូច្នេះ ។

ចំណែកទេវបុត្រអង្គ ទី ២ ពោលថា ÷

(២១៣) "បុគ្គលឯណា គប្បីស្វះស្វែងរកទ្រព្យជាគ្រឿងពេញចិត្ត ដោយធម៌ មិនគប្បីលួចយកនូវទ្រព្យគេ ដោយការបោកប្រាស់ បានទ្រព្យទាំងឡាយហើយ មិនគួរស្រវឹង, បុគ្គលនោះឯង ទើបគួរប្រដាប់ នូវផ្កាត្រឡាចបាន" ។

បណ្តាបទទាំងនោះ បទថា "**ធម្មេន វិត្តំ**" មានសេចក្តីថា គប្បីស្វះស្វែង គឺគប្បីស្វែងរក នូវទ្រព្យគ្រឿងពេញចិត្ត មានមាសប្រាក់ជាដើម ដោយអាជីវៈដ៏បរិសុទ្ធ ។ បទថា "**និកត្យា**" ប្រែថា ដោយការបោកបញ្ឆោត ។ បទថា "**ភោគេ**" គឺនូវទ្រព្យទាំងឡាយ មានសំពត់ និងគ្រឿងអាភរណៈជាដើម ។

ចំណែកទេវបុត្រអង្គ ទី ៣ ពោលថា ÷

(២១៤) "បុគ្គលណា មានចិត្តមិនឆាប់ហើរ ដូចជារមៀត, មានសទ្ធាមិនរសាយ និង បុគ្គលណាមិនគប្បីបរិភោគនូវវត្ថុមានរសជាតឆ្ងាញ់ តែម្នាក់ឯង, បុគ្គលនោះឯង ទើបគួរប្រដាប់ផ្កាត្រឡាយបាន" ។

បណ្តាបទទាំងនោះ បទថា "**អហាលិទ្ធំ**" មានសេចក្តីថា ចិត្ត របស់បុគ្គលណា មិនមែនជាធម្មជាតស្មើដោយរមៀត គឺ រមែងមិនហើរទៅ យ៉ាងឆាប់រហ័ស ដូចជាទឹកជ្រលក់រមៀត បានដល់ជាធម្មជាតស្ថិតស្ថេរគង់រង់តែម្តង ។ បទថា "**អវិរាគិនី**" គឺ កំណត់នូវកម្ម ឬ វិបាក ។ ម្យ៉ាងទៀត សទ្ធារបស់បុគ្គលណា គឺ អ្នកជឿនូវពាក្យ រមែងមិនរសាយ គឺ មិនបែកធ្លាយ ព្រោះហេតុ មានប្រមាណតិចតួចប៉ុណ្ណោះ ។ ២ បទថា "**ឯកោ សាទុំ**" មានសេចក្តីថា បុគ្គលណា មិនធ្វើនូវពួកយាចក ឬ បុគ្គលដទៃ ដែលជាអ្នកគួរដល់ការបែងចែក (ឲ្យនៅ) ខាងក្រៅហើយ រមែងបរិភោគ នូវភោជនដែលមានរសជាតឆ្ងាញ់ តែម្នាក់ឯង គឺ ចែករំលែកហើយ ទើបបរិភោគ ។

ចំណែក ទេវបុត្រអង្គ ទី ៤ ពោលថា ÷

(២១៥) "**បុគ្គលណា មិនជេរប្រទេច នូវសប្បុរសទាំងឡាយ ក្នុងទីចំពោះមុខ ឬ កំបាំងមុខ ជាអ្នកនិយាយយ៉ាងណា ធ្វើយ៉ាងនោះ, បុគ្គលនោះឯង ទើបគួរប្រដាប់ នូវផ្តាត្រឡាចបាន**" ។

បណ្តាបទទាំងនោះ បទថា "**សន្តេ**" មានសេចក្តីថា

បុគ្គលណា មិនជេរប្រទេច គឺមិនជេរស្តី នូវបុរសទាំងឡាយ ជាអ្នក ស្ងប់រម្ងាប់ហើយ គឺបុរសដែលជាបណ្ឌិត អ្នកប្រកបហើយ ដោយ គុណមានសីលជាដើម ។ បទថា "**យថាវាទី**" មានសេចក្តីថា រមែងពោលនូវរឿងណា ដោយវាចា, រមែងធ្វើនូវរឿងនោះឯង ដោយកាយ ។

(២១៦) ក៏នៅក្នុងទីបញ្ចប់នៃគាថា របស់ទេវបុត្រនោះ ។ បុរោហិត គិត ថា "បណ្តាគុណទាំងនេះ សូម្បីគុណតែមួយ ក៏មិន មាន ដល់អាត្មាអញឡើយ, អាត្មាអញ នឹងធ្វើការពោលមុសាវាទ សុំនូវគ្រឿងប្រដាប់ទាំងនេះហើយ នាំយកមកប្រដាប់តាក់តែង, ធ្វើ យ៉ាងនេះ ជននឹងស្គាល់អាត្មាអញ ថា 'បុរោហិតនេះ ជាអ្នកបរិបូណ៌ ហើយដោយគុណ' ដូច្នេះ" ក៏បានធ្វើហើយ យ៉ាងដូច្នោះ ។ ទេវបុត្រទាំង ៤ អង្គនោះ បានឲ្យរង្វេលផ្តាទាំងឡាយ ៤ ដល់ បុរោហិតនោះឯងហើយ ក៏ទៅកាន់ទេវលោក ។ ក្នុងពេលដែល ទេវបុត្រទាំង ៤ អង្គនោះ ទៅហើយ សេចក្តីវេទនាដ៏ច្រើន បាន កើតឡើងហើយ ញ្ជ៏ក្បាល របស់បុរោហិត ។ ក្បាលរបស់ បុរោហិតនោះ ប្រៀបដូចជាដែកស្រួចដោតហើយ និង ប្រៀចដូច ជាយន្តដែកកិនកំទេចហើយ ។ បុរោហិតនោះ ទទួលវេទនាហើយ ស្រែកយំ ដោយសំឡេងដ៏ខ្លាំងថា "ខ្ញុំនិយាយមុសាវាទ កាន់យក

នូវរង្វែលផ្កាទាំងឡាយនេះ មកប្រដាប់ហើយ, អ្នកទាំងឡាយ ចូរជួយយករង្វែលផ្កាទាំងនេះ ចេញអំពីក្បាល របស់ខ្ញុំផង" ។ ពួកមនុស្សទាំងឡាយ សូម្បីជួយគ្នាយករង្វែលផ្កាទាំងនោះចេញ ក៏មិនអាច ដើម្បីនឹងជួយយកចេញបានឡើយ ។ ផ្កាទាំងឡាយ បានមានហើយ ដូចជាគេរុំព័ទ្ធហើយ ដោយបន្ទះដែក ។ មនុស្សទាំងឡាយ បានលើកពបុរោហិតនោះ នាំទៅផ្ទះហើយ ។ បុរោហិតនោះ ស្រែកយំហើយ រហូត ៧ ថ្ងៃ ។ ដោយកាលកន្លងទៅ ៧ ថ្ងៃ ព្រះរាជ ទ្រង់ព្រះតម្រិះថា "បុរោហិត អ្នកទ្រុស្តសីល កុំបីស្លាប់ឡើយ" ហើយ ទ្រង់ត្រាស់បញ្ជាឲ្យលេងមហោស្រពម្តងទៀត ។ ទេវបុត្រទាំង ៤ អង្គនោះ បានមកម្តងទៀតហើយ ។ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យនាំយកបុរោហិតមកហើយ ទ្រង់ញុំាងទេវបុត្រទាំងនោះ ឲ្យអត់ទោស ដល់បុរោហិតនោះហើយ ។ ទេវបុត្រទាំងឡាយ បានតិះដៀល បុរោហិតនោះ ក្នុងកណ្តាលជំនុំបរិស័ទ ថា 'ផ្កាទាំងឡាយនេះ មិនសមគួរ ដល់អ្នកជាបុគ្គលទ្រុស្តសីលឡើយ, អ្នកជាអ្នកមានសេចក្តីសម្គាល់ថា 'អាត្មាអញ នឹងបញ្ឆោតទេវបុត្រទាំង ៤ អង្គនេះ' ដូច្នេះ, ផលនៃមុសាវាទ របស់ខ្លួន គឺអ្នកបានហើយ" ដូច្នេះហើយ ទើបបាននាំយកនូវរង្វែលចេញ អំពីក្បាលនៃបុរោហិតនោះ ស្រេចហើយ ក៏ទៅកាន់ទីឋាន របស់ខ្លួនដូចដើម ។

រឿងព្រាហ្មណ៍និយាយមុសាវាទ មកក្នុងអដ្ឋកថាកក្ការជាតក ក្នុងតតិយវគ្គ នៃចតុក្កនិបាត ។

(រឿងអចេលឈ្មោះករម្ភិយៈ)

(២១៧) ក្នុងអតីតកាល អចេលម្នាក់ ឈ្មោះថា ករម្ភិយៈ អាស្រ័យស្រុក ឈ្មោះករម្ភិយបដ្ដនៈ ឈប់នៅក្នុងទីជិតសមុទ្រ ។ ស្តេចនាគមួយឈ្មោះបណ្ឋារៈក្តី ស្តេចគ្រុឌក្តី រមែងមកកាន់ទីចំរុងរបស់អចេលនោះ ។ ថ្ងៃមួយ បណ្តាសត្វទាំង ២នោះ ស្តេចគ្រុឌមកមុនហើយ ពោលថា "បពិត្រលោកដ៏ចំរើន ពួកញាតិ របស់យើងខ្ញុំទាំងឡាយ កាលចាប់នូវពួកនាគ រមែងវិនាសទៅ ជាច្រើន, យើងខ្ញុំទាំងឡាយ តែងមិនដឹង នូវពិធីចាប់នាគទេ, បានឮមកថា ហេតុនៃសេចក្តីស្ងាត់កំបាំង របស់នាគទាំងនោះមាន, សូមលោកម្ចាស់សួរស្តេចនាគនោះ ហើយប្រាប់ ដល់ពួកខ្ញុំផង" ដូច្នេះហើយ ក៏ចៀសចេញទៅ ។ អចេលនោះ ទទួលថា "ប្រពៃណាស់" ហើយ សួរនូវហេតុអាថ៌កំបាំងនោះ នឹងស្តេចនាគ ជារឿយៗ ។ ស្តេចនាគ មិនប្រាប់ រហូត ២ ថ្ងៃ ក្នុងថ្ងៃទី ៣, កាលបើអចេលនោះ ពោលថា "ខ្ញុំនឹងមិនប្រាប់ ដល់អ្នកណាឡើយ, ចូរអ្នកកុំមានការភ័យខ្លាច ប្រាប់មកចុះ" ដូច្នេះ, ទើបពោលថា "បពិត្រលោក

ម្ចាស់ដ៏ចំរើន បើដូច្នោះ សូមលោកម្ចាស់ កុំប្រាប់ដល់បុគ្គលដទៃឡើយ" ដូច្នេះ បានទទួលពាក្យប្តេជ្ញាហើយ ប្រាប់ហេតុនៃសេចក្តីអាថិកំបាំង របស់ខ្លួន ដល់អចេលទ្រុស្តសីល ជាអ្នកចូលចិត្តពោលពាក្យមុសានោះថា "បពិត្រលោកម្ចាស់ដ៏ចំរើន យើងខ្ញុំទាំងឡាយ លេបនូវដុំថ្មធំៗ ទាំងឡាយ ជាអ្នកធ្ងន់ ដេកហើយ ក្នុងពេលដែលពួកគ្រូឧមក បែរមុខបើកធ្មេញហើយ ប្រាថ្នាដើម្បីនឹងខាំនូវគ្រូឧទាំងនោះ, ពួកគ្រូឧទាំងនោះ មកហើយ តែងចាប់ក្បាលរបស់យើងខ្ញុំទាំងឡាយ, កាលបើគ្រូឧទាំងនោះ ព្យាយាមដើម្បីនឹងលើកនូវពួកយើងខ្ញុំ ដែលមានភារៈដ៏ធ្ងន់ ដេកហើយនុ៎ះឯង, ទឹកក៏ឡើងមក (ទឹកជន់) ។ គ្រូឧទាំងឡាយនោះ ក៏លិចចុះទៅស្ងាប់ ឮដ៏ខាងក្នុងទឹកនុ៎ះឯង, គ្រូឧទាំងឡាយជាច្រើន រមែងវិនាសទៅ ព្រោះហេតុនេះ, កាលបើពួកគ្រូឧទាំងនោះ ចាប់នូវពួកយើងខ្ញុំ, ប្រយោជន៍អ្វី ដោយក្បាល ដែលពួកគ្រូឧចាប់ហើយ, ពួកគ្រូឧទាំងឡាយ ចាប់ត្រង់កន្ទុយហើយ ធ្វើពួកយើងខ្ញុំ ឱ្យមានក្បាលចុះក្រោម ឱ្យសម្រកអាហារ ដែលពួកយើងខ្ញុំទទួលហើយ ធ្វើឱ្យពួកយើងខ្ញុំស្រាលហើយ រមែងអាចដើម្បីនឹងទៅបាន" ដូច្នេះហើយ ទើបចៀសចេញទៅ ។ កាលបើស្តេចនាគនោះ ចៀសចេញទៅហើយ, ស្តេចគ្រុឧ ក៏មកហើយ ។ អ្នកបួសអចេល

បានប្រាប់នូវហេតុទាំងអស់នោះ ដល់ស្តេចគ្រុឌហើយ ។ ស្តេចគ្រុឌ ស្តាប់ពាក្យនោះហើយ ក៏ចាប់ស្តេចនាគនោះ ត្រង់កន្ទុយហើយ បាន ធ្វើស្តេចនាគ ឲ្យមានក្បាលចុះក្រោម ឲ្យសម្រកអាហារ ដែលស្តេច នាគទទួលហើយ ទើបបានហោះទៅកាន់អាកាស ក្នុងថ្ងៃនោះឯង ។ ស្តេចនាគ ទម្លាក់ក្បាលចុះក្រោម ពោលថា "អាស្មាអញ មិនបាន រក្សាសេចក្តីអាថិកំបាំងហើយ ប្រាប់ដល់បុគ្គលអ្នកទ្រុស្តសីល ទើប បាននាំសេចក្តីទុក្ខមកដល់អាស្មាអញ" ហើយ ក៏បានស្រែកយំ ដោយ ប្រការផ្សេងៗ ។ ស្តេចគ្រុឌ បានតិះដៀល ស្តេចនាគនោះ ថា "អ្នកប្រាប់រឿងអាថិកំបាំង របស់ខ្លួន ដល់អ្នកបួសអចេល ឥឡូវនេះ តើស្រែកយំដើម្បីប្រយោជន៍អ្វី?" ដូច្នេះ, កាលស្តេចនាគនោះ សុំ នូវជីវិត, ទើបបានឲ្យហើយ នូវជីវិត ដល់ស្តេចនាគនោះ ។ សត្វ ទាំង ២ នោះ ជាអ្នកសាមគ្គីគ្នា សប្បាយរីករាយ ជាមិត្រមិនបែក បាក់គ្នាហើយ ចាប់តាំងពីពេលនោះមក ។ ចំណែក ស្តេចនាគ ក្រោធខឹង ចំពោះអចេល បានទៅកាន់អាស្រមបទ របស់អចេល នោះហើយ ក៏តិះដៀលអចេលនោះ ដោយប្រការផ្សេងៗ កាលនឹង ដាក់ផ្តាសា បានពោលគាថានេះ ក្នុងបណ្ឌរកជាតក ក្នុងតីសនិបាត[1] ថា ÷

(២១៨) "ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្រ

---

១ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ២០៨

ដែលមិនបានប្រទូស្តវិញផង ជាអ្នកញុះញង់ផង, ដោយពាក្យសច្ចៈនេះ សូមឱ្យក្បាល របស់អ្នកឯង បែកជា ៧ ភាគ "។

បណ្តាបទទាំងនោះ បទថា "**អទុដ្ឋស្ស**" មានសេចក្តីថា ម្នាលលោកដ៏ចំរើន លោកជាអ្នកប្រទូស្តមិត្រ ។ ដោយពាក្យសច្ចៈនេះថា "លោកជាអ្នកប្រទូស្តផង ជាអ្នកញុះញង់ផង"។ កាលបើស្តេចនាគ មើលឃើញនុ៎ះឯង, ក្បាលរបស់អចេល បានបែកហើយដោយ ៧ ភាគ ។ ផែនដី ក៏បានឱ្យប្រហោង ដល់អចេលនោះ ក្នុងទីដែលគេអង្គុយហើយនុ៎ះឯង ។ អ្នកបួសអចេលនោះ ពោលមុសា ត្រូវផែនដីស្រូប ចូលទៅកាន់ផែនដីហើយ ក៏បានទៅកើតក្នុងអវិចីនរក ដោយប្រការដូច្នេះឯង ។

រឿងអចេលឈ្មោះកវឡិយៈ ចប់ ។

ពណ៌នាអំពីរឿង ក្នុងមុសាវាទ ចប់ ។

(រឿងព្រះរាជាសោយព្រះរាជបុត្រ)

(២១៩) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ព្រះរាជាមួយព្រះអង្គ ប្រាសចាកទឹកស្រវឹងហើយ ទ្រង់មិនអាច សូម្បីដើម្បី

ទ្រង់ប្រព្រឹត្តព្រះរាជកិច្ច ដើម្បីនឹងទ្រង់សោយព្រះក្រយាហារ ដែលមិនមានសាច់បានឡើយ ។ ក្នុងព្រះនគរ ក្នុងថ្ងៃឧបោសថទាំងឡាយ មិនមានការសម្លាប់សត្វទេ ។ បុគ្គលអ្នកធ្វើអាហារ (ចុងភៅ) ទិញសាច់ ក្នុងតិថីទី ១៣ នៃបក្សនុ៎ះឯងហើយ បានយកមកទុក ។ សាច់នោះ អ្នកធ្វើអាហារ ទុកមិនបានល្មមឡើយ, ឆ្កែទាំងឡាយ បានខាំស៊ីហើយ ។ បុគ្គលអ្នកធ្វើអាហារ មិនបានសាច់ ក្នុងថ្ងៃឧបោសថ មិនអាច ដើម្បីនាំក្រយាហារ ចូលទៅថ្វាយ ដល់ព្រះរាជបាន ទើបក្រាបទូលសេចក្តីនោះ ដល់ព្រះនាងទេវី ។ ព្រះនាងទ្រង់មានព្រះតម្រាស់ ថា “នែអ្នក ព្រះរាជបុត្រ របស់យើង ជាទីស្រឡាញ់ពេញព្រះរាជហឫទ័យ របស់ព្រះរាជា, ព្រះរាជា កាលទតព្រះនេត្រឃើញព្រះរាជបុត្រនោះហើយ ទ្រង់ថើប បបោសអង្អែលនូវព្រះរាជបុត្រនោះឯង រមែងមិនទ្រង់ជ្រាប សូម្បីនូវព្រះក្រយាហារ របស់ព្រះអង្គ មានសាច់ឬ មិនមានសាច់, ខ្ញុំនឹងប្រដាប់ព្រះរាជបុត្រហើយ ឱ្យគង់នៅលើព្រះឧរុ (ភ្លៅ) របស់ព្រះរាជា, ក្នុងពេលដែលព្រះរាជាទ្រង់ក្រសាល (លេងប្រឡែង) ជាមួយព្រះរាជបុត្រ របស់ព្រះអង្គនោះ អ្នកគប្បីបង្ហោនព្រះក្រយាហារចូលទៅថ្វាយ” ហើយ ទ្រង់បានធ្វើ យ៉ាងដូច្នោះហើយ ។ ក្នុងកាលនោះ អ្នកធ្វើអាហារ បាននាំព្រះក្រយាហារចូលទៅហើយ ។ ព្រះរាជាទ្រង់

ស្រវឹងហើយ ព្រោះការស្រវឹងសុរា ទ្រង់ទតព្រះនេត្រមិនឃើញ
សាច់ ក្នុងថាស ទើបទ្រង់ត្រាស់សួរថា "សាច់នៅ ឯណា ?" ។
បុគ្គលអ្នកធ្វើអាហារ ក្រាបទូលថា "បពិត្រព្រះសម្មតិទេព ថ្ងៃនេះ
គឺជាថ្ងៃឧបោសថ, ទូលព្រះបង្គំមិនបានសាច់ឡើយ" ។ ព្រះរាជា
ទ្រង់ត្រាស់ថា "ឈ្មោះថាសាច់សំរាប់អញ រកបានដោយក្រណាស់"
ហើយ មួលកព្រះរាជបុត្រ ឲ្យដល់ការក្ស័យព្រះជន្មហើយ ទើប
បោះទៅខាងមុខ នៃអ្នកធ្វើអាហារហើយ ត្រាស់បញ្ជាថា "ចូរអ្នក
ចាត់ចែងហើយ នាំយកមក ដោយប្រញាប់" ។ បុគ្គលអ្នកធ្វើ
អាហារនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ សូម្បីបុគ្គលម្នាក់ ក៏
មិនអាច ដើម្បីនឹងស្រែកយំ ឬ ក្រាបទូលបានឡើយ ព្រោះភ័យ
ខ្លាចចំពោះព្រះរាជា ។ ព្រះរាជា ទ្រង់សោយ ព្រះក្រយាស្ងោយ
ដោយសាច់របស់ព្រះឱរស ទ្រង់ព្រះបន្ទំហើយ ក្នុងវេលាទៀបភ្លឺ
ទ្រង់តើនឡើង ស្វាងពីស្រវឹងហើយ ទ្រង់ត្រាស់ថា "ចូរអ្នកទាំង
ឡាយ នាំយកព្រះរាជបុត្រ របស់ខ្ញុំមក" ។ ក្នុងខណៈនោះ
ព្រះនាងទេវី ទ្រង់ព្រះកន្សែង ក្រាបទូលថា "បពិត្រព្រះសម្មតិទេព
ក្នុងថ្ងៃម្សិលមិញ ព្រះអង្គទ្រង់សម្លាប់ព្រះរាជបុត្រហើយ ទ្រង់បាន
សោយព្រះក្រយាស្ងោយ ជាមួយព្រះមំសៈ របស់ព្រះរាជបុត្រ" ។
ព្រះរាជា ទ្រង់ព្រះកន្សែង ព្រោះសេចក្តីសោក ក្នុងព្រះរាជបុត្រ

ទ្រង់ទតឃើញទោស ក្នុងការសោយទឹកស្រវឹងថា "ទុក្ខនេះ កើតឡើងហើយ ដល់អាត្មាអញ ព្រោះអាស្រ័យការផឹកសុរា" ដូច្នេះ ទ្រង់បានចាប់ធូលីមកជូតព្រះភក្ត្រហើយ ទ្រង់អធិដ្ឋាន ថា "ចាប់តាំងអំពីពេលនេះទៅ អាត្មាអញ ពុំទាន់បានសម្រេចព្រះអរហាត្ត ដរាបណា, អាត្មាអញ នឹងមិនផឹកនូវសុរាដែលជាហេតុនៃសេចក្តីវិនាស ប្រាកដដូច្នេះ ដរាបនោះ" ។ តាំងតែអំពីពេលនោះមក ព្រះរាជាអង្គនោះ ទ្រង់មិនសោយនូវសុរាឡើយ ។

រឿងព្រះរាជាសោយព្រះរាជឱរស មកក្នុងអដ្ឋកថាធម្មទ្ធជជាតកក

ក្នុងសត្តមវគ្គ នៃទុកនិបាត ។

(រឿងក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី)

(២២០) ក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី ញុំាងប្រាក់ចំនួន ៤០ កោដិ ដែលជារបស់នៃមាតាបិតា ឱ្យវិនាសហើយ ដោយការប្រើប្រាស់ឱ្យអស់ទៅ ព្រោះការផឹកសុរា បានទៅកាន់សំណាក់ នៃសេដ្ឋីហើយ ។ ឯសេដ្ឋីនោះ ក៏បានឱ្យទ្រព្យ ១ ពាន់ កហាបណៈដល់ក្មួយនោះ ដោយប្រាប់ថា "ចូរអ្នកធ្វើ នូវការលក់ដូរចុះ" ។ ក្មួយនោះ បានធ្វើទ្រព្យ ១ ពាន់កហាបណៈនោះឯង ឱ្យវិនាសហើយ បានទៅរកម្តងទៀត ។ សេដ្ឋីឱ្យទ្រព្យ ៥០០ កហាបណៈ ថ្មីទៀត,

កាលបើក្មួយនោះ ញ៉ាំងទ្រព្យ ៥០០ កហាបណៈនោះឯង ឲ្យវិនាស អស់ហើយ មកថ្មីម្តងទៀត, ទើបបានឲ្យសំពត់សាដកសាច់គ្រគ្រើម ២ កំណាត់ទៅ និងញ៉ាំងបុគ្គលឲ្យចាប់ក្មួយនោះ ដែលធ្វើសំពត់ សាដកនោះឯង ឲ្យវិនាសទៅហើយ មកវកម្តងទៀត ត្រង់ក ហើយ ក៏បានឲ្យបណ្តេញចេញទៅហើយ ។ ក្មួយនោះ ជាអ្នកគ្មានទីពឹង នៅ អាស្រ័យជញ្ជាំងផ្ទះនៃជនដទៃ បានធ្វើកាលកិរិយាហើយ ។ ពួក មនុស្សទាំងឡាយ បាននាំគ្នាអូសខ្មោចនេះនោះ យកទៅចោល ខាង ក្រៅហើយ ។ ឯសេដ្ឋី បានទៅកាន់វត្តហើយ ក្រាបទូលរឿង រ៉ាវ របស់ក្មួយ ទាំងអស់នោះ ដល់ព្រះសាស្តាហើយ ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ក្នុងកាលមុន តថាគត សូម្បី ឲ្យឆ្នាំងកំណប់ ដែលឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ក៏មិនអាច ដើម្បីនឹងញ៉ាំងបុរសណា ឲ្យឆ្អែតស្កប់ស្កល់បានឡើយ, អ្នកនឹង ញ៉ាំងបុរសនោះ ឲ្យឆ្អែតស្កប់ស្កល់បាន យ៉ាងដូចម្តេចទៅ" ដូច្នេះ ហើយ ទ្រង់នាំអតីតនិទានមក (សំដែងថា) ÷

(រឿងអ្នកលេងសុរា)

(២២១) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រះពោធិសត្វ កើតជាសេដ្ឋី មានទ្រព្យកប់ទុក ក្នុងផែនដីចំនួន ៤០ កោដិ បានធ្វើ

បុណ្យទាំងឡាយ មានទានជាដើម ស្លាប់ (អំពីអត្តភាពនោះ) ហើយ ក៏បានទៅកើតជាស្តេចសក្កទេវរាជ ។ ក៏បុត្ររបស់ព្រះពោធិសត្វ នោះ មានតែមួយប៉ុណ្ណោះ ។ បុត្រនោះ, កាលបិតា ធ្វើកាលៈទៅ ហើយ, ក៏បានឱ្យបុគ្គលធ្វើមណ្ឌប មានមហាជនចោមរោមហើយ ផឹកនូវសុរា ។ បុត្រនោះ ឱ្យទ្រព្យ ម្តង ១ ពាន់ៗ ដល់ជនទាំងឡាយ អ្នកធ្វើនូវការលោតហាក់ របាំ រាំ និង ច្រៀងជាដើម ដល់នូវភាពជាអ្នកលេង មានអ្នកលេងស្រី អ្នកលេងសុរា និង អ្នកលេងស៊ីសាច់ជាដើម ជាអ្នកស្ថិតនៅ ឈ្លក់វង្វេងហើយ ក្នុងមហោស្រព មានការរាំ ច្រៀង និង ប្រគំជាដើម ត្រាច់ចរទៅ ញុំាងទ្រព្យចំនួន ៤០ កោដិ និង ភណ្ឌៈដែលជាគ្រឿងឧបករណ៍ នៃគ្រឿងឧបភោគ និងបរិភោគ ឱ្យវិនាសអស់ហើយ ក្នុងកាលមិនយូរឡើយ ជាបុគ្គលក្រីក្រ កំព្រា ស្លៀកសំពត់កញ្ជាស់ ដើរទៅហើយ ។ សក្កទេវរាជ ទ្រង់ជ្រាបថាកូននោះ ជាអ្នកក្រីក្រលំបាក ទើបស្តេចយាងមក ព្រោះសេចក្តីស្រឡាញ់ចំពោះបុត្រ ទ្រង់ប្រទានឆ្នាំងកំណប់ ដែលឱ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងហើយ ទ្រង់ត្រាស់ថា " នែកូនសំឡាញ់ ឆ្នាំងនេះ នឹងមិនបែក ដោយវិធីណា, អ្នកចូររក្សាឆ្នាំងនោះទុក ដោយវិធីនោះចុះ, ព្រោះថា កាលបើឆ្នាំងនេះមានដល់អ្នក, ឈ្មោះថា ការកំណាត់ នៃទ្រព្យ នឹងមិនមាន, ចូរអ្នកកុំបីប្រមាទឡើយ "

ដូច្នេះហើយ ទើបស្តេចយាងទៅទីឋានរបស់ព្រះអង្គដូចដើមវិញ ។ ចាប់តាំងពីពេលនោះមក បុត្រនោះ តែងដើមផឹកសុរា ។ ក្រោយមកថ្ងៃមួយ គេស្រវឹងហើយ បោះហើយទទួល ។ នូវឆ្នាំងនោះ លើអាកាស (ទទួល) ផ្លាតហើយ មួយគ្រា ។ ឆ្នាំងបានធ្លាក់ មកលើផែនដីបែកហើយ ។ តាំងពីពេលនោះមក បុត្រនោះ ជាអ្នកទីទាល់ក្រ ម្តងទៀត ស្លៀកសំពត់កញ្ជាស់ មានដៃកាន់អំបែងក្បឿង នៅអាស្រ័យជញ្ជាំងផ្ទះ នៃជនដទៃ បានធ្វើកាលកិរិយាហើយ ។

(២២២) ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់សំដែងធម៌ ដល់សេដ្ឋី ទ្រង់បានត្រាស់គាថាទាំងឡាយ ៣ ក្នុងភទ្រយដជាតក ក្នុងបញ្ចមវគ្គ នៃតិកនិបាត ថា ÷

"អ្នកលេងនោះ បានន្ទូវឆ្នាំងកំណប់ ដែលឲ្យ(1)ន្ទូវ
សេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយថែរក្សាឆ្នាំងនោះ
ដរាបណា, អ្នកលេងនោះ រមែងដល់ន្ទូវសេចក្តី
សុខ ដរាបនោះ ។ ក្នុងកាលណា អ្នកលេង
នោះ ស្រវឹងហើយផង គឃ្លើនផង បានបំបែក
ឆ្នាំងហើយ ព្រោះសេចក្តីប្រមាទ, ក្នុងកាលនោះ
គេជាអ្នកអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់

---

1 ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៧៦

កន្ទបផង ជាពាលផង រមែងក្តៅក្រហល់ក្រហាយ ក្នុងកាលជាខាងក្រោយ, បុគ្គលណាបាននូវទ្រព្យ យ៉ាងដូច្នេះហើយ ប្រើប្រាស់ដោយសេចក្តីប្រមាទ បុគ្គលនោះ ជាអ្នកឥតប្រាជ្ញា រមែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ដូចជាអ្នកលេង ដែលក្តៅក្រហាយស្តាយក្រោយ ព្រោះតែបំបែកឆ្នាំង ចោល យ៉ាងដូច្នោះឯង" ។

(២២៣) បណ្តាបទទាំងនោះ បទថា "**សព្វកាមទទំ**" មានសេចក្តីថា នូវឆ្នាំងដែលអាច ដើម្បីនឹងឲ្យ នូវវត្ថុកាមទាំងពួងបាន ។ បទថា "**កូដំ**" ជាពាក្យវៀចនៈនៃឆ្នាំង ។ បទថា "**យាវ**" បានដល់ អស់កាលមានប្រមាណត្រឹមណា ។ បទថា "**អនុបាលេតិ**" គឺ រមែងរក្សា ។ បទថា "**មត្តោ**" គឺ ស្រវឹងហើយ ព្រោះការស្រវឹងសុរា ។ បទថា "**ទិត្តោ**" គឺ គយ្លើនហើយ ព្រោះសេចក្តីគយ្លើន ។ បាទគាថាថា "**បមាទា កុម្ភមព្ភិទា**" បានដល់ បានបំបែកហើយ នូវឆ្នាំង ដោយសេចក្តីប្រមាទ ។ ២ បទថា "**នគ្គោ ច បោត្តោ ច**" មានសេចក្តីថា គ្រាខ្លះ ជាអ្នកអាក្រាត គ្រាខ្លះ ជាអ្នកស្លៀកកំណាត់សំពត់កន្ទប

ព្រោះជាអ្នកស្លៀកកំណាត់សំពត់ចាស់ និងកំណាត់កន្ទប ។ បទ ថា "បមត្តោ" មានសេចក្តីថា ដោយសេចក្តីប្រមាទ ។ បទ ថា "តប្បតិ" គឺ រមែងសៅសោក ។

រឿងអ្នកលេងសុរា ចប់ ។

រឿងបុត្ររបស់សេដ្ឋីអ្នកមានទ្រព្យច្រើន ក្នុងជរាវគ្គ នៃធម្មបទក្តី កុម្ភជាតកក្តី ក្នុងគីសនិបាត បណ្ឌិតគប្បីប្រមូលមក ។

ពណ៌នាអំពីរឿង ក្នុងការផឹកទឹកស្រវឹង ចប់ ។

ក៏រឿងដែលខ្ញុំបានពោលហើយ ទាំងអស់នោះ គឺលោកបានហើយ អំពីទីផ្សេងៗ ។ ចំណែករឿងតទៅនេះ គឺលោកបានហើយ អំពីទីជាមួយគ្នា ។

(រឿងនាងយក្ខិនីដែលប្រព្រឹត្តក្បត់ចិត្ត)

(២២៤) ក្នុងអតីតកាល ព្រះអគ្គមហេសី របស់ព្រះរាជាក្រុងពារាណសី ប្រព្រឹត្តក្បត់ព្រះទ័យ ត្រូវព្រះរាជាត្រាស់សួរហើយ ទើបទ្រង់ធ្វើព្រះសម្បថ ថា "ប្រសិនបើ ទូលព្រះបង្គំប្រព្រឹត្តក្បត់ព្រះហឫទ័យព្រះអង្គ, ទូលព្រះបង្គំ នឹងកើតជានាងយក្ខិនី មានមុខដូចជាមុខនៃសេះ" ដូច្នេះហើយ ទើបទ្រង់ទិវង្គតទៅ បានទៅកើតជានាងយក្ខិនី មានមុខដូចជាសេះ ក្នុងរូងភ្នំជាទីសម្រាក

ក្បែរជើងភ្នំមួយ ឧបដ្ឋាកស្តេចវេស្សវ័ណ អស់ ៣ ឆ្នាំ បានហើយ ដើម្បីនឹងស៊ីមនុស្សទាំងឡាយ ក្នុងទីប្រមាណ ៣០ យោជន៍ ដោយបណ្តោយ ក្នុងទីប្រមាណ ៥ យោជន៍ ដោយទទឹង ។ ថ្ងៃមួយ នាងយក្ខិនីនោះ ចាប់ព្រាហ្មណ៍រូបស្អាតបានហើយ ឱ្យដេកលើខ្នងនាំទៅកាន់គុហា បានទទួលសម្ផស្សនៃបុរសហើយ ក៏ញ៉ាំងសេចក្តីស្រឡាញ់ ឱ្យកើតឡើងហើយ ក្នុងព្រាហ្មណ៍នោះ ដោយអំណាចនៃកិលេស មិនបានស៊ីនូវព្រាហ្មណ៍នោះទេ បានយកធ្វើជាប្តីហើយ តាំងអំពីពេលនោះមក កាលចាប់ពួកមនុស្សបាន ក៏យកវត្ថុទាំងឡាយ មានសំពត់ អង្ករ និងប្រេងជាដើម ហើយឱ្យភោជនដែលមានរសជាតឆ្ងាញ់ផ្សេងៗ ដល់ព្រាហ្មណ៍នោះ ខ្លួនឯងស៊ីសាច់មនុស្ស ។ មួយទៀត ក្នុងពេលដែលទៅរកចំណីអាហារ ព្រោះខ្លាចព្រាហ្មណ៍នោះរត់ចេញ នាងយក្ខិនីនោះ បានយកសីលាយ៉ាងធំមកបិទទ្វារហើយទើបទៅ ។ ក្នុងកាលនោះ ព្រះពោធិសត្វ បានកើត ក្នុងផ្ទៃពោះ នៃនាងយក្ខិនីនោះ ។ ដោយកាលកន្លងទៅបាន ១០ ខែ នាងយក្ខិនីនោះ ក៏បានសម្រាលកូនមក ជាអ្នកមានសេចក្តីស្រឡាញ់ដ៏មានកម្លាំង ក្នុងបិតានិងបុត្រទាំងនោះ បានដាក់បិតានិងបុត្រទាំង ២ នោះ ពួនខាងក្នុង បិទទ្វារហើយ ទើបទៅ ។ ព្រះពោធិសត្វចំរើនវ័យហើយ ដោយលំដាប់ ថ្ងៃមួយ ក្នុងពេលដែលនាងយក្ខិនី

នោះទៅហើយ ទើបប្រមៀលសីលាចេញហើយ ដាក់ចិតា (ឱ្យនៅ) ខាងក្រៅ ។ នាងយក្ខិនី មកហើយ ស្តាប់ឮ ថា "បពិត្រអ្នកម្តាយ កូនបានយកសីលាចេញ, យើងខ្ញុំមិនអាច ដើម្បីអង្គុយនៅ ក្នុងទីងងឹតបានឡើយ" ដូច្នេះ មិនបានពោលពាក្យអ្វីមួយឡើយ ព្រោះសេចក្តីស្រឡាញ់ចំពោះបុត្រ ។ ក្រោយមក ថ្ងៃមួយ កុមារបានសួរថា "បពិត្រលោកឪពុក មុខរបស់អ្នកម្តាយ និង លោកឪពុករបស់ខ្ញុំ មិនដូចគ្នាទេ, តើមានហេតុអ្វី ?" ។ បិតាបានតប ថា "នែកូនសំឡាញ់ មាតារបស់អ្នក ជានាងយក្ខិនី, យើងទាំង ២ នាក់ ជាមនុស្ស" ។ កុមារបានស្តាប់ពាក្យបិតានោះហើយ ក្នុងថ្ងៃមួយ, កាលបើមាតាទៅហើយ, ក៏នាំបិតារត់ចេញ ។ នាងយក្ខិនី មកហើយមិនឃើញជនទាំង ២ នាក់នោះ ទើបរត់ទៅដោយកម្លាំងល្បឿនដូចជាខ្យល់ បានចាប់ជនទាំង ២ នាក់នោះត្រឡប់មកវិញហើយ ។ ក្នុង ២-៣ ថ្ងៃ មកទៀត កាលបើកូននាំគ្នារត់ចេញទៅ យ៉ាងដូច្នេះ, នាងយក្ខិនី ក៏បាននាំយកមកវិញ ។ ព្រះពោធិសត្វ គិត ថា "ឱកាសដែលជាទីកំណត់ គប្បីមានដល់មាតារបស់អាត្មាអញ, ធ្វើដូចម្តេចហ្ន៎ អាត្មាអញ ត្រូវតែសួរខេត្តនៃទីដែលប្រព្រឹត្តទៅ នៃអាជ្ញា របស់មាតាអាត្មាអញនោះ ហើយគប្បីកន្លងនូវខេត្តនោះ រត់គេចចេញទៅ" ហើយ ក៏សួរខេត្តដែននោះ ។

ឯនាងយក្ខិនីនោះ ក៏បានប្រាប់ដល់កូននោះហើយ ។ ព្រះពោធិសត្វ
នោះ ដោយកាលកន្លងទៅបាន ២-៣ ថ្ងៃ ទើបបញ្ជិះចិតាដាក់លើ
ស្មា ហើយក៏រត់ទៅ ដោយល្បឿនលឿនដូចជាខ្យល់ បានទៅដល់
ច្រាំងសមុទ្រដែលជាខេត្តកំណាត់ ទើបបានទៅកាន់កណ្តាលសមុទ្រ
ហើយ ។ ឯនាងយក្ខិនីនោះ បានទៅតាម ឈរនៅ ត្រង់ច្រាំងនៃ
សមុទ្រហើយ សូម្បីសុំអង្វរករ នូវប្តីនិងកូនទាំង ២ នាក់នោះ
ដោយប្រការផ្សេងៗ ក៏មិនអាចដើម្បីឲ្យប្តីនិងកូនទាំង ២ នាក់នោះ
ត្រឡប់វិញបានឡើយ សូម្បីត្រូវសេចក្តីទុក្ខប្រាកដដូច្នោះគ្របសង្កត់
ហើយ ក៏ប្រាថ្នានឹងឲ្យមន្ត ព្រោះសេចក្តីស្រឡាញ់ចំពោះកូន ទើប
បានពោល យ៉ាងដូច្នេះថា “នែកូនសំឡាញ់ ប្រសិនបើ កូនឯងមិន
ត្រឡប់មកវិញទេ, ធម្មតាការរស់នៅ ក្នុងមនុស្សលោក ជាទុក្ខ,
ព្រោះថា អ្នកមិនចេះសិប្បៈ រមែងមិនអាចចិញ្ចឹមជីវិតបានឡើយ,
ម្តាយចេះវិជ្ជាមួយ ឈ្មោះថា ចិន្តាមណី, ដោយអានុភាពនៃវិជ្ជា
ឈ្មោះចិន្តាមណីនោះ បុគ្គលអាច ដើម្បីនឹងទៅតាមគន្លងជើង នៃ
ជនទាំងឡាយសូម្បីអ្នកលួចភ័ណ្ឌៈហើយ ទៅហើយបាន ក្នុងទីបំផុត
នៃ ១២ ឆ្នាំបាន, វិជ្ជាឈ្មោះ ចិន្តាមណីនេះ នឹងជាគ្រឿងចិញ្ចឹម
ជីវិត របស់កូនឯង, នែកូនប្រុសសំឡាញ់ ចូរកូនរៀនយកមន្ត
ដែលមានតម្លៃកាត់មិនបានចុះ” ។ ព្រះពោធិសត្វ ឈរនៅ ត្រង់

ត្រង់កណ្តាលសមុទ្រនុ៎ះឯង ថ្វាយបង្គំម្តាយហើយ រៀនយកនូវមន្ត ថ្វាយបង្គំម្តាយ (ម្តងទៀត) ហើយ ទើបពោលថា "បពិត្រអ្នកម្តាយ សូមអ្នកម្តាយ អញ្ជើញទៅចុះ" ។ នាងយក្ខិនីនោះ ពោលថា "នែកូនមាសម្តាយ កាលបើអ្នកទាំង ២ នាក់ មិនត្រឡប់មកវិញទេ, ជីវិត របស់ម្តាយ គង់មិនមានទេ" ដូច្នេះហើយ ក៏ប្រហារជើមទ្រូង មានហឫទ័យបែកហើយ ព្រោះសេចក្តីសោកចំពោះបុត្រ ស្លាប់ហើយ បានដួលចុះ ក្នុងទីនោះភ្លាម ។ ព្រះអគ្គមហេសីនោះ ក្នុងកាលមុន បានធ្វើមិច្ឆាចារ និយាយកុហកហើយ កើតជានាងយក្ខិនី ព្រោះកម្លាំងនៃការស្បថ ដល់ហើយនូវសេចក្តីស្លាប់ យ៉ាងអនាថា ដោយប្រការដូច្នេះឯង ។

រឿងនាងយក្ខិនីអ្នកប្រព្រឹត្តក្បត់ចិត្ត ចប់ ។

(២២៥) គ្រានោះ ព្រះពោធិសត្វ បានធ្វើនូវជើងថ្កល បូជា (ដុត) មាតាហើយ បានញុំាងទីប៉ាអាឱ្យរលត់ស្រេច ក៏ធ្វើការបូជា ដោយផ្កាឈើ ថ្វាយបង្គំហើយ ទើបទូញយំ បាននាំបិតាទៅកាន់ក្រុងពារាណសី បានឈរនៅត្រង់ទ្វារព្រះរាជវាំងហើយ ឱ្យបុគ្គលក្រាបទូល ដល់ព្រះរាជា ថា "មាណពដែលឆ្លាត ក្នុងគន្លងជើង មកហើយ" ដូច្នេះ, កាលព្រះរាជា ទ្រង់ត្រាស់ ថា "បុរសនោះ ចូរមកចុះ" ដូច្នេះហើយ ក៏ចូលទៅក្រាបថ្វាយបង្គំហើយ ត្រូវព្រះរាជា

អង្គនោះ ត្រាស់សួរហើយ ទើបក្រាបទូលនូវសិប្បៈដែលខ្លួនចេះ, កាលបើព្រះរាជាទ្រង់ត្រាស់បញ្ជា ថា "បើដូច្នោះ ចូរអ្នកឲ្យបង្ហាក នូវយើង" ដូច្នេះ, ទើបក្រាបទូល ថា "ទូលព្រះបង្គំ កាលបានទ្រព្យ ១ ពាន់កហាបណៈ រៀងរាល់ថ្ងៃ នឹងឲ្យបង្ហាក" ។ ព្រះរាជា ទ្រង់ត្រាស់ ថា "ប្រពៃណាស់" ហើយ ទ្រង់ត្រាស់បញ្ជាឲ្យព្រះរាជទានទ្រព្យ ១ ពាន់កហាបណៈ ជារៀងរាល់ថ្ងៃ ។ ក្រោយមក ថ្ងៃមួយ បុរោហិត ក្រាបទូលថា "បពិត្រព្រះមហារាជ យើងទាំងឡាយ មិនដឹងថា 'បុរសនេះ មានសិប្បៈនោះ ឬក៏មិនមានទេ, ពួកយើង នឹងសាកល្បងមើលនូវបុរសនោះ ជាមុនសិន 'ដូច្នេះ" ។ ព្រះរាជា ទ្រង់ព្រមទទួលហើយ ។ ព្រះរាជានិងបុរោហិតទាំងពីរនាក់នោះ កាលធ្វើនូវចោរកម្ម ទើបលួចយកវត្ថុមានតម្លៃ គឺរតនៈ ចុះអំពីប្រាសាទហើយ ទំលុះ ពួដ៏ខាងក្នុងព្រះរាជនិវេសន៍ ៣ ដង ដាក់ជណ្តើរហើយ ទើបចុះទៅខាងក្រៅ តាមកំពូលនៃកំពែង បានចូលទៅកាន់សាលាវិនិច្ឆ័យហើយ ក៏បានមកវិញ ម្តងទៀត ដាក់ជណ្តើរហើយ ទើបចុះទៅ តាមកំពូលនៃកំពែង បានទៅកាន់មាត់ស្រះបោក្ខរណីហើយ បានធ្វើប្រទក្សិណ ៣ ដង ទើបបានចុះទៅ (កាន់ស្រះ) លាក់ភ័ណ្ឌៈ ពួដ៏ខាងក្នុងស្រះបោក្ខរណីហើយ ទើបបានឡើងទៅកាន់ប្រាសាទ ។ ក្នុងថ្ងៃស្អែកឡើង សេចក្តី

កោលាហលតែមួយ បានកើតឡើងហើយ ថា "បានឮថា ពួកចោរ បានលួចយករតនៈ ចេញអំពីព្រះរាជនិវេសន៍ហើយ"។ ព្រះរាជា ទ្រង់ធ្វើដូចជាមិនទ្រង់ជ្រាប ទ្រង់បានត្រាស់បញ្ជាឱ្យហៅ នូវព្រះពោធិសត្វមកហើយ មានព្រះរាជឱង្ការថា "ចូរអ្នកពិចារណារកមើលចោរ"។ ព្រះពោធិសត្វនោះ បានក្រាបទូលថា "បពិត្រព្រះសម្មតិទេព ប្រពៃហើយ" ដូច្នេះ ថ្វាយបង្គំមាគាហើយ ទើបបានរាយមន្ត ឈរនៅត្រង់ផ្នែព្រះរោង ក្រាបទូលថា "បពិត្រព្រះមហារាជ ស្នាមជើង នៃចោរទាំងឡាយ ២ នាក់ រមែងប្រាកដ" ហើយ ទៅក្នុងទីទាំងពួង តាមគន្លងស្នាមជើង នៃចោរទាំង ២ នោះ បាននាំយកកញ្ចប់ភ័ណ្ឌៈ ដូចជាខ្លួនបានដាក់ទុកហើយ ចេញមក សំដែងដល់ព្រះរាជា ហើយក្រាបទូលថា "បពិត្រព្រះមហារាជ ចោរទាំង ២ នាក់នោះ គឺទូលព្រះបង្គំ បានស្គាល់ច្បាស់ហើយ"។

ព្រះរាជា. តើអ្នកអាចចាប់ពួកចោរមកឱ្យបានឬទេ ?។

ព្រះពោធិសត្វ. បពិត្រព្រះសម្មតិទេព ចោរទាំង ២ នោះ នៅក្នុងទីនេះឯង, មិនមែននៅឆ្ងាយទេ។

ព្រះរាជា. ក៏អ្នកណា ជាចោរ ?, អ្នកណា ជាចោរ ?។

ព្រះពោធិសត្វ. បពិត្រព្រះសម្មតិទេព អ្នកណា ប្រាថ្នា, អ្នកនោះឯង ជាចោរ, ហេតុនោះ ចូរលើកទុកសិនចុះ, នឹងមាន

ប្រយោជន៍អ្វី ដោយពួកចោរ ចាប់ដើមអំពីកាលដែលព្រះអង្គ ទ្រង់បានកញ្ចប់នៃកំណ្លោះហើយ, សូមព្រះអង្គ កុំបីត្រាស់សួរឡើយ ។

ព្រះរាជា នែអ្នក ខ្ញុំនឹងឲ្យទ្រព្យ ១ ពាន់កហាបណៈដល់អ្នក, ចូរអ្នកចាប់ចោរទាំងឡាយហើយ យកមកឲ្យខ្ញុំ ។

ព្រះពោធិសត្វ ព្រោះសេចក្តីអនុគ្រោះ ដល់ព្រះរាជា សូម្បីប្រាថ្នានឹងបិទបាំង នូវចោរកម្ម របស់ព្រះអង្គ ក៏ត្រូវព្រះអង្គ ទ្រង់ត្រាស់សួរហើយញុះ ។ ទើបនាំរឿងទាំង ៨ ក្នុងអតីតកាលមក ។

(រឿងទី ១)

(២២៦) ក្នុងអតីតកាល អ្នករបាំម្នាក់ ដែលនៅក្នុងស្រុកក្នុងទីមិនឆ្ងាយ អំពីក្រុងពារាណសី ឈ្មោះថា បាតលី ស្រវឹងសុរាហើយ ដើរឆ្លងស្ទឹង ត្រូវទឹកកួចយកទៅហើយ ពោលថា "ទឹកជាទីពឹងអាស្រ័យ របស់មហាជន រមែងសម្លាប់អាត្មាអញ" ដូច្នេះហើយ ក៏បានធ្វើកាលកិរិយាហើយ ។

(រឿងទី ២)

(២២៧) ក្នុងអតីតកាល ស្មូនឆ្នាំង ដែលនៅក្នុងស្រុកក្បែរមាត់ទ្វារក្រុងពារាណសីម្នាក់ បានយកដីស្អិត ក្នុងអន្លង់មួយដើម្បីប្រយោជន៍ដល់ការធ្វើភាជនៈ ។ ក្នុងខណៈនោះឯង ក្លៀង

ក៏ធ្លាក់ចុះមកហើយ ។ ទឹកជន់មកលិច ញ្ជាំងជើងនៃអន្ទុងឲ្យបាក់ រលំហើយ ។ ក្បាលរបស់ស្ទូនឆ្នាំងនោះ បែកហើយ ព្រោះបាក់ ជើងអន្ទុងនោះ ។ នាយស្ទូនឆ្នាំងនោះ ទូញយំថា "មហាប្រឹថពី ដែលជាទីពឹងអាស្រ័យ របស់មហាជន បានទំលាយក្បាល របស់ អាត្មាអញហើយ" ។

(រឿងទី ៣)

(២២៨) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី កាលបើផ្ទះ ត្រូវភ្លើងឆេះ, ក៏មិនអាចដើម្បីនឹងចេញមកបាន ទើប ពោលថា "ភ្លើងជាទីពឹងអាស្រ័យ របស់មហាជន រមែងឆេះ នូវ អាត្មាអញ" ដូច្នេះហើយ ក៏បានធ្វើកាលៈហើយ ។

(រឿងទី ៤)

(២២៩) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី នោះឯង បរិភោគច្រើនហួសពេក ក៏មិនអាចដើម្បីនឹងញ្ជាំងម្ហូប អាហារ ឲ្យរលាយទៅបាន ទើបពោលថា "ភ័ត្តដែលជាទីពឹង អាស្រ័យ របស់មហាជន រមែងញ្ជាំងអាត្មាអញឲ្យស្លាប់" ដូច្នេះ បានស្លាប់ហើយ ។

(រឿងទី ៥)

(២៣០) ក្នុងអតីតកាល ខ្យល់បានបក់បោកឡើងហើយ បំផ្លាញនូវកោយ របស់បុរសម្នាក់ ក្នុងក្រុងពារាណសីនោះឯង ។ បុរសនោះ បានទូញយំ ថា "ខ្យល់ដែលជាទីពឹងអាស្រ័យ របស់មហាជន ក្នុងរដូវក្តៅ រមែងទម្លាយនូវកោយ របស់អាត្មាអញ" ។

(រឿងទី ៦)

(២៣១) ក្នុងអតីតកាល ក្នុងហិមវន្តប្រទេស បានមានដើមឈើធំ មួយដើម ជាទីនៅអាស្រ័យ របស់សត្វបក្សីជាច្រើនពាន់ ។ មែកទាំងគូនៃដើមឈើធំនោះ បានសង្កៀតគ្នាហើយ ញ៉ាំងផ្សែង និងកំទេចនៃភ្លើង ឲ្យធ្លាក់ចុះហើយ ។ សត្វបក្សីទាំងឡាយ ឃើញនូវផ្សែង និងកំទេចនៃភ្លើងនោះហើយ ទើបពោលថា "ដើមឈើធំនេះ ជាទីពឹងអាស្រ័យ របស់ពួកយើង, ឥឡូវនេះ វាបានញ៉ាំងភ័យឲ្យកើតឡើងហើយ" ដូច្នេះហើយ ក៏ហើរចេញទៅ ។

រឿងទី ៦ ចប់ ។

(រឿងទី ៧)

(រឿងកូនប្រសាស្រីសម្លាប់ម្តាយក្មេក)

(២៣២) ក្នុងអតីតកាល កុលបុត្រម្នាក់ ក្នុងស្រុកឈ្មោះ

កាសី, កាលបើបិតា ធ្វើកាលៈទៅហើយ, ក៏ប្រតិបត្តិនូវមាតា ។ មាតា បាននាំយកស្ត្រីម្នាក់មក ដើម្បីកូនប្រុសនោះ អ្នកមិនប្រាថ្នាចង់បាននុ៎ះឯង ។ ក៏ស្ត្រីនោះ បាននាំមាតារបស់ខ្លួនមកនៅ ក្នុងទីនោះជាដំបូង បានធ្វើឱ្យម្តាយក្មេកស្រឡាញ់ហើយ ក្រោយមក ចំរើនដោយឫត្រ និង ធីតាទាំងឡាយ ក៏ប្រាថ្នាចង់សម្លាប់ម្តាយក្មេកនោះចោល ទើបប្រាប់ ដល់ស្វាមី ។

ស្វាមី. ឈ្មោះថា ការសម្លាប់មនុស្ស ជាកម្មធ្ងន់ណាស់, ពួកយើង នឹងសម្លាប់មាតានោះ បានយ៉ាងដូចម្តេចទៅ ? ។

ភរិយា. បពិត្រលោកប្តី ក្នុងពេលដែលគាត់សម្រាន្តលក់ ពួកយើង នឹងនាំយកគាត់ជាមួយនឹងគ្រែនុ៎ះឯង ទៅបោះចោល ក្នុងស្ទឹងដែលមានសត្វក្រពើកាច។ ក្នុងទីខាងក្រោយផ្ទះ របស់យើង, ក្នុងកាលនោះ សត្វក្រពើទាំងឡាយ នឹងត្របាក់លេចគាត់ ”។

ស្វាមី. នែនាងដ៏ចំរើន មាតា របស់អូន សម្រាន្តនៅ ត្រង់ទីឯណា ? ។

ភរិយា. គាត់សម្រាន្តនៅ ក្បែរមាតា របស់ចង់ឯង ។

ស្វាមី. បើដូច្នោះ ចូរអូនទៅចុះ, ចូរអូន ចងខ្សែ ត្រង់គ្រែដែលមាតា របស់ចង់សម្រាន្តហើយ ធ្វើនូវសញ្ញាទុក ។

ភរិយានោះ បានធ្វើហើយ យ៉ាងដូច្នោះឯង ។

ស្វាមីក្រៅនេះ ពោលថា "ចូរអូនរង់ចាំ បន្តិចសិនចុះ, ចាំឲ្យ ពួកមនុស្ស ដេកលក់សិន" ដូច្នេះហើយ ក៏ធ្វើទំនងដូចជាដេកលក់ ហើយ ទៅចងខ្សែនោះ ត្រង់ត្រែរបស់ម្តាយ នៃភរិយា ស្រេចហើយ ទើបដាស់ភរិយាឲ្យក្រោកឡើង ។ ភរិយា និងស្វាមីទាំង ២ នោះ បានលើកនូវមាតា របស់ភរិយានោះ មួយអន្លើដោយត្រែន៉ុះឯង ទៅ ទម្លាក់ចោល ក្នុងទឹកស្ទឹងហើយ ។ សត្វក្រពើទាំងឡាយ បាន ត្របាក់ស៊ី នូវមាតានៃភរិយានោះហើយ ។ ក្នុងថ្ងៃស្អែកឡើង ភរិយានោះ បានដឹងថា មាតាបានត្រូវផ្លាស់ប្តូរគ្នា ទើបពោលថា "នែលោកប្តី បងឯងបានសម្លាប់ម្តាយ របស់អូនហើយ, ឥឡូវនេះ ពួកយើង នឹងធ្វើជើងថ្ពរ ក្នុងទីប៉ាឆាហើយ ដាក់មាតារបស់បងឯង ក្នុងភ្លើង ឲ្យស្លាប់ទៅ" ។ ស្វាមីនោះ យល់ព្រមថា "ល្អហើយ" ។ ស្វាមីនិងភរិយាទាំង ២ នោះ បាននាំយកមាតា ដែលកំពុងតែដេក លក់នោះ ទៅដាក់ (លើជើងថ្ពរនោះ) ហើយ ។ ត្រានោះ ស្វាមី នោះ ពោលថា "នែនាងដ៏ចំរើន តើអូនបានយកភ្លើងមកទេ ?" ។

ភរិយា . បពិត្រអ្នកប្តី អូនភ្លេចទៅហើយ ។

ស្វាមី . បើដូច្នោះ ចូរអូនទៅយកមក ។

ភរិយា . បពិត្រអ្នកប្តី អូនមិនអាច (មិនហ៊ានទៅទេ), សូម្បីបើបងឯងទៅហើយ, អូនក៏មិនអាចនៅបានដែរ, ពួកយើង

នឹងទៅទាំង ២ នាក់ ។

កាលបើស្វាមីនិងភរិយាទាំង ២ នាក់នោះ ទៅហើយ, ស្ត្រីចាស់ ត្រូវខ្យល់ត្រជាក់ជាត់ ឱ្យក្រោកឡើងហើយ ដឹងថា "អ្នកទាំង ២ នាក់នេះ ប្រាថ្នាចង់សម្លាប់អាត្មាអញ បានទៅហើយ ដើម្បីប្រយោជន៍ដល់ភ្លើង" ដូច្នេះហើយ ទើបគិតថា "ពួកវាទាំង ២ នាក់នេះ មិនដឹងកម្លាំង របស់អញទេ" ដូច្នេះ បានញុំាងសាកសពមួយ ឱ្យដេកលើគ្រែហើយ យកកំណាត់សំពត់ចាស់ៗ មកបិទបាំងស្រេចហើយក៏ដើរ ចូលទៅកាន់គុហាជាទីសម្រាកមួយ ក្នុងទីប៉ារានោះឯង ។ ម្ចាយចាស់នោះ នាំកូនប្រសាស្រីមក ដើម្បីប្រយោជន៍ដល់ទីពឹងអាស្រ័យ របស់ខ្លួន តែត្រឡប់ជាមានភ័យកើតឡើងអំពីកូនប្រសានោះវិញ ដោយប្រការដូច្នេះ ។ ស្វាមីនិងភរិយាទាំង ២ នាក់ក្រៅនេះ នាំយកភ្លើងមកហើយ ក៏ដុតសាកសព ដោយសេចក្តីសម្គាល់ថាស្ត្រីចាស់ ហើយបានចៀសចេញទៅ ។ ក៏ក្នុងទីសម្រាកក្នុងគុហានោះ ចោរម្នាក់ បានលាក់កញ្ចប់ភណ្ឌៈទុកមុន ។ ចោរនោះ មកហើយ ដើម្បីយកនូវកញ្ចប់ភណ្ឌៈនោះ បានឃើញនូវស្ត្រីចាស់នោះហើយ មានសេចក្តីសម្គាល់ថា ជានាងយក្ខិនី ទើបគិតថា "កញ្ចប់ភណ្ឌៈ របស់អញ ត្រូវអមនុស្សហួងហែងហើយ" ដូច្នេះហើយ ក៏បានទៅនាំយកគ្រូខ្មោចមក ។ គ្រូធ្វើនូវមន្ត ចូលទៅកាន់

គុហាហើយ ។ ស្ត្រីចាស់នោះ ពោលថា "ខ្ញុំមិនមែនជានាងយក្ខិនីទេ, អ្នកចូរអញ្ជើញមកចុះ, យើងទាំង ២ នាក់នឹងចែកទ្រព្យគ្នា" ។ គ្រូពោលថា "ខ្ញុំគប្បីជឿបាន យ៉ាងដូចម្តេច ?" ។ ស្ត្រីចាស់នោះពោលថា "ចូរអ្នក ដាក់អណ្តាត របស់អ្នក មកលើអណ្តាត របស់នាងខ្ញុំចុះ" ។ គ្រូនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ ស្ត្រីចាស់នោះបានកាត់អណ្តាតរបស់គ្រូនោះ ឲ្យដាច់ហើយ ។ គ្រូនោះ គិតថា "នាងនេះជានាងយក្ខិនី ពិតមែន" ដូច្នេះហើយ ក៏ស្រែកយំ បានគេចចេញទៅហើយ ។ ចំណែកចោរ ក៏បានរត់គេចទៅហើយដែរ ។ ក្នុងថ្ងៃស្អែកឡើង ម្តាយចាស់នោះ បាននាំយកកញ្ចប់រតនៈផ្សេង ។ ដើរទៅកាន់ផ្ទះហើយ ។ កូនប្រសាស្រី បានឃើញទ្រព្យនោះហើយ ទើបសួរថា "បពិត្រអ្នកម្តាយ តើអ្នកម្តាយ បានទ្រព្យនេះ ក្នុងទីឯណា ?" ។ ម្តាយចាស់នោះ ឆ្លើយថា "នែនាង ជនទាំងឡាយដែលត្រូវគេដុតហើយ លើជើងថ្កូរឈើ ក្នុងទីប៉ាឆា រមែងបាននូវទ្រព្យដូច្នេះ" ។ កូនប្រសាស្រីនោះ សួរថា "បពិត្រអ្នកម្តាយ តើកូនស្រី អាចបានដែរឬទេ" ។ ម្តាយចាស់ ឆ្លើយថា "កូនឯង ជាអ្នកប្រាកដស្មើដូចម្តាយ នឹងបាន" ។ កូនប្រសាស្រីនោះ ជាមនុស្សល្ងង់ខ្លៅ បានពោលប្រាប់ ដល់ប្តីដែលជាមនុស្សល្ងង់ខ្លៅ ព្រោះសេចក្តីល្មោភក្នុងទ្រព្យ ទើបឲ្យគេដុតខ្លួន ក្នុងប៉ាឆានោះ បានធ្វើ

នូវកាលៈហើយ ។ កូនប្រសាស្រីនោះ ដល់ហើយនូវសេចក្តីស្លាប់ ខ្លួនឯងតែម្តង ព្រោះប្រាថ្នាចង់ឱ្យអ្នកដទៃស្លាប់ដោយប្រការដូច្នេះ ។

រឿងកូនប្រសាស្រីសម្លាប់ម្តាយក្មេក ចប់ ។

(រឿងទី ៨)

(២៣៣) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី ប្រាថ្នាបុត្រ បានបុត្រនោះហើយ ចិញ្ចឹម ដោយគិតថា "បុត្រនេះ នឹងចិញ្ចឹមអញ ក្នុងពេលខ្លួនចាស់ជរា" ។ ប៉ុន្តែបុត្របានបណ្តេញ ឪពុកនោះ ដែលដល់ជរាភាពហើយ ចេញអំពីផ្ទះ ដោយពោលថា "លោកឪពុក មិនអាចដើម្បីធ្វើការងារបាន, ចូរលោកឪពុកចេញ អំពីផ្ទះនេះទៅចុះ" ។ ឪពុកនោះ ចិញ្ចឹមជីវិត ដោយការសុំទាន គេ ដោយសេចក្តីលំបាក ទើបទូញយំ ថា "អាត្មាអញ ចិញ្ចឹមហើយ នូវបុត្រណា ដោយគិតថា 'បុត្រនឹងជាទីពឹងអាស្រ័យ របស់អញ ក្នុងពេលដែលខ្លួនចាស់' ដូច្នេះ, ភ័យកើតឡើងហើយ ដល់អញ ព្រោះបុត្រនោះ" ដូច្នេះ ។

ព្រះពោធិសត្វនោះ លុះនាំអតីតនិទានទាំងឡាយមក យ៉ាងដូច្នេះហើយ ទើបក្រាបទូលថា "បុគ្គលម្នាក់ដែលជាទីពឹងអាស្រ័យ របស់មហាជន ដូចជាវត្ថុទាំងឡាយ មានទឹកជាដើម ជាទីពឹង

អាស្រ័យ របស់មហាជន ដូចជាដើមឈើ ជាទីពឹងអាស្រ័យ របស់សត្វស្លាបទាំងឡាយ ដូចជាកូនប្រសាស្រី ជាទីពឹងអាស្រ័យ របស់ម្តាយក្មេក និង ដូចជាកូន ជាទីពឹងអាស្រ័យ របស់ឪពុក បានលួចយកកញ្ចប់ភណ្ឌៈហើយ, បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាបថា 'បុរសឈ្មោះនុ៎ះ ជាចោរ' ដូច្នេះ ព្រោះហេតុនេះ"។ ព្រះរាជា ទ្រង់មានព្រះរាជឱង្ការថា "បើដូច្នោះ ចូរអ្នកប្រកាសក្នុងកណ្តាលបរិស័ទថា 'អ្នកឈ្មោះនុ៎ះ ជាចោរ និង អ្នកឈ្មោះនុ៎ះ ជាចោរ' ដូច្នេះ"។ ព្រះពោធិសត្វ ពោលថា "ព្រះរាជាព្រះអង្គនេះ រមែងមិនឱ្យ ដើម្បីរក្សានូវព្រះអង្គ, ឥឡូវនេះ ខ្ញុំនឹងចាប់នូវចោរ" ដូច្នេះហើយ ទើបពោលថា "ម្នាលអ្នកដ៏ចំរើនទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់(ពាក្យ)របស់ខ្ញុំ, ព្រះរាជា និងបុរោហិត បានធ្វើហើយ នូវចោរកម្ម, ចាប់ដើមអំពីពេលនេះទៅ អ្នកទាំងឡាយ ចូររក្សា នូវទ្រព្យនិងស្រូវ ដែលជារបស់នៃខ្លួន"។ ពួកមនុស្សទាំងឡាយ ស្តាប់ពាក្យនោះហើយ និយាយថា "ព្រះរាជាព្រះអង្គនេះ ទ្រង់ប្រាថ្នាដើម្បីលើកឡើង នូវទោស មកលើបុគ្គលដទៃ ទើបទ្រង់លាក់ភណ្ឌៈ របស់ព្រះអង្គ ទុកក្នុងស្រះបោក្ខរណី ដោយព្រះអង្គឯងតែម្តងហើយ ទ្រង់ត្រាស់ឱ្យស្វែងរកពួកចោរ, ពេលឥឡូវនេះ តាំងអំពីពេលនេះតទៅ ពួកយើងទាំងឡាយ នឹង

សម្លាប់ព្រះរាជាដែលអាក្រក់នោះចោល ដើម្បីកុំឲ្យធ្វើនូវចោរកម្ម តទៅទៀត" ដូច្នេះហើយ មានដៃកាន់ដំបងនិងអន្ទងជាដើម បានក្រោកឡើងហើយ រាយព្រះរាជាព្រមទាំងបុរោហិត ឲ្យដល់ការក្សប់ជីវិត បានអភិសេកព្រះពោធិសត្វ ក្នុងរាជសម្បត្តិហើយ ។

ក៏បណ្តាជនទាំងនោះ អ្នករបាំឈ្មោះបាតលី ដល់ហើយ នូវសេចក្តីស្លាប់ យ៉ាងអនាថា ព្រោះទោសនៃសុរា, កូនប្រសាស្រី ដល់ហើយ នូវសេចក្តីស្លាប់ យ៉ាងអនាថា ព្រោះទោសនៃការសម្លាប់សត្វមានជីវិត ក្នុងចំណែកនៃកាលជាខាងដើម, ព្រះរាជា និងបុរោហិតទាំង ២ រូបនេះ ដល់ហើយនូវសេចក្តីស្លាប់ យ៉ាងអនាថា ព្រោះទោសនៃអទិន្នាទាន ដូច្នេះឯង ។

ក៏រឿងទាំងអស់ តាមដែលបានពោលមកហើយនេះ បណ្ឌិតគប្បីទាញយក ដោយពិស្តារ ចាកអដ្ឋកថាចតុក្កសុលជាតក ក្នុងនវកនិបាត ។

(២៣៤) បុគ្គលអ្នកបង្កពៀរ រមែងដល់ នូវសេចក្តីទុក្ខដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ បុគ្គលអ្នកភ័យខ្លាចតែពៀរ គប្បីវៀរចាកពៀរនោះ ។ មួយទៀត បុគ្គលអ្នកដែលភ័យខ្លាចអំពីនរក គប្បីវៀរចាកពៀរ ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ព្រះសារីបុត្តត្ថេរ ទើប

ទ្រង់ត្រាស់ទុកហើយ ក្នុងគិហិសូត្រ ក្នុងចតុត្ថបណ្ណាសកៈ[1] នៃ
បញ្ចកនិបាត អង្គុត្តរនិកាយ ថា ÷

"អ្នកប្រាជ្ញ ឃើញភ័យ ក្នុងនរកហើយ ត្រូវវៀរ
បាបទាំងឡាយ, ត្រូវសមាទាន នូវអរិយធម៌
ហើយវៀរ ។ កាលបើមានសេចក្តីព្យាយាម,
មិនត្រូវបៀតបៀនសត្វទាំងឡាយផង កាលដឹង
មិនត្រូវនិយាយកុហកផង មិនត្រូវកាន់យកទ្រព្យ
ដែលគេមិនបានឲ្យផង ត្រូវសន្តោសតែនឹង
ភរិយារបស់ខ្លួន មិនត្រូវត្រេកត្រអាលនឹងភរិយា
របស់ជនដទៃផង មិនត្រូវផឹកមេរ័យ និងសុរា
ដែលនាំចិត្តឲ្យវង្វេងផង" ។

អដ្ឋកថាគិហិសូត្រនោះ ថា "សីល ៥ ព្រះមានព្រះភាគ ទ្រង់
ត្រាស់ថា 'អរិយធម៌' ក្នុងពាក្យថា '**អរិយធម្មំ សមាទាយ**' នេះ ។
២ បទថា '**មេរយំ វារុណឹ**' មានសេចក្តីថា នូវមេរ័យ ៤ យ៉ាង
និងសុរា ៥ យ៉ាង" ។

(២៣៥) ព្រោះហេតុនោះ កុសលចេតនាអ្នកបណ្តោញពៀរ
ពោលគឺអរិយធម៌ បណ្ឌិតត្រូវតែសមាទាន ដោយពិត ។ ព្រោះ

---

[1] ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ១៧១

បុគ្គលកាលសមាទានកុសលចេតនាអ្នកបណ្តោញពៀរនោះ ឈ្មោះថា ឱ្យទាន ពោលគឺវិរ័តិ ដែលមានផលច្រើនជាង ។ ពិតមែនដូច្នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទាន ៤ យ៉ាង ក្នុងកូដទន្តសូត្រ ដោយឈ្មោះថា យញ្ញ យ៉ាងដូច្នេះថា "យញ្ញ ពោលគឺការឱ្យភត្ត ជាប្រចាំ មានផលច្រើនជាង យញ្ញជាប្រក្រតី, យញ្ញ ពោលគឺការឱ្យវិហារ មានផលច្រើនជាង យញ្ញ ពោលគឺការឱ្យភត្ត ជាប្រចាំនោះ, យញ្ញ ពោលគឺការដល់សរណៈ មានផលច្រើនជាង យញ្ញ ពោលគឺការឱ្យវិហារនោះ, យញ្ញ ពោលគឺសីល ៥ មានផលច្រើនជាង យញ្ញ ពោលគឺការដល់សរណៈនោះ" ដូច្នេះ ។

(២៣៦) ក៏ក្នុងអដ្ឋកថាកូដទន្តសូត្រនោះ លោកពោលសេចក្តីថា "ព្រោះការដល់សរណៈ ជាគុណជាតឈ្មោះថា យញ្ញ ដោយអំណាចការលះបង់នូវជីវិត ដល់ព្រះរតនៈទាំង ៣ រមែងឱ្យនូវសម្បត្តិក្នុងឋានសួគ៌ ព្រោះហេតុនោះ ការដល់សរណៈ ទើបមានផលច្រើនជាងការឱ្យវិហារទៅទៀត ។ មួយទៀត សីល ៥ នោះ មានផលច្រើនជាងការដល់សរណៈនោះទៅទៀត ព្រោះការមិនមានទានដែលដូចជាសីល ៥" ដូច្នេះហើយ ដើម្បីនឹងញុំាងសេចក្តីនោះ ឱ្យសម្រេច ដោយបាលី ទើបសំដែងបាលីថា "ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ចាត់ជាមហាទាន ជាទានដែលបណ្ឌិតដឹងថា

ជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ (កល្យាណជន) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនធ្លាប់រោយរាយហើយ រមែងមិនខ្ជាត់ខ្ជាយ (ក្នុងពេលឥឡូវនេះ) នឹងមិនខ្ជាត់ខ្ជាយ (ក្នុងអនាគត) ជាទានដែលសមណៈ ឬព្រាហ្មណ៍ទាំងឡាយ ជាវិញ្ញូជន មិនបានតិះដៀលហើយ" ។ ទាន ៥ យ៉ាង តើដូចម្តេចខ្លះ?[1] ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ លះបង់បាណាតិបាតហើយ ជាអ្នកវៀរចាកបាណាតិបាត, ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកវៀរចាកបាណាតិបាតហើយ រមែងឈ្មោះថាឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន, លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយ ទាននេះ ចាត់ជាមហាទាន ជាទានដែលបណ្ឌិតដឹងថាជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ (កល្យាណជន) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនធ្លាប់រោយរាយហើយ រមែងមិនខ្ជាត់

---

១ ត្រៃបិដក ភាគទី ៤៨ / ទំព័រទី ១៧៨

ខ្ចាយ នឹងមិនខ្ចាត់ខ្ចាយ ជាទានដែលពួកសមណៈ ឬព្រាហ្មណ៍ ជាវិញ្ញូជន មិនតិះដៀលឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន . . . លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ . . . លះបង់មុសាវាទ វៀរចាកមុសាវាទ . . . លះបង់សុរាមេរយ-មជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន . . . ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះឯង ចាត់ជាមហាទាន . . . ជាទានដែលសមណៈ ឬ ព្រាហ្មណ៍ទាំងឡាយ មិនតិះដៀលឡើយ” ដូច្នេះហើយ ពោលទៀតថា “ក៏សីល ៥ នេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា យ័ញ្ញ ព្រោះភាវៈជាសីលដែលព្រះអរិយសាវ័ក បានសមាទានហើយ ដោយតាំងចិត្តថា ‘អញ នឹងលះបង់ នូវសេចក្តីស្រឡាញ់ខ្លួន និង សេចក្តីស្រឡាញ់ជីវិតហើយ រក្សា’ ដូច្នេះ” ។

(២៣៧) ជីកាកូដទន្តសូត្រនោះថា “ទានទាំងឡាយ ឈ្មោះថា អគ្គញ្ញៈ ព្រោះភាវៈជាទានដែលបណ្ឌិតដឹងថា ‘ប្រសើរ’ ។ ឈ្មោះថា រត្តញ្ញៈ ព្រោះភាវៈជាទានដែលបណ្ឌិតដឹងហើយ ដោយរាត្រីដ៏យូរ ។ ឈ្មោះថា វំសញ្ញៈ ព្រោះភាវៈជាទានដែលបណ្ឌិតដឹងថា ‘ជាវង្សៃនៃអរិយជនទាំងឡាយ គឺនៃសាធុជនទាំងឡាយ’ ។ ឈ្មោះថា បោរាណៈ ព្រោះអត្ថថា ‘ទានទាំងឡាយនុ៎ះ ជារបស់នៃ

ពួកបូរាណ គឺពួកបុរសក្នុងជំនាន់ដើម' ។ ឈ្មោះថា អសង្កិណៈ ព្រោះអត្ថថា 'ទានទាំងនោះ គឺសាធុជនទាំងឡាយ មិនរោយរាយ គឺមិនបោះចោល មិនបោះបង់ចោលហើយ ដោយប្រការទាំងពួង គឺសូម្បីដោយប្រការណាៗមួយ' ។ មួយទៀត ទានទាំងឡាយ នោះ មានន័យ ដូចតទៅនេះ ទានទាំងនុ៎ះ គឺសាធុជនទាំងឡាយ មិន រោយរាយហើយ ក្នុងអតីតកាល យ៉ាងណាមិញ, ក្នុងកាលឥឡូវ នេះ និងក្នុងអនាគត ក៏មិនធ្លាប់រោយរាយហើយ យ៉ាងដូច្នោះដែរ ហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា '**អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ**' ។ ព្រោះភាវៈជាទានដែលលោកមិនរោយរាយនោះឯង ទើបឈ្មោះថា ជាទានដែលសមណៈ ឬព្រាហ្មណ៍ទាំងឡាយ មិនតិះដៀលហើយ គឺមិនបដិសេធហើយ ។ ព្រោះថា ក្នុងកាលណាក៏ដោយ សមណៈនិងព្រាហ្មណ៍ទាំងឡាយ ជាវិញ្ញូ រមែងមិនអំណោយបាបធម៌ មានការបៀតបៀនជាដើម ។ ច្រើនបទថា "**អបរិមាណានំ សត្តានំ អភយំ ទេតិ**' មានសេចក្តីថា ឈ្មោះថា រមែងឲ្យនូវភាពមិនមានភ័យ ដល់ពួកសត្វ សូម្បីទាំងអស់ ព្រោះភាវៈជាអ្នកមានអាជ្ញា ក្នុងសត្វទាំងពួង បានទម្លាក់ចោលហើយ ។ ព្រោះភ័យអំពីព្រះអរិយសាវ័ក រមែងមិនមាន ដល់ជនណាមួយឡើយ ។ បទថា '**អវេរំ**' ប្រែថា ភាពមិនមានពៀរ ។

បទថា '**អព្យាបជ្ឈំ**' ប្រែថា ភាពជាអ្នកមិនមានទុក្ខ" ដូច្នេះ ។

(២៣៨) អាចារ្យអ្នកចោទ គប្បីចោទថា "បញ្ចសីល ប្រព្រឹត្តទៅក្នុងកាលទាំងពួង, មួយទៀត បញ្ចសីលនោះ មិនមែនជាទីកើតនៃវិមុត្តិ ដោយចំណែកមួយ, ចំណែក សរណាគមន៍ មានកិរិយាឧបត្ថម្ភឡើង នៃព្រះពុទ្ធជាហេតុ ជាទីកើតឡើងនៃវិមុត្តិ ដោយចំណែកមួយមែនពិត មិនមែនទេឬ ?, ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ភាវៈ នៃបញ្ចសីល ថាមានផលច្រើនជាង សរណាគមន៍ ក្នុងកូដទន្តសូត្រនោះ ?" ។ ខ្ញុំនឹងឆ្លើយ ។ ភាវៈនៃបញ្ចសីល មានផលច្រើនជាង សរណាគមន៍នុ៎ះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយក ត្រឹមតែសីល ៥ ប៉ុណ្ណោះ ។ ប៉ុន្តែ ព្រះអង្គត្រាស់សំដៅយកបញ្ចសីល ដែលបុគ្គលតាំងនៅក្នុងសរណៈហើយ ទើបរក្សា ។ ដោយហេតុនោះ ក្នុងអដ្ឋកថាកូដទន្តសូត្រ ព្រះអដ្ឋកថាចារ្យ ទើបពោលថា "សរណាគមន៍នុ៎ះឯង ប្រសើរជាងបញ្ចសីល ក៏ពិតមែន, ទោះជាដូច្នោះ បញ្ចសីលនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា 'មានផលច្រើន ដោយអំណាចសីលដែលបុគ្គលតាំងនៅ ក្នុងសរណៈហើយ ទើបរក្សា' ដូច្នេះ" ។

ជីកាកូដទន្តសូត្រនោះថា "បទថា '**ជេដ្ឋកំ**' គឺខ្ពង់ខ្ពស់ ។ ដោយ ២ បទថា '**សរណោ បតិដ្ឋាយ**' នេះ ព្រះអដ្ឋកថាចារ្យ

ពោលនូវភាវៈ នៃសីលនោះ គឺសរណាគមន៍ តាក់តែងហើយ" ។

អដ្ឋកថាកថាវត្ថុថា "វិរតិ ឈ្មោះថា ទាន ព្រោះអត្ថថា កាត់ទម្លាក់ និង ព្រោះអត្ថថាកាត់ផ្តាច់ ។ មែនពិត វិរតិនោះ កាលកើតឡើង រមែងកាត់ចោល និង រមែងកាត់ផ្តាត់ នូវចេតនាជាគ្រឿងទ្រុស្តសីល ពោលគឺ ហេតុដែលគួរខ្លាច និង ហេតុដែលគួរភ័យខ្លាច ជាដើម ព្រោះហេតុនោះ វិរតិនោះ ទើបឈ្មោះថា ទាន" ។

ដីកានៃកូដទន្តសូត្រថា "ពួកនៃធាតុមាន **ទិវ** ធាតុជាដើម ថា '**ទា** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថាកាត់ទម្លាក់ សម្រេចរូបជា **ទិយតិ**' ។ ភាវៈនៃសីលជាគុណជាត ឈ្មោះថា ទាន ព្រោះភាវៈនៃសីលនោះ ជាអភ័យទាន, ម្យ៉ាងទៀត បុគ្គល រមែងចិញ្ចឹម គឺរមែងរក្សា នូវពួកសត្វ មិនមានសេសសល់ ដោយចេតនាកម្ម នោះ ព្រោះហេតុនោះ ចេតនាកម្មនោះ ឈ្មោះថា ទាន គឺសីល" ។

ពួកនៃធាតុមាន **ភូ** ធាតុជាដើមថា "**ទេ** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថា ចិញ្ចឹម, ចេតនាកម្មណា រមែងចិញ្ចឹម គឺរមែងរក្សា ព្រោះហេតុនោះ ចេតនាកម្មនោះ ឈ្មោះថា អ្នកចិញ្ចឹម គឺចេតនាកម្ម អ្នករក្សា ។

ពណ៌នាពីការវៀរចាកបាប និង ការសង្រួមចាកការផឹកទឹកស្រវឹង ចប់ ។

ពណ៌នាអំពីសេចក្តីមិនប្រមាទ

(២៣៩) ធម៌មួយ ដែលជាសឹកសត្រូវ ដល់សេចក្តីប្រមាទ ឈ្មោះថា សេចក្តីមិនប្រមាទ ។ បណ្តាសេចក្តីប្រមាទ និងសេចក្តីមិនប្រមាទទាំង ២ នោះ អាការ គឺការស្រែងទូទៅ ឈ្មោះថា សេចក្តីប្រមាទ ។ មែនពិត ព្រះមានព្រះភាគ[1] ទ្រង់ត្រាស់ ថា “បណ្តាសេចក្តីប្រមាទ និង សេចក្តីមិនប្រមាទទាំង ២ នោះ សេចក្តីប្រមាទតើដូចម្តេច ? ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ដោយកាយទុច្ចរិតក្តី ដោយវចីទុច្ចរិតក្តី ដោយមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តិទំនង់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការធ្វេសប្រហែស ក្នុងការចំរើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះ ណា, នេះហៅថា សេចក្តីប្រមាទ ។

បាលីខុទ្ទកវត្ថុវិភង្គ ចប់ ។

---

១ ត្រៃបិដក ភាគទី ៨២ / ទំព័រទី ១៥១

(២៤០) អដ្ឋកថាវិភង្គថា "២ បទថា **'ចិត្តស្ស វោស្សគ្គោ'** គឺការមិនអត់សង្កត់ (ចិត្ត) ដោយសតិ ហើយបណ្តោយចិត្តទៅក្នុងទីទាំងឡាយ មានប្រមាណប៉ុណ្ណោះនេះ, អធិប្បាយថា 'កិរិយាប្រាសចាកសតិ'។ បទថា **'វោស្សគ្គានុប្បទានំ'** បានដល់ កិរិយាឱ្យកម្លាំង ដល់ការបណ្តោយ, អធិប្បាយថា 'ការបណ្តោយ (ចិត្ត) ទៅញយៗ'។ ការមិនធ្វើដោយគោរព ដោយអំណាចការធ្វើដោយមិនគោរព ដល់បុគ្គលក្តី ដល់ទេយ្យធម៌ក្តី ក្នុងការចំរើននូវកុសលធម៌ទាំងឡាយ មានទានជាដើមនេះ ឈ្មោះថា ការមិនធ្វើដោយគោរព"។

ជីកាឆដ្ឋវគ្គ ក្នុងឯកនិបាត អង្គុត្តរនិកាយថា "ការមិនធ្វើដោយគោរព ដល់បុគ្គលក្តី ដល់ទេយ្យធម៌ក្តី ក្នុងការប្រព្រឹត្តិនូវកុសលធម៌មានទានជាដើមនោះ ឈ្មោះថា **អសក្កច្ចកិរិយតា**។ ការមាន នៃសេចក្តីជាប់តគ្នា ឈ្មោះថា ភាវៈនៃសេចក្តីព្យាយាមប្រព្រឹត្តទៅរឿយៗ, ការធ្វើ ដោយភាវៈនៃសេចក្តីព្យាយាមដែលប្រព្រឹត្តទៅរឿយៗ ឈ្មោះថា ការធ្វើដោយសេចក្តីជាប់តគ្នា, **សាតច្ចកិរិយា** នោះឯង ឈ្មោះថា ការធ្វើដោយសេចក្តីជាប់តគ្នា, កិរិយាធ្វើដោយសេចក្តីជាប់តគ្នា មិនមាន ឈ្មោះថា ការធ្វើដោយសេចក្តីមិនជាប់តគ្នា។ បទថា **'អនដ្ឋិតកិរិយតា'** គឺការធ្វើ

ដោយមិនឈប់ មិនមាន បានដល់ ការធ្វើដោយគ្មានចន្លោះ មិនមាន ឈ្មោះថា ភាវៈមិនមានការធ្វើដោយមិនឈប់ "។

(២៤១) អដ្ឋកថាវិភង្គថា "ការធ្វើដោយមិនឈប់ មិនមាន ឈ្មោះថា ភាវៈមិនមានការធ្វើដោយមិនឈប់ ។ ធម្មតា សត្វ បង្គួយ (លូន) ទៅបានបន្តិចហើយ ក៏ឈប់បន្តិច មិនលូនទៅជាប់តគ្នាទេ យ៉ាងណាមិញ, បុគ្គលឯណា ក្នុងថ្ងៃមួយ ថ្វាយទានក្តី ធ្វើការបូជាក្តី ស្តាប់ធម៌ក្តី បំពេញសមណធម៌ក្តី ហើយ តមកអស់កាលដ៏យូរ ទើបបានធ្វើម្តងទៀត មិនបានញ៉ាំងកុសលទាំងនោះ ឲ្យប្រព្រឹត្តទៅ ជាប់តគ្នាទៀយ ក៏យ៉ាងដូច្នោះដែរ, កិរិយាធ្វើនោះ របស់បុគ្គលនោះ ព្រះមានព្រះភាគ ត្រាស់ហៅថា ភាវៈមិនមានការធ្វើដោយមិនជាប់តគ្នា ។ បទថា "**ឱលីនវុត្តិតា**" គឺ ឈ្មោះថា ភាវៈជាអ្នកប្រព្រឹត្តទំរន់ ព្រោះមិនមានសេចក្តីខ្ជះខ្ជែង ពោលគឺ ការធ្វើមិនមានចន្លោះ ។ ភាវៈជាអ្នកមានសេចក្តីពេញចិត្ត ដោយអំណាចសេចក្តីព្យាយាម ក្នុងការបំពេញកុសល បានទម្លាក់ចោលហើយ ឈ្មោះថា ភាវៈជាអ្នកមានធ្នន់ បានទម្លាក់ចោលហើយ ។ កិរិយាទម្លាក់ចុះ នូវធុរៈ ដោយអំណាចនៃសេចក្តីព្យាយាម ឈ្មោះថា ភាវៈជាអ្នកមានធុរៈដាក់ចុះហើយ, អធិប្បាយថា " ភាវៈជាអ្នកមានចិត្តចុះខ្សឹនថយ "។ ការមិនមានកិរិយាតាំងនៅ ក្នុងការបំពេញ

កុសល ឈ្មោះថា កិរិយាមិនតាំងមាំ" ។

ជីកាឯកនិបាត អង្គុត្តរនិកាយ ថា "កិរិយាមិនប្រកបរឿយៗ ឈ្មោះថា ការមិនតាមប្រកប ។ ការមិនមាន នៃកិច្ចទាំងឡាយមាន កិរិយាគប់រកជាដើម ក្នុងកុសលធម៌ទាំងឡាយ ឈ្មោះថា អាការមាន ការមិនសេពគប់ជាដើម ។ សព្ទថា **'បមាទោ'** ជាសព្ទសំដែងដោយសរុប ។ សព្ទថា **'បមជ្ជនា'** ជាសព្ទសំដែងអាការៈ ។ សព្ទថា **'បមជ្ជិតត្តំ'** ជាសព្ទសំដែងនូវភាវៈ" ។

(២៤២) អដ្ឋកថាវិភង្គ ថា "ការធ្វេសប្រហែស ឈ្មោះថា សេចក្តីប្រមាទ ។ ពាក្យថា **'យោ ឯវរូបោ បមាទោ'** នេះ ឈ្មោះថា ជាពាក្យសំដែងនូវអាការៈ ព្រោះមិនមានទីបំផុត នៃការបរិយាយអត្ថ និងការបរិយាយព្យញ្ជនៈ ។

ដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់អធិប្បាយថា 'សេចក្តីប្រមាទនេះឯណា ដែលតថាគតសំដែងហើយ តាំងតែពីដើម, មួយទៀត សេចក្តីប្រមាទឯណាដទៃទៀត ដែលមានអាការៈយ៉ាងដូច្នេះ មានជាតិយ៉ាងដូច្នេះ ដែលដល់នូវការរាប់ថា 'សេចក្តីធ្វេសប្រហែស' ដោយអំណាចនៃអាការៈ គឺកិរិយាស្រវឹងទួទៅ ថា 'សេចក្តីប្រមាទ' ដោយអំណាចភាវៈជាធម្មជាតិ គឺការស្រវឹងទួទៅ, សេចក្តីស្រវឹងទួទៅនេះ តថាគតហៅថា 'សេចក្តីប្រមាទ' ។

ក៏សេចក្តីប្រមាទនេះ បណ្ឌិតគប្បីជ្រាប ដោយលក្ខណៈថា មានការលះបង់សតិទៅ ក្នុងកាមគុណទាំង ៥ ជាលក្ខណៈ, មានការលះបង់នូវសតិទៅ ក្នុងកាមគុណទាំង ៥ នោះ ដូចគ្នាដែរ ជាអាការៈ" ។

(២៤៣) ក្នុងសេចក្តីប្រមាទ និង សេចក្តីមិនប្រមាទទាំង ២ យ៉ាងនោះ សេចក្តីប្រមាទ រមែងប្រព្រឹត្តទៅ ដើម្បីកិរិយាកើតឡើងនៃអកុសល និង ដើម្បីសេចក្តីសាបសូន្យនៃកុសល, សេចក្តីមិនប្រមាទ រមែងប្រព្រឹត្តទៅ ដើម្បីកិរិយាកើតឡើងនៃកុសល និង ដើម្បីសេចក្តីសាបសូន្យទៅនៃអកុសល ។ ដោយហេតុនោះ ក្នុងវគ្គទី ៦ នៃឯកនិបាត អង្គុត្តរនិកាយ[1] ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគត រកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចជាសេចក្តីប្រមាទនេះ សោះឡើយ, ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលប្រមាទហើយ, ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង" និងទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌ មិន

---

១ ត្រៃបិដក ភាគទី ៤០ / ទំព័រទី ២១

ទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចសេចក្តីមិនប្រមាទនេះ សោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនប្រមាទហើយ, ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង, ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង" ។

(២៤៤) អដ្ឋកថានៃសូត្រទាំង ២ នោះ ថា "បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា '**យថយិទំ ភិក្ខវេ បមាទោ**' នេះ មានវិនិច្ឆ័យ ដូចតទៅនេះ ÷

បទថា '**ភិក្ខវេ**' ជាអាលបនៈ ។ អធិប្បាយថា 'សេចក្តីប្រមាទនេះ យ៉ាងណា' ។ អាការៈនៃសេចក្តីស្រវឹងទូទៅ ឈ្មោះថាសេចក្តីប្រមាទ ។ ពាក្យថា '**ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តិ**' នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃឈាននិងវិបស្សនា ។ ក៏កាលបើមគ្គនិងផល កើតឡើងហើយ អស់រយៈមួយដង, ឈ្មោះថា សេចក្តីសាបសូន្យ ម្តងទៀត រមែងមិនមាន ។ សេចក្តីមិនប្រមាទ បណ្ឌិតគប្បីជ្រាបដោយពិស្តារ ដោយអំណាចនៃប្រតិបក្ស នៃសេចក្តីប្រមាទ" ។

(២៤៥) ដីកានៃសូត្រទាំង ២ នោះ ថា "បទថា '**ឥទំ**' ជាបទសំដែង ដោយការខុសផ្លាតនៃលិង្គ, ម្យ៉ាងទៀត

បទថា 'ឥទំ' នេះ ជាបទនិបាត ដូចជាបទ ឥទំ ក្នុងសព្វទាំងឡាយ ថា 'យទិទំ' ដូច្នេះជាដើម ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា 'អយំ បមាទោតិ អត្ថោ' ។ កិរិយាដល់នូវសេចក្តីប្រមាទ ឈ្មោះថា អាការនៃការស្រវឹងទួទៅ ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវភាវៈនៃសេចក្តីប្រមាទជាធម៌មានទោស ដោយបទថា 'បរិហាយន្តិ' នេះ ។ បទថា 'បរិហាយន្តិ' នេះនោះ ព្រះអង្គទ្រង់សំដែង ដោយអំណាចនៃលោកិយធម៌ មិនមែនទ្រង់សំដែងដោយអំណាចនៃលោកុត្តរធម៌ទេ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'ឧប្បន្នា ។ បេ ។ ឥទំ' ដូច្នេះជាដើម ។ បុគ្គលរមែងស្រវឹងទួទៅ ដោយធម៌នុ៎ះ មិនមាន ហេតុនោះ ធម៌នុ៎ះ ទើបឈ្មោះថា អប្បមាទ (ធម៌ដែលមិនមែនជាហេតុស្រវឹងទួទៅ) គឺធម៌ដែលជាប្រតិបក្ស ដល់សេចក្តីប្រមាទ បានដល់ ការមិននៅប្រាសចាកសតិ ។ ពាក្យថា សេចក្តីមិនប្រមាទនុ៎ះ ដោយសេចក្តីជាឈ្មោះ នៃសតិដែលតម្កល់នៅមាំជានិច្ច ។ ចំណែកសេចក្តីប្រមាទ បណ្ឌិតគប្បីឃើញថា ជាការកើតឡើង នៃចិត្តជាផ្នែកខាងអកុសល ជាប្រតិបក្សដល់សតិ ឬដល់សតិនិងសម្បជញ្ញៈ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា 'បណ្ឌិតគប្បីជ្រាបសេចក្តីមិនប្រមាទ ដោយពិស្តារ ដោយអំណាច នៃភាវៈជា

ប្រតិបក្សដល់សេចក្តីប្រមាទ" ។

(២៤៦) សេចក្តីមិនប្រមាទនេះ ជាធម៌មានឧបការៈច្រើន ក្នុងធម៌ដែលមិនមានទោសទាំងឡាយ ព្រោះអត្ថ ថា "រមែងប្រព្រឹត្ត ទៅ សូម្បីដើម្បីកិរិយាកើតឡើងនៃកុសល" ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ព្រះធម្មសេនាបតី កាលនឹងសំដែងធម៌ ដល់ភិក្ខុ ទាំងឡាយ ទើបពោលថា "ម្នាលអ្នកដ៏មានអាយុទាំងឡាយ ធម៌មួយ មានឧបការៈច្រើន ។ ធម៌មួយមានឧបការៈច្រើនតើដូចម្តេច ? ។ គឺ សេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌មួយនេះ ជាធម៌មានឧបការៈច្រើន" ដូច្នេះ ។

បាលីទសុត្តរសូត្រ មកក្នុងបាដិកវគ្គ ។

(២៤៧) អដ្ឋកថាទសុត្តរសូត្រនោះ ថា "បណ្តាបទទាំង នោះ ព្រះថេរៈសំដែងសេចក្តីមិនប្រមាទ ដែលមានឧបការៈច្រើន ដែលជាប្រយោជន៍ទូទៅ ដោយបាលីថា '**អប្បមាទោ កុសលេសុ ធម្មេសុ**' ដូច្នេះ ។ មែនពិត ឈ្មោះថា សេចក្តីមិនប្រមាទនេះ ជា ធម៌មានឧបការៈច្រើន ក្នុងធម៌ទាំងពួង ដែលឈ្មោះថា កុសលធម៌ ព្រោះអត្ថថា មិនមានទោស គឺ ក្នុងការបំពេញសីល, ក្នុងការ សង្រួមឥន្ទ្រីយ៍, ក្នុងភាពជាអ្នកស្គាល់ប្រមាណ ក្នុងភោជន, ក្នុង ការប្រកបរឿយៗនូវសេចក្តីភ្ញាក់រលឹក, ក្នុងធម៌ទាំង ៧ ប្រការ,

ក្នុងកិរិយាញុំាងវិបស្សនាឲ្យកាន់យកនូវគតិ(ដើម្បីបានមគ្គនិងផល), ក្នុងបដិសម្ភិទាទាំង ៤ មានអត្ថបដិសម្ភិទាជាដើម, ក្នុងធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម, ក្នុងឋានៈនិងមិនមែនឋានៈ, ក្នុងសមាបត្តិដែលជាគ្រឿងនៅដ៏ធំ, ក្នុងអរិយសច្ច, ក្នុងពោធិបក្ខិយធម៌ មានសតិបដ្ឋានជាដើម, ក្នុងវិជ្ជាទាំង ៨ មានវិបស្សនាញ្ញាណជាដើម ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ កាលទ្រង់ប្រៀបធៀប នូវសេចក្តីមិនប្រមាទនោះ ដោយសេចក្តីឧបមាទាំងឡាយ មានព្រះសាស្តា និង គន្ធង្គជើងនៃជំរីជាដើម ដោយន័យជាដើមថា 'ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានប្រមាណប៉ុន្មាន ទោះមិនមានជើងក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី, ព្រះតថាគត បណ្ឌិតពោលថា 'ជាអ្នកប្រសើរបំផុតជាងសត្វទាំងឡាយនោះ' យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូលប្រជុំរួមចុះក្នុងសេចក្តីមិនប្រមាទ, សេចក្តីមិនប្រមាទ បណ្ឌិតពោលថា 'ជាកំពូលនៃកុសលធម៌ទាំងឡាយនោះ' ដូច្នេះ ទ្រង់ត្រាស់សរសើរហើយ នូវសេចក្តីមិនប្រមាទនោះ មានប្រការផ្សេងៗ

ក្នុងអប្បមាទវគ្គ ក្នុងសំយុត្តនិកាយ ។ ព្រះថេរៈ រួបរួមសេចក្តីមិនប្រមាទទាំងអស់នោះ ដោយបទតែមួយប៉ុណ្ណោះ ហើយពោលថា **'អប្បមាទោ កុសលេសុ ធម្មេសុ'** ។ ក៏ភាវៈនៃសេចក្តីមិនប្រមាទនោះ ជាធម៌មានឧបការៈច្រើន បណ្ឌិតគប្បីសំដែង សូម្បីដោយអប្បមាទវគ្គ ក្នុងធម្មបទ ។ សូម្បីដោយរឿងព្រះបាទអសោក ក៏គប្បីសំដែងបានដែរ ។

សេចក្តីសង្ខេបថា ព្រះរាជាទ្រង់ព្រះនាមអសោក ទ្រង់ព្រះសណ្តាប់នូវកថា របស់និគ្រោធសាមណេរ ថា 'សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់' ដូច្នេះជាដើម ហើយទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់ប៉ុណ្ណោះសិនចុះ, លោកម្ចាស់បានសំដែងព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈ ដល់ក្បោមហើយ' ដូច្នេះ ទ្រង់ជ្រះថ្លាហើយ ក្នុងសាមណេរ ទ្រង់ត្រាស់បញ្ជាឱ្យកសាងហើយនូវព្រះវិហារ ៨៤.០០០ ខ្នង ។ ភាវៈនៃសេចក្តីមិនប្រមាទជាធម៌មានឧបការៈច្រើន គឺភិក្ខុអ្នកដល់ព្រមដោយកម្លាំង គប្បីសំដែង គប្បីពោលសូម្បីដោយព្រះត្រៃបិដក ដោយប្រការដូច្នេះ ។ ព្រះធម្មកថិក កាលនាំមកនូវសូត្រ ឬគាថាណាមួយ ដើម្បីសំដែងនូវសេចក្តីមិនប្រមាទ គឺបុគ្គលណាមួយ មិនគួរពោលថា 'លោកស្ថិតនៅហើយ ក្នុងឋានៈដែលមិនគួរ នាំមកហើយ, ជាអ្នកស្ទុះទៅ

ហើយ ដោយទីដែលមិនមែនជាកំពង់ ។ ក្នុងការនាំយកនូវសូត្រ ឬគាថាមក ដើម្បីសំដែងសេចក្តីមិនប្រមាទនេះ កម្លាំង និងកម្លាំង កំហែង របស់ព្រះធម្មកថិកនុ៎ះឯង ជាប្រមាណ ។

(២៤៨) ដីកាទសុត្តរសូត្រនោះថា "២ បទថា **'សព្ពត្ថកំ ឧបការកំ'** គឺមានឧការៈដល់សេចក្តីប្រតិបត្តិត្រឹមត្រូវ ដែលមានប្រយោជន៍គ្រប់បែបយ៉ាងពិត ។ ឥឡូវនេះ ព្រះអដ្ឋកថាចារ្យ ពោលពាក្យថា **'អយញ្ហិ'** ដូច្នេះជាដើម ដើម្បីសំដែងសេចក្តីនោះ ដោយពិស្តារ ។ បទថា **'វិបស្សនាគព្ភគ្គណ្ហាបនេ'** មានសេចក្តីថា វិបស្សនាជាន់ខ្ពស់ រមែងចាស់ក្លា ជាបញ្ញាដ៏មោះមុត និងទូលំទូលាយ រមែងតក្លាប់ ដោយមគ្គ យ៉ាងណាមិញ, ក្នុងការចំរើនវិបស្សនា ដែលជាចំណែកខាងដើម ក៏ដូច្នោះដែរ ។ បទថា **'អត្តប្បដិសម្ភិទាទីសុ'** គឺក្នុងបដិសម្ភិទាទាំងឡាយ មានអត្ថបដិសម្ភិទាជាដើម ដែលព្រះយោគាវចរ គប្បីឱ្យសម្រេច ។ អធិប្បាយថា 'ជាគ្រឿងឧបត្ថម្ភ និងគាំទ្រ នូវបដិសម្ភិទាទាំងនោះ' ។ សូម្បីក្នុងបទដទៃទៀត ក្រៅអំពីបទនេះ ក៏នំយនេះដូចគ្នាដែរ ។ បទថា **'ឋានាឋានេសុ'** គឺក្នុងឋានៈ និងមិនមែនឋានៈ ដែលបុគ្គលគប្បីដឹង ។ បទថា **'មហាវិហារសមាបត្តិយំ'** គឺក្នុងសមាបត្តិជាគ្រឿងនៅ មានឈានជាដើម ដ៏ធំ ។ ព្រះអដ្ឋកថាចារ្យ រមែង

សង្គ្រោះ នូវវិបស្សនាញ្ញាណទាំងឡាយ មានឫទ្ធិខាងផ្លូវចិត្តជាដើម ដោយអាទិសព្ទ ក្នុងបទថា **'វិបស្សនាញ្ញាណាទីសុ'** ។ ២ បទ ថា **'អដ្ឋសុ វិជ្ជាសុ'** គឺក្នុងវិជ្ជាទាំង ៨ ប្រការ ដែលមកហើយ ក្នុងអម្ពដ្ឋសូត្រ ។ វាចាជាគ្រឿងប្រកប ថា 'ដោយហេតុនោះឯង ទើប ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរ' ។ បទថា **'នំ'** បានដល់ សេចក្តីមិនប្រមាទ ។ បទថា **'ថាមសម្បន្នេន'** គឺអ្នក ប្រកបព្រមដោយកម្លាំងនៃញ្ញាណ ។ បទថា **'ទីបេត្វា'** គឺ ប្រកាសហើយ ថា 'សេចក្តីមិនប្រមាទជាធម៌មានឧបការៈច្រើន ក្នុង កិរិយាញុំាងកុសលធម៌ទាំងឡាយ ឲ្យដល់ព្រម ដោយប្រការយ៉ាង នេះឯង, មានឧបការៈច្រើន ដោយប្រការយ៉ាងនេះឯង' ។ ព្រះអដ្ឋកថាចារ្យពោលពាក្យថា **'យង្កិញ្ចិ'** ដូច្នេះជាដើម ដើម្បី សំដែងថា 'កិរិយាពោលទាញយកសេចក្តី ដែលជាបក្សពួកនៃធម៌ ដែលមិនមានទោស ឯណានីមួយ មករួមចូលគ្នា ក្នុងសេចក្តីមិន ប្រមាទ ក៏សមគួរ ដូច្នេះ" ។

(២៤៩) អដ្ឋកថាអប្បមាទវគ្គ ក្នុងមហាវគ្គសំយុត្តថា 'បណ្ឌិតគប្បីឃើញសេចក្តី ក្នុងពាក្យថា **'ឯវមេវ ខោ'** នេះ ថា 'ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរលើស ជាងសត្វទាំងពួង យ៉ាងណាមិញ, សេចក្តីមិនប្រមាទដែលជាអ្នកឲ្យធ្វើ (ជាតួអង្គ)

ជាកំពូល នៃកុសលធម៌ទាំងឡាយទាំងពួង ក៏យ៉ាងនោះដែរ' ។ សួរថា 'ក៏សេចក្តីមិនប្រមាទនុ៎ះ ត្រឹមតែជាលោកិយៈ, ចំណែកកុសលធម៌ទាំងឡាយ ជាលោកុត្តរៈក៏មាន, មួយទៀត សេចក្តីមិនប្រមាទនេះ ជាកាមាវចរប៉ុណ្ណោះ, ចំណែកកុសលធម៌ទាំងឡាយ ជាធម៌ប្រព្រឹត្តទៅក្នុងភូមិ ៤ មិនមែនទេឬ ?, សេចក្តីមិនប្រមាទនេះ ជាកំពូលនៃកុសលធម៌ទាំងនោះ បានយ៉ាងដូចម្តេចទៅ ?' ។ ឆ្លើយថា 'សេចក្តីមិនប្រមាទនេះ ជាកំពូលនៃកុសលធម៌ទាំងនោះ ព្រោះអត្ថថាជាហេតុឱ្យបានចំពោះ' ។ មែនពិត កុសលធម៌ទាំងនោះ គឺបុគ្គលតែងបាន ដោយសេចក្តីមិនប្រមាទ, ព្រោះហេតុនោះ សេចក្តីមិនប្រមាទនោះ ទើបឈ្មោះថា ជាកំពូលនៃកុសលធម៌ទាំងឡាយនោះ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់នេះថា '**សព្ពេ តេ អប្បមាទមូលកា**' ដូច្នេះជាដើម' ដូច្នេះ" ។

អដ្ឋកថាទុតិយវគ្គ ក្នុងទសកនិបាត អង្គុត្តរនិកាយ ក៏យ៉ាងដូច្នោះដែរ ។

(២៥០) ជីកានៃសូត្រទាំង ២ នោះ ថា "សេចក្តីមិនប្រមាទ ដែលប្រព្រឹត្តទៅ ដោយអំណាចការវៀរចាកធម៌ដែលគួរវៀរចាក និងការញុំាងធម៌ដែលគួរឱ្យដល់ព្រម ឱ្យដល់ព្រមនោះ ។

ថា 'អកុសលធម៌ទាំងឡាយនេះ គឺបុគ្គលគប្បីលះបង់, កុសលធម៌ទាំងឡាយនេះ គឺបុគ្គលគប្បីឱ្យដល់ព្រម' ដូច្នេះ ឈ្មោះថា សេចក្តីមិនប្រមាទដែលជាអ្នកឱ្យធ្វើ ។ បទថា '**ឯសោ**' គឺ ទាញយក **អប្បមាទោ** ចូលមក ។ សេចក្តីមិនប្រមាទនេះ ជាលោកិយៈតែម្យ៉ាងប៉ុណ្ណោះ, មិនមែនជាលោកុត្តរទេ ។ ក៏ព្រះអដ្ឋកថាចារ្យពោលនូវសេចក្តីមិនប្រមាទនុ៎ះឯង ដោយពាក្យថា '**អយញ្ហ ឯសោ**' ។ បទថា '**តេសំ**' គឺ នៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងឡាយ ។ បទថា '**បដិលាភកត្តេន**' គឺ ព្រោះអត្ថថា ជាហេតុឱ្យបានចំពោះ" ។

(២៥១) បទថា "**សត្ថុហត្ថិបទាទីហិ**' គឺ ដោយសេចក្តីឧបមាទាំង ១០ ប្រការ ពោលគឺ ព្រះតថាគត គន្លងជើងនៃដំរី ជំហូលនៃផ្ទះកំពូល ស្លាំពាក់ ចន្ទក្រហម ផ្កាម្លិះ ស្តេចចក្រពត្តិ រស្មីនៃព្រះចន្ទ ព្រះអាទិត្យ និងសំពត់អ្នកដែនកាសី ។ សេចក្តីឧបមាទាំងអស់នោះ អ្នកសិក្សាគប្បីត្រួតមើល ក្នុងមហាវគ្គសំយុត្ត ។

សេចក្តីឧបមា ដោយគន្លងជើងនៃដំរី ក្នុងមហាវគ្គសំយុត្ត អ្នកសិក្សាគប្បីជ្រាបដូចតទៅនេះ ថា "ម្នាលភិក្ខុទាំងឡាយ បទជាតទាំងឡាយ របស់សត្វទាំងឡាយ ដែលគ្រាច់ទៅ លើផែនដី ឯណាមួយ, បទជាតទាំងអស់នោះ រមែងដល់នូវការរួមចុះ ក្នុងគន្លង

ជើងនៃដំរី, មនុស្សលោក ពោលថា 'គន្លងជើងនៃដំរី ជាស្នាមជើងដែលធំជាង ស្នាមជើងនៃសត្វទាំងឡាយនោះ ព្រោះគន្លងជើងដំរីជាគន្លងជើងធំ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណាមួយ, កុសលធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាមូល រួមចុះក្នុងសេចក្តីមិនប្រមាទ, សេចក្តីមិនប្រមាទ បណ្ឌិតតែងពោលថា ជាកំពូលនៃកុសលធម៌ទាំងឡាយនោះ ក៏យ៉ាងដូច្នោះដែរ" ។

(២៥២) អដ្ឋកថាមហាវគ្គសំយុត្ត និងទសកនិបាត ក្នុងអង្គុត្តរនិកាយ និងអដ្ឋកថាមហាហត្ថិបទោបមសូត្រ ក្នុងមូលបណ្ណាសកៈថា "បណ្តាបទទាំងនោះ បទថា **'ជង្គលានំ'** គឺ ដែលមានប្រក្រតីត្រាច់ទៅលើផ្ទៃនៃផែនដី ។ បទថា **'បាណានំ'** គឺ នៃពួកសត្វដែលមានជើង ។ គន្លងជើង ឈ្មោះថា បទជាត ។ ២ បទថា **'សមោធានំ គច្ឆន្តិ'** គឺ រមែងដល់ នូវការតាំងចុះបានដល់ការរួមចុះ ។ បទថា **'អគ្គមក្ខាយតិ'** គឺ ដែលមនុស្សលោកតែងពោលថា ប្រសើរបំផុត ។ ២ បទថា **'យទិទំ មហន្តត្តេន'** គឺ គន្លងជើងនៃដំរីនេះ មនុស្សលោកតែងពោលថា ជារបស់ប្រសើរ ព្រោះជាគន្លងជើងដែលធំ, អធិប្បាយថា 'មិនពោលថា ជារបស់ប្រសើរ ដោយអំណាចនៃគុណឡើយ' ដូច្នេះ" ។

ដីកាមហាវារវគ្គសំយុត្តជាដើមនោះ ថា "បទថា **'ជង្គលានំ'** គឺ ដែលមានប្រក្រកីគ្រាច់ទៅលើផែនដី ។ ក៏ **ជង្គលៈ** សំឡេ ក្នុងបទថា **'ជង្គលានំ'** នេះ ជាសំឡេចរិយាយអំពីផែនដី ដោយភាពជាធម្មជាតិស្មើគ្នា ដោយភាពជារបស់រឹង, មិនមែនជាសំឡេច្រាប់នូវប្រទេសដ៏ឆ្ងាយ ដែលមិនច្រាកដមានឡើយ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា **'បឋវីតលសញ្ជាតានំ'** ដូច្នេះ ។ ពាក្យថា **'សបាទកប្បាណានំ'** ព្រះអដ្ឋកថាចារ្យ ពោលធ្វើឱ្យបានពិស្តារ ព្រោះលោកកំពុងតែពោល នូវគន្លងជើង ។ បទថា **'សមោធានំ'** គឺ នូវភាវៈគឺការធ្លាក់ចុះឮដ៏ខាងក្នុង ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា **'ឱធានំ ឧបក្ខេបំ'** ។ អធិប្បាយថា **'បុគ្គលគប្បីនាំចូលទៅរួបរួម'** ដូច្នេះ " ។

(២៥៣) សេចក្តីមិនប្រមាទ គឺបុគ្គលគប្បីបំពេញដោយពិត ព្រោះសេចក្តីមិនប្រមាទនោះ ជាធម៌មានឧបការៈច្រើនដោយប្រការដូច្នេះ ។ មែនពិត បុគ្គលអ្នកបំពេញសេចក្តីមិនប្រមាទនោះ រមែងបានសម្រេច នូវគុណមានការមិនភ័យខ្លាចចំពោះមរណៈជាដើម ។ ដោយហេតុនោះ ក្នុងតតិយបណ្ណាសកៈនៃចតុក្កនិបាត អង្គុត្តរនិកាយ[1] ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីបំពេញសេចក្តីមិនប្រមាទ

---

១ ត្រៃបិដក ភាគទី ៤២ / ទំព័រទី ៣០១

ដោយហេតុ ៤ យ៉ាង ។ ដោយហេតុ ៤ យ៉ាង តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ នូវកាយទុច្ចរិត ចូរចំរើននូវកាយសុចរិតវិញ ទាំងកុំបីប្រមាទ ក្នុងការលះបង់ នូវកាយទុច្ចរិត ចំរើននូវកាយសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវវចីទុច្ចរិត ចូរចំរើននូវវចីសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់វចីទុច្ចរិត ចំរើនវចីសុរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់មនោទុច្ចរិត ចូរចំរើននូវមនោសុចរិតវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់មនោទុច្ចរិត ចំរើនមនោសុចរិតនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវមិច្ឆាទិដ្ឋិ ចូរចំរើននូវសម្មាទិដ្ឋិវិញ ទាំងកុំបីធ្វេសប្រហែស ក្នុងការលះបង់មិច្ឆាទិដ្ឋិ ចំរើនសម្មាទិដ្ឋិនោះឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពេលណា ភិក្ខុលះបង់នូវកាយទុច្ចរិត ចំរើននូវកាយសុចរិត លះបង់វចីទុច្ចរិត ចំរើនវចីសុចរិត លះបង់នូវមនោទុច្ចរិត ចំរើនមនោសុចរិត លះបង់នូវមិច្ឆាទិដ្ឋិ ចំរើននូវសម្មាទិដ្ឋិហើយ, ក្នុងពេលនោះ ភិក្ខុនោះ តែងមិនខ្លាចសេចក្តីស្លាប់ ដែលប្រព្រឹត្តទៅក្នុងខាងមុខ” ដូច្នេះ និងទ្រង់ត្រាស់ ថា “ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនប្រមាទ គឺការថែរក្សាចិត្ត

ដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួន ក្នុងហេតុ ៤ យ៉ាង ។ ហេតុ ៤ យ៉ាង តើដូចម្តេចខ្លះ ? ។ គឺសេចក្តីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួន ថា 'ចិត្តរបស់អាត្មាអញ កុំត្រេកត្រអាលទៅ ក្នុងធម៌ទាំងឡាយ ដែលគួរត្រេកត្រអាលឡើយ ១' ។ សេចក្តីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួន ថា 'ចិត្តរបស់អាត្មាអញ កុំប្រទូស្ត ក្នុងធម៌ទាំងឡាយ ដែលគួរប្រទូស្តឡើយ ១' ។ សេចក្តីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួន ថា 'ចិត្តរបស់អាត្មាអញ កុំភាន់ច្រឡំ ក្នុងធម៌ទាំងឡាយ ដែលគួរភាន់ច្រឡំឡើយ ១' ។ សេចក្តីមិនប្រមាទ បានដល់ការថែរក្សាចិត្តដោយសតិ គឺភិក្ខុគប្បីធ្វើ តាមសមគួរដល់ខ្លួនថា 'ចិត្តរបស់អាត្មាអញ កុំស្រវឹង ក្នុងធម៌ទាំងឡាយ ដែលគួរស្រវឹងឡើយ ១' ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើភិក្ខុ មានចិត្តមិនត្រេកអរ ក្នុងធម៌ដែលគួរត្រេកអរ ព្រោះប្រាសចាករាគៈ, មានចិត្តមិនប្រទូស្ត ក្នុងធម៌ដែលគួរប្រទូស្ត ព្រោះប្រាសចាកទោសៈ, មានចិត្តមិនវង្វេង ក្នុងធម៌ដែលគួរវង្វេង ព្រោះប្រាសចាកមោហៈ, មានចិត្តមិនស្រវឹង ក្នុងធម៌ដែលគួរស្រវឹង ព្រោះប្រាសចាកពីសេចក្តីស្រវឹងហើយ,

ក្នុងកាលនោះ ភិក្ខុនោះ រមែងមិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនដល់នូវសេចក្តីតក់ស្លុត ទាំងមិនប្រព្រឹត្តទៅ ព្រោះហេតុតែពាក្យរបស់សមណៈ" ។

(២៥៤) អដ្ឋកថាឋានសូត្រ ថា "បណ្តាបទទាំងនោះ បទថា **'យតោ ខោ'** គឺ ក្នុងកាលឯណា ។ បទថា **'សម្បរាយិកស្ស'** នុ៎ះ គ្រាន់តែជាទេសនា ។ ក៏ព្រះខីណាស្រពរមែងមិនភ័យខ្លាចចំពោះសេចក្តីស្លាប់ ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព និងប្រព្រឹត្តទៅក្នុងទិដ្ឋធម្ម ។ ក៏ព្រះខីណាស្រពនោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះបំណងយកហើយ ក្នុងទីនេះ ។ ប៉ុន្តែអាចារ្យពួកខ្លះពោលថា "ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយក ព្រះអរិយបុគ្គលទាំងពួង ចាប់តាំងអំពីព្រះសោតាបន្នជាដើមទៅ ព្រោះព្រះបាលីថា **'សម្មាទិដ្ឋិ ភាវិតា'** ដូច្នេះ" ។

អដ្ឋកថាអារក្ខសូត្រ ថា "បទថា **'អត្តរូបេន'** បានដល់តាមសមគួរ គឺតាមគួរ ដល់ខ្លួន, អធិប្បាយថា 'តាមសេចក្តីប្រាថ្នាចំពោះប្រយោជន៍សុខ' ។ បទថា **'រជនីយេសុ'** បានដល់ជាបច្ច័យនៃរាគៈ ។ បទថា **'ធម្មេសុ'** គឺ ក្នុងសភាវៈទាំងឡាយ, អធិប្បាយថា 'ក្នុងអារម្មណ៍ដែលជាទីប្រាថ្នាទាំងឡាយ' ។ នយក្នុងបទទាំងពួង បណ្ឌិតគប្បីជ្រាប យ៉ាងដូច្នេះដែរ ។ បទថា

'**នច្ឆម្ភតិ**' គឺ តែងមិនញាប់ញ័រ ដោយអំណាចទិដ្ឋិ ។ សូម្បីក្នុងបទដ៏សេសសល់ទាំងឡាយ ក៏ន័យនេះដូចគ្នាដែរ ។ ច្រើនបទថា '**ន ច បន សមណវចនហេតុបិ គច្ឆតិ**' មានសេចក្តីថា ភិក្ខុមិនបានលះបង់ទិដ្ឋិរបស់ខ្លួនហើយ ប្រព្រឹត្តទៅ ដោយអំណាចទិដ្ឋិនៃបុគ្គលទាំងនោះ សូម្បីព្រោះពាក្យរបស់សមណៈទាំងឡាយ អ្នកមានប្រក្រតីពោលរឿងផ្សេង ជាហេតុឡើយ ។ សូម្បីក្នុងទីនេះ ក៏ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយកព្រះខីណាស្រព ដូចគ្នាដែរ "។

(២៥៥) សេចក្តីមិនប្រមាទនុ៎ះ ជាធម៌មានឧបការៈច្រើនក្នុងធម៌ដែលមិនមានទោសទាំងឡាយ រមែងនាំគុណ មានការមិនខ្លាចចំពោះមរណៈជាដើម មកឱ្យដល់បុគ្គលអ្នកបំពេញសេចក្តីមិនប្រមាទនោះ យ៉ាងដូច្នេះឯង, ព្រោះហេតុនោះ សេចក្តីមិនប្រមាទទើបឈ្មោះថា ជាមង្គល ។ សូម្បីក្នុងអដ្ឋកថា ក៏លោកសំដៅយកសេចក្តីនេះឯង ទើបពោលថា 'សេចក្តីមិនប្រមាទនោះ ឈ្មោះថាជាមង្គល ព្រោះជាហេតុបានសម្រេចកុសលធម៌មានប្រការផ្សេងៗ ឬ ព្រោះជាហេតុបានសម្រេចអមតធម៌' ដូច្នេះហើយ សំដែងបទនៃព្រះសូត្រថា 'កាលបើបុគ្គលមិនប្រមាទ ជាអ្នកមានសេចក្តីព្យាយាមដុតកិលេសឱ្យក្តៅ' និងថា 'សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់' ដូច្នេះជាដើម ។ បណ្តាបទនៃព្រះសូត្រទាំង ២ នោះ

២ បទថា **'អប្បមត្តស្ស អាតាបិនោ'** នេះ មកហើយ ក្នុងព្រះសូត្រជាច្រើនកន្លែង ។ ម្យ៉ាងទៀត ២ បទនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងវិមុត្តិសូត្រ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ថា 'កាលបើបុគ្គលមិនប្រមាទហើយ មានព្យាយាមញុាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅហើយរស់នៅ, ចិត្តដែលមិនទាន់រួចផុតស្រឡះ រមែងរួចផុតស្រឡះ ឬអាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏រមែងដល់ នូវការអស់ទៅ" ។

(២៥៦) អដ្ឋកថានៃព្រះសូត្រ ដែលមកក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយជាដើមថា "ឈ្មោះថា ជាអ្នកមិនប្រមាទ ព្រោះការមិននៅប្រាសចាកសតិ ។ ឈ្មោះថា ជាអ្នកមានព្យាយាមញុាំងកិលេសឲ្យក្តៅ ព្រោះដុតកំដៅកិលេសដោយសេចក្តីព្យាយាម ។ ឈ្មោះថា ជាអ្នកមានខ្លួនបានបញ្ជូនទៅហើយ, អធិប្បាយថា 'ជាអ្នកមានខ្លួនបានផ្ញើទៅហើយ ព្រោះជាអ្នកមិនអាឡោះអាល័យក្នុងកាយ និងជីវិត" ។

ជីកានៃព្រះសូត្រនោះ ថា "សេចក្តីព្យាយាម ឈ្មោះថា អាតបៈ ព្រោះអត្ថថា ជាគ្រឿងដុត និង ជាគ្រឿងដុតកំទេច នូវកិលេសទាំងឡាយ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'វីរិយាតាបេន អាតាបិនោ'** ។ អធិប្បាយថា 'ជាអ្នកមាន

សេចក្តីព្យាយាម' ។ បទថា '**បេសិតត្តស្ស**' គឺ ជាអ្នកមានចិត្ត បានចូលទៅកាន់សេចក្តីសម្រេចប្រយោជន៍ តាមដែលខ្លួនប្រាថ្នា" ។

(២៥៧) ពាក្យជាគាថានេះ ថា ÷

" សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់, សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់, ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់, ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាស្លាប់បាត់ទៅហើយ " ដូច្នេះ

គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងធម្មបទក៏មាន ។ រុក្ខទេវតា ដែលអាស្រ័យនៅ លើដើមទំលាប់ដែលមានក្រម៉ កាលឱ្យឱវាទ ដល់ព្រះរាជាព្រះនាមបញ្ចាលៈ បានពោលហើយ ក្នុងកណ្ហតិណ្ហកជាតក ក្នុងទីបញ្ចប់នៃតឹង្សនិបាតក៏មាន ។

(២៥៨) អដ្ឋកថានៃជាតកនោះ ថា "បណ្តាបទទាំងនោះ ការមិននៅប្រាសចាកសតិ ឈ្មោះថា សេចក្តីមិនប្រមាទ ។ ២ បទ ថា '**អមតំ បទំ**' គឺ ជាផ្លូវឱ្យដល់ បានដល់ ជាហេតុបានសំរេចអមតៈ គឺព្រះនិព្វាន ។ ២ បទថា '**មច្ចុនោ បទំ**' គឺ ជាហេតុនៃសេចក្តីស្លាប់ ។ ក៏បុគ្គលដែលប្រមាទហើយ កាលមិនអាច

ដើម្បីនឹងចំរើនវិបស្សនាហើយ សម្រេចនូវភាពជាអ្នកមិនមានបដិសន្ធិបាន ឈ្មោះថា រមែងកើត និងស្លាប់ ក្នុងសំសារវដ្តរឿយៗ, ព្រោះហេតុនោះ សេចក្តីមិនប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃសេចក្តីមិនស្លាប់ ។ បទថា **'ន មីយន្តិ'** មានសេចក្តីថា បុគ្គលអ្នកមិនប្រមាទ ចំរើនវិបស្សនាហើយ ដល់នូវភាពជាអ្នកមិនមានបដិសន្ធិ ឈ្មោះថា រមែងមិនស្លាប់ ព្រោះភាវៈជាអ្នកមិនកើតហើយ ក្នុងសំសារវដ្តរឿយៗ ។ ២ បទថា **'យេ បមត្តា'** ជាដើម មានសេចក្តីថា បពិត្រព្រះមហារាជ បុគ្គលទាំងឡាយឯណា ជាអ្នកប្រមាទហើយ, បុគ្គលទាំងឡាយនោះ ព្រះអង្គគប្បីឃើញថា ដូចជាបុគ្គលដែលស្លាប់ទៅហើយ ។ សួរថា: ព្រោះហេតុអ្វី ? ។ ឆ្លើយថា: ព្រោះភាពនៃបុគ្គលនោះ ជាអ្នកមិនញុំាងកិច្ចឲ្យសំរេច ។ អធិប្បាយថា 'ក៏សេចក្តីសង្ឃឹម សេចក្តីប្រាថ្នា ឬសេចក្តីតាំងចិត្តមាំថា 'អាត្មាអញ នឹងឲ្យទាន នឹងរក្សាសីល នឹងធ្វើឧបោសថកម្ម នឹងធ្វើនូវកុសលដ៏ល្អ' ដូច្នេះ រមែងមិនមាន សូម្បីដល់បុគ្គលដែលបានស្លាប់ទៅហើយ ព្រោះជាអ្នកមានវិញ្ញាណទៅប្រាសហើយ, សូម្បីបុគ្គលដែលប្រមាទហើយ ក៏រមែងមិនមានសេចក្តីសង្ឃឹមជាដើមនោះ ព្រោះមិនមានសេចក្តីមិនប្រមាទ ព្រោះហេតុដូច្នេះនោះ បុគ្គលទាំង ២ ពួកនោះ ទើបជាអ្នកដូចគ្នាតែមួយ ដោយពិត" ។

អដ្ឋកថាធម្មបទ ថា "សូម្បីសេចក្តីគិតតែមួយថា 'អាត្មាអញ នឹងថ្វាយទាន នឹងរក្សាសីល នឹងធ្វើនូវឧបោសថកម្ម' ដូច្នេះ រមែងមិនកើតទេ ដល់បុគ្គលអ្នកប្រមាទ ដែលជាគ្រហស្ថ ជាមុនសិន, សូម្បីជាបព្វជិតទាំងឡាយ ក៏រមែងមិនកើតសេចក្តីគិតតែមួយថា 'អាត្មាអញ នឹងចំពេញវត្ត មានអាចារិយវត្ត និងឧបជ្ឈាយវត្ត ជាដើម នឹងសមាទាន នូវធុតង្គទាំងឡាយ នឹងចំរើនភាវនា' ដូច្នេះដែរ, បុគ្គលអ្នកប្រមាទហើយទាំងនោះ នឹងមានអ្វីជាហេតុឱ្យខុសផ្សេងពីគ្នា ចាកបុគ្គលដែលបានស្លាប់បាត់ទៅហើយហ្ន៎ ?" ។

ពណ៌នាអំពីសេចក្តីមិនប្រមាទ ចប់ ។

(២៥៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់មង្គល ៣ ប្រការ គឺ ការវៀរចាកបាប ១ ការសង្រួមចាកកិរិយាផឹកទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ១ ដោយព្រះគាថានេះឯង ដោយប្រការដូច្នេះ ។ ក៏ភិក្ខុទាំងឡាយ ក្នុងពេលនេះ ភាគច្រើន រមែងសូត្រតាមអំណាច ន គណៈ ថា "**រតិវិ**" ។

ប៉ុន្តែ ន គណៈ រមែងមិនត្រឹមត្រូវ ព្រោះភាវៈនៃពាក្យ ថា "**ន ស្នាទិម្ហា**" ជាពាក្យដែលលោកអាចារ្យបានហាមឃាត់ហើយ ក្នុងពាក្យនេះ ថា "**ស** គណៈ និង **ន** គណៈ រមែងមិនមាន អំពីខាង

មុខអក្សរខាងដើម ក្នុងបាទទាំងឡាយ ដែលមានអក្សរ ៨ តួ, យ គណៈ រមែងមានបាន ខាងមុខ ៤ អក្សរ ក្នុងព្រឹទ្ធិឯណា, ព្រឹទ្ធិនោះ ឈ្មោះថា "**រត្តឆ័ន្ទ**" ដូច្នេះ, ជ គណៈ ថា "**រតីវិ**" ន្ទុំះឯង រមែងត្រឹមត្រូវ ព្រោះលោកមិនបានហាមឃាត់ហើយ ។ សូម្បី យ គណៈ ថា "**រតីបា**" រមែងត្រឹមត្រូវ ព្រោះពាក្យ ថា "**យោណ្ណវា**" ដូច្នេះ និង រមែងសមដោយ យ គណៈ ថា "**ច ធម្មេ**" ដូច្នេះ ។ សូម្បីពាក្យជាគាថានេះ ក៏ជាបថ្យាវត្ត ដោយប្រការដូច្នេះឯង ។

ពណ៌នាសេចក្តីនៃគាថាទី ៦ ចប់ ។

សាមគ្គីជាកម្មាំង សាមគ្គីនាំឱ្យបានសេចក្តីសុខ
ប្រទេសជាតិខ្វះការសាមគ្គីមិនបានសុខឡើយ ។

ប្រែចប់ ថ្ងៃសុក្រ ៤ រោច ខែទុតិយាសាធ បញ្ចស័ក ព.ស.២៥៣៦

ត្រូវនឹងថ្ងៃ ទី ៦ ខែសីហា ឆ្នាំ ១៩៩៣

(វេលាយប់)

ពណ៌នាសេចក្តីនៃគាថាទី៧

---

(២៦០) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៧ ដូចតទៅនេះ ÷ ភាពជាអ្នកធ្ងន់ ឈ្មោះថា **គារវៈ** ។ ភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឈ្មោះថា **និវាតៈ** ។ សេចក្តីសន្តោស ឈ្មោះថា **សន្តុដ្ឋី** ។ ភាពគឺការដឹងខុបការៈដែលលោកធ្វើហើយ ឈ្មោះថា **កតញ្ញុតា** ។ កិរិយាស្តាប់ធម៌ ក្នុងសម័យ ឈ្មោះថា **ការស្តាប់ធម៌ តាមកាល** ។

បទថា “**ឯតំ**” មានសេចក្តីថា ម្នាលទេវតា ចូរអ្នកប្រកាន់យកថា “សេចក្តីគោរព ១ សេចក្តីប្រព្រឹត្តបន្ទាបខ្លួន ១ សេចក្តីត្រេកអរដោយវត្ថុជារបស់ខ្លួន ១ ភាពជាអ្នកដឹងខុបការៈដែលលោកបានធ្វើហើយ ១ ការស្តាប់ធម៌ ១, កម្មទាំង ៥ យ៉ាង មានសេចក្តីគោរពជាដើមនេះ ជាមង្គលដ៏ខ្ពង់ខ្ពស់” ។

សេចក្តីសង្ខេប ក្នុងគាថានេះ មានតែប៉ុណ្ណោះ ។

ចំណែកសេចក្តីពិស្តារ ក្នុងគាថានេះ មានដូចតទៅនេះ ÷

ពណ៌នារំពីសេចក្តីគោរព

* * *

(២៦១) បុគ្គលទាំងឡាយ ដែលគួរធ្វើឲ្យធ្ងន់ ឈ្មោះថា ត្រូ ។ ព្រោះហេតុនោះ ក្នុងសទ្ទនីតិ ទើបព្រះអគ្គវង្សមហាថេរៈ ពោលថា "**គរុ** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថថាខ្ពង់ខ្ពស់" ។ បុគ្គលដែលគួរ ដល់សេចក្តីគោរពទាំងឡាយ មានមាតា និង បិតា ជាដើម ឈ្មោះថា ត្រូ ។ មែនពិត បុគ្គលដែលគួរគោរពទាំងឡាយ នោះ អ្នកប្រាជ្ញទាំងឡាយហៅថា "ត្រូ" ព្រោះអត្ថ ថា "អណ្តែត ឡើង គឺ រះឡើង បានដល់ បើកឡើង គឺជាអ្នកខ្ពង់ខ្ពស់ហើយ គឺជាអ្នកប្រាកដជាក់ស្តែង" ។ មួយទៀត មាតានិងបិតាជាដើម នោះ លោកហៅថា "ត្រូ" ព្រោះអត្ថថាធ្ងន់ ដូចជាឆ័ត្រថ្ម ។ ភាវៈនៃបុគ្គលដែលធ្ងន់ទាំងឡាយ ឈ្មោះថា **គារវៈ** បានដល់ កិរិយាធ្វើឲ្យធ្ងន់ ក្នុងបុគ្គលដែលគួរគោរព មានមាតានិងបិតាទាំង ឡាយជាដើមនោះ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើប លោកពោល ថា "កិរិយាធ្វើឲ្យធ្ងន់ គឺភាពជាអ្នកមានសេចក្តីគោរព តាមសមគួរ ក្នុងបុគ្គលទាំងឡាយ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះ សាវ័ករបស់ព្រះតថាគត អាចារ្យ ព្រះឧបជ្ឈាយ៍ មាតា បិតា បង ប្អូនប្រុស និង បងប្អូនស្រីជាដើម ដែលគួរដល់ការប្រកបដោយ

កិរិយាធ្វើឱ្យធូរធ្ងន់ ឈ្មោះថា សេចក្តីគោរព ” ។ សេចក្តីគោរព នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “ ជាមង្គល ” ព្រោះជាហេតុ នៃឥដ្ឋផលមានការទៅកាន់សុគតិភពជាដើម ។ ក៏ភាវៈនៃសេចក្តី មិនគោរពនោះ មិនមែនជាមង្គល គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ សំដែងហើយ ដោយការត្រាស់សំដែងនូវភាវៈ នៃសេចក្តីគោរព នោះ ជាមង្គល ។ មែនពិត សេចក្តីមិនគោរព គប្បីជ្រាបថា មិន មែនជាមង្គល ព្រោះជាហេតុនៃអនិដ្ឋផល មានការទៅកាន់ទុគ្គតិ ជាដើម ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ សំដែងធម៌ ដល់សុកមាណព ទើបទ្រង់ត្រាស់ ថា ÷

“ ម្នាលមាណព ក៏ស្ត្រី ឬ បុរសពួកខ្លះ ក្នុងលោកនេះ(១) ជាអ្នករឹងត្អឹង មានមានះក្រៃលែង (មើលងាយគេ) មិនសំពះ នូវបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឱ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ មិនឱ្យផ្លូវដល់បុគ្គល ដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈ ដល់បុគ្គលដែលគួរធ្វើសក្ការៈ មិន ធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អាន ដល់បុគ្គលដែលគួររាប់អាន មិនបូជា ដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់មក យ៉ាងនេះ បុគ្គលនោះ លុះទំលាយរាងកាយ បន្ទាប់អំពីសេចក្តី

---

១ ត្រៃបិដក ភាគទី ២៨ / ទំព័រទី ៦៤

ស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិសัយ អសុរកាយ នរក, បើបុគ្គលនោះ ទំលាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើត ក្នុងកំណើតតិរច្ឆាន ប្រេតវិសัយ អសុរកាយ នរកទេ, បើបានត្រឡប់មកកាន់ភាពជាមនុស្សវិញ ក្រោយមក កើតក្នុងទីណា ។ រមែងជាអ្នកមានត្រកូលថោកទាប ក្នុងទីនោះ ។ ។ ម្នាលមាណព បុគ្គលដែលរឹងត្អឹង មើលងាយ ។ ល ។ មិនបូជា ដល់បុគ្គលដែលគួរបូជា នេះ ឈ្មោះថា ជាបដិបទាប្រព្រឹត្តទៅដើម្បី មានត្រកូលថោកទាប ។

ម្នាលមាណព មួយទៀត ស្ត្រី ឬ បុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះនូវបុគ្គលដែលគួរសំពះ ក្រោកទទួលនូវបុគ្គលដែលគួរក្រោកទទួល ឱ្យអាសនៈ ដល់បុគ្គល ដែលគួរឱ្យអាសនៈ ឱ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈ ដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព ដល់បុគ្គលដែល គួរធ្វើសេចក្តីគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាបុគ្គល ដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបំពេញយ៉ាងនេះ បានកាន់ខ្ជាប់មកយ៉ាងនេះ បុគ្គលនោះ លុះទំលាយរាងកាយបន្ទាប់ អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក, បើបុគ្គលនោះ ទំលាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិន

ទៅកើតក្នុងសុគតិ សួគ៌ ទេវលោកទេ, បើបានត្រឡប់មកកាន់ភាពជាមនុស្ស ក្រោយមក កើតក្នុងទីណា។ រមែងជាអ្នកមានត្រកូលដ៏ខ្ពង់ខ្ពស់ ក្នុងទីនោះ។ ។ ម្នាលមាណព បុគ្គលដែលមិនរឹងត្អឹង មិនមើលងាយ ។ល។ រមែងបូជានូវបុគ្គលដែលគួរបូជា នេះ ឈ្មោះថា ជាបដិបទាប្រព្រឹត្តទៅដើម្បីមានត្រកូលខ្ពង់ខ្ពស់ ” ដូច្នេះ ។

ចារីក្នុងចូឡកម្មវិភង្គសូត្រ ក្នុងចតុត្ថវគ្គ នៃខុទ្ទកនិកាយសកៈ ។

(២៦២) នំយមកក្នុងអដ្ឋកថាចូឡកម្មវិភង្គសូត្រនោះ ថា “ បទថា ‘**អភិវាទេតព្ពំ**’ គឺ បុគ្គលដែលគួរដល់ការអភិវាទ បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរិយសាវ័ក ។ សូម្បីក្នុងបុគ្គលដែលគួរក្រោកទទួលជាដើម ក៏នំយនេះដូចគ្នាដែរ ។ បទថា ‘**សមត្តេន**’ គឺ ដែលខ្លួនបានបំពេញហើយ ។ បទថា ‘**សមាទិន្នេន**’ គឺ ដែលខ្លួនកាន់ខ្ជាប់ហើយ គឺពាល់ត្រូវហើយ ។ បទថា ‘**យទិទំ**’ មានសេចក្តីថា កម្ម គឺភាពជាអ្នករឹងត្អឹង មានមានះក្រៃលែងនេះឯណា, បដិបទានេះ ”។

ដីកានៃចូឡកម្មវិភង្គសូត្រនោះ ថា “ បទថា ‘**សមត្តេន**’ គឺ ដែលអាច បានដល់ ដែលមានសមត្ថភាព ។ អធិប្បាយថា ‘កម្ម នោះ ជាកម្មអាចដើម្បីនឹងឱ្យផល ដោយប្រការណា, ព្រោះ

កម្មដែលខ្លួនបានធ្វើ គឺ បានសន្សំទុកហើយ ដោយប្រការនោះ' ។ ក៏កម្មប្រាកដដូច្នោះ ឈ្មោះថា មិនមានខ្វះខាត ដោយកិច្ចរបស់ខ្លួន ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា 'គឺខ្លួនបំពេញហើយ' ។ ក្នុងបទថា '**សមាទិន្នេន**' នេះ ការកាន់ខ្ជាប់ គឺ ការពាល់ត្រូវ ដោយតណ្ហានិងទិដ្ឋិ ឈ្មោះថា ការសមាទាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'ដែលខ្លួនកាន់ខ្ជាប់ហើយ គឺដែលខ្លួនពាល់ត្រូវហើយ' ។ ឈ្មោះថា បដិបទា ព្រោះវិគ្រោះ ថា 'ជាគ្រឿងធ្វើដំណើរទៅកាន់សុគតិ ឬទុគ្គតិ នៃបុគ្គល' បានដល់ កម្ម" ។

(២៦៣) ម្យ៉ាងទៀត សេចក្តីគោរព ឈ្មោះថា ជាមង្គល ព្រោះជាហេតុបានសម្រេច នូវភាពជាអ្នកមិនវិនាសសាបសូន្យ ។ ដោយហេតុនោះ ទើបទេវតាមួយអង្គ ពោលហើយ ក្នុងសំណាក់ នៃព្រះមានព្រះភាគ ថា "បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយ ៧ ប្រការនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យ ដល់ភិក្ខុ ។ ធម៌ទាំង ៧ ប្រការនោះ តើដូចម្តេចខ្លះ ? ។ គឺភាពជាអ្នកគោរពក្នុងព្រះសាស្តា ១ ភាពជាអ្នកគោរពក្នុងព្រះធម៌ ១ ភាពជាអ្នកគោរពក្នុងព្រះសង្ឃ ១ ភាពជាអ្នកគោរពក្នុងការសិក្សា ១ ភាពជាអ្នកគោរពក្នុងសមាធិ ១ ភាពជាអ្នកគោរពក្នុងសេចក្តី

មិនប្រមាទ ១ ភាពជាអ្នកគោរពក្នុងការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំង ៧ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យ ដល់ភិក្ខុ" ។ ទេវតាអង្គនោះ លុះបានថ្លែងយ៉ាងនេះហើយ ក៏បាត់ហើយ ក្នុងទីនោះឯង ។

ចំណែកព្រះសាស្តា ក្នុងថ្ងៃស្អែកឡើង ទ្រង់បានត្រាស់នូវពាក្យ ដែលទេវតានោះពោលហើយ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់បានត្រាស់ព្រះគាថាទាំងឡាយ ២ នេះ ក្នុងអប្បមាទសូត្រ ក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសកៈ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ[1] ថា

" ភិក្ខុ មានសេចក្ដីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានសេចក្ដីគោរពព្រះសាស្តាផង មានសេចក្ដីគោរពព្រះធម៌ផង មានសេចក្ដីគោរពដ៏ក្លៀវក្លាចំពោះព្រះសង្ឆផង មានសេចក្ដីគោរពចំពោះសមាធិផង មានសេចក្ដីគោរពដ៏ក្លៀវក្លាចំពោះការសិក្សាផង មានសេចក្ដីគោរពចំពោះសេចក្ដីមិនប្រមាទផង មានសេចក្ដីគោរពចំពោះការធ្វើបដិសណ្ឋារៈផង មិនគួរនឹងសាបសូន្យឡើយ រមែងស្ថិតនៅ ក្នុងទីជិតនៃព្រះនិព្វាន" ។

---

១ ត្រៃបិដក ភាគទី ៤៧ / ទំព័រទី ៥៦

(២៦៤) អដ្ឋកថានៃអបរិហានសូត្រ ក្នុងចតុត្ថវគ្គ នៃបឋមបណ្ណាសកៈ ក្នុងឆក្កនិបាត អង្គុត្តរនិកាយ ថា "បណ្ដាសេចក្ដីគោរពទាំង ៧ យ៉ាងនោះ ការធ្វើសេចក្ដីគោរព ក្នុងព្រះសាស្ដា ឈ្មោះថា **សត្ថុគារវតា** ។ សេចក្ដីគោរព ក្នុងលោកុត្តរធម៌ទាំង ៩ ប្រការ ឈ្មោះថា **ធម្មគារវតា** ។ សេចក្ដីគោរព ក្នុងព្រះសង្ឃ ឈ្មោះថា **សង្ឃគារវតា** ។ ការធ្វើសេចក្ដីគោរព ក្នុងសិក្ខាទាំង ៣ យ៉ាង ឈ្មោះថា **សិក្ខាគារវតា** ។ សេចក្ដីគោរពក្នុងសេចក្ដីមិនប្រមាទ ឈ្មោះថា **អប្បមាទគារវតា** ។ សេចក្ដីគោរព ក្នុងការធ្វើបដិសណ្ឋារៈ ២ យ៉ាង ដោយអំណាចធម៌ និង អាមិស ឈ្មោះថា **បដិសណ្ឋារគារវតា** ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ដូចតទៅនេះ ÷ ព្រះសាស្ដា ជាទីគោរព របស់ភិក្ខុនោះ មាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានព្រះសាស្ដាជាទីគោរព ។ ធម៌ជាទីគោរព របស់ភិក្ខុនោះ មាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានធម៌ជាទីគោរព ។ បទថា 'តិព្វគារវោ' គឺ មានសេចក្ដីគោរពដ៏ខ្លាំងក្លា ។ សេចក្ដីគោរពក្នុងការធ្វើបដិណ្ឋារៈ មានដល់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានសេចក្ដីគោរព ក្នុងការធ្វើបដិសណ្ឋារៈ" ។

អដ្ឋកថាអប្បមាទវគ្គ ក្នុងធម្មបទ ថា "បាទគាថាថា 'អភព្វោ

បរិហានាយ មានសេចក្តីថា ភិក្ខុនោះ គឺ អ្នកប្រាកដដូច្នោះ ជាអ្នកមិនគួរ ដើម្បីនឹងសាបសូន្យ ចាកធម៌ គឺសមថៈនិង វិបស្សនា ឬចាកមគ្គនិងផល គឺថា រមែងសាបសូន្យ ចាកមគ្គទាំងឡាយ ក៏ទេដែរ ទាំងមិនបានសម្រេច នូវមគ្គនិងផល ដែលខ្លួនមិនទាន់បាន សម្រេច ក៏ទេដែរ ។ បាទគាថាថា **'និព្វានស្សេវ សន្តិកេ'** មានសេចក្តីថា រមែងមាន ក្នុងទីជិត សូម្បីនៃកិលេសបរិនិព្វាន សូម្បីនៃអនុបាទាបរិនិព្វាន ដោយពិត "។

(សេចក្តីមិនគោរពក្នុងព្រះរតនត្រៃ)

(២៦៥) ក៏ព្រោះកាលបើសេចក្តីមិនគោរព គឺខ្ញុំបានពោលទុកជាមុនហើយ, សេចក្តីគោរព ក៏រមែងយល់បាន ដោយងាយដែរ ហេតុនោះ ខ្ញុំនឹងប្រមូលការពណ៌នាអំពីសេចក្តីមិនគោរព មកទុកជាមុន ។ ពាក្យនេះ ព្រះអដ្ឋកថាចារ្យ បានពោលហើយ ក្នុងអដ្ឋកថាឆក្កនិទ្ទេស ក្នុងខុទ្ទកវិភង្គ និង ក្នុងអដ្ឋកថាឆក្កនិទ្ទេស ក្នុងសង្គីតិសូត្រ ថា ÷

"ភិក្ខុឯណា កាលបើព្រះសាស្តា ទ្រង់ព្រះធរមាននៅឡើយ, មិនបានទៅកាន់ទីឧបដ្ឋាក ក្នុងកាលទាំង ៣, កាលបើព្រះសាស្តា មិនទ្រង់ឆ្លងព្រះបាទុក (មិនពាក់ស្បែកជើង) ស្តេចយាងចង្រ្កម,

(ភិក្ខុនេះ) ពាក់ស្បែកជើង ដើរចង្ក្រម, កាលបើព្រះសាស្តាទ្រង់ស្តេចចង្ក្រម លើទីចង្ក្រមទាប, (ភិក្ខុនេះ) ដើរចង្ក្រម លើទីចង្ក្រមខ្ពស់, កាលបើព្រះសាស្តាទ្រង់គង់នៅ ព្ធដ៏ខាងក្រោម, (ភិក្ខុនេះ) នៅព្ធដ៏ខាងលើ គ្រង (ចីពរ) គ្របស្មាទាំងសងខាងបាំងឆ័ត្រ ពាក់ស្បែកជើង ស្រង់ទឹក បន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ក្នុងទីដែលព្រះសាស្តាទ្រង់ទតព្រះនេត្រឃើញ ឬក៏ កាលបើព្រះសាស្តាទ្រង់ស្តេចបរិនិព្វានបាត់ទៅហើយ, (ភិក្ខុនេះ) មិនទៅថ្វាយបង្គំព្រះចេតិយ ធ្វើនូវសេចក្តីមិនគោរពគ្រប់បែបយ៉ាង តាមដែលបានពោលហើយ ក្នុងទីដែលព្រះសាស្តាទ្រង់ទតព្រះនេត្រឃើញ ក្នុងទីជាទីប្រាកដនៃព្រះចេតិយ, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះសាស្តា ។

មួយទៀត ភិក្ខុណា, កាលបើគេប្រកាសការស្តាប់ធម៌, មិនទៅដោយគោរព មិនស្តាប់ធម៌ដោយគោរព (គិតតែ) សិងលក់ ឬក៏ អង្គុយនិយាយគ្នាលេង មិនរៀន មិនចាំទុក មិនប្រាប់ ដោយគោរព, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះធម៌ ។

មួយទៀត ភិក្ខុណា គឺភិក្ខុជាថេរៈ មិនបាននិមន្តហើយ (ក៏) សំដែងធម៌ ប្រាប់នូវបញ្ហា ដើរ ឈរ អង្គុយ បៀតត្រសៀតនូវភិក្ខុទាំងឡាយដែលចាស់ ។ យកសំពត់រឹតក្បាលជង្គង់ ឬក៏

យកដៃត្របោមក្បាលជង្គង់ គ្រង (ចីពរ) គ្របស្មាទាំងសងខាង បាំងឆ្អឹងត្រគាក ពាក់ស្បែកជើង នៅកណ្តាលជំនុំព្រះសង្ឃ, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះសង្ឃ ។ មែនពិត កាលបើភិក្ខុ ធ្វើសេចក្តីមិនគោរព សូម្បីក្នុងភិក្ខុមួយរូប ក៏ឈ្មោះថា រមែង មិនធ្វើសេចក្តីគោរព ក្នុងព្រះសង្ឃដូចគ្នាដែរ " ។

(២៦៦) ជីកាសង្គីតិសូត្រ ថា "កម្មដែលភិក្ខុបានធ្វើហើយ ចំពោះព្រះចេតិយ ក៏ដូចជាកម្មដែលភិក្ខុបានធ្វើហើយ ចំពោះព្រះ សាស្តាដែរ យ៉ាងណាមិញ, កម្មដែលភិក្ខុបានធ្វើហើយ ខាងមុខ នៃព្រះចេតិយ ក៏ដូចជាកម្មដែលភិក្ខុបានធ្វើហើយ ខាងមុខនៃព្រះ សាស្តាដូចគ្នាដែរ ក៏យ៉ាងដូច្នោះ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យថា **'បរិនិព្ពុតេ វា បន'** ដូច្នេះជាដើម ។ ២ បទថា **'សក្កច្ចំ ន គច្ឆតិ'** គឺ ញុំាងសេចក្តីមិនគោរព ឲ្យកើតឡើងហើយ ចូលទៅរក ។ កាលបើចំណែកមួយនៃសិក្ខា គឺភិក្ខុ ធ្វើឲ្យកម្រើកហើយ និង សេចក្តីមិនគោរព គឺភិក្ខុបានធ្វើហើយ, សិក្ខា រមែងកម្រើក និង សេចក្តីមិនគោរព ក៏ឈ្មោះថា គឺភិក្ខុបាន ធ្វើហើយ ក្នុងសិក្ខាទាំងអស់ដែរ, ការសមាទាននូវសំវរៈ រមែង មាន ដោយការប្រជុំគ្នា, ការបែកធ្លាយ នៃសំវរៈ រមែងមាន ដោយអវយវៈ យ៉ាងណាមិញ, កាលបើភិក្ខុធ្វើសេចក្តីមិនគោរព

សូម្បីក្នុងភិក្ខុមួយរូបហើយ ក៏ឈ្មោះថា រមែងធ្វើសេចក្តីមិនគោរព ក្នុងព្រះសង្ឃដូចគ្នា យ៉ាងដូច្នោះដែរ "។

(២៦៧) អដ្ឋកថាកស្សបសំយុត្ត ក្នុងនិទានវគ្គថា "ភិក្ខុណា កាលដើរទៅ កាន់លានព្រះចេតិយ បាំងឆ័ត្រ ពាក់ទ្រនាប់ជើង ដើរក្រឡេកមើលទៅផ្លូវផ្សេង និយាយបណ្តើរ, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះសាស្តា ។ ភិក្ខុណា, កាលបើគេប្រកាសពេលស្តាប់ធម៌, មានពួកភិក្ខុកម្លោះនិងសាមណេរចោមរោមហើយ អង្គុយក្តី ធ្វើកិច្ចទាំងឡាយផ្សេងៗ ទៀត មាននវកម្មជាដើមក្តី អង្គុយលក់ ក្នុងសាលាស្តាប់ធម៌ក្តី ឬក៏ ជាអ្នកមានចិត្តរវើរវាយ អង្គុយនិយាយរឿងផ្សេងៗ, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះធម៌ ។ ភិក្ខុណា ទៅកាន់ទីឱបដ្ឋាកព្រះថេរៈហើយ មិនបានថ្វាយបង្គំអង្គុយ យកដៃទៅត្រវោមក្បាលជង្គង់ ឬក៏យកសំពត់មករឹតក្បាលជង្គង់ ឬក៏ ធ្វើការគ្រវាសដៃនិងជើងជាទៃទៀត គឺព្រះថេរៈ មិនបាននិមន្តហើយ ក៏និយាយ ក្នុងសំណាក់នៃភិក្ខុទាំងឡាយដែលចាស់, ភិក្ខុនេះ ឈ្មោះថា មិនគោរព ក្នុងព្រះសង្ឃ "។

អដ្ឋកថាសង្គីតិសូត្រ ថា "ក៏ភិក្ខុ កាលមិនញុំាងសិក្ខាទាំង ៣ យ៉ាង ឲ្យបានបរិបូណ៌នុ៎ះឯង ឈ្មោះថា មិនគោរព ក្នុងសិក្ខា "។

ជីកាសង្គីតិសូត្រ ថា "ភិក្ខុដែលឈ្មោះថា មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខា សូម្បីព្រោះហេតុត្រឹមតែការមិនអើពើប៉ុណ្ណោះ ឈ្មោះថា មិនគោរព ក្នុងសិក្ខា ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា 'កាលមិនឲ្យបរិបូណ៌នុ៎ះឯង ឈ្មោះថា មិនមានសេចក្តីគោរព ក្នុងសិក្ខា' ដូច្នេះ" ។

អដ្ឋកថាកស្សបសំយុត្ត ថា "ភិក្ខុអ្នកមិនញុំាងសមាបត្តិ ៨ ឲ្យកើតឡើង ឬក៏ មិនធ្វើសេចក្តីព្យាយាម ដើម្បីប្រយោជន៍ដល់ការញុំាងសមាបត្តិទាំង ៨ នោះ ឲ្យកើតឡើង ឈ្មោះថា ជាអ្នកមិនគោរព ក្នុងសមាធិ" ។

អដ្ឋកថាសង្គីតិសូត្រ ថា "ភិក្ខុអ្នកមិនចំរើនធម៌ ដែលមានសេចក្តីមិនប្រមាទជាលក្ខណៈ ឈ្មោះថា មិនគោរព ក្នុងសេចក្តីមិនប្រមាទ ។ ភិក្ខុអ្នកមិនធ្វើបដិសណ្ឋារៈ សូម្បីទាំង ២ យ៉ាង ឈ្មោះថា មិនគោរព ក្នុងការធ្វើបដិសណ្ឋារៈ ។ សេចក្តីគោរព បណ្ឌិតគប្បីជ្រាប ដោយអំណាចន័យ ដែលផ្ទុយអំពីគ្នា នឹងពាក្យដែលបានពោលមកហើយ" ។

ជីកាសង្គីតិសូត្រនោះ ថា "ធម៌ដែលមានសេចក្តីមិនប្រមាទជាលក្ខណៈ ឈ្មោះថា សម្មាបដិបត្តិ ។ បទថា 'ទុវិធំ' គឺ មាន ២ យ៉ាង ដោយអំណាចធម៌ និង អាមិស" ។

(២៦៨) បទទាំង ២ គឺ សណ្ហាវៈ ១ បដិសណ្ហាវៈ ១ ដោយសេចក្តី ជាបទតែមួយ ។ ពិតមែនដូច្នោះ ក្នុងចតុត្ថវគ្គ នៃតតិយបណ្ណាសកៈ ក្នុងទុកនិបាត អង្គុត្តរនិកាយ[1] ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រទី ១ ថា "ម្នាលភិក្ខុទាំងឡាយ ការរាក់ទាក់ ទាំងឡាយនេះ មាន ២ យ៉ាង, ការរាក់ទាក់ ២ យ៉ាង តើដូចម្តេច ខ្លះ ?, គឺការរាក់ទាក់ដោយអាមិស ១ ការរាក់ដោយធម៌ ១, ម្នាលភិក្ខុទាំងឡាយ ការរាក់ទាក់មាន ២ យ៉ាងនេះឯង, ម្នាលភិក្ខុ ទាំងឡាយ បណ្តាការរាក់ទាក់ទាំង ២ យ៉ាងនេះ ការរាក់ទាក់ ដោយធម៌នេះ ប្រសើរជាង" ដូច្នេះ និង ទ្រង់ត្រាស់ព្រះសូត្រទី ២ ថា "ម្នាលភិក្ខុទាំងឡាយ បដិសណ្ហាវៈទាំងឡាយនេះ មាន ២ យ៉ាង, បដិសណ្ហាវៈ ២ យ៉ាង តើដូចម្តេចខ្លះ ?, គឺបដិសណ្ហាវៈ ដោយអាមិស ១ បដិសណ្ហាវៈ ដោយធម៌ ១" ដូច្នេះជាដើម ។

(២៦៩) អដ្ឋកថានៃសូត្រទាំង ២ នោះ ថា "ការបិទបាំង ដោយអំណាចការបិទបាំងនូវទោស របស់ខ្លួននិងអ្នកដទៃ ដោយ បច្ច័យទាំងឡាយ ៤ ឈ្មោះថា ការរាក់ទាក់ ដោយអាមិស ។ ការបិទបាំង ដោយធម៌ ឈ្មោះថា ការរាក់ទាក់ ដោយធម៌ ។ ពាក្យត្រឹមតែឧបសគ្គ ជាសេចក្តីប្លែកគ្នា ក្នុងគាថាទី ២" ។

អដ្ឋកថាសង្គីតិសូត្រ ថា "លោកសន្និវាសនេះ មានប្រហោង

---

១ ត្រៃបិដក ភាគទី ៤០ / ទំព័រទី ២០៨

ដោយហេតុ ๒ យ៉ាង គឺ ដោយអាមិស ๑ ដោយធម៌ ๑, ការបិទបាំងនូវប្រហោងនៃលោកសន្និវាសនោះ ដោយអាមិសនិងដោយធម៌ ដោយប្រការដែលប្រហោងនោះ នឹងប្រាកដមិនបាន ដូចជាការបិទបាំងនូវកៅអី ដោយគ្រឿងកម្រាលដូច្នោះឯង ឈ្មោះថា បដិសណ្ឋារៈ ។ ក៏បណ្តាបដិសណ្ឋារៈទាំង ๒ យ៉ាងនោះ ការសង្គ្រោះដោយអាមិស ឈ្មោះថា អាមិសបដិសណ្ឋារៈ ។ ភិក្ខុអ្នកធ្វើអាមិសបដិសណ្ឋារៈនោះ សូម្បីមិនកាន់យកនូវរបស់ដ៏ល្អហើយ ឲ្យដល់មាតានិងបិតាទាំងឡាយ ដល់វេយ្យាវច្ចករ អ្នកបម្រើភិក្ខុ ដល់ព្រះរាជា និងដល់ពួកចោរ ក៏សមគួរ ។ ព្រោះថា កាលបើរបស់ដ៏ល្អ គឺភិក្ខុពាល់ត្រូវហើយឲ្យ, ព្រះរាជានិងពួកចោរ រមែងធ្វើនូវសេចក្តីវិនាសក៏មាន ធ្វើឲ្យដល់ការអស់ទៅ នៃជីវិតក៏មាន, កាលបើរបស់ដ៏ល្អ គឺភិក្ខុមិនបានពាល់ត្រូវហើយឲ្យទៅ, ព្រះរាជានិងពួកទាំងនោះ រមែងមានចិត្តត្រេកអរ ។ ក៏ក្នុងការធ្វើនូវបដិសណ្ឋារៈនេះ គប្បីសំដែងរឿងទាំងឡាយ មានរឿងព្រះបាទចោរនាគជាដើម ។ ការសង្គ្រោះ ដោយធម៌ យ៉ាងនេះ គឺការឲ្យឱទ្ទេស ការពណ៌នាបាលី ការសំដែងធម៌ ដោយសេចក្តីគោរព ឈ្មោះថា ធម្មបដិសណ្ឋារៈ" ។

ដីកាសង្គីតិសូត្រនោះ ថា "លោកសន្និវាសនេះ មានប្រហោង

ដោយហេតុ ២ យ៉ាង គឺ ដោយអាមិសដែលខ្លួនមិនបាន ១ ដោយធម៌យ៉ាងដូច្នោះឯង ១, ក៏ការបិទ គឺ ការបិទបាំង បានដល់ការញ៉ុក នូវប្រហោង គឺ រន្ធ គឺ កន្លែងដែលចែកធ្លាយ ដែលមាននៅក្នុងចន្លោះ នៃខ្លួននិងបុគ្គលដទៃ ព្រោះមិនបានអាមិសនិងធម៌ ឈ្មោះថា បដិសណ្ឋារៈ ។ ២ បទថា **'អត្តំ អគ្គហេត្វា'** គឺ មិនចាប់យកនូវរបស់ដ៏ល្អ ដើម្បីខ្លួន ។ ការសំដែងបាលី និងអដ្ឋកថា ឈ្មោះថា ការឱ្យឱទ្ទេស ។ ការពណ៌នាសេចក្តី នៃបាលី ឈ្មោះថា ការពណ៌នាបាលី ។ ការប្រាប់ធម៌ ដោយអំណាចនៃវិធីមានការប្រាប់ដោយសំឡេង និង ដោយបទជាដើម ឈ្មោះថា ការប្រាប់នូវធម៌ ” ។

(២៧០) សូម្បីក្នុងនិក្ខេបកណ្ឌ ព្រះធម្មសេនាបតី ក៏បានពោលហើយ ថា “ ក្នុងមាតិកាដែលបានលើកឡើងមក តាំងទុកនោះ បដិសណ្ឋារៈ តើដូចម្តេចទៅ ? ” គឺ អាមិសបដិសណ្ឋារៈ ១ ធម្មបដិសណ្ឋារៈ ១, បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទទួលដោយអាមិសបដិសណ្ឋារៈខ្លះ ដោយធម្មបដិសណ្ឋារៈខ្លះ , នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា ‘ បដិសណ្ឋារៈ ” ។

(២៧១) អដ្ឋកថានៃនិក្ខេបកណ្ឌ ថា “ ២ បទថា **'បដិសណ្ឋារកោ ហោតិ'** មានសេចក្តីថា ក៏ប្រហោងទាំង

ឡាយ នៃលោកសន្និវាស មាន ២ យ៉ាងប៉ុណ្ណោះឯង, បុគ្គលជាអ្នកបិទបាំងនូវប្រហោងទាំង ២ នោះ គឺ រមែងធ្វើបដិសណ្ឋារៈមិនដែលដាច់ ។ ក៏ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គ្រាន់តែឃើញភិក្ខុអាគន្តុកៈ កំពុងតែនិមន្តមក គប្បីក្រោកទទួលហើយ ទទួលយកនូវបាត្រនិងចីពរ គប្បីឲ្យអាសនៈ គប្បីបក់ដោយដៃតស្លឹកស្នោត គប្បីលាងជើងហើយ លាបដោយប្រេង, កាលបើទឹកដោះរាវថ្លាទឹកអំពៅនិងប្រេងមាន, គប្បីប្រគេនភេសជ្ជៈ គប្បីសួរដោយទឹកសម្រាប់ឆាន់ គប្បីបោសសំអាតអាវាស ។ អាមិសបដិសណ្ឋារៈ ឈ្មោះថា គឺភិក្ខុបានធ្វើហើយ ដោយឯកទេស យ៉ាងដូច្នេះឯង ។ មួយទៀត ក្នុងវេលាល្ងាច កាលបើភិក្ខុអាគន្តុកៈ សូម្បីជាអ្នកខ្ចីវស្សាជាង មិនបាននិមន្តមកកាន់ទីបំរុងរបស់ខ្លួនទេ, ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីនិមន្តទៅភាន់សំណាក់នៃភិក្ខុអាគន្តុកៈនោះ អង្គុយហើយ កុំសួរបញ្ហា ក្នុងរឿងដែលមិនមែនជាវិស័យ គប្បីសួរបញ្ហា ក្នុងវិស័យ របស់ភិក្ខុអាគន្តុកៈនោះ ។ ភិក្ខុអ្នកធ្វើនូវបដិសណ្ឋារៈ មិនគួរសួរថា 'អ្នកទាំងឡាយ ជាអ្នកពោលគម្ពីរអ្វីដែរ ?' ដូច្នេះ ត្រូវសួរថា 'អាចារ្យនិងព្រះឧបជ្ឈាយ៍ តែងប្រើគម្ពីរណាខ្លះ ?' ដូច្នេះហើយ គប្បីសួរបញ្ហា ក្នុងឋានៈដែលល្មមសមគួរ ។ បើភិក្ខុអាគន្តុកៈនោះ អាចឆ្លើយបាន, ការធ្វើបាន

យ៉ាងនេះនុ៎ះ ជាការល្អ, បើភិក្ខុអាគន្តុកៈនោះ មិនអាចឆ្លើយបានទេ, ត្រូវតែឆ្លើយឱ្យខ្លួនឯង ។ ធម្មបដិសណ្ឋារៈ ឈ្មោះថា គឺភិក្ខុបានធ្វើហើយ ដោយឯកទេស ដោយប្រការដូច្នេះ ។ បើភិក្ខុអាគន្តុកៈនោះ នៅក្នុងសំណាក់របស់ខ្លួន, គប្បីនាំភិក្ខុអាគន្តុកៈនោះ ទៅបិណ្ឌបាត ជាញឹកញាប់ ។ បើភិក្ខុអាគន្តុកៈនោះ មិនចង់ទៅទេ, ក្នុងថ្ងៃស្អែកឡើង ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីនាំភិក្ខុអាគន្តុកៈនោះទៅ ដោយការទៅតាមប្រក្រតី និមន្តបិណ្ឌបាត ក្នុងផ្ទះមួយហើយ គប្បីបញ្ជូនមកវិញ ។ បើភិក្ខុទាំងឡាយ ជាអ្នកគឺពួកទាយកនិមន្តហើយ ក្នុងទិសភាគដទៃ, ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីនាំភិក្ខុអាគន្តុកៈ អ្នកប្រាថ្នានោះ ទៅផង ។ កាលបើភិក្ខុអាគន្តុកៈនោះ ពោលថា 'ទិសភាគនុ៎ះ មិនត្រូវចិត្តខ្ញុំទេ' ដូច្នេះហើយ មិនប្រាថ្នា (ដើម្បីនឹងទៅ), ភិក្ខុម្ចាស់វត្ត ត្រូវបញ្ជូនភិក្ខុដែលនៅសល់ទាំងឡាយទៅ ហើយត្រូវនាំភិក្ខុអាគន្តុកៈនោះទៅបិណ្ឌបាត ។ គប្បីប្រគេនអាមិសដែលខ្លួនបានមក ដល់ភិក្ខុអាគន្តុកៈនោះ ។ អាមិសបដិសណ្ឋារៈ ឈ្មោះថា គឺភិក្ខុបានធ្វើហើយ ដោយឯកទេស ដោយប្រការដូច្នេះ ។ សួរថា 'ក៏ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីឱ្យអាមិសដែលខ្លួនបានមកហើយ ដល់បុគ្គលដូចម្តេច ?' ។ ឆ្លើយថា 'គប្បីប្រគេន ដល់ភិក្ខុអាគន្តុកៈ

មុនគេ ។ បើភិក្ខុទាំងឡាយដែលអាពាធឬភិក្ខុទាំងឡាយដែលមិនមានវស្សាមាននៅ, គប្បីប្រគេន ដល់ភិក្ខុទាំងឡាយនោះឯង, គប្បីប្រគេនដល់ព្រះអាចារ្យនិងព្រះឧបជ្ឈាយ៍ ។ គប្បីឱ្យដល់ភិក្ខុអ្នកថែរក្សាឃ្លាំង ។ ចំណែកភិក្ខុអ្នកបំពេញសារាណីយធម៌ គប្បីប្រគេន ដល់ភិក្ខុអាគន្តុកៈទាំងឡាយ ដែលនិមន្តមកហើយ ។ សូម្បី ១០០ ដង សូម្បី ១.០០០ ដង ចាប់តាំងអំពីអាសនៈនៃព្រះថេរៈចុះមក ។ មួយទៀត ភិក្ខុរូបណា ។ មិនទាន់បានភត្ត, ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីប្រគេនដល់ភិក្ខុរូបនោះ ។ ។ ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ និមន្តចេញទៅខាងក្រៅផ្ទះ ឃើញមនុស្សចាស់ជរា មនុស្សអនាថា ឬនាងភិក្ខុនី គប្បីឱ្យសូម្បីដល់បុគ្គលទាំងនោះ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍)

(អ្នកធ្វើអាមិសបដិសណ្ឋារៈ)

(២៧២) បានឮមកថា កាលបើភុត្តសាលគ្រាម ត្រូវពួកចោរប្លន់, ព្រះថេរីជាខីណាស្រព ១ រូប ចេញអំពីនិរោធសមាបត្តិក្នុងខណៈនោះឯង បានឱ្យនាងភិក្ខុនីក្រមុំកាន់កញ្ចប់ភ័ណ្ឌៈ ហើយដើរផ្លូវ ព្រមជាមួយនឹងមហាជន ក្នុងវេលាថ្ងៃត្រង់ បានមកដល់មាត់ទ្វារស្រុកនង្គុលនគរ ទើបអង្គុយ (សំរាក) ក្បែរគល់ឈើ ។

ក្នុងសម័យនោះ ព្រះមហានាគថេរ អ្នកមានប្រក្រតីនៅក្នុងកាឡវល្លីមណ្ឌប បាននិមន្តទៅបិណ្ឌបាត ក្នុងស្រុកនង្គលនគរហើយ និមន្តចេញមក ជួបនូវព្រះថេរី ទើបសួរដោយអើពើ ដោយភ័ក្តៗ ព្រះថេរីនោះ ឆ្លើយថា 'បាត្ររបស់នាងខ្ញុំមិនមានទេ'។ ព្រះថេរៈពោលថា 'សូមអ្នកនិមន្តរាន់ ដោយបាត្រនេះឯង' ដូច្នេះហើយ ទើបបានប្រគេនព្រមទាំងបាត្រទៅ។ ព្រះថេរីរាន់ស្រេចហើយ លាងបាត្រប្រគេន ដល់ព្រះថេរៈ ហើយពោលថា 'ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ នឹងលំបាក ដោយកិក្ខាចារសិនចុះ, បពិត្រព្រះគុណម្ចាស់ ក៏ចាប់តាំងអំពីពេលនេះទៅ ឈ្មោះថា ការក្តៅក្រហាយដោយកិក្ខា នឹងមិនមាន ដល់ព្រះគុណម្ចាស់ឡើយ'។ ចាប់តាំងពីពេលនោះមក ឈ្មោះថា បិណ្ឌបាតដែលមានតម្លៃតិចជាងអំពី ១ កហាបណៈ មិនដែលកើតឡើងហើយ ដល់ព្រះថេរៈ។ នេះឈ្មោះថា អាមិសបដិសណ្ឋារៈ។

(ធម្មបដិសណ្ឋារៈ)

ភិក្ខុអ្នកធ្វើបដិសណ្ឋារៈនេះ គប្បីតាំងនៅ ក្នុងចំណែកនៃការសង្រ្គោះហើយ ប្រាប់កម្មដ្ឋាន ដល់ភិក្ខុនោះ។ គប្បីបង្រៀនធម៌។ គប្បីបន្ទោបង់នូវសេចក្តីរាយមាយចិត្ត។ គប្បីធ្វើកិច្ច

ដែលគួរធ្វើដែលកើតឡើងហើយ ។ គប្បីឱ្យអព្ភាន វុដ្ឋាន មានត និងបវារណាសកម្ម ។ បុគ្គលអ្នកគួរដល់បព្វជ្ជា គប្បីឱ្យបព្វជ្ជា ។ អ្នកគួរដល់ឧបសម្បទ គប្បីឱ្យឧបសម្បទ ។ សូម្បីនាងភិក្ខុនីដែលប្រាថ្នាចង់ឧបសម្បទ ក្នុងសំណាក់របស់ខ្លួន ភិក្ខុនីងធ្វើកម្មវាចាក៏សមគួរ ។ នេះ ឈ្មោះថា ធម្មបដិសណ្ឋារៈ ។

ជីកានិក្ខេបកណ្ឌនោះ ថា "២ បទថា **'សង្គហបក្ខេ ឋត្វា'** មានសេចក្តីថា គឺភិក្ខុអ្នកប្រាថ្នានូវសេចក្តីសង្គ្រោះនុ៎ះឯង គប្បីប្រាប់ឱ្យ, អធិប្បាយថា មិនមែនប្រាប់ឱ្យ ព្រោះហេតុត្រឹមតែលាភនិងសក្ការៈជាដើមឡើយ ។ ការងារដែលត្រូវធ្វើ ដោយពិតប្រាកដ ចាត់ទុកថាជាកិច្ច ។ ការងារក្រៅអំពីនេះ គឺគ្រាន់តែជាករណីយ៍ ។ ការចេញអំពីអាបត្តិដទៃ ចាកអព្ភានកម្ម ជាវុដ្ឋាន" ។

(អនាមដ្ឋបិណ្ឌបាតភិក្ខុគួរឱ្យដល់មាតាបិតា)

(២៧៣) អដ្ឋកថាកេសជ្ជករណវត្ថុ ក្នុងតតិយបារាជិក ថា "អនាមដ្ឋបិណ្ឌបាត (បិណ្ឌបាតដែលភិក្ខុមិនទាន់បានចាប់កាន់) ភិក្ខុគប្បីឱ្យ ដល់មាតានិងបិតាទាំងឡាយជាមុនសិន ។ ប្រសិនបើបិណ្ឌបាតនោះ ជារបស់មានតម្លៃដល់ទៅ ១ កហាបណៈ, ក៏មិនចាត់ថា ជាការញុំាងទានដែលទាយកឱ្យដោយសទ្ធា ឱ្យធ្លាក់ចុះឡើយ ។

គប្បីឲ្យ សូម្បីដល់បុគ្គលទាំងនេះ គឺ ពួកជនដែលឧបដ្ឋាកមាតាបិតា
វេយ្យាវច្ចករ បណ្ឌុបលាសៈ ។ បណ្តាជនទាំងនោះ សូម្បីដាក់ក្នុង
ភាជនៈហើយឲ្យ ដល់បណ្ឌុបលាសៈ ក៏សមគួរ ។ លើកលែងតែ
បណ្ឌុបលាសៈនោះចេញ នឹងដាក់ក្នុងភាជនៈ ហើយឲ្យ ដល់គ្រហស្ថ
ទាំងឡាយដទៃទៀត សូម្បីជាមាតាបិតា ក៏មិនគួរ ។ ព្រោះថា
គ្រឿងប្រើប្រាស់របស់បព្វជិត ជារបស់ស្ថិតនៅក្នុងឋានៈជាចេតិយ
របស់ពួកគ្រហស្ថ ។ ម្យ៉ាងទៀត ធម្មតាអនាមដ្ឋបិណ្ឌបាតនេះ
ភិក្ខុគប្បីឲ្យ សូម្បីដល់ចោរដែលមានឈ្មោះសំឡេង សូម្បីដល់
ឥស្សរជនដែលមកដល់ហើយ ។ ព្រោះហេតុអ្វី ? ។ ព្រោះថា
ទាំងចោរ ទាំងឥស្សរជនទាំងនោះ, កាលបើបិណ្ឌបាត សូម្បីភិក្ខុ
មិនឲ្យក្តី, ក៏ក្រោធថា 'មិនឲ្យ' ដូច្នេះ, សូម្បីភិក្ខុចាប់ឲ្យក្តី,
ក៏រមែងក្រោធថា 'ឲ្យរបស់ដែលជាដែល' ។ មែនពិត ទាំងចោរ
ទាំងឥស្សរជនទាំងនោះ ក្រោធហើយ រមែងផ្តាច់បង់ភិក្ខុចាកជីវិត
ក៏មាន រមែងធ្វើសេចក្តីអន្តរាយ ដល់ព្រះសាសនាក៏មាន ។ ក៏ក្នុង
រឿងនេះ គប្បីសំដែងរឿងព្រះបាទចោរនាគ ទ្រង់ប្រាថ្នារាជសម្បត្តិ
ស្តេចយាងទៅ (ជាឧទាហរណ៍) ។ បដិសណ្ឋារៈ គឺភិក្ខុគប្បីធ្វើ
ដល់បុគ្គលណាមួយ ដែលមកដល់វិហារហើយ ទោះជាភ្ជៀវក្តី
ជាមនុស្សក្រីក្រក្តី ជាចោរក្តី ជាឥស្សរជនក្តី ដោយពិត ។

សួរថា 'គប្បីធ្វើ យ៉ាងដូចម្តេច ?'។ ឆ្លើយថា 'ភិក្ខុឃើញភ្ញៀវ ដែលអស់ស្បៀង មកដល់វិហារហើយ គប្បីឲ្យទឹកសម្រាប់ផឹក ដោយប្រាប់ថា 'សូមអ្នកអញ្ជើញពិសាទឹក' ដូច្នេះជាមុន ។ គប្បីឲ្យប្រេងសម្រាប់លាបជើង ។ អាគន្តុកៈដែលមកហើយ ក្នុងកាលភិក្ខុគប្បីឲ្យយាគូនិងភត្ត ។ អាគន្តុកៈដែលមកហើយ ក្នុងសម័យវិកាល បើអង្ករមាន, គប្បីឲ្យអង្ករ ។ ភិក្ខុមិនត្រូវពោលថា 'អ្នកមកដល់ហើយ ក្នុងសម័យមិនមែនជាកាល ចូរអ្នកទៅវិញចុះ'។ គប្បីឲ្យទីដេក ។ ភិក្ខុមិនប្រាថ្នា (អ្វី) ឡើយ គប្បីធ្វើកិច្ចការគ្រប់បែបយ៉ាង ។ ភិក្ខុមិនគួរញុំាងចិត្ត ឲ្យកើតឡើងថា 'ធម្មតាពួកមនុស្ស អ្នកប្រគេនបច្ច័យ ៤, កាលបើអាត្មាអញ ធ្វើសេចក្តីសង្រ្គោះ យ៉ាងដូច្នេះ, នឹងជ្រះថ្លាហើយ ធ្វើឧបការៈរឿយៗ' ។ សូម្បីវត្តុជារបស់សង្ឃ ក៏ភិក្ខុគប្បីឲ្យ ដល់ពួកចោរបានដែរ" ។

(២៧៤) ជីកានៃភេសជ្ជករណវត្តុនោះ ថា "បិណ្ឌបាតដែលភិក្ខុបានមកហើយ អំពីដៃនៃបុគ្គល ដែលមិនមែនជាបព្វជិត មានចំណែកដ៏ប្រសើរ គឺខ្លួន ឬបព្វជិតដទៃទៀត មិនទាន់បានប៉ះពាល់ហើយ ឈ្មោះថា អនាមដ្ឋបិណ្ឌបាត" ។

នវជីកាថា "បិណ្ឌបាត ដែលមានចំណែកដ៏ប្រសើរ គឺភិក្ខុមិនទាន់បានប៉ះពាល់, អធិប្បាយថា 'គឺអ្នកណាមួយ មិនទាន់បាន

បរិភោគ ឈ្មោះថា អនាមដ្ឋបិណ្ឌបាត ។ បទថា **'ថាលកេ'** បានដល់ ក្នុងភាជនៈដែលធ្វើហើយ ដោយសំរឹទ្ធិជាដើម ដែលជារបស់នៃសង្ឃ ។ ចំណែកបាត្រ ក៏លោកសង្គ្រោះ ចូលក្នុងពាក្យនេះផងដែរ ។ ដោយពាក្យថា 'មិនគួរ' នេះ ព្រះអដ្ឋកថាចារ្យសំដែងថា 'ជាអាបត្តិទុក្កដ' ដូច្នេះ" ។

ដីកានៃភេសជ្ជករណវត្ថុនោះថា "បទថា **'ទាមរិកចោរស្ស'** បានដល់ ចោរអ្នកមានឈ្មោះល្បីល្បាញ ដែលប្រាថ្នាចង់បាននូវរាជសម្បត្តិ ។ ក្នុងពាក្យថា 'រឿងរបស់ព្រះបាទចោរនាគ' នេះគប្បីជ្រាបសេចក្តី ដូចតទៅនេះ ÷

បានឮថា ព្រះថេរៈគិតថា 'កាលបើអាត្មាអញថ្វាយបិណ្ឌបាតដែលអាត្មាអញប៉ះពាល់ហើយ ដល់ព្រះបាទចោរនាគ, ព្រះអង្គនឹងទ្រង់ព្រះពិរោធ, អាត្មាអញនឹងថ្វាយបិណ្ឌបាតដែលមានចំណែកដ៏ប្រសើរ ដែលអាត្មាអញមិនទាន់បានប៉ះពាល់ហើយ នឹងមិនគួរ' ដូច្នេះហើយ ទើបបានចាប់យកចំណែកបិណ្ឌបាត ដោយដៃដែលចាប់បាត្រនុ៎ះឯងហើយ ក៏បានថ្វាយភ័ត្ត ក្នុងបាត្រ ទាំងអស់ទៅ ។ ព្រះអង្គ ទ្រង់បានសព្វព្រះរាជហឫទ័យហើយ ដោយភ័ត្តនោះ" ។

(២៧៥) អដ្ឋកថានិក្ខេបកណ្ឌ ថា "ភិក្ខុអ្នកធ្វើបដិសណ្ឋារៈដោយបដិសណ្ឋារៈ ២ យ៉ាងនេះ រមែងញុំាងលាភ ដែលមិនទាន់

កើតឡើង ឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយ ឲ្យបានស្ថិតនៅគង់វង់ រមែងថែរក្សាជីវិត របស់ខ្លួនបាន ក្នុងទីដែលមានសេចក្តីរង្កៀសសង្ស័យ ដូចជាព្រះថេរៈ ដែលបានចាប់យកចំណែកចិញ្ចាបដ៏ប្រសើរ ដោយដៃដែលចាប់បាត្រនុ៎ះឯងហើយ ចាក់ភ័ក្តដោយបាត្រនុ៎ះឯង ថ្វាយដល់ព្រះបាទចោរនាគ ដូច្នោះឯង ។ ក៏ក្នុងការញុាំងលាភ ដែលមិនទាន់បានឲ្យកើតឡើង គប្បីសំដែងរឿងមហាកេសជ្ជទាន ដែលព្រះរាជា ទ្រង់ព្រះនាមព្រះមហានាគស្តេចយាងចេញ អំពីច្រាំងខាងអាយនោះ ស្តេចយាងទៅកាន់ច្រាំងខាងនាយ ទ្រង់បាននូវសេចក្តីសង្រ្គោះ ក្នុងសំណាក់នៃព្រះថេរៈមួយរូបហើយ ស្តេចយាងត្រឡប់មក ទ្រង់បានស្ថិតនៅ ក្នុងព្រះរាជសម្បត្តិ ម្តងទៀត ទ្រង់ឲ្យប្រព្រឹត្តទៅ ក្នុងបត្តម្ពង្គណវិហារ ដរាបដល់អស់ព្រះជន្មាយុ ។ ក្នុងការធ្វើលាភដែលកើតឡើងហើយ ឲ្យបានស្ថិតស្ថេរគង់វង់ គប្បីសំដែងរឿងដែលពួកចោរបានទទួលបដិសណ្ឋារៈ អំពីដៃនៃព្រះទីឃភាណកអភយត្ថេរហើយ មិនបាននាំគ្នាប្លន់ភ័ណ្ឌ ក្នុងចេតិយបព៌តវិហារ ”។

(២៧៦) អដ្ឋកថាកេសជ្ជកវណ្ណនា ថា “ ដើម្បីសំដែងអានិសង្សនៃការធ្វើបដិសណ្ឋារៈ ព្រះអដ្ឋកថាចារ្យ បានពោលរឿងទាំងឡាយ យ៉ាងច្រើន ដោយពិស្តារ ទុកក្នុងមហាអដ្ឋកថា

មានជាអាទិ៍យ៉ាងនេះ គឺ រឿងព្រះបាទចោរនាគ រឿងព្រះរាជា ព្រះនាមមហានាគ ដែលទ្រង់ស្តេចយាងទៅកាន់ជម្ពូទ្វីប ជាមួយនឹង ព្រះរាជភាគា រឿងអាមាត្យទាំង ៤ នាក់ ក្នុងរជ្ជកាលនៃព្រះបាទ បិតុរាជ រឿងអភយចោរ ។

បណ្តារឿងទាំងនោះ នឹងសំដែងរឿងមួយ ដូចតទៅនេះ ÷

(រឿងអភយចោរ)

បានឮមកថា ក្នុងកោះសីហឡៈ ចោរ ឈ្មោះអភ័យ មាន បរិវារប្រមាណ ៥០០ នាក់ បោះបន្ទាយនៅ ក្នុងទីកន្លែងមួយ ញុំាងប្រជាជនឲ្យភៀសខ្លួនចេញទៅ អស់ទីប្រមាណ ៣ យោជន៍ ដោយជុំវិញ ។ ប្រជាជនអ្នកនៅក្នុងអនុរាធបុរី ឆ្លងទន្លេ កលម្អកនទីមិនបាន ។ លើផ្លូវទៅចេតិយគិរីវិហារ ការសញ្ចរ ទៅមកនៃប្រជាជន ដាច់ខាតហើយ ។ ក្រោយមកថ្ងៃមួយ ពួកចោរ បាននាំគ្នាទៅហើយ ដោយគិតថា 'ពួកយើង នឹងប្លន់នូវ ចេតិយគិរីវិហារ' ។ ពួកញ្ជោមវត្ត បានឃើញហើយ ទើបប្រាប់ ដល់ព្រះទីឃភាណកអភយត្ថេរ ។ ព្រះថេរៈ សួរថា 'តើវត្ត ទាំងឡាយ មានទឹកដោះរាវថ្លា និង ទឹកអំពៅជាដើមមានទេ ?' ។

ពួកញ្ជោមវត្ត . បពិត្រព្រះគុណម្ចាស់ មាន ។

ព្រះថេរៈ . ពួកអ្នកទាំងឡាយ ចូរឱ្យដល់ពួកចោរចុះ ។ តើអង្ករ មានឬទេ ? ។

ពួកញោមវត្ត . បពិត្រព្រះគុណម្ចាស់ អង្ករ បន្លែស្រស់ និងគោរស ដែលគេនាំយកមកហើយ ដើម្បីព្រះសង្ឃ មាន ។

ព្រះថេរៈ . ពួកអ្នកចូរចាត់ចែងភ័ត្ត ឱ្យដល់ពួកចោរ ។

ពួកញោមវត្ត . បានធ្វើហើយ ដូចជាព្រះថេរៈប្រាប់ ។

ពួកចោរបរិភោគភ័ត្តហើយ សួរថា 'តើបដិសណ្ឋារៈនេះ អ្នកណា ធ្វើហើយ ?' ។

ពួកញោមវត្ត . ព្រះអភយត្ថេរជាម្ចាស់របស់ពួកយើងខ្ញុំ ។

ពួកចោរ បានទៅសំណាក់ របស់ព្រះថេរៈ ថ្វាយបង្គំហើយ ពោលថា 'ពួកខ្ញុំព្រះករុណា មកហើយ ដោយគិតថា 'ពួកយើងនឹងប្លន់យក នូវវត្ថុជារបស់ព្រះសង្ឃនិងព្រះចេតិយ' ដូច្នេះ, ប៉ុន្តែ ពួកខ្ញុំព្រះករុណា ជាអ្នកជ្រះថ្លាហើយ ដោយការធ្វើបដិសណ្ឋារៈនេះ របស់ព្រះគុណម្ចាស់, ចាប់តាំងអំពីថ្ងៃនេះទៅ ការថែរក្សាដែលប្រកបដោយធម៌ ក្នុងព្រះវិហារ ចូរជានាទីនៃពួកយើងខ្ញុំចុះ, ពួកអ្នកនគរ ចូរមកថ្វាយទាន, ចូរថ្វាយបង្គំព្រះចេតិយចុះ' ។

ក៏ចាប់ដើមអំពីពេលនោះមក កាលបើអ្នកគនរ មកដើម្បីថ្វាយទាន, ពួកចោរទាំងនោះ ក៏ទៅទទួលដល់មាត់ទន្លេតែម្តង

ចាំថែរក្សា នាំទៅវិហារ, កាលបើពួកអ្នកនគរកំពុងថ្វាយទាន ក្នុងវិហារ, ក៏នាំគ្នាឈរចាំធ្វើការថែរក្សា ។ ចំណែកពួកអ្នកនគរទាំងនោះ ក៏ឱ្យភ័ត្តដ៏សេសសល់ ដែលភិក្ខុទាំងឡាយឆាន់ហើយ ដល់ពួកចោរ ។ សូម្បីក្នុងពេលត្រឡប់ទៅវិញ ពួកចោរទាំងនោះ ក៏ជូនពួកអ្នកនគរទាំងនោះដល់មាត់ច្រាំងទន្លេហើយ ទើបវិលត្រឡប់មកវិញ ។

ក្រោយមកថ្ងៃមួយ បានកើតមានពាក្យគិះជៀល ចំពោះភិក្ខុសង្ឃ ថា 'ព្រះថេរៈ បានឱ្យវត្ថុជារបស់នៃសង្ឃ ដល់ពួកចោរព្រោះប្រកាន់ថាខ្លួនជាធំ' ។ ព្រះថេរៈ បញ្ជាឱ្យធ្វើការប្រជុំសង្ឃ ហើយពោល ថា 'ពួកចោរ បាននាំគ្នាមកហើយ ដោយតាំងចិត្ត ថា 'ពួកយើង នឹងប្តូរយកទ្រព្យថ្លៃចង្ការាន់តាមប្រក្រតី របស់សង្ឃ និងទ្រព្យរបស់ចេតិយ' ដូច្នេះ, កាលបើដូច្នោះ ទើបខ្ញុំធ្វើបដិណ្ណាវៈ ដល់ពួកចោរទាំងនោះ មានប្រមាណប៉ុណ្ណោះ ដោយគិតឃើញ ថា 'ពួកចោរ នឹងមិនប្តូរ ដោយប្រការយ៉ាងនេះ' ដូច្នេះ, ពួកអ្នកទាំងឡាយ ចូរយករបស់ទាំងអស់រួមបញ្ចូលគ្នាហើយ រាយតម្លៃចុះ, ពួកអ្នកទាំងឡាយ ចូរយករបស់ដែលពួកចោរមិនបានប្តូរយកទៅ ដោយហេតុនោះ រួមបញ្ចូលជាមួយគ្នាហើយ រាយតម្លៃមើលចុះ' ។ ទ្រព្យសម្បត្តិ ដែលព្រះថេរៈ ឱ្យទៅទាំងអស់ អំពី

ទ្រព្យរបស់សង្ឃនោះ មានតម្លៃមិនស្មើគ្រឿងកម្រាល ដែលវិចិត្រដ៏ល្អ មួយផ្ទាំង ក្នុងរោងព្រះចេតិយឡើយ ។ លំដាប់នោះ ពួកភិក្ខុទាំងឡាយ ពោល ថា 'ព្រះថេរៈធ្វើបដិសណ្ឋារៈល្អហើយ, អ្នកណាមួយ មិនបានដើម្បីចោទ ឬដើម្បីឱ្យលោកឱ្យការណ៍ឡើយ, សំណាង ឬការលួចយក មិនមាន' ។ បដិសណ្ឋារៈ មានអានិសង្សច្រើន យ៉ាងដូច្នេះឯង, ភិក្ខុជាបណ្ឌិត កំណត់ដូចបានពោលមកហើយ គប្បីធ្វើបដិសណ្ឋារៈ" ។

ជីកាភេសជ្ជករណវត្ថុនោះ ថា "បទថា '**ឧព្ភាសេត្វា**' មានសេចក្តីថា អភយចោរ ប្លន់រហូតទីប្រមាណ ៣ យោជន៍ ដោយជុំវិញ បណ្តេញពួកមនុស្ស ឱ្យរត់ហើយ ធ្វើទីកន្លែងនោះ មិនឱ្យជាទីនៅ របស់ពួកជនដទៃ ។ ពាក្យថា '**សង្ឃស្ស អត្ថាយ អាហដា**' បានដល់ នាំមកអំពីទ្រព្យថ្លៃអាហារដែលសំរាប់ដាំស្មូ ដើម្បីប្រយោជន៍ដល់ថ្ងៃនោះ ។ បទថា '**វរបោត្ថកចិត្តត្ថរកំ**' បានដល់ គ្រឿងកម្រាលដ៏វិចិត្រ ដោយរូបភាពដ៏ប្រសើរៗ ច្រើនជាអនេកប្បការ" ។

រឿងអភយចោរ ចប់ ។

(២៧៧) ក៏ក្នុងពាក្យថា "ក្នុងរជ្ជកាលនៃព្រះបាទចិតុរាជ" នេះ មានការពណ៌នា ដោយពិស្តារ ដូចតទៅនេះ ÷

(រឿងព្រះបាទបិតុរាជ)

បានឮមកថា ព្រះរាជាទ្រង់ព្រះនាមសទ្ធាតិស្សៈ ទ្រង់មានព្រះរាជបុត្រ ៤ ព្រះអង្គ គឺ ព្រះរាជបុត្រព្រះនាមលញ្ឆតិស្សៈ ១ ព្រះនាមថូលត្ថនកៈ ១ ព្រះនាមខល្លាដនាគៈ ១ ព្រះនាមវដ្តគាមណីអភ័យ ១ ។ បណ្តាព្រះរាជបុត្រទាំងនោះ ព្រះបាទខល្លាដនាគ ទ្រង់មានព្រះឱរសព្រះនាម មហាចូឡិកៈ ។ ព្រះបាទវដ្តគាមណីអភ័យ មានព្រះរាជឱរស ទ្រង់ព្រះនាម មហានាគ ។ ក៏ព្រះបាទវដ្តគាមណីអភ័យ ទ្រង់សោយរាជ្យហើយ ក៏ទ្រង់បានតែងតាំងព្រះរាជនត្តា របស់ព្រះអង្គ ក្នុងព្រះតំណែង នៃព្រះរាជបុត្រ ។ ព្រោះហេតុនោះ ព្រះរាជាព្រះអង្គនោះ ទើបប្រាកដព្រះនាមថា "ព្រះបាទបិតុរាជ" ។ កាលបើព្រះរាជាអង្គនោះ ទ្រង់គ្រងរាជសម្បត្តិ បាន ៥ ខែ, មានពួកទមិឡ ៥ នាក់ គឺ ចូឡហត្ថៈ ពាហិយៈ បុនយមារៈ បីឡយមារៈ និង ទាធិយៈ បាននាំគ្នាមកហើយ ដើម្បីដណ្តើមយករាជសម្បត្តិ ។ ព្រះរាជាទ្រង់បានតយុទ្ធ ជាមួយនឹងពួកទមិឡទាំងនោះ ទ្រង់បរាជ័យហើយ ទើបទ្រង់នាំយកជនទាំងឡាយ ៣ នាក់ គឺ ព្រះនាងអនុឡាទេវី ១ ព្រះរាជនត្តាព្រះនាម មហាចូឡិកៈ ១ ព្រះរាជឱរសព្រះនាម មហានាគ ១ ស្តេចយាងគេចចេញទៅហើយ ។ ព្រះអង្គ

ព្រមទាំងព្រះរាជឱរស និង ព្រះអគ្គមហេសី ទ្រង់ពួនសម្ងំហើយ ក្នុងព្រៃក្បែរវេស្សគិរីវិហារ ក្នុងមលយប្រទេស ។

លំដាប់នោះ ព្រះថេរៈ មួយអង្គ ឈ្មោះថា កុធិក្កលមហាតិស្សត្ថេរ ជាកុលុបកៈ របស់ព្រះអង្គ បានថ្វាយព្រះក្រយាហារ ដល់ព្រះរាជា ។ ដោយហេតុនោះ ទើបព្រះមហានាមត្ថេរ បានពោលពាក្យជាគាថា ក្នុងបរិច្ឆេទទី ៣៤ នៃគម្ពីរមហាវង្ស ថា÷

> “ក៏ព្រះកុធិក្កលមហាតិស្សត្ថេរ បានឃើញព្រះបាទបិតុរាជនោះ ក្នុងព្រៃក្បែរវេស្សគិរីវិហារនោះ ហើយ ក៏វៀរស្រឡះអនាមដ្ឋបិណ្ឌបាតទាន បានថ្វាយព្រះក្រយាស្ងោយ (ដល់ព្រះអង្គ) ហើយ” ។

បណ្តាបទទាំងនោះ ២ បទថា “**តហិ តុ តំ**” គឺ បានឃើញនូវព្រះរាជាអង្គនោះ ក្នុងព្រៃក្បែរវេស្សគិរីវិហារនោះ ។ បទថា “**បាទា**” គឺ បានថ្វាយហើយ សូម្បីនូវព្រះក្រយាស្ងោយ ។ ពាក្យថា “**អនាមដ្ឋបិណ្ឌទានំ វិវជ្ជិយ**” មានសេចក្តីថា ការបែងចែក នូវចំណែកនៃបិណ្ឌៈ ចាកបិណ្ឌបាត ដែលទាយកគប្បីឱ្យដោយសទ្ធា គឺទាយកប្រគេនហើយ ដើម្បីប្រយោជន៍ ដល់ខ្លួន ហើយឱ្យដល់ពួកគ្រហស្ថ មុននុ៎ះឯង ឈ្មោះថា អនាមដ្ឋបិណ្ឌបាត,

វៀរស្រឡះហើយ នូវអនាមដ្ឋបិណ្ឌបាតទាននោះ, អធិប្បាយថា 'ខ្ញុំនឯងវៀរស្រឡះ ព្រោះជាអ្នកប្រាថ្នាក្នុងសិក្ខាហើយ ទើបបានថ្វាយព្រះក្រយាស្ងោយ ដល់ព្រះរាជា' ។

(២៧៨) ចំណែកឯព្រះរាជា ទ្រង់គង់ប្រមូលយកព្រះកម្លាំង ក្នុងទីនោះៗ ក្នុងមលយប្រទេស ទ្រង់បានហើយនូវអមាត្យ ៨ នាក់ មានកវិសីសអមាត្យ និងខត្តិយអមាត្យជាដើម ដែលគេសន្មតថាជានាយទាហានជាន់ខ្ពស់ ។ ក្រោយមក ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះពិរោធ ចំពោះកវិសីសអមាត្យ ទើបទ្រង់ត្រាស់បញ្ជាឲ្យប្រហារជីវិតកវិសីសអមាត្យនោះចោល ។

លំដាប់នោះ ពួកអមាត្យដទៃទៀត ៧ នាក់ បានក្រោធខឹងចំពោះព្រះរាជា ថា "ព្រះរាជានេះ ទ្រង់ជាអ្នកប្រទូសរ៉ាយមិត្រ" ហើយបោះបង់ព្រះរាជានោះ ចៀសចេញទៅ តាមសេចក្តីពេញចិត្ត ត្រូវពួកចោរដណ្តើមយកសំពត់ (ខោនិងអាវ) ក្នុងចន្លោះផ្លូវ ទើបស្លៀកពាក់មែកឈើហើយ ក៏បានចូលទៅកាន់វិហារ ឈ្មោះ ហាម្ពកល្លកៈ ។ ព្រះតិស្សត្ថេរ ជាអ្នកទ្រទ្រង់និកាយ ៤ មួយរូប ក្នុងវិហារនោះ ឃើញអមាត្យទាំងនោះហើយ ទើបបាននាំយកសំពត់ និងទឹកអំពៅជាដើម ដែលខ្លួនបានមកហើយ អំពីទីនិមន្ត ក្នុងថ្ងៃនោះ មកឲ្យ ដោយពាក្យថា "ម្នាលឧបាសកទាំងឡាយ កាលបើ

សេចក្តីស្និទ្ធស្នាល ក្នុងព្រះភិក្ខុសង្ឃមាន, ពួកអ្នកទាំងឡាយ ចូរទទួលយកនូវរបស់ទាំងឡាយនេះចុះ" ។ ពួកអមាត្យទាំងនោះ ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ ជាអ្នកស្និទ្ធស្នាល ក្នុងព្រះភិក្ខុសង្ឃ ទាំងមាតានិងបិតា របស់ពួកខ្ញុំព្រះករុណា ក៏ជាឧបាសកឧបាសិកាដែរ" ដូច្នេះហើយ ក៏បានទទួលយករបស់របរទាំងនោះ ។ ព្រះថេរៈ សួរថា "តើពួកអ្នកទាំងឡាយ អញ្ជើញទៅ ក្នុងទីណា ?" ។ ពួកអមាត្យទាំងនោះ បានប្រាប់រឿងរ៉ាវទាំងអស់ហើយ ។ ព្រះថេរៈនោះ បានសួរថា "ព្រះរាជាអង្គនោះ គឺពួកអ្នកទាំងឡាយ បានឧបត្ថម្ភហើយ តើអាច ដើម្បីធ្វើការលើកស្ទួយព្រះសាសនាបាន ឬក៏ មិនបាន ?" ។ ពួកអមាត្យទាំងនោះ ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កិរិយាធ្វើការលើកស្ទួយព្រះសាសនា ក្នុងទីបនេះ របស់ព្រះរាជា ចូរស្តេះទុកមួយអន្លើសិនចុះ, សូម្បីក្នុងជម្ពូទ្វី ក៏ព្រះអង្គទ្រង់ធ្វើបាន ដោយពិតណាស់" ។ ព្រះថេរៈ បានស្តាប់ពាក្យនោះហើយ ទើបគិតថា "ព្រះបាទបិគុរាជ ត្រូវបានពួក នាយទាហានជាន់ខ្ពស់ ដែលមិនមែនជាសឹកសត្រូវ ចំពោះព្រះសាសនា ទាំងនេះឯង ជួយឧបត្ថម្ភហើយ ទ្រង់បានបក្សពួកហើយ នឹងទ្រង់អាច ដើម្បីនឹងលើកតម្កើងព្រះសាសនាបាន, បានពួកជនដទៃឧបត្ថម្ភហើយ នឹង

ទ្រង់មិនអាច ដើម្បីនឹងលើកស្ទួយព្រះសាសនាបានទេ, ព្រោះហេតុនោះ អាត្មាអញ នឹងញ្ជាំងព្រះរាជា ឲ្យទ្រង់អត់ទោស ដល់ពួកអមាត្យទាំងនេះ" ដូច្នេះហើយ ក៏បាននាំពួកអមាត្យទាំងនោះ ទៅកាន់ព្រះដំណាក់នៃព្រះរាជា ព្រមជាមួយព្រះកុធិក្កលមហាតិស្សត្ថេរ ដែលបាននិមន្តមក ក្នុងវិហារនោះ ។ ព្រះថេរៈទាំង ២ អង្គនោះ បានញ្ជាំងព្រះរាជា និង ពួកអមាត្យទាំងនោះ ឲ្យអត់ទោស ដល់គ្នានឹងគ្នាហើយ ទើបបាននិមន្តទៅកាន់ទីស្ថានដូចដើម ។ ចំណែកព្រះរាជា ទ្រង់ស្តេចគង់នៅ ក្នុងមលយប្រទេស អស់ ១៤ ឆ្នាំ ៧ ខែ ហើយ មានពួកអមាត្យទាំងនោះ ចោមរោម ស្តេចយាងមកអំពីមលយប្រទេសនោះ ទ្រង់បានធ្វើគត់ ព្រះបាទទាធិយៈទមិឡ ដែលកំពុងគ្រប់គ្រងរាជសម្បត្តិ ខាងក្រោយទមិឡទាំងអស់ហើយ ទ្រង់បានជាព្រះរាជា ម្តងទៀត ទើបទ្រង់បានត្រាស់បញ្ជាឲ្យសាងអភយគិរីវិហារឡើងហើយ ។ ដូច្នោះ អ្នកប្រាជ្ញគម្បីជ្រាបថា "ព្រះរាជាព្រះនាមវដ្តគាមណីអភ័យ ទ្រង់កសាងអភយគិរីវិហារ ក្នុងទីបំជុតនៃ ៤៤៣ ឆ្នាំ និង ១ ខែ រាប់តាំងអំពីព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះបរិនិព្វានមក ខាងក្រោយ អំពីព្រះមហាវិហារ ដែលព្រះបាទទេវានម្បិយតិស្សៈ ទ្រង់បានកសាងឡើងហើយ ក្នុងឆ្នាំខាងដើម" ។ ព្រះរាជាអង្គនោះ ទ្រង់បានឲ្យកសាងព្រះវិហារនោះ

ស្រេចហើយ ទ្រង់អារាធនានិមន្តព្រះកុធិក្តលមហាតិស្សត្ថេរ ដែលថ្វាយព្រះក្រយាស្ងោយ ដល់ព្រះអង្គ ក្នុងកាលមុន មកហើយ ទើបទ្រង់វេរប្រគេនព្រះវិហារនោះ ដល់ព្រះកុធិក្តលមហាតិស្សត្ថេរនោះ ហើយ ទ្រង់នឹករលឹក នូវឧបការគុណដែលព្រះថេរៈលោកបានធ្វើ ហើយ ក្នុងកាលមុន ទើបទ្រង់បានទំនុកបំរុង ដោយគោរព ។

រឿងព្រះបាទបិតុរាជ ចប់ ។

(រឿងអមាត្យរបស់ព្រះបាទបិតុរាជ)

(២៧៩) ពួកអមាត្យទាំង ៧ នាក់នោះឯង បានឱ្យគេសាង ហើយនូវព្រះវិហារ ៥ ខ្នង ។ មែនពិត បណ្តាអមាត្យទាំងនោះ អមាត្យឈ្មោះថា ឧត្តិយៈ បានឱ្យគេសាងវិហារ ឈ្មោះ ទក្ខិណៈ ក្នុងទិសទក្សិណ អំពីក្រុងអនុរាធបុរី ។ អមាត្យឈ្មោះ ចូឡៈ បានឱ្យគេសាងវិហារ ឈ្មោះ ចូឡៈ ក្នុងទិសខាងកើត អំពីទក្សិណ-វិហារ ។ អមាត្យ ឈ្មោះ សាលិយៈ បានឱ្យគេសាងវិហារ ឈ្មោះ សាលិយៈ ។ អមាត្យ ឈ្មោះ បព្វតៈ បានឱ្យគេសាងវិហារ ឈ្មោះ បព្វតៈ ។ អមាត្យ ឈ្មោះ តិស្សៈ បានឱ្យគេសាងវិហារ ឈ្មោះ ឧត្តរតិស្សៈ ។ អមាត្យទាំងនោះ បានឱ្យគេសាងវិហារទាំងអស់ រួចស្រេចហើយ ទើបអារាធនានិមន្តព្រះមហាកល្លកមហាតិស្សត្ថេរ

ដែលធ្លាប់ធ្វើឧបការគុណ ដល់ខ្លួន មកហើយ ក៏បានវេរប្រគេនព្រះវិហារទាំងនោះ ដល់ព្រះថេរៈនោះហើយ ។ ដោយហេតុនោះ ទើបព្រះមហានាមស្ថេរ ពោលពាក្យជាគាថា ក្នុងគម្ពីរមហាវង្ស ថា

> " ក៏អមាត្យទាំងឡាយនោះ ពោលថា ' ដោយអំណាចនៃបដិសណ្ឋារៈ របស់ព្រះគុណម្ចាស់ទាំងឡាយ ពួកខ្ញុំព្រះករុណា ទើបសូមថ្វាយព្រះវិហារទាំងឡាយ ដែលពួកខ្ញុំព្រះករុណា បានឲ្យកសាងហើយ ដល់ព្រះគុណម្ចាស់ទាំងឡាយ ' ដូច្នេះហើយ ក៏បានវេរប្រគេនហើយ, ព្រះថេរៈបានឲ្យភិក្ខុទាំងឡាយនោះ ។ នៅក្នុងព្រះវិហារទាំងពួង តាមសមគួរហើយ, ពួកអមាត្យទាំងឡាយ បានថ្វាយហើយនូវគ្រឿងបរិក្ខារផ្សេង ។ ដែលសមគួរដល់សមណៈ ដល់ព្រះសង្ឃ " ។

បណ្តាបទទាំងនោះ បទថា " បដិសណ្ឋារវសេន " មានសេចក្តីថា ក៏អមាត្យទាំងនោះ ពោលថា ' បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមប្រគេនព្រះវិហារទាំងឡាយ ដែលពួកខ្ញុំព្រះករុណា បានឲ្យគេកសាងរួចស្រេចហើយ ដល់ព្រះ

គុណម្ចាស់ទាំងឡាយ ដោយអំណាចនៃបដិសណ្ឋារៈ ដែលព្រះគុណម្ចាស់ទាំងឡាយ បានធ្វើហើយ ដល់ខ្ញុំព្រះករុណាទាំងឡាយ ជាអ្នកមិនមានទីពឹង ក្នុងកាលមុន ។ បទថា "**សព្ពត្ថ**" មានសេចក្តីថា ព្រះថេរៈ បានឱ្យពួកភិក្ខុអ្នកមាននិកាយ ៥ នោះ ។ នៅក្នុងព្រះវិហារទាំងឡាយ តាមសមគួរ ។ បទថា "**សមណារហោ**" មានសេចក្តីថា ពួកអមាត្យទាំងឡាយ បានប្រគេននូវបច្ច័យ ៤ មានចីវរជាដើម ដែលសមគួរ គឺដែលជាកប្បិយៈ ដល់សមណៈទាំងឡាយ ដល់ព្រះសង្ឃហើយ ដូច្នេះឯង ។

រឿងអមាត្យរបស់ព្រះបាទបិតុរាជ ចប់ ។

(រឿងព្រះបាទចោរនាគ)

(២៨០) ក៏ព្រះបាទបិតុរាជ ទ្រង់ស្ថិតនៅក្នុងរាជសម្បត្តិ ម្តងទៀតហើយ ទ្រង់បានចំពេញបុណ្យជាច្រើន និង ទ្រង់ត្រាស់បញ្ជាឱ្យសរសេរព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ទុកក្នុងស្លឹករឹត ទ្រង់ស្ថិតនៅ រហូតព្រះជន្មាយុហើយ ទើបស្តេចសោយទិវង្គតទៅ ។ កាលបើព្រះអង្គ ទ្រង់ស្តេចទិវង្គតទៅហើយ, ពួកអមាត្យ ក៏បានអភិសេក នូវព្រះបាទមហាចូឡិកៈ ដែលជាព្រះរាជនត្តា របស់ព្រះអង្គ ក្នុងរាជសម្បត្តិ ។

គ្រានោះ ព្រះរាជាព្រះនាមមហានាគ ដែលជាព្រះរាជបុត្រ របស់ព្រះអង្គ ទ្រង់ព្រះពិរោធហើយ កាលទ្រង់ធ្វើចោរកម្ម ព្រោះ ហេតុតែរាជសម្បត្តិ ទ្រង់បានគង់នៅ ក្នុងទីនោះ ៗ ក្នុងជនបទ, ព្រះអង្គ ទ្រង់បានទីជាទីគង់នៅ ក្នុងព្រះវិហារណា ៗ ទ្រង់សព្វព្រះ ទ័យហើយ ៗ ចំណែក ក្នុងវិហារណា ៗ ពួកភិក្ខុទាំងឡាយ មិនបានថ្វាយ ទីជាទីគង់នៅដល់ព្រះអង្គ, ព្រះអង្គ ទ្រង់ព្រះពិរោធ ហើយ ចងពៀរ ក្រោយមក ទ្រង់បានគ្រងរាជសម្បត្តិហើយ ទើប ទ្រង់ត្រាស់បញ្ជា ឲ្យគេរើរុះវិហារទាំងឡាយនោះ ៗ ចោលទាំង អស់ហើយ ៗ ដោយហេតុនោះ ព្រះមហានាមត្ថេរ ទើបពោល ពាក្យជាគាថា ទុកក្នុងបរិច្ឆេទទី ៣៥ នៃគម្ពីរមហាវង្ស ថា ÷

"ក្នុងកាលនោះ ព្រះឱរស របស់ព្រះរាជាទ្រង់ ព្រះនាមវដ្តគាមណីអភ័យ ទ្រង់បានប្រព្រឹត្តជា ចោរ ក្នុងរជ្ជកាល នៃព្រះបាទមហាចូឡិក: ទ្រង់ ប្រាកដព្រះនាមថា 'ព្រះបាទចោរនាគ' កាលបើ ព្រះបាទមហាចូឡិក: ទ្រង់បានលះបង់រាជសម្បត្តិ ហើយ, ទើបព្រះអង្គស្តេចយាងមកគ្រប់គ្រងនូវ រាជសម្បត្តិ, ព្រះអង្គជាក្សត្រ មានព្រះបញ្ញា

លង់ខ្លៅ ព្រះអង្គមិនបាននូវទីគង់នៅ ក្នុងវិហារ ទាំងឡាយណា ក្នុងពេលដែលព្រះអង្គជាចោរ ព្រះអង្គ ទ្រង់បានត្រាស់បញ្ជា ឲ្យគេរុះរើនូវ វិហារទាំងឡាយនោះ ១៨ កន្លែង" ។

បណ្តាបទទាំងនោះ បទថា "**អាគតោ**" គឺ ស្តេចយាងមក អំពីជនបទ កាន់អនុរាធបុរី ។ បទថា "**យេសុ**" គឺ ក្នុងវិហារ ទាំងឡាយណា ។ ព្រះបាទចោរនាគនោះ ជាព្រះរាជាលាមក អាក្រក់ ត្រូវព្រះទេវី របស់ព្រះអង្គ ឲ្យសោយថ្នាំពិស ទ្រង់ទិវង្គត ហើយ ក៏បានទៅកើត ក្នុងលោកន្តរិកនរក ដោយប្រការដូច្នេះ ។

រឿងព្រះបាទចោរនាគ ចប់ ។

ពណ៌នាអំពីការធ្វើបដិសណ្ឋារៈ ចប់ ។

(ការមិនធ្វើបដិសណ្ឋារៈជាអពមង្គល)

(២៨១)_ ម្យ៉ាងទៀត ធម្មតាគ្រហស្ថ គប្បីជាអ្នកមាន សេចក្តីគោរព ក្នុងព្រះពុទ្ធជាដើម ដូចជាពួកជនដែលរស់នៅ ក្នុង និគម ឈ្មោះអស្សបុរៈ ក្នុងជនបទ ដូច្នោះឯង ។

នៃយដែលមក ក្នុងអដ្ឋកថានៃមហាអស្សបុរសូត្រនោះ ថា ÷

" បានឮមកថា មនុស្សទាំងឡាយ ក្នុងនិគមនោះ ជាអ្នកមានសទ្ធា ជ្រះថ្លាហើយ ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ឃើញ សូម្បីនូវសាមណេរ ដែលបានបួសហើយ ក្នុងថ្ងៃនោះ ក៏ធ្វើឱ្យដូចជា ព្រះថេរៈដែលមានវស្សាជាង់ទៅ ១០០, បានឃើញនូវភិក្ខុសង្ឃ ដែលនិមន្តចូលទៅបិណ្ឌបាត ក្នុងបុព្វណ្ហសម័យហើយ កំពុងតែ កាន់នូវគ្រឿងឧបករណ៍ មានពូជស្រូវនិងនង្គ័លជាដើម ដើរទៅ កាន់ស្រែក្តី កំពុងកាន់នូវគ្រឿងសស្ត្រាមានកាំបិតព្រាជាដើម ដើរ ចូលទៅកាន់ព្រៃក្តី ក៏បានទម្លាក់គ្រឿងឧបករណ៍ទាំងនោះចោល ហើយ នាំគ្នាបោសសំអាត នូវទីសម្រាប់គង់ សាលាឆាន់ មណ្ឌប ឬគល់ឈើ ក្រាលនូវអាសនៈទាំងឡាយ ចាត់តាំងជើងបាត្រ និង ទឹកសម្រាប់ឆាន់ ទុកស្រេចហើយ ដើម្បីព្រះភិក្ខុសង្ឃ បាននិមន្ត ភិក្ខុសង្ឃ ឱ្យគង់ហើយ ក៏ប្រគេននូវយាគូនិងគ្រឿងចង្ហាន់ជាដើម បានជូនដំណើរភិក្ខុសង្ឃ ដែលលោកបានធ្វើភត្តកិច្ចស្រេចហើយ បន្ទាប់អំពីនោះ ទើបបានកាន់យកឧបករណ៍ទាំងឡាយនោះ ទៅ កាន់ស្រែ ឬព្រៃ ហើយធ្វើការងារ របស់ខ្លួន ។ ។ សូម្បីក្នុង ទីធ្វើការងារ ឈ្មោះថាការសន្ទនាព្រាស្រ័យគ្នាជាទៃ មិនមានដល់ ជនទាំងឡាយនោះឡើយ ។ ពួកជនទាំងឡាយនោះ តែងពោល សរសើរនូវគុណ របស់ព្រះភិក្ខុសង្ឃតែប៉ុណ្ណោះ ថា ' បុគ្គលទាំង

ឡាយ ៨ ពួក គឺ លោកអ្នកដែលតាំងនៅ ក្នុងមគ្គ ៤ លោកអ្នក ដែលតាំងនៅ ក្នុងផល ៤ ឈ្មោះថា ព្រះអរិយសង្ឃ, បុគ្គលទាំង ៨ ពួកនោះ ជាអ្នកប្រកបព្រម ដោយសីល យ៉ាងដូច្នេះ ដោយការប្រព្រឹត្តិ យ៉ាងដូច្នេះ ដោយការប្រតិបត្តិ យ៉ាងដូច្នេះ ជាអ្នក មានសេចក្តីអៀនខ្មាស មានសីលជាទីស្រឡាញ់ មានគុណដ៏ល្អ ប្រសើរ ដូច្នេះ ។ ពួកជនអ្នកនៅ ក្នុងអស្សបុរនិគមទាំងនោះ មកអំពីធ្វើការងារ ទទួលទានអាហារល្ងាចស្រេចហើយ អង្គុយ នៅត្រង់មាត់ទ្វារផ្ទះក្តី ចូលទៅកាន់បន្ទប់ដេកហើយ អង្គុយក្តី រមែងពោលសរសើរ នូវគុណរបស់ព្រះភិក្ខុសង្ឃ តែម្យ៉ាង ។

ព្រះមានព្រះភាគ ទ្រង់ទតព្រះនេត្រឃើញនូវការនមស្សការ គោរព នៃពួកមនុស្សទាំងឡាយនោះហើយ កាលទ្រង់អាស្រ័យនូវ និគមនោះ ស្តេចគង់នៅ ទើបទ្រង់សំដែង នូវមហាអស្សបុរសូត្រ ក្នុងចតុត្ថវគ្គ នៃមូលបណ្ណាសកៈ" ។

(២៨២) ដីកាមហាអស្សបុរសូត្រនោះ ថា "ក្នុងពាក្យថា **'ឯវរូបេន សីលេន'** ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ព្រះអដ្ឋកថាចារ្យ ពោល វារិតសីល (សីលដែលព្រះពុទ្ធទ្រង់ហាម ដែលជាព្រះពុទ្ធអាជ្ញា) ដោយ **សីល** សព្ទ ។ សំដែងសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ដោយ **សីល** សព្ទនោះ ។

សំដែងចារិត្តសីល (សីលគឺជាចរិយា ដែលគប្បីប្រព្រឹត្ត) ដោយ **អាចារៈ** សព្ទ ។ សំដែងកាយសមាចារ និង វចីសមាចារ ដែលបរិសុទ្ធល្អ ដោយ **អាចារៈ** សព្ទនោះ ។ សំដែងសម្មាបដិបត្តិ ដែលសង្គ្រោះ ដោយសមថៈ វិបស្សនា មគ្គ និង ផល ដោយ **បដិបត្តិ** សព្ទ ។ ដោយបទថា '**លជ្ជិនោ**' នេះ ព្រះអដ្ឋកថាចារ្យ សំដែងនូវហេតុដែលជាឫសគល់នៃសីល និង អាចារៈ ដូចបានពោលមកហើយ ។ ដោយបទថា '**បេសលា**' នេះ ព្រះអដ្ឋកថាចារ្យ សំដែងសេចក្តីបរិសុទ្ធិ ។ ដោយបទថា '**ឧឡារគុណា**' នេះ ព្រះអដ្ឋកថាចារ្យ សំដែងសេចក្តីបរិបូណ៌នៃការប្រតិបត្តិ ។ ព្រះអដ្ឋកថាចារ្យ សំដែងពាក្យនេះថា '**ភិក្ខុសង្ឃស្សេវ វណ្ណំ កថេន្តិ**' ព្រោះភាវៈនៃឧបាសក ឧបាសិកាទាំងនោះ ជាអ្នកខ្វល់ខ្វាយ ក្នុងកិត្តិគុណ របស់ភិក្ខុទាំងឡាយ ដោយច្រើន ។ ក៏ជនទាំងឡាយនោះ ជាអ្នកជ្រះថ្លាយ៉ាងក្រៃលែង ទាំងក្នុងព្រះសទ្ធម្ម ទាំងក្នុងព្រះសម្មាសម្ពុទ្ធ ដោយពិត ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**ពុទ្ធមាមកា ធម្មមាមកា សង្ឃមាមកា**' ដូច្នេះ ។ មែនពិត ក្នុងវត្តទាំងបី ជនទាំងឡាយ ជ្រះថ្លាក្រៃលែងហើយ ក្នុងវត្ត ១ ឈ្មោះថា ជ្រះថ្លាក្រៃលែងហើយ ក្នុងវត្តទាំង ២ ដទៃទៀតដែរ ព្រោះភាវៈនៃវត្តទាំងបីនោះ ឥតមានការបែកចេញពីគ្នាបាន" ។

(២៨៣) ចំណែកបព្វជិត ក៏គប្បីជាអ្នកមានសេចក្តីគោរពដល់គ្នានឹងគ្នា ដូចសត្វទាំងបី ដែលជាសំឡាញ់នឹងគ្នា យ៉ាងដូច្នោះ ។

(រឿងសត្វទាំងបី ចេះគោរពគ្នា)

បានឮថា ក្នុងអតីតកាល សត្វទាំងឡាយ ៣ ជាសំឡាញ់គ្នា គឺ សត្វទទា ១ សត្វស្វា ១ សត្វជំរី ១ អាស្រ័យនូវដើមជ្រៃដ៏ធំមួយដើម រស់នៅ ក្នុងហិមវន្តប្រទេស ។ ជាដំបូង សត្វទាំង ៣ នោះ រស់នៅមិនគោរព ដល់គ្នានឹងគ្នាទេ ព្រោះមិនដឹងថា "អ្នកនេះជាអ្នកចាស់ជាង" ។ ថ្ងៃមួយ សត្វទាំងនោះ គិតគ្នាថា "ការដែលពួកយើង រស់នៅ ដោយអាការៈយ៉ាងនេះ មិនសមគួរឡើយ, បើដូច្នោះ មានតែពួកយើងទាំងឡាយ, បុគ្គលណាមួយជាអ្នកដែលចាស់ជាងពួកយើង, គប្បីធ្វើនូវគារវកិច្ចទាំងឡាយមានការក្រាបថ្វាយបង្គំជាដើម ដល់បុគ្គលនោះ តាំងនៅ ក្នុងឱវាទនៃបុគ្គលនោះចុះ" ដូច្នេះហើយ ទើបបានសួរគ្នានឹងគ្នាថា "ម្នាលសំឡាញ់ទាំងឡាយ ពួកអ្នកទាំងឡាយ ស្គាល់នូវដើមជ្រៃនេះ ចាប់តាំងអំពីដើមជ្រៃនេះ មានទំហំប៉ុនណាមក ? " ។

លំដាប់នោះ សត្វជំរី ពោលថា "ម្នាលសំឡាញ់ទាំងឡាយ ក្នុងកាលដែលខ្ញុំនៅជាកូនជំរីតូចៗ ខ្ញុំដើរទៅ ប៉ះគុម្ពជ្រៃនេះ នៅត្រង់ចន្លោះនៃភ្លៅទាំង ២ និង ក្នុងពេលដែលខ្ញុំធំឡើងហើយ

មែកបណ្តូល នៃដើមជ្រៃនេះ តែងកកិតនូវផ្ទៃតរបស់ខ្ញុំ, ដូច្នេះ ខ្ញុំស្គាល់នូវដើមជ្រៃនេះ តាំងពីពេលដែលខ្ញុំនៅជាក្មេងតូចៗមក"។

សត្វស្វា ពោលថា "ម្នាលសំឡាញ់ទាំងឡាយ ខ្ញុំកាលនៅជាកូនស្វាបៅដោះនៅឡើយ អង្គុយលើផែនដី មិនចាំបាច់ងើយកឡើយ ខាំស៊ីបណ្តូល (ត្រួយខ្ចី) នៃដើមជ្រៃនេះបាន, ដូច្នេះ ខ្ញុំស្គាល់នូវដើមជ្រៃនេះ តាំងពីពេលដែលខ្ញុំនៅពីក្មេងតូចៗមក"។

លំដាប់នោះ សត្វទទា ពោលថា "ម្នាលសំឡាញ់ទាំងឡាយ ក្នុងកាលមុន ដើមជ្រៃធំនេះ មាននៅក្នុងទីឯណោះ, ខ្ញុំស៊ីផ្លែនៃដើមជ្រៃធំនោះហើយ បានជុះអាចម៍ ក្នុងទីនេះ, ដើមជ្រៃធំនេះ កើតហើយ អំពីអាចម៍ របស់ខ្ញុំនោះ, ដូច្នេះ ខ្ញុំស្គាល់ដើមជ្រៃធំនេះ តាំងអំពីពេលដែលដើមជ្រៃនេះកើតហើយ, ព្រោះហេតុនោះ ខ្ញុំជាអ្នកចាស់ជាង ពួកអ្នកទាំងឡាយ"។

ចាប់តាំងពីពេលនោះមក សត្វស្វា និងសត្វជំរីទាំង ២ នោះ ក៏ប្រព្រឹត្តឱនលំទោនសត្វទទានោះ ដោយការធ្វើសក្ការៈ គោរព និងកិរិយាថ្វាយបង្គំជាដើម បានស្ថិតនៅហើយ ក្នុងឱវាទ របស់សត្វទទានោះ។ ឯសត្វទទានោះ ក៏បានឱ្យសត្វទាំង ២ នោះ តាំងនៅ ក្នុងសីល ៥ សូម្បីខ្លួនឯង ក៏សមាទានហើយនូវសីល ៥។ សត្វទាំង ៣ នោះ តាំងនៅហើយ ក្នុងបញ្ចសីល មានសេចក្តីគោរព

កោតក្រែងដល់គ្នាទៅវិញទៅមក ក្នុងពេលអស់អាយុ ក៏បានទៅកើតក្នុងទេវលោក ។ រីឯដែលសត្វជាសំឡាញ់នឹងគ្នាទាំង ៣ នោះ បានសមាទានហើយ បានឈ្មោះថា ជាតិត្តិរព្រហ្មចរិយៈ ។

ចំណែកព្រះសាស្តា លុះទ្រង់នាំអតីតនិទានមក (សំដែង) យ៉ាងនេះហើយ កាលទ្រង់ឱវាទនូវភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏ឈ្មោះថា សត្វទាំងឡាយនោះ គ្រាន់តែជាសត្វតិរច្ឆាន រស់នៅមានសេចក្តីគោរព កោតក្រែងដល់គ្នានឹងគ្នា, ចំណែកអ្នកទាំងឡាយ បួសហើយ ក្នុងព្រះធម្មវិនัย ដែលតថាគតសំដែងល្អហើយ យ៉ាងនេះ ព្រោះហេតុអ្វី ទើបរស់នៅ មិនមានសេចក្តីគោរព កោតក្រែងដល់គ្នាទៅវិញទៅមក ?" ដូច្នេះហើយ កាលទ្រង់សំដែងធម៌ ទើបទ្រង់បានត្រាស់នូវព្រះគាថានេះ ក្នុងតិត្តិរជាតក ក្នុងចតុត្ថវគ្គ នៃឯកនិបាត[1] ថា ÷

(២៨៤) "ពួកជនណា ជាអ្នកឈ្លាស ក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចំរើនហើយ, ពួកជននោះ អ្នកផងគប្បីសរសើរ ក្នុងបច្ចុប្បន្នផង, សម្បរលោក របស់ពួកជននោះ ក៏ជាសុគតិផង" ។

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៧

បណ្តាបទទាំងនោះ ក្នុងបទថា "**វុឌ្ឍិំ**" នេះ បានដល់បុគ្គលអ្នកចំរើនទាំងឡាយ ៣ គឺ ជាតិវុឌ្ឍ វយវុឌ្ឍ គុណវុឌ្ឍ ។ បណ្តាវុឌ្ឍបុគ្គលទាំង ៣ ពួកនោះ បុគ្គលអ្នកដល់ព្រមហើយ ដោយជាតិ ឈ្មោះថា **ជាតិវុឌ្ឍ** ។ បុគ្គលអ្នកតាំងនៅហើយ ក្នុងវ័យ ឈ្មោះថា **វយវុឌ្ឍ** ។ បុគ្គលអ្នកដល់ព្រមហើយ ដោយគុណ ឈ្មោះថា **គុណវុឌ្ឍ** ។ បណ្តាវុឌ្ឍបុគ្គលទាំង ៣ ពួកនោះ បុគ្គលអ្នកចំរើនដោយវ័យ បរិបូណ៌ហើយដោយគុណ ព្រះមានព្រះភាគ ទ្រង់ព្រះបំណង ថា "វុឌ្ឍៈ" ក្នុងបទថា "**វុឌ្ឍិំ**" នេះ ។ បទថា "**អបចាយន្តិ**" គឺ រមែងបូជា ដោយកម្ម គឺការប្រព្រឹត្តិកោតក្រែងចំពោះអ្នកដែលចំរើន ។ ២ បទថា "**ធម្មស្ស កោវិទោ**" បានដល់ ជាអ្នកឆ្លាតវាងវៃ ក្នុងជេដ្ឋាបចាយនធម៌ ។ ២ បទថា "**ទិដ្ឋេ ធម្មេ ច**" បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា "**បាសំសា**" គឺ គួរដល់ការសរសើរ ។ បាទគាថាថា "**សម្បរាយោ ច សុគ្គតិ**" មានសេចក្តីថា ភព ឈ្មោះថា សម្បរាយៈ ព្រោះអត្ថថា 'សត្វទាំងឡាយ គប្បីដល់ព្រមព្ធដ៏ខាងមុខ គឺលះលោកនេះទៅហើយ គប្បីដល់' បានដល់ បរលោក អធិប្បាយថា 'បរលោក របស់ពួកជននោះ រមែងជាសុគតិពិត' ។

ក៏ក្នុងគាថានេះ ប្រមូលយកសេចក្តី មានដូចតទៅនេះ ថា

"ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយឯណាមួយ ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកចោកទាបក្តី គ្រហស្ថក្តី បព្វជិតក្តី សត្វតិរច្ឆានក្តី ជាអ្នកឈ្លាសវាងវៃ គឺឆ្លាត ក្នុងជេដ្ឋាបចាយនធម៌ រមែងធ្វើសេចក្តីគោរពកោតក្រែង ចំពោះបុគ្គលអ្នកចំរើនដោយវ័យទាំងឡាយ ដែលដល់ព្រមដោយគុណ, សត្វទាំងឡាយនោះ រមែងបាននូវសេចក្តីសរសើរ គឺកោតសរសើរ និងការស្ងើចសរសើរ ថា 'ជាអ្នកប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលអ្នកដែលចំរើនបំផុត" ដូច្នេះ ក្នុងអត្តភាពនេះ និងព្រោះការបែកធ្លាយទៅនៃរាងកាយ រមែងទៅកើត ក្នុងឋានសួគ៌" ។

រឿងសត្វដែលជាសំឡាញ់នឹងគ្នា ចប់ ។

ការពណ៌នាអំពីបទថា សេចក្តីគោរព ចប់ ។

ប្រែចប់ថ្ងៃសៅរ៍ ១២ រោច ខែទុតិយាសាធ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃ ទី ១៤ សីហា ១៩៩៣
វេលាយប់

ពណ៌នាអំពីការប្រព្រឹត្តិបន្ទាបខ្លួន

(២៨៥) ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាថា "ភាពជាអ្នកមានចិត្តឱនលំទោន គឺ ភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឈ្មោះថា **និវាតៈ**។ បុគ្គលអ្នកប្រកបព្រមហើយ ដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួនឯណា មានមានះដាក់ចុះហើយ ជាអ្នកមានសេចក្តីរឹងត្អឹងដាក់ចុះហើយ ជាអ្នកប្រាកដស្មើដោយកំណាត់សំពត់សម្រាប់ជូតជើង ជាអ្នកស្មើដោយគោឧសភដែលមានស្នែងបាក់ហើយ និងជាអ្នកស្មើដោយពស់មានពិសដែលត្រូវគេដកយកចង្កឹមចេញហើយ ជាអ្នកមានវាចាដ៏ទន់ភ្លន់ មានវាចានាំមកនូវភាវៈនៃបុគ្គលជាទីស្រឡាញ់ មានវាចាពោលនាំមកនូវសេចក្តីសុខ, នេះ ឈ្មោះថា **និវាតៈ** (សេចក្តីប្រព្រឹត្តបន្ទាបខ្លួន)" ។

(២៨៦) ចំណែកក្នុងអដ្ឋកថាបញ្ចកនិបាត អង្គុត្តរនិកាយ លោកពោលថា "(ព្រះអរិយសាវ័កទាំងឡាយ រមែងសេពគប់) នូវបុគ្គលអ្នកប្រព្រឹត្តបន្ទាបខ្លួន" ។

ជីកាបញ្ចកនិបាត អង្គុត្តរនិកាយនោះ ថា "នូវបុគ្គលអ្នកមានសេចក្តីឱនលំទោន ជាប្រក្រតី" ។

អដ្ឋកថាកុលទូសកសិក្ខាបទ ថា "បទថា '**សណ្ហា**'

មានសេចក្តីថា ដ៏ល្អិត គឺ ឆ្លាតដើម្បីបង្ហោនចូលទៅ កាន់ជនជាឧបាសក ក្នុងឋានៈដ៏សមគួរ យ៉ាងនេះ ថា 'បពិត្រអ្នកម្តាយ លោកឱពុក បងស្រី' ។ បទថា **'សខិលា'** បានដល់ ប្រកបហើយដោយសេចក្តីនឹមនួន ។ ពាក្យថា **'សុខសម្ភាសា'** នេះ ជាពាក្យពោលដល់ហេតុនៃពាក្យខាងដើម ។ មែនពិត វាចារបស់ព្រះអស្សជិនិងព្រះបុនព្វសុកៈទាំងឡាយណា ជាវាចាពោលនាំមកនូវសេចក្តីសុខ ជាវាចានាំមកនូវសេចក្តីរីករាយ ជាវាចាមិនមានទោសពិរោះដល់ត្រចៀក, ព្រះអស្សជិនិងព្រះបុនព្វសុកៈទាំងឡាយនោះ ជនអ្នកនៅក្នុងកិជាគិរីជនបទ ហៅថា 'ជាអ្នកមានវាចានាំមកនូវភាវៈនៃបុគ្គលជាទីស្រឡាញ់' ដូច្នេះ" ។

អដ្ឋកថាទុកនិបាត អង្គុត្តរនិកាយ ថា "ភាវៈនៃបុគ្គលជាអ្នករីករាយសប្បាយ ដោយអំណាចវាចាដ៏ផ្អែមល្ហែម ឈ្មោះថា **សាខល្យំ**" ។

ជីកាទុកនិបាត អង្គុត្តរនិកាយនោះ ថា "បុគ្គលអ្នកមានវាចាផ្អែមល្ហែម លោកហៅថា **សខិលៈ** ។ ភាវៈនៃបុគ្គលអ្នកមានវាចាដ៏ផ្អែមល្ហែមនោះ ឈ្មោះថា **សាខល្យំ** គឺ ភាពជាអ្នកមានវាចាដ៏ផ្អែមល្ហែម ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'សណ្ហវាចាវសេន សម្មោទមានភាវោ'** ដូច្នេះ ។

មែនពិត ឈ្មោះថា ភាវៈនៃបុគ្គលអ្នកវីករាយ ដោយអំណាចវាចាដ៏ទន់ភ្លន់ ឈ្មោះថា ភាវៈនៃបុគ្គលជាអ្នកមានវាចាដ៏ទន់ភ្លន់ ”។

អដ្ឋកថាសង្គីតិសូត្រ ថា “ ភាវៈនៃបុគ្គលជាអ្នកវីករាយ សប្បាយនិងត្រេកអរ ឈ្មោះថា **សាខល្យំ** ”។

ជីកាសង្គីតិសូត្រនោះ ថា “ភាវៈនៃបុគ្គលអ្នកវីករាយ ជាអ្នកត្រេកអរ ឈ្មោះថា **មទ្ទវៈ** គឺ ភាវៈនៃបុគ្គលអ្នកវីករាយ និងត្រេកអរ ”។

បាលីនិក្ខេបកណ្ឌ ថា “ភាវៈជាអ្នកមានវាចាដ៏ទន់ភ្លន់ ភាវៈជាអ្នកមានវាចាជាទីស្រឡាញ់ ភាវៈជាអ្នកមានវាចាមិនអាក្រក់ក្នុងបុគ្គលនោះឯណា, នេះ តថាគតហៅថា **សាខល្យំ** ”។

អដ្ឋកថានិក្ខេបកណ្ឌនោះ ថា “ ២ បទថា ‘ **យា តត្ថ** ’ គឺ ក្នុងបុគ្គលនោះឯណា ។ ភាវៈនៃបុគ្គលជាអ្នកមានវាចាដ៏ល្ងិតម៉ដ្ឋ ឈ្មោះថា **សណ្ហវាចតា** ។ ភាវៈនៃបុគ្គលជាអ្នកមានវាចាដ៏ទន់ភ្លន់ ឈ្មោះថា **សខិលវាចតា** ។ ភាវៈនៃបុគ្គលជាអ្នកមានវាចាមិនរឹងរូស ឈ្មោះថា **អផរុសវាចតា** ”។

(២៨៧) មែនពិត ទោះបីបុគ្គលណា (ក៏ដោយ) កាលឃើញទោសនៃភាពជាអ្នករឹងត្អឹង ដោយអំណាចនៃការប្រកាន់ខ្លួនក្រៃលែង គប្បីជាអ្នកមានការប្រព្រឹត្តិបន្ទាបខ្លួន មិនរឹងត្អឹង ។

ព្រោះថា ភាវៈនៃបុគ្គលជាអ្នកវឹងត្ឹង ជាហេតុនៃសេចក្តីវិនាស ។

ហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា÷

“ នរជនឯណា ជាអ្នកប្រកាន់ដោយជាតិ ប្រកាន់ដោយទ្រព្យ ប្រកាន់ដោយគោត្រ រមែងមើលងាយនូវញាតិរបស់ខ្លួន, កម្មទាំង ៤ យ៉ាង របស់នរជននោះ ជាប្រធាន នៃសេចក្តីវិនាស ” ។

អដ្ឋកថាចរាភវសូត្រនោះ ថា “ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា ញុំាងមានះឱ្យកើតឡើងហើយ ថា ‘ អាត្មាអញ ជាអ្នកបរិបូណ៌ហើយដោយជាតិ ’ ដូច្នេះ ជាអ្នកវឹងរូស ដោយមានះនោះ ជាអ្នកប៉ោងឡើងហើយ ដូចជាស្នប់ដែលពេញ ដោយខ្យល់ មិនឱនលំទោន ដល់អ្នកណាមួយ, បុគ្គលនោះ ឈ្មោះថា ជាអ្នកវឹងរូស ដោយជាតិ ។ ក្នុងបុគ្គលអ្នកវឹងរូស ដោយទ្រព្យ និងដោយគោត្រ ក៏នំយនេះ ដូចគ្នាដែរ ។

២ បទថា ‘ **សញ្ញាតឹ អតិមញ្ញេតិ** ’ មានសេចក្តីថា តែងមើលងាយ សូម្បីនូវញាតិ របស់ខ្លួន ដោយជាតិ ដូចជាពួកស្តេចសាកិយៈ ទ្រង់មើលងាយនូវព្រះរាជកុមារព្រះនាមវិឌូឌភៈ យ៉ាងដូច្នោះឯង, មួយទៀត រមែងមើលងាយ ដោយទ្រព្យផង ថា

'អ្នកនេះ ជាមនុស្សកំព្រា ក្រីក្រ' ដូច្នេះ មិនធ្វើសូម្បីនូវកិច្ចត្រឹមតែសាមីចិកម្ម ។ ពួកញាតិទាំងនោះ រមែងប្រាថ្នានូវសេចក្តីវិនាសតែម្យ៉ាង ដល់បុគ្គលនោះ ។ ដោយព្រះគាថានេះ ព្រះមានព្រះភាគទ្រង់ត្រាស់កម្មទាំង ៤ យ៉ាង ដោយហេតុថា ជាប្រធាននៃសេចក្តីវិនាស តែម្យ៉ាងប៉ុណ្ណោះឯង ដោយលក្ខណៈ" ។

ក៏ក្នុងពាក្យថា "**សក្យា វិយ វិឌូឌភំ**" នេះ មានសេចក្តីថា ដូចជាស្តេចសាកិយៈទាំងឡាយ មើលងាយព្រះរាជកុមារ ទ្រង់ព្រះនាមថា វិឌូឌភៈ ដូច្នោះឯង ។

(រឿងព្រះបាទវិឌូឌភៈសម្លាប់ពួកស្តេចសាកិយៈ)

(២៨៨) បានឮថា ស្តេចសាកិយៈ ទ្រង់ព្រះនាមថា ព្រះមហានាម ជាព្រះជេដ្ឋភាតា របស់ព្រះអនុរុទ្ធ ជាព្រះរាជបុត្រ របស់ចូឡបិតា នៃព្រះសាស្តា ទ្រង់នៅរួមជាមួយនាងទាសី របស់ព្រះអង្គ ឈ្មោះនាងមុណ្ឌា ទ្រង់បានព្រះធីតាព្រះនាមថា ព្រះនាងវាសភខត្តិយា ទ្រង់ថ្វាយព្រះរាជធីតា ដែលមានព្រះជន្ម ១៦ ព្រះវស្សា ដល់ព្រះបាទបសេនទិកោសល ។ ព្រះនាងវាសភខត្តិយានោះ ទ្រង់អាស្រ័យនូវព្រះរាជា ទ្រង់បានហើយនូវព្រះរាជបុត្រ ទ្រង់ព្រះនាមថា វិឌូឌភៈ ។ ព្រះរាជកុមារ ព្រះនាមវិឌូឌភៈ

ក្នុងកាលដែលព្រះអង្គមានព្រះជន្មបាន ១៦ ព្រះវស្សា ទ្រង់មានព្រះបំណងចង់គាល់ព្រះញាតិទាំងឡាយ របស់ព្រះអង្គ ទ្រង់ស្តេចយាងទៅក្រុងកបិលពស្តុ ទ្រង់បានគង់នៅ ក្នុងព្រះនគរនោះ ២-៣ ថ្ងៃហើយ ទើបស្តេចយាងត្រឡប់មកវិញ ។

លំដាប់នោះ នាងទាសីម្នាក់ ត្រូវស្តេចសាកិយៈទាំងឡាយ ត្រាស់បញ្ជាហើយ ទើបបានជេរប្រទេចផ្ទួន ៗ ថា "នេះ ជាបន្ទះក្តារ ដែលកូននាងទាសីអង្គុយ" ដូច្នេះហើយ ទើបយកទឹកដោះសុទ្ធ ទៅលាងបន្ទះក្តារ ដែលព្រះរាជកុមារព្រះនាមវិឌូឌភៈនោះ ទ្រង់បានគង់ហើយ ។

ក្នុងខណៈនោះ រាជបុរស របស់ព្រះបាទវិឌូឌភរាជកុមារ ភ្លេចហើយនូវអាវុធ ទើបត្រឡប់មក ដើម្បីយកអាវុធនោះ បានញ្ជសំឡេងជេរប្រទេចនោះហើយ ទើបសួរ បានដឹងរឿងនោះ អំពីនាងទាសីនោះហើយ ក៏តាមទៅទាន់ហើយ ប្រាប់ដល់ពួកពល ។ សេចក្តីកោលាហលដ៏ធំ បានកើតឡើងហើយ ថា "បានញ្ជថា ព្រះនាងវាសភខត្តិយា ជាធីតារបស់នាងទាសី" ។

ព្រះបាទវិឌូឌភរាជកុមារ ទ្រង់ព្រះសណ្តាប់សំឡេងនោះហើយ ទើបទ្រង់បានចងនូវពៀរទុក ថា "ពួកស្តេចសាកិយៈទាំងនុ៉ះ ចូរលាងបន្ទះក្តារ ដែលអញអង្គុយហើយ ដោយទឹកដោះសុទ្ធ

មុនសិនចុះ, តែអាត្មាអញ ស្ថិតនៅក្នុងរាជសម្បត្តិហើយ នឹងញុំាងបុគ្គលឱ្យលាងនូវបន្ទុះក្តារនោះ ដោយលោហិត ក្នុងចំពង់ក របស់ស្តេចសាកិយៈទាំងនោះ" ដូច្នេះ ក្រោយមក ទ្រង់បានជាព្រះរាជាហើយ ស្តេចយាងទៅក្រុងកបិលព័ស្តុ ដោយពួកពលជាច្រើន ទ្រង់បានត្រាស់បញ្ជា ថា "នែនាយ ស្តេចសាកិយៈទាំងឡាយណាៗ ពោលថា 'យើងទាំងឡាយ ជាស្តេចសាកិយៈ' ដូច្នេះ, អ្នកទាំងឡាយ ចូរសម្លាប់ពួកស្តេចសាកិយៈទាំងអស់នោះៗ ចោល, ប៉ុន្តែពួកជនទាំងឡាយណា ឈរនៅហើយ ក្នុងព្រះដំណាក់ នៃស្តេចព្រះមហានាម ដែលជាព្រះរាជអយ្យកោ, អ្នកទាំងឡាយ ចូរឱ្យនូវជីវិត ដល់ជនទាំងឡាយនោះចុះ" ដូច្នេះហើយ ទ្រង់ត្រាស់បញ្ជាឱ្យសម្លាប់ពួកស្តេចសាកិយៈទាំងអស់ ចាប់ផ្តើមពីពួកទារក ដែលនៅបៅដោះ ហើយឱ្យលាងបន្ទុះក្តារនោះ ដោយលោហិត ក្នុងចំពង់ក នៃស្តេចសាកិយៈទាំងឡាយនោះ ។ ត្រកូលវង្សនៃស្តេចសាកិយៈ បានត្រូវព្រះបាទវិឌូឌភរាជកុមារ បំផ្លាញអស់ហើយ ដោយប្រការដូច្នេះ ។ សាកិយៈទាំងឡាយនោះ បានដល់ហើយនូវសេចក្តីវិនាស ដោយអំណាចភាពជាអ្នកមានមានះរឹងត្អឹង ដោយជាតិ ដោយប្រការដូច្នេះ ។ សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនុ៎ះ មានតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ អ្នកសិក្សាគប្បី

ត្រួតពិនិត្យមើល ក្នុងអដ្ឋកថាបុប្ផវគ្គ នៃធម្មបទ និង ក្នុងអដ្ឋកថា កទ្ទសាលជាតក ក្នុងទ្វាទសនិបាត ។

រឿងស្តេចសាកិយៈ ចប់ ។

(២៨៩) ធម្មតាបុគ្គលអ្នកមានមានះដ៏ក្រៃលែង រមែងញុំាងយស ដែលកើតឡើងហើយ ឲ្យវិនាសបាត់ទៅ តែម្យ៉ាង ។ ក្នុងជំណើរនោះ មានរឿងដូចតទៅនេះ (ជាខុទាហរណ៍) ÷

(រឿងឆ្កែចចកចង់ធ្វើជាស្តេច)

ក្នុងអតីតកាល បុរោហិត របស់ព្រះរាជាក្រុងពារាណសី បានជាអ្នកចេះមន្ត ឈ្មោះថា បឋវីជយៈ ។ មន្តសម្រាប់ចង្អុលចិត្ត លោកហៅថា "បឋវីជយមន្ត" ។

ក្នុងថ្ងៃមួយ បុរោហិតនោះគិត ថា "អាត្មាអញ នឹងទន្ទេញនូវមន្ត" ដូច្នេះ ទើបបានអង្គុយ លើខ្នងនៃថ្ម លើទីទួលមួយ ក្នុងព្រៃ ធ្វើការស្វាធ្យាយហើយ ក៏បានចៀសចេញទៅ ។ ក៏ក្នុងពេលដែលបុរោហិតនោះ ធ្វើការស្វាធ្យាយ ឆ្កែចចកមួយ ដេកនៅក្នុងរូងមួយ បានស្តាប់មន្តនោះហើយ ទើបបានធ្វើឲ្យស្ទាត់ជំនាញ ។ បានឮថា ឆ្កែចចកនោះ ក្នុងអត្តភាពដែលកន្លងទៅហើយ ដោយលំដាប់ បានកើតជាព្រាហ្មណ៍ម្នាក់ ជាអ្នកមានមន្ត ឈ្មោះបឋវីជយ

ដែលខ្លួនបានចាំស្នាក់ជំនាញហើយ ។ ឆ្កែចចកនោះ ចូលទៅកាន់ព្រៃ ស្វាធ្យាយមន្តនោះហើយ បញ្ជាពួកឆ្កែចចកជាច្រើនរយហើយ ធ្វើសត្វជើង ៤ ទាំងឡាយទាំងពួង មានដំរី សេះ សីហៈ ខ្លាធំ ជ្រូក និង ម្រឹគជាដើម (ឲ្យនៅ) ក្នុងអំណាចរបស់ខ្លួន ហើយបានកើតស្តេចឈ្មោះថា សព្វទាឋៈ បានធ្វើឆ្កែចចកញីមួយ ជាអគ្គមហេសី ។ សត្វរាជសីហ៍ ឈរនៅលើខ្នង នៃដំរីទាំងឡាយ ២ ។ ស្តេចឆ្កែចចក ឈ្មោះសព្វទាឋៈ អង្គុយនៅ លើខ្នងរាជសីហ៍ ជាមួយឆ្កែចចកញីដែលជាអគ្គមហេសី ។ ស្តេចឆ្កែចចកនោះ បានជាសត្វមានយសសក្តិ យ៉ាងធំសម្បើមហើយ ។ ស្តេចឆ្កែចចកនោះ ស្រវឹងពេញទំហឹងហើយ ដោយភាពជាសត្វមានយសសក្តិធំ បានញុំាងមានះ ឲ្យកើតឡើងហើយ ថា "អាត្មាអញ នឹងដណ្តើមយកនូវរាជសម្បត្តិ ក្នុងទីក្រុងពារាណសី" ដូច្នេះ មានសត្វជើង ៤ ទាំងអស់ចោមរោម បានទៅហើយ ។ បរិស័ទ បានមានហើយ ១២ យោជន៍ ។ ស្តេចឆ្កែចចកនោះ បានបញ្ជូន ពតិមានទៅថ្វាយដល់ព្រះរាជា ដោយទូត ក្នុងទីដែលមិនឆ្ងាយ អំពីព្រះនគរ មានជាអាទិ៍ថា "ព្រះរាជា ចូរឲ្យរាជសម្បត្តិ ឬក៏ ចូរឲ្យនូវការធ្វើសង្គ្រាម" ដូច្នេះ ។

មនុស្សទាំងឡាយ បានភ័យខ្លាច ស្លុតស្លន់ហើយ ទើបបាន

ចិទហើយនូវទ្វារនៃព្រះនគរ ។ បុរោហិត បានញុំាងព្រះរាជា និងមនុស្សទាំងឡាយទាំងពួង ឲ្យត្រេកអរហើយ ពោលថា “អ្នកទាំងឡាយ ចូរកុំភ័យខ្លាចឡើយ, ការធ្វើសង្គ្រាម ជាមួយនឹងស្តេចឆ្កែចចកនោះ ចូរជាភារកិច្ចរបស់ខ្ញុំ” ហើយឡើងទៅលើប៉ម ក្បែរទ្វារ ពោលថា “នែសព្វទាឋៈ សំឡាញ់ អ្នកនឹងធ្វើឧបាយដូចម្តេច ទើបដណ្តើមយករាជសម្បត្តិនេះបាន ?”។

សិគាលរាជ ពោលថា “ខ្ញុំនឹងញុំាងស្តេចរាជសីហ៍ ឲ្យបន្លឺនូវសីហានាទហើយ ធ្វើឲ្យមនុស្សទាំងឡាយ ដល់នូវការអស់ទៅនៃជីវិតហើយ ទើបដណ្តើមយក”។

បុរោហិតនោះ (ស្តាប់ហើយ) ក៏ចុះអំពីប៉មហើយ ញុំាងបុគ្គលឲ្យរាយស្គរ ត្រាច់ទៅ ប្រកាសថា “ជនទាំងឡាយទាំងពួង ចូរញុ៉ំកនូវរន្ធត្រចៀកទាំងឡាយ ដោយម្សៅសណ្តែក”។ ពួកមនុស្សទាំងឡាយ បានចិទហើយ នូវរន្ធត្រចៀក របស់សត្វជើង ៤ ទាំងឡាយ ដោយទីបំផុតរហូតដល់សត្វឆ្មាទាំងឡាយ និង រន្ធត្រចៀករបស់ខ្លួនៗ ដោយម្សៅសណ្តែក ។

បុរោហិត បានឡើងទៅកាន់ប៉ម ជាថ្មីម្តងទៀតហើយ ពោលថា “នែសព្វទាឋៈ អ្នកឯង នឹងមិនអាចញុំាងរាជសីហ៍ ឲ្យបន្លឺនូវសីហានាទបានឡើយ, ព្រោះថា ស្តេចកេសររាជសីហ៍ ជាសត្វ

ដល់ព្រមហើយដោយជាតិ មានជើងមុខនិងជើងក្រោយមានសម្បុរ ក្រហមល្អ នឹងមិនធ្វើតាមបញ្ជា របស់ឆ្កែចចកកញ្ជាស់ ដូចជាអ្នក ឯងឡើយ, ប្រសិនបើ អ្នកឯងអាច, អ្នកឯង ចូរញ៉ាំងស្តេច រាជសីហ៍ ឱ្យបន្លឺ (សីហនាទ) ចុះ" ។

សិគាលរាជនោះ ជាសត្វរឹងត្អឹងដោយមានះ ពោលឡើងថា "សីហៈទាំងឡាយដទៃ ចូរស្លេះទុកសិនចុះ, ខ្ញុំអង្គុយនៅលើខ្នង របស់សីហៈណា, ខ្ញុំនឹងឱ្យសីហៈនោះឯងបន្លឺ" ដូច្នេះហើយ ក៏បាន ឱ្យសញ្ញា ដោយជើង ។ ស្តេចរាជសីហ៍ ច្របាច់មាត់ ត្រង់ពោង នៃដំរី បន្លឺនូវសីហនាទ ដែលសត្វដទៃឱ្យប្រព្រឹត្តទៅមិនបាន អស់ វារៈ ៣ ដង ។ ដំរីទាំងឡាយ ជាសត្វដល់ហើយនូវសេចក្តីតក់-ស្លុត បានជាន់ក្បាលឆ្កែចចក ដែលធ្លាក់ហើយ ក្បែរជើង ធ្វើឱ្យ ខ្ទេចល្ហែតល្ហន់ ញ៉ាំងឆ្កែចចកនោះ ឱ្យដល់ហើយ នូវការអស់ទៅ នៃ ជីវិត ។ ដំរីទាំងឡាយនោះ ចាក់គ្នាទៅវិញទៅមក បានដួលស្លាប់ ហើយ ។ លើកលែងតែសត្វសីហៈទាំងឡាយចេញ សត្វជើង ៤ ដែលសេសសល់ទាំងអស់ បានស្លាប់ហើយ ក្នុងទីនោះឯង ។ សត្វ សីហៈទាំងឡាយ បានរត់គេចចូលព្រៃអស់ហើយ ។ គំនរនៃសាច់ បានមានហើយ ដល់ទៅ ១២ យោជន៍ ។ បុរោហិត បានញ៉ាំង បុគ្គលឱ្យរាយស្គរ ជើរប្រកាស ថា "ជនទាំងឡាយដែលចង់បាន

សាច់ ចូរនាំយកសាច់ទៅចុះ" ។ មនុស្សទាំងឡាយ បរិភោគសាច់ហើយ ក៏បានហាលសាច់ដែលនៅសល់ ធ្វើជាសាច់ងៀតហើយ ។

អាចារ្យពួកខ្លះ ពោល ថា "បានឮថា សាច់ងៀត បានកើតឡើងហើយ ក្នុងកាលនោះ" ។ ក៏ក្នុងពួកធាតុ មាន **ភូ** ធាតុ ជាដើម លោកពោល ថា "**វល្ល** ធាតុ ប្រព្រឹត្តទៅ ក្នុងអត្ថ ថា ការពាររារាំង, ជនទាំងឡាយ រមែងការពារ គឺ រារាំង រក្សា នូវសត្វទាំងឡាយ មានក្អែកនិងខ្លែងជាដើម ដើម្បីប្រយោជន៍ដល់កិរិយាមិនឱ្យស៊ី អំពីចំណែកនៃសាច់នេះ ហេតុនោះ ចំណែកនៃសាច់នេះ ទើបឈ្មោះថា **វល្លុរោ** (ជាដៃនរក្សានៃជន)" ។ **វល្លុរោ** សំឡេ ចុះ **ឧរ** បច្ច័យ ដោយសទ្ទនីតិសូត្រ ថា "**ឧរោ វិទាទិតោ**" (**ឧរ** បច្ច័យ រមែងចុះបាន អំពីខាងមុខនៃធាតុ មាន **វិទ** ធាតុជាដើម) ។

(២៩០) ស្តេចឆ្កែចចកនោះ ញុាំងយសដែលកើតឡើងហើយ ឱ្យសាបសូន្យអស់ហើយ សូម្បីខ្លួនឯង ក៏បានដល់ហើយ នូវសេចក្តីទុក្ខ គឺមរណៈ ដោយអំណាចភាវៈជាសត្វមានមានះរឹងត្អឹង ដោយប្រការដូច្នេះ ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ ថា ÷

"ក៏ឆ្កែចចក រឹងត្អឹងដោយមានៈ ត្រូវការដោយ[1] បរិវារ (ច្រើន) ក៏ដល់នូវភូមិសម្បត្តិដ៏ធំ បានជាស្តេចនៃពួកសត្វមានចង្កូមទាំងពួង, បណ្តាមនុស្សទាំងឡាយ ក៏យ៉ាងដូច្នោះដែរ មនុស្សណាជាអ្នកមានបរិវារ, មនុស្សនោះ ឈ្មោះថា ជាធំក្នុងពួកបរិវារនោះ ដូចជាឆ្កែចចក (បានជាធំ) ជាងសត្វមានចង្កូមទាំងឡាយ ដូច្នោះឯង" ។

បណ្តាបទទាំងនោះ បទថា "**មានត្ថទ្ធោ**" មានសេចក្តីថា ជាសត្វរឹងត្អឹង ដោយមានៈ ដែលកើតឡើងហើយ ព្រោះអាស្រ័យបរិវារ ។ បទថា "**អត្ថិកោ**" គឺ ជាសត្វត្រូវការ ដោយបរិវារយ៉ាងក្រៃលែង ។ ២ បទថា "**មហតឹ ភូមឹ**" គឺ នូវសម្បត្តិយ៉ាងធំ ។ បាទគាថាថា "**រាជាសិ សព្ពទាបិនំ**" មានសេចក្តីថា បានជាស្តេចនៃពួកសត្វមានចង្កូមទាំងពួង ។ ច្រើនបទថា "**សោ ហិ តត្ថ មហា**" មានសេចក្តីថា បុរសនោះ គឺ អ្នកដែលបរិបូណ៌ហើយដោយបរិវារ រមែងឈ្មោះថា ជាធំ ក្នុងបរិវារទាំងឡាយនោះ ។ បាទគាថាថា "**សិគាលោ វិយ ទាបិនំ**" មានសេចក្តីថា រមែងបានជាធំ ដូចជាឆ្កែចចក បានជាធំ ជាងពួក

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៣១

សត្វមានចង្កូមទាំងឡាយ យ៉ាងដូច្នោះ, កាលបើដូច្នោះ បុរសនោះ ដល់ហើយនូវមានះ អាស្រ័យបរិវារនោះហើយ រមែងដល់នូវសេចក្តីវិនាស ដូចជាឆ្កែចចក យ៉ាងដូច្នោះឯង ” ។

រឿងឆ្កែចចក មកក្នុងអដ្ឋកថាសព្វទាឋិជាតក ក្នុងទសមវគ្គ នៃខុទ្ទកនិកាត ។

(កិរិយាប្រព្រឹត្តិបន្ទាបខ្លួនជាមង្គល)

(២៩១) ភាវៈនៃបុគ្គលជាអ្នករឹងត្អឹង បណ្ឌិតគប្បីជ្រាបថា “មិនមែនជាមង្គល” ព្រោះជាហេតុនៃសេចក្តីវិនាស ដោយប្រការដូច្នេះ ។ ចំណែក ការប្រព្រឹត្តិបន្ទាបខ្លួន ពោលគឺភាពជាអ្នកមិនរឹងត្អឹង ឈ្មោះថា ជាមង្គល ព្រោះជាហេតុឲ្យបាននូវគុណាមានយសសក្តិជាដើម ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងសិគាលសូត្រ ថា ÷

“ បុគ្គលជាបណ្ឌិត ដែលបរិបូណ៌ដោយសីល មានភាពជាអ្នកល្អិតឬត់ចត់ មានប្រាជ្ញាវាងវៃ មានសេចក្តីប្រព្រឹត្តិបន្ទាបខ្លួន និង ជាអ្នកមិនរឹងត្អឹង, បុគ្គលប្រាកដដូច្នោះ រមែងបាន នូវយសសក្តិ ” ។

អដ្ឋកថាសិគាលសូត្រនោះ ថា “ បណ្តាបទទាំងនោះ បទថា ‘**បណ្ឌិតោ**’ មានសេចក្តីថា ជាបណ្ឌិត ក្នុងឋានៈដែលថ្វាយបង្គំនូវទិសទាំងឡាយ ។ បទថា ‘**សណ្ហោ**’ មានសេចក្តីថា ជាអ្នកល្អិតឆ្លាត់ចត់ ដោយការឃើញអត្ថយ៉ាងសុខុម ឬក៏ ដោយការពោលនូវពាក្យដ៏ទន់ភ្លន់ផ្អែមល្អែម ។ បទថា ‘**បដិភានវា**’ មានសេចក្តីថា ជាអ្នកឆ្លាតវាងវៃ ដោយឋានៈដែលថ្វាយបង្គំទិសទាំងឡាយ ។ បទថា ‘**និវាតវុត្តី**’ ប្រែថា ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា ‘**អត្តទ្ធោ**’ ប្រែថា រៀរចាកភាពជាអ្នកប្រកាន់ខ្លួន” ។

យោជនាថា “ បទថា ‘**ទិសានមស្សនដ្ឋានេ**’ មានសេចក្តីថា ជាបណ្ឌិត គឺ ជាអ្នកឆ្លាត ជាអ្នកឈ្លាសវាងវៃ ក្នុងហេតុដែលថ្វាយបង្គំទិស តាមដែលបានពោលហើយ ដែលខ្លួនសម្គាល់ថា ជាការចូលទៅតាំងនៅចំពោះ រមែងបាននូវយសសក្តិ ” ។

ដីកានៃសិគាលសូត្រនោះ ថា “ ក៏ក្នុងបទថា ‘**សណ្ហោ សណ្ហគុណោ**’ នេះ ដើម្បីនឹងសំដែង ថា ‘បញ្ញាយ៉ាងសុខុមនិងល្អិត វាចាដ៏ទន់ភ្លន់’ ដូច្នេះ ព្រោះប្រកបដោយគុណយ៉ាងល្អិតឆ្លាត់ចត់ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា ‘**សុខុម ... ភណនេន វា**’ ដូច្នេះ ។ បទថា ‘**ទិសានមស្សនដ្ឋានេន**’ នេះ មានការវិនិច្ឆ័យ ថា បុគ្គលកាលប្រតិបត្តិ ដោយន័យតាមដែលបាន

ពោលហើយ ឈ្មោះថា រមែងថ្វាយបង្គំទិសទាំងឡាយ តាមដែលបានពោលហើយ ដោយញាណឯណា, ញាណនោះ ជាហេតុនៃការថ្វាយបង្គំទិសទាំងឡាយ, បុគ្គលនោះ ជាអ្នកឈ្លាសវាងវៃដោយញាណនោះ, ម្យ៉ាងទៀត បុគ្គលនោះ កាលប្រតិបត្តិនូវកិច្ច ដែលជាប្រយោជន៍ ដោយញាណនោះ ដោយអំណាចប្រកបខ្ជល់ខ្ជាយហើយ ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'ជាអ្នកឈ្លាសវាងវៃ' ក្នុងគាថានេះ ។ បទថា '**និវាតវុត្តី**' គឺ ជាអ្នកប្រព្រឹត្តឱនលំទោនជាប្រក្រតី ។ បទថា '**អត្ថទ្ធោ**' គឺ ជាអ្នករឹងត្អឹង មិនមាន ។ បទថា '**ថម្ភរហិតោ**' មានសេចក្តីថា វៀរចាកភាពជាអ្នកប្រកាន់ខ្លួន ដែលមានការប៉ោងឡើង នៃចិត្តជាលក្ខណៈ" ។

ពណ៌នាអំពីបទថា ការប្រព្រឹត្តិបន្ទាបខ្លួន ចប់ ។



ប្រែចប់ថ្ងៃពុធ ១ កើត ខែស្រាពណ៍ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ថ្ងៃទី ១៨ សីហា ១៩៩៣
ល្ងាច

ពណ៌នាអំពីសេចក្តីសន្តោស

---

(២៩២) សេចក្តីសន្តោសដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្តុដ្ឋី** ។ ក្នុងបទថា "**សន្តុដ្ឋី**" នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷ បុគ្គលឈ្មោះថា ជាអ្នកសន្តោស ព្រោះវិគ្រោះថា "រមែងត្រេកអរ ដោយបច្ច័យតាមមានតាមបាន" ។ ក៏បទថា "**សំ**" គ្រាន់តែជាឧបសគ្គ ។ មួយទៀត បទថា "**សំ**" នេះ រមែងប្រកបនូវសេចក្តីបាន ៣ យ៉ាង គឺ **សកំ សន្តំ សមំ** ។

ដោយហេតុនោះ ក្នុងអដ្ឋកថាមេត្តសូត្រ ក្នុងបឋមវគ្គ នៃសុត្តនិបាត ទើបព្រះអដ្ឋកថាចារ្យ ពោលថា "ភិក្ខុឈ្មោះថា ជាអ្នកសន្តោស ព្រោះអត្ថវិគ្រោះថា 'រមែងត្រេកអរ ដោយសេចក្តីសន្តោស ១២ យ៉ាង' ។ ម្យ៉ាងទៀត ភិក្ខុឈ្មោះថា ជាអ្នកត្រេកអរ ព្រោះអត្ថវិគ្រោះថា 'រមែងត្រេកអរ' ។ ភិក្ខុឈ្មោះថា ជាអ្នកសន្តោស ព្រោះអត្ថវិគ្រោះថា 'ជាអ្នកត្រេកអរដោយបច្ច័យរបស់ខ្លួន ត្រេកអរដោយបច្ច័យដែលមាន ត្រេកអរដោយស្មាំស្មើ' ។

បណ្តាអត្ថទាំង ៣ យ៉ាងនោះ បច្ច័យ ៤ ឯណា ដែលព្រះឧបជ្ឈាយ៍ បានសំដែងហើយ ក្នុងមណ្ឌលដែលជាទីឧបសម្បទ ថា

'**បិណ្ឌិយាលោបភោជនំ និស្សាយ**' ដូច្នេះជាដើម ដែលខ្លួនឯងទទួលហើយ, បច្ច័យនោះ ឈ្មោះថា **សកំ** (បច្ច័យរបស់ខ្លួន) ។ ភិក្ខុមិនសំដែងនូវវិការៈ ទាំងក្នុងវេលាទទួល ទាំងក្នុងវេលាបរិភោគ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយបច្ច័យ ៤ នោះ ដែលល្អ ឬក៏មិនល្អ ដែលពួកទាយកប្រគេនហើយ ដោយគោរព ឬមិនគោរព ព្រះមានព្រះភាគ ត្រាស់ថា 'ជាអ្នកសន្តោសដោយបច្ច័យរបស់ខ្លួន' ។

បច្ច័យ ៤ ឯណា ជារបស់ដែលខ្លួនបានហើយ គឺ មានជាប់ខ្លួន, បច្ច័យ ៤ នោះ ឈ្មោះថា **សន្និ** (បច្ច័យដែលមាន), ភិក្ខុកាលត្រេកអរ ដោយបច្ច័យ ៤ នោះ ដែលមានប៉ុណ្ណោះ មិនប្រាថ្នាបច្ច័យដទៃទៀត ក្រៅអំពីបច្ច័យទាំង ៤ នោះ លះបង់ចោលនូវភាពជាអ្នកប្រាថ្នាច្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា 'ជាអ្នកសន្តោស ដោយបច្ច័យដែលមាន' ។

ការលះបង់នូវសេចក្តីត្រេកអរ និងសេចក្តីថ្នាំងថ្នាក់ចិត្ត ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា **សមំ** (ស្ងាំស្ងៀ) ។ ភិក្ខុកាលសន្តោស ក្នុងអារម្មណ៍ទាំងពួង ដោយបច្ច័យដែលស្ងាំស្ងៀ នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា 'ជាអ្នកសន្តោស ដោយបច្ច័យដែលស្ងាំស្ងៀ' ដូច្នេះ" ។

(២៩៣) សូម្បីក្នុងជីវកសូត្របសំយុត្ត ក៏លោកពោលថា

"បទថា '**សន្តុដ្ឋោ**' មានសេចក្តីថា ព្រះមហាកស្សបត្ថេរ ជាអ្នកសន្តោស ដោយចង្ហាន់ខ្ពស់ៗ ទាបៗ ដែលជារបស់ខ្លួន ដែលជារបស់ដែលមាន ឬដែលស្មាំស្មើប៉ុណ្ណោះ"។

ជីកាឯកនិបាត អង្គុត្តរនិកាយ ថា "សេចក្តីសន្តោស ឈ្មោះថា **តុដ្ឋី**, ម្យ៉ាងទៀត សេចក្តីសន្តោស ដោយស្មាំស្មើ របស់កិក្ខុនោះមាន ហេតុនោះ កិក្ខុនោះ ឈ្មោះថា **សន្តុដ្ឋិ** (អ្នកមានសេចក្តីសន្តោស ដោយស្មាំស្មើ)"។

ភាវៈនៃបុគ្គលជាអ្នកមានសេចក្តីត្រេកអរ ដោយអាការៈដែលស្មាំស្មើ ឬជាអ្នកសន្តោស ឈ្មោះថា **សន្តុដ្ឋី**។ **ណ** បច្ច័យចុះក្នុងអត្ថនៃភាវៈ ដោយសូត្រថា "**ណ វិសមាទីហិ** (**ណ** បច្ច័យ រមែងចុះបានតែខាងមុខ នៃសព្ទទាំងឡាយ មាន **វិសម** សព្ទជាដើម)"។ **ឥ** បច្ច័យ រមែងចុះបានតែខាងមុខ នៃលិង្គដែលប្រព្រឹត្តទៅក្នុងឥត្ថីលិង្គ មាន **ណ** បច្ច័យជាទីបំផុតដោយសូត្រថា "**ណាវណិកណោយ្យ ណន្តូហិ** (**ឥ** បច្ច័យដែលប្រព្រឹត្តទៅ ក្នុងឥត្ថីលិង្គ រមែងចុះបានតែខាងមុខ នៃបច្ច័យទាំងឡាយ ដែលមាន **ណាវ ណិក ណោយ្យ** និង **ណ** បច្ច័យ ជាទីបំផុត)"។

(២៩៤) ចំណែកក្នុងអដ្ឋកថាកស្សបសំយុត្ត សង្គីតិសូត្រ និងចតុក្កនិបាត អង្គុត្តរនិកាយ ព្រះអដ្ឋកថាចារ្យទាំងឡាយ បាន

ពោលថា " បទថា **'ឥតរិតរេន'** មានសេចក្តីថា ព្រះមហាកស្សបៈ ត្រេកអរហើយ បណ្តាបច្ច័យទាំងឡាយដែលគ្រោតគ្រាត ល្ហិតហ្មត់ សៅហ្មង ប្រណីត ធន់ និង ចាស់ ដោយបច្ច័យឯណាមួយ ក៏ទេ, តាមពិត ជាអ្នកត្រេកអរហើយ ដោយបច្ច័យក្រៅនេះនិងក្រៅនេះ គឺ ដោយបច្ច័យឯណាមួយ បណ្តាបច្ច័យទាំងឡាយមានបច្ច័យដែលខ្ជួនបានហើយ យ៉ាងដូចម្តេច ជាដើម " ។

ដីកាកស្សបសំយុត្តថា " **ឥតរីតរ** បច្ច័យ ក្នុងបទថា **'ឥតរិតរេន'** នោះ មាន ២ យ៉ាង គឺ បច្ច័យដែលកើតឡើងតាមប្រក្រតី ១ ដែលកើតឡើងដោយញាណ ១ ។ បណ្តា **ឥតរិតរ** បច្ច័យទាំង ២ យ៉ាងនោះ ព្រះអដ្ឋកថាចារ្យ លើកទុកស្លេះសិនហើយ នូវបច្ច័យដែលកើតឡើងដោយប្រក្រតី សំដែងតែបច្ច័យដែលកើតឡើងដោយញាណ តែម្យ៉ាងប៉ុណ្ណោះ ទើបពោលពាក្យថា **'ន ថូលសុខុម'** ដូច្នេះជាដើម " ។

ដីកាសង្គីតិសូត្រ និង ចតុក្កនិបាត នៃអង្គុត្តរនិកាយ ថា " បទថា **'ឥតរិតរេន'** គឺ ដោយបច្ច័យក្រៅនេះៗ ។ **ឥតរ** សំឌ្ឍ ជាសំឌ្ឍពោលសេចក្តីមិននិយម ដោយពិតប្រាកដ កាលពោល ២ - ៣ ដង រមែងមានសេចក្តីស្មើគ្នានឹង **យង្កិញ្ចិ** សំឌ្ឍ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'យេន កេនចិ'** ។

ឥតរីតរ បច្ច័យសព្ទនេះនោះ ជាសព្ទពោលបច្ច័យណាមួយ សូម្បីបណ្តាបច្ច័យទាំងឡាយ ដែលខ្ជួនបានហើយ យ៉ាងដូចម្តេចជាដើម ដូចជា **ឥតរីតរ** សព្ទ ដែលពោលដល់បច្ច័យទាំងឡាយ មានបច្ច័យដែលគ្រោតគ្រាតជាដើម បច្ច័ណាមួយ ដូច្នោះឯង ព្រោះពោលដោយមិនពិតប្រាកដន៎ុះឯង ដោយប្រការដូច្នេះ ។ បណ្តាបច្ច័យទាំង ២ យ៉ាងនោះ ព្រះអដ្ឋកថាចារ្យ កាលសំដែងនូវភាវៈនៃព្រះមហាកស្សបត្ថេរ ប្រាថ្នាចំពោះតែបច្ច័យផ្នែកទី ២ ប៉ុណ្ណោះ ក្នុងព្រះសូត្រនេះ ទើបពោលថា '**អថ ខោ**' ដូច្នេះជាដើម ។ មានពាក្យសួរថា 'ក៏ឥតរីតរបច្ច័យទាំងឡាយ សូម្បីតាមដែលខ្ជួនបានហើយ យ៉ាងដូចម្តេចជាដើម គឺជាបច្ច័យដែលគ្រោតគ្រាតជាដើមន៎ុះឯង មិនមែនទេឬ ?' ។ ឆ្លើយថា 'ពាក្យន៎ុះពិត' ។ សូម្បីជាយ៉ាងដូច្នោះក៏ដោយ សេចក្តីប្លែកគ្នា តែងមាន, ព្រោះថា សេចក្តីសន្តោស ក្នុងឥតរីតរបច្ច័យទាំងឡាយ ដែលគ្រោតគ្រាតជាដើម តាមដែលខ្ជួនបានហើយ យ៉ាងដូចម្តេច ឯណា, សេចក្តីសន្តោសនោះ ឈ្មោះថា យថាលាភសន្តោស (ត្រេកអរតាមមានតាមបាន) ដោយពិត, ដទៃក្រៅអំពីនេះ មិនឈ្មោះថា យថាលាភសន្តោសឡើយ ។ ព្រោះថា សេចក្តីសន្តោសក្រៅអំពីនេះនោះ អាស្រ័យត្រឹមតែបច្ច័យ គឺព្រះមហាកស្សបត្ថេរ

មិនប្រាថ្នាហើយ ដោយពិតនុ៎ះ លោកប្រាថ្នាសេចក្តីសន្តោសដែលជាទីអាស្រ័យ នូវភាវៈគឺសេចក្តីសមគួរដល់កម្លាំងកាយ របស់ខ្លួនដូច្នេះឯង ។ គប្បីជ្រាបសន្និដ្ឋានថា 'ក៏បច្ច័យទាំងឡាយ ៣ យ៉ាង មានបច្ច័យដែលគ្រោតគ្រាតជាដើម រមែងបាន ក្នុងចីពរ ។ បច្ច័យដែលជាកណ្តាល ទូទៅដល់បច្ច័យទាំង ៤ យ៉ាង, ចំណែកបច្ច័យចុងក្រោយគេ រមែងបាន ទាំងក្នុងចីពរ ទាំងក្នុងសេនាសនៈ' ដូច្នេះ " ។

(២៩៥) ក៏ក្នុងដីកាសាមញ្ញផលសូត្រ កស្សបសំយុត្ត និងឯកនិបាត អង្គុត្តរនិកាយ លោកពោលថា " ម្យ៉ាងទៀត វត្ថុដែលអាក្រក់ លោកហៅថា ក្រៅអំពីនេះ ព្រោះភាវៈជាវត្ថុដែលជំទៃផ្សេងក្រៅអំពីវត្ថុដែលប្រណីត, មួយទៀត សូម្បីវត្ថុដែលប្រណីត ក៏ឈ្មោះថា ក្រៅអំពីនេះដែរ ព្រោះភាវៈជាវត្ថុជំទៃក្រៅអំពីវត្ថុដែលអាក្រក់, ក៏ភាវៈនៃវត្ថុជារបស់ជំទៃក្រៅអំពីនេះ សំរេចហើយ ដោយការសំឡឹងរំពៃ " ។

វត្ថុក្រៅអំពីនេះផង ក្រៅអំពីនេះផង ឈ្មោះថាឥតរិតរបច្ច័យ, ឥតរិតរបច្ច័យនោះឯង ឈ្មោះថា បច្ច័យ, សេចក្តីសន្តោសដោយឥតរិតរបច្ច័យនោះ ឈ្មោះថា ឥតរិតរបច្ច័យសន្តោស, ឥតរិតរបច្ច័យសន្តោសនោះ គឺ សេចក្តីមិនលោភលន់ នុ៎ះឯង,

ដោយហេតុនោះ ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ទើបព្រះអដ្ឋកថាចារ្យ ពោលថា "សេចក្តីសន្តោស ពោលគឺការមិនលោភ ឈ្មោះថា **សន្តុដ្ឋិតា** "។

ជីកាឯកនិបាត អង្គុត្តរនិកាយនោះ និងជីកាសាមញ្ញផលសូត្រ និង កស្សបសំយុត្ត ថា "ភិក្ខុរមែងត្រេកអរ ដោយបច្ច័យមានចីវរជាដើម ដែលអាក្រក់ ឬ ប្រណីត ប្រកបដោយធម៌ ឯណាមួយ, ធម៌នោះ ប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ គឺសេចក្តីមិនលោភលន់ ឈ្មោះថា ឥតរវបច្ច័យសន្តោស "។

(២៩៦) សេចក្តីសន្តោស គឺការមិនលោភលន់ មានតែមួយប៉ុណ្ណោះ ក៏ពិតមែន, ទោះបីជាយ៉ាងដូច្នោះ ដោយប្រភេទនៃអារម្មណ៍ រមែងមាន ៤ យ៉ាង ដោយអំណាចបច្ច័យ ៤, មួយទៀត រមែងមាន ១២ យ៉ាង ដោយប្រភេទ នៃតិកៈទាំងឡាយ ៤ (៣ ពួក ១ ពួក មាន ៤ ៗ) ព្រោះធ្វើវិភាគថា 'សេចក្តីសន្តោស ក្នុងបច្ច័យទាំងឡាយ ៤ បច្ច័យមួយៗ មាន ៣ ៗ ដោយអំណាច នៃយថាលាភសន្តោស យថាពលសន្តោស និងយថាសារុប្បសន្តោស ។ ដោយហេតុនោះ ក្នុងអដ្ឋកថាទាំងពួង ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបពោលថា "សេចក្តីសន្តោសនោះ មាន ១២ យ៉ាង "។

(២៩៧) មែនពិត ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលសេចក្តីសន្តោស ១២ យ៉ាង ទុកហើយ ក្នុងឋានៈទាំងឡាយនេះ គឺ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ក្នុងទីឃនិកាយ, ក្នុងអដ្ឋកថាវជិរនិត-សូត្រ ក្នុងតតិយវគ្គ មូលបណ្ណាសកៈ ក្នុងមជ្ឈិមនិកាយ, ក្នុងអដ្ឋកថាកស្សបសំយុត្ត ក្នុងសំយុត្តនិកាយ, ក្នុងអដ្ឋកថាឯកនិបាត ក្នុងអង្គុត្តរនិកាយ, ក្នុងអដ្ឋកថាមង្គលសូត្រ ក្នុងខុទ្ទកបាឋៈ និង សុត្តនិបាត ក្នុងខុទ្ទកនិកាយ ។

(សន្តោស ១២ យ៉ាង)

អដ្ឋកថាមង្គលសូត្រ ក្នុងខុទ្ទកបាឋៈជាដើម ថា “លោក ពោលសេចក្តីសន្តោស ១២ យ៉ាង តើដូចម្តេច ? ។ ភិក្ខុ ក្នុង ព្រះធម្មវិន័យនេះ បាននូវចីវរល្អ ឬមិនល្អក៏ដោយ, ភិក្ខុនោះ រមែងញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយចីវរនោះប៉ុណ្ណោះ មិន ប្រាថ្នានូវចីវរដទៃទៀត សូម្បីបាន ក៏មិនទទួលដែរ, អាការៈ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាលាភសន្តោស ក្នុងចីវរ ។ ក៏ប្រសិនបើ ភិក្ខុជាអ្នកមានអាពាធ កាលគ្រង់ចីវរដែលធ្ងន់ រមែងក្រោមចុះ ឬ លំបាក, ភិក្ខុនោះ ប្តូរចីវរដ៏ធ្ងន់នោះ ជាមួយ នឹងភិក្ខុដែលជាទីពេញចិត្តហើយ ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ

ដោយចីវរដែលស្រាល ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាពលសន្តោស ក្នុងចីវរ ។ ភិក្ខុដទៃទៀត ជាអ្នកបានបច្ច័យដែលប្រណីត, បណ្តាបច្ច័យទាំងឡាយ មានបាត្រនិងចីវរជាដើម ភិក្ខុនោះ បាននូវចីវរដែលមានតម្លៃច្រើន ឯណាមួយហើយ ក៏គិតថា 'ចីវរនេះ សមគួរ ដល់ព្រះថេរៈទាំងឡាយដែលបួសយូរហើយ, ចីវរនេះ សមគួរ ដល់ភិក្ខុទាំងឡាយដែលជាពហុស្សូត' ដូច្នេះហើយ ក៏បានប្រគេនចីវរដែលមានតម្លៃច្រើននោះ ដល់ព្រះថេរៈដែលបួសយូរ ឬ ភិក្ខុដែលជាពហុស្សូតទាំងឡាយនោះ ហើយបានស្វះស្វែងរកសំពត់ទាំងឡាយដែលឥតជាយ អំពីទីឋានឯណាមួយ គឺ អំពីគំនរសម្រាម ឬអំពីព្រៃ ដោយខ្លួនឯង សូម្បីធ្វើសង្ឃាដី ដោយសំពត់ដែលមិនមានជាយទាំងនោះហើយប្រើប្រាស់ ក៏ឈ្មោះថា ជាអ្នកសន្តោសពិត, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងចីវរ (ត្រេកអរតាមសមគួរ ក្នុងចីវរ) ។

មួយទៀត ភិក្ខុក្នុងព្រះធម្មវិន័យនេះ បាននូវបិណ្ឌបាតសៅហ្មង ឬប្រណីត, ភិក្ខុនោះ រមែងញុាំងអត្តភាព ឱ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះ តែប៉ុណ្ណោះ មិនប្រាថ្នានូវបិណ្ឌបាតដទៃសូម្បីបាន ក៏មិនទទួល, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា

យថាលាភសន្តោស ក្នុងបិណ្ឌបាត ។ ក៏ប្រសិនបើ ភិក្ខុជាអ្នក មានអាពាធ ឆាន់បិណ្ឌបាតដែលសៅហ្មងហើយ រមែងដល់នូវ ការទាស់នឹងរោគ យ៉ាងខ្លាំង, ភិក្ខុនោះ ប្រគេនបិណ្ឌបាតនោះ ដល់ភិក្ខុដែលជាទីស្រឡាញ់ពេញចិត្តគ្នា ហើយឆាន់នូវទឹកដោះរាវ ថ្លា ទឹកដោះជូរ ទឹកឃ្មុំ និង ទឹកដោះស្រស់ជាដើម អំពីដៃរបស់ ភិក្ខុដែលជាទីស្រឡាញ់ពេញចិត្តនឹងគ្នានោះ សូម្បីធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការៈរបស់ភិក្ខុនេះ នោះ ឈ្មោះថា យថាពលសន្តោស ក្នុងបិណ្ឌបាត ។ ភិក្ខុមួយ ទៀត បាននូវបិណ្ឌបាតដ៏ប្រណីត, ភិក្ខុនោះ នឹកគិតថា 'បិណ្ឌបាតនេះ សមគួរដល់ព្រះថេរៈទាំងឡាយ ដែលបួសយូរហើយ និងសមគួរដល់ពួកភិក្ខុដែលជាសព្រហ្មចារីដទៃទៀត ដែលប្រាស ចាកបិណ្ឌបាតដ៏ប្រណីត មិនញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ' ដូច្នេះ ហើយ ក៏ប្រគេននូវបិណ្ឌបាតនោះ ដល់ព្រះថេរៈទាំងឡាយ ដែល បួសយូរហើយ ឬ ភិក្ខុដែលជាសព្រហ្មចារីទាំងឡាយនោះ ហើយ ស្រាច់ទៅបិណ្ឌបាត ដោយខ្លួនឯង សូម្បីឆាន់នូវអាហារដែល ច្របូកច្របល់គ្នា ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការៈ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងបិណ្ឌបាត ។

មួយទៀត សេនាសនៈ បានមកដល់ភិក្ខុ ក្នុងព្រះធម្មវិនយ

នេះ, ភិក្ខុនោះ រមែងត្រេកអរ ដោយសេនាសនៈនោះ តែប៉ុណ្ណោះ មិនទទួលនូវសេនាសនៈដទៃ សូម្បីតែប្រសើរជាង ដែលបានមកដល់ (ខ្លួន) ម្តងទៀត, អាការៈ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាលាភសន្តោស ក្នុងសេនាសនៈ ។ ក៏ប្រសិនបើ ភិក្ខុនោះ ជាអ្នកមានអាពាធ, ភិក្ខុនោះ កាលនៅ ក្នុងសេនាសនៈដែលគ្មានខ្យល់ រមែងរសាប់រសល់ យ៉ាងក្រៃលែង ព្រោះរោគទាំងឡាយ មានរោគប្រមាត់ជាដើម, ភិក្ខុនោះ សូម្បីប្រគេននូវសេនាសនៈ នោះ ដល់ភិក្ខុដែលជាទីស្រឡាញ់ពេញចិត្តនឹងគ្នាហើយ នៅក្នុងសេនាសនៈ ដែលមានខ្យល់ចេញចូលត្រជាក់ (ស្រួល) ដែលបានមកដល់ភិក្ខុដែលត្រូវចិត្តនឹងគ្នានោះ ធ្វើនូវសមណធម៌ ក៏ឈ្មោះ ថា ជាអ្នកសន្តោស ដោយពិត, អាការៈ របស់ភិក្ខុនេះនោះ ឈ្មោះថា យថាពលសន្តោស ក្នុងសេនាសនៈ ។ ភិក្ខុមួយទៀត មិនបានទទួលនូវសេនាសនៈ ដ៏ប្រសើរ សូម្បីបានមកដល់ (ខ្លួន) ហើយ, ភិក្ខុនោះ គិតថា ៈ ធម្មតាសេនាសនៈដ៏ប្រសើរ រមែងជាទីតាំងនៃសេចក្តីប្រមាទ ព្រោះហេតុនោះ ថីនមិទ្ធៈ គឺ សេចក្តីងងុយងោកងក់ រមែងគ្របសង្កត់ ដល់ភិក្ខុដែលអង្គុយ នៅក្នុងសេនាសនៈ ដ៏ប្រសើរនោះបាន, ក៏កាលបើ ភិក្ខុនោះ ត្រូវសេចក្តីងងុយដេកគ្របសង្កត់ហើយ ក្រោកឡើងមក ម្តងទៀត, សេចក្តី

វិតកទាំងឡាយដ៏លាមក រមែងពុះពោរពាលដាលឡើង ដូច្នេះ ហើយ ក៏ហាមឃាត់សេនាសនៈនោះ សូម្បីនៅ ក្នុងទីកណ្តាលវាល ក្រោមដើមឈើ និង កុដិដែលបាំងដោយស្លឹកឈើ ទីកន្លែងឯណាមួយ ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្តោស ក្នុងសេនាសនៈ ។

មួយទៀត ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ បាននូវភេសជ្ជៈសម្រាប់បំបាត់ជម្ងឺ ដែលសៅហ្មងឬប្រណីត, ភិក្ខុនោះ រមែងញុាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយគិលានភេសជ្ជៈនោះ មិនប្រាថ្នានូវគិលានភេសជ្ជៈដទៃទៀត សូម្បីបាន ក៏មិនទទួល, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាលាភសន្តោស ក្នុងគិលានប្បច្ច័យ ។ ក៏ប្រសិនបើ ភិក្ខុនោះ មានអាពាធ ប្រាថ្នាចង់បានប្រេង តែបាននូវទឹកអំពៅ, ភិក្ខុនោះ ប្រគេនទឹកអំពៅនោះទៅដល់ភិក្ខុដែលជាទីស្រឡាញ់ពេញចិត្តនឹងគ្នា ហើយធ្វើនូវភេសជ្ជៈ ដោយប្រេងនោះ អំពីដៃរបស់ភិក្ខុ ដែលជាទីស្រឡាញ់ពេញចិត្តនឹងគ្នានោះ សូម្បីធ្វើនូវសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោស ដោយពិត, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាពលសន្តោស ក្នុងគិលានប្បច្ច័យ ។ ភិក្ខុមួយទៀត កាលត្រូវឱ្យបាសកជាក់ផ្លែស្រម៉ដ្រាំដោយទឹកមូត្រ ក្នុងភាជនៈមួយហើយ ជាក់ភេសជ្ជៈ ដែលមានរសជាតិ ៤ យ៉ាង

ក្នុងភាជនៈមួយហើយ ពោលថា ' បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ចូរព្រះគុណម្ចាស់ ទទួលយកចុះ, បើព្រះគុណម្ចាស់ត្រូវការ ' ដូច្នេះ, ប្រសិនបើ អាពាធរបស់ភិក្ខុនោះ សូចប់រម្ងាប់ទៅបាន ដោយភេសជ្ជៈទាំង ២ យ៉ាងនោះ សូម្បីភេសជ្ជៈណាមួយក៏ដោយ, លំដាប់នោះ ភិក្ខុនោះ កាលនឹកឃើញ នូវព្រះតម្រាស់ដែលព្រះមានព្រះភាគទ្រង់ត្រាស់ ថា ' ឈ្មោះថា ផ្លែស្រម៉ដែលត្រាំដោយទឹកមូត្រ គឺអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់បានត្រាស់សរសើរហើយ, និង ការបួសនេះ អាស្រ័យនូវទឹកមូត្រត្រាំ (ស្ពុយ) ធ្វើជាថ្នាំ, អ្នកគប្បីធ្វើសេចក្តីព្យាយាម ក្នុងថ្នាំផ្លែស្រម៉ដែលត្រាំ ដោយទឹកមូត្រស្ពុយនោះ ដរាបដល់អស់ជីវិត ' ដូច្នេះ ហាមឃាត់នូវភេសជ្ជៈដែលមានរសជាតិ ៤ យ៉ាង កាលធ្វើនូវភេសជ្ជៈ ដោយផ្លែស្រម៉ដែលត្រាំដោយទឹកមូត្រស្ពុយ ក៏ឈ្មោះថា ជាអ្នកសន្តោស យ៉ាងក្រៃលែង, អាការៈរបស់ភិក្ខុនេះនោះ ឈ្មោះថា យថាសារុប្បសន្តោសក្នុងគិលានប្បច្ច័យ " ។

(២៩៨) អដ្ឋកថាសាមញ្ញផលសូត្រជាដើម ឃើញប្លែកខុសគ្នា បន្តិចបន្តួច ។ សូម្បីអដ្ឋកថាសាមញ្ញផលសូត្រនោះ ក៏គប្បីត្រួតនិពិត្យមើលដែរ ។

ក្នុងដីកាសាមញ្ញផលសូត្រជាដើម លោកពោលថា " សេចក្តី

សន្តោស ដោយបច្ច័យតាមដែលបាន គឺ បច្ច័យសមគួរដល់លាភ របស់ខ្លួន ឈ្មោះថា យថាលាភសន្តោស ។ សូម្បីក្នុង ២ បទ ដែលនៅសេសសល់ ក៏មាននិយ័យដូចនេះដែរ ។ បច្ច័យ ឈ្មោះថា **លាភ** ព្រោះអត្ថថា 'គឺភិក្ខុត្រូវបាន' ។ លាភណា។ ឈ្មោះថា លាភតាមដែលខ្លួនបានយ៉ាងណា, សេចក្តីសន្តោស ដោយលាភ តាមដែលខ្លួនបានយ៉ាងណានោះ ឈ្មោះថា យថាលាភសន្តោស ។ បទថា '**ពលំ**' គឺ កម្លាំងកាយ ។ បទថា '**សារុប្បំ**' គឺ តាមសមគួរ ដល់ភិក្ខុ ។ ឈ្មោះថា ការមិនប្រាថ្នាបច្ច័យដទៃ ក្រៅអំពីបច្ច័យ ដែលខ្លួនបានហើយយ៉ាងណា គប្បីជាអាការៈនៃកិរិយាប្រព្រឹត្តិទៅ សូម្បីដើម្បីភាពជាអ្នកប្រាថ្នាតិច ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ កាលសំដែងសេចក្តីសរុប (បំព្រួញ) នៃសេចក្តីសន្តោស ដែលមិនខុសផ្សេងអំពីគ្នា ចាកសេចក្តីមិនប្រាថ្នានុ៎ះឯង ទើបពោល ថា '**លភន្តោបិ ន គណ្ហាតិ**' ដូច្នេះ "។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោល ថា "**អាពាធិកោ ហោតិ**" ។

(២៩៩) ចំណែកក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ជាដើម លោកពោល ថា "ក៏ភិក្ខុណា ជាអ្នកទុព្វលភាព ដោយប្រក្រតីឬ ជាអ្នកត្រូវអាពាធនិងជរាគ្របសង្កត់, ភិក្ខុនោះ កាលត្រង់ចីវរធ្ងន់

រមែងលំបាក ” ។

២ បទថា “ **តំ បរិវត្តេត្វា** ” មានសេចក្តីថា ផ្លាស់ប្តូរនូវចីវរនោះ ដោយអំណាចប្រយោជន៍ថា ‘ចីវរដែលធ្ងន់ តែងមិននាំសេចក្តីជាសុកមកឱ្យទេ តែនាំសេចក្តីលំបាកសរីរៈមកឱ្យ ដល់ភិក្ខុទាំងឡាយ ដែលទុព្ភាពដោយប្រក្រតីជាដើម’ ដូច្នេះ, មិនមែនផ្លាស់ប្តូរ ដោយអំណាចភាពជាអ្នកប្រាថ្នាច្រើនឡើយ ។ កិរិយាប្រើប្រាស់ចីវរដែលស្រាល មិនមែនជាការខុសចាកសេចក្តីសន្តោសទេ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា “ **លហុកេន យាបេន្តោបិ សន្តុដ្ឋោ វ ហោតិ** ” ដូច្នេះ ។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលថា “ បានហើយនូវចីវរដែលមានតម្លៃច្រើន ” ។

អដ្ឋកថានៃសូត្រដទៃអំពីនេះ ថា “ បានហើយ នូវចីវរដែលមានតម្លៃច្រើន ឬបាត្រនិងចីវរដែលស្រាល ” ។

ដីកានៃសូត្រដទៃអំពីនេះនោះ ថា “ ការបានចីវរដែលមានតម្លៃច្រើន ឬ ចីវរដែលស្រាល ហើយលះបង់ចីវរដែលមានតម្លៃច្រើនជាដើមនោះ ទទួលយកចីវរដទៃទៀតក្រៅអំពីនោះ មិនមែនជាការខុស ចាកសេចក្តីសន្តោសឡើយ ព្រោះជាអ្នកតាំងនៅហើយក្នុងន័យនៃយថាសារុប្បសន្តោស ព្រោះហេតុនោះ ទើបព្រះ

អដ្ឋកថាចារ្យពោលថា 'តេសំ ។បេ។ ធារេន្តោបិ សន្តុដ្ឋោ វ ហោតិ' ដូច្នេះ ។ គប្បីជ្រាបអធិប្បាយ សូម្បីក្នុងបច្ច័យដែលនៅសេសសល់ទាំងឡាយ ដោយប្រកាន់យក **អបិ** សព្ទ ក្នុងនិទ្ទេសនៃយថាពលសន្តោស និង យថាសារុប្បសន្តោស យ៉ាងដូច្នេះឯង" ។

(៣០០) ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលថា "ភិក្ខុជាអ្នកមានអាពាធ ឆាន់ហើយ នូវបិណ្ឌបាតដែលសៅហ្មង រមែងដល់នូវការទម្លាស់ នឹងរោគ យ៉ាងខ្លាំង" ។

អដ្ឋកថានៃសូត្រក្រៅអំពីនេះ ថា "ក៏ភិក្ខុណា បាននូវបិណ្ឌបាតដែលជាសត្រូវដោយប្រក្រតី ឬ ដែលជាទម្លាស់នឹងរោគរបស់ខ្លួន, ភិក្ខុនោះ មិនមានសេចក្តីសប្បាយ ដោយបិណ្ឌបាតណាដែលខ្លួនបានឆាន់ហើយ, ភិក្ខុនោះ ប្រគេនបិណ្ឌបាតនោះទៅ ដល់ភិក្ខុដែលត្រូវចិត្តនឹងគ្នា ហើយឆាន់ភោជនដែលសប្បាយ អំពីដៃរបស់ភិក្ខុដែលត្រូវចិត្តនឹងគ្នានោះ" ។

ជីកាកស្សបសំយុត្ត ថា "បទថា 'បកតិ' បានដល់ រោគទាំងឡាយ មានរោគខ្យល់ជាប្រក្រតីជាដើម ។ សេចក្តីវិតកទាំងឡាយ ដ៏លាមក រមែងប្រាកដមាន យ៉ាងឆាប់រហ័ស ដល់ភិក្ខុដែលក្រោកឡើងហើយ ព្រោះត្រូវការងងុយងក់គ្របសង្កត់" ។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ លោកពោលហើយ ថា "ធ្វើ

នូវកេសដ្ឋៈ ដោយប្រែង អំពីដៃរបស់ភិក្ខុនោះ ” ។

អដ្ឋកថាសូត្រជទៃអំពីនេះ ថា “ សូម្បីទទួលនូវប្រែង អំពីដៃរបស់ភិក្ខុនោះហើយ ឬ ស្វែងរកកេសដ្ឋៈជទៃទៀតនុ៎ះឯង ហើយធ្វើនូវកេសដ្ឋៈ ” ។

ជីកាសាមញ្ញផលសូត្រជដើម ថា “ បទថា ‘ **មុត្តហរីតកំ** ’ មានសេចក្តីថា ផ្លែស្រម៉ ដែលបុគ្គលចោលហើយ ដោយភាពជារបស់ស្អុយ ដែលបុគ្គលត្រាំហើយដោយទឹកមូត្រគោ ។ ២ បទថា ‘ **ពុទ្ធាទីហិ វណ្ណិតំ** ’ មានសេចក្តីថា ដែលអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ទ្រង់ត្រាស់សរសើរហើយ ដោយពាក្យថា ‘ បព្ពជ្ជា អាស្រ័យថ្នាំដែលត្រាំដោយទឹកមូត្រស្អុយ ’ ដូច្នេះជាដើម ដើម្បីនឹងទ្រង់បបួលនូវភិក្ខុទាំងឡាយ ក្នុងភាពជាអ្នកមានសេចក្តីប្រាថ្នាតិច និង ភាពជាអ្នកសន្តោស ។ ភិក្ខុ ឈ្មោះថា ជាអ្នកសន្តោស យ៉ាងក្រៃលែងពិត ព្រោះជាអ្នកប្រកបដោយសេចក្តីសន្តោស យ៉ាងក្រៃលែង គឺ យ៉ាងខ្ពង់ខ្ពស់ ” ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ និង វេវិនីតសូត្រ ថា “ បណ្តាសេចក្តីសន្តោស ក្នុងបច្ច័យចំពោះមួយ ៗ ទាំង ៣ យ៉ាងនេះ យថាសារុប្បសន្តោសប៉ុណ្ណោះ ជាសេចក្តីសន្តោសដ៏ប្រសើរ ” ។

ជីកានៃសូត្រទាំង ២ នោះ ថា “ ភិក្ខុ ឈ្មោះថា ជាអ្នកប្រសើរ

ព្រោះប្រព្រឹត្តទៅ ក្នុងបច្ច័យនោះ ។ ដោយអំណាចសេចក្តីត្រេកអរ អាស្រ័យនូវសេចក្តីសមគួរនុ៎ះឯង " ។

ពណ៌នាអំពីសេចក្តីសន្តោស ១២ យ៉ាង ចប់ ។

(៣០១) អដ្ឋកថាសាមញ្ញផលសូត្រ ចូឡហត្ថិបទោបមសូត្រ និងអដ្ឋកថាចតុត្ថបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា " មួយទៀត បរិក្ខារទាំងឡាយ ៨ គឺ ត្រៃចីវរ បាត្រ កូនកាំបិត សម្រាប់ចិតឈើជម្រះធ្មេញ ម្ជុល ១ វត្ថុពន្ធន៍ចង្កេះ សំពត់ សម្រាប់ត្រងទឹក រមែងសមគួរ ដល់ភិក្ខុដែលប្រកបព្រម ដោយសេចក្តីសន្តោស ដោយឥតរិតរបច្ច័យ ទាំង ១២ យ៉ាងនេះ ។

មែនពិត សូម្បីពាក្យនេះ បូរាណាចារ្យ បានពោលហើយ ថា

> ' បរិក្ខារទាំងឡាយនេះ គឺ ត្រៃចីវរ បាត្រ កាំបិត (កោរ) ម្ជុល និងវត្ថុពន្ធន៍ចង្កេះ ត្រូវជា ៨ នឹង សំពត់សម្រាប់ត្រងទឹក រមែងសមគួរ ដល់ភិក្ខុ ដែលប្រកបសេចក្តីព្យាយាម ' ។

គ្រឿងបរិក្ខារទាំងអស់នោះ ជាគ្រឿងបរិហារកាយ ក៏បាន បរិហារពោះក៏បាន ។ បើមានពាក្យសួរ ថា ' គ្រឿងបរិក្ខារទាំងឡាយនោះ ជាគ្រឿងបរិហារកាយ បរិហារពោះ

បាន យ៉ាងដូចម្តេច ? ’ ។ គប្បីឆ្លើយថា ‘ នឹងពណ៌នាចីវរមុន, ចីវរ រមែងបរិហារ គឺ ចិញ្ចឹម នូវរាងកាយ ក្នុងពេលដែលស្លៀក និង គ្រងហើយត្រាច់ទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ជាគ្រឿងបរិហារនូវរាងកាយ, ចីវរ រមែងបរិហារ គឺ ចិញ្ចឹមនូវពោះ ក្នុងពេលដែលយកជាយចីវរ មកត្រងទឹកហើយឆាន់ និងក្នុងពេលដែលវៃចខ្ចប់ផ្លែឈើដែលត្រូវឆាន់ ដោយជាយចីវរនុ៎ះ យកទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ជាគ្រឿងបរិហារនូវពោះ ។ ចំណែកបាត្រ ក៏ជាគ្រឿងបរិហារ នូវរាងកាយ ក្នុងពេលដែលយកបាត្រនោះ មកដងទឹកហើយស្រង់ និង ក្នុងពេលដែលយកបាត្រនោះទៅដងទឹកហើយ ធ្វើការប្រោះព្រំនូវកុដិ, បាត្រជាគ្រឿងបរិហារនូវពោះ ក្នុងពេលដែលទទួលអាហារ ដោយបាត្រនោះហើយ យកមកឆាន់ ។ ឯកាំបិតព្រា រមែងជាគ្រឿងបរិហារនូវរាងកាយ ក្នុងពេលដែលចិតឈើជម្រះធ្មេញ និង ក្នុងពេលដែលធ្វើជើងគ្រែ កៅអី (តាំង) និង ដងក្រុត, កាំបិតព្រារមែងជាគ្រឿងបរិហារនូវពោះ ក្នុងពេលដែលកាប់អំពៅ និងបកផ្លែដូងជាដើម ។ ចំណែកម្ជុល ជាគ្រឿងបរិហារនូវរាងកាយ ក្នុងពេលដែលដេរចីវរ ជាគ្រឿងបរិហារពោះ ក្នុងពេលដែលចាក់នំ ឬ ផ្លែឈើហើយឆាន់ ។ សូម្បីវត្ថុពន្ធន៍ចង្កេះ

ក៏ជាគ្រឿងបរិហាររាងកាយ ក្នុងពេលដែលក្រវាត់ហើយគ្រាច់ទៅ ជាគ្រឿងបរិហារពោះ ក្នុងពេលដែលចងនូវវត្ថុទាំងឡាយ មានអំពៅជាដើមហើយ កាន់យកទៅ ។ ចំណែកសំពត់សម្រាប់ត្រងទឹក ជាគ្រឿងបរិហាររាងកាយ ក្នុងពេលដែលត្រងទឹក ដោយសំពត់នោះហើយស្រង់ និង ក្នុងពោលដែលត្រងទឹក ដោយសំពត់នោះហើយ ធ្វើការប្រោះព្រំសេនាសនៈ, សំពត់សម្រាប់ត្រងទឹក ជាគ្រឿងបរិហារពោះ ក្នុងពេលដែលត្រងទឹកសម្រាប់ឆាន់និង ទឹកបានៈ និង ក្នុងពេលដែលវៃចខ្ចប់ នូវអង្កនិងអំបុកជាដើម ដោយសំពត់នោះឯង ហើយឆាន់ ។ នេះ គឺជាប្រមាណនៃគ្រឿងបរិក្ខារ របស់ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះឯង ។ ចំណែកភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៩ ចូលទៅកាន់ទីកន្លែងសិង (នឹងមាន) គ្រឿងកម្រាលសម្រាប់សេនាសនៈនោះ ឬ កូនសោ ក៏សមគួរ ។ ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ១០ (នឹងមាន) សំពត់និសីទនៈ ឬកំណាត់ស្បែក ក៏សមគួរ ។ ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ១១ (នឹងមាន) ឈើច្រត់សម្រាប់មនុស្សឆ្លាស់ ឬ ត្រឡោកប្រែង ក៏គួរ ។ ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ១២ (នឹងមាន) ឆត្រ ឬ ទ្រនាប់ជើង ក៏សមគួរ ។ ក៏បណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកមានគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះ ឈ្មោះថា ជាអ្នកសន្តោស, ភិក្ខុទាំង

ឡាយក្រៅអំពីនេះ គឺអ្នកណាមួយ ក៏មិនគួរពោលថា 'ជាអ្នកមិនសន្តោស ជាអ្នកមានសេចក្តីប្រាថ្នាច្រើន ជាអ្នកស្វែងរកធំ' ដូច្នេះឡើយ ។ ភិក្ខុទាំងឡាយទាំងពួងនេះ ជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកដែលគេចិញ្ចឹមងាយ ជាអ្នកមានសេចក្តីប្រព្រឹត្តិស្រាល មែនពិត" ។

(៣០២) ជីកានៃសូត្រទាំងនោះ ថា "ព្រះអដ្ឋកថាចារ្យ កាលសំដែង ថា 'ការប្រមូលបរិក្ខារក្រៅអំពីនោះ ចូលក្នុងចំណោមនៃបរិក្ខារទាំងឡាយ ៨ រមែងមានព្រម ដោយមិនប្លែកគ្នា ដោយកិរិយាចោទ ក្នុងហេតុត្រឹមតែចីវរ និង បិណ្ឌបាតទាំងឡាយ ជាគ្រឿងបរិហារនូវកាយ និងពោះ ដោយលំដាប់' ដូច្នេះ ទើបពោលនូវពាក្យ ថា 'ភិក្ខុទាំងអស់នោះ' ដូច្នេះជាដើម ។

បទថា 'ឯតេបិ' ជាដើម អធិប្បាយថា សូម្បីភិក្ខុទាំងឡាយ អ្នកមានបរិក្ខារ ៩ ជាដើម ក៏ឈ្មោះថា ជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ដូចគ្នាដែរ, ព្រោះថា នឹងចាត់ថា ជាអ្នកមានសេចក្តីប្រាថ្នាច្រើន ឬ ជាអ្នកមិនសន្តោស ដោយគ្រឿងបរិក្ខារមានប្រមាណប៉ុណ្ណោះ ក៏មិនបានឡើយ" ។

នំយមកក្នុងអដ្ឋកថានៃសូត្រ នោះៗ ថា "ក៏ភិក្ខុអ្នកមានបរិក្ខារ ៨ វេចខ្ចប់នូវកូនកាំបិតតូច (កាំបិតកោរ) និង ម្ជុល

ក្នុងសំពត់សម្រាប់ត្រងទឹកហើយ ដាក់ខាងក្នុងនៃបាត្រ ស្តាយបាត្រ ដាក់លើចុងស្មារ ស្លៀកនិងត្រងត្រៃចីវរ ចងវត្ថុពន្ធន៍ចង្កេះហើយ ចៀសចេញទៅ យ៉ាងសុខសប្បាយ តាមសេចក្តីប្រាថ្នា ។ ភិក្ខុនោះ ឈ្មោះថា មិនចាំបាច់ត្រឡប់មកយកអ្វីទៀតឡើយ ។ ព្រោះហេតុនោះ ទេសនា ក្នុងសាមញ្ញផលសូត្រជាដើម មកហើយ ដោយអំណាចភិក្ខុអ្នកមានបរិក្ខារ ៨ ប៉ុណ្ណោះ, មិនមែនមកដោយអំណាចនៃពួកភិក្ខុ អ្នកមានបរិក្ខារ ៩ ជាដើមឡើយ ” ។

(៣០៣) សេចក្តីសន្តោស មានដល់ទៅ ១២ យ៉ាង ក៏ពិតមែនហើយ, ទោះជាដូច្នោះ ដោយសង្ខេប មាន ៣ យ៉ាង ដោយអំណាចសេចក្តីសន្តោសតាមមានតាមបាន សន្តោសតាមកម្លាំង និងសន្តោសតាមសមគួរ ។ ភិក្ខុអ្នកត្រេកអរ ដោយបច្ច័យទាំងឡាយ ៣ យ៉ាងនោះ ឈ្មោះថា ជាអ្នកត្រេកអរ ដោយបច្ច័យតាមល្មមសមគួរ ។ ដោយហេតុនោះ ក្នុងអដ្ឋកថានៃអរិយវង្ស ៤ ក្នុងសង្គីតិសូត្រ និង ក្នុងអដ្ឋកថានៃអរិយវង្សសូត្រ ក្នុងបឋមបណ្ណាសកៈ នៃចតុក្កនិបាត អង្គុត្តរនិកាយ ព្រះអដ្ឋកថាចារ្យពោលហើយ ថា “ខ្ញុំសំដៅយកសេចក្តីសន្តោសទាំងឡាយ ៣ យ៉ាងនេះ ទើបពោលថា ‘ភិក្ខុជាអ្នកសន្តោស គឺជាអ្នកសន្តោស ដោយចីវរ តាមល្មមសមគួរ គឺបណ្តាចីវរទាំងឡាយតាមដែលបានហើយ

ជាដើម ដោយចីវរយ៉ាងណាមួយ ដូច្នេះ ។

ដីកានៃអរិយវង្សចតុក្កៈ ក្នុងសង្គីតិសូត្រនិងអរិយវង្សសូត្រ នោះ ថា "ពាក្យថា **ឥមេ តយោ សន្តោសេ** នេះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ដោយអំណាចសេចក្តីសន្តោសទាំង ៣ យ៉ាង ជាទីរួបរួមនៃសេចក្តីសន្តោសគ្រប់បែបយ៉ាង ។ ក៏ព្រះអដ្ឋកថាចារ្យ បំព្រួញនូវគិលានបច្ច័យ ខាងមុខ ចូលក្នុងបិណ្ឌបាត យ៉ាងដូច្នេះហើយ ពោលសេចក្តីសន្តោស ឯណា គ្រប់ ៥០ យ៉ាង គឺ សេចក្តីសន្តោស ក្នុងចីវរ ២០, សន្តោស ក្នុងបិណ្ឌបាត ១៥, សន្តោស ក្នុងសេនាសនៈ ១៥, សេចក្តីសន្តោសទាំងអស់នោះ រមែងដល់នូវការសង្គ្រោះ គឺ ការរួបរួមចូល ក្នុងសេចក្តីសន្តោសទាំងឡាយ ៣ យ៉ាងនេះឯង តាមសមគួរ ។

(៣០៤) អដ្ឋកថានៃសង្គីតិសូត្រ និង ចតុក្កនិបាត នៃអង្គុត្តរនិកាយ ថា "ក៏សេចក្តីសន្តោស ក្នុងចីវរ មាន ២០ យ៉ាង គឺ សេចក្តីសន្តោស ក្នុងការត្រិះរិះ, សន្តោស ក្នុងការដើរផ្លូវ, សន្តោស ក្នុងការស្វែងរក, សន្តោស ក្នុងការបានចំពោះ, សន្តោស ក្នុងការទទួលល្មមតាមប្រមាណ, សន្តោស ក្នុងការវៀរចាកអំពីសេចក្តីឡូឡា, សន្តោសតាមមានតាមបាន, សន្តោសតាមកម្លាំង, សន្តោសតាមសមគួរ, សន្តោស ក្នុងទឹក, សន្តោស

ក្នុងការលាងជម្រះ, សន្តោស ក្នុងការធ្វើ, សន្តោស ក្នុងការប៉ាន់ប្រមាណ, សន្តោស ក្នុងអំបោះ, សន្តោស ក្នុងការដេរ, សន្តោស ក្នុងការជ្រលក់, សន្តោស ក្នុងការធ្វើកប្បៈ, សន្តោស ក្នុងការប្រើប្រាស់, សន្តោស ក្នុងការរៀរចាកការសន្សំ និង សន្តោស ក្នុងការលះបង់ ។ បណ្តាសេចក្តីសន្តោសទាំង ២០ យ៉ាងនោះ ភិក្ខុអ្នកមានសេចក្តីត្រេកអរ នៅចាំវស្សា រហូតត្រៃមាសហើយ ត្រិះរិះ ត្រឹមតែមួយខែ ក៏សមគួរ ។ ព្រោះថា ភិក្ខុនោះ បវារណាចេញវស្សាហើយ រមែងធ្វើនូវចីវរ ក្នុងខែដែលជាទីកើតឡើងនៃចីវរ ។ ភិក្ខុអ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត រមែងធ្វើបាន ដោយកន្លះខែតែប៉ុណ្ណោះឯង ។ កិរិយាត្រិះរិះ អស់កាលត្រឹមតែមួយខែ ឬកន្លះខែ យ៉ាងដូច្នេះ ឈ្មោះថា វិតក្កសន្តោស ។

(៣០៥) ក៏ភិក្ខុអ្នកត្រេកអរហើយ ដោយវិតក្កសន្តោស គប្បីដូចជាព្រះថេរៈ អ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត ដែលនៅក្នុងបាចីនខណ្ឌរាជីវិហារ ។

(រឿងព្រះថេរៈអ្នកទ្រទ្រង់សំពត់បំសុកូលជាវត្ត)

បានឮមកថា ព្រះថេរៈ និមន្តមកហើយ ដោយនឹកគិត ថា

'អាត្មាអញ នឹងថ្វាយបង្គំនូវព្រះចេតិយ ក្នុងចេតិយបព៌តវិហារ' ដូច្នេះ ថ្វាយបង្គំចេតិយហើយ ក៏គិតថា 'ចីវរ របស់អាត្មាអញ ចាស់ហើយ, អាត្មាអញ នឹងបាន ក្នុងទីជាទីនៅ នៃភិក្ខុទាំងឡាយ ដែលច្រើន' ។ ភិក្ខុអង្គនោះ និមន្តទៅកាន់មហាវិហារ ជួបនឹងព្រះសង្ឃត្ថេរហើយ សួរទីជាទីនៅហើយ នៅក្នុងមហាវិហារនោះ លុះស្អែកឡើង ទើបបានយកចីវរមកហើយ ថ្វាយបង្គំព្រះថេរៈ ។

ព្រះថេរៈសួរថា 'ម្នាលលោកដ៏មានអាយុ មានហេតុអ្វី ?' ។

ភិក្ខុនោះ ឆ្លើយថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា នឹងនិមន្តទៅកាន់មាត់ទ្វារនៃផ្ទះ' ។

ព្រះថេរៈ ពោលថា 'ម្នាលអាវុសោ ឯខ្ញុំក៏នឹងទៅដែរ' ។

ភិក្ខុនោះ ទទួលថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ល្អណាស់' ដូច្នេះហើយ ក៏និមន្តទៅឈរនៅ ក្បែរស៊ុមមាត់ទ្វារ នៃមហាពោធិ៍ គិតថា 'អាត្មាអញ នឹងបាននូវចីវរដែលជាទីពេញចិត្ត ក្នុងទីជាទីនៅ នៃអ្នកមានបុណ្យទាំងឡាយ' ដូច្នេះហើយ គិតថា 'សេចក្តីត្រិះរិះ របស់អាត្មាអញ មិនបរិសុទ្ធឡើយ' ហើយ ទើបត្រឡប់ចេញអំពីទីនោះឯង, លុះដល់ព្រឹកឡើង ភិក្ខុនោះ ក៏និមន្តទៅកាន់ទីជិតនៃទីទួលឈ្មោះបេណ្ឌាម្ពៈ, ថ្ងៃស្អែកឡើង បានត្រឡប់មកពីទ្វារនៃទិសឧត្តរ នៃមហាចេតិយ យ៉ាងដូច្នោះដែរ សូម្បីក្នុងថ្ងៃទី ៤

ក៏បាននិមន្តទៅហើយ កាន់សំណាក់នៃព្រះថេរៈ ។ ព្រះថេរៈគិតថា 'សេចក្តីត្រិះរិះ របស់ភិក្ខុរូបនេះ នឹងមិនបរិសុទ្ធ' ហើយកាន់យកចីវរ សួរបញ្ហា និមន្តទៅផ្ទះ ព្រមជាមួយនឹងភិក្ខុរូបនោះឯង ។

ក៏ក្នុងរាត្រីនោះ មនុស្សម្នាក់ ត្រូវខ្មួចរៈជាប់ចំពាក់ហើយ (ក្តៀនលាមក) បានបន្ទោបង់ខ្មួចរៈដាក់ លើសំពត់សាដកនេះឯង ហើយបានចោលសំពត់សាដកនោះ ក្នុងទីគំនរនៃសង្រ្កាម ។ ព្រះថេរៈ អ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត បានឃើញនូវសំពត់សាដកនោះ ដែលមានសត្វរុយក្បាលខៀវទាំងឡាយ ទំរោមជុំជិតអស់ហើយ ទើបបានផ្គងនូវអញ្ជលីឡើង ។

ព្រះមហាថេរៈ សួរថា 'ម្នាលអ្នកដ៏មានអាយុ ព្រោះហេតុអ្វី បានជាលោកផ្គង នូវអញ្ជលី ចំពោះទីជាទីចោលនៃសង្រ្កាម ?' ។

ព្រះថេរៈអង្គនោះ ឆ្លើយថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា មិនបានផ្គងអញ្ជលី ចំពោះទីជាទីចោលសង្រ្កាមទេ, ខ្ញុំព្រះករុណា បានផ្គងអញ្ជលី ចំពោះព្រះទសពល ដែលជាព្រះបិតា របស់ខ្ញុំព្រះករុណាទេតើ, បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះទសពល ព្រះអង្គទ្រង់រលាស់ចោល នូវសត្វតូចតាចទាំងឡាយ ដែលមានប្រមាណ ១ តុម្ពៈ ហើយទ្រង់កាន់យកនូវសំពត់បង្សុកូលដែលគេរុំព័ទ្ធ (រាងកាយ) របស់នាងបុណ្ណទាសី (យកទៅ) បោះ

ចោលហើយ អំពីព្រៃខ្មោច ទ្រង់ធ្វើកម្មដែលគេធ្វើបានដោយក្រ' ។ ព្រះមហាថេរៈ គិតហើយ ថា 'សេចក្តីត្រិះរិះ របស់ព្រះថេរៈដែលមានកិរិយាទ្រទ្រង់ នូវសំពត់បង្សុកូលជាវត្ត បរិសុទ្ធហើយ' ។ ឯព្រះថេរៈអ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត បានឈរនៅហើយ ក្នុងទីនោះឯង ចំរើនវិបស្សនា ក៏បានសម្រេចផល ៣ ហើយ កាន់យកនូវសំពត់សាងកនោះ មកធ្វើជាចីវរ គ្រងហើយ ក៏បាននិមន្តទៅ កាន់បាចីនខណ្ឌរាជីវិហារ បានសម្រេចព្រះអរហត្ត ដែលមានផលដ៏ប្រសើរហើយ ។

(៣០៦) ក៏ការដែលភិក្ខុនិមន្តទៅ ដើម្បីប្រយោជន៍ដល់ចីវរ មិនបានគិតថា 'អាត្មាអញ នឹងបាន ក្នុងទីណាមួយហ្ន៎?' ហើយ និមន្តទៅដោយយកកម្មដ្ឋានជាធំប៉ុណ្ណោះ ឈ្មោះថា សន្តោសក្នុងការដើរផ្លូវ ។ ក៏ការដែលភិក្ខុស្វែងរក (ចីវរ) មិនបានស្វែងរក ព្រមជាមួយនឹងភិក្ខុសាមញ្ញធម្មតាឡើយ បាននាំយកភិក្ខុអ្នកមានសេចក្តីអៀនខ្មាស មានសីលជាទីស្រឡាញ់ទៅហើយ ស្វែងរក ឈ្មោះថា សន្តោសក្នុងការស្វែងរក ។ ការដែលភិក្ខុស្វែងរក យ៉ាងដូច្នេះ ឃើញនូវចីវរដែលទាយកនាំយកមក អំពីទីឆ្ងាយនុ៎ះឯង មិនបានត្រិះរិះ យ៉ាងនេះ ថា 'ចីវរនោះ នឹងជាទីពេញចិត្ត, ចីវរនោះ នឹងមិនជាទីពេញចិត្ត' ហើយត្រេកអរ ក្នុង

ចីវរដែលគ្រោតគ្រាតនិងប្រណីតជាដើម ដោយចីវរតាមដែលខ្លួនបានហើយ យ៉ាងណាប៉ុណ្ណោះ ឈ្មោះថា សន្តោក្នុងការបានចំពោះ ។ ការដែលភិក្ខុ សូម្បីកាន់យកនូវចីវរដែលខ្លួនបានហើយ យ៉ាងដូច្នោះ ត្រេកអរ ដោយចីវរត្រឹមតែល្មមគ្រប់គ្រាន់ ដល់ខ្លួនឯង ថា 'សំពត់មានប្រមាណប៉ុណ្ណោះ នឹងមាន ដើម្បីចីវរ ២ ជាន់, សំពត់មានប្រមាណប៉ុណ្ណោះ នឹងមាន ដើម្បីចីវរ ១ ជាន់' ដូច្នេះ តែប៉ុណ្ណោះ ឈ្មោះថា សន្តោសក្នុងការកាន់យកតែល្មមប្រមាណ ។ មួយទៀត ការដែលភិក្ខុស្វែងរកចីវរ មិនគិតថា 'អាត្មាអញ នឹងបាននូវចីវរដែលជាទីពេញចិត្ត ត្រង់មាត់ទ្វារផ្ទះ នៃបុគ្គលឈ្មោះនុ៎ះ' ដូច្នេះហើយ និមន្តទៅតាមលំដាប់ទ្វារ ឈ្មោះថា សន្តោសក្នុងការរៀរចាកសេចក្តីឡូឡា ។ ការដែលភិក្ខុអាចញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយបណ្តាចីវរដែលសៅហ្មងឬប្រណីត ចីវរណាមួយ ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយចីវរតាមដែលខ្លួនបានហើយយ៉ាងណានុ៎ះឯង ឈ្មោះថា សន្តោសក្នុងបច្ច័យតាមដែលខ្លួនបានហើយ ។ ការដែលដឹងនូវកម្លាំង របស់ខ្លួនហើយ ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយចីវរដែលជាគ្រឿងអាច ដើម្បីនឹងឲ្យប្រព្រឹត្តទៅបាន ឈ្មោះថា សន្តោសក្នុងបច្ច័យតាមកម្លាំង ។ ការដែលភិក្ខុប្រគេន នូវចីវរដែលជាទីពេញចិត្ត ដល់ភិក្ខុដទៃ

ហើយ ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយចីវរឯណាមួយ រមស់ខ្លួន ឈ្មោះថា សន្តោសក្នុងបច្ច័យតាមសមគួរ ។ ការមិនជ្រើសរើសថា 'ទឹកក្នុងទីណា ជាទីពេញចិត្ត, ក្នុងទីណា មិនជាទីពេញចិត្ត' ដូច្នេះហើយ បោកដោយទឹកដែលសមគួរនឹងបោកបាន ឯណាមួយ ឈ្មោះថា សន្តោសក្នុងទឹក ។ ក៏ការដែលភិក្ខុរៀរចាកទឹកដែលសៅហ្មង (កករល្អក់) ដោយជីលៀង ជ័រឈើ និងទឹកដែលមានស្លឹកឈើស្អុយ ទើបសមគួរ ។ ក៏ការដែលភិក្ខុបោក (ចីវរ) មិនយកកំណាត់ឈើជាដើមដំហើយ បោកច្របាច់ ដោយដៃ ឈ្មោះថា សន្តោសក្នុងការបោក ។ មួយទៀត ការដែលភិក្ខុបោកចីវរដែលមិនស្អាត សូម្បីដោយទឹកដែលគេដាក់ស្លឹកឈើហើយ ដាំទឹកឱ្យក្តៅ (ស្ងោរ) ក៏សមគួរ ។ ការដែលភិក្ខុបោកធ្វើ យ៉ាងដូច្នេះ មិនញុំាងចិត្តឱ្យកម្រើក ថា 'ចីវរនេះ គ្រោតគ្រាត, ចីវរនេះ ហ្មត់ល្អ' ដូច្នេះហើយ ធ្វើដោយទំនងដែលសមល្មមនុ៎ះឯង ឈ្មោះថា សន្តោសក្នុងការធ្វើ ។ ការធ្វើចីវរគ្រាន់តែល្មមសមគ្នានឹងបិទបាំងមណ្ឌលទាំង ៣ ឈ្មោះថា សន្តោសក្នុងការធ្វើឱ្យសមប្រមាណ ។ មួយទៀត ការដែលភិក្ខុមិនត្រាច់ទៅ ដោយគិតថា 'អាត្មាអញនឹងស្វែងរកអំបោះ ដែលជាទីពេញចិត្ត ដើម្បីនឹងធ្វើចីវរ' ដូច្នេះហើយ កាន់យកអំបោះបែបណាមួយនុ៎ះឯង ដែលបុគ្គលនាំយកមក

តាំងទុកហើយ ត្រង់ទីទាំងឡាយមានថ្ពល់ជាដើម ឬ ទេវដ្ឋាន ឬ ដែលបុគ្គលនាំមកតាំងទុកហើយ ក្បែរជើង ហើយធ្វើ ឈ្មោះថា សន្តោសក្នុងអំបោះ ។ ក៏ក្នុងវេលាដែលភ្ជាប់សំពត់កុសិ គប្បីចោះ (ដេរ) ៧ ដង ក្នុងទីប្រមាណមួយចង្កុលដៃ ។ ព្រោះថា កាលបើភិក្ខុធ្វើ យ៉ាងដូច្នេះ, ភិក្ខុរូបណា ដែលមិនមែនជាសំឡាញ់, សូម្បីវត្តកេទ រមែងមិនមាន ដល់ភិក្ខុរូបនោះ ។ តែសូម្បីក្នុងទីប្រមាណ ៣ អង្គុលី ក៏គប្បីចោះ (ដេរ) ៧ ដង ។ កាលបើភិក្ខុធ្វើ យ៉ាងដូច្នេះ, សូម្បីភិក្ខុអ្នកដើរផ្លូវ ក៏គប្បីជាសំឡាញ់បានដោយពិត ។ ភិក្ខុរូបណា មិនជាសំឡាញ់, វត្តកេទ ក៏មិនមាន ដល់ភិក្ខុរូបនោះ ។ កិរិយាធ្វើនេះ ឈ្មោះថា សន្តោសក្នុងការដេរ ។ ក៏ភិក្ខុកាលនឹងជ្រលក់ (ចីវរ) មិនគួរដើរស្វែងរកនូវទឹកជ្រលក់ទាំងឡាយ មានទឹកជ្រលក់ដើមជ្រៃខ្មៅជាដើមឡើយ ។ បណ្តាទឹកជ្រលក់ទាំងឡាយ មានទឹកជ្រលក់ដើមកន្ធតជាដើម ភិក្ខុនោះ បាននូវទឹកជ្រលក់បែបណា, ក៏គប្បីជ្រលក់ ដោយទឹកជ្រលក់នោះ ។ ភិក្ខុកាលបើមិនបាន (ដូច្នោះ) ទេ គប្បីកាន់យកនូវទឹកជ្រលក់ ដែលពួកមនុស្ស កាន់យកនូវក្រែចៅ ក្នុងព្រៃហើយទម្លាក់ចោល ឬក៏ កាកដែលពួកភិក្ខុស្ងោរហើយចោល ហើយទើបជ្រលក់ ។ ការធ្វើយ៉ាងនេះ ឈ្មោះថា សន្តោសក្នុងទឹកជ្រលក់ ។

ការដែលភិក្ខុកាន់យកចណ្តាពណ៌ខៀវ ពណ៌ភក់ ពណ៌ខ្មៅ និងពណ៌ខ្មៅស្នេរខៀវ ពណ៌ឯណាមួយហើយ ធ្វើកប្បពិន្ទុ ដែលប្រាកដមាន ដល់បុគ្គលអ្នកអង្គុយលើខ្នងដំរី ឈ្មោះថា សន្តោសក្នុងការធ្វើកប្បពិន្ទុ ។ ការប្រើប្រាស់ ដោយអំណាចល្មមគ្រាន់តែនឹងបិទបាំងនូវអវយវៈ ដែលញ៉ាំងសេចក្តីអៀនខ្មាស ឲ្យកម្រើកប៉ុណ្ណោះ ឈ្មោះថា សន្តោសក្នុងការប្រើប្រាស់ ។

ព្រះមហាសិវត្ថេរ ពោលថា ‘ក៏ការដែលភិក្ខុ បាននូវសំពត់ហើយ តែនៅមិនទាន់បាននូវអំបោះ ឬម្ជុល ឬអ្នកធ្វើ នឹងទុកសិនក៏សមគួរ, កាលបើបាននូវអំបោះជាដើមនោះ នឹងទុកសិនមិនសមគួរ ។ សូម្បីចីវរដែលបានធ្វើហើយ បើភិក្ខុនោះ ជាអ្នកប្រាថ្នាចង់ឲ្យ ដល់សហធម្មិកទាំងឡាយ មានអន្តេវាសិកជាដើម, ក៏សហធម្មិកទាំងឡាយ មានអន្តេវាសិកជាដើមនោះ ជាអ្នកមិនទាន់មកជុំគ្នាទេ, នឹងរក្សាទុកសិន រហូតដល់មក (ជុំគ្នា) ក៏សមគួរ, កាលបើអន្តេវាសិកជាដើមនោះ គ្រាន់តែមកដល់ហើយ, គប្បីឲ្យដោយពិត, កាលបើមិនអាចដើម្បីនឹងឲ្យទេ, គប្បីអធិដ្ឋានទុកសិន ។ កាលបើចីវរដទៃមិនមានទេ, នឹងអធិដ្ឋានសូម្បីនូវសំពត់សម្រាប់ក្រាលសិង ក៏សមគួរ ។ ព្រោះថា ចីវរដែលមិនបានអធិដ្ឋានហើយនុ៎ះឯង រមែងជាសន្និធិ (ការសន្សំទុក) ដោយពិត ។

ចីវរដែលបានអធិដ្ឋានហើយ មិនមែនជាសន្និធិឡើយ' ដូច្នេះ ។ ការធ្វើនេះ ឈ្មោះថា សន្តោសក្នុងកិរិយាវៀរចាកការសន្សំទុក ។ មួយទៀត ភិក្ខុកាលនឹងលះបង់ មិនគប្បីឲ្យ ព្រោះយល់មុខឡើយ, គប្បីតាំងនៅ ក្នុងសារាណីយធម៌ហើយ ទើបលះឲ្យ ដូច្នេះ ការធ្វើនេះ ឈ្មោះថា ជាសន្តោសក្នុងការលះបង់ ។

(សន្តោស ក្នុងបិណ្ឌបាត ១៥ យ៉ាង)

ចំណែកសេចក្តីសន្តោស ក្នុងបិណ្ឌបាត មាន ១៥ យ៉ាង គឺ វិតក្កសន្តោស គមនសន្តោស បរិយេសនសន្តោស បដិលាភសន្តោស បដិគ្គហាណសន្តោស មត្តបដិគ្គហាណសន្តោស លោលុប្បវិវជ្ជន-សន្តោស យថាលាភសន្តោស យថាពលសន្តោស យថាសារុប្ប-សន្តោស ឧបការសន្តោស បរិមាណសន្តោស បរិភោគសន្តោស សន្និធិបរិវជ្ជនសន្តោស និង វិស្សជ្ជនសន្តោស ។

បណ្តាសេចក្តីសន្តោសទាំង ១៥ យ៉ាងនោះ ភិក្ខុអ្នកត្រេកអរ លប់មុខហើយ រមែងត្រិះរិះ ។ ក៏ភិក្ខុអ្នកមានកិរិយាត្រាច់ទៅ បិណ្ឌបាតជាវត្ត និមន្តទៅ ជាមួយនឹងពួកគណៈហើយ ក្នុងពេលឧបដ្ឋាកព្រះថេរៈ ក្នុងវេលាល្ងាច, កាលបើព្រះថេរៈសួរថា' ក្នុងថ្ងៃស្អែកនេះ ពួកយើង នឹងទៅបិណ្ឌបាត ក្នុងទីណា ? ' ដូច្នេះ,

ពោលថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ពួកយើង នឹងទៅបិណ្ឌបាត ក្នុងស្រុកនោះ' ដូច្នេះ នឹកគិតនូវទីមានប្រមាណប៉ុណ្ណោះ ចាប់ដើមអំពីទីនោះទៅ មិនគួរត្រិះរិះឡើយ ។ ភិក្ខុអ្នកស្រាច់ទៅតែម្នាក់ឯង គប្បីឈរត្រិះរិះ ក្នុងរោងសម្រាប់ត្រិះរិះ ។ ភិក្ខុកាលបើត្រិះរិះ ចាប់ដើមអំពីទីនោះទៅ រមែងជាអ្នកឃ្លាត មាននៅខាងក្រៅ អំពីអរិយវង្ស ។ នេះ ឈ្មោះថា សន្តោសក្នុងការត្រិះរិះ ។ ក៏ភិក្ខុ ចូលទៅដើម្បីបិណ្ឌបាត មិននឹកគិត ថា 'អាត្មាអញ នឹងបាន ក្នុងទីណា ?' ដូច្នេះ គប្បីនិមន្តទៅ ដោយគិតយកកម្មដ្ឋានជាធំ ។ នេះ ឈ្មោះថា សន្តោសក្នុងការធ្វើដំណើរ ។ ភិក្ខុកាលស្វែងរក មិនត្រូវនាំយកភិក្ខុធម្មតាសាមញ្ញទៅទេ គប្បីនាំយកភិក្ខុអ្នកមានសេចក្តីអៀនខ្មាស មានសីលជាទីស្រឡាញ់ទៅស្វែងរកប៉ុណ្ណោះ ។ នេះ ឈ្មោះថា សន្តោសក្នុងការស្វែងរក ។ ភិក្ខុឃើញទាយកនាំយកអាហារមក អំពីទីឆ្ងាយ មិនគប្បីញុំងចិត្តឲ្យកើតឡើង ថា 'អាហារនុ៎ះ ជាទីពេញចិត្ត, អាហារនុ៎ះ មិនជាទីពេញចិត្ត' ។ នេះ ឈ្មោះថា សន្តោសក្នុងការបានចំពោះ ។ ភិក្ខុមិនគួរគិត ថា 'អាត្មាអញ នឹងទទួលនូវបិណ្ឌបាត ដែលជាទីពេញចិត្តនេះ, នឹងមិនទទួលបិណ្ឌបាត ដែលមិនជាទីពេញចិត្តនេះ' ដូច្នេះហើយ គប្បីទទួលនូវបិណ្ឌបាត ឯណាមួយ ដែលល្មមគ្រាន់

នឹងញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។ នេះ ឈ្មោះថា សន្តោសក្នុងការទទួលយក ។

មួយទៀត ក្នុងបិណ្ឌបាតនេះ ទេយ្យធម៌ មានច្រើន, តែទាយកប្រាថ្នានឹងប្រគេនបន្តិចបន្តួច, ភិក្ខុគួរទទួលតែបន្តិចបន្តួច ។ សូម្បីតែទេយ្យធម៌ មានច្រើន, ទាំងទាយក ក៏ជាអ្នកប្រាថ្នានឹងប្រគេនច្រើន, ភិក្ខុគប្បីទទួល តែល្មមប្រមាណប៉ុណ្ណោះ ។ ទេយ្យធម៌ មានមិនច្រើន, ទាំងទាយក ជាអ្នកប្រាថ្នានឹងប្រគេនតែបន្តិចបន្តួច, ភិក្ខុគប្បីទទួលតែបន្តិចបន្តួច ។ ទេយ្យធម៌ មានមិនច្រើន, តែទាយក ប្រាថ្នានឹងប្រគេនច្រើន, ភិក្ខុគប្បីទទួលតែល្មមប្រមាណប៉ុណ្ណោះ ។ ព្រោះថា ភិក្ខុកាលមិនដឹងនូវប្រមាណ ក្នុងការទទួល រមែងកំចាត់សេចក្តីជ្រះថ្លា របស់មនុស្សទាំងឡាយ ឲ្យខូចខាតទៅ រមែងញុំាងទានដែលគេគប្បីប្រគេនដោយសទ្ធា ឲ្យធ្លាក់ចុះទៅ រមែងមិនធ្វើតាមពាក្យប្រៀនប្រដៅ រមែងមិនអាច ដើម្បីផ្គងចិត្ត សូម្បីនៃមាតាបង្កើតបានឡើយ ។ លុះត្រាតែដឹងនូវប្រមាណនុ៎ះឯង ហើយទើបគួរទទួល យ៉ាងនេះ ព្រោះហេតុដូច្នេះ នេះ ឈ្មោះថា សន្តោសក្នុងការទទួលតែល្មមប្រមាណ ។ ភិក្ខុមិនគួរនិមន្តទៅ កាន់ត្រកូលដែលស្មុកស្មម្តែប៉ុណ្ណោះ គប្បីនិមន្តទៅ តាមលំដាប់ទ្វារ ។ នេះ ឈ្មោះថា

សន្តោសក្នុងការរៀរចាកការលោភលន់ចង់បានច្រើន ។ សេចក្តីសន្តោសទាំងឡាយ មានសេចក្តីសន្តោស តាមមានតាមបានជាដើម មានន័យដូចបានពោលហើយ ក្នុងចីវរនុ៎ះឯង ។ ការដឹងខ្លួបការៈយ៉ាងនេះ ថា 'អាត្មាអញ បរិភោគនូវបិណ្ឌបាតហើយ នឹងតាមរក្សានូវសមណធម៌' ដូច្នេះហើយ ទើបបរិភោគ ឈ្មោះថា សន្តោសក្នុងការដឹងខ្លួបការៈ ។ ភិក្ខុមិនគួរទទួលនូវបិណ្ឌបាត ដែលទាយកដាក់ពេញបាត្រហើយ នាំយកមក ។ កាលបើអនុបសម្បន្ន មាន, ភិក្ខុគប្បីឲ្យអនុបសម្បន្ននោះ ទទួល, បើមិនមាន អនុបសម្បន្នទេ, គប្បីឲ្យទាយកនាំយកទៅ ហើយទទួលយក នូវរបស់ដែលល្មមគ្រាន់តែទទួលប្រគេនបាន ។ នេះ ឈ្មោះថា សន្តោសក្នុងការស្គាល់ប្រមាណ ។ ការរាន់ ដោយគិត ដូច្នេះ ថា 'ការរាន់នេះ ជាហេតុបន្ទោបង់ នូវសេចក្តីស្រេកឃ្លានបាន, ការចេញចាកទុក្ខរមែងមាន ព្រោះការរាន់នេះ' ដូច្នេះ ឈ្មោះថា សន្តោសក្នុងការរាន់ ។ ភិក្ខុមិនគួរ តម្កល់ទុកហើយ ។ រាន់, អាការដូចពោលមកនេះ ឈ្មោះថា សន្តោសក្នុងការរៀរចាកការសន្សំទុក ។ ភិក្ខុមិនគួរយល់មុខហើយ តាំងនៅក្នុងសារាណីយធម៌ លះបង់ឲ្យ ។ នេះ ឈ្មោះថា សន្តោសក្នុងការលះបង់ឲ្យ ។

សូម្បីក្នុងសេនាសនៈ ក៏មានសេចក្តីសន្តោស ១៥ យ៉ាង

មានវិតក្កសន្តោសជាដើម ។ សេចក្តីសន្តោសទាំងឡាយនោះ គប្បីជ្រាប ដោយនិយ្យដូចបានពោលហើយ ក្នុងបិណ្ឌបាតនុ៎ះឯង ។ ចំណែកគិលានបច្ច័យ ចូលជាមួយគ្នានឹងបិណ្ឌបាតនុ៎ះឯង ។ ក្នុងគិលានបច្ច័យនោះ ភិក្ខុគប្បីត្រេកអរ ដោយយថាលាភសន្តោស យថាពលសន្តោស និង យថាសារុប្បសន្តោសតែប៉ុណ្ណោះ ” ។

ពណ៌នាសេចក្តីនៃការសន្តោស ១៥ យ៉ាង ចប់ ។

(៣០៧) ជីកាសង្គីតិសូត្រ និង ចតុក្កនិបាត អង្គុត្តរនិកាយ នោះ ថា “ បទថា ‘**សាទកភិក្ខុនា**’ បានដល់ ភិក្ខុដែលត្រេកអរ ចំពោះចីវរ របស់គហបតី ។ បទថា ‘**ឯកមាសមត្តំ**’ មានសេចក្តីថា ភិក្ខុនឹងត្រិះរិះ ត្រឹមតែមួយខែ ដែលដឹងថាជាខែដែលសម្រាប់ធ្វើចីវរ ក៏សមគួរ, អធិប្បាយថា ‘នឹងត្រិះរិះ ឱ្យលើសហួសអំពីនោះទៅ មិនសមគួរទេ’ ។ មែនពិត ការប្រតិបត្តិក្នុងព្រះសាសនា រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់កិរិយាគ្របសង្កត់នូវសេចក្តីចង់បាន សូម្បីនូវវត្ថុទាំងពួង ព្រោះហេតុនោះ ភិក្ខុអ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត រមែងធ្វើបាន ដោយពេលកន្លះខែប៉ុណ្ណោះ ព្រោះភាវៈនៃការបានចំពោះជារបស់ដែលមិនជាប់ជំពាក់នឹងអ្នកដទៃ ។ តែព្រះមានព្រះភាគ

ទ្រង់អនុញ្ញាត ប្រមាណមួយខែ ព្រោះការបាន របស់ភិក្ខុដែលត្រេកអរ ដោយគហបតីចីវរក្រៅនេះ ជាប់ជំពាក់នឹងអ្នកដទៃ, ការត្រិះរិះត្រឹមតែមួយខែ ឬ កន្លះខែ ដូចពណ៌នាមកនេះ ឈ្មោះថាសន្តោសក្នុងការត្រិះរិះ ព្រោះភាវៈនៃការត្រិះរិះ ប្រព្រឹត្តទៅតាមកាលវេលា គឺលោកកំណត់ហើយ ។ ភិក្ខុសូម្បីកាលប្រាថ្នានូវព្រះមហាថេរៈ ធ្វើជាសំឡាញ់ របស់ខ្លួន ក្នុងការស្វែងរកនោះ ពោលហើយ ដោយសេចក្តីគោរព យ៉ាងខ្លាំង យ៉ាងដូច្នេះ ថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា នឹងទៅកាន់ទ្វារផ្ទះ' ។ ចំណែកព្រះថេរៈ យល់អធ្យាស្រ័យ របស់ភិក្ខុនោះហើយ ពោលថា 'ម្នាលលោកដ៏មានអាយុ ចំណែកខ្ញុំ ក៏នឹងទៅដែរ' ។ ព្រះថេរៈ សួរនូវបញ្ហា ដោយគិត ថា 'ឱកាសនៃសេចក្តីត្រិះរិះ ចូរកុំមានដល់ភិក្ខុរូបនេះ' ដូច្នេះ ទើបចូលទៅកាន់ស្រុក ។

បទថា '**ឧច្ចារបលិពុទ្ធោ**' គឺ ជាអ្នកត្រូវឧច្ចារៈបៀត-បៀនហើយ ។ ក្នុងកាលនោះ ព្រះថេរៈអ្នកមានកិរិយាទ្រទ្រង់នូវសំពត់បង្សុកូលជាវត្ត ឈរនៅក្នុងទីនោះឯង ចំរើនវិបស្សនាហើយ ក៏បានសម្រេចផលទាំងឡាយ ៣ ព្រោះភាវៈនៃកិលេសទាំងឡាយ គឺលោកគ្របសង្កត់បានហើយ ព្រោះភាវៈនៃកម្លាំងរបស់បីតិ និង សោមនស្ស ដែលកើតឡើងហើយ ក្នុងព្រះតថាគត

ដោយការលើកដល់ទុក្ករកិរិយា របស់ព្រះមានព្រះភាគ ជាប្រមុខជាធម្មជាតិមានកម្លាំង ។ សូម្បីការនឹកគិត ថា 'អាត្មាអញ នឹងបាន ក្នុងទីឯណា ?' ដូច្នេះ គឺជាហេតុដំបូងនៃការប្រាថ្នានូវលោភ ព្រោះហេតុនោះ ក្នុងគមនសន្តោសនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**អចិន្តេត្វា**' ដូច្នេះ ។ នឹងចាំបាច់ពោលធ្វើអ្វី ក្នុងការនឹកគិតជាដើម យ៉ាងដូច្នេះ ថា 'អាត្មាអញ នឹងបាននូវរបស់ដែលល្អ, នឹងបាននូវរបស់ដែលជាទីពេញចិត្ត' ដូច្នេះ ។

ដើម្បីនឹងចៀសវាងនូវពាក្យសួរ ថា 'ក៏ភិក្ខុ គប្បីនិមន្តទៅយ៉ាងដូចម្តេច ?' ដូច្នេះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា '**កម្មដ្ឋានសីសេនេវ គមនំ**' ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ សំដែង ថា 'ភិក្ខុមិនគួរគិត សូម្បីនូវវត្ថុអ្វីមួយ ព្រោះអាស្រ័យចីវរឡើយ' ។ ភិក្ខុអ្នកមានសីលមិនជាទីស្រឡាញ់ គប្បីជាបច្ច័យ ក្នុងការស្វែងរកដែលមិនសមគួរ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**បេសលំ ភិក្ខុំ គហេត្វា**' ដូច្នេះ ។

បទថា '**អាហរិយមានំ**' មានសេចក្តីថា នូវសំពត់ដែលធ្លាក់ហើយ ក្នុងទីប៉ាឆា ដែលបុរសឯណាមួយ ដឹងថា 'ភិក្ខុទាំងឡាយនេះ ស្រាច់ទៅស្វែងរក នូវសំពត់បង្សុកូល' ដូច្នេះហើយ

នាំយកមក អំពីទីប៉ាវានោះ ។ ច្រើនបទថា **'ឯវំ លទ្ធំ គណ្ហន្តស្សាបិ'** មានសេចក្តីថា សូម្បីមិនញុំាងសេចក្តីសន្តោសក្នុងការបានចំពោះ ឱ្យកម្រើកឡើយ កាន់យកចីវរដែលខ្លួនបានហើយយ៉ាងដូច្នោះ ។ ២ បទថា **'អត្តនោ បហោនកមត្តេនេវ'** មានសេចក្តីថា ដោយប្រមាណដែលគ្រប់គ្រាន់ ដល់ខ្លួននុ៎ះឯង ដើម្បីប្រយោជន៍ដល់សំពត់បង្សុកូល មួយជាន់ ឬពីរជាន់ តាមដែលខ្លួនបានហើយ ។ ព្រះអដ្ឋកថាចារ្យ ហាមឃាត់ការប្រាថ្នាចំពោះ ខ្ពស់ឡើងទៅ ដោយ **ឯវ** សព្ទ ដែលជាអវធារណៈ ។ ការដែលភិក្ខុនិមន្តទៅ ដើម្បីភិក្ខា ក្នុងផ្ទះ ត្រាច់ទៅតាមលំដាប់ទ្វារ ដូចជានិមន្តទៅតាមលំដាប់នៃច្រក ឈ្មោះថា ការរៀរចាកកិរិយាលោភលន់ច្រើន ព្រោះសេចក្តីលោភលន់ច្រើន ក្នុងចីវរ គឺលោកបានលើកឡើងឆ្ងាយហើយ ។ បទថា **'យាបេតុំ'** ប្រែថា ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ។ បទថា **'ធោវនុបគេន'** ប្រែថា គួរដល់ការបោកគក់ ។ បទថា **'បណ្ណានិ'** បានដល់ស្លឹកឈើទាំងឡាយមានស្លឹកស្វាយ និងស្លឹកព្រីងជាដើម ។ បទថា **'អកោបេត្វា'** គឺ មិនញុំាងសេចក្តីសន្តោស ឱ្យកម្រើកហើយ ។ បទថា **'បហោនកនីហារេនេវ'** មានសេចក្តីថា ខ្លួនប្រាថ្នានឹងធ្វើបណ្តាត្រៃចីពរ មានសង្ឃាដជាដើម នូវរបស់ណាមួយ,

ការកាន់យក នូវសំពត់សាច់គ្រោតគ្រាត ឬសាច់ម៉ដ្ឋជាដើម តាមដែលខ្លួនបានហើយធ្វើ ដោយទំនងដែលនឹងគ្រប់គ្រាន់ ដល់ត្រៃចីវរមានស្បង់ជាដើមនោះ ។

បទថា '**តិមណ្ឌលប្បដិច្ឆាទនមត្តស្សេវ**' មានសេចក្តីថា ធ្វើចីវរល្មមគ្រាន់បិទបាំង នូវមណ្ឌប ៣ ប៉ុណ្ណោះ យ៉ាងដូច្នេះ គឺ បើសិនជាសំពត់សម្រាប់ស្លៀក បិតបាំងមណ្ឌលផ្ចិត មណ្ឌលជង្គង់, បើសិនជាសំពត់ក្រៅអំពីនេះ បិទបាំងមណ្ឌលចង្កេះ មណ្ឌលជង្គង់ ។ ក៏ប្រមាណនោះ ដោយសេចក្តី ក៏ជាប្រមាណដូចបានពោលហើយ ដោយទាបបំផុត នៃត្រៃចីវរនុ៎ះឯង ។ បទថា '**អវិចរិត្វា**' ប្រែថា មិនគ្រាច់រង្គាត់ទៅហើយ ។ បទថា '**កុសិពន្ធនកាលេ**' បានដល់ ក្នុងពេលប្រកបនូវមណ្ឌលហើយដេរបញ្ចូលជាមួយគ្នា ។ ២ បទថា '**សត្ត វារេ**' គឺ អស់វារៈដែលដេរ ៧ ដង ។

ការមិនធ្វើឱ្យប្លែកអ្វីៗ ដោយសំដែងកប្បពិន្ទុ ឈ្មោះថា សន្តោសក្នុងការធ្វើកប្បពិន្ទុ ។ ដើម្បីនឹងសំដែងប្រយោជន៍ ក្នុងការប្រើប្រាស់ចីវរ ដោយត្រង់នុ៎ះឯង ថា ' ការប្រើប្រាស់ចីវរមែងសម្រេចបាន ព្រោះឱ្យបានសម្រេចប្រយោជន៍ មានការជួយការពារនូវត្រជាក់ជាដើម ' ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា

'ហិរិកោបិនប្បដិច្ឆាទនមត្តវសេន' ដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា 'ដើម្បីគ្រាន់តែចិទ្ទបាំងអវយវៈដែលញ៉ាំងសេចក្តីអៀនខ្មាសឲ្យកម្រើក' ។ បទថា 'វដ្តតិ' មានសេចក្តីថា សេចក្តីសន្តោស រមែងមិនកម្រើកជាមុន ព្រោះមិនទាន់បានសម្ភារៈ និង ទក្ខិណេយ្យបុគ្គល ។ ២ បទថា 'សារាណីយធម្មេ ឋត្វា' មានសេចក្តីថា ស្ថិតនៅហើយ ក្នុងភាវៈជាអ្នកមានការបរិភោគ ដោយទូទៅ ជាមួយភិក្ខុទាំងឡាយដែលមានសីល ។ ភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្តរមែងត្រិះរិះ ថា 'ក្នុងថ្ងៃនេះ អាត្មាអញ នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងទីឯណាហ្ន៎ ?' ។ កាលបើព្រះថេរៈ ពោលថា 'ក្នុងថ្ងៃស្អែកនេះ ពួកយើង នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងទីឯណា ?' ដូច្នេះ, ភិក្ខុនោះ ពោលថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ពួកយើង នឹងត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងផ្ទះឈ្មោះនុ៎ះ' ។ នេះ ជាការឲ្យនូវពាក្យតប ក៏ពិតមែនហើយ, ទោះបីជាដូច្នោះ ព្រះអដ្ឋកថាចារ្យ ពោលថា 'ឯត្តកំ ចិន្តេត្វា' ដូច្នេះ ព្រោះសំដៅយកចិត្តដែលជាហេតុគិតហើយ ទើបពោល ។ ២ បទថា 'តតោ បដ្ឋាយ' មានសេចក្តីថា ចាប់ដើមតាំងអំពីពេលដែលភិក្ខុនោះ ឈរត្រិះរិះនៅ ក្នុងរោងសម្រាប់ត្រិះរិះ គឺថា បន្ទាប់

អំពីពេលនោះទៅ ។ ពាក្យថា **'អរិយវំសា ចុតោ ហោតិ'** នេះ អ្នកសិក្សាគប្បីកាន់យក ដោយអំណាច នៃភិក្ខុដែលតាំងនៅក្នុងអរិយវង្សទាំង ៣ យ៉ាង, មិនគប្បីកាន់យក ដោយអំណាចភិក្ខុដែលប្រព្រឹត្តតែម្នាក់ឯងប៉ុណ្ណោះឡើយ ។ មែនពិត ភិក្ខុទាំងអស់ ដែលតាំងនៅក្នុងអរិយវង្ស តែងបាន ដើម្បីនឹងត្រិះរិះតែមួយជងប៉ុណ្ណោះឯង, ក្រៅអំពីនោះ រមែងមិនបាន ដើម្បីនឹងត្រិះរិះឡើយ ។ បទថា **'បរិពាហិរោ'** គឺ ជាអ្នកមាននៅខាងក្រៅអំពីភាវៈជាអ្នកតាំងនៅ ក្នុងអរិយវង្ស ។ វិតក្កសន្តោសនេះនោះ រមែងមិនកម្រើក និងបរិសុទ្ធបាន ដោយការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ។ សូម្បីក្នុងសេចក្តីសន្តោសដទៃទៀតក្រៅអំពីវិតក្កសន្តោសនេះ ក៏នំយនេះដូចគ្នាដែរ ។ ដោយហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យ ពោលថា **'កម្មដ្ឋានសីសេន គន្តព្វំ'** ។ **ឯវ** សព្ទ ក្នុងបទថា **'គហេតព្វមេវ'** នេះ ប្រកបក្នុងឋានៈដែលមិនសមគួរ, គប្បីប្រកបថា **'យាបនមត្តមេវ គហេតព្វំ'** ។ បទថា **'ឯត្ថ'** គឺ ក្នុងការទទួលនូវបិណ្ឌបាតនេះ ។ បទថា **'អប្បំ'** មានសេចក្តីថា ភិក្ខុគប្បីទទួលតែបន្តិចបន្តួច សូម្បីដោយប្រមាណដែលឈ្មេមគ្រប់គ្រាន់នឹងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ នៃខ្លួន ដើម្បីញ៉ាំងចិត្ត របស់ទាយក ឲ្យត្រេកអរ ។ បទថា

'បមាណោនេវ' គឺ គប្បីទទួលតែបន្តិចបន្តួច ដោយប្រមាណដែលល្មមគ្រប់គ្រាន់នឹងញុំាងអត្តភាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។ ព្រះអដ្ឋកថាចារ្យ ដើម្បីសំដែងហេតុ ក្នុងពាក្យនេះថា **'អប្បំ គហេតព្វំ បមាណេន គហេតព្វំ'** ដូច្នេះ ទើបពោលពាក្យថា **'បដិគ្គហណស្មឹ'** ដូច្នេះជាដើម ។ បទថា **'មក្ខេតិ'** ប្រែថា រមែងកំចាត់ ។ បទថា **'វិនិបាតេតិ'** គឺ រមែងធ្វើឲ្យវិនាស ព្រោះប្រកបក្នុងឋានៈដែលមិនសមគួរ ។ បទថា **'សាសនំ'** គឺ ពាក្យប្រៀនប្រដៅ បានដល់ ពាក្យទូន្មាន របស់ព្រះសាស្តា ។ បទថា **'ន ករោតិ'** គឺ រមែងមិនប្រតិបត្តិ ។ កិរិយាគ្រាច់ទៅ តាមលំដាប់ទ្វារ ដូចជាភិក្ខុអ្នកគ្រាច់ទៅតាមលំដាប់ច្រក ឈ្មោះថា សន្តោសក្នុងការរៀរចាកសេចក្តីលោភលន់ច្រើន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា **'ទ្វារប្បដិបាដិយា គន្តព្វំ'** ។ បទថា **'ហារាបេត្វា'** បានដល់ នាំយករបស់ដែលលើសចេញ ។ ភិក្ខុរមែងរលាស់ចេញ ចាកសេចក្តីត្រេកអរ ក្នុងអាហារ ដោយការបរិភោគនោះ ហេតុនោះ ការបរិភោគនោះ ឈ្មោះថា **និស្សរណៈ** គឺ ភាពជាអ្នកមានសេចក្តីត្រូវការ ដើម្បីបន្ទោបង់នូវសេចក្តីស្រេកឃ្លាន ។ ក៏ប្រយោជន៍ មានការតាំងនៅ នៃរាងកាយជាដើម មកហើយ ដោយការដល់នូវសេចក្តីត្រូវការនុ៎ះឯង

ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា '**ជិយច្ឆាយ... សន្តោសោ នាម**' ដូច្នេះ ។ អធិប្បាយថា 'ភិក្ខុមិនគួរតម្កល់ទុកហើយ ។ បរិភោគ សូម្បីក្នុងថ្ងៃនោះ' ។ ឯប្រយោជន៍ដទៃក្រៅពីនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមហើយ ដោយសិក្ខាបទន៉ុះឯង ។ ២ បទថា '**សារាណីយធម្មេ ឱតេន**' មានសេចក្ដីថា ជាអ្នកតាំងនៅហើយ ក្នុងភាពជាអ្នកមានការបរិភោគជាសាធារណៈ ជាមួយនឹងភិក្ខុទាំងឡាយដែលមានសីល ។ ២ បទថា '**ឱណ្ឌបាតេ វុត្តនយេនេវ**' មានសេចក្ដីថា សេចក្ដីសន្តោស ក្នុងសេនាសនៈ ទាំងនោះ គប្បីជ្រាប ដោយន័យដែលបានពោលហើយ ក្នុងឱណ្ឌបាតន៉ុះឯង តាមសមគួរ ដោយន័យជាដើម ថា 'ភិក្ខុអ្នកត្រេកអរ រមែងត្រិះរិះ ថា 'ក្នុងថ្ងៃនេះ អាត្មាអញ នឹងនៅក្នុងទីឯណា ?' ដូច្នេះ ។ ភិក្ខុកាលត្រិះរិះលើសហួសអំពីនោះទៅ រមែងឃ្លាត គឺ នៅខាងក្រៅ ចាកអរិយវង្ស ។ មួយទៀត ពាក្យទាំងអស់ មានជាអាទិ៍ យ៉ាងដូច្នេះ ថា 'ភិក្ខុសូម្បីកាលស្វែងរកនូវសេនាសនៈ មិនត្រូវគិត ថា 'អាត្មាអញ នឹងបានក្នុងទីឯណា ?' ដូច្នេះ គប្បីត្រាច់ទៅ ដោយយកកម្មដ្ឋានជាធំ ប៉ុណ្ណោះ' ដូច្នេះ ក៏មានន័យដូចគ្នានឹងន័យមុនន៉ុះឯង ។

ចើមានពាក្យសួរថា 'ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ

កាលទ្រង់សំដែង នូវសេចក្តីសន្តោសក្នុងបច្ច័យ ក្នុងសង្គីតិសូត្រនេះ មិនទ្រង់កាន់យកសេចក្តីសន្តោស ក្នុងគិលានបច្ច័យផង ?' ។ ព្រះអដ្ឋកថាចារ្យ កាលសំដែង (ពាក្យឆ្លើយ) ថា 'ក៏រឿងនោះ លោកមិនត្រូវយល់ឃើញយ៉ាងនោះទេ' ទើបពោល ថា '**គិលានប្បច្ចយោ បន បិណ្ឌបាតំយេវ បវិដ្ឋោ**' ដូច្នេះ ។ អធិប្បាយថា 'ព្រោះភាវៈនៃគិលានប្បច្ច័យនោះ ជារបស់ស្មើគ្នា (នឹងបិណ្ឌបាត) ដោយភាពជារបស់ដែលភិក្ខុគប្បីលេបចូលទៅ' ។

បើមានពាក្យចោទសួរ ថា 'បើសិនជាមាន ការប្រកាន់យកសេចក្តី យ៉ាងដូច្នោះ, គប្បីប្រាថ្នាសេចក្តីសន្តោស ១៥ យ៉ាង មានវិតក្កសន្តោសជាដើមផង សូម្បីក្នុងគិលានប្បច្ច័យនោះ ដូចជាក្នុងបិណ្ឌបាតផងដែរ ?' ដូច្នេះ, ព្រះអដ្ឋកថាចារ្យ កាលនឹងសំដែង ថា 'មិនគួរប្រាថ្នា' ទើបពោលពាក្យ ថា '**តត្ថ**' ដូច្នេះជាដើម" ។

ដីកានៃសេចក្តីសន្តោស ៥០ យ៉ាង ចប់ ។

(៣០៨) ក្នុងអដ្ឋកថាមង្គលសូត្រនេះ ព្រះអដ្ឋកថាចារ្យ បានពោលហើយ ថា 'សេចក្តីសន្តោស សូម្បីទាំងអស់នេះ ដែលមានប្រភេទដូចបានពោលមកហើយយ៉ាងនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា '**សេចក្តីសន្តោស**' ។ សេចក្តីសន្តោសនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃការបានសម្រេច នូវ

ការលះបង់បាបធម៌ទាំងឡាយ មានការប្រាថ្នាច្រើនហួសប្រមាណ ការប្រាថ្នាធំ និង សេចក្តីប្រាថ្នាដ៏លាមកជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាហេតុនៃការឧបត្ថម្ភគាំទ្រព្រះអរិយមគ្គ និង ព្រោះភាពជាហេតុនៃសេចក្តីចំរើន មានការមិនជាប់ជំពាក់ ក្នុងទិសទាំង ៤ ជាដើម" ។

អដ្ឋកថាខុទ្ទកវិភង្គ ថា "ភារៈគឺសេចក្តីប្រាថ្នាក្រៃលែងនូវលោភ របស់ខ្លួន នៃបព្វជិតដែលមិនសន្តោសហើយ ដោយបច្ច័យមានចីវរបច្ច័យជាដើម ដែលខ្លួនបានហើយនោះ ។ ឬក៏ នៃគ្រហស្ថអ្នកមិនសន្តោសហើយ ដោយរូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ដែលខ្លួនបានហើយនោះ ។ ឈ្មោះថា **អតិច្ឆតា** ។ សូម្បីពាក្យថា '**អត្រិច្ឆតា**' គឺជាឈ្មោះនៃ **អតិច្ឆតា** នុ៎ះឯង" ។

(៣០៩) ដីកានៃខុទ្ទកវិភង្គនោះ ថា 'មានអត្ថវិគ្រោះថា 'បុគ្គលណា តែងប្រាថ្នាច្រើន ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អតិច្ឆិច្ឆោ** (អ្នកប្រាថ្នាច្រើន)' ។ កាលបើព្រះអដ្ឋកថាចារ្យ គួរពោលពាក្យថា 'ភារៈនៃបុគ្គលជាអ្នកប្រាថ្នាច្រើននោះ ឈ្មោះថា **អតិច្ឆិច្ឆតា**' ដូច្នេះ, ប៉ុន្តែ លោកធ្វើនូវការលប់ **ច** អក្សរចោលចេញហើយ ពោលថា '**អតិច្ឆតា**' ដូច្នេះ ។ ក៏ **អតិច្ឆតា** នោះឯង គឺព្រះអដ្ឋកថាចារ្យ ហៅថា **អត្រិច្ឆតា** ព្រោះហេតុនោះ

គប្បីជ្រាបចបទសម្រេច សូម្បីក្នុងពាក្យថា **'អត្រិច្ឆតា'** នោះ ដោយពិធីដែលមកហើយ ក្នុងនិរុត្តិបករណ៍ ។ មួយទៀត សេចក្តីប្រាថ្នាក្នុងបច្ច័យនោះ ។ កន្លងហួសនូវបច្ច័យ តាមដែលខ្លួនបានហើយ ឈ្មោះថា **អត្រិច្ឆតា** ។ **អត្រិច្ឆតា** នោះឯង ព្រះអដ្ឋកថាចារ្យ ហៅថា **អតិច្ឆតា** ព្រោះធ្វើអាទេស ត្រ អក្សរ ទៅជា **ត** អក្សរ" ។

អនុដីកានៃខុទ្ទកវិភង្គនោះ ថា "បទថា **'នេរុត្តិវិធានេន'** មានសេចក្តីថា ដោយការផ្លាស់ ត្រ អក្សរ ឲ្យដល់ភាពជា **ត** អក្សរ" ។

ដីកានៃឯកនិបាត អង្គុត្តរនិកាយជាដើម ថា "សេចក្តីប្រាថ្នាក្នុងបច្ច័យនោះ ។ ឈ្មោះថា **អត្រិច្ឆតា** " ។

អដ្ឋកថាវេវិនីតិសូត្រ និង ឯកនិបាតអង្គុត្តរនិកាយជាដើម ថា "សេចក្តីប្រាថ្នានូវលាភ របស់បុគ្គលដទៃ នៃបុគ្គលអ្នកមិនចេះឆ្អែតឆ្អន់ហើយ ក្នុងលាភរបស់ខ្លួន ឈ្មោះថា **អត្រិច្ឆតា** " ។

(៣១០) មែនពិត វត្ថុដែលខ្លួនបានហើយ សូម្បីជារបស់ប្រណីត ក៏រមែងប្រាកដ ដល់បុគ្គលអ្នកប្រាថ្នាច្រើនហួស ដូចជារបស់ដែលអាក្រក់ដូច្នោះ, វត្ថុដែលអ្នកដទៃបានហើយ សូម្បីជារបស់ដែលអាក្រក់ ក៏រមែងប្រាកដ ដូចជារបស់ដែលប្រណីតដូច្នោះ ។ យាគូដែលបុគ្គលចំអិនហើយ កត្តុ ឬ នំ ក្នុងភាជនៈ

ជាមួយគ្នា ដែលទាយកដាក់ចូលទៅ ក្នុងបាត្ររបស់ខ្លួន រមែងប្រាកដដូចជារបស់អាក្រក់, (ចំណែក) យាគូជាដើម ដែលពួកទាយក ដាក់ចូលទៅហើយ ក្នុងបាត្ររបស់ភិក្ខុដទៃ រមែងប្រាកដដូចជារបស់ដែលប្រណីត ។ ក៏សេចក្តីប្រាថ្នាច្រើនហួសនេះ រមែងមានទាំងពួកគ្រហស្ថនិងបព្វជិត ទាំងពួកសត្វតិរច្ឆាន ។

ក្នុងដំណើរនេះ មានរឿងនេះ (ជាខុទាហរណ៍) ។

បានឮថា កុដុម្ពីក៍ម្នាក់ និមន្តនាងភិក្ខុនី ៣០ រូប ហើយបានប្រគេននូវភត្ត ព្រមទាំងនំ ។ ព្រះសង្ឃថេរី បានឲ្យដូរនំក្នុងបាត្រ របស់នាងភិក្ខុនីទាំងឡាយហើយ ទើបបានឆាន់នូវនំដែលខ្លួនបានហើយនុ៎ះឯង ជាខាងក្រោយ ។

រឿងនេះមកក្នុងអដ្ឋកថាខុទ្ទកវិភង្គ ។

(រឿងព្រះរាជបុត្រ)

(៣១១) ក្នុងអតីតកាល ព្រះរាជឱរស របស់ព្រះរាជាក្រុងពារាណសី ត្រូវព្រះរាជបិតានិរទេសចោលហើយ ទើបបាននាំព្រះនាងអសិតាភូ ដែលជាព្រះទេវី របស់ព្រះអង្គ ចូលទៅកាន់ព្រៃហោមពាន ទ្រង់សោយនូវត្រីសាច់ និងផ្លែឈើ គង់នៅហើយក្នុងបណ្ណសាលា ។ ព្រះរាជឱរសនោះ ទ្រង់ទតឃើញនាងកិន្នរី

មួយ ទ្រង់មានព្រះទ័យប្រតិពទ្ធ ទ្រង់បានលះបង់ នូវព្រះទេវីហើយ ស្តេចយាងទៅតាមគន្លងជើង នៃនាងកិន្នរីនោះ ។

ព្រះនាងទេវី ទ្រង់ព្រះតម្រិះ ថា "ព្រះរាជាអង្គនេះ ទ្រង់មិនរាប់អាននូវអាត្មាអញទេ ទើបស្តេចយាងទៅតាមនាងកិន្នរី" ហើយ ទ្រង់យាងទៅរកតាបសមួយអង្គ បានរៀនបរិកម្មកសិណ ហើយ ទ្រង់ញុំាងឈាននិងអភិញ្ញា ឲ្យកើតឡើងហើយ បានស្តេចយាងមក ទ្រង់គង់នៅ ក្បែរទ្វារនៃបណ្ណសាលា របស់ព្រះអង្គ ។ ឯព្រះរាជកុមារអង្គនោះ កាលទ្រង់យាងតាមនាងកិន្នរី ទ្រង់ទតព្រះនេត្រមិនឃើញ នូវផ្លូវដែលនាងកិន្នរីនោះទៅ ទើបទ្រង់អស់សេចក្តីសង្ឃឹមហើយ ទ្រង់ស្តេចយាងមកវិញ ។ ព្រះនាងទេវី ទ្រង់ទតព្រះនេត្រឃើញព្រះរាជកុមារនោះកំពុងតែយាងមក ក៏បានហោះឡើងទៅក្នុងដ៏អាកាសហើយ យាងទៅទីដទៃ ។ ក្នុងពេលដែលព្រះនាងទេវីនោះយាងទៅហើយ ព្រះរាជកុមារនោះ ទ្រង់ព្រះកន្សែង ទ្រង់បានត្រាស់នូវគាថានេះ ក្នុងអសិតាភូជាតក ក្នុងវគ្គទី ៩ នៃទុកនិបាត[1] ថា ÷

"បុគ្គលអ្នកមានសេចក្តីប្រាថ្នាដ៏លើសលុប រមែងសាបសូន្យ ចាកប្រយោជន៍ ព្រោះសេចក្តីលោភ

---

១ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១២៥

ហួសហេតុផង ព្រោះសេចក្តីស្រវឹង ក្នុងការចង់បានហួសហេតុផង ដូចយើងសាបសូន្យ ចាកព្រះរាជធីតាព្រះនាមអសិតាភូ ដូច្នោះឯង"។

បណ្តាបទទាំងនោះ បាទគាថា ថា "**អត្រិច្ឆំ អតិលោភេន**" មានសេចក្តីថា សេចក្តីចង់បានដែលមិនមានទីបំផុត ពោលគឺសេចក្តីប្រាថ្នា ក្នុងកាមគុណនោះៗ ព្រះរាជកុមារ ទ្រង់ត្រាស់ហៅថា **អត្រិច្ឆា**, សេចក្តីលោភលន់ ដែលប្រព្រឹត្តទៅហួសកម្រិត ព្រះរាជកុមារ ទ្រង់ត្រាស់ថា **អតិលោភោ**។

បទថា "**អតិលោភមទេន ច**" មានសេចក្តីថា ធម្មតាសេចក្តីស្រវឹង ដោយអំណាចសេចក្តីលោភលន់ហួសហេតុ ព្រោះញុំាងសេចក្តីស្រវឹង ថា ខ្លួនជាបុរស ឱ្យកើតឡើង បានកើតឡើងហើយ។ មានព្រះតម្រាស់ ដែលព្រះរាជកុមារ ទ្រង់ត្រាស់អធិប្បាយ យ៉ាងដូច្នេះ ថា "បុគ្គលអ្នកប្រាថ្នាហួសហេតុ ដោយអំណាចសេចក្តីប្រាថ្នាក្រៃលែង រមែងសាបសូន្យ ចាកប្រយោជន៍ដូចជាយើង សាបសូន្យហើយ ចាកព្រះនាងអសិតាភូរាជធីតា យ៉ាងដូច្នោះឯង ព្រោះសេចក្តីលោភលន់ហួសហេតុផង ព្រោះសេចក្តីស្រវឹង ដោយអំណាចការចង់បានហួសហេតុផង" ដូច្នេះ។

(៣១២) ចាប់តាំងអំពីពេលនោះមក ព្រះរាជកុមារនោះ ទ្រង់នៅក្នុងព្រៃ តែមួយព្រះអង្គឯងគត់ ដោយកាលកន្លងទៅនៃព្រះរាជបិតា ទើបបានស្តេចយាងទៅទទួលរាជសម្បត្តិហើយ ។

ចំណែកក្នុងអដ្ឋកថានៃវិភង្គ ព្រះអដ្ឋកថាចារ្យ ពោលថា "ទេវតាដែលស្ថិតនៅលើដើមឈើ បានពោលគាថានេះ ថា ÷

'បុគ្គលមានសេចក្តីប្រាថ្នាលើសលុបនោះ រមែងសាបសូន្យ ចាកប្រយោជន៍ខ្លួន ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានាងចន្ទកិន្នរី ទ្រង់សាបសូន្យហើយ ចាកព្រះនាងអសិតាភូ យ៉ាងដូច្នោះឯង ព្រោះសេចក្តីលោភលន់ហួសហេតុផង ព្រោះសេចក្តីស្រវឹងក្នុងការចង់បានហួសហេតុផង' ។

ទេវតា បានធ្វើនូវការចំអកឡកឡឺយ ជាមួយនឹងព្រះរាជា ថា 'បុគ្គលអ្នកប្រាថ្នាដ៏លើសលុប រមែងសាបសូន្យ ចាកប្រយោជន៍របស់ខ្លួន គឺ រមែងញុាំងប្រយោជន៍របស់ខ្លួន ឲ្យហិនហោចទៅ ព្រោះសេចក្តីលោភលន់ហួសហេតុ ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានូវនាងចន្ទកិន្នរី ទ្រង់បានសាបសូន្យហើយ ចាកព្រះរាជទេវី ទ្រង់ព្រះនាមអសិតាភូ ដូច្នោះឯង" ។

ដីកានៃវិភង្គនោះ ថា "បទថា **'អត្រិច្ឆំ'** មានសេចក្តីថា ប្រាថ្នាហួសហេតុ គឺ ប្រាថ្នាដ៏ក្រៃលែង ។ ព្រោះហេតុអ្វី ? ។ ព្រោះសេចក្តីលោភលន់ហួសហេតុផង ព្រោះសេចក្តីស្រវឹង ដោយអំណាចសេចក្តីចង់បានហួសហេតុ ពោលគឺសេចក្តីប្រាថ្នា ដោយអំណាចនៃសេចក្តីល្មោភហួសហេតុផង ។ ប្រយោជន៍របស់ខ្លួនទៅតា ហៅថា **'អត្តា'** ។ ២ បទថា **'ហាយតិ ជីយតិ'** មានសេចក្តីថា ប្រយោជន៍ដែលខ្លួនកាន់យកហើយ ឬប្រយោជន៍ដែលខ្លួនបានសម្រេចហើយ ព្រោះហេតុនោះ ប្រយោជន៍នោះទើបឈ្មោះថា **អត្តា**, អធិប្បាយថា រមែងញុំាងប្រយោជន៍ដែលខ្លួនបានកាន់យកហើយ ឬដែលខ្លួនបានសម្រេចហើយនោះ ឱ្យហិនហោចទៅ ដូចព្រះរាជកុមារ ទ្រង់ប្រាថ្នានាងចន្ទកិន្នរី ទ្រង់បានសាបសូន្យហើយ ចាកព្រះនាងអសិតាភូទេវី ដូច្នោះឯង" ។

អនុដីកាវិភង្គនោះ ថា "ក្នុង ២ បទថា **'អត្តហិតំ អត្តា'** នេះ ព្រះដីកាចារ្យ ពោលនិទ្ទេស ដោយការលប់បទខាងចុង ដូចជាឧទាហរណ៍ថា **'រូបភវោ រូបំ'** និងថា **'ភីមសេនោ ភីមោ'** ដូច្នោះឯង ។ គប្បីជ្រាបបទសម្រេច ដោយន័យនៃនិរុត្តិបករណ៍ថា **'អាទិន្នោ បត្តោ វា អត្តោតិ អត្តា'** យ៉ាងដូច្នេះ" ។

ពាក្យទាំងអស់នោះ រមែងខុសចាកបាលីក្នុងជាតក តាម ដែលបានពោលហើយ ព្រមទាំងអដ្ឋកថា ។

រឿងព្រះរាជបុត្រ ចប់ ។

(៣១៣) ន័យមកក្នុងអដ្ឋកថាខុទ្ទកវិភង្គ និង អដ្ឋកថា សង្គីតិសូត្រ ថា " ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ កូន របស់សេដ្ឋី ឈ្មោះមិត្តវិន្ទុកៈ ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លាហើយ ត្រូវមាតាប្រាប់ថា 'នែកូនប្រុសសំឡាញ់ ថ្ងៃនេះ ចូរកូនរក្សានូវ ឧបោសថ ស្តាប់ធម៌ ក្នុងព្រះវិហារ រហូតមួយរាត្រី, ម្តាយនឹងឲ្យ ទ្រព្យ ១ ពាន់ ដល់អ្នក' ដូច្នេះហើយ បានសមាទាន នូវឧបោសថ ព្រោះសេចក្តីលោភក្នុងទ្រព្យ ហើយកំណត់ថា 'ទីនេះ នឹងមិន មានភ័យ ពីណាមក' ហើយ ក៏បានដេកលក់ ក្រោមធម្មាសនៈ រហូតទាំងរាត្រី ដល់ព្រឹកឡើង ទើបបានទៅផ្ទះ ទទួលយកទ្រព្យ ១ ពាន់ភ្លាមហើយ ញុាំបបរ ។ នាយមិត្តវិន្ទុកៈនោះ ប្រាថ្នាចង់ អុំទូកឆ្លងសមុទ្រ ដោយសង្ឃឹម ថា 'អញ នឹងរួបរួមទ្រព្យ' ។

លំដាប់នោះ មាតាបានហាមឃាត់ នាយមិត្តវិន្ទុកៈនោះ ថា 'នែកូនសំឡាញ់ ក្នុងត្រកូលនេះ មានទ្រព្យដល់ទៅ ៤០ កោដិ, កូនកុំទៅឡើយ' ។ នាយមិត្តវិន្ទុកៈនោះ មិនស្តាប់ហើយ ចចេស ទៅទាល់តែបាន ។ មាតានោះ បានឈររាំងហើយនៅខាងមុខ ។

នាយមិត្តវិន្ទកៈនោះ ក្រោធហើយ គិតថា 'ម្តាយ (របស់អញ) នេះ ឈរវាំងនៅពីខាងមុខ' ដូច្នេះ បានកន្ត្តងមាតា ដែលខ្លួនប្រហារ ឱ្យដួលចុះហើយ ដោយជើង ទើបបានទៅហើយ ។ កាលបើ នាយមិត្តវិន្ទកៈនោះ ចុះទូកទៅ, ក្នុងថ្ងៃទី ៧ ទូកក៏បានកឿង ហើយ ។ មនុស្សទាំងឡាយ បានឱ្យចាប់ស្លាកកាឡកណ្ណីហើយ ។ ស្លាកនោះ បានធ្លាក់ដល់នាយមិត្តវិន្ទកៈនោះឯង ដល់ទៅ ៣ ដង ។ ពួកមនុស្ស បានឱ្យក្បួន ដល់នាយមិត្តវិន្ទកៈនោះហើយ បោះទម្លាក់ ចោលទៅក្នុងសមុទ្រ ។ នាយមិត្តវិន្ទកៈនោះ អណ្តែតទៅដល់ កោះមួយហើយ សោយសម្បត្តិ ជាមួយនឹងពួកនាងវិមានិកប្រេត សូម្បីត្រូវពួកវិមានិកប្រេតទាំងនោះ ហាមប្រាមថា 'សូមលោក កុំទៅ ខាងមុខៗ ឡើយ' ដូច្នេះ កាល (ដើរ) ទស្សនាមើលនូវ សម្បត្តិទ្វីគុណានោះៗ ក៏បានឃើញប្រេតមួយ ដែលទូលកង់ចក្រ ដ៏មុត ដោយលំដាប់ ។ កង់ចក្រនោះ បានប្រាកដហើយ ដល់ នាយមិត្តវិន្ទកៈនោះ ប្រៀបដូចជាផ្កាឈូក ។ នាយមិត្តវិន្ទកៈ បង្វរកវសុំ ថា 'ចូរអ្នកឱ្យនូវផ្កាឈូកនោះ ដល់ខ្ញុំ' ។ ប្រេតនោះ ពោលថា 'ម្នាលអ្នក នេះមិនមែនជាផ្កាឈូកទេ, នុ៎ះ ជាកង់ចក្រ ដ៏មុតទេតើ' ។ នាយមិត្តវិន្ទកៈនោះ ពោលថា 'អ្នកមិនចង់ឱ្យ ដល់ខ្ញុំ ទើបបញ្ឆោតខ្ញុំ, តើខ្ញុំមិនធ្លាប់ឃើញ ផ្កាឈូកឬ ? ' ។

ប្រែតក្រៅនេះ គិតថា 'ឯបុរសនេះ ពិតជាធ្វើកម្មដូចជាកម្មដែល អាត្មាអញបានធ្វើហើយ ទើបប្រាថ្នាចង់ទទួល នូវផលនៃកម្មនោះ' ដូច្នេះហើយ ទើបបានពាក់កងចក្រទៅ លើអំបែងក្បាល របស់នាយមិត្តវិន្ទកៈនោះ ហើយក៏បានរត់គេចចេញទៅ" ។

(៣១៤) ជីកាសង្គីតិសូត្រ ថា "អធិប្បាយថា 'ព្រោះសេចក្តីលោភក្នុងទ្រព្យ មិនមែនព្រោះការពេញចិត្ត ក្នុងធម៌ទេ' ។ ឈ្មោះថា មិនមានភ័យមកអំពីទីណា ព្រោះភាវៈជាសភាពដែលអ្នកណាមួយ គប្បីឱ្យក្រោកឡើងមិនបាន ។ មាតា បានហាមប្រាមហើយ ដោយបំណងថា 'ធម្មតាការធ្វើដំណើរតាមសមុទ្រ មានអន្តរាយច្រើន' ។ ២ បទថា **'អន្តរំ កត្វា'** មានសេចក្តីថា បានធ្វើមាតា ត្រង់ចន្លោះ នៃជើងទាំង ២ ដោយអំណាច នៃការកន្លងទៅលើ ។ ទូកបានឈប់នៅនឹងហើយ ព្រោះខ្យល់មិនបក់បោក ដោយកម្លាំងនៃកម្មដ៏លាមក របស់នាយមិត្តវិន្ទកៈនោះ ។

នាយមិត្តវិន្ទកៈនោះ សោយនូវសម្បត្តិ ដោយអានុភាពនៃឧបោសថកម្ម ដែលខ្លួនបានរក្សាហើយ អស់រយៈពេល ១ ថ្ងៃ ត្រូវពួកនាងវិមានិកប្រែត ឯទៀតៗ ហាមប្រាមហើយ ដូចជានាងវិមានិកប្រែតពួកមុនៗ ហាមប្រាមថា 'ចូរលោក កុំអញ្ជើញទៅខាងមុខៗឡើយ' យ៉ាងដូច្នេះ ព្រោះហេតុនោះ ទើបព្រះ

អដ្ឋកថាចារ្យ ពោល ថា 'តាហិ បរតោ បរតោ មា អគមាសីតិ វុច្ចមានោ' ដូច្នេះ ។ បទថា 'ខុរចក្កធរំ' មានសេចក្តីថា នូវបុរសម្នាក់ ដែលទូលកង់ចក្រដ៏មុត ដូចជាកាំបិតកោរដ៏មុត ។ កង់ចក្រនោះ បានប្រាកដហើយ ដោយកម្លាំងនៃកម្មដ៏លាមក" ។

(៣១៥) ក្នុងគ្រានោះ ព្រះពោធិសត្វ សោយជាតិជាស្តេច នៃទេវតាមួយអង្គ ត្រាច់ចរិកទៅ ក្នុងឧស្សុទនរក បានទៅដល់ទីនោះហើយ ។ នាយមិត្តវិន្ទកៈ បានឃើញព្រះពោធិសត្វនោះ ហើយ ទើបសួរ ថា "បពិត្រស្តេចទេវតា ជាម្ចាស់ កង់ចក្រនេះ រមែងគ្របសង្កត់កិន ដូចជាគ្រឿងកិន (ត្បាល់កិន) កិនកំទេច នូវគ្រាប់ល្ង ដូច្នោះ, បាបអ្វីហ្ន៎ ដែលខ្ញុំបានធ្វើហើយ ?" ។

លំដាប់នោះ ព្រះពោធិសត្វ កាលសំដែងនូវកម្មដែលគេបានធ្វើហើយ ដល់គេ ទើបបានពោលនូវគាថា ៣ ក្នុងចតុទ្វារជាតក ក្នុងទសកនិបាត[1] ថា ÷

"អ្នកបានទ្រព្យជាង ២០ សែន មិនបានធ្វើតាម ពាក្យ របស់ញាតិទាំងឡាយ ដែលជាអ្នកជួយ អនុគ្រោះ ដោយល្អ, អ្នកបានស្ទុះលឿនទៅកាន់ ទូក ដែលអណ្តែតទៅកាន់សមុទ្រសាគរ ដ៏ធំធេង

---

១ ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ១៦២

ដែលជាទីសម្រេចប្រយោជន៍តិចតួច បានសោយ
នូវសម្បត្តិ ជាមួយនឹងនាងវេមានិកប្រេត ៤ នាក់
ហើយបាននាងវេមានិកប្រេត ៨ នាក់ លុះចេញ
អំពីនាងវេមានិកប្រេត ៨ នាក់ហើយ ក៏បាននូវ
នាងវេមានិកប្រេត ១៦ នាក់, អ្នកចេញអំពី
នាងវេមានិកប្រេត ១៦ នាក់ហើយ ក៏បាននូវ
នាងវេមានិកប្រេត ៣២ នាក់, អ្នកជាមនុស្ស
មានសេចក្តីប្រាថ្នា ដ៏លើសលប់ បានមកប្រទះ
នឹងកងចក្រ ទាំងកងចក្រ ក៏វិលកិន នូវអំបែង
ក្បាល នៃបុរសដែលមានសេចក្តីប្រាថ្នា គ្រប
សង្កត់ហើយ" ។

(៣១៦) អដ្ឋកថាជាតក ថា "បណ្តាបទទាំងនោះ បទថា 'លទ្ធា' មានសេចក្តីថា ធ្វើឧបោសថកម្ម និង ទទួលយកទ្រព្យ ១ ពាន់ អំពីសំណាក់នៃមាតា កាលធ្វើនូវការលក់ដូរ បានហើយ នូវទ្រព្យ ១ ពាន់ និងទ្រព្យជាង ២០ សែន (ទៀត) ។ បទថា 'នាករិ' មានសេចក្តីថា អ្នកមិនសន្តោសហើយ ដោយទ្រព្យនោះ ស្ទុះទៅកាន់សមុទ្រ ដោយទូក សូម្បីត្រូវមាតាសំដែងទោស ក្នុង

សមុទ្រហើយ ហាមប្រាម ក៏មិនបានធ្វើតាមពាក្យ របស់ញាតិទាំងឡាយអ្នកជួយអនុគ្រោះ ដោយល្អឡើយ បានស្ទុះលឿនទៅកាន់ទូកដែលអណ្តែតទៅកាន់សមុទ្រសាគរ ដ៏ធំធេង ដែលអាចធ្វើឲ្យទូកលោតផ្លោះទៅបាន ។ បទថា '**អប្បសិទ្ធិយំ**' គឺ ដែលមានសេចក្តីសម្រេចតិច បានដល់ មានសេចក្តីវិនាសច្រើន ។ ២ បទថា '**ចតុព្ពិ អដ្ឋ**' មានសេចក្តីថា ដោយអានិសង្ស នៃឧបោសថកម្ម ដែលខ្លួនបានធ្វើហើយ អស់រយៈពេល ១ ថ្ងៃ ព្រោះអាស្រ័យមាតាទើបអ្នកបានហើយ នូវស្រី ៤ នាក់ ក្នុងវិមានកែវផលិក, បន្ទាប់អំពីនោះមក អ្នកបានហើយ នូវស្រី ៨ នាក់ ក្នុងវិមានប្រាក់ បានស្រី ១៦ នាក់ ក្នុងវិមានកែវមណី បានស្រី ៣២ នាក់ ក្នុងវិមានមាស" ។

(៣១៧) ដីកានៃសង្គីតិសូត្រថា "បទថា '**ចតុព្ពិ**' មានសេចក្តីថា ព្រមជាមួយនឹងនាងវេមានិកប្រេតទាំងឡាយ ៤ នាក់ ដែលដូចជានាងទេពអប្សរ ។ ២ បទថា '**សម្បត្តឹ អនុភវិត្វា**' គឺ ជាពាក្យដែលនៅសល់ (គួរនាំយកមកបញ្ចូល) ។ បទថា '**អដ្ឋជ្ឈគមា**' មានសេចក្តីថា បានជួបប្រទះនាងវេមានិកប្រេត ៨ នាក់ ដែលប្រសើរជាងនោះ ដោយគុណមានរូបជាដើម ។ បទថា '**អត្រិច្ឆំ**' មានសេចក្តីថា ឈ្មោះថា ប្រាថ្នាក្នុងកាមគុណ

នោះ ។ ព្រោះភាវៈជាអ្នកប្រកបព្រម ដោយសេចក្តីលោភលន់ហួស ហេតុ ពោលគឺប្រាថ្នាចង់បានដ៏សើលលប់ ” ។

អដ្ឋកថាជាតក ថា “ ២ បទថា ‘**អត្រិច្ឆំ ចក្កមាសទោ**’ មានសេចក្តីថា អ្នកជាមនុស្សអាក្រក់ មិនត្រេកអរហើយ ដោយទ្រព្យតាមដែលខ្លួនបានហើយ ឈ្មោះថា ប្រាថ្នាចង់បានហួសហេតុ ព្រោះភាពជាអ្នកប្រកព្រមហើយ ដោយសេចក្តីប្រាថ្នាដ៏លើសលប់ ពោលគឺសេចក្តីលោភលន់ ដែលកន្លងហួស នូវទ្រព្យដែលខ្លួនបានហើយ ។ យ៉ាងដូច្នេះថា ‘អាត្មាអញ នឹងបានលើស គឺច្រើនឡើងទៅ ។’ ដូច្នេះ ព្រោះភាវៈនៃឱបោថសកម្មនោះ អស់ហើយ ទើបបានកន្លងស្រីទាំង ឡាយ ៣២ នាក់ហើយ បានទៅដល់ស្រុកប្រេតនេះ បានទទួលហើយ (នូវចក្រដ៏មុត) ដោយផលនៃអកុសលគឺការរោយប្រហារនូវមាតានោះ ។ បាឋៈថា ‘**អតិច្ឆំ**’ ដូច្នេះក៏មានខ្លះ ។ អធិប្បាយថា ‘ប្រាថ្នាចង់បានហួសហេតុ” ។

ដីកានៃសង្គីតិសូត្រ ថា “ បទថា ‘**ចក្កំ**’ បានដល់ នូវចក្រដ៏មុតដូចកាំបិតកោរ ។ បទថា ‘**អាសទោ**’ មានសេចក្តីថា រមែងត្រេកអរទូទៅ ព្រោះភាវៈនៃអកុសលកម្មនោះ ជាហេតុនាំសេចក្តីវិនាសមកឱ្យ ” ។

ដីកាវិភង្គ ថា “ បទថា ‘**ឥច្ឆាហតស្ស**’ គឺ ជាអ្នកត្រូវ

សេចក្តីប្រាថ្នាចង់បានបៀតបៀនហើយ" ។

អដ្ឋកថាជាតកថា "បទថា 'ភមតិ' មានសេចក្តីថា ចក្រនេះ កាលកិននូវអំបែងក្បាល របស់អ្នកនោះ ដែលជាអ្នកត្រូវសេចក្តីប្រាថ្នាចង់បានគ្របសង្កត់ហើយ ក្នុងពេលឥឡូវនេះ រមែងវិលនៅ លើអំបែងក្បាល ដូចចក្រនៃនាយស្មូនឆ្នាំង យ៉ាងដូច្នោះ" ។

រឿងនាយមិត្តវិន្ទកៈ អ្នកសិក្សាគប្បីត្រួតពិនិត្យមើល ក្នុងមិត្តវិន្ទកជាតក ក្នុងនវមវគ្គ នៃឯកនិបាត និង ក្នុងទុតិយវគ្គ នៃបញ្ចកនិបាត ។

(រឿងខ្លាឃ្មុំ)

(៣១៨) ក្នុងអតីតកាល ខ្លាឃ្មុំមួយ នៅក្នុងគុម្ពោតព្រៃក្បែរបណ្ណសាលា របស់តាបសមួយរូប ជាសត្វត្រូវសេចក្តីប្រាថ្នាដ៏លើសលប់គ្របសង្កត់ហើយ បានចេញអំពីព្រៃ ចូលទៅកាន់បច្ចន្តគ្រាមហើយ ចូលទៅកាន់គុម្ពោតព្រៃ ។ មនុស្សទាំងឡាយ កាន់ធ្នូនិងដំបងជាដើមនៅនឹងដៃ បានលោមព័ទ្ធនូវគុម្ពោតព្រៃនោះហើយ បានយកធ្នូនិងដំបង រាយខ្លាឃ្មុំនោះ ដែលកំពុងតែបោលរត់ចេញទៅ ។ ខ្លាឃ្មុំនោះ បែកក្បាលហើយ មានឈាមហូរចេញ បានបោលទៅកាន់ទីនៅរបស់ខ្លួនហើយ គិតថា "សេចក្តីទុក្ខនេះ បានកើតឡើងហើយ ដល់អញ ដោយអំណាច

នៃសេចក្តីលោភលន់ គឺការចង់បានដ៏លើសលប់, ឥឡូវនេះ អញ
គ្របសង្កត់ (សេចក្តីលោភ) មិនបានហើយ នឹងមិនទទួលអាហារ
ចំណីឡើយ" ដូច្នេះហើយ បានទៅកាន់អាស្រមបទ អធិដ្ឋាននូវ
អង្គនៃឧបោសថហើយក៏ដេក ត្រូវតាបសសួរ ថា "ថ្ងៃនេះ អ្នកឯង
រក្សាឧបោសថ ដើម្បីប្រយោជន៍អ្វី ?" ដូច្នេះហើយ បានពោល
គាថាទាំងឡាយ ២ នេះ ក្នុងបញ្ចុបោសថជាតក ក្នុងបកិណ្ណកៈ(១) ថា +

"ខ្ញុំមើលងាយនូវលំនៅ របស់ខ្លួន បានចូលទៅ
កាន់ស្រុកនៃមល្លជន ព្រោះតែសេចក្តីប្រាថ្នា
ដ៏លើសលប់ ។ ពួកជនចេញមកអំពីស្រុកនោះ
ហើយ ក៏វាយខ្ញុំដោយធ្នូ ។ ខ្ញុំនោះ បែកក្បាល
ប្រឡាក់ឈាមអស់ទាំងខ្លួន ហើយបានត្រឡប់មក
កាន់ទីលំនៅដែលខ្លួនធ្លាប់នៅវិញ ។ ហេតុនោះ
បានជាខ្ញុំរក្សាឧបោសថ, សូមកុំឱ្យសេចក្តីប្រាថ្នា
លើសលប់ មកគ្របសង្កត់បានទៀតឡើយ" ។

អដ្ឋកថាជាតក ថា "បណ្តាបទទាំងនោះ បទថា 'អតិហីឡ-
យានោ' គឺ មើលងាយ បានដល់ តិះដៀល ។ បទថា
'កោទណ្ឌកេន' បានដល់ ដោយដងធ្នូទាំងឡាយ និង ដោយ

---

១ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ៣០

ដំបងទាំងឡាយ" ។

អដ្ឋកថាខុទ្ទកវិភង្គ ថា "ខ្ញុំបានទៅកាន់មលកជនបទ" ។

ដីកានៃវិភង្គ ថា "បទថា '**អតិហេឡយានោ**' ប្រែថា កាលមើលងាយ ។ បទថា '**មលកំ**' បានដល់ កាន់ជនបទដែលមានឈ្មោះ យ៉ាងដូច្នោះ ឬកាន់ទីវាល ។ បទថា '**កោទណ្ឌកេន**' គឺ ដោយដងនៃកោទណ្ឌ (ធ្នូ) ។ អាចារ្យពួកខ្លះ ពោល ថា 'ដោយដំបង' ។ បទថា '**រុហិរមក្ខិតង្គោ**' ប្រែថា មានខ្លួនប្រឡាក់ឈាមជោកហើយ" ។

រឿងខ្លាឃ្មុំ ចប់ ។

ពណ៌នាអំពីរឿងនៃសេចក្តីប្រាថ្នាដ៏លើសលប់ ចប់ ។

(៣១៩) អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ថា "ដែលឈ្មោះថា **មហិច្ឆតា** បានដល់ សេចក្តីលោភលន់ច្រើន ដែលព្រះអដ្ឋកថាចារ្យ បានសំដៅយក ពោលទុកហើយ ថា 'បណ្តាធម៌ទាំងនោះ ភាពជាអ្នកប្រាថ្នាច្រើន តើដូចម្តេច ? គឺ សេចក្តីប្រាថ្នាដ៏ក្រៃលែង របស់បព្វជិតអ្នកមិនត្រេកអរហើយ ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ បរិក្ខារ តាមដែលខ្លួនបានហើយ ឬរបស់គ្រហស្ថ អ្នកមិនត្រេកអរហើយ ដោយកាមគុណទាំង ៥ ,

សេចក្តីប្រាថ្នា គឺ ការប្រព្រឹត្តិទៅ នៃសេចក្តីប្រាថ្នា ភាពជាអ្នក មានសេចក្តីប្រាថ្នាច្រើន សេចក្តីស្រឡាញ់ សេចក្តីត្រេកត្រអាល ដ៏ខ្លាំងខ្លានៃចិត្ត នេះឯណា, នេះលោកហៅថា **មហិច្ឆតា** ។

ជីកាឯកនិបាត អង្គុត្តរនិកាយនោះ ថា “ សេចក្តីប្រាថ្នា របស់ បុគ្គលនុ៎ះ ច្រើន ហេតុនោះ បុគ្គលនោះ ឈ្មោះថា **មហិច្ឆោ** (អ្នកមានសេចក្តីប្រាថ្នាច្រើន) ។ ភាវៈនៃបុគ្គលអ្នកមាន សេចក្តីប្រាថ្នាច្រើននោះ ឈ្មោះថា **មហិច្ឆតា** ។ សេចក្តីលោក ដែលមានអារម្មណ៍ច្រើន ឈ្មោះថា **មហាលោភោ** ព្រោះ សេចក្តីចង់បានចំពោះវត្ថុដែលធំ និងវត្ថុដែលច្រើន ។ ដោយ ពាក្យថា ‘ **ឥតរីតរ** ’ ជាដើម លោកពោលភាវៈជាអ្នកប្រាថ្នាធំ ដែលកើតឡើងដល់បព្វជិតទាំងឡាយ ។ ពាក្យថា ‘ **បញ្ចហិ វា កាមគុណេហិ** ’ ដូច្នេះជាដើម លោកពោលហើយ ដោយ អំណាចនៃគ្រហស្ថទាំងឡាយ ” ។

អដ្ឋកថាវិភង្គ ថា “ ភាពជាអ្នកប្រាថ្នា ដោយវិសេស ឈ្មោះថា **អិយ្យោកម្យតា** ។ សេចក្តីប្រាថ្នា ដោយអំណាច នៃសេចក្តីចង់បាន, សេចក្តីប្រាថ្នានុ៎ះឯង ឈ្មោះថា ការប្រព្រឹត្តិ ទៅនៃសេចក្តីប្រាថ្នា ឬអាការនៃសេចក្តីប្រាថ្នា ” ។

ជីកាឯកនិបាត អង្គុត្តរនិកាយ ថា “ កិរិយាប្រព្រឹត្តិទៅ

ដោយអំណាចនៃសេចក្តីប្រាថ្នា ឈ្មោះថា **ឥច្ឆាគតំ** ។ ភាពជាអ្នកប្រាថ្នាច្រើន ឈ្មោះថា **មហិច្ឆតា** ។ ប៉ុន្តែ ដោយសេចក្តីភាពជាអ្នកប្រាថ្នាច្រើននេះ ក៏គឺរាគៈនុ៎ះឯង ព្រោះហេតុនោះ ទើបលោក ពោលថា '**រាគោ សារាគោ**' ដូច្នេះជាដើម" ។

អដ្ឋកថាឈ្មោះអដ្ឋសាលិនី ថា "សភាវៈណា រមែងត្រេកអរក្រៃលែង ហេតុនោះ សភាវៈនោះ ឈ្មោះថា **សារាគោ** (សភាវៈដែលត្រេកអរក្រៃលែង)" ។

អដ្ឋកថាវិភង្គ ថា "បុគ្គលរមែងប្រាថ្នា នូវវត្ថុច្រើន ឬថា សេចក្តីប្រាថ្នា របស់បុគ្គលនោះធំ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **មហិច្ឆោ** (អ្នកមានសេចក្តីប្រាថ្នានូវវត្ថុច្រើន ឬក៏មានសេចក្តីប្រាថ្នាធំ) ។ ភាពនៃបុគ្គលជាអ្នកមានសេចក្តីប្រាថ្នាច្រើននោះ ឈ្មោះថា **មហិច្ឆតា**" ។

(៣២០) អដ្ឋកថាវជិរពុទ្ធិតសូត្រ និង ឯកនិបាត អង្គុត្តរនិកាយ ថា "ក៏ភាវៈគឺការសរសើរនូវគុណដែលមាន និង ភាពជាអ្នកមិនស្គាល់ប្រមាណ ក្នុងការទទួល ឈ្មោះថា **មហិច្ឆតា** ។

ឯភាពជាអ្នកប្រាថ្នាច្រើននោះ មកហើយ ដោយន័យនេះឯង ថា 'បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងប្រាថ្នា ថា 'ជនចូរដឹងនូវអាត្មាអញ ថា 'ជាអ្នកមានសទ្ធា' ដូច្នេះ, ជាអ្នក

មានសីល រមែងប្រាថ្នាថា 'ជនចូរដឹងនូវអាត្មាអញ ថា 'ជាអ្នកមានសីល' ដូច្នេះឯង" ។

ដីកានៃថេរគាថា និង ឯកនិបាត អង្គុត្តរនិកាយនោះថា "កិរិយាស្ថិតនៅ ក្នុងការប្រព្រឹត្តិ ដោយសេចក្តីប្រាថ្នា ហើយប្រកាសនូវគុណាមានសីល និងធុតង្គធម៌ជាដើម ដែលមាននៅក្នុងខ្លួន ឈ្មោះថា សេចក្តីពោលសរសើរគុណដែលមាន ។ ក៏សូម្បីភាពជាអ្នកមិនស្គាល់ប្រមាណ ក្នុងការទទួល រមែងមានដល់បុគ្គលអ្នកប្រាកដដូច្នោះ ។ មានសម្ពន្ធ ថា 'សូម្បីភាពជាអ្នកមិនស្គាល់នូវប្រមាណនោះ ក៏មកហើយ ក្នុងព្រះអភិធម្ម ដូចគ្នាដែរ" ។

(៣២១) អដ្ឋកថាវិភង្គ ថា "មែនពិត បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន រមែងជាអ្នកមានចំណង់នឹងប្រកាស នូវសីលគុន: ឬក៏គុណានៃធុតង្គ ដោយហោចទៅ សូម្បីនូវគុណាត្រឹមតែការនៅក្នុងព្រៃ របស់ខ្លួន សូម្បីមានប្រមាណតិចតួច ដល់មហាជនអ្នកដែលស្គាល់នុ៎ះឯង ប្រៀបដូចជា អ្នកជំនួញ ដែលវេចខ្ចប់នូវរបស់របរ ដោយថ្នក់ កាន់យកនូវគញ្ចប់នៃគ្រឿងប្រដាប់ដោយដៃហើយ ដាក់នូវរបស់របរដែលគួរដាក់ ក្នុងថ្នក់នុ៎ះឯង, កាលបើមហាជន មើលឃើញនុ៎ះឯង, រមែងចាត់ចែង ពាយនាយលក់ថា 'អ្នកទាំងឡាយ ចូរអញ្ជើញជួយទទួល (ជួយទិញ) នូវរបស់

ឈ្មោះនុ៎ះ ។ ’ យ៉ាងដូច្នោះឯង, ក៏លុះប្រកាសហើយ មិននិយាយ ថា ‘ ឈមគ្រប់គ្រាន់ហើយ ’ ដូច្នេះ រមែងទទួលនូវបច្ច័យទាំងឡាយ ដែលទាយកនាំចូលមកហើយ សូម្បីដោយរទេះ ។ មែនពិត សភាពទាំងឡាយ ៣ យ៉ាង គឺបុគ្គលមិនអាច ដើម្បីឲ្យពេញបាន ឡើយ គឺ ភ្លើង បុគ្គលមិនអាចឲ្យពេញបាន ដោយប្រឆេះ, សមុទ្រ បុគ្គលមិនអាចឲ្យពេញបាន ដោយទឹក, បុគ្គលអ្នកមានសេចក្តី ប្រាថ្នាច្រើន គឺបុគ្គលមិនអាចឲ្យពេញ ដោយបច្ច័យទាំងឡាយ បានឡើយ ដោយប្រការដូច្នេះឯង ។

> បុគ្គលកាលឲ្យបច្ច័យទាំងឡាយដ៏ច្រើន ក៏មិនគប្បី ញុាំង សូម្បីសភាពទាំងឡាយ ៣ យ៉ាងនេះ គឺ គំនរភ្លើង ១ សមុទ្រ ១ បុគ្គលអ្នកប្រាថ្នាច្រើន ១ ឲ្យពេញបរិបូណ៌បានឡើយ ” ។

ដីកានៃវិភង្គនោះ ថា “ រមែងជាអ្នកមានចំណង ដើម្បីនឹង ប្រកាស ដល់មហាជនអ្នកស្គាល់នុ៎ះឯង ឲ្យក្រៃលែងឡើង ។ ដូច ជានៅចាំងាស់គឿន យ៉ាងដូច្នោះ ។ បទថា ‘ **បច្ចយេ** ’ បានដល់ នូវបច្ច័យមានប្រឆេះភ្លើងជាដើម ” ។

អនុដីកា ថា “ បទថា ‘ **ឧបាទានាទិប្បច្ចយេ** ’ មានសេចក្តី

ថា បច្ច័យដែលជាហេតុឲ្យពេញបរិបូណ៌ មានប្រឆេះ ទឹក និង ចីពរ ជាដើម" ។

(៣២២) ក៏បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន រមែងមិនអាច ដើម្បីយកចិត្ត សូម្បីនៃមាតាបង្កើតបានឡើយ, នឹងចាំបាច់ពោលធ្វើអ្វី ដល់ខុបដ្ឋាកទាំងឡាយនុ៎ះឡើយ ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាខុទាហរណ៍) +

(រឿងភិក្ខុកម្លោះ)

បានឮថា ភិក្ខុកម្លោះមួយរូប ចូលចិត្ត (ឆាន់) នំអំបែង ។ លំដាប់នោះ មាតារបស់ភិក្ខុនោះ កាលសាកល្បងនូវសេចក្តីបដិបត្តិ គិតថា "បើកូនប្រុស របស់ខ្ញុំ ស្គាល់ប្រមាណ ក្នុងការទទួល, ខ្ញុំនឹងប្រគេននូវនំ ដល់លោកកូននោះ រហូតត្រៃមាសទាំងអស់" ដូច្នេះហើយ ក្នុងថ្ងៃចូលព្រះវស្សា បានប្រគេននំមួយ ជាដំបូង, កាលបើភិក្ខុរូបនោះ ឆាន់នំនោះហើយ, បានប្រគេននំទី ២, កាលបើភិក្ខុរូបនោះ ឆាន់នំទី ២ នោះហើយ, ក៏បានប្រគេនហើយនូវនំទី ៣ ។ ភិក្ខុកម្លោះ មិនបានពោលថា "គ្រប់គ្រាន់ហើយ" គិតតែពីឆាន់ប៉ុណ្ណោះ ។ មាតាបានដឹងថាភិក្ខុនោះ មិនស្គាល់នូវប្រមាណ ទើបគិតថា "នំសម្រាប់ត្រៃមាសទាំងអស់គឺលោកកូនខ្ញុំបានឆាន់ហើយ ក្នុងថ្ងៃនេះឯង" ហើយ ក៏មិនបានប្រគេន សូម្បីតែ

នំមួយដុំ (ដល់ភិក្ខុនោះ) ចាប់តាំងពីថ្ងៃទី ២ មក ។

រឿងភិក្ខុកម្លោះ ចប់ ។

(រឿងព្រះរាជាព្រះនាមតិស្សៈ)

(៣២៣) ចំណែកព្រះបាទតិស្សមហារាជ កាលទ្រង់ថ្វាយទាន ដល់ព្រះភិក្ខុសង្ឃ ក្នុងចេតិយបព៌តវិហារ ជារៀងរាល់ថ្ងៃ ត្រូវពួកអ្នកជនបទ ក្រាបទូលថា "បពិត្រព្រះមហារាជ ព្រោះហេតុអ្វី បានជាព្រះអង្គ ទ្រង់សោតគប់នូវទីស្ថានតែមួយកន្លែងប៉ុណ្ណោះ ?, ការដែលព្រះអង្គ ទ្រង់ថ្វាយទាន ក្នុងទីកន្លែងដទៃទៀត រមែងមិនសមគួរទេឬ ?" ដូច្នេះហើយ ក្នុងថ្ងៃទី ២ ទ្រង់បានត្រាស់បញ្ជា ឱ្យថ្វាយមហាទាន ក្នុងទីក្រុងអនុរាធបុរី ។

សូម្បីភិក្ខុមួយរូប ក៏មិនស្គាល់ប្រមាណ ក្នុងការទទួល ។ ខាទនីយៈនិងភោជនីយាហារ ដែលភិក្ខុមួយរូប ។ បានទទួលហើយ មនុស្សទាំងឡាយ ២-៣ នាក់ ទើបលើករួច ។

ក្នុងថ្ងៃទី ២ ព្រះរាជា ទ្រង់ត្រាស់បញ្ជាឱ្យនិមន្តភិក្ខុសង្ឃ ក្នុងចេតិយបព៌តវិហារហើយ ទ្រង់ត្រាស់ថា "សូមព្រះគុណម្ចាស់ទាំងឡាយ ឱ្យនូវបាត្រមក" ដូច្នេះ ក្នុងពេលដែលភិក្ខុទាំងឡាយនោះ និមន្តមកដល់ខាងក្នុងនៃព្រះបរមរាជវាំងហើយ ។ សូម្បីភិក្ខុមួយរូប ក៏មិនបានថ្វាយហើយនូវបាត្រ ដោយបានថ្វាយព្រះពរថា

" បពិត្រព្រះមហារាជ ឈ្មួមគ្រប់គ្រាន់ហើយ, ភិក្ខុទាំងឡាយ នឹងទទួលនូវភិក្ខា តាមប្រមាណ របស់ខ្លួន " ។ ភិក្ខុទាំងឡាយ ទាំងពួង បានទទួលហើយ នូវភិក្ខាដ៏សមគួរនឹងប្រមាណនុ៎ះឯង ។

ព្រះរាជា ទ្រង់មានព្រះរាជឱង្ការថា ' អ្នកទាំងឡាយ ចូរមើលចុះ, បណ្តាភិក្ខុទាំងឡាយ របស់ពួកអ្នក សូម្បីភិក្ខុមួយរូប ក៏មិនស្គាល់នូវប្រមាណឡើយ, កាលពីថ្ងៃម្សិលមិញ មិនបានមានវត្ថុអ្វី នៅសេសសល់ឡើយ, ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ ទទួលយកហើយតែបន្តិច, វត្ថុជាច្រើននណាស់ មាននៅសល់តែម្តង " ហើយ ទ្រង់សព្វព្រះរាជហឫទ័យ ក្នុងភាពនៃភិក្ខុទាំងឡាយ ក្នុងចេតិយបព៌តវិហារនោះ ជាអ្នកស្គាល់ប្រមាណ និង ទ្រង់មិនបានសព្វព្រះរាជហឫទ័យហើយ ក្នុងភាពនៃភិក្ខុក្រៅអំពីនេះ ជាអ្នកមិនស្គាល់នូវប្រមាណ ។

រឿងព្រះរាជាព្រះនាមតិស្សៈ ចប់ ។

រឿងទាំងពីរ មកក្នុងអដ្ឋកថាខុទ្ទកវិភង្គ ។

(រឿងនាងថូលនន្ទាភិក្ខុនី)

(៣២៤) ឧបាសកម្នាក់ ក្នុងក្រុងសាវត្ថី បានបវារណានាងភិក្ខុនីសង្ឃ ដោយមើមខ្ទឹមហើយ បានបញ្ជាបុគ្គលអ្នករក្សា

ស្រែ ថា "បើនាងភិក្ខុនី និមន្តមក, អ្នកចូរប្រគេននូវមើមខ្ទឹម ដល់នាងភិក្ខុនីមួយរូប ។ ២ - ៣ កញ្ចប់ផង" ។ ក្រោយមក ថ្ងៃមួយ នាងភិក្ខុនីឈ្មោះថូលនន្ទា ព្រមទាំងបរិវារ និមន្តទៅកាន់ ស្រែហើយ មិនស្គាល់ប្រមាណ បានឲ្យគេនាំយកមើមខ្ទឹមទៅ យ៉ាង ច្រើន ។ ចំណែកអ្នករក្សាស្រែ បានលើកទោសហើយ ។

ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់បានតិះដៀល នាងថូលនន្ទាភិក្ខុនីហើយ ទើបទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន រមែងមិនជាទី ស្រឡាញ់ មិនជាទីពេញចិត្ត សូម្បីរបស់មាតាបង្កើតឡើយ ទាំង មិនអាច ដើម្បីញ៉ាំងមហាជនអ្នកដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លា បាន ឬដើម្បីញ៉ាំងមហាជនអ្នកដែលជ្រះថ្លាហើយ ឲ្យជ្រះថ្លា ដោយប្រមាណ យ៉ាងក្រៃលែងបានឡើយ ទាំងមិនអាច ដើម្បី ញ៉ាំងលាភដែលមិនទាន់បានកើតឡើងហើយ ឲ្យកើតឡើងបាន ឬ ដើម្បីធ្វើលាភដែលកើតឡើងហើយ ឲ្យស្ថិតនៅគង់វង់បានឡើយ, ចំណែក បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច រមែងអាច" ដូច្នេះហើយ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ នាងថូលនន្ទាភិក្ខុនី ជាអ្នក ប្រាថ្នាច្រើន មិនមែនតែក្នុងពេលឥឡូវនេះប៉ុណ្ណោះទេ, សូម្បី ក្នុងកាលមុន ក៏ជាអ្នកប្រាថ្នាច្រើនដូចគ្នាដែរ" ដូច្នេះហើយ

ទើបទ្រង់បាននាំ នូវអតីតនិទានមក (ត្រាស់សំដែង) ថា ÷

(៣២៥) ក្នុងអតីតកាល ព្រាហ្មណ៍ម្នាក់ ក្នុងក្រុងពារាណសី ធ្វើមរណកាលហើយ ក៏បានទៅកើត ក្នុងកំណើតនៃហង្សមាស ។ ហង្សមាសនោះ កាលពិចារណា ដោយញាណដែលជាគ្រឿងរឭក ជាតិបាន ក៏បានឃើញភរិយានិងពួកកូនស្រី របស់ខ្លួន កំពុងតែធ្វើការស៊ីឈ្នួលអ្នកដទៃ មកចិញ្ចឹមជីវិត ហើយក៏បានទៅ ក្នុងទីនោះ ព្រោះសេចក្តីស្រឡាញ់ ចំពោះភរិយា និងកូនស្រីទាំងនោះ បាននិយាយប្រាប់រឿងរ៉ាវទាំងអស់ហើយ ទើបឲ្យនូវរោមស្លាបមួយ ដល់ភរិយានិងកូនស្រីទាំងនោះ ហើយបានប្រាប់ ថា "ចាប់តាំងអំពីថ្ងៃនេះទៅ សូមអ្នកទាំងអស់គ្នា កុំបីធ្វើការស៊ីឈ្នួលអ្នកដទៃឡើយ, ពួកអ្នកចូរលក់រោមស្លាបនេះហើយ ចិញ្ចឹមជីវិត តាមសប្បាយចុះ" ដូច្នេះហើយ ក៏បានចៀសចេញទៅ ។ បានឮថា រោមស្លាបហង្សនោះ សម្រេចដោយមាស ជារបស់គួរដល់ការដំ និងដែបាន ។ ហង្សមាសនោះ បានហើរទៅ (ជម្រុះ) រោមស្លាបឲ្យម្តងមួយ ៗ ក្នុងចន្លោះ ៗ (ដល់ភរិយានិងកូនស្រីទាំងនោះ) ដោយទំនងនេះ ។ នាងព្រាហ្មណីនិងកូនស្រីទាំងឡាយ បានជាអ្នកមានស្តុកស្តម្ភហើយ ។ ក្រោយមក ថ្ងៃមួយ នាងព្រាហ្មណីបានពោល ថា "នែនាងទាំងឡាយ ធម្មតាចិត្ត របស់សត្វតិរច្ឆាន

ទាំងឡាយ ជាធម្មជាតដែលដឹងបានដោយពិបាក, ជួនកាល ខ្មីពុក របស់កូនឯងទាំងអស់គ្នា មិនគប្បីមក ក្នុងទីនេះ, ឥឡូវនេះ ក្នុងពេលដែលខ្មីពុក របស់កូនឯងនោះមកហើយ ពួកយើង នឹងចាប់ដករោមស្លាបទាំងអស់ "។ ពួកកូនស្រី បានហាមឃាត់ម្តាយនោះហើយ ។ ក៏ក្នុងថ្ងៃស្អែកឡើង កាលបើសត្វហង្សមាសនោះ ហើរមកដល់ហើយ, នាងព្រាហ្មណីនោះ បានធ្វើហើយ យ៉ាងដូច្នោះ ព្រោះភាពនៃខ្លួនជាអ្នកប្រាថ្នាច្រើន ។ រោមស្លាបទាំងអស់ បាន (ក្លាយ) ដូចជារោមស្លាប របស់សត្វកុកក្រកអស់ហើយ ព្រោះភាវៈជារបស់ ដែលនាងព្រាហ្មណីបោចយកហើយ ដោយការធ្វើតាមកម្លាំង ប្រាសចាកសេចក្តីពេញចិត្ត របស់សត្វហង្ស ។ សត្វហង្ស មិនអាចហើរទៅបានឡើយ ។ នាងព្រាហ្មណី បានក្រែងសត្វហង្សនោះ ក្នុងទ្រុងដ៏ធំ ចិញ្ចឹមហើយ ។ រោមស្លាប របស់សត្វហង្សនោះ បានដុះឡើងជាថ្មីហើយ ក៏បានក្លាយទៅជារោមពណ៌ស ។ សត្វហង្សនោះ មានរោមស្លាបដុះឡើងហើយ បានហើរទៅទីលំនៅឋាន របស់ខ្លួន លែងត្រឡប់មកវិញហើយ ។

(៣២៦) ព្រះសាស្តា លុះទ្រង់បាននាំយកអតីតនិទាន មកហើយ ទើបទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីឈ្មោះថុលនន្ទា ជាអ្នកប្រាថ្នាច្រើន មិនមែនតែក្នុងពេលឥឡូវនេះ

ប៉ុណ្ណោះទេ, សូម្បីក្នុងកាលមុន នាងថូលនន្ទាភិក្ខុនីនេះ ក៏ជាអ្នកប្រាថ្នាច្រើនដូចគ្នាដែរ, ក៏ព្រោះភាពជាអ្នកប្រាថ្នាច្រើន ទើបនាងសាបសូន្យហើយ ចាកមាស ក្នុងកាលមុន, មួយទៀត ក្នុងពេលឥឡូវនេះ នាងក៏បានសាបសូន្យ ចាកមើមខ្ទឹម យ៉ាងដូច្នោះដែរ ព្រោះភាពនៃខ្លួនជាអ្នកប្រាថ្នាច្រើន, ព្រោះហេតុនោះ ចាប់តាំងអំពីថ្ងៃនេះទៅ នាងថូលនន្ទាភិក្ខុនី នឹងមិនបាន ដើម្បីរាន់នូវមើមខ្ទឹមបានឡើយ, ក៏សូម្បីនាងភិក្ខុនីដែលសេសសល់ទាំងឡាយ អាស្រ័យនាងថូលនន្ទាភិក្ខុនីនោះហើយ ក៏មិនអាចរាន់បាន ដូចជានាងថូលនន្ទាភិក្ខុនីដែរ, ព្រោះហេតុនោះ ភិក្ខុសូម្បីបានច្រើន ក៏គប្បីស្គាល់ប្រមាណដោយពិត, តែបានតិច ក៏គប្បីធ្វើសេចក្តីសន្តោស ដោយបច្ច័យតាមដែលខ្លួនបានហើយប៉ុណ្ណោះ, ភិក្ខុមិនត្រូវប្រាថ្នាឲ្យខ្ពស់ហួសឡើយ" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ក្នុងសុវណ្ណហំសជាតក ក្នុងចុទ្ទសមវគ្គ ឯកនិបាត[1] ថា +

"បុគ្គលបានទ្រព្យណាហើយ, បុគ្គលគប្បីត្រេកអរ
ដោយទ្រព្យនោះ, ព្រោះថា សេចក្តីល្មោភហួស
ជារបស់លាមក, (ដូចជានាងព្រាហ្មណី) ក៏
សាបសូន្យ ចាកមាស ព្រោះចាប់រាជហង្ស" ។

---

[1] ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៦០

បណ្តាបទទាំងនោះ បទថា "តុដ្ឋព្យំ" ប្រែថា គប្បីត្រេកអរ ។

ក៏ព្រះដ៏មានព្រះភាគ លុះទ្រង់ត្រាស់ យ៉ាងដូច្នេះហើយ ទ្រង់បានបញ្ញត្តនូវសិក្ខាបទ ថា "ក៏ភិក្ខុនីរូបណា គប្បីឆាន់ខ្ទឹម, ភិក្ខុនីរូបនោះ ត្រូវអាបត្តិបាចិត្តិយ៍" ។

រឿងនាងថុលនន្ទាភិក្ខុនី ចប់ ។

(៣២៧) សូម្បីរឿងឆ្កែចចក ដែលឃើញជំរីមួយស្លាប់ហើយ បានចូលទៅខាងក្នុងពោះ តាមទ្វារច្ចមគ្គ របស់ជំរីនោះ ដោយអំណាចនៃសេចក្តីល្មោភច្រើន, កាលបើទ្វារមគ្គ បិទជិតហើយ, ក៏មិនអាចចេញមកបានឡើយ ទើបនៅកើតទុក្ខ យ៉ាងយូរក្នុងពោះជំរីនោះ ថ្ងៃមួយ កាលបើភ្លៀងធ្លាក់, ទ្វារមគ្គបើកហើយ, ទើបបានចេញ ទៅកាន់អាស្រមបទ របស់តាបសមួយរូបហើយ សមាទានអង្គនៃឧបោសថ ដើម្បីប្រយោជន៍ដល់ការគ្របសង្កត់នូវសេចក្តីលោភហើយទើបដេក ក្នុងអដ្ឋកថាបញ្ចុបោសថជាតក ក៏គប្បីប្រមូលយកមក (សំដែងដដែរ) ។

ពណ៌នាអំពីរឿងនៃភាពជាអ្នកប្រាថ្នាច្រើន ចប់ ។

(៣២៨) អដ្ឋកថាវិនីតសូត្រ និង ឯកនិបាត អង្គុត្តរនិកាយ ថា "ក៏ភាវៈ គឺការប្រកាសនូវគុណដែលមិនមាន និង ភាព

នៃបុគ្គលជាអ្នកមិនស្គាល់នូវប្រមាណ ក្នុងការទទួល ឈ្មោះថា ភាពនៃបុគ្គលជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក ។ **បាបិច្ឆតា** នោះ មកហើយ ក្នុងព្រះអភិធម្មន៍ឯង ដោយន័យជាដើម ថា ' បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា បានគិតហើយ ថា ' សូមជនដឹងនូវអាត្មាអញ ថា ' ជាអ្នកមានសទ្ធា ' ដូច្នេះ ' ។ បុគ្គលអ្នកប្រកបព្រមហើយ ដោយភាពជាអ្នកប្រាថ្នាដ៏លាមកនោះ រមែងតាំងនៅ ក្នុងភាពជាអ្នកបោកបញ្ឆោត ដោយពិត " ។

ដីកានៃវេវិនីតសូត្រ និង ឯកនិបាត អង្គុត្តរនិកាយនោះ ថា " សេចក្តីប្រាថ្នា ដ៏អាក្រក់ គឺ ដ៏លាមក ដ៏ទាបថោក ព្រោះភាវៈ គឺការប្រកាសគុណដែលមិនមាន ឈ្មោះថា **បាបិច្ឆតា** ។ កិរិយាប្រកាសគុណដែលមិននៅ ក្នុងខ្លួន ធ្វើដូចជាមាននៅ ក្នុងខ្លួន ដល់ពួកជនដទៃ ឈ្មោះថា ភាពគឺការប្រកាសគុណដែលមិនមាន " ។

(៣២៩) ក៏ក្នុងពាក្យថា **" អស្សទ្ធោ សមានោ "** ដូច្នេះ ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ " បុគ្គលណា ជាអ្នកមិនមានសទ្ធា រមែងសំដែងអាការៈដូចជាមានសទ្ធា, មិនមែនជាព្រះខីណាស្រព រមែងសំដែងអាការៈដូចជាព្រះខីណាស្រព, បុគ្គលនោះ ឈ្មោះថា ជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក ។ រមែងសំដែង យ៉ាងដូចម្តេច ? ។ គឺ ភិក្ខុអ្នកមិនមានសទ្ធា ក្នុងពេល

ដែលពួកមនុស្សមកកាន់ព្រះវិហារ ក្នុងថ្ងៃឆ្លងព្រះវិហារ រមែងបោសនូវព្រះវិហារជាមុន ចោលសម្រាម ដឹងថា មនុស្សទាំងនោះឃើញហើយ ក៏និមន្តទៅកាន់លានព្រះចេតិយ បោសសំអាត ចោលសម្រាម កៀរដីខ្សាច់ឱ្យស្មើ លាងសេនាសនៈទាំងឡាយ ស្រោចទឹកត្រង់ដើមពោធិ៍ ។ ពួកមនុស្ស ឃើញភិក្ខុនោះហើយ គិតថា 'ភិក្ខុអ្នកថែរក្សាព្រះវិហារ រូបដទៃ ឃើញដូចជាមិនមាន, ព្រះថេរៈអ្នកមានសទ្ធារូបនេះប៉ុណ្ណោះ រមែងថែរក្សាព្រះវិហារ' ដូច្នេះហើយ ក្នុងពេលទៅវិញ និមន្តហើយ ទើបទៅ ។ ចំណែកភិក្ខុដែលមិនមែនជាព្រះខីណាស្រព ឃើញពួកក្មេងអ្នកស្រុកហើយ សួរថា 'មាតាបិតា របស់ពួកអ្នកទាំងឡាយ តែងនិយាយ ដល់អាត្មា ថាដូចម្តេចខ្លះ ?' ដូច្នេះហើយ, កាលចើពួកក្មេងទាំងនោះពិតពុទ្ធដីកាថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន មាតាបិតា របស់ពួកខ្ញុំព្រះករុណា តែងនិយាយថា 'ព្រះគុណម្ចាស់ ជាព្រះអរហន្ត' ដូច្នេះហើយ, ទើបគិត ថា 'ពួកគហបតីទាំងឡាយ ជាអ្នកឆ្លាតដរាបណា, អាត្មាអញ ក៏មិនអាច ដើម្បីបោកបញ្ឆោត ដរាបនោះបានឡើយ' ហើយ សំដែងការៈ នៃខ្លួនជាព្រះខីណាស្រព ។ ក៏ចំណែក ពួកបាបបុគ្គលដទៃទៀត មានព្រះអរហន្តពាងទឹក និងព្រះអរហន្តពួរជ្រៃជាដើម ក៏គប្បីជ្រាប ក្នុងបាបិច្ឆតានិទ្ទេសនេះ ។

(រឿងព្រះអរហន្តពាងទឹក)

(៣៣០) បានឮថា មនុស្សអ្នកកុហកម្នាក់ កប់ពាងទឹកទុកខាងក្នុងបន្ទប់ ក្នុងពេលដែលពួកមនុស្សមក ក៏តែងចូលទៅ (លាក់ខ្លួន) ។ ពួកមនុស្ស បានសួរ ថា "ព្រះថេរៈ និមន្តទៅទីណាហើយ ?" ដូច្នេះ, កាលបើពួកកូនសិស្ស ប្រាប់ថា "ព្រះថេរៈ នៅខាងក្នុងបន្ទប់" ដូច្នេះ, សូម្បីចូលទៅត្រួតពិនិត្យមើល ក៏មិនឃើញហើយ ទើបចេញមក ។

ក្នុងខណៈនោះ មនុស្សកុហកនោះ បានចេញអំពីពាងទឹកមកហើយអង្គុយ លើកៅអី ។ ពួកមនុស្សទាំងនោះ ពោលថា "ព្រះថេរៈ មិនមាន" ដូច្នេះ, កាលបើពួកកូនសិស្ស ពោលថា "ព្រះថេរៈ នៅខាងក្នុងបន្ទប់នុ៎ះឯង" ដូច្នេះ, ទើបបានចូលទៅម្តងទៀត បានឃើញមនុស្សកុហកនោះហើយ ក៏សួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន គ្រាដំបូង យើងខ្ញុំទាំងឡាយ មិនឃើញទើបបានចេញមកហើយ, តើព្រះគុណម្ចាស់ និមន្តទៅហើយ ក្នុងទីឯណា ?" ។ មនុស្សកុហកនោះ រមែងសំដែង នូវភាពនៃខ្លួន ដូចជាព្រះអរហន្ត ដោយពាក្យ ថា "ធម្មតាពួកសមណៈ រមែងទៅកាន់ទីឋាន ដែលខ្លួនប្រាថ្នាហើយ ។" ។

រឿងព្រះអរហន្តពាងទឹក/ ចប់ ។

(រឿងព្រះអរហន្តពួរជ្រៃ)

(៣៣១) មនុស្សកុហកម្នាក់ទៀត រស់នៅក្នុងបណ្ណាសាលា ក្បែរភ្នំមួយ ។ ជើមជ្រៃមួយជើម មាននៅ ខាងក្រោយ នៃបណ្ណាសាលា របស់មនុស្សកុហកនោះឯង ។ ពួរនៃជើមជ្រៃនោះ បានដុះសំយុងទៅ ស្ថិតនៅ លើផែនដី ក្នុងកាលខាងក្រោយមក ។ មនុស្សទាំងឡាយ ទៅតាមផ្លូវនោះហើយ ក៏និមន្តមនុស្សកុហកនោះ ។ មនុស្សកុហកនោះ កាន់បាត្រនិងចីវរហើយ ចុះមកតាមពួរជ្រៃហើយ សំដែងខ្លួន ក្បែរមាត់ទ្វារផ្ទះ ។

មនុស្សទាំងឡាយ មកហើយខាងក្រោយ សួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះគុណម្ចាស់ និមន្តមក តាមផ្លូវណា ? "។ មនុស្សកុហកនោះ សំដែងនូវភាវៈនៃខ្លួនដូចជាព្រះខីណាស្រពដោយពាក្យថា "ធម្មតាផ្លូវមក របស់សមណៈទាំងឡាយ មិនត្រូវសួរឡើយ, សមណៈទាំងឡាយ តែងមកកាន់ទីឋាន ដែលខ្លួនប្រាថ្នាហើយ ។ ប៉ុណ្ណោះឯង "។

គ្រានោះ ឧបាសកម្នាក់ នៅចាំចាប់ បានឃើញមនុស្សកុហកនោះ កំពុងតែចុះមក តាមពួរជ្រៃ បានកាត់ (ពួរជ្រៃ) ពីខាងក្រោយ បន្សល់ទុក តែប្រមាណតិចតួច ។ មនុស្សកុហកមិនដឹងហេតុនោះ ក៏ចុះមក តាមពួរជ្រៃ បានធ្លាក់ចុះហើយ ។

បាត្រដីបែកហើយ ។ មនុស្សកុហកនោះ គិតថា "អាត្មាអញត្រូវ ពួកមនុស្ស ដឹងហើយ" ហើយ ក៏បានចេញរត់ទៅហើយ ។

រឿងព្រះអរហន្តពួរជ្រៃ ចប់ ។

ចំណែកសេចក្តីពិស្តារ ក្នុងរឿងនេះ គប្បីកាន់យក ចាក អដ្ឋកថាខុទ្ទកវិភង្គ ។

ពណ៌នាអំពីរឿងភាពនៃបុគ្គលអ្នកប្រាថ្នាលាភមក ចប់ ។

(៣៣២) ក្នុងអដ្ឋកថាទាំងឡាយ ព្រះអដ្ឋកថាចារ្យ សំដែង សូម្បីភាពនៃបុគ្គលជាអ្នកមិនស្គាល់ប្រមាណ របស់ពួកភិក្ខុអ្នកមាន សេចក្តីប្រាថ្នាលាភមកនិងអ្នកប្រាថ្នាច្រើន ដោយប្រការដូច្នេះ ។ មែនពិត បាបបុគ្គលទាំងនោះ រមែងញុំាងសេចក្តីប្រាថ្នាដ៏លាភមក និងសេចក្តីប្រាថ្នាច្រើន ឱ្យកើតឡើង ព្រោះភាវៈ គឺការមិនស្គាល់ ប្រមាណ ក្នុងការទទួល, ហេតុនោះ បុគ្គលអ្នកទទួល គប្បី ជាអ្នកស្គាល់ប្រមាណ ។ ដោយហេតុនោះ ព្រះដ៏មានព្រះ ភាគ កាលទ្រង់សំដែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ ក្នុងបដិគ្គាហកសូត្រ ក្នុងតេរសមវគ្គ ឯកធម្មបាលី ក្នុងឯកនិបាត អង្គុត្តរនិកាយ ថា "ភិក្ខុអ្នកទទួល គប្បីស្គាល់ប្រមាណ" ដូច្នេះ ។

អដ្ឋកថាបដិគ្គាហកសូត្រនោះ ថា "បណ្តាបទទាំងនោះ ២ បទ ថា 'មត្តា ជានិតព្វា' មានសេចក្តីថា បុគ្គលអ្នកទទួល គប្បី

ស្គាល់ប្រមាណ ។ គប្បីស្គាល់ យ៉ាងដូចម្តេច ? ។ មែនពិត បុគ្គលអ្នកទទួលនោះ គប្បីដឹងអំណាចនៃទាយក គប្បីដឹងអំណាចនៃទេយ្យធម៌ គប្បីដឹងកម្លាំង របស់ខ្លួន" ។

ជីកាបដិគ្គាហកសូត្រនោះ ថា "អធ្យាស្រ័យ ដែលផ្សេងគ្នា ដោយការទូលំទូលាយ និង មិនទូលំទូលាយ ឈ្មោះថា អំណាចនៃទាយក ។ ភាវៈនៃវត្ថុមានតិច ឬ ច្រើននុ៎ះឯង ឈ្មោះថា អំណាចនៃទេយ្យធម៌ ។ ប្រមាណដែលឈ្មួមគ្រាន់តែញ៉ាំងអត្តភាព ឱ្យប្រព្រឹត្តទៅ ឈ្មោះថា កម្លាំងរបស់ខ្លួន" ។

(៣៣៣) ក៏បុគ្គលណា ស្គាល់នូវប្រមាណ, បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាថ្នាតិច ក្នុងបច្ច័យ បណ្តាបុគ្គលអ្នកប្រាថ្នាតិច ៤ ពួកនេះ គឺ អ្នកប្រាថ្នាតិចក្នុងបច្ច័យ ១ អ្នកប្រាថ្នាតិចក្នុងធុតង្គ ១ អ្នកប្រាថ្នាតិចក្នុងព្រះបរិយត្តិ ១ អ្នកប្រាថ្នាតិចក្នុងមគ្គនិងផលដែលខ្លួនសម្រេច ១ ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាអប្បិច្ឆតាសូត្រ ក្នុងវគ្គទី ៧ ក្នុងឯកនិបាត អង្គុត្តរនិកាយ និង ក្នុងអដ្ឋកថាវេរញ្ជសូត្រ ថា "បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងបច្ច័យទាំង ៤ ឈ្មោះថា អ្នកមានសេចក្តីប្រាថ្នាតិចក្នុងបច្ច័យ ។ បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចក្នុងបច្ច័យនោះ រមែងដឹងនូវអំណាចនៃទាយក រមែង

ដឹងនូវអំណាច នៃទេយ្យធម៌ រមែងដឹងនូវកម្លាំង របស់ខ្លួន ។ ក៏ប្រសិនបើ ទេយ្យធម៌មានច្រើន, ទាយកជាអ្នកមានបំណងចង់ប្រគេនតែបន្តិចបន្តួច, ភិក្ខុទទួលតែបន្តិចបន្តួច ដោយអំណាចនៃទាយក ។ ទេយ្យធម៌ មានបន្តិចបន្តួច, ទាយកមានបំណងចង់ប្រគេនច្រើន, ភិក្ខុទទួលតែបន្តិចបន្តួច ដោយអំណាចនៃទេយ្យធម៌ ។ សូម្បីទេយ្យធម៌ មានច្រើន, ទាំងទាយក ក៏ជាអ្នកមានបំណងចង់ប្រគេនច្រើន, ភិក្ខុនោះ ដឹងនូវកម្លាំងរបស់ខ្លួនហើយ ទទួលយកតែល្មមប្រមាណប៉ុណ្ណោះ" ។

អដ្ឋកថាទសុត្តរសូត្រ ក្នុងបាដិកវគ្គ ថា "ភិក្ខុអ្នកប្រាថ្នាតិចក្នុងបច្ច័យ, កាលបើទាយកប្រគេនច្រើន, រមែងទទួលយកតែបន្តិចបន្តួច, កាលបើទាយកប្រគេនបន្តិចបន្តួច, រមែងទទួលយកតែបន្តិចបន្តួចចុះមក ឬក៏មិនទទួលយកឡើយ, មិនមែនជាអ្នកទទួលយក ដោយមិនមានសេសសល់ឡើយ" ។

(៣៣៤) អដ្ឋកថាបដិគ្គាហកសូត្រ ថា "មែនពិត ភិក្ខុអ្នកស្គាល់នូវប្រមាណហើយ ទទួលយក ដោយអាការយ៉ាងដូច្នោះ ឈ្មោះថា រមែងបំពេញអប្បិច្ឆបដិបទា ។ លាភដែលមិនទាន់កើតឡើង រមែងកើតឡើង ដល់ភិក្ខុនោះ, លាភដែលកើតឡើងហើយ រមែងស្ថិតនៅគង់វង់, ជនទាំងឡាយ ដែលមិនទាន់

ជ្រះថ្លាហើយ រមែងជ្រះថ្លា, ជនទាំងឡាយ ដែលជ្រះថ្លាហើយ រមែងដល់នូវសេចក្តីជ្រះថ្លា ច្រើនឡើងទៀត, ភិក្ខុរូបនោះ រមែងដូចជាកែវក្អែក របស់មហាជន, រមែងធ្វើនូវព្រះសាសនា ឱ្យស្ថិតនៅបានយូរអង្វែងថែមទៀតផង ។

ក្នុងដំណើរនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ÷

(៣៣៥) បានឮថា ក្នុងរោហនជនបទ ភិក្ខុកម្លោះមួយរូប ក្នុងកុឡម្ពវិយវិហារ ក្នុងសម័យដែលភិក្ខា រកបានដោយកម្រ បាននូវបាយមួយវែក ដើម្បីប្រយោជន៍ដល់ការឆាន់ ក្នុងផ្ទះរបស់កុលបុត្រម្នាក់ ឈ្មោះ លម្ពកណ្ណកៈ ក្នុងស្រុកនោះ និង បាននូវបាយមួយវែកប៉ុណ្ណោះ ដើម្បីត្រូវការចង់កាន់យកទៅ ។ ថ្ងៃមួយ ភិក្ខុរូបនោះ ឃើញភិក្ខុអាគន្តុកៈមួយរូប ក្នុងផ្ទះនោះ ក៏បានទទួលយកបាយតែមួយវែកប៉ុណ្ណោះ ។ លំដាប់នោះ កុលបុត្រនោះ បានជ្រះថ្លា ចំពោះភិក្ខុរូបនោះ ព្រោះហេតុនោះហើយ ទើបបានប្រាប់ដល់មិត្រនិងអាមាត្យទាំងឡាយ ក្នុងមាត់ទ្វារនៃព្រះរាជវាំង ថា "ព្រះគុណម្ចាស់ដ៏ចំរើន ដែលចូលទៅកាន់ត្រកូល របស់ពួកយើងខ្ញុំ មានព្រះនាមយ៉ាងនេះ" ។ ពួកមិត្រនិងអាមាត្យទាំងពួងនោះ ជ្រះថ្លា ក្នុងអប្បិច្ឆគុណ របស់ភិក្ខុរូបនោះ ហើយក៏បានតាំងភត្តជាប្រចាំ ៦០ សំរាប់ ដោយពេលមួយថ្ងៃប៉ុណ្ណោះ ។ ភិក្ខុអ្នក

មានសេចក្តីប្រាថ្នាតិច រមែងញុំាងលាភ ដែលមិនទាន់កើតឡើង ហើយ ឲ្យកើតឡើង ដោយប្រការដូច្នេះឯង ។

(៣៣៦) ក៏ព្រះបាទសង្ខាតិស្សមហារាជ ទ្រង់បានសាក ល្បងមើល នូវតិស្សអាមាត្យ ដែលជាចូឡុបដ្ឋាក ទ្រង់ត្រាស់បញ្ជា ឲ្យតិស្សអាមាត្យនោះ អាំងនូវសក្ខរទាមួយហើយ ទ្រង់ត្រាស់បញ្ជា ឲ្យនាំយកមក ។ គ្រានោះ ក្នុងពេលស្ងៀយ ព្រះអង្គទ្រង់ ព្រះតម្រិះថា 'អាត្មាអញ នឹងឲ្យចំណែកដ៏ល្អហើយ ទើបសោយ' ហើយ ទ្រង់ប្រគេនសាច់ទទា ដល់សាមណេរ ក្នុងបរិវេណនៃ កណ្ហកសលវិហារ, កាលបើសាមណេររូបនោះ ទទួលតែបន្តិច ប៉ុណ្ណោះ, ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងគុណនៃការប្រាថ្នាតិច របស់សាមណេរនោះហើយ ទ្រង់ត្រាស់ថា 'បពិត្រសាមណេរ ខ្ញុំព្រះករុណាមានចិត្តជ្រះថ្លាហើយ, ខ្ញុំព្រះករុណានឹងប្រគេន នូវភត្តជាប្រចាំ ៨ សម្រាប់ ដល់សាមណេរ' ។

សាមណេរ. បពិត្រព្រះមហារាជ អាត្មាភាព សូមប្រគេន ដល់ព្រះឧបជ្ឈាយ៍ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនភត្តជាប្រចាំដទៃទៀត ៨ សម្រាប់ ។

សាមណេរ. អាត្មាភាព សូមប្រគេនភត្តទាំងនោះ ដល់

ព្រះអាចារ្យ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនភត្ត ៨ សម្រាប់ទៀត ។

សាមណេរ. អាត្មាភាព សូមប្រគេនភត្តទាំងនោះ ដល់ពួកសហធម្មិក អ្នករួមព្រះឧបជ្ឈាយ៍ជាមួយគ្នា ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនភត្ត ៨ សម្រាប់ទៀត ។

សាមណេរ. អាត្មាភាព សូមប្រគេនភត្តទាំងនោះ ដល់ព្រះភិក្ខុសង្ឃ ។

ព្រះរាជា. ខ្ញុំព្រះករុណា ប្រគេនភត្ត ៨ សម្រាប់ទៀត ។

សាមណេរ ទទួលយកហើយ ។ លាភដែលកើតឡើងហើយ ដល់សាមណេរអ្នកមានសេចក្តីប្រាថ្នាតិចនោះ រមែងជាលាភស្ថិតស្ថេរគង់វង់ យ៉ាងដូច្នេះឯង ។

(៣៣៧) បានឮថា ទីឃព្រាហ្មណ៍ អញ្ជើញព្រាហ្មណ៍ទាំងឡាយមកបរិភោគ បានឱ្យភត្តម្នាក់ៗ ៥ ដុំលៃ ក៏មិនអាចដើម្បីនឹងឱ្យព្រាហ្មណ៍ទាំងនោះ ឆ្អែតឆ្អន់បានឡើយ ។

ថ្ងៃមួយ ព្រាហ្មណ៍នោះ បានដឹងរឿងវ៉ាវ ថា 'បានឮថា ធម្មតាសមណៈទាំងឡាយ ជាអ្នកមានសេចក្តីប្រាថ្នាតិច' ដូច្នេះ ដើម្បីនឹងសាកល្បងមើល ទើបបានឱ្យមនុស្សនាំយកភត្តទៅកាន់ព្រះវិហារ ក្នុងពេលដែលព្រះភិក្ខុសង្ឃធ្វើភត្តកិច្ច ហើយក៏បាន

ឃើញភិក្ខុទាំងឡាយ ប្រមាណ ៣០ រូប កំពុងតែឆាន់ ក្នុងសាលា សម្រាប់ឆាន់ ទើបបាននាំយកភត្តមួយផ្តិល ដើរទៅកាន់សំណាក់ នៃព្រះសង្ឃត្ថេរ ។ ព្រះថេរៈបានញុំាងម្រាមដៃឱ្យកម្រើកហើយ ចាប់យកតែបន្តិចប៉ុណ្ណោះ ។ ដោយទំនងនេះឯង ភត្តមួយផ្តិល បានដល់ទៅភិក្ខុទាំងឡាយគ្រប់អង្គហើយ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា 'បានឮថា សមណៈទាំងនេះ មានគុណ ពិតមែនតែម្តង' ដូច្នេះហើយ ជ្រះថ្លាក្នុងភាពជាអ្នក មានសេចក្តីប្រាថ្នាតិច បានលះបង់ទ្រព្យ ១ ពាន់ ឱ្យកសាងព្រះចេតិយ ក្នុងព្រះវិហារនោះឯងហើយ ។ ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាហើយ រមែងជ្រះថ្លា ដោយប្រការដូច្នេះ ។

(៣៣៨) កិច្ចដោយរឿង (ដែលសំដែងជាខុទាហរណ៍) ក្នុងពាក្យនេះថា '**បសន្នា តិយ្យោ បសាទមាបជ្ជន្តិ**' មិនមាន ។ ក៏សេចក្តីជ្រះថ្លា រមែងចំរើន ដោយក្រៃលែង ដល់ពួកជនអ្នក ដែលជ្រះថ្លាហើយ ដោយពិត ព្រោះឃើញភិក្ខុអ្នកមានសេចក្តី ប្រាថ្នាតិច ។ ក៏មហាជន ឃើញភិក្ខុទាំងឡាយអ្នកមានសេចក្តី ប្រាថ្នាតិច ដូចជាព្រះមជ្ឈន្តិកត្ថេរជាដើមហើយ រមែងសម្គាល់ ដើម្បីកើតជាអ្នកមានសេចក្តីប្រាថ្នាតិច ព្រោះហេតុនោះ ភិក្ខុអ្នក ប្រាថ្នាតិច ឈ្មោះថា ជាអ្នកប្រៀបបាននឹងកែវភ្នែក នៃមហាជន ។

(៣៣៩) មួយទៀត ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ឈ្មោះថា ធ្វើព្រះសាសនា ឲ្យស្ថិតនៅយូរអង្វែងបាន ព្រោះព្រះតម្រាស់ថា 'ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច រមែងប្រព្រឹត្តទៅ ដើម្បីស្ថិតនៅគង់វង់ ដើម្បីមិនសាបសូន្យ ដើម្បីមិនអន្តរធានទៅ នៃព្រះសទ្ធម្ម' ដូច្នេះ" ។

(៣៤០) ជីកានៃបដិគ្គាហកសូត្រនោះ ថា "បទថា **'អនុប្បន្នស្ស'** មានសេចក្តីថា លាភដែលមិនទាន់បានកើតឡើង រមែងកើតឡើង ដល់បុគ្គលនោះ ។ ២ បទថា **'ចក្ខុភូតោ ហោតិ'** មានសេចក្តីថា រមែងដូចជាកែវភ្នែក របស់មហាជន ។ បទថា **'ចិរដ្ឋិតិកំ'** មានសេចក្តីថា រមែងធ្វើនូវព្រះសាសនា ឲ្យស្ថិតនៅយូរអង្វែងបាន ដោយការញុំាងលាភ ដែលមិនទាន់បានកើតឡើង ឲ្យកើតឡើង និង ដោយការញុំាងសេចក្តីជ្រះថ្លា ឲ្យកើតឡើង ដល់មហាជន ។ បទថា **'កុឡុម្ពរិយវិហារេ'** គឺ ក្នុងព្រះវិហារដែលអាស្រ័យនៅជិតស្រុកឈ្មោះ កុឡុម្ពរិយៈ។ បទថា **'កុញ្ជនត្ថាយ'** មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការគង់ឆាន់ក្នុងផ្ទះនោះឯង ។ ២ បទថា **'គហេត្វា គមនត្ថាយ'** មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការទទួលយកទៅ ឰដ៏ខាងក្រៅនៃផ្ទះ ។ បទថា **'ធុវភត្តានិ'** បានដល់ ភត្តជាប្រចាំ ។ បទថា

'ចូឡុបដ្ឋាកំ' គឺ អ្នកធ្វើការខ្វល់ខ្វាយ ។ ២ បទថា '**អប្បិច្ឆោ ភវិតុំ**' មានសេចក្តីថា មហាជន រមែងសម្គាល់ ដើម្បីកើតជាអ្នកមានសេចក្តីប្រាថ្នាតិចខ្លួនឯង ដោយការដល់ នូវកិរិយាប្រព្រឹត្តិទៅតាមសេចក្តីយល់ឃើញ" ។

(៣៤១) បាលីនៃអប្បិច្ឆតាសូត្រ មាននៅ ក្នុងទសមវគ្គ នៃឯកនិបាត អង្គុត្តរនិកាយ យ៉ាងនេះ ថា "ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច រមែងប្រព្រឹត្តទៅ ដើម្បីការស្ថិតនៅ (យូរអង្វែង) នៃព្រះសទ្ធម្ម" ដូច្នេះជាដើម ។

ព្រោះហេតុនោះ ភិក្ខុអ្នកមានចំណង ដើម្បីការស្ថិតនៅជាយូរអង្វែង នៃព្រះសាសនា គប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ដូចជាព្រះនិគមគ្គាមវាសីតិស្សត្ថេរ និង កណ្ហតាបស ដូច្នោះឯង ។

(រឿងព្រះតិស្សត្ថេរ)

(៣៤២) បានឮថា ព្រះតិស្សត្ថេរ ជាកុលបុត្រ ក្នុងស្រុកនិគម មិនឆ្ងាយអំពីក្រុងសាវត្ថី លុះបព្វជ្ជាហើយ ជាអ្នកមានសេចក្តីប្រាថ្នាតិច សន្តោស និមន្តទៅបិណ្ឌបាត ជាប្រចាំ តែក្នុងផ្ទះនៃពួកញាតិប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយ ពោលថា "ព្រះតិស្សត្ថេរនេះ នៅច្រឡូកច្រឡំ ដោយក្រុមញាតិ, កាលបើទាយកទាំងឡាយ

មានអនាថបិណ្ឌិកសេដ្ឋីជាដើម ថ្វាយមហាទានក្តី, កាលបើព្រះបាទបសេនទិកោសលទ្រង់ថ្វាយអសទិសទានក្តី, ក៏លោកមិននិមន្តមកកាន់ក្រុងសាវត្ថីឡើយ" ហើយ ក៏បានក្រាលទូល ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់មានព្រះបំណងនឹងប្រទាន នូវសាធុការពរដល់ព្រះថេរៈនោះ ទ្រង់ត្រាស់ឱ្យហៅព្រះថេរៈនោះមកហើយ ទើបទ្រង់ត្រាស់សួរ ។ ព្រះថេរៈ បានក្រាបទូលថា "ខ្ញុំព្រះករុណាមិនបានមកហើយ ដោយនឹកគិតថា 'អាត្មាអញ អាស្រ័យពួកញាតិទាំងនេះហើយ រមែងបាន នូវអាហារល្មមគួរនឹងទំពារលេបបាន, កាលបើអាត្មាអញ បានអាហារល្មមគ្រាន់ញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅបានហើយ, នឹងមានប្រយោជន៍អ្វី ដោយការទៅស្វែងរក នូវអាហារមកទៀត' ដូច្នេះ" ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ប្រពៃណាស់ៗ" ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិចនេះ ជាបែបផែន ជាប្រពៃណី របស់តថាគត" ហើយសំដែងចូឡសុវកជាតក ទ្រង់ត្រាស់ ថា "ធម្មភាភិក្ខុ គប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ដូចជាព្រះនិគមគ្គាមវាសីតិស្សៈដូច្នោះឯង" ហើយ ទ្រង់ត្រាស់ នូវព្រះគាថា ក្នុងអប្បមាទវគ្គ នៃធម្មបទ ថា "**អប្បមាទរតោ ភិក្ខុ**" ដូច្នេះជាដើម ។

ក្នុងទីបញ្ចប់នៃព្រះគាថា ព្រះតិស្សត្ថេរ បានសម្រេចហើយ នូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

(រឿងកណ្ហតាបស)

(៣៤៣) ចំណែកកណ្ហតាបស ធ្វើដើមតាសក់ក្អែកមួយ ក្នុងហោមវន្តប្រទេស ឲ្យជាទីគោចរគ្រាម មិនបានសាងបណ្ណសាលា បាននៅហើយ ក្បែរគល់ឈើនោះឯង ។ តាបសរូបនោះ ជាអ្នក មានសេចក្តីប្រាថ្នាតិចក្រៃលែង អាស្រ័យនៅ តែក្នុងទីនោះប៉ុណ្ណោះ មិននិមន្តទៅ ក្នុងទីដទៃទៀត ដើម្បីផលាផលឡើយ ក្នុងពេល ដែលដើមឈើមានផ្លែ ក៏ឆាន់នូវផ្លែ ក្នុងពេលដែលដើមឈើ ចេញផ្កា ក៏ឆាន់ផ្កា ក្នុងពេលដែលដើមឈើលាស់សន្លឹក ក៏ឆាន់ សន្លឹក ក្នុងពេលដែលដើមឈើចេញក្រមរ ក៏ឆាន់ក្រមរ ។

ក្នុងថ្ងៃមួយ តាបសនោះ កាលនឹងបេះយកផ្លែទាំងឡាយ នៃដើមឈើនោះ មិនបានក្រោកឡើងបេះយក ក្នុងប្រទេសដទៃ ដោយកិរិយាប្រព្រឹត្តិលោភលន់ គង់នៅតាមដើមនុ៎ះឯង បានលាត ដៃទៅបេះយកផ្លែឈើដែលស្ថិត ក្នុងទីប្រមាណ ១ ហត្ថ មិនបាន រើសថា ជាទីពេញចិត្ត ឬ មិនពេញចិត្ត សូម្បីក្នុងផ្លែឈើទាំងនោះ ឡើយ ហើយចាប់យកតែផ្លែដែលមកដល់ប៉ុណ្ណោះ ។ ដោយ

តេជះនៃសីល របស់តាបសអ្នកសន្តោសដ៏ខ្ពង់ខ្ពស់ យ៉ាងដូច្នេះនោះ អាសនៈ របស់ស្តេចសក្កទេវរាជ បានកើតក្តៅហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចយាងមក ក្នុងទីនោះ ទ្រង់ជ្រះថ្លាហើយ បានប្រទានពរ ដល់តាបសនោះ ទ្រង់បានធ្វើដើមឈើនោះ ឲ្យមានផលជាប់ជានិច្ច មានរសជាតផ្អែមហើយ ទ្រង់ស្តេចយាងទៅ កាន់ទីស្ថានរបស់ព្រះអង្ត ដូចដើមវិញ ។

រឿងកណ្ហតាបស មកក្នុងកណ្ហជាតក ក្នុងទសកនិបាត ។

រឿងអ្នកប្រាថ្នាតិច ក្នុងបច្ច័យ ចប់ ។

(៣៤៤) អដ្ឋកថាទសុត្តរសូត្រ ថា "ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងធុតង្ត រមែងមិនឲ្យពួកជនដទៃដឹងថាខ្លួនជាអ្នករក្សាធុតង្តឡើយ ដូចជាព្រះថេរៈដែលជាបង បណ្តាព្រះថេរៈដែលត្រូវជាបងប្អូននឹងគ្នា ២ រូប យ៉ាងដូច្នោះឯង" ។

(រឿងព្រះថេរៈ ២ រូប បងប្អូននឹងគ្នា)

ព្រះថេរៈបងប្អូនគ្នា ២ រូប នៅហើយ ក្នុងចេតិយបពិត ។ ព្រះថេរៈ ជាប្អូន កាន់យកបាច់អំពៅ ដែលឧបដ្ឋាកបានធ្វើទៅប្រគេនហើយ ក៏បាននិមន្តទៅសំណាក់ របស់ព្រះថេរៈ ដែលជាបង ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ធ្វើ

នូវការងាន់ចុះ" ។ ក៏វេលានោះ គឺជាវេលាដែលព្រះថេរៈ ធ្វើ
ភត្តកិច្ច ខ្ពរមាត់ស្រេចហើយ ។ ព្រះថេរៈនោះ ពោលហើយ ថា
"ម្នាលអ្នកដ៏មានអាយុ គ្រប់គ្រាន់ហើយ" ។ ព្រះថេរៈដែលជា
ប្អូន បានសួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន តើព្រះគុណម្ចាស់
ជាអ្នករក្សាធុតង្គ នៃបុគ្គលអ្នកងាន់ ក្នុងអាសនៈតែមួយឬ ?" ។
ព្រះថេរៈ ពោល ថា "ម្នាលអ្នកដ៏មានអាយុ អ្នកចូរនាំយកបាច់
អំពៅមកចុះ" ដូច្នេះ សូម្បីជាអ្នករក្សាឯកាសនិកធុតង្គ អស់
រយៈពេល ៥០ ឆ្នាំ ក៏បិទបាំងនូវអង្គនៃធុតង្គ ធ្វើការងាន់ហើយ
ទើបអធិដ្ឋានអង្គនៃធុតង្គស្រេចហើយ ក៏បាននិមន្តទៅ ។

រឿងព្រះថេរៈ បងប្អូននឹងគ្នា ២ រូប មកក្នុងអដ្ឋកថា
ឯកនិបាត អង្គុត្តរនិកាយ និងវេវិនីតសូត្រ ។

រឿងព្រះមហាកុមារកស្សបត្ថេរ អ្នករក្សាធុតង្គ គឺកិរិយា
នៅក្នុងទីប៉ាឆាជាវត្ត ក៏គួរត្រួតមើល ក្នុងអដ្ឋកថាទាំងឡាយនោះ ។

រឿងភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងធុតង្គ ចប់ ។

(៣៤៥) អដ្ឋកថាទសុត្តរសូត្រ ថា "ភិក្ខុអ្នកមានសេចក្តី
ប្រាថ្នាតិចក្នុងព្រះបរិយត្តិ សូម្បីជាអ្នកចេះព្រះត្រៃបិដកក៏មិនប្រាថ្នា
ចង់ឲ្យអ្នកណាមួយដឹង ថា ខ្ញុំជាពហុស្សូតដែរ ប្រៀបដូចជាព្រះ
តិស្សត្ថេរ ដែលអាស្រ័យនៅ ក្នុងទីក្រុងសាកេត ដូច្នោះឯង" ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយជាដើម ថា "បានឮថា ព្រះថេរៈគិតថា 'ខណៈ មិនមាន' ដូច្នេះ មិនបានធ្វើនូវខុទ្ទេស និងបរិបុច្ឆា ត្រូវពួកសិស្ស ជាស់តឿន ថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះគុណម្ចាស់ នឹងបាននូវខណៈជាទីមរណភាព នៅពេលណា ?' ដូច្នេះហើយ ទើបបានលះបង់ចោលនូវពួកគណៈ ហើយនិមន្តទៅកាន់ព្រះវិហារ ក្បែរមាត់សមុទ្រដែលមានដីខ្សាច់ ដូចផ្កាកណ្ណិការ ជាអ្នកមានឧបការៈ ដល់ភិក្ខុជាព្រះថេរៈ ជាអ្នកទើបនឹងបួសថ្មី និងជាកណ្តាល ក្នុងព្រះវិហារនោះ រហូតខាងក្នុងរដូវវស្សា ក្នុងថ្ងៃឧបោសថ ក្នុងថ្ងៃមហាបវារណា បានញុំាងអ្នកជនបទ ឲ្យរំជើបរំជួលហើយ ដោយធម្មកថា ទើបបាននិមន្តទៅហើយ" ។

ដីកានៃឯកនិបាត អង្គុត្តរនិកាយជាដើមនោះ ថា "២ បទថា **'ឧបការោ ហុត្វា'** មានសេចក្តីថា ជាអ្នកមានឧបការៈ ដោយការរៀននិងការសាកសួរជាដើម ដោយអំណាចព្រះបរិយត្តិធម៌ ។ ២ បទថា **'ជនបទំ ខោភេត្វា'** មានសេចក្តីថា ញុំាងមហាជនដែលប្រជុំគ្នាហើយ ឲ្យរំជើបរំជួលហើយ ដោយអំណាចការធ្វើឲ្យព្រឺរោម ការឲ្យនូវសាធុការពរ និង ការលើកទឡ្ហីង នូវកំណាត់សំពត់ជាដើម និង ញុំាងមហាជនដទៃទៀត ឲ្យរំជើបរំជួលហើយ ដោយអំណាច នៃសេចក្តីកោលាហល ថា 'ធ្វើដូចម្តេចទៅហ្ន៎ ?

អាត្មាអញ នឹងបានស្តាប់ធម៌ ក្នុងសំណាក់ព្រះគុណម្ចាស់ដ៏ចំរើន' ។ ប្រសិនបើ ព្រះថេរៈ គប្បីប្រាថ្នាដើម្បីនឹងញុំាងអ្នកជនបទ ឲ្យដឹងថា ខ្ញុំនលោក ជាពហុស្សូត, ព្រះថេរៈក៏គប្បីញុំាងអ្នកជនបទ ឲ្យរំដើបរំជួល សំដែងធម៌ ក្នុងពេលខាងដើមតែម្តង ។ បទថា 'គតោ' មានសេចក្តីថា ព្រះថេរៈនិមន្តទៅហើយ មុនព្រះអរុណរះឡើងតែម្តង ព្រោះភាវៈជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងព្រះបរិយត្តិ ដោយភាវៈគឺការខ្ជាចក្រែងមហាជនដឹងថា 'ធម្មកថា គឺព្រះថេរៈណាធ្វើហើយ ក្នុងរាត្រី, ព្រះថេរៈរូបនោះ គឺព្រះថេរៈនេះឯង" ។

រឿងភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងព្រះបរិយត្តិ ចប់ ។

(៣៤៦) អដ្ឋកថាទសុត្តរសូត្រ ថា "ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងកិរិយាត្រាស់ដឹង រមែងមិនឲ្យពួកជនដទៃដឹងបានថា ខ្ញុំនបានសម្រេចមគ្គផលឡើយ ដូចជាព្រះមជ្ឈន្តិកត្ថេរដូច្នោះឯង" ។

អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយជាដើម ថា "បានឮថា ព្រះថេរៈ បានជាព្រះមហាខីណាស្រព ។ ក៏បាត្រនិងចីពរ របស់ព្រះថេរៈនោះ មានតម្លៃប្រមាណ ១ បាទប៉ុណ្ណោះ ។ ព្រះថេរៈនោះ បានជាព្រះសង្ឃត្ថេរ ក្នុងថ្ងៃឆ្លងព្រះវិហារ របស់ព្រះបាទ

អសោកធម្មរាជា ។ ពេលនោះ មនុស្សទាំងឡាយ ឃើញនូវភាពនៃព្រះថេរៈនោះ ជាអ្នកសៅហ្មងក្រៃពេក ទើបបានពោល ថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ នៅចាំ ឰដ៏ខាងក្រៅបន្តិចសិនចុះ' ។ ព្រះថេរៈ គិត ថា 'កាលបើព្រះខីណាស្រពអ្នកប្រាកដដូចជាអាត្មាអញ ធ្វើនូវសេចក្តីសង្គ្រោះ ដល់ព្រះរាជា, ព្រះថេរៈដទៃទៀត រូបណាទៅហ្ន៎ នឹងធ្វើបាន ?' ដូច្នេះហើយ ទើបមុជចូលទៅក្នុងផែនដីហើយ បានងើបផុសឡើង ទទួលយកដុំបាយ ដែលព្រះរាជាទ្រង់លើកប្រគេនព្រះសង្ឃត្ថេរនុ៎ះឯង" ។

ជីកានៃឯកនិបាត អង្គុត្តរនិកាយជាដើមនោះ ថា "បទថា **'អតិលូខភាវំ'** មានសេចក្តីថា មនុស្សទាំងឡាយ បានឃើញនូវភាពសៅហ្មងដ៏ក្រៃលែង ដោយអំណាច នៃបាត្រនិងចីពរហើយ គិតថា 'ថ្ងៃនេះ គឺជាថ្ងៃមង្គល, ព្រះរាជា គប្បីធ្វើព្រះគុណម្ចាស់ដ៏ចំរើន ជាអ្នកមានបាត្រនិងចីពរដែលបានរៀបចំល្អប្រសើរហើយ ឲ្យជាប្រធាន' ហើយ ពោលថា 'បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់ នៅរង់ចាំ ខាងក្រៅបន្តិចសិនចុះ' ។ បទថា **'និម្មុជ្ជិត្វា'** បានដល់ កាលបើពួកមនុស្សមិនដឹងនុ៎ះឯង, ព្រះថេរៈបានមុជចូល ក្នុងផែនដីហើយ ងើបផុសឡើងទទួលភ្លាម ។ ប្រសិនបើព្រះថេរៈ គប្បីប្រាថ្នា ថា 'សូមឲ្យមនុស្សទាំងឡាយ

ដឹងថា អាត្មាអញ ជាព្រះខីណាស្រព ដូច្នេះ, មនុស្សទាំងឡាយ ក៏មិនគប្បីពោលនឹងព្រះថេរៈនោះ ថា 'សូមព្រះគុណម្ចាស់ នៅចាំខាងក្រៅសិនចុះ' ដូច្នេះ ។ ប៉ុន្តែសេចក្តីគិត យ៉ាងដូច្នោះឯង មិនគប្បីកើតឡើង ដល់ព្រះខីណាស្រពទាំងឡាយឡើយ" ។

រឿងភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងអធិគម ចប់ ។

(៣៤៧) ក៏ភិក្ខុទាំងឡាយទាំងពួងនោះ លោកហៅថា "ជាអ្នកមានសេចក្តីប្រាថ្នាតិច" ព្រោះមិនមានសេចក្តីប្រាថ្នា ក្នុងបច្ច័យទាំងឡាយជាដើម ។ ក៏ **អប្ប** សព្ទ ក្នុងបទថា "**អប្បិច្ឆា**" នេះ ជាសេចក្តីនៃ **អភាវ** ។

ដោយហេតុនោះ ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ ទើបលោកពោលថា "បទថា '**អប្បិច្ឆស្ស**' ប្រែថា ជាអ្នកមិនមានសេចក្តីប្រាថ្នា ។ ក៏ក្នុងបទថា '**អប្បិច្ឆស្ស**' នេះ ព្យញ្ជនៈប្រៀបដូចជាមាននៅសេសសល់, ចំណែកសេចក្តី មិនមាននៅសេសសល់ឡើយ ។ មែនពិត ព្រះខីណាស្រពនោះ ព្រះដ៏មានព្រះភាគ មិនទ្រង់ត្រាស់ថា "**អប្បិច្ឆោ**" ព្រោះសេចក្តីប្រាថ្នាដែលមានប្រមាណតិចតួច នៅមាននៅឡើយ ។ តែព្រះអង្គទ្រង់ត្រាស់ថា "**អប្បិច្ឆោ**" ដូច្នេះ ក៏ព្រោះមិនមានសេចក្តីប្រាថ្នា គឺព្រោះមានការមិនលោភដែលខ្លួនសេពថ្នឹកហើយរឿយៗនុ៎ះឯង" ។

(៣៤៨) ដីកានៃឯកនិបាត អង្គុត្តរនិកាយនោះ ថា "**អប្ប** សព្ទ ជាអត្ថនៃ **អភាវ** ដូចជា **អប្ប** សព្ទ ក្នុងប្រយោគជាដើម ថា '**អប្បាពាធោ អប្បាតង្កោ**' ដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា '**អនិច្ឆស្ស**' ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់សំដែងយកការមិនមាននៃអាពាធ ផ្សេងដោយរោគ មានរោគក្អែក និងរោគក្នុងពោះជាដើម ដែលប្រាកដមាន ក្នុងលោក ទើបទ្រង់ត្រាស់ថា '**អប្បាពាធោ អប្បាតង្កោ**' ដូច្នេះ ។ ឥឡូវនេះ ដើម្បីធ្វើសេចក្តីដែលបានពោលហើយនុ៎ះឯង ឲ្យច្បាស់ជាងមុន ទើបលោកពោលថា '**ឯត្ថ ហិ**' ដូច្នេះជាដើម ។ ព្យញ្ជនៈប្រៀបដូចជាមានសេចក្តីនៅសេសសល់ ព្រោះ **អប្ប** សព្ទ ប្រាកដមានសូម្បីក្នុងអត្ថថាបន្តិចបន្តួច ។ ចំណែកសេចក្តីមិនមានសេចក្តីនៅសេសសល់ឡើយ ព្រោះភាវៈនៃការមិនមានសេចក្តីប្រាថ្នា ក្នុងបច្ច័យ គឺលោកបានអធិប្បាយហើយ ដោយប្រការទាំងពួង ។ ព្រោះហេតុនោះ ទើបលោកពោលថា '**ន ហិ**' ដូច្នេះជាដើម" ។

ភាវៈនៃ **អប្ប** សព្ទ ជាអត្ថនៃ **អភាវ** គប្បីត្រួតមើលក្នុងអដ្ឋកថាវេរញ្ជិតសូត្រនិងទសុត្តរសូត្រ និងដីកានៃសូត្រនោះ ។

(៣៤៩) ភិក្ខុអ្នកប្រាថ្នាដើម្បីនឹងបំពេញបដិបទា ដែលជាប់ទាក់ទងនឹងការប្រាថ្នាតិច ក្នុងបច្ច័យ គប្បីជាអ្នកដឹងប្រមាណ ក្នុងការទទួល ដោយប្រការដូច្នេះ ។ មែនពិត ភិក្ខុកាលរស់នៅ យ៉ាងដូច្នេះ ឈ្មោះថា ជាអ្នកសន្តោស, ក៏បាបធម៌ទាំងឡាយ មានភាពជាអ្នកមានសេចក្តីប្រាថ្នាដ៏លើសលប់ជាដើម គឺភិក្ខុអ្នកសន្តោស តែងលះបង់បាន ។ ព្រោះហេតុនោះ សេចក្តីសន្តោស របស់ភិក្ខុរូបនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា 'ជាមង្គល' ។ ក៏ភិក្ខុទាំងឡាយ ជាអ្នកសន្តោស ទៅកាន់សុគតិ ហួសផុតពីការគណនា (រាប់មិនអស់) ។ នឹងមានប្រយោជន៍អ្វី ដោយរឿងរ៉ាវ (ដែលត្រូវយកមកសំដែង) ។ ក៏ភិក្ខុអ្នកស្ថិតនៅ ក្នុងសេចក្តីសន្តោស រមែងបានសម្រេចព្រះអរិយមគ្គ ។ ហេតុនោះ សេចក្តីសន្តោសនោះ របស់ភិក្ខុរូបនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា "ជាគ្រឿងឧបត្ថម្ភនូវអរិយមគ្គ" ។ ក៏ក្នុងដំណើរនេះ មានព្រះថេរៈអ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បង្សុកូលជាវត្ត ដែលអាស្រ័យនៅក្នុងបាចីនខណ្ឌរាជីវិហារ ជាឧទាហរណ៍ ។ រឿង ខ្ញុំពោលហើយ ក្នុងចីវរសន្តោសន៉ុះឯង ព្ធដ៏ខាងក្រោយ ។

(៣៥០) ក៏ភិក្ខុអ្នកសន្តោសហើយ រមែងជាអ្នកប្រព្រឹត្ត ដូចជាកុយរមាស ។ ហេតុនោះ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ

ជាដើម ទើបលោកពោល ថា "ភិក្ខុអ្នកសន្តោសនោះ កាលប្រើប្រាស់នូវសេនាសនៈ ដែលខ្លួនប្រាថ្នាហើយៗ គឺ ដងព្រៃ គល់ឈើ ញកព្រៃ ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង នៅតែម្នាក់ឯង មិនមានសំឡាញ់ ក្នុងឥរិយាបថទាំងពួង ប្រៀបដូចជាកូនសរ ដែលរបូតចេញផុតអំពីខ្សែ និងប្រៀបដូចជាដំរីចុះប្រែង ចៀសចេញអំពីហ្វូង ដូច្នោះឯង រមែងដល់ នូវភាពជាអ្នកប្រៀបដូចជាកុយរមាស ដែលលោកពណ៌នាហើយ យ៉ាងដូច្នេះ ថា ÷

> "ភិក្ខុអ្នកសន្តោសហើយ រមែងរស់នៅជាសុខ ក្នុងទិសទាំង ៤ និង ជាអ្នកមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត កាលសន្តោស ដោយបច្ច័យក្រៅនេះនិងក្រៅនេះ (តាមមានតាមបាន) គ្របសង្កត់ នូវសេចក្តីអន្តរាយទាំងឡាយបាន ជាអ្នកមិនភ័យខ្លាច ជាបុគ្គលម្នាក់ឯង ប្រៀបដូចជាកុយរមាស គប្បីគ្រាច់ចរទៅ"។

សួរថា "តើអ្នកណាពណ៌នាទុកហើយ ?"។ ឆ្លើយថា "ព្រះបច្ចេកពុទ្ធមួយអង្គ បានពណ៌នាទុកហើយ"។

បានឮថា ព្រះបច្ចេកពុទ្ធអង្គនោះ ជាព្រះរាជាក្នុងទីក្រុង

ពារាណសី ទ្រង់គង់នៅ លើព្រះរាជបល្ល័ង្ក ទ្រង់ញុំាងវិបស្សនា ឲ្យ
ចំរើនហើយ ក៏បានសម្រេចព្រះបច្ចេកពោធិញ្ញាណ ទ្រង់បានភាសិត
ហើយនូវឧទានគាថា ថា "**ចាតុទ្ទិសោ**" ដូច្នេះជាដើម ។ គាថា
នោះ មកហើយ ក្នុងខគ្គវិសាណសូត្រ ក្នុងបឋមវគ្គ សុត្តនិបាត ។

(៣៥១) អដ្ឋកថាខគ្គវិសាណសូត្រ ថា "បណ្តាបទទាំង
នោះ បទថា '**ចាតុទ្ទិសោ**' មានសេចក្តីថា ជាអ្នកមានប្រក្រតីនៅ
តាមសប្បាយ ក្នុងទិសទាំង ៤ ។ ព្រហ្មវិហារភាវនា គឺភិក្ខុរូប
នោះ ផ្សព្វផ្សាយទៅហើយ ដោយន័យ ថា '**ឯកំ ទិសំ ផរិត្វា
វិហរតិ**' ដូច្នេះជាដើម ។ ទិសទាំងឡាយ ៤ របស់ភិក្ខុអ្នក
សន្តោសនោះ តែងមាន ព្រោះហេតុនោះឯង ភិក្ខុអ្នកសន្តោស
នោះ ឈ្មោះថា **ចាតុទ្ទិសោ** ។ ភិក្ខុអ្នកសន្តោស រមែងមិន
ក្រហល់ក្រហាយ ព្រោះភ័យខ្លាច ក្នុងសត្វ ឬសង្ខារ ក្នុងទីណា
ក្នុងទិសទាំងឡាយនោះ ព្រោះហេតុនោះ ភិក្ខុអ្នកសន្តោសនោះ
ឈ្មោះថា **អប្បដិឃោ** (អ្នកមិនក្រហល់ក្រហាយ) ។ បទថា
'**សន្តុស្សមានោ**' មានសេចក្តីថា ជាអ្នកសន្តោស ដោយអំណាច
សេចក្តីសន្តោស ១២ យ៉ាង ។ បទថា '**ឥតរីតរេន**' គឺ ដោយ
បច្ច័យដែលខ្ពស់ៗ ទាបៗ ។ ក្នុងពាក្យថា '**បរិស្សយានំ
សហិតា**' នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ៖ សេចក្តីអន្តរាយ

ទាំងឡាយ រមែងបៀតបៀនដោយជុំវិញ គឺ រមែងញុំាងកាយ និង ចិត្ត ឱ្យតក់ស្លុត ទើបឈ្មោះថា **បរិស្សយានិ** ។ ម្យ៉ាងទៀត សេចក្តីអន្តរាយទាំងឡាយ ដល់ព្រមហើយ ដល់កាយនិងចិត្តទាំង ឡាយនោះ ទើបឈ្មោះថា **បរិស្សយានិ** ។ ពាក្យថា **'បរិស្សយានិ'** នេះ ជាឈ្មោះ នៃសេចក្តីអន្តរាយខាងផ្លូវកាយ និងចិត្ត ដែលប្រព្រឹត្តទៅឰដ៏ខាងក្រៅ មានសីហៈនិងខ្លាធំជាដើម និងដែលប្រព្រឹត្តទៅឰដ៏ខាងក្នុង មានកាមច្ឆន្ទៈជាដើម ។ កិក្ខុ អ្នកសន្តោស រមែងគ្របសង្កត់ នូវសេចក្តីអន្តរាយទាំងឡាយនោះ ដោយអធិវាសនខន្តី និង ដោយធម៌ទាំងឡាយ មានសេចក្តីព្យាយាម ជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកគ្របសង្កត់នូវសេចក្តី អន្តរាយទាំងឡាយបានហើយ ។ ឈ្មោះថា ជាអ្នកមិនតក់ស្លុត ព្រោះមិនមានភ័យ ដែលធ្វើនូវភាពជាអ្នកតក់ស្លុត " ។

ជីកានៃចូឡហត្ថិបទោបមសូត្រ និង ចតុក្កនិបាត អង្គុត្តរ-និកាយ ថា " ជាបុគ្គលម្នាក់ឯង មិនមានសំឡាញ់ ទៅហើយនុ៎ះឯង, អធិប្បាយថា ' ឈ្មោះថា ជាអ្នកប្រៀបបាននឹងកុយរមាស ព្រោះ ភាវៈជាអ្នកដូចជាស្នែង នៃសត្វម្រឹគ ដែលបានឈ្មោះថា រមាស គប្បីត្រាច់ចរទៅ ' ដូច្នេះ " ។

អដ្ឋកថាខគ្គវិសាណសូត្រ ថា " កុយនៃសត្វរមាស ឈ្មោះថា

ខគ្គវិសាណ ។ **កប្ប** សព្ទ ជាអត្ថនៃបដិភាគ (ភាគប្រដូច) ។ សមដូចជាពាក្យដែលព្រះបច្ចេកពុទ្ធ ទ្រង់ត្រាស់អធិប្បាយទុក ថា 'ប្រៀបដូចជាកុយរមាស' ដូច្នេះ ។

(៣៥២) សេចក្តីនេះ ថា "មួយវិញទៀត ភិក្ខុអ្នកមិនសន្តោសហើយ រមែងសាបសូន្យ ចាកទ្រព្យខ្លះ ចាកជីវិតខ្លះ, ភិក្ខុអ្នកសន្តោសហើយ រមែងមិនសាបសូន្យ" ដូច្នេះ គប្បីសំដែងសូម្បីដោយជរូទបានជាតក ក្នុងបឋមវគ្គ នៃតិកនិបាត ។

មែនពិត ទ្រព្យ របស់បុគ្គលអ្នកសន្តោសហើយ សូម្បីបាត់បង់ទៅហើយ ក៏រមែងមាននៅជាប្រក្រតី ដូចដើមវិញ ។

ក្នុងដំណើរនោះ មានរឿងនេះ (ជាឧទាហរណ៍) ÷

(រឿងស្តេចសេក)

ក្នុងអតីតកាល ព្រះពោធិសត្វ សោយជាតិជាស្តេចសេក ក្នុងព្រៃឧទុម្ពរ (ព្រៃល្វា) ក្បែរមាត់ច្រាំងទន្លេគង្គា, កាលបើផ្លែឈើរបស់ខ្លួនអស់ហើយ, ក៏ចឹកស៊ីតែពន្លក (ត្រួយ) សន្ធឹកសំបក ឬក្រមរ ដែលមាននៅសល់ហើយប៉ុណ្ណោះឯង ហើយបានផឹកទឹក ក្នុងទន្លេគង្គា ជាសត្វមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស យ៉ាងក្រៃលែង មិនហើរទៅ ក្នុងទីស្ថានដទៃឡើយ ។

ដោយគុណនៃភាពជាអ្នកមានសេចក្តីប្រាថ្នាតិច និង សន្តោស របស់ស្តេចសេកនោះ ភពរបស់ស្តេចសក្កទេវរាជ បានកម្រើកហើយ ។ ស្តេចសក្កទេវរាជ ជ្រាបហេតុនោះហើយ ទ្រង់បានញុំាងដើមឈើនោះ ឱ្យក្រៀមស្ងួតអស់ហើយ ដោយអានុភាពរបស់ព្រះអង្គ ដើម្បីនឹងសាកល្បងនូវស្តេចសេកនោះ ។ ដើមឈើ មាននៅត្រឹមតែដង្គត់ ធ្លុះដាច់អស់ហើយ, កាលបើខ្យល់បក់បោកមក, ក៏បញ្ចេញសំឡេង ដូចជាត្រែវបុគ្គលគោះ បានតាំងនៅហើយ ។ លំអង ទាំងឡាយ ក៏ចេញមកអំពីប្រហោងទាំងឡាយនៃដើមឈើនោះ ។ ស្តេចសេក បានចឹកស៊ីលំអងទាំងនោះហើយ មិនបានហើរទៅ ក្នុងទីស្ថានដទៃទៀត មិនបាននឹកគិតដល់ខ្យល់ និង កំដៅថ្ងៃឡើយ បានទំនៅលើចុងដង្គត់ដើមខ្ទុម្ពរហើយ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រះថ្លាហើយ ទើបបានដងទឹក ក្នុងទន្លេគង្គា មកស្រោចដង្គត់ឈើនោះហើយ ។ ក្នុងពេលជាមួយគ្នានោះឯង ដើមឈើ ក៏បានសម្បូរដោយមែកនិងបង្គាប មានផ្លែផ្អែម ដុះឡើងហើយ ។

រឿងស្តេចសេក មកក្នុងអដ្ឋកថាចូឡសុវណ្ណជាតក ក្នុងនវកនិបាត ។

(៣៥៣) ព្រោះហេតុនោះ ភិក្ខុអ្នកមានបំណងចង់ ឱ្យព្រះសាសនាស្ថិតនៅអស់កាលជាយូរអង្វែង គប្បីជាអ្នកសន្តោសចុះ ។

ព្រោះថា ភាវៈជាអ្នកមានសេចក្តីសន្តោស រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិននិនាស នៃព្រះសាសនា, ភាពជាអ្នកមិនមានសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស នៃព្រះសាសនា ។

ព្រោះហេតុនោះ ក្នុងទសមវគ្គ នៃឯកនិបាត អង្គុត្តរនិកាយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ថា "ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ដូចជាសេចក្តីមិនសន្តោសនេះសោះឡើយ, ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោសទេ ទើបប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម" ដូច្នេះ និងទ្រង់ត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិនឃើញ នូវសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីបឹតនៅ មិននិនាស មិនអន្តរធានព្រះសទ្ធម្ម ដូចជាសេចក្តីសន្តោសនេះសោះឡើយ, ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោសទេ ទើបប្រព្រឹត្តទៅ ដើម្បីបឹតនៅ មិននិនាស មិនអន្តរធានព្រះសទ្ធម្ម" ដូច្នេះ ។

(៣៥៤) អដ្ឋកថានៃសូត្រទាំង ២ នោះ ថា "បណ្តាបទទាំងនោះ បទថា '**សទ្ធម្មស្ស**' គឺ នៃធម៌ដ៏ល្អ, អធិប្បាយថា 'នៃព្រះសាសនា' ។ បទថា '**សម្មោសាយ**' គឺ ដើម្បីសេចក្តី

វិនាស ។ បទថា **'អន្តរធានាយ'** គឺ ដើម្បីសេចក្តីមិនប្រាកដ ។ បទថា **'បិតិយា'** គឺ ដើម្បីបិតនៅអស់កាលដ៏យូរ ។ ពាក្យថា **'អសម្មោសាយ អនន្តរធានាយ'** គប្បីជ្រាប ដោយន័យដែលជាប្រតិបក្ស ដូចបានពោលមកហើយនុ៎ះឯង" ។

ជីកានៃសូត្រទាំង ២ នោះ ថា "គប្បីប្រកាន់យកសេចក្តីដោយពាក្យ យ៉ាងនេះ ថា 'ដើម្បីមិនវិនាស' ដូច្នេះជាដើម ក្នុងបទថា **'វុត្តប្បដិបក្ខនយេន'** ដូច្នេះ" ។

(៣៥៥) ក៏ព្រះតម្រាស់ទាំងអស់នុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សំដៅយក នូវភាពជាអ្នកមានសេចក្តីសន្តោស និងភាពជាអ្នកមិនមានសេចក្តីសន្តោស ក្នុងបច្ច័យទាំងឡាយ មានចីវរបច្ច័យជាដើម ។ ក៏ភាពជាអ្នកមានសេចក្តីសន្តោស ក្នុងធម៌ទាំងឡាយដែលមិនមានទោស មានទាននិងសីលជាដើម មិនសមគួរឡើយ, ភាពជាអ្នកមិនសន្តោស ក្នុងធម៌ទាំងឡាយនោះឯង ទើបសមគួរ ។

ហេតុនោះ ក្នុងគតិយបណ្ណាសកៈ ទុកនិបាត អង្គុត្តរនិកាយ ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ថា "**អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ**" ដូច្នេះ ។

(៣៥៦) ក្នុងអដ្ឋកថាទុកនិបាត អង្គុត្តរនិកាយនោះ លោកពោលទុកហើយ ថា "ភាពជាអ្នកមិនសន្តោស ក្នុងកុសលធម៌

ទាំងឡាយ លើកលែងតែការបានសម្រេចព្រះអរហាត្តចេញ ឈ្មោះថា **អសន្តុដ្ឋិតា** ”។

ដីកានៃតតិយបណ្ណាសកៈនោះ ថា “ ២ បទថា ‘**អញ្ញត្រ អរហត្តប្បត្តា**’ បានដល់ វៀរចាកការបានសម្រេចព្រះអរហត្ត”។

បាលីនិក្ខេបកណ្ឌ ថា “ពាក្យថា ‘**អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ**’ មានសេចក្តីថា សេចក្តីប្រាថ្នា ដ៏ក្រៃលែង នៃបុគ្គលអ្នកមិនសន្តោស ដោយការចំរើនកុសលធម៌ទាំងឡាយឯណា ”។

ដីកានៃសង្គីតិសូត្រ ថា “ ២ បទថា ‘**កុសលានំ ធម្មានំ**’ គឺ នូវធម៌ដែលមិនមានទោសទាំងឡាយមានសីលជាដើម។ បទថា ‘**ភាវនាយ**’ បានដល់ ដោយកិរិយាធ្វើឲ្យកើតឡើង និង ដោយកិរិយាធ្វើឲ្យចំរើនឡើង។ បទថា ‘**អសន្តុដ្ឋស្ស**’ មានសេចក្តីថា អ្នកមិនសន្តោស ដោយអំណាចនៃការដល់ នូវសេចក្តីរួញរាស្ទាក់ស្ទើរ ដោយគិតថា ‘ដោយហេតុមានប្រមាណប៉ុណ្ណោះ ក៏គ្រប់គ្រាន់ហើយ, ដោយហេតុមានប្រមាណប៉ុណ្ណោះ ក៏គ្រប់គ្រាន់ហើយ ’។ សេចក្តីប្រាថ្នា ក្នុងកិរិយាធ្វើឲ្យកើតឡើង ដោយក្រៃលែង ។ ឈ្មោះថា **ភិយ្យោកម្យតា** ”។

(៣៥៧) អដ្ឋកថានិក្ខេបកណ្ឌ ថា “ សេចក្តីប្រាថ្នា ដោយវិសេស ឈ្មោះថា **ភិយ្យោកម្យតា** ។ បុគ្គលពួកខ្លះ ក្នុង

លោកនេះ ជាដំបូងនុ៎ះឯង រមែងប្រគេនបក្ខិកភត្តខ្លះ សលាកភត្តខ្លះ, បុគ្គលនោះ ជាអ្នកមិនសន្តោស ដោយការប្រគេននោះ ទើបប្រគេនភត្តប្រចាំ សង្ឃភត្ត សំពត់ចំណាំវស្សា ឱ្យកសាងអារាមប្រគេនបច្ច័យទាំង ៤ ថែមទៀតផង, ជាអ្នកមិនសន្តោស សូម្បីក្នុងការប្រគេននោះ ក៏ទទួលនូវសរណៈ សមាទានសីល ៥, ជាអ្នកមិនសន្តោស សូម្បីក្នុងការទទួលសរណៈជាដើមនោះ ទើបបួស, លុះបួសហើយ ក៏រៀន ១ និកាយ ២ និកាយ ព្រះពុទ្ធវចនៈគឺព្រះត្រៃបិដក ញុំាងសមាបត្តិទាំង ៨ ឱ្យកើតឡើង ចំរើនវិបស្សនាហើយ ក៏ឈោងយកព្រះអរហត្ត, ចាប់តាំងពីបានសម្រេចនូវព្រះអរហត្តហើយ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានសេចក្តីសន្តោសយ៉ាងធំ ។ ក៏សេចក្តីប្រាថ្នា ដោយវិសេស ក្នុងព្រះអរហត្តយ៉ាងដូច្នេះ ឈ្មោះថា **អិយ្យោកម្យតា** ” ។

អដ្ឋកថាសង្គីតិសូត្រ ថា “ ក៏បុគ្គលជាអ្នកព្រមព្រៀង ដោយសេចក្តីប្រាថ្នា យ៉ាងក្រៃលែងនោះ បំពេញសីលហើយ រមែងញុំាងឈាន ឱ្យកើតឡើង, បានឈានហើយ រមែងប្រារព្ធវិបស្សនា, ប្រារព្ធវិបស្សនាហើយ ក៏ចាប់យកនូវព្រះអរហត្ត រមែងមិនដល់នូវការឈប់សម្រាក (រសាយចិត្ត) ក្នុងចន្លោះ ” ។

(៣៥៨) ព្រោះហេតុនោះ កុលបុត្រ មិនគួរធ្វើសេចក្តី

សន្តោស ដោយការញុំាងកុសល ឲ្យកើតឡើងឡើយ ។ ព្រោះថា បុគ្គលកាលធ្វើនូវបុណ្យ ជារឿយ ។ រមែងបានសម្រេចសូម្បីនូវ សេចក្តីសុខដែលជាលោកុត្តរ ដូចជាព្រាហ្មណ៍ម្នាក់ អាស្រ័យនៅ ក្នុងទីក្រុងសាវត្ថី ដូច្នោះឯង ។

(រឿងព្រាហ្មណ៍ម្នាក់)

បានឮថា ថ្ងៃមួយ ព្រាហ្មណ៍នោះ ចេញ (ពីផ្ទះ) តាំងតែ អំពីព្រឹកព្រលឹមហើយ ក្រឡេកមើលភិក្ខុទាំងឡាយ ដែលកំពុងតែ គ្រងចីវរ ក្នុងទីកន្លែងមួយ ដែលមានស្មៅដុះឡើង បានឃើញ នូវមុមចីវរ របស់ភិក្ខុមួយអង្គ មកប៉ះរះ លើស្មៅទាំងឡាយ ទទឹកជោក ដោយតំណក់ទឹកសន្សើមហើយ ទើបគិតថា “ អាត្មា អញ ធ្វើទីកន្លែងនេះ ឲ្យអស់ស្មៅ ទើបសមគួរ ” ដូច្នេះហើយ លុះថ្ងៃស្អែកឡើង ទើបយកចបមកចាំងជម្រះទីកន្លែងនោះហើយ ធ្វើឲ្យដូចជាទីមណ្ឌលនៃលាន សូម្បីក្នុងថ្ងៃស្អែកឡើងទៀត ក៏បាន ទៅហើយ ក្នុងទីនោះ បានឃើញមុមចីវរ របស់ភិក្ខុមួយរូប ធ្លាក់ មកលើផែនដី ប្រឡាក់ដោយធូលី ទើបគិត ថា “ ការដែល អាត្មាអញ កៀរនូវដីខ្សាច់ ក្នុងទីនេះ ទើបសមគួរ ” ដូច្នេះហើយ ក៏បានធ្វើហើយ យ៉ាងដូច្នោះឯង ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលមុនភត្ត កើតមានកំដៅថ្ងៃក្តៅយ៉ាងខ្លាំង ។ សូម្បីក្នុងគ្រានោះ ព្រាហ្មណ៍នោះ ក៏បានទៅក្នុងទីនោះ បានឃើញញើសកំពុងហូរចេញយ៉ាងស្រស្រាក់ អំពីសរីរៈរាងកាយ របស់ភិក្ខុទាំងឡាយ ដែលកំពុងគ្រងចីវរ ទើបបានឱ្យកសាងមណ្ឌបឡើង ក្នុងទីនោះ ។ ថ្ងៃក្រោយមកទៀត មានភ្លៀងធ្លាក់ តាំងតែអំពីព្រលឹមស្រាង ។ សូម្បីក្នុងពេលនោះ ព្រាហ្មណ៍នោះ ក៏បានទៅ ក្នុងទីនោះ បានឃើញហើយនូវភិក្ខុទាំងឡាយមានចីវរទទឹកជោក ក៏ឱ្យគេរុះរើមណ្ឌបចេញហើយ ឱ្យកសាងសាលា ក្នុងទីនោះ ជាអ្នកមានបំណងចង់ធ្វើការឆ្លងសាលា ទើបបាននិមន្តព្រះសាស្តា ព្រមទាំងព្រះសង្ឃ មកគង់នៅ ក្នុងសាលានោះ ហើយថ្វាយទាន ក្នុងពេលចប់ភត្តកិច្ចស្រេចហើយ ទើបបានក្រាបទូលនូវកម្ម ដែលខ្លួនបានធ្វើហើយគ្រប់បែបយ៉ាង ចាប់ដើមតាំងអំពីគ្រាដំបូងមក ដល់ព្រះសាស្តា ។

ព្រះសាស្តា ទ្រង់សំដែងថា “ម្នាលព្រាហ្មណ៍ ធម្មតាបណ្ឌិតកាលធ្វើកុសល ម្តងបន្តិច ។ រាល់ ។ ខណៈ រមែងកម្ចាត់បង់នូវសេចក្តីសៅហ្មង របស់ខ្លួន ដោយលំដាប់ បានដោយពិតប្រាកដ” ដូច្នេះ ទើបទ្រង់បានត្រាស់ហើយ នូវព្រះគាថានេះ ក្នុងមលវគ្គនៃធម្មបទ ថា ÷

(៣៥៩) "អ្នកមានប្រាជ្ញា គួរកំចាត់បង់ចោល
នូវមន្ទិល របស់ខ្លួន បន្តិចម្តងៗ រាល់ៗ ខណៈ
ដោយលំដាប់ ប្រៀបដូចជាងមាស ជំរះចោល
នូវស្នើមឬច្រែះ របស់មាស យ៉ាងដូច្នោះឯង"។

បណ្តាបទទាំងនោះ បទថា "**អនុបុព្ពេន**" គឺ តាមលំដាប់បានដល់ ដោយហូរហែ ។ បទថា "**មេធាវី**" មានសេចក្តីថា បុគ្គលអ្នកប្រកបព្រមហើយ ដោយបញ្ញាដ៏រុងរឿង ក្នុងព្រះធម៌ កាលធ្វើកុសល បន្តិចម្តងៗ រាល់ៗ ខណៈ គឺរាល់ៗ ពេល ។

បាទគាថា ថា "**កម្មារោ រជតស្សេវ**" មានសេចក្តីថា ដូចជាជាងមាស ជម្រះចោលនូវស្នើមឬច្រែះនៃមាស ដូច្នោះឯង ។

បទថា "**និទ្ធមេ**" មានសេចក្តីថា គប្បីកំចាត់ គឺយកចេញ នូវមន្ទិល គឺរាគៈជាដើមរបស់ខ្លួន, អធិប្បាយថា "ប្រៀបដូចជាជាងមាស ធ្វើមាសឱ្យក្តៅហើយ ដំនាំយកស្នើមឬច្រែះចេញ អស់វារៈពេលមួយដងប៉ុណ្ណោះ រមែងមិនអាច ដើម្បីធ្វើគ្រឿងប្រដាប់ យ៉ាងទំនើបៗបានឡើយ, ប៉ុន្តែកាលបើដុតដំនាំយកស្នើមឬច្រែះចេញ ជារឿយៗ បន្ទាប់អំពីនោះមក ទើបធ្វើនូវគ្រឿងប្រដាប់ដ៏ទំនើបៗ ច្រើនជាអនេកបាន យ៉ាងណាមិញ,

បុគ្គលជាបណ្ឌិត កាលធ្វើនូវកុសលជារឿយ ៗ កំចាត់ចោលនូវមន្ទិលមានរាគៈជាដើម របស់ខ្លួនបានហើយ ជាអ្នកបានកំចាត់មន្ទិលចោលហើយ គឺ មិនមានកិលេស ក៏យ៉ាងដូចោះដែរ" ។

ក្នុងទីបញ្ចប់នៃព្រះគាថា ព្រាហ្មណ៍នោះ ក៏បានសម្រេចជាព្រះសោតាបន្នបុគ្គលហើយ ។

រឿងព្រាហ្មណ៍ម្នាក់ ចប់ ។

ការពណ៌នាអំពីបទ ថា សេចក្តីសន្តោស ចប់ ។

(មង្គលត្ថទីបនីប្រែ ភាគទី៣ ចប់)

សូមសេចក្តីសម្រេចកើតមានដល់អ្នកសិក្សាគ្រប់ ៗរូបកុំបីខាន ។

ប្រែចប់ថ្ងៃព្រហស្បតិ៍ ៨ កើត ខែភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃទី ២៣ ខែកញ្ញា ១៩៩៣
វេលាម៉ោង ១០: ១១ នាទី ព្រឹក

ស្តេចអង្គនោះ ត្រាស់ប្រាប់ភ្លាមថា ម្នាលសម្លាញ់ ចូរអ្នកនាំយក
ម្ហូបអាហារដ៏ឆ្ងាញ់ ប្រណីតជាច្រើនមក ដើម្បីឲ្យយើងបរិភោគ
ឲ្យបានច្រើនតាមចិត្តប្រាថ្នាចុះ ព្រោះថាយើងមិនដែលឃើញ
ឬស្តាប់ឮនូវរសជាតិដ៏ឆ្ងាញ់ ប្រណីតយ៉ាងនេះ ក្នុងកាលមុន
ឡើយ ដោយហេតុនេះ ទើបយើងនឹងបរិភោគនូវរសជាតិដ៏
ឆ្ងាញ់ ប្រណីតនេះ ឲ្យបានច្រើនតាមចិត្តប្រាថ្នា ដោយប្រាកដ
ម្នាលសម្លាញ់ ក្នុងកាលមុន យើងមិនដែលបរិភោគនូវរសជាតិ
ដ៏ឆ្ងាញ់ ប្រណីតយ៉ាងនេះ ដូចជាសម្តេចព្រះបាទវេស្សន្តរ
ព្រះមហាក្សត្រ ដែលទ្រង់ព្រះនាមថា ជេតៈ ក្នុងក្រុងសេតៈ
ដែលមានកំពែងជាច្រើនជាន់ ដែលមានទ្វារជាច្រើន ដែលមាន
ប្រាសាទជាច្រើន ដែលមានផ្លូវជាច្រើន ដែលមានផ្លូវបំបែក
ជាច្រើន ដែលមានផ្លូវបំបែកជាច្រើនប្រសព្វគ្នា ដែលមានផ្លូវ
ធំជាច្រើន ដែលមានផ្លូវតូចជាច្រើន ដែលមានផ្លូវតូចជាច្រើន
ប្រសព្វគ្នា ដែលមានផ្លូវតូចជាច្រើនប្រសព្វគ្នា ដែលមានផ្លូវ
ធំជាច្រើនប្រសព្វគ្នា ដែលមានផ្លូវតូចជាច្រើនប្រសព្វគ្នា ដែល
មានផ្លូវធំជាច្រើនប្រសព្វគ្នា ដែលមានផ្លូវតូចជាច្រើនប្រសព្វគ្នា
ដែលមានផ្លូវធំជាច្រើនប្រសព្វគ្នា ដែលមានផ្លូវតូចជាច្រើន
ប្រសព្វគ្នា ដែលមានផ្លូវធំជាច្រើនប្រសព្វគ្នា ដែលមានផ្លូវ
តូចជាច្រើនប្រសព្វគ្នា ដែលមានផ្លូវធំជាច្រើនប្រសព្វគ្នា ដែល
មានផ្លូវតូចជាច្រើនប្រសព្វគ្នា ដែលមានផ្លូវធំជាច្រើនប្រសព្វគ្នា
ដែលមានផ្លូវតូចជាច្រើនប្រសព្វគ្នា ដែលមានផ្លូវធំ

ចត្តនានានៃពុទ្ធិកសមាគមន៍ព្រះសង្ឆខ្មែរដែលបាន
ជួយឧបត្ថម្ភក្នុងការបោះពុម្ពសៀវតោ
មង្គលត្ថនីបនីប្រែ ទាំង ៤ ភាគ ដើម្បីចែកផ្សាយ
ជាធម្មទាននេះ មានដូចតទៅ

១- វត្តខេមរពុទ្ធិការាម ទីក្រុងឡងបឹច
២- វត្តវិបស្សនារាម ទីក្រុងឡងបឹច
៣- វត្តពុទ្ធរង្សី ទីក្រុងហុស្ទុន តិចសាស់
៤- វត្តផេតពន ទីក្រុងដាល់ឡាស់ តិចសាស់
៥- វត្តខេមររតនារាម ទីក្រុងសាន់ឌីកូ
៦- វត្តសុវណ្ណគីរី ទីក្រុងសាន់ឌីកូ
៧- វត្តសាន់តាអាណា ទីក្រុងសាន់តាអាណា
៨- វត្តពុទ្ធសាសនរង្សី ទីក្រុងហ្រ្វេះស្ទូ
៩- វត្តសាន់ហូសេ ទីក្រុងសាន់ហូសេ
១០- វត្តប៉ូម៉ូណារាម ទីក្រុងប៉ូម៉ូណា
១១- វត្តត្រែកូដ ទីក្រុងអិលអេ
១២- វត្តធម្មិការាម ទីក្រុងប្រូវីដង់
១៣- វត្តធម្មចក្តារាម ទីក្រុងស៊ីអាថុល
១៤- វត្តសាមគ្គីរតនារាម ទីក្រុងតាក់កុមា

ព្រមទាំងពុទ្ធបរិស័ទទូទាំងសហរដ្ឋអាមេរិកដែលមាន
រាយនាម ក្នុងភាគទី១-២ នោះផង ។